# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

# កម្រងឯកសារពាក់ព័ន្ធនឹងរបាយការណ៍

# ស្តីពី

# ការអនុវត្តសិទ្ធិកុមារនៅកម្ពុជា

ចងក្រងដោយ : ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ

ឧបត្ថម្ភដោយ : unicef ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្ស

# កម្រងឯកសារពាក់ព័ន្ធនឹងរបាយការណ៍

# ស្តីពី

# ការអនុវត្តសិទ្ធិកុមារនៅកម្ពុជា

# ផ្នែកទី៣

## ឧត្តមស្នងការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស

# សេចក្តីសង្កេតចុងក្រោយ
# របស់គណៈកម្មាធិការសិទ្ធិកុមារ

សម័យប្រជុំលើកទី២៤
ការពិចារណាលើរបាយការណ៍ដាក់ជូនដោយរដ្ឋភាគី
ផ្អែកតាមមាត្រា ៤៤ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ
ចំពោះប្រទេសកម្ពុជា

ខែឧសភា ឆ្នាំ២០០០

# ផ្នែកទី១

## របាយការណ៍ដំបូង ស្តីពីការអនុវត្ត
## សិទ្ធិកុមារ

# ផ្នែកទី២

## របាយការណ៍ឆ្លើយតបសំណួរដែលពាក់ព័ន្ធនឹង
## របាយការណ៍ដំបូងរបស់ប្រទេសកម្ពុជា ស្តីពី
## ការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារ

ខែ ឧសភា ឆ្នាំ២០០០

# ផ្នែកទី៧

## លទ្ធផលសិក្ខាសាលា ស្តីពីអនុសាសន៍របស់ អ.ស.ប
## លើការអនុវត្តអនុសញ្ញា ស្តីពី សិទ្ធិកុមារនៅកម្ពុជា
## ១៦.១៧ វិច្ឆកា ២០០០

**រៀបចំដោយ គណៈកម្មាធិការអង្គការក្រៅរដ្ឋាភិបាលដើម្បីសិទ្ធិកុមារ**

ឧបត្ថម្ភដោយ : អង្គការលីកាដូ អង្គការយូនីសេហ្វ អង្គការសង្គ្រោះកុមារ

# ផ្នែកទី៤

កំណត់ហេតុសង្ខេបនៃកិច្ចប្រជុំលើកទី ៦២៩ : កម្ពុជា ១២,០៧,២០០០

## គណៈកម្មាធិការសិទ្ធិកុមារ

### សម័យប្រជុំលើកទី ២៤

## កំណត់ហេតុសង្ខេបនៃកិច្ចការប្រជុំលើកទី ៦២៩

### ដែលត្រូវបានធ្វើឡើងនៅ the Palais Wilson ទីក្រុងហ្សឺណែវ

### ថ្ងៃពុធ ទី២៤ ខែឧសភា ឆ្នាំ២០០០ នៅម៉ោង ១០:០០ នាទីព្រឹក

**ប្រធាន** : លោកស្រី **OUEDRAOGO**

### មាតិកា

ការពិនិត្យពិចារណាលើរបាយការណ៍របស់រដ្ឋជាភាគី (ត)

របាយការណ៍ដំបូងរបស់កម្ពុជា

កិច្ចប្រជុំបានចាប់ផ្តើមនៅម៉ោង ១០ :១០នាទីព្រឹក

ការពិនិត្យពិចារណាលើរបាយការណ៍របស់រដ្ឋជាភាគី (របៀបវារៈទី ៤) (ត)

របាយការណ៍ដំបូងរបស់កម្ពុជា **(CRC/C/11/Add.16; CRC/C/Q/CAM/1;**

ការឆ្លើយតបជាលាយលក្ខ័អក្សរ ដោយរដ្ឋាភិបាលកម្ពុជា

(ឯកសារមិនផ្លូវការជាភាសាអង់គ្លេសតែមួយមុខត្រូវបានចែកចាយក្នុងសាលាប្រជុំ)

# ផ្នែកទី៥

កំណត់ហេតុសង្ខេបនៃកិច្ចប្រជុំលើកទី ៦៣០ : កម្ពុជា ៣០,០៥,២០០០

## គណៈកម្មាធិការសិទ្ធិកុមារ

### សម័យប្រជុំលើកទី ២៤

## កំណត់ហេតុសង្ខេបនៃកិច្ចការប្រជុំលើកទី ៦៣០

**ដែលត្រូវបានប្រារព្ធធ្វើឡើងនៅ the Palais Wilson ទីក្រុងហ្សឺណែវ**

**ថ្ងៃពុធ ទី២៤ ខែឧសភា ឆ្នាំ២០០០ នៅម៉ោង៣:០០នាទីល្ងាច**

ប្រធាន : លោកស្រី **OUEDRAOGO**

### មាតិកា

ការពិនិត្យពិចារណាលើរបាយការណ៍របស់រដ្ឋជាភាគី (ត)

របាយការណ៍ដំបូងរបស់កម្ពុជា (ត)

# ផ្នែកទី៦

## របាយការណ៍សិក្ខាសាលា ស្តីពី ការអនុវត្ត របស់រាជរដ្ឋាភិបាលចំពោះសេចក្តីសង្កេតចុងក្រោយ របស់គណៈកម្មាធិការសិទ្ធិកុមារ នៃ អ.ស.ប

## ២២-២៣ មករា ២០០១




រៀបចំដោយ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ

# **បុព្វកថា**

អនុសញ្ញាស្តីពីសិទ្ធិកុមារ ត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៨៩។ អនុសញ្ញានេះត្រូវបានក្រុមប្រឹក្សាជាតិជាន់ខ្ពស់នៃប្រទេសកម្ពុជា(SNC)ចុះហត្ថលេខាទទួលស្គាល់ នៅថ្ងៃទី២២ ខែកញ្ញា ឆ្នាំ១៩៩២ និងត្រូវបានផ្តល់សច្ចាប័ននៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩២។ ក្នុងនាមជាប្រទេសហត្ថលេខី កម្ពុជាមានកាតព្វកិច្ចធ្វើរបាយការណ៍ ក).របាយការណ៍ដំបូងស្តីពីការអនុវត្តសិទ្ធិកុមារ នៅ២ឆ្នាំក្រោយបន្ទាប់ពីផ្តល់សច្ចាប័ន ខ). ធ្វើរបាយការណ៍រៀងរាល់៥ឆ្នាំ ដើម្បីជូនដល់គណៈកម្មាធិការសិទ្ធិកុមារនៃអង្គការសហប្រជាជាតិ។

កម្ពុជាបានធ្វើរបាយការណ៍ដំបូងជូនគណៈកម្មាធិការសិទ្ធិកុមារ នៅថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៩៧។ នៅថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០០ គណៈប្រតិភូជាន់ខ្ពស់នៃរាជរដ្ឋាភិបាលកម្ពុជាចំនួន៣រូប ដឹកនាំដោយឯកឧត្តម **អ៊ឹម សិទ្ធី** រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា បានចូលរួមសម័យប្រជុំលើកទី៦៤១ របស់គណៈកម្មាធិការសិទ្ធិកុមារ នៅទីក្រុងហ្សឺណែវ ដើម្បីធ្វើការសន្ទនា និងដាក់ជូនចម្លើយតបទៅនឹងសំណួរដែលពាក់ព័ន្ធនឹងរបាយការណ៍ដំបូង។ គណៈកម្មាធិការបានចេញនូវសេចក្តីសង្កេតចុងក្រោយ ដែលជាការពិចារណា លើរបាយការណ៍ និងចម្លើយរបស់ប្រទេសកម្ពុជា ។

ក្នុងគោលបំណងផ្សព្វផ្សាយសេចក្តីសង្កេតចុងក្រោយនេះ និងដើម្បីផ្តល់ឱកាសឱ្យសង្គមស៊ីវិល ពិភាក្សា កំណត់លំដាប់បញ្ហាជាអាទិភាព និងលើកអនុសាសន៍ជូនសិក្ខាសាលាថ្នាក់ជាតិ អង្គការNGO.CRC បានធ្វើសិក្ខាសាលាមួយ នៅថ្ងៃទី១៦-១៧ ខែវិច្ឆិកា ឆ្នាំ ២០០០។

នៅថ្ងៃទី២២-២៣ ខែមករា ឆ្នាំ២០០១ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ដោយមានការឧបត្ថម្ភពីអង្គការយូនីសេហ្វ និងការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅកម្ពុជា បានរៀបចំសិក្ខាសាលាសថ្នាក់ជាតិ ស្តីពីការអនុវត្តរបស់រាជរដ្ឋាភិបាលចំពោះសេចក្តីសង្កេតចុងក្រោយរបស់គណៈកម្មាធិការសិទ្ធិកុមារ ក្នុងគោលបំណងផ្សព្វផ្សាយអនុសាសន៍ទាំងនេះ និងដើម្បីឱ្យក្រសួង ស្ថាប័នទាំងអស់ពិនិត្យ ពិចារណា ហើយកំណត់ទិសដៅ និងផែនការដាក់ស្តែងសំរាប់អនុវត្តក្នុង៥ឆ្នាំខាងមុខ។

ឯកសារទាំងនេះត្រូវបានចងក្រងជាសៀវភៅ ទុកជូនក្រសួង ស្ថាប័ន អង្គការពាក់ព័ននានា ដើម្បីស្វែងយល់សំរាប់ជាទុនក្នុងការរៀបចំគោលនយោបាយ ឬកម្មវិធីផ្សេងៗ ដែលជាឧត្តមប្រយោជន៍របស់កុមារ។

សូមថ្លែងនូវអំណរគុណយ៉ាងជ្រាលជ្រៅចំពោះអង្គការយូនីសេហ្វ និងការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំនៅកម្ពុជា ដែលបានឧបត្ថម្ភថវិកាសំរាប់រៀបចំសិក្ខាសាលាថ្នាក់ជាតិ និងបោះពុម្ពសៀវភៅនេះ។

សូមប្រសិទ្ធិពរជូនដល់ថ្នាក់ដឹកនាំនៃរាជរដ្ឋាភិបាល ថ្នាក់ដឹកនាំ និងមន្ត្រីនៃក្រសួង ស្ថាប័ន ព្រមទាំងអង្គការជាតិ អន្តរជាតិទាំងអស់ដែលបានគាំទ្រ និងធ្វើសកម្មភាពដើម្បីលើកស្ទួយសិទ្ធិកុមារនៅកម្ពុជា សូមប្រកបដោយពុទ្ធពរទាំងប្រាំប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភានៈ កុំបីឃ្លៀងឃ្លាតឡើយ។

**ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ**

# មាតិកា

## បុព្វកថា

## ផ្នែកទី ១ : របាយការណ៍ដំបូង ស្តីពីការអនុវត្តសិទ្ធិកុមារ

ទំព័រ


**សេចក្តីផ្តើម**

I- ទឹកដី និងប្រជាជន ...............................................................................................១

II- អំពីសេដ្ឋកិច្ច ...............................................................................................២

III- រចនាសម្ព័ន្ធនយោបាយទូទៅ ...............................................................................................២

**I- វិធានការអនុវត្តន៍ទូទៅ**

ក- វិធានការដើម្បីឱ្យច្បាប់ជាតិ និងគោលនយោបាយជាតិស្របទៅនឹងអនុសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិកុមារ..........៥

ខ- យន្តការសំរបសំរួលគោលនយោបាយដែលទាក់ទងនឹងកុមារ និងតាមដានត្រួតពិនិត្យការអនុវត្តអនុសញ្ញា.....៧

គ- សហប្រតិបត្តិការអន្តរជាតិ ...............................................................................................៨

**II- និយមន័យកុមារ**

និយមន័យកុមារ ...............................................................................................៩

**III- គោលការណ៍ទូទៅ**

ក- ការមិនរើសអើង...............................................................................................១០

ខ- ឧត្តមប្រយោជន៍របស់កុមារ ...............................................................................................១១

គ- សិទ្ធិរស់រានមានជីវិត និងអភិវឌ្ឍន៍ ...............................................................................................១២

ឃ- ការទទួលស្គាល់លើទស្សនៈរបស់កុមារ ...............................................................................................១២

**IV- សិទ្ធិពលរដ្ឋ និងសេរីភាព**

ក- ឈ្មោះ និងសញ្ជាតិ ...............................................................................................១៣

ខ- ការការពារអត្តសញ្ញាណ ...............................................................................................១៤

គ- សេរីភាពក្នុងការបញ្ចេញយោបល់...............................................................................................១៤

ឃ- ពតិមានសមស្របដែលអាចទទួលបាន ...............................................................................................១៥

ង- សេរីភាពផ្នែកគំនិត មនសិកា និងសាសនា ...............................................................................................១៦

ច- សេរីភាពក្នុងការបង្កើតសមាគម និងសេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធី ...............................................................................................១៧

ឆ- ការការពារសិទ្ធិឯកជនរបស់កុមារ...............................................................................................១៨

ជ- សិទ្ធិរួចពីទារុណកម្ម ឬអំពើឃោរឃៅ បន្ទាបបន្ថោក ឬដាក់ទណ្ឌកម្ម ...............................................................................................២០

**V- បរិយាកាសគ្រួសារ និងកិច្ចថែទាំផ្សេងទៀត**

ក- ការណែនាំចំពោះមាតា បិតា ...............................................................................................២២

ខ- ការទទួលខុសត្រូវរបស់មាតា បិតា.....២៣

គ- ការបំបែកពីមាតាបិតា.....២៤

ឃ- ការជួបជុំគ្រួសារវិញ.....២៥

ង- ការជម្រុញឱ្យមានការថែទាំកុមារ.....២៥

ច- កុមារឃ្លាតចេញពីបរិយាកាសគ្រួសារ.....២៦

ឆ- ការសុំកូនចិញ្ចឹម.....២៧

ជ- ការបញ្ជូនកុមារខុសច្បាប់ និងការមិនវិលត្រឡប់របស់កុមារ.....២៨

ឈ- ការរំលោភ និងការមិនយកចិត្តទុកដាក់ចំពោះកុមារ.....២៨

ញ- ការពិនិត្យតាមដានកុមារ ដែលដាក់ឱ្យគេថែរក្សា.....២៩

**VI- សុខភាពមូលដ្ឋាន និងសុខុមាលភាព**

ក- ការរស់រានមានជីវិត ការអភិវឌ្ឍ និងករិតជីវភាព.....៣០

ខ- កុមារពិការ.....៣១

គ- សុខភាព និងសេវាវេជ្ជសាស្ត្រ.....៣៣

ឃ- សន្តិសុខសង្គម និងសេវាថែទាំសុខភាពកុមារ.....៣៧

ង- ករិតជីវភាពរស់នៅ.....៤០

**VII- ការអប់រំ ការលំហែរ និងសកម្មភាពវប្បធម៌**

I- ការអប់រំ បញ្ចូលទាំងការអប់រំវិជ្ជាជីវៈ និងការណែនាំ.....៤២

ក- បរិបទច្បាប់.....៤២

ខ- មត្តេយ្យសិក្សា និងការអប់រំចំណេះទូទៅ.....៤៣

គ- ការអប់រំក្រៅប្រព័ន្ធ.....៤៦

II- គោលបំណងនៃការអប់រំ.....៤៧

III- ការលំហែ វិស្សមកាល និងសកម្មភាពវប្បធម៌.....៤៨

**VIII- វិធានការការពារពិសេស**

ក- កុមារក្នុងស្ថានភាពអាសន្ន.....៤៩

១- កុមារភៀសខ្លួន.....៤៩

២- កុមារស្ថិតក្នុងស្ថានភាពជំលោះសព្វាវុធ.....៥០

ខ- កុមារទំនាស់នឹងច្បាប់.....៥១

១- កុមារ និង ភាពយុត្តិធម៌.....៥១

២- កុមារដែលត្រូវដកហូតសេរីភាព.....៥២

៣- ការផ្តន្ទាទោសអនីតិជន.....៥៣

គ- កុមារដែលស្ថិតនៅក្រោមការកេងប្រវ័ញ្ច.....៥៤

១- កុមារពលករ....................................................................................................៥៤
២- ការប្រើគ្រឿងញៀន..............................................................................................៥៦
៣- ការជួញដូរ ការកេងប្រវ័ញ្ច និងការរំលោភខាងផ្លូវភេទ........................................................៥៦
ឃ- កុមារជាជនជាតិភាគតិច .........................................................................................៥៧

IX- **យោបល់រួម**

- យោបល់រួម.........................................................................................................៥៨
- ឧបសម្ព័ន្ធ............................................................................................................៥៩

## ផ្នែកទី ២ : របាយការណ៍ឆ្លើយតបសំណួរដែលពាក់ព័ន្ធនឹងរបាយការណ៍ដំបូង របស់ប្រទេសកម្ពុជាស្តីពីការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារ

- វិធានការអនុវត្តន៍ទូទៅ ...............................................................................................៦១
- និយមន័យកុមារ ......................................................................................................៦៧
- គោលការណ៍ទូទៅ.....................................................................................................៦៨
- សិទ្ធិពលរដ្ឋ និងសេរីភាព ..............................................................................................៧១
- បរិយាកាសគ្រួសារ និងកិច្ចថែទាំផ្សេងៗទៀត......................................................................៧២
- សុខភាពមូលដ្ឋាន និងសុខុមាលភាព..............................................................................៧៦
- ការអប់រំ ការលំហែ និងសកម្មភាពវប្បធម៌ .......................................................................៨៣
- វិធានការការពារពិសេស ..............................................................................................៨៧

## ផ្នែកទី ៣ : សេចក្តីសន្និដ្ឋានចុងក្រោយរបស់គណៈកម្មាធិការសិទ្ធិកុមារ

ក- សេចក្តីផ្តើម..........................................................................................................១០៥
ខ- ទិដ្ឋភាពវិជ្ជមាន.....................................................................................................១០៥
គ- កត្តា និងការលំបាកដែលរារាំងវឌ្ឍនភាពក្នុងការអនុវត្តអនុសញ្ញា .........................................១០៦
ឃ- បញ្ហាចំបងៗនៃការព្រួយបារម្ភ និងអនុសាសន៍ ..............................................................១០៦

## ផ្នែកទី ៤ : កំណត់ហេតុសង្ខេបនៃកិច្ចប្រជុំលើកទី ៦២៩

- កំណត់ហេតុសង្ខេបនៃកិច្ចប្រជុំលើកទី ៦២៩ **នៅម៉ោង ១០ : ០០នាទីព្រឹក** ..........................................១១៩

## ផ្នែកទី ៥ : កំណត់ហេតុសង្ខេបនៃកិច្ចប្រជុំលើកទី ៦៣០

- កំណត់ហេតុសង្ខេបនៃកិច្ចប្រជុំលើកទី ៦៣០ **នៅម៉ោង ៣ : ០០នាទីល្ងាច**..........................................១២៩

## ផ្នែកទី ៦ : របាយការណ៍សិក្ខាសាលា ស្តីពីការអនុវត្តរបស់រាជរដ្ឋាភិបាលចំពោះសេចក្តីសង្កេតចុងក្រោយ


- របាយការណ៍សិក្ខាសាលាស្តីពី ការអនុវត្តរបស់រាជរដ្ឋាភិបាលចំពោះសេចក្តីសង្កេតចុងក្រោយ របស់គណៈកម្មាធិការសិទ្ធិកុមារនៃ អ.ស.ប........................................................................................១៤៣
- សុន្ទរកថារបស់ឯកឧត្តម អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួង ស.ក.ប.យ និងជាប្រធាន ក.ជ.ក.ក.....................១៤៦
- សុន្ទរកថាថ្លែងដោយឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី និងជាសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ.................១៤៨
- លទ្ធផលនៃការអនុវត្តកម្មវិធីសកម្មភាពជាតិដើម្បីកុមារនៅកម្ពុជាឆ្នាំ ១៩៩៨-២០០០..........................១៥១
- សេចក្តីសង្កេតចុងក្រោយរបស់គណៈកម្មាធិការនៃ អ.ស.ប លើសិទ្ធិកុមារនៅកម្ពុជា...........................១៦១
- លទ្ធផលសិក្ខាសាលារបស់អង្គការក្រៅរដ្ឋាភិបាលស្តីពីអនុសាសន៍របស់ អ.ស.ប លើការអនុវត្ត អនុសញ្ញាស្តីពីសិទ្ធិកុមារនៅកម្ពុជា......................................................................................១៦៥
- លទ្ធផលរបស់ក្រុមពិភាក្សា ........................................................................................................១៦៧
- មន្ត្រីតំណាងក្រសួងពិភាក្សាលើកម្មវិធី និងសកម្មភាពរបស់ក្រសួងសំរាប់អនុវត្តឆ្នាំ ២០០១ ..................១៧២
- សុន្ទរកថារបស់ឯកឧត្តម សុខ អាន ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ....................១៧៤


## ផ្នែកទី ៧ : លទ្ធផលសិក្ខាសាលាស្តីពី អនុសាសន៍របស់ អ.ស.ប លើការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារនៅកម្ពុជា


ក- លំដាប់អាទិភាពនៃអនុសាសន៍ របស់អង្គការសហប្រជាជាតិ ........................................................១៨១
១- វិធានការអនុវត្តន៍ទូទៅ ........................................................................................................១៨១
២- និយមន័យ ...........................................................................................................................១៨២
៣- គោលការណ៍ទូទៅ ................................................................................................................១៨២
៤- សិទ្ធិ និងសេរីភាពរដ្ឋ ..........................................................................................................១៨២
៥- បរិយាកាសគ្រួសារ និងការថែរក្សាចំលាស់ .............................................................................១៨៣
៦- សុខភាពមូលដ្ឋាន និងសុខុមាលភាព .....................................................................................១៨៣
៧- ការអប់រំ ការលំហែ និងសកម្មភាពវប្បធម៌.............................................................................១៨៤
៨- វិធានការការពារពិសេស .......................................................................................................១៨៤
ខ- អនុសាសន៍របស់អង្គការក្រៅរដ្ឋាភិបាលទៅលើការអនុវត្តអនុសាសន៍របស់ អ.ស.ប............................១៨៥
១- វិធានការអនុវត្តទូទៅ ...........................................................................................................១៨៦
២- និយមន័យ គោលការណ៍ទូទៅ និងសិទ្ធិសេរីភាពពលរដ្ឋ ..............................................................១៨៧
៣- បរិយាកាសគ្រួសារ និងការថែរក្សាចំលាស់..............................................................................១៨៧
៤- សុខភាពមូលដ្ឋាន និងសុខុមាលភាព .......................................................................................១៨៨
៥- ការអប់រំ ការលំហែ និងសកម្មភាពវប្បធម៌ ..............................................................................១៨៩
៦- វិធានការការពារពិសេស .......................................................................................................១៨៩

# សេចក្ដីផ្ដើម

**១-** ព្រះរាជាណាចក្រកម្ពុជា បានទទួលរងនូវមហាវិនាសកម្មដ៏ខ្លោចផ្សាបំផុត ដែលបង្កឡើងដោយសង្គ្រាមរ៉ាំរ៉ៃ អូសបន្លាយជាងពីរទសវត្សកន្លងមកនេះ។ កម្ពុជាដែលធ្លាប់មានកេរ្ដិ៍ឈ្មោះល្បីល្បាញ អារ្យធម៌ថ្កុំថ្កើង ប្រទេសសម្បូររុងរឿង ត្រូវបានធ្លាក់ចុះគួរឱ្យសែនរន្ធត់ និងសោកស្ដាយបំផុតនៅគ្រប់វិស័យរបស់ជាតិ ។

**២-** រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដែលទើបតែប្រសូត្រឡើងពីការបោះឆ្នោតជាសកល និងត្រឹមត្រូវកាលពីថ្ងៃទី២៣ ដល់២៨ ខែឧសភា ឆ្នាំ១៩៩៣ ក្រោមការរៀបចំរបស់អង្គការសហប្រជាជាតិ ត្រូវទទួលបន្ទុកដ៏ធ្ងន់ធ្ងរក្នុងការស្តារប្រទេសជាតិឱ្យរួចផុតពីភ័យន្តរាយ ឈានសំដៅទៅរកសុវត្ថិភាព វឌ្ឍនភាពសំបូររុងរឿង ដោយប្រកាន់យកលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ជាមាគ៌ាសំរាប់ធ្វើដំណើរ ។

## I- ទឹកដី និង ប្រជាជន

**៣-** ប្រទេសកម្ពុជាស្ថិតនៅក្នុងទ្វីបអាស៊ីភាគអាគ្នេយ៍ មានផ្ទៃដីទំហំ១៨១.០៣៥ គីឡូម៉ែត្រក្រឡា។ ប្រមាណជាពីរភាគបីនៃទឹកដីគ្របដណ្ដប់ទៅដោយព្រៃឈើ ជួរភ្នំ និង កូនភ្នំ។ ប្រជាជនភាគច្រើនរស់នៅតាមវាលទំនាបនៃទន្លេមេគង្គ។ តាមការសង្កេតសេដ្ឋកិច្ច សង្គមកិច្ចនៅកម្ពុជា (ខែតុលា ១៩៩៣-១៩៩៤ រៀបចំដោយក្រសួងផែនការ ) ប្រទេសកម្ពុជាមានប្រជាជន ៩.៨៦៩.៧៤៩នាក់ ដែល៨៥%រស់នៅជនបទ និង១៥% រស់នៅក្នុងក្រុង។ គិតជាមធ្យមក្នុងមួយគីឡូម៉ែតការ៉េ មានប្រជាជនរស់នៅប្រមាណ ៥៥នាក់ ។

<u>ជនជាតិ</u>

**៤-** ប្រទេសកម្ពុជាមានជនជាតិ :

- ជនជាតិខ្មែរ ៩0%
- ខ្មែរឥស្លាមមានប្រមាណ ២00.000នាក់
- ជនជាតិភាគតិច (កុលសម្ព័ន្ធ ) មាន ១៦ជនជាតិ ដែលមានភាសាផ្សេងៗគ្នា រស់នៅខេត្តនានា តំបន់ខ្ពង់រាបភាគឥសាននៃប្រទេស (តំបន់ព្រៃភ្នំ ) មានប្រមាណ ៧៥.000នាក់ ។
- ជនជាតិបរទេស :
  + ជនជាតិចិនប្រមាណ ២00.000នាក់
  + ជនជាតិវៀតណាមប្រមាណ ៥%

**៥-** ជនជាតិនិមួយៗ ត្រូវបានអនុញ្ញាតឱ្យប្រើភាសា និង គោរពទំនៀមទំលាប់ប្រពៃណីដើមរបស់គេ។ ប៉ុន្តែភាសា និង អក្សរប្រើជាផ្លូវការ គឺភាសា និង អក្សរខ្មែរ ។

<u>អត្រា និង អាយុកាលមធ្យមរបស់ប្រជាជន</u>

**៦-** តាមការអង្កេតខាងលើនេះ ៤៣,៧% នៃប្រជាជនមានអាយុក្រោម១៥ឆ្នាំ (ប្រុស ៤៦,៦% ស្រី ៤១,១%) ហើយ និង ៤,១% មានអាយុលើសពី៦៥ឆ្នាំ (ប្រុស៣,៦% ស្រី៤,៥%)។ ជាទូទៅប្រជាជនមានអាយុកាលមធ្យមរស់នៅក្រោម៥0ឆ្នាំ។

<u>ការស្លាប់របស់កុមារ</u>

**៧-** ក្នុងឆ្នាំ១៩៩៣ អត្រាស្លាប់របស់កុមារមាន ១១៧ ភាគពាន់ អ្នកដែលស្លាប់ក្រោមអាយុ៥ឆ្នាំមាន១៨៣ ភាគពាន់។ ការស្លាប់នៅពេលកើតមាន៩%។ ការកើតមិនគ្រប់ខែធ្វើឱ្យការស្លាប់របស់កុមារមាន៣១% ហើយធ្វើឱ្យមានការលំបាកមាន ២៨%។ ជម្ងឺខាងផ្លូវដកដង្ហើម២០% គ្រុនចាញ់១៣% និងរាគមួល១៦% នេះគឺជាមូលហេតុសំខាន់នៃការស្លាប់របស់កុមារ ដែលមានអាយុពី ២ឆ្នាំ ដល់ ៤ឆ្នាំ ។

សាសនា

**៨-** ព្រះពុទ្ធសាសនា ជាសាសនារបស់រដ្ឋ ដែលមានប្រជាពលរដ្ឋចំនួន៩៧,៥% ជាពុទ្ធសាសនិក។ ក្រៅពីនេះនៅមានសាសនាសំខាន់ពីរទៀតកំពុងធ្វើសកម្មភាពគឺ សាសនាឥស្លាម សាសនាកាតូលិក និង សាសនាមួយចំនួនទៀតដែលមានសាសនិកតិចតួចនៅឡើយ ។

ការសិក្សាអប់រំ

**៩-** កុមារអាយុពី៦ឆ្នាំ ដល់១៦ឆ្នាំ ត្រូវតែបានទទួលការអប់រំយ៉ាងតិចប្រាំបួនឆ្នាំនៅកំរិតសិក្សាទីមួយ។ កុមារភាគច្រើនបានបន្តការសិក្សាលើកំរិតសិក្សាជាកាតព្វកិច្ចនេះ ។ ការសិក្សានៅកំរិតសិក្សាទី២ មិនកំណត់ជាកាតព្វកិច្ចទេ គឺគេអាចបន្តពីកំរិត១បានហើយត្រូវសិក្សា៤ឆ្នាំទៀត។ ការសិក្សានៅកំរិត១ និងកំរិត២ ពុំមានបង់ថ្លៃសិក្សាទេ។ ការសិក្សានៅឧត្តមសិក្សា រដ្ឋបានឧបត្ថម្ភអាហារកិច្ចដល់អ្នកក្រីក្រ។ បច្ចុប្បន្ននេះនៅមានអនក្ខរជនជាមនុស្សចាស់ ៣៤,៧% ។

## II- អំពីសេដ្ឋកិច្ច

**១០-** ក្នុងឆ្នាំ ១៩៩៤ ផលិតផលក្នុងស្រុកសរុបគិតតាមថ្លៃទីផ្សារជាក់ស្តែងប៉ាន់ស្មានមាន ៦,០៤៨,០០០ លានរៀល ( ប្រមាណ ២,៣៤០លានដុល្លាអាមេរិក) ។ ផលិតផលក្នុងស្រុកសរុបគិតតាមថ្លៃស្ថេរភាពឆ្នាំ១៩៨៩ កើនឡើង៥% ក្នុងឆ្នាំ១៩៩៤ ហើយសមាមាត្រផ្នែកកសិកម្មមាន៤៥% ឧស្សាហកម្ម២០% និង សេវាកម្ម៣៥%។ កសិកម្មគឺជាផ្នែកសំខាន់នៃសេដ្ឋកិច្ចជាតិ ដោយមានផលិតកម្មស្រូវមានសមាមាត្រខ្ពស់ជាងគេ ហើយរៀងរាល់ឆ្នាំមានការនាំចេញកៅស៊ូ ព្រៃឈើ និងផលិតផលនេសាទ។ ផលិតផលជាតិសរុបសំរាប់មនុស្សម្នាក់ ដែលគេប៉ាន់ស្មានមានប្រមាណ១៨០$អាមេរិក ក្នុងឆ្នាំ១៩៩៣។ នៅឆ្នាំ១៩៩៣ មានអតិផរណាប្រមាណ ៣១%។ អត្រាអ្នកគ្មានអាជីពក្នុងឆ្នាំ ១៩៩៣-១៩៩៤ នេះមាន ២,៥%។

## III- រចនាសម្ព័ន្ធនយោបាយទូទៅ

ប្រវត្តិនយោបាយសង្ខេប :

**១១-** កម្ពុជា ជាប្រទេសដែលបានទទួលគ្រោះមហន្តរាយយ៉ាងធ្ងន់ធ្ងរបំផុតដោយសង្គ្រាមរ៉ាំរ៉ៃបន្តបន្ទាប់អស់រយៈពេលជាងពីរទសវត្សកន្លងមក និង ជាពិសេសគ្រោះប្រល័យពូជសាសន៍ដោយពួកខ្មែរក្រហម។

**១២-** កិច្ចព្រមព្រៀងអន្តរជាតិ នៅទីក្រុងប៉ារីសថ្ងៃទី ២៣ តុលា ១៩៩១ រវាងភាគីខ្មែរទាំងបួន បានបង្កើតឡើងនៅឧត្តមក្រុមប្រឹក្សាជាតិជាន់ខ្ពស់ ដែលមានតួនាទីដឹកនាំការបង្រួបបង្រួមផ្សះផ្សាជាតិ។ អាជ្ញាធរបណ្តោះអាសន្ននៃអង្គការសហប្រជាជាតិមានវត្តមាននៅកម្ពុជាដើម្បីចូលរួមត្រួតពិនិត្យមើលការអនុវត្តកិច្ចព្រមព្រៀង និងរៀបចំការបោះឆ្នោតជាទូទៅនៅ ឆ្នាំ១៩៩៣។

**១៣-** ក្រោយការបោះឆ្នោត សភាធម្មនុញ្ញត្រូវបានបង្កើតឡើង ហើយបានរៀបចំរដ្ឋធម្មនុញ្ញសំរេចជាស្ថាពរនៅថ្ងៃទី ២១ កញ្ញា ១៩៩៣ និង បានបង្កើតឡើងនូវរាជរដ្ឋាភិបាល ដែលដឹកនាំដោយនាយករដ្ឋមន្ត្រីទី១ និង នាយករដ្ឋមន្ត្រីទី២ ។

**របបនយោបាយ** :

**១៤-** ប្រទេសកម្ពុជាមានរបបនយោបាយប្រជាធិបតេយ្យសេរីពហុបក្ស ឈ្មោះថា " ព្រះរាជាណាចក្រកម្ពុជា " ជារដ្ឋឯករាជ្យ អធិបតេយ្យ សន្តិភាព អព្យាក្រឹត្យអចិន្ត្រៃយ៍ និង មិនចូលបក្សសម្ព័ន្ធ ។

**១៥-** ការអនុវត្តលទ្ធិប្រជាធិបតេយ្យជាជំហានដំបូងនៅព្រះរាជាណាចក្រកម្ពុជា មានជួបការលំបាកជាច្រើន ដែលពុំទាន់ធានាបាននូវដំណើរនៃលទ្ធិប្រជាធិបតេយ្យពិតប្រាកដនៅឡើយ ។ ប៉ុន្តែរាជរដ្ឋាភិបាលបានខិតខំធ្វើឱ្យសុក្រឹត្យជាបណ្តើរៗនូវដំណើរការអនុវត្តឱ្យមានលទ្ធិប្រជាធិបតេយ្យពិតប្រាកដ ដូចជាបង្កើនការកសាងប្រព័ន្ធច្បាប់ ពង្រឹងការអនុវត្តច្បាប់ និងធានាដល់ការគោរពសិទ្ធិបុគ្គល ។

**ប្រព័ន្ធរដ្ឋាភិបាល** :

**១៦-** ក្នុងការគ្រប់គ្រងរដ្ឋ ព្រះរាជាណាចក្រកម្ពុជាបានបែងចែកអំណាចជាបីដាច់ពីគ្នា រវាងអំណាចនីតិបញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ ។

**១៧-** ទាក់ទងនឹងអំណាចនីតិប្រតិបត្តិ ព្រះមហាក្សត្រទ្រង់គ្រងរាជសម្បត្តិ តែទ្រង់មិនកាន់អំណាចទេ។ នាយករដ្ឋមន្ត្រីទី១ ជាអ្នកដឹកនាំ គណៈរដ្ឋមន្ត្រីជាប្រមុខរាជរដ្ឋាភិបាល អមដោយឧបនាយករដ្ឋមន្ត្រី ព្រមទាំងមានទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និង រដ្ឋលេខាធិការជាសមាជិក។ ប៉ុន្តែក្នុងនីតិកាលទី១នេះ រាជរដ្ឋាភិបាលកម្ពុជាត្រូវដឹកនាំដោយនាយករដ្ឋមន្ត្រី២រូប គឺនាយករដ្ឋមន្ត្រីទី១ និង នាយករដ្ឋមន្ត្រីទី២ ។

**១៨-** អំណាចនីតិបញ្ញត្តិអនុវត្តដោយរដ្ឋសភាជាតិ។ រដ្ឋសភាជាតិមានសមាជិក១២០នាក់ ដែលត្រូវជ្រើសរើស ក្នុង៥ឆ្នាំម្តង ដោយការបោះឆ្នោតជាសកល ដោយសេរី ដោយស្មើភាព ដោយចំពោះ និងតាមវិធីជ្រើសរើសឆ្នោតជាសម្ងាត់។ ឆ្លងតាមការបោះឆ្នោតឆ្នាំ១៩៩៣ គណៈបក្សនយោបាយចំនួន៤ បានជាប់ឆ្នោតមានតំណាងរបស់ខ្លួននៅក្នុងសភាជាតិ។ គណៈបក្សហ៊្វុនស៊ិនប៉ិចមានសមាជិកចំនួន៥៨នាក់ គណៈបក្សប្រជាជនមានសមាជិកតំណាងចំនួន៥១នាក់ គណៈបក្សប្រជាធិបតេយ្យសេរីនិយមព្រះពុទ្ធសាសនាមានសមាជិកតំណាងចំនួន១០នាក់ និង គណៈបក្សម៉ូលីណាកាមានសមាជិកតំណាងចំនួន១នាក់។

**១៩-** អនុវត្តតាមមាត្រា១០៩ នៃរដ្ឋធម្មនុញ្ញនៅព្រះរាជាណាចក្រកម្ពុជា មានតែសាលាជំរះក្តីមួយគត់ ទទួលរឿងក្តីទាំងអស់ រួមទាំងរឿងក្តីរដ្ឋបាលផង។

ចាប់តាំងពីឆ្នាំ ១៩៩៣មក សាលាជំរះក្តីមានពីរថ្នាក់ មានតុលាការជាន់ដំបូង២១ខេត្ត-ក្រុង អាចសំរេចសេចក្តី ដោយបើកផ្លូវតវ៉ានៅចំពោះមុខសាលាឧទ្ធរណ៍នៅភ្នំពេញ លើកលែងតែមានការជំនុំជំរះជាលើកដំបូង និងជាលើកចុងក្រោយ ។

សាលាជំរះក្តីពីរថ្នាក់ផ្តល់អត្ថប្រយោជន៍នៃកិច្ចការពារចៅក្រមថ្នាក់ដំបូង មិនឱ្យទទួលខុសត្រូវតែឯកឯងលើសេចក្តី និងការវិនិច្ឆ័យរបស់ខ្លួន ដែលអាចឱ្យមានការពិនិត្យជាថ្មីឡើងវិញពីអង្គច្បាប់ និង អង្គហេតុតាមការប្តឹងសុំ។

តុលាការកំពូលសំរេចសេចក្តីលើអង្គច្បាប់តាមអំណាចទីមួយ ហើយសំរេចលើអង្គច្បាប់ និងអង្គហេតុតាមអំណាចទីពីរ។

តុលាការយោធាមានសមត្ថកិច្ចជំនុំជំរះបើកផ្លូវឧទ្ធរណ៍នូវបទល្មើសយោធា។

**២០-** មាត្រា១១៧ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បានគម្រោងបង្កើតក្រុមប្រឹក្សាធម្មនុញ្ញមួយ មានបេសកកម្មត្រួតពិនិត្យអនុលោមភាពធម្មនុញ្ញភាពនៃច្បាប់ដែលអនុម័តដោយរដ្ឋសភា និងត្រួតពិនិត្យនិយ័តភាពនៃការបោះឆ្នោតជ្រើសរើស

តំណាងរាស្ត្រ។ បច្ចុប្បន្នអង្គការចាត់តាំងនេះមិនទាន់បានបង្កើតទេ ដោយមានការយឺតយ៉ាវក្នុងការអនុម័តច្បាប់ស្តីពី ការរៀបចំ និង ការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដែលរដ្ឋធម្មនុញ្ញកំណត់ឱ្យមានសមាជិក០៣រូប ចូលរួមក្នុងក្រុមប្រឹក្សាធម្មនុញ្ញ។

**២១-** នៅថ្ងៃទី២២ ធ្នូ ១៩៩៤ រដ្ឋសភាបានអនុម័តច្បាប់ស្តីពីសកម្មភាព និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ដែលរាជរដ្ឋាភិបាលបានដាក់ជូនតាំងពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ១៩៩៣។

អង្គការចាត់តាំងនេះកំពុងរៀបចំមានចៅក្រមប្រាំពីររូប រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ឬតំណាងក្រសួងយុត្តិធម៌មួយរូប ហើយស្ថិតក្រោមព្រះរាជធិបតីភាពនៃព្រះមហាក្សត្រ។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមធានាឯករាជ្យភាពចៅក្រមពីពេលនេះតទៅ។ ឧត្តមក្រុមប្រឹក្សាចៅក្រមសំរេចការស្នើតែងតាំង និងការផ្លាស់ប្តូរចៅក្រម។

**២២-** បច្ចុប្បន្ននេះ មានចៅក្រម១៣៩នាក់ តែងតាំងដោយប្រមុខរដ្ឋ ហើយត្រូវបែងចែកទៅតាមតុលាការទាំង២១ ខេត្ត-ក្រុង សាលាឧទ្ធរណ៍ និង តុលាការកំពូល។

ចៅក្រមថ្មីចំនួន៤២នាក់ កំពុងធ្វើកម្មសិក្សាក្រោយពីបានប្រឡងជ្រើសរើស និង ធ្វើការបណ្តុះបណ្តាល ផ្នែកទ្រឹស្តី។

ក្រសួងយុត្តិធម៌បានរៀបចំឡើងវិញនូវរចនាសម្ព័ន្ធរដ្ឋបាលរបស់ខ្លួន ក្នុងនោះមានបង្កើតថ្មីនូវអាគារធិការដ្ឋានកិច្ចការយុត្តិធម៌ដើម្បីត្រួតពិនិត្យគុណភាពការងារខាងរដ្ឋបាលរបស់ចៅក្រម។

ម្យ៉ាងទៀតដើម្បីធានាការគ្រប់គ្រងអង្គចៅក្រមឱ្យបានល្អ ក្រសួងយុត្តិធម៌បានកែទម្រង់រចនាសម្ព័ន្ធធ្វើការងាររបស់ខ្លួនៈ

- ផ្នែកអប់រំបណ្តុះបណ្តាលមួយ បានបង្កើតឡើងនៅក្នុងនាយកដ្ឋានបុគ្គលិក និង បណ្តុះបណ្តាល
- បានបើកសន្និបាតបូកសរុបការងារប្រចាំឆ្នាំ១៩៩៤ ដោយបានវាយតម្លៃលើកិច្ចការដឹកនាំការងាររបស់តុលាការខេត្ត-ក្រុង។ តាមការកែទម្រង់ថ្មីនេះ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ជានិច្ចកាលធានាឯករាជ្យភាពរបស់ចៅក្រម ត្រួតពិនិត្យកិច្ចការរដ្ឋបាល លើកកំពស់ការងារ ដើម្បីការពារចៅក្រម។

**<u>អង្គការចាត់តាំងរដ្ឋបាល</u>** :

**២៣-** បច្ចុប្បន្ននេះ នៅព្រះរាជាណាចក្រកម្ពុជាមាន១៩ខេត្ត និង ក្រុង៣ ដែលគ្រប់គ្រងដឹកនាំដោយអភិបាល និង អភិបាល-រងខេត្ត-ក្រុង។ ស្រុក និងខណ្ឌចំនួន១៧០ គ្រប់គ្រងដោយអភិបាលស្រុក-ខណ្ឌ។ ឃុំ-សង្កាត់ចំនួន១៥៤៥ ដែលគ្រប់គ្រងដោយមេឃុំ និង ចៅសង្កាត់ ។

**២៤-** ប្រទេសកម្ពុជាបានចុះហត្ថលេខាលើអនុសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិកុមារនៅថ្ងៃទី២២ កញ្ញា ១៩៩២

**២៥-** ប្រទេសកម្ពុជាបានចូលជាភាគីនៃអនុសញ្ញាផ្សេងៗទៀតដូចជា :

. អនុសញ្ញា ស្តីពីការបង្ការ និង ផ្តន្ទាទោសឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ "១៩ សីហា ១៩៥០"

. អនុសញ្ញាអន្តរជាតិ ស្តីពីការបំបាត់ចោលសព្វបែបយ៉ាងនៃការប្រកាន់ពូជសាសន៍ " ៤ វិច្ឆិកា ១៩៨៣ "

. អនុសញ្ញាប្រឆាំងទារុណកម្ម និងការផ្តន្ទាទោស ឬការប្រព្រឹត្តទាំងឡាយណា ដែលឃោរឃៅអមនុស្សធម៌ ឬ ដែលនាំឱ្យបាត់បង់តម្លៃជាមនុស្ស " ២២ កញ្ញា ១៩៩២ "

. អនុសញ្ញាស្តីពីការបំបាត់រាល់ទំរង់នៃការរើសអើងប្រឆាំងនឹងនារីភេទ " ២២ កញ្ញា ១៩៩២ "

. អនុសញ្ញាអន្តរជាតិ ស្តីពីជនភៀសខ្លួន " ២២ កញ្ញា ១៩៩២ "

. ពិធីសារទាក់ទងនឹងស្ថានភាពរបស់ជនភៀសខ្លួន " ២២ កញ្ញា ១៩៩២ "

. កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិស៊ីវិល និង នយោបាយ " ២៦ ឧសភា ១៩៩២ "

. កតិកាសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌ " ២៦ ឧសភា ១៩៩២ "

. អនុសញ្ញាអន្តរជាតិ ស្តីពីការលុបបំបាត់ចោល និង ការបង្រ្កាបបទឧក្រិដ្ឋអាប៉ាថេដ

. អនុសញ្ញាបន្ថែមទាក់ទងទៅនឹងការលុបបំបាត់របបទាសភាព ការប្រព្រឹត្តបែបទាសភាព និងការលុបបំបាត់ស្ថាប័ន និងការអនុវត្តតាមបែបទាសភាព ។

**២៦-** រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាក្នុងមាត្រាទី៤៨ បានចែងថា រដ្ឋធានារក្សាការពារសិទ្ធិរបស់កុមារ ដែលមានចែងក្នុងអនុសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិកុមារ ។

**២៧-** រាជរដ្ឋាភិបាលបានបញ្ជូនគណៈប្រតិភូទៅចូលរួមក្នុងសន្និសីទតំបន់លើកទី២ ស្តីអំពីអនុសញ្ញាទាក់ទងដល់សិទ្ធិកុមារក្នុងភូមិភាគអាស៊ីអគ្នេយ៍ និងសន្តិភាពដែលបានប្រព្រឹត្តឡើងនៅទីក្រុងប៉េកាំងពីថ្ងៃទី៤ ដល់ទី៨ សីហា ១៩៩២ លើកទី៣ នៅទីក្រុងហាណូយពីថ្ងៃទី៣ ដល់ទី៧ មេសា ១៩៩៥។ សន្និសីទថ្នាក់រដ្ឋមន្ត្រីដើម្បីតំបន់អាស៊ីខាងកើត និងសន្តិភាព ក្នុងគោលដៅសំរាប់កុមារ និង ការអភិវឌ្ឍរហូតដល់ឆ្នាំ២០០០ ដែលប្រព្រឹត្តឡើងនៅទីក្រុងហាណូយ ពីថ្ងៃទី១៣ ដល់ថ្ងៃទី១៦ វិច្ឆិកា ១៩៩៥ ព្រមទាំងសន្និសីទអន្តរជាតិលើកទី៣ នៃកិច្ចការពារកុមារ ដែលប្រព្រឹត្តឡើងនៅទីក្រុងប៉ារីសពីថ្ងៃទី៨ ដល់៩ ធ្នូ ១៩៩៤។

**២៨-** រាជរដ្ឋាភិបាលតែងយកចិត្តទុកដាក់លើបញ្ហាផ្សេងៗ ដែលទាក់ទងនឹងកុមារ ដោយបានសហការជាមួយអង្គការអន្តរជាតិ អង្គការមនុស្សធម៌នានា ក្នុងការរៀបចំកម្មវិធី និងយន្តការសំរាប់ការពារសិទ្ធិកុមារ ស្របទៅនឹងបទបញ្ញត្តិនៃអនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារ ។

*

*   *

# I- វិធានការអនុវត្តទូទៅ

**********

## ក- វិធានការដើម្បីឱ្យច្បាប់ជាតិ និងគោលនយោបាយជាតិស្របទៅនឹងអនុសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិកុមារ

**២៩-** មុន និងក្រោយការឱ្យសច្ចាប័នលើអនុសញ្ញាអន្តរជាតិ ស្តីពីសិទ្ធិកុមារ ប្រទេសកម្ពុជាមានច្បាប់មួយចំនួនដែលបានកំណត់នូវបទបញ្ញត្តិផ្សេងៗ ទាក់ទងនឹងការការពារសិទ្ធិ និងផលប្រយោជន៍របស់កុមារ ។

**៣០-** ច្បាប់ការងារ ១៩៩២ បានកំណត់អំពីរបៀបគ្រងគ្រងការងាររបស់ក្មេងដែលមិនទាន់ពេញវ័យ ដើម្បីជៀសវាងការកេងប្រវ័ញ្ចលើពលកម្មកុមារ និងដើម្បីគិតគូរដល់ការថែទាំសុខភាពកុមារ ។

មាត្រា ១៧៣ : " ក្មេងទាំងពីរភេទអាយុតិចជាង១៦ឆ្នាំ មិនអាចឱ្យចូលធ្វើការជាអ្នកស៊ីឈ្នួល និយោជិក ជាងឬកូនជាង ក្នុងសហគ្រាសណាមួយទេ ទោះប្រភេទណាក៏ដោយ " ។

មាត្រា ១៧៤ : "អធិការការងារអាចសុំឱ្យគ្រូពេទ្យដែលកាន់កាប់ក្រសួងសាធារណៈណាមួយ មកពិនិត្យក្មេងអាយុតិចជាង១៨ឆ្នាំ ដែលធ្វើការក្នុងសហគ្រាសដើម្បីបញ្ជាក់ថាការងារដែលគេដាក់ឱ្យនោះ មិនលើស កំលាំងទេ..." ។

មាត្រា ១៧៨ : " ...ស្ត្រីទាំងឡាយត្រូវមានសិទ្ធិឈប់សំរាកកៅសិបថ្ងៃ ដើម្បីសំរាលកូន..." ។

៣១- ច្បាប់អាពាហ៍ពិពាហ៍ និង គ្រួសារ ១៩៨៩ មានបទបញ្ញត្តិជាច្រើនទាក់ទងដល់កុមារ (មាត្រា ១-២-៤-៥-៨២ ដល់១១៩ , ១១៩ ដល់ ១១២)។ ច្បាប់នេះបានចែងអំពីការទទួលខុសត្រូវរបស់ឪពុកម្តាយ ឬអាណាព្យាបាល ក្នុងការចិញ្ចឹម ថែរក្សាកូន ជំរុញការបណ្តុះបណ្តាលសីលធម៌ និងការអប់រំកូនឱ្យក្លាយទៅជាពលរដ្ឋល្អ មានមនសិកាស្នេហាជាតិ ស្រឡាញ់ការងារ មានសម្បជញ្ញៈទទួលខុសត្រូវចំពោះសង្គម (មាត្រា ១១៥) ។

៣២- ច្បាប់ព្រហ្មទណ្ឌអន្តរកាល ឆ្នាំ ១៩៩៣ " មាត្រា១៤ កថាខ័ណ្ឌ៥ ចែងថា អនីតិជនអាយុតិចជាង១៣ឆ្នាំ មិនត្រូវជាប់ឃុំឃាំងជាបណ្តោះអាសន្នទេ ។ អនីតិជនដែលមានអាយុពី ១៣ ទៅ ១៨ឆ្នាំ មិនត្រូវជាប់ឃុំឃាំងជាបណ្តោះអាសន្នលើសពី ១ខែទេ។ រយៈពេលនេះអាចទ្វេឡើងជាពីរ បើសិនជាមានការចោទប្រកាន់ពីបទឧក្រិដ្ឋណាមួយ"។ មាត្រា ៤២ កថាខ័ណ្ឌ៣ ចែងថា "នឹងត្រូវផ្តន្ទាទោសដាក់គុកពី២ឆ្នាំ ទៅ៦ឆ្នាំដែរ ចំពោះជនណាដែលបានល្បួងអូសទាញ ឬបង្វែងគំនិតអនីតិជនដើម្បីធ្វើពេស្យាចារ ឬអាជីវកម្មពេស្យាចារលើអនីតិជន ទោះបីមានការព្រមព្រៀងក៏ដោយ។ " មាត្រា ៦៨ បានចែងអំពីស្ថាន សំរាលទោស និងគ្រាប្រណីចំពោះអនីតិភាព ។

៣៣- ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌឆ្នាំ ១៩៨៩ និង ឆ្នាំ ១៩៩៣ មានបទបញ្ញត្តិពិសេស១ទាក់ទងដល់អនីតិជន (មាត្រា ២៨ " ១៩៨៩ " មាត្រា ២២, ៣៤, ៥៤, ៧៦, ១៦២ និង ២៣១ " ១៩៩៣ ")។

៣៤- បទបញ្ញត្តិនៃច្បាប់ដែលបានរៀបរាប់ខាងលើនេះ នៅបន្តការអនុវត្តរហូតមកដល់បច្ចុប្បន្ន ។

៣៥- បន្ទាប់ពីបានឱ្យសច្ចាប័នលើអនុសញ្ញា ស្តីពីសិទ្ធិកុមារ រដ្ឋធម្មនុញ្ញ និងច្បាប់ផ្សេង១ ព្រះរាជាណាចក្រកម្ពុជាបានកំណត់នូវបទបញ្ញត្តិមួយចំនួនដែលមានអត្ថន័យស្របនឹងអនុសញ្ញានេះ ។

៣៦- ច្បាប់រដ្ឋធម្មនុញ្ញមាត្រា ៤៨ បានចែងថា : រដ្ឋធានារក្សាការពារសិទ្ធិកុមារដែលមានចែងក្នុងអនុសញ្ញា ស្តីពីកុមារ ជាពិសេសសិទ្ធិមានជីវិតរស់នៅ សិទ្ធិទទួលការអប់រំរៀនសូត្រ សិទ្ធិត្រូវបានទទួលការគាំពារក្នុងស្ថានការណ៍មានសង្គ្រាម និង ការការពារប្រឆាំងនឹងអាជីវកម្មសេដ្ឋកិច្ច ឬ កាមគុណលើកុមារ ។

មាត្រា ៦៨ : សិទ្ធិក្នុងការទទួលការអប់រំនៅសាលារៀនសាធារណៈដោយឥតគិតថ្លៃ នៅបឋមសិក្សា និងមធ្យមសិក្សា និង កាតព្វកិច្ចសិក្សាយ៉ាងតិច ៩ឆ្នាំ នៅសាលាសាធារណៈ ។

មាត្រា ៤៧ : មាតាបិតាមានកាតព្វកិច្ចចិញ្ចឹមបីបាច់ថែរក្សា និង អប់រំកូនឱ្យទៅជាពលរដ្ឋល្អ។

មាត្រា ៧៣ : រដ្ឋយកចិត្តទុកដាក់ចំពោះកុមារ និង មាតា។ រដ្ឋរៀបចំឱ្យមានទារកដ្ឋាន និង ជួយឧបត្ថម្ភនារីដែលមានកូនច្រើនក្នុងបន្ទុក ហើយឥតទីពឹង ។

៣៧- ព្រះរាជក្រឹត្យលេខ នស/រកត/០២៩៤/១៣ ចុះថ្ងៃទី ០៨/០២/៩៤ និងលេខ សន/រកត/១០៩៤/៨៣ ចុះថ្ងៃទី ២៤/១០/៩៤ ស្តីពីការបង្កើតទីស្តីការយុវនីតិសម្បទា ដែលមានសមត្ថភាពគ្រប់គ្រងក្មេងពីអាយុ៧ឆ្នាំ ដល់ ១៧ឆ្នាំ ដែលប្រព្រឹត្តអំពើអបាយមុខ ចោរកម្មក្នុងទូទាំងប្រទេស និង មានតួនាទីកែប្រែអភិវឌ្ឍន៍ធនធានមនុស្សឱ្យមានការរីកចំរើន ទាំងជីវភាព ស្មារតី និង សំភារៈ ដោយប្រែក្លាយពីជនគ្មានវិន័យ គ្មានសីលធម៌ ទៅជាប្រជាពលរដ្ឋស្អាតស្អំប្រកបដោយវិន័យថ្លៃថ្នូរ ។

៣៨- សេចក្តីប្រកាសអំពីគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាកាលពីខែ តុលា ១៩៩៣ បានយកចិត្តទុកដាក់ដល់ការអប់រំថែបំប៉នចំណេះដឹងរបស់កុមារ និងការពារសុខុមាលភាពរបស់មាតា និងកុមារ ដែលជាមាគ៌ានយោបាយមួយ ធ្វើឱ្យកុមារកម្ពុជាមានពន្លឺថ្មីក្នុងក្តីសង្ឃឹមនៃកិច្ចអភិវឌ្ឍលើគ្រប់វិស័យនៃសិទ្ធិរបស់ខ្លួន ។

**៣៩-** រាជរដ្ឋាភិបាល ជានិច្ចកាលតែងយកចិត្តទុកដាក់ដល់បញ្ហាដែលទាក់ទងនឹងកុមារ ដោយដាក់កុមារជាបញ្ហាចំបង និង ចាត់ទុកកុមារជាសសរទ្រូងរបស់ជាតិ ជាទំពាំងស្នងឫស្សី ។

**៤០-** ក្នុងវិស័យសុខាភិបាល រាជរដ្ឋាភិបាលបានដាក់វិធានការប្រឆាំងទល់នឹងជម្ងឺឆ្លងផ្សេងៗ ជម្ងឺគ្រុនឈាម ជម្ងឺស្វិតដៃ ជើង ដោយការធ្វើការផ្សព្វផ្សាយ លើកកំពស់ស្មារតីនៃការចាក់ថ្នាំការពារជម្ងឺ៦មុខ។ រដ្ឋបានយកចិត្តទុកដាក់ដល់សុខភាពរបស់កុមារ កំព្រាដែលរស់នៅក្នុងមជ្ឈមណ្ឌលសង្គ្រោះ ។

**៤១-** ក្នុងវិស័យអប់រំ រាជរដ្ឋាភិបាលបានដាក់ផែនការប្រយុទ្ធប្រឆាំងនឹងគ្រោះមិនចេះអក្សរ ដោយត្រូវជំរុញកុមារចាប់ពី អាយុ៦ឆ្នាំ ត្រូវចូលសាលារៀន ជាពិសេសនៅតាមជនបទដាច់ស្រយាល រដ្ឋបានយកចិត្តទុកដាក់លើការសង់សាលារៀន និង ឧបត្ថម្ភសំភារៈសិក្សា ។ ប្រព័ន្ធអប់រំត្រូវបានធ្វើការកែលំអ ក្នុងគោលបំណងពង្រីកចំណេះដឹង និង សមត្ថភាពរបស់កុមារឱ្យបាន ទូលំទូលាយ សំរាប់ឱ្យទៅបន្តការសិក្សាផ្នែកបច្ចេកទេស និង ជំនាញវិជ្ជាជីវៈផ្សេងៗ ។

**៤២-** ក្នុងវិស័យសង្គមកិច្ច រាជរដ្ឋាភិបាលមាននយោបាយការពារសិទ្ធិកុមារលើគ្រប់ករណីដែលកុមារជួបប្រទះនូវស្ថានភាព លំបាកផ្សេងៗដូចជាការកេងប្រវ័ញ្ចលើពលកម្ម ការរំលោភតាមរូបភាពផ្សេងៗ។ មជ្ឈមណ្ឌលត្រូវបានបង្កើតនៅតាមខេត្ត-ក្រុង ខ្លះសំរាប់ប្រមូល និងអប់រំកុមារអនាថាគ្មានទីស្នាក់អាស្រ័យ និងកុមារ កំព្រាគ្មានអាណាព្យាបាល។ មណ្ឌលអប់រំមុខជំនាញ វិជ្ជាជីវៈ សំរាប់កុមារពិការ និងកុមារកំព្រាត្រូវបានបង្កើតឡើងដោយមានការជួយឧបត្ថម្ភពីអង្គការមនុស្សធម៌នានា ។

## ខ. <u>យន្តការសំរបសំរួលគោលនយោបាយដែលទាក់ទងនឹងកុមារ និងតាមដានត្រួតពិនិត្យការអនុវត្តអនុសញ្ញា</u>

**៤៣-** តាមអនុក្រឹត្យលេខ៨៣អនក្រ ចុះថ្ងៃទី២០ វិច្ឆិកា ១៩៩៥ រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតក្រុមប្រឹក្សាជាតិកម្ពុជា ដើម្បីកុមារ ទទួលបន្ទុកធានាកិច្ចសហការសម្របសម្រួលដ៏សមស្រប ក្នុងការអនុវត្តការតាមដាន ពិនិត្យ និងវាយតម្លៃលើគោល នយោបាយទាំងឡាយ និងកម្មវិធីដែលទាក់ទងនឹងការរស់រានមានជីវិត ការអភិវឌ្ឍ ការការពារ ការលើកកំពស់សុខុមាលភាព និង ការចូលរួមចំណែករបស់កុមារកម្ពុជា ( មាត្រា១) ។

ក្រុមប្រឹក្សាជាតិនេះ មានរដ្ឋលេខាធិការក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន ជាប្រធាន មានតំណាងក្រសួង ១១ តំណាងទីស្តីការគណៈរដ្ឋមន្ត្រី និង តំណាងកាកបាទក្រហមកម្ពុជាជាសមាជិក ( មាត្រា២ ) ។

តំណាងភ្នាក់ងារអង្គការសហប្រជាជាតិ អង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ តំណាងវិទ្យាស្ថានស្រាវជ្រាវពាក់ពន្ធ័ ក្នុងស្រុក អង្គការផ្តល់ជំនួយទ្វេរភាគី អាចចូលរួមប្រជុំតាមការអញ្ជើញរបស់ក្រុមប្រឹក្សា ( មាត្រា៣ ) ។

ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ជាស្ថាប័នថ្នាក់ជាតិសំរាប់ការងារពិគ្រោះយោបល់ សំរបសំរួលសកម្មភាពទាំងឡាយ ដែលពាក់ព័ន្ធនឹងបញ្ហាកុមារនៅក្នុងប្រទេសកម្ពុជា ជួយរាជរដ្ឋាភិបាលក្នុងការតាមដាន និង ធ្វើរបាយការណ៍លើបញ្ហាទាំងឡាយ ដែលពាក់ព័ន្ធនឹងកុមារ ដូចជាអនុសញ្ញាស្តីពីសិទ្ធិកុមារ និងកម្មវិធីសកម្មភាពជាតិសំរាប់កុមារ។ ស្រាវជ្រាវ និងជូនពត៌មានស្តីពី សេចក្តីត្រូវការ និងបញ្ហាទាំងឡាយដែលពាក់ព័ន្ធនឹងកុមារកម្ពុជាទៅរាជរដ្ឋាភិបាល ស្ថាប័ន និងអង្គការនានាដែលមានសមត្ថកិច្ច។ ទំនាក់ទំនងជាមួយសហគមជាតិ និង អន្តរជាតិ ដែលមានការងារប្រហាក់ប្រហែលគ្នា ដើម្បីប្តូរយោបល់ បទពិសោធន៍ និងទស្សនៈ វិកចំរើន ដែលទាក់ទងនឹងគោលដៅរួមក្នុងការកែលំអរស្ថានភាពរបស់កុមារ ( មាត្រា៤ ) ។ ក្រុមប្រឹក្សាជាតិនេះមានអគ្គលេខា-ធិការដ្ឋានអចិន្ត្រៃយ៍មួយ ( មាត្រា៦) ។ ក្រុមប្រឹក្សាជាតិត្រូវបានប្រកាសជាផ្លូវការនៅថ្ងៃទី ២០ វិច្ឆិកា ១៩៩៥ ក្រោមអធិបតី ភាពរបស់សម្តេចនាយករដ្ឋមន្ត្រីទាំង២ ដែលជាប្រធានកិត្តិយស ។

៤៤- រាជរដ្ឋាភិបាល បានបង្កើតគណៈកម្មការអន្តរក្រសួងមួយ ទទួលបន្ទុកសរសេររបាយការណ៍ស្តីពីសិទ្ធិមនុស្ស ជូនអង្គការសហប្រជាជាតិ ( សេចក្តីសំរេចលេខ ៣៤ សសរ ចុះថ្ងៃទី ២៨ មិនា ១៩៩៤ ) ។ គណៈកម្មការនេះ បានបង្កើតអនុគណៈកម្មការមួយ ទទួលបន្ទុកសរសេររបាយការណ៍ស្តីពីសិទ្ធិកុមារ ។

៤៥- រាជរដ្ឋាភិបាល បានរៀបចំបង្កើតទីស្តីការយុវនីតិសម្បទា ដែលមានសមត្ថកិច្ចគ្រប់គ្រងក្មេងពីអាយុ៧ឆ្នាំ ដល់១៧ឆ្នាំ ដែលប្រព្រឹត្តអំពើអបាយមុខ និង ចោរកម្ម និងមានតួនាទីកែប្រែអភិវឌ្ឍន៍ធនធានមនុស្ស ។

៤៦- ក្នុងក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន មានផ្នែកសង្គ្រោះកុមារ (Child Welfare Group) ដែលទទួលបន្ទុកការពារ និងបង្កើនកំរិតជីវភាពរស់នៅរបស់កុមារ ។

៤៧- មជ្ឈមណ្ឌលគាំពារមាតា និងទារក និង មន្ទីរពេទ្យកុមារនានា ត្រូវបានបង្កើតឡើងនៅក្នុងក្រសួងសុខាភិបាល ។ មជ្ឈមណ្ឌលនេះ មានភារកិច្ចគាំពារព្យាបាលសុខភាពមាតា និងកុមារ និងអនុវត្តកម្មវិធីពន្យាកំណើត ។

៤៨- រដ្ឋលេខាធិការដ្ឋានកិច្ចការនារី បានបង្កើតនាយកដ្ឋានការពារសិទ្ធិស្ត្រី និងកុមារ និង នាយកដ្ឋានការពារសុខភាពស្ត្រី និងកុមារ ។ នាយកដ្ឋានទាំង២មានភារកិច្ចអប់រំសុខភាព និងការពារសិទ្ធិកុមារ ។

៤៩- ក្រសួងអប់រំ បានបង្កើតអគ្គនាយកដ្ឋានអប់រំ យុវជន និងកីឡា ដែលមានតួនាទីយ៉ាងសំខាន់ក្នុងការអប់រំយុវជន និងកុមារដោយបានលើកនូវទិសដៅសំខាន់ៗ គឺត្រូវអប់រំឱ្យកុមារមានចំណេះ ត្រូវបង្កឱ្យកុមារលេងកីឡា បង្កើតការកំសាន្តផ្សេងៗ បណ្តុះឱ្យកុមារមានឧត្តមគតិជាតិ ។

៥០- ក្នុងស្ថានភាពនេះ កម្ពុជាបានដាក់ផែនការជាតិ សកម្មភាពដើម្បីកុមារ ដែលជាផ្នែកមួយនៃផែនការ៥ឆ្នាំ សេដ្ឋកិច្ច-សង្គមកិច្ច ដែលដាក់បង្ហាញក្នុងការប្រជុំនៃអ្នកផ្តល់ជំនួយនៅទីក្រុងតូក្យូ ខែមេសា ១៩៩៦ ។

៥១- មានការផ្សព្វផ្សាយជាសាធារណៈតាមប្រព័ន្ធឃោសនាផ្សេងៗ : ទូរទស្សន៍ វិទ្យុ សារពតិមាន សៀវភៅស្តីពីសិទ្ធិកុមារ បដា ពាក្យស្លោក ក្នុងគោលបំណងឱ្យសាធារណៈជនយល់ដឹងអំពីសិទ្ធិកុមារ និងដើម្បីឱ្យកុមារយល់ដឹងអំពីអ្វីដែលខ្លួនមាន ប៉ុន្តែការផ្សាយនេះមិនទាន់បានទូលំទូលាយ និងមានប្រសិទ្ធភាពនៅឡើយទេ ។

## គ- <u>សហប្រតិបត្តិការអន្តរជាតិ</u>

៥២- រាជរដ្ឋាភិបាលកម្ពុជាបានទទួលជំនួយឧបត្ថម្ភពីអង្គការអន្តរជាតិ អង្គការក្រៅរដ្ឋាភិបាល និងសមាគមមនុស្សធម៌នានា ក្នុងការរួមចំណែកដោះស្រាយបញ្ហាជីវភាពរស់នៅ និងសុខុមាលភាពរបស់កុមារកម្ពុជា ។ ក៏ប៉ុន្តែតម្រូវការចាំបាច់ជាមូលដ្ឋានរបស់កុមារកម្ពុជា នៅតែមានទំហំធំធេងនៅឡើយ ។

៥៣- អង្គការទាំងនេះ បាននឹងកំពុងចូលរួមយ៉ាងសកម្មលើសកម្មភាពដែលពាក់ពន្ធ័នឹងការអនុវត្តអនុសញ្ញា ស្តីពីសិទ្ធិកុមារ ដែលក្នុងនោះមានវិស័យសំខាន់ៗដូចជា សង្គមកិច្ច អប់រំ សុខាភិបាល សកម្មភាពលំអិត មានបញ្ជាក់ក្នុងផ្នែកនិមួយៗ ។

*

*   *

## II- និយមន័យកុមារ ( Definition of the Child )

( អនុសញ្ញាមាត្រា១ )

**៥៤-** ប្រទេសកម្ពុជាពុំទាន់មានច្បាប់ណាមួយដែលឱ្យនិយមន័យច្បាស់លាស់អំពីកុមារ ឬកំណត់អាយុដាច់ណាត់សំរាប់បែងចែកកុមារ និងមនុស្សពេញវ័យនៅឡើយ ។

**៥៥-** មាត្រា៣៤នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា គ្រាន់តែកំណត់ថាប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុយ៉ាងតិច១៨ឆ្នាំ មានសិទ្ធិបោះឆ្នោត។ ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ ដែលមានអាយុយ៉ាងតិច២៥ឆ្នាំ អាចឈរឈ្មោះឱ្យគេបោះឆ្នោត ។

**៥៦-** មាត្រា២ នៃច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ បានហាមឃាត់ដាច់ខាតនូវអាពាហ៍ពិពាហ៍ ដែលគូស្រករនៅក្មេងពេក។ មាត្រា៥នៃច្បាប់នេះបានកំណត់ថា អាចរៀបអាពាហ៍ពិពាហ៍បាន បុរសចាប់ពីអាយុ២០ឆ្នាំ នារីចាប់ពីអាយុ១៨ឆ្នាំ។ មាត្រា ៩៧ ចែងថា : " និតិភាពត្រូវកំណត់ចាប់តាំងពីអាយុ១៨ឆ្នាំឡើងទៅ " ។ មាត្រា១៤ នៃក្រឹត្យច្បាប់លេខ ៣៨ ក្រច ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា បានចែងថា : " ជនទាំងឡាយដែលមានអាយុគ្រប់១៨ឆ្នាំ អាចធ្វើកិច្ចសន្យាបានគ្រប់ពេល វេលា លើកលែងតែជនគំហាត់ដែលមានចែងក្នុងច្បាប់ " ។

**៥៧-** មាត្រា១៧៣ នៃច្បាប់ការងារ បានកំណត់ថា ក្មេងទាំងពីរភេទអាយុតិចជាង១៦ឆ្នាំ មិនអាចឱ្យចូលធ្វើការងារជាអ្នកស៊ីឈ្នួល និយោជិក ជាង ឬកូនជាងក្នុងសហគ្រាសណាមួយទេ ទោះប្រភេទណាក៏ដោយ។ ចំណែកឯមាត្រា ១៧៧ បានកំណត់ថា ការងារចំពោះក្មេងដែលមានអាយុតិចជាង១៨ឆ្នាំ ចាំបាច់ត្រូវមានការយល់ព្រមពីឪពុកម្តាយ ឬអាណាព្យាបាល ។

**៥៨-** ពិតមែនតែគ្មានការកំណត់អាយុអប្បបរមាសំរាប់ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ប៉ុន្តែច្បាប់ព្រហ្មទណ្ឌអន្តរកាលដែលមានអនុភាពអនុវត្ត ហើយមានបទបញ្ញត្តិមិនផ្ទុយពីរដ្ឋធម្មនុញ្ញ និង ពុំទាន់មានបទបញ្ញត្តិថ្មីណាមកជំនួសនោះ បានចែងក្នុងមាត្រា ១៤ ថា : " អនីតិជនអាយុតិចជាង១៣ឆ្នាំ មិនត្រូវចាប់ឃុំឃាំងជាបណ្តោះអាសន្នទេ ។ អនីតជនដែលមានអាយុ ១៣ ទៅ១៨ឆ្នាំ មិនត្រូវជាប់ឃុំឃាំងលើពី១ខែទេ "។ មាត្រា ៦៨-២ ចែងថា : " ចំពោះជនជាប់ចោទដែលមានអាយុតិចជាង ១៨ឆ្នាំ ទ័ណ្ឌកម្មដែលមានក្នុងបណ្តាមាត្រាមុនៗ ត្រូវកាត់បន្ថយពាក់កណ្តាល... " ។

**៥៩-** ជាទូទៅ បទបញ្ញត្តិទាំងឡាយដែលបានរៀបរាប់ខាងលើ ត្រូវបានគោរពដាក់ឱ្យអនុវត្ត ដោយបានបែងចែកច្បាស់លាស់ចំពោះវ័យរបស់កុមារ និងវ័យរបស់នីតិជនទៅតាមវិស័យនិមួយៗដោយឡែកពីគ្នា។ នៅតាមស្ថាប័នរដ្ឋ និង តាមសហគ្រាសឯកជន ការជ្រើសរើសមន្ត្រីរាជការ និយោជិក កម្មករ ត្រូវបានកំណត់ច្បាស់លាស់លើលក្ខខ័ណ្ឌអាយុ។ ការត្រួតពិនិត្យលើការប្រើប្រាស់កំលាំងពលកម្មកុមារនៅតាមសហគ្រាស រោងចក្រ និងការដ្ឋានផ្សេងៗ បានប្រព្រឹត្តទៅជារឿយៗក្នុងគោលបំណងការពារសិទ្ធិ និង ផលប្រយោជន៍របស់កុមារ ។

**៦០-** ក៏ប៉ុន្តែផលវិបាកនៃសង្គ្រាមជាងពីរទសវត្សន៍កន្លងមក បានបន្សល់នូវបញ្ហាជាច្រើន ជាកត្តាធ្វើឱ្យការអនុវត្តច្បាប់ដែលទាក់ទងនឹងការការពារសិទ្ធិកុមារជួបប្រទះនូវការខ្វះចន្លោះខ្លះៗ។ ភាពទីទ័លក្ររបស់ឪពុកម្តាយ ដែលគ្មានការងារធ្វើភាពជរារបស់ឪពុក ឬម្តាយមេម៉ាយ បានបង្ខំឱ្យកូនខ្លះដែលស្ថិតក្នុងវ័យកុមារនៅឡើយជួយរកស៊ីចិញ្ចឹមជីវិតគ្រួសារ ដោយធ្វើកិច្ចការធ្ងន់ៗ ដូចជាអូសទឹកលក់ កាប់អុសលក់ ហើយត្រូវដកខ្លួនចេញពីការសិក្សានៅសាលារៀនទៀតផង ក្មេងខ្លះត្រូវជួយធ្វើការងារស្រែចំការរបស់ឪពុកម្តាយជារៀងរាល់ថ្ងៃ ឯក្មេងខ្លះទៀតត្រូវប្រព្រឹត្តកិច្ចការផ្សេងៗ ដើម្បីបានកំរៃដោះស្រាយជីវភាព។ ការរៀបអាពាហ៍ពិពាហ៍ ខ្លះនៅតាមជនបទក៏បានប្រព្រឹត្តមុនអាយុកំណត់ក្នុងច្បាប់ដែរ ។

**៦១-** រាជរដ្ឋាភិបាលបានយល់ដឹងអំពីបញ្ហានេះ ហើយកំពុងតែពិនិត្យ និង ស្វែងរកមធ្យោបាយដោះស្រាយជាបន្តបន្ទាប់ ដោយពឹងផ្អែកជាមូលដ្ឋានទៅលើជំនួយបរទេស និង ការវិនិយោគទុនដើម្បីលើកស្ទួយសេដ្ឋកិច្ចកែលំអ និង អភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធប្រទេស ដែលជាគន្លឹះសំរាប់លើកស្ទួយជីវភាពប្រជារាស្ត្រ ជាពិសេសកុមារ ។

*

*     *

# III. គោលការណ៍ទូទៅ

ៜៜៜៜៜៜៜៜៜៜ

**ក.** **ការមិនរើសអើង** ( អនុសញ្ញាមាត្រា២ )

**បរិបទច្បាប់**

**៦២-** រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា :

មាត្រា៣១ : " ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់ ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើត ជាតិ ឋានៈសង្គម ធនធាន ឬ ស្ថានភាពឯទៀតឡើយ "។

មាត្រា៣៥ : " ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និង វប្បធម៌របស់ប្រទេសជាតិ " ។

**៦៣-** ច្បាប់អាពាហ៍ពិពាហ៍ និង គ្រួសារ :

មាត្រា១០៤ : " ...កូនឥតខាន់ស្លា ដែលត្រូវបានទទួលស្គាល់ មានករណីយកិច្ច និង មានសិទ្ធិដូចគ្នានឹងកូនមានខាន់ស្លាដែរ...... "។

មាត្រា១១៧ : កូនប្រុស និង កូនស្រីមានសិទ្ធិ និង ករណីយកិច្ចដូចគ្នាក្នុងគ្រួសារ ។

**ការអនុវត្ត**

**៦៤-** រាជរដ្ឋាភិបាល បានយកចិត្តទុកដាក់លើជីវភាពរស់នៅរបស់កុមារ និងមាតាគ្រប់តំបន់ក្នុងប្រទេស។ ក្នុងកម្មវិធីអភិវឌ្ឍន៍ជនបទរបស់រដ្ឋាភិបាល មានការសាងសង់មន្ទីរពេទ្យ សាលារៀនទាំងនៅទីក្រុង ទីជនបទដាច់ស្រយាល ជាពិសេសក្នុងតំបន់ដែលមានជនជាតិភាគតិចរស់នៅ ដោយគ្មានប្រកាន់សញ្ជាតិ ទំនៀមទំលាប់ ជំនឿ សាសនា ភាសាឡើយ។ មិនតែប៉ុណ្ណោះ រដ្ឋាភិបាលផ្តល់លទ្ធភាពយ៉ាងទូលាយដល់ការលើកស្ទួយវប្បធម៌របស់ក្រុមជនជាតិតាមវិធានការដូចជា អនុញ្ញាតិឱ្យបើកសាលារៀនចិន វិហារឥស្លាម ការធ្វើបុណ្យផ្សេងៗ ក្រៅពីពុទ្ធសាសនា ។

**៦៥-** ដោយសារស្ថានភាពសេដ្ឋកិច្ច ដែលទើបតែងើបពីសង្គ្រាមស៊ីវិល គេសង្កេតឃើញការអប់រំ ថែបំប៉នរបស់កុមារ នៅតាមទីក្រុង និងតាមជនបទមានភាពខុសគ្នាយ៉ាងខ្លាំងនៅឡើយ។ កត្តាដែលនាំឱ្យមានគំលាតគ្នាយ៉ាងនេះ បណ្តាលមកពីការអភិវឌ្ឍនៅទីជនបទ មានកំរិតទាបជាងទីក្រុង មកពីការខ្វះខាតមធ្យោបាយទំនាក់ទំនង ជាពិសេសប្រព័ន្ធនៃការផ្សព្វផ្សាយមិនទាន់បានពង្រាយឱ្យបានទូទាំងប្រទេស ។

៦៦- ម្យ៉ាងវិញទៀតរហូតមកដល់បច្ចុប្បន្ននេះ ការរើសអើងផ្លូវភេទនៅមានសេសសល់នៅឡើយ គឺនៅក្នុងគ្រួសារមួយចំនួន បុរសនៅតែតាំងខ្លួនជាចៅហ្វាយនាយលើស្ត្រីនៅឡើយ ។ កុមារីមិនសូវមានសិទ្ធិដើរហើរដូចកុមារាទេ ។

៦៧- ដើម្បីដោះស្រាយបញ្ហានេះ រដ្ឋាភិបាលបានខិតខំទៅតាមធនធានដែលខ្លួនមាន គួបផ្សំជាមួយនឹងជំនួយពីអង្គការអន្តរជាតិនានា បន្តការអភិវឌ្ឍជនបទ សាងសង់សាលារៀន រៀបចំប្រព័ន្ធការផ្សាយជាបណ្តើរៗ ក្នុងគោលបំណងផ្សព្វផ្សាយឱ្យប្រជាពលរដ្ឋទាំងអស់ ជាពិសេសកុមារបានដឹងស្គាល់យ៉ាងច្បាស់អំពីសិទ្ធិរបស់ខ្លួន។

## ខ. **<u>ឧត្តមប្រយោជន៍របស់កុមារ</u>** ( អនុសញ្ញាមាត្រា៣ )

### - <u>បរិបទច្បាប់</u>

៦៨- <u>រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា :</u>

មាត្រា៦៨ : " រដ្ឋផ្តល់ការអប់រំផ្នែកបឋម និង មធ្យមសិក្សានៅសាលារៀនសាធារណៈ សំរាប់ប្រជាពលរដ្ឋគ្រប់រូបដោយឥតបង់ថ្លៃ " ។

មាត្រា៧២ : " និយាយអំពីការរៀបចំឱ្យមានគិលានដ្ឋាន និង មន្ទីរសម្ភពដល់ជនបទ " ។

មាត្រា៧៣ : " រដ្ឋយកចិត្តទុកដាក់ចំពោះកុមារ និង មាតា។ រដ្ឋរៀបចំឱ្យមានទារដ្ឋាន និង ជួយឧបត្ថម្ភនារីដែលមានកូនច្រើនក្នុងបន្ទុកហើយឥតទីពឹង " ។

៦៩- ព្រះរាជក្រឹត្យលេខ ន.ស/រ.ក.ត./០២៩៤/១៣ ចុះថ្ងៃទី០៨-០២-៩៤ និង លេខ ស.ន/រ.ក.ត./ ១០៩៤/ ៨៣ ចុះថ្ងៃទី ២៤-១០-៩៤ ស្តីពីការបង្កើតទីស្តីការយុវនីតិសម្បទា ។

៧០- ច្បាប់ការងារ មាត្រា១៧៤ ដល់ ១៧៦ : តម្រូវឱ្យនាយកគ្រឹះស្ថានឧស្សាហកម្មយកចិត្តទុកដាក់ជាពិសេសលើកុមារ ដោយត្រូវមានបញ្ជីចុះឈ្មោះ កាលបរិច្ឆេទកំណើតក្មេងក្រោមអាយុ១៨ឆ្នាំ ត្រូវមានការតាមដានសុខភាព ។

៧១- ច្បាប់ព្រហ្មទ័ណ្ឌអន្តរកាល( អ៊ុនតាក់) ។ "....អនីតិជនអាយុតិចជាង១៣ឆ្នាំ មិនត្រូវជាប់ឃុំឃាំងជាបណ្តោះអាសន្នទេ..." អនីតិជនដែលមានអាយុពី១៣ ទៅ ១៨ឆ្នាំ មិនត្រូវជាប់ឃុំឃាំងជាបណ្តោះអាសន្នលើសពីមួយខែទេ ។

៧២- មាត្រា៧៣ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ចែងថា " ដើម្បីផលប្រយោជន៍របស់កូន ការឱ្យភាគីណាមួយរក្សាកូនត្រូវសំរេចតាមការយល់ព្រមនៃប្តីប្រពន្ធដែលលែងលះគ្នានោះ " ។

៧៣- ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារត្រូវបានបង្កើតនៅថ្ងៃទី២០ វិច្ឆិកា ១៩៩៥ ។

### - <u>ការអនុវត្ត</u>

៧៤- រាជរដ្ឋាភិបាលតែងយកចិត្តទុកដាក់ជាចម្បងលើឧត្តមប្រយោជន៍របស់កុមារ ផាសុខភាពរបស់កុមារ បង្កើតកម្មវិធីអប់រំតាមប្រព័ន្ធឃោសនាផ្សេងៗដល់ឪពុកម្តាយ ឬអាណាព្យាបាលឱ្យយល់ពីករណីយកិច្ចក្នុងការអប់រំថែទាំ និងការពារកុមារ ។

៧៥- ក៏ប៉ុន្តែភាពក្រីក្រ និង កង្វះការយល់ដឹងរបស់គ្រួសារភាគច្រើន បានជះឥទ្ធិពលយ៉ាងខ្លាំងទៅលើផាសុខភាពរបស់កុមារ ចំណេះដឹងរបស់កុមារ។ ឪពុកម្តាយជាអាណាព្យាបាលមួយចំនួន មិនទាន់បានយកចិត្តទុកដាក់ទៅលើឧត្តមប្រយោជន៍របស់កុមារឡើយ រដ្ឋក៏ពុំទាន់មានលទ្ធភាពគិតគូរឱ្យបានខ្លាំងក្លាទៅលើឧត្តមប្រយោជន៍របស់ក្មេងអនាថាដែលរស់នៅតាមចិញ្ចើមថ្នល់។

៧៦- រដ្ឋាភិបាលបានធ្វើកិច្ចសហប្រតិបត្តិការជាមួយអង្គការយូនីសេហ្វ និងមជ្ឈមណ្ឌលសិទ្ធិមនុស្ស ក្នុងការបណ្តុះបណ្តាលមន្ត្រីរាជការឱ្យយល់ដឹងអំពីសិទ្ធិរបស់កុមារ ហើយតាមរយៈមន្ត្រីរាជការ បានឈានទៅដល់ការអប់រំប្រជាជនទូទាំងប្រទេស។

## គ. សិទ្ធិរស់រានមានជីវិត និង អភិវឌ្ឍន៍ ( អនុសញ្ញាមាត្រា ៦ )

~ **បរិបទច្បាប់**

**៧៧-** រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា :

មាត្រា៣២ : " ជនគ្រប់រូបមានសិទ្ធិរស់រានមានជីវិត..." ។

មាត្រា៤៨ : " រដ្ឋធានារក្សាការពារសិទ្ធិកុមារដែលមានចែងក្នុងអនុសញ្ញា ស្ដីពីសិទ្ធិកុមារ ជាពិសេសសិទ្ធិមានជីវិតរស់នៅ..." ។

**៧៨-** ច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ :

មាត្រា៧៤ : " ឪពុក ឬ ម្ដាយលះលែងគ្នា ត្រូវជួយផ្គត់ផ្គង់បីបាច់ថែរក្សា ជួយផ្ដល់សោហ៊ុយអប់រំ និង រៀនសូត្រដល់កូន... "

~ **ការអនុវត្ត**

**៧៩-** កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលក្នុងវិស័យសុខាភិបាល បានយកចិត្តទុកដាក់ទៅលើផ្នែកគាំពារមាតា និងទារកជាពិសេស។ ដូច្នេះ មិនថាតែនៅទីក្រុងធំៗទេ សូម្បីតែនៅតំបន់ជនបទស្រុកស្រែចំការ គេឃើញមានការចាក់ថ្នាំការពារជម្ងឺកុមារផ្សេងៗ ដូចជាចាក់ថ្នាំការពារជម្ងឺ៦មុខដោយឥតគិតថ្លៃ ដោយបង្កើតជាទិវាចាក់ថ្នាំការពារ ឬក៏មានផ្នែកចាក់ថ្នាំការពារជាអចិន្ត្រៃយ៍នៅតាមមន្ទីរពេទ្យទាំងឡាយក្នុងទីក្រុង រហូតដល់ទីជនបទ តែនៅទីកន្លែងដែលមានអសន្តិសុខយើងពុំអាចអនុវត្តការចាក់ថ្នាំនេះបានទេ។ ទោះបីមានការយកចិត្តទុកដាក់យ៉ាងនេះក៏ដោយ ក៏អត្រាស្លាប់របស់កុមារនៅតែមានកំរិតខ្ពស់នៅឡើយ។ (តាមអង្គការយូនីសេហ្វ អត្រាស្លាប់របស់កុមារមាន ១១៥ភាគពាន់) ហើយអត្រាស្លាប់ក្រោមអាយុ៥ឆ្នាំមាន ១៨១ភាគពាន់)។

## ឃ. ការទទួលស្គាល់លើទស្សនៈរបស់កុមារ ( មាត្រា១២ នៃអនុសញ្ញា )

~ **បរិបទច្បាប់**

**៨០-** រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា :

មាត្រា៤៧ : " ប្រជាពលរដ្ឋខ្មែរមានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន....." ។

~ **ការអនុវត្ត**

**៨១-** ក្នុងការអនុវត្តសិទ្ធិនេះ កុមារអាចបញ្ចេញមតិរបស់ខ្លួននៅតាមសាលារៀន តាមរយៈសំនួរចំលើយដែលគ្រូចោទមកតាមរយៈការប្រជុំ តាមគំនូររូបភាព និង តាមការនិទានរឿងផ្សេងៗ ។

ក្នុងករណីឪពុកម្ដាយមានការលែងលះគ្នា ចៅក្រមតែងតែផ្ដល់សិទ្ធិឱ្យកុមារដែលជាកូនបញ្ចេញនូវទស្សនៈក្នុងការរស់នៅក្រោមអាណាព្យាបាល ដោយឱ្យកុមារធ្វើការសំរេចចិត្ត តើរស់នៅជាមួយឪពុក ឬជាមួយម្ដាយ។ ប៉ុន្តែចៅក្រមក៏មានសិទ្ធិសំរេចអំពីបញ្ហានេះដែរ ដោយគិតទៅលើផលប្រយោជន៍របស់កុមារ ។

**៨២-** ក្នុងប្រព័ន្ធឃោសនាមានវិទ្យុ និងទូរទស្សន៍ជាដើម មានរៀបចំកម្មវិធី " នាទីកុមារ " ដែលក្នុងនោះកុមារអាចបង្ហាញពីចិត្តគំនិតរបស់គេ អំពីអ្វីដែលគេយល់ឃើញបានដោយសេរី។ ជាពិសេសទៅទៀតនោះ កុមារត្រូវបានគេអនុញ្ញាតឱ្យសំដែងគំនិតរបស់គេផ្ទាល់ ជុំវិញបញ្ហាសិទ្ធិរបស់គេនៅក្នុងសិក្ខាសាលាស្ដីពីសិទ្ធិកុមារ ។

**៨៣-** ក៏ប៉ុន្តែ ទោះជាយ៉ាងណាក៏ដោយ កុមារនៅតែមិនទាន់បានប្រើប្រាស់ឱ្យអស់លទ្ធភាពនៅឡើយនូវសិទ្ធិរបស់ខ្លួនក្នុងការបញ្ចេញមតិនេះ។ ហេតុទាំងនេះ បណ្ដាលមកពីទម្លាប់របស់ខ្មែរដែលមិនសូវឱ្យក្មេងនិយាយស្ដីតវ៉ាច្រើន សីលធម៌ខ្មែរ មិនឱ្យក្មេង

លូកមាត់និយាយពេលចាស់ៗជជែកពិភាក្សាគ្នា គ្រូបង្រៀនខ្លះៗ មនុស្សពេញវ័យខ្លះៗ មិនទាន់យកចិត្តទុកដាក់លើការបញ្ចេញគំនិតរបស់ក្មេងនៅឡើយទេ ដោយគេយល់ថាក្មេង មិនទាន់ចេះគិតវែងឆ្ងាយ ។

*

*  *

## IV. សិទ្ធិពលរដ្ឋ និង សេរីភាព

ccccccccccc

**ក-** **ឈ្មោះ និង សញ្ជាតិ** ( អនុសញ្ញាមាត្រា៧ )

**-** **បរិបទច្បាប់**

**៨៤-** រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា :

មាត្រា៣៣ : ប្រជាពលរដ្ឋខ្មែរមិនអាចត្រូវបានដកសញ្ជាតិ ការទទួលសញ្ជាតិខ្មែរត្រូវកំណត់ក្នុងច្បាប់ ។

មាត្រា៤៧ : កំណត់អំពីកាតព្វកិច្ចរបស់ឪពុកម្តាយក្នុងការចិញ្ចឹមកូន ។

**៨៥-** ច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ :

មាត្រា៨២ រហូតដល់១១៤ បានកំណត់អំពីសិទ្ធិរបស់កុមារ ( កូនមានខាន់ស្លា, កូនឥតខាន់ស្លា, កូនចិញ្ចឹម ) ក្នុងការមានឈ្មោះ ក្នុងការស្គាល់ឪពុកម្តាយខ្លួន និងក្នុងការទទួលការថែទាំពីអ្នកទាំងនោះ ។

**-** **ការអនុវត្ត**

**៨៦-** ជាទូទៅនៅក្នុងព្រះរាជាណាចក្រកម្ពុជា បន្ទាប់ពីកុមារប្រសូត្រចេញមកឪពុកម្តាយតែងតែនាំកូនទៅចុះបញ្ជីអត្រានុកូលដ្ឋានតាមឃុំ ឬសង្កាត់ដែលខ្លួនរស់នៅ ដោយបញ្ជាក់លើសំបុត្រកំណើតអំពី ឈ្មោះ សញ្ជាតិ ថ្ងៃ ខែ ឆ្នាំ និង ទីកន្លែងកំណើត។ ការចុះបញ្ជីអត្រានុកូលដ្ឋានកូនរបស់មន្ត្រីរាជការគឺចុះដោយស្វ័យប្រវត្តិ។ ចំពោះឪពុកម្តាយមួយចំនួនមិនបានយកកូនទៅចុះបញ្ជីឬមានការយឺតយ៉ាវក្នុងការនាំចុះបញ្ជី ដោយគិតថារឿងនេះគឺគ្មានបានទទួលការបង្ខិតបង្ខំ ឬដាក់ពិន័យពីជនណាម្នាក់ឡើយ។ ចំពោះកុមារជាកូនជនភៀសខ្លួនដែលកើតនៅលើទឹកដីកម្ពុជាពុំទាន់មានការផ្តល់សញ្ជាតិនៅឡើយ។ បញ្ហានេះមានចែងនៅក្នុងសេចក្តីព្រាងច្បាប់ស្តីពីសញ្ជាតិ ។ ច្បាប់ស្តីពីសញ្ជាតិនេះ សភាជាតិកំពុងពិនិត្យ និងពិភាក្សា។

**៨៧-** ចំពោះកូនដែលគេបោះបង់ចោល ឬកូនចិញ្ចឹម ដាក់ឈ្មោះ និងត្រកូលតាមឪពុកចិញ្ចឹម ( មាត្រា ១១៤ នៃច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ )។

**៨៨-** កូនឥតខាន់ស្លា ត្រូវយកត្រកូលរបស់ឪពុក ឬម្តាយដែលទទួលស្គាល់ខ្លួន។ ប្រសិនបើឪពុក និងម្តាយទាំងពីរទទួលស្គាល់កូននោះ ត្រូវយកត្រកូលរបស់ឪពុក ។( មាត្រា១០៣ ច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ )

**៨៩-** ក៏ប៉ុន្តែ នៅតាមតំបន់ដាច់ស្រយាល និងតំបន់អសន្តិសុខ ការចុះបញ្ជីអត្រានុកូលដ្ឋានរបស់កូនដែលទើបកើត មិនទាន់បានអនុវត្តគ្រប់ជ្រុងជ្រោយនៅឡើយទេ ដោយការយល់ដឹង និងមធ្យោបាយ។

**៩០-** សេចក្ដីព្រាងច្បាប់ស្ដីពីសញ្ជាតិ បានធ្វើឡើងអនុលោមទៅតាមគោលការណ៍នៃអនុសញ្ញាស្ដីពីសិទ្ធិកុមារ ។ រាជរដ្ឋាភិបាលមានសង្ឃឹមថា ច្បាប់នេះជាមូលដ្ឋានសំរាប់ផ្សព្វផ្សាយដល់មាតាបិតា ឱ្យយល់ពីករណីយកិច្ចរបស់ខ្លួន ក្នុងការនាំកូនទៅចុះបញ្ជីអត្រានុកូលដ្ឋាន ។

ក្រសួងមហាផ្ទៃបានធ្វើការណែនាំដល់រដ្ឋអំណាចមូលដ្ឋាន ជាពិសេសរដ្ឋអំណាចឃុំ-សង្កាត់ ឱ្យណែនាំប្រជាជនឱ្យយល់ពីសារៈសំខាន់ពីការចុះបញ្ជីកំណើតកូន ។

**ខ.** **<u>ការការពារអត្តសញ្ញាណ</u>** ( អនុសញ្ញាមាត្រា៨ )

- **<u>បរិបទច្បាប់</u>**

**៩១-** មាត្រា៣៣នៃរដ្ឋធម្មនុញ្ញចែងថា ប្រជាពលរដ្ឋខ្មែរមិនអាចត្រូវបានដកសញ្ជាតិ និរទេស ឬចាប់បញ្ជូនខ្លួនទៅឱ្យប្រទេសក្រៅណាមួយឡើយ លើកលែងតែមានកិច្ចព្រមព្រៀងជាមួយគ្នាទៅវិញទៅមក ។

- **<u>ការអនុវត្ត</u>**

**៩២-** ថ្វីត្បិតតែកម្ពុជាពុំទាន់មានច្បាប់ស្ដីពីសញ្ជាតិ និងច្បាប់ដែលទាក់ទងនឹងការការពារអត្តសញ្ញាណក៏ដោយ ក្នុងការអនុវត្តកន្លងមក យោងតាមកំណត់សំរេចលេខ១៥៣.៨០ ក.ណ.ក.ប ចុះថ្ងៃ ២៨-៦-១៩៨០ របស់ក្រុមប្រឹក្សារដ្ឋ រាជរដ្ឋាភិបាលបានការពារអត្តសញ្ញាណរបស់ពលរដ្ឋ ដូចជាឈ្មោះ ជនជាតិ សញ្ជាតិ ភេទ សាសនា ទំនាក់ទំនងគ្រួសារ ដោយរៀបចំឱ្យមានប័ណ្ណគ្រួសារដែលមានឈ្មោះ ភេទ ឆ្នាំកំណើត សញ្ជាតិ មុខរបរ ហើយប័ណ្ណនេះអាចយកទៅប្រើប្រាស់ជាផ្លូវការ ។

ការធ្វើប័ណ្ណគ្រួសារ មានជួបការលំបាកស្មុគស្មាញខ្លះនៅតាមតំបន់អសន្តិសុខ ដោយសារមានការផ្លាស់ប្ដូរទីកន្លែងរបស់គ្រួសារ និង ការបាក់បែកគ្រួសារ ។

**គ.** **<u>សេរីភាពក្នុងការបញ្ចេញយោបល់</u>** ( អនុសញ្ញាមាត្រា១៣ )

- **<u>បរិបទច្បាប់</u>**

**៩៣-** មាត្រា៤១ នៃរដ្ឋធម្មនុញ្ញបានចែងថា ប្រជាពលរដ្ឋខ្មែរមានសេរីភាពក្នុងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារពត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការប្រជុំ ។

**៩៤-** មាត្រា២៨ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល បានចែងពីសេរីភាពក្នុងការសំដែងមតិនយោបាយ ។

- **<u>ការអនុវត្ត</u>**

**៩៥-** កុមារកម្ពុជាមានសិទ្ធិសេរីភាពក្នុងការទទួលពត៌មានផ្សេងៗពីសំណាក់គ្រួសារ សង្គម សាលារៀន ប្រព័ន្ធឃោសនាតាមរយៈការប្រៀនប្រដៅណែនាំអប់រំផ្សេងៗ ក្នុងគោលបំណងឱ្យកុមារបានក្លាយទៅជាពលរដ្ឋល្អ ។ ជាមួយនឹងសិទ្ធិទទួលពត៌មាននេះកុមារកម្ពុជាក៏មានសិទ្ធិបញ្ចេញគំនិតយោបល់ របស់ខ្លួនតាមរយៈការសំដែងសិល្បៈ ផ្ទាំងគំនូរ ការប្រជុំជាដើម ។

**៩៦-** រាជរដ្ឋាភិបាលពុំមានវិធានការណាមួយហាមឃាត់កុមារ ក្នុងការប្រើប្រាស់សិទ្ធិរបស់ខ្លួនក្នុង ការបញ្ចេញយោបល់ទេ ប៉ុន្តែទន្ទឹមនឹងនេះសិទ្ធិទទួល និងផ្សព្វផ្សាយពត៌មានរបស់កុមារកម្ពុជា មិនទាន់ប្រព្រឹត្តទៅ ផុលផុសនៅឡើយទេដោយបណ្ដាលមកពី :

ក្នុងសង្គមកម្ពុជា តាមទម្លាប់ឪពុកម្ដាយ និងអាណាព្យាបាលតែងតែធ្វើការគៀបសង្កត់កូនចៅ របស់ខ្លួនក្នុងការនិយាយស្ដីបញ្ចេញមតិច្រើនដោយហេតុនេះហើយទើបបណ្ដាលឱ្យកុមារខ្វះសេចក្ដីក្លាហាន អាប់គំនិត ប្រាជ្ញា និងមានការរួញរាក្នុងការសំដែងគំនិតរបស់ខ្លួន ។

. ប្រជាពលរដ្ឋភាគច្រើនមានកំរិតជីវភាពទាប

. កង្វះខាតឯកសារសំរាប់ឱ្យកុមារបានធ្វើការសិក្សាស្រាវជ្រាវ និងបណ្ដុះគំនិតថ្មីទាន់សម័យ

. ការយល់ដឹងរបស់មាតាបិតាភាគច្រើនមានកំរិតទាប ជាពិសេសនៅតាមជនបទដាច់ស្រយាល

. ការអប់រំមិនសូវមានប្រសិទ្ធភាព

. បញ្ហាសន្តិសុខសង្គម និងការខ្វះខាតប្រព័ន្ធផ្សព្វផ្សាយនៅតាមតំបន់ដាច់ស្រយាល

៩៧- ការអនុវត្តរបបនយោបាយប្រជាធិបតេយ្យសេរីនៃរាជរដ្ឋាភិបាល គឺជាជំហានមួយឈានទៅរកការធានា និង ការពារសិទ្ធិពលរដ្ឋ ជាពិសេសសិទ្ធិកុមារក្នុងការបញ្ចេញយោបល់ ។

៩៨- យើងត្រូវការជំនួយបច្ចេកទេសពីអង្គការជាតិ និងអន្តរជាតិនានា ដើម្បីជួយកាត់បន្ថយកត្តាដែលមានចោទខាងលើ ។

៩៩- រាជរដ្ឋាភិបាល បានបង្កើតឱ្យមានកីឡាបាល់ទាត់ បាល់ទះ បាល់បោះ ។ល។ បង្កើតឱ្យមានក្រុមកាយរិទ្ធ កុមារស្ម័គ្រចិត្ត នៅតាមសាលារៀនមួយចំនួន និងបង្កើតឱ្យមានកម្មវិធីសំនួរចម្លើយសំរាប់កុមារា កុមារីនៅក្នុងទូរទស្សន៍ជាតិ។ នេះជាកត្តានាំឱ្យកុមារមានភាពក្លាហានរឹកដុះដាលផ្នែកគំនិតប្រាជ្ញា កុមារមានសេរីភាពងាយស្រួលក្នុងការបញ្ចេញយោបល់។

**ឃ. <u>ពត៌មានសមស្របដែលអាចទទួលបាន</u>** ( មាត្រា១៧ នៃអនុសញ្ញា )

. **<u>បរិបទច្បាប់</u>**

១០០- រដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣ ត្រង់មាត្រា៤១ បានចែងថា : " ប្រជាពលរដ្ឋខ្មែរមាន សេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារពត៌មាន សេរីភាពខាងការបោះពុម្ពផ្សាយ សេរីភាពខាងការប្រជុំ។

១០១- បច្ចុប្បន្ននៅព្រះរាជាណាចក្រកម្ពុជាពុំទាន់មានច្បាប់ដើម្បីការពារកុមារពីការទស្សនាខ្សែភាពយន្ត ឬវីដេអូដែលមានអំពើហឹង្សា ឬអាសអាភាសនៅឡើយទេ។

- ច្បាប់សារពត៌មាន បានហាមឃាត់មិនឱ្យផ្សាយអត្ថបទ ឬរូបភាពអាសអាភាស។ ក្រសួងពត៌មានចេញលិខិតណែនាំដល់គ្រប់បណ្ណាគារកាសែតមិនឱ្យផ្សាយអត្ថបទ និង រូបភាពអាសអាភាស ( លិខិតលេខ៦៦៦ / ៩៤ )

- ក្រសួងឃោសនាការ និងវប្បធម៌បានណែនាំដោយហាមមិនឱ្យបញ្ចាំងខ្សែភាពយន្ត វីដេអូរឿងអាសអាភាសនៅតាមរោងសាធារណៈ ។

. **<u>ការអនុវត្ត</u>**

១០២- ថ្វីត្បិតតែបណ្ដាញពត៌មានជាតិត្រូវខ្ទេចខ្ទាំដោយសារសង្គ្រាមក៏ដោយ ក៏ក្រោយថ្ងៃរំលំរបបកម្ពុជាប្រជាធិបតេយ្យមក ជាពិសេសក្រោយពេលបោះឆ្នោតបង្កើតសភាថ្មី និងរដ្ឋាភិបាលថ្មីដែលគាំទ្រឡើងដោយអង្គការសហប្រជាជាតិក្នុងឆ្នាំ១៩៩៣ មក រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដោយមានការជ្រោមជ្រែងពីអង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាលនានាបានរៀបចំតាមលទ្ធភាពរបស់ខ្លួននូវបណ្ដាញពត៌មានផ្សេងៗ សំរាប់ឱ្យកុមារបានទទួលដើម្បីជម្រុញឱ្យកុមារមានផាសុខភាពខាងផ្នែកស្មារតី និងសតិបញ្ញា។ តាមកម្មវិធីទូរទស្សន៍មានធ្វើការចាក់ផ្សាយគំនូរជីវចល សំរាប់ជាចំណីអារម្មណ៍ដល់កុមារ ហើយខ្លឹមសារនៃគំនូរជីវចល នេះមិនមែនត្រឹមតែឱ្យកុមារទស្សនាសប្បាយសើចប៉ុណ្ណោះទេតែជាវិធីម្យ៉ាងអប់រំកុមារឱ្យស្គាល់អ្វីដែលល្អអ្វីដែលអាក្រក់ បណ្ដុះចិត្តកុមារឱ្យចេះស្រឡាញ់រាប់អានគ្នាជួយគ្នាក្នុងគ្រាអាសន្ន ។ល។ ជាមួយគ្នានេះដែរ កម្មវិធីនាទីកុមារតាមទូរទស្សន៍កម្ពុជា ទូរទស្សន៍កងយោធពលខេមរៈភូមិន្ទ ទូរទស្សន៍ខ្មែរលេខ៩ បានបង្ហាញអំពីការចូលរួមរបស់កុមារក្នុងការបញ្ចេញមតិយោបល់តាមរយៈការនិទានរឿង តាមរយៈការឆ្លើយនឹងសំនួរ ។ល។

វិទ្យុជាតិកម្ពុជាក៏មានកម្មវិធី " នាទីកុមារ " របស់ខ្លួនដែរ។ តាមនាទីនេះ កុមារអាចស្តាប់រឿងរ៉ាវនានា ដែលទាក់ទងនឹងជីវភាព និងការអប់រំកុមារ ។

ក្រៅពីនេះការយល់ដឹងសង្គមអំពីជីវភាពសង្គម វប្បធម៌ទៅតាមសាលារៀនដែរ ដូចជាក្នុងមេរៀន ប្រវត្តិវិទ្យា សីលធម៌ បរិស្ថាន ។ល។

នៅតាមបណ្ណាល័យ តាមសាលារៀន និងក្នុងបណ្ណាល័យជាតិក៏មានឯកសារខ្លះៗ ដែលជារូបភាពរឿង និទានពីសង្គមជីវភាពក្នុងប្រទេស និងបរទេស។ រឿងនិទានភាគច្រើនជារឿងបកប្រែពីភាសារុស្ស៊ី ។

**១០៣-** មិនតែប៉ុណ្ណោះ អង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាលនានា ជាពិសេសអង្គការយូនីសេហ្វ បានចំណាយទុនជាច្រើនសំរាប់ផលិតសៀវភៅសំរាប់កុមារ ក្នុងនោះមួយផ្នែកធំជាសៀវភៅសិក្សា ។

**១០៤-** ជាមួយនឹងការប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ក្នុងលទ្ធភាពដ៏ស្តួចស្តើងរបស់ខ្លួននេះ ក៏គេសង្កេតឃើញនៅមានចំនុចខ្វះខាតជាច្រើន ដែលរដ្ឋាភិបាលនឹងខិតខំបំបាត់ជាបណ្តើរនូវចំណុចខ្សោយនេះ ។

ថ្វីត្បិតតែមានការផ្សាយ " នាទីកុមារ " ក្នុងកម្មវិធីទូរទស្សន៍ក្តី វិទ្យុជាតិក្តី ក៏ការផ្សាយនេះមិនបានជ្រួតជ្រាបដល់កុមារទាំងអស់ទូទាំងប្រទេសនៅឡើយ។ សារពត៌មានទាំងឡាយមិនទាន់ចាប់អារម្មណ៍ ឬមិនទាន់បានចំណាយ ទំព័រណាមួយរបស់ខ្លួនសំរាប់ឧទ្ទិសដល់កុមារដែរ។ ចំណែកឯសៀវភៅសំរាប់កុមារ ក្រៅពីសៀវភៅ សិក្សាក៏ចំនួនសៀវភៅសំរាប់កំសាន្ត ឬបណ្តុះគំនិតកុមារនៅមានកំរិតទាបនៅឡើយ ហើយការចែកចាយ ក៏មិនទាន់បានទូទាំងប្រទេសនៅឡើយ ។

ទន្ទឹមនេះទៀតដោយសារការខ្វះខាតការត្រួតពិនិត្យឱ្យបានល្អ កុមារមួយចំនួនបែរជាទទួលការលំហែពីការសែតវីដេអូអាសអាភាស ឬរឿងរ៉ាវដែលទាក់ទងនឹងការបាញ់ប្រហារ ឃាដកម្ម ដែលមិនសមស្របទៅតាមវ័យរបស់គេឡើយ។

ក្នុងការទទួលពត៌មាន កុមារដែលរស់នៅជនបទដាច់ស្រយាលមានការពិបាកដោយសាជីវភាពឪពុកម្តាយក្រតោកយ៉ាកពេកគ្មានលទ្ធភាពនឹងទិញវិទ្យុ ឬទូរទស្សន៍ស្តាប់ និងមើលបាន ។

**១០៥-** រាជរដ្ឋាភិបាលកំពុងធ្វើសកម្មភាពមួយជំហានៗ តាមរយៈក្រសួងអប់រំយុវជន និងកីឡា តែងជាសៀវភៅសិក្សា ឬផ្ទាំងរូបភាពផ្សេងៗតាមលទ្ធភាព ដើម្បីឱ្យកុមារខ្មែរទូទាំងប្រទេសបានទទួល ។

**ខ.** **<u>សេរីភាពផ្នែកគំនិត មនសិកា និងសាសនា</u>** ( អនុសញ្ញាមាត្រា១៤ )

**~** **<u>បរិបទច្បាប់</u>**

**១០៦-** <u>រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៣</u> :

មាត្រា៣១ : ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និងករណីយកិច្ចដូចគ្នាទាំងអស់ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ សាសនា ជំនឿសាសនា និន្នាការនយោបាយដើមកំណើត ឋានៈសង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ...។

មាត្រា៤៣ :ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានសិទ្ធិពេញទីខាងជំនឿ។ សេរីភាពខាងជំនឿ និងការប្រតិបត្តិខាងផ្លូវសាសនា ត្រូវបានរដ្ឋធានាក្នុងលក្ខខ័ណ្ឌដែលមិនប៉ះពាល់ដល់ជំនឿសាសនាដ៏ទៃទៀត ដល់សណ្តាប់ធ្នាប់ និងសន្តិសុខសាធារណៈ។ ព្រះពុទ្ធសាសនា ជាសាសនារបស់រដ្ឋ ។

**~** **<u>ការអនុវត្ត</u>**

**១០៧-** នៅព្រះរាជាណាចក្រកម្ពុជា គ្មានច្បាប់ណាមួយដែលបំបិទសិទ្ធិកុមារខាងផ្នែកគំនិត មនសិកា និងសាសនាឡើយ

ជាពិសេសក្រោយពេលដែលប្រទេសកម្ពុជាបានចុះហត្ថលេខាទទួលស្គាល់ និងសន្យាថាអនុវត្តឱ្យបានត្រឹមត្រូវតាមអនុសញ្ញាអន្តរជាតិ ស្តីអំពីសិទ្ធិកុមារក្នុងឆ្នាំ១៩៩២ កន្លងទៅនេះទេ ។

**១០៨-** ព្រះពុទ្ធសាសនា ជាសាសនារបស់រដ្ឋ។ នៅព្រះរាជាណាចក្រកម្ពុជា ប្រជាពលរដ្ឋខ្មែរចំនួន៩៧,៥% កាន់ព្រះពុទ្ធសាសនា វត្ត មានចំនួន៣,៣២៦ និង មានព្រះសង្ឃចំនួន៣៩,៣៨២ អង្គ ។

ក្រៅពីព្រះពុទ្ធសាសនា រាជរដ្ឋាភិបាលមិនហាមឃាត់ចំពោះសាសនាផ្សេងៗទេ ហើយសាសនាទាំងនោះមាន :

. សាសនាឥស្លាម មានវិហារ៣៣០កន្លែង មានបរិស័ទ២២១.៧៥៣នាក់

. សាសនាគ្រីស្ត មានវិហារកាតូលិក៩កន្លែង មានបរិស័ទជាង ១.៤០០នាក់

. សាសនាប្រូតេសតង់ មានវិហារ១១៥កន្លែង មានបរិស័ទ១៣.០១៨នាក់

. សាសនាកៅដាយ មានវិហារ១កន្លែង មានបរិស័ទ១០៦នាក់

. សាសនាចិនចំរុះ មានវិហារ៣២កន្លែង មានបរិស័ទ១២២.០០០នាក់

យើងមិនទាន់បញ្ចូលកម្មវិធីសិក្សាអំពីសាសនា នៅក្នុងសាលារៀននៅឡើយទេ ។

ក្នុងវត្តអារាមនានានៃព្រះរាជាណាចក្រកម្ពុជា មានកុមារមួយចំនួនស្ម័គ្រចិត្តបួសជាសង្ឃ ហើយបានទទួលការសិក្សានៅក្នុងវត្ត ។

**១០៩-** ជាមួយនឹងការប្រៀនប្រដៅឱ្យកុមារយល់ ស្គាល់ការខុសត្រូវក្នុងរង្វង់គ្រួសារឪពុកម្តាយ បានបញ្ជូនកូនចៅឱ្យទៅសិក្សានៅតាមសាលារៀន ដើម្បីក្រេបជញ្ជក់យកតម្រេះវិជ្ជា និងលត់ដំអត្តចរិកខ្លះ ឱ្យទៅជាពលរដ្ឋប្រកបដោយមនសិកាជាតិប្រកបដោយសុឆន្ទៈ និងប្រកបដោយទស្សនៈវែងឆ្ងាយ និង ភ្លឺស្វាង ។

**១១០-** ជាមួយគ្នានឹងមាតាបិតាដែលជាមេគ្រួសារ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា បាននឹងកំពុងលើកទឹកចិត្តកុមារកម្ពុជា ជាពិសេសកុមារជនជាតិភាគតិច ឱ្យរៀនសូត្រ និងគោរពទៅតាមជំនឿទំនាម ទំលាប់សាសនាខ្លួនដូចជាការអនុញ្ញាតដោយចំហក្នុងការបង្កើតសាលារៀនភាសាចិន អនុញ្ញាតឱ្យបើកវិហារឥស្លាម និងសាសនាដ៏ទៃទៀត ។

**១១១-** ក៏ប៉ុន្តែ ដោយយោលទៅតាមទំនាមទំលាប់ចាស់ពីបុរាណមក កុមារខ្មែរមិនទាន់មាន សិទ្ធិពេញលេញខាងផ្នែកគំនិតនៅឡើយទេ។ ឪពុកម្តាយភាគច្រើននៅតែប្រកាន់យកគំណែល " ក្មេងត្រូវតែគោរពចាស់ " និងគៀបគៀតកូនចៅមិនឱ្យបញ្ចេញគំនិត អ្វីដែលខុសនឹងគំនិតគាត់ឡើយ ទោះជាគំនិតនេះជឿនលឿនក៏ដោយ ។

ក្នុងករណីនេះរាជរដ្ឋាភិបាលនឹងខិតខំយ៉ាងណាពន្យល់អប់រំដល់មាតាបិតា អាណាព្យាបាលឱ្យបានយល់ច្បាស់ពីសិទ្ធិរបស់កុមារក្នុងការរិះគិតបញ្ចេញយោបល់ ។ល។

ចំពោះការផ្សព្វផ្សាយជំនឿសាសនាវិញ រាជរដ្ឋាភិបាលបន្តលើកទឹកចិត្តសកម្មភាពនេះបន្តទៀតក្នុងលក្ខខ័ណ្ឌមួយ គឺមិនយកអ្វីជាខែលដើម្បីបង្ខំឱ្យគេចូលជឿសាសនាមួយឡើយ ជាពិសេសការប្រកាន់សាសនា និងការបណ្តុះបង្អាប់សាសនាដ៏ទៃទៀត។

## ច~ <u>សេរីភាពក្នុងការបង្កើតសមាគម និងសេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធី</u> ( អនុសញ្ញាមាត្រា១៥ )

### ~ <u>បរិបទច្បាប់</u>

**១១២-** <u>រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា :</u>

មាត្រា៤១ : ប្រជាពលរដ្ឋខ្មែរមានសេរីភាពខាងការបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារពត៌មាន សេរីភាពខាងបោះពុម្ពផ្សាយ សេរីភាពខាងការប្រជុំ ។

មាត្រា៤២ : ប្រជាពលរដ្ឋខ្មែរមានសិទ្ធិបង្កើតសមាគមន៏ និងគណៈបក្សនយោបាយ...។

សេចក្ដីណែនាំលេខ៤៧៤ របស់ក្រសួងមហាផ្ទៃចុះថ្ងៃទី ២ កក្កដា ១៩៩៤ ស្ដីពីការបង្កើតសមាគមន៍ ។

~ **ការអនុវត្ត**

**១១៣-** សមាគម " កុមារ " មិនទាន់បានបង្កើតនៅឡើយទេ ឬមិនទាន់មាននរណាផ្ដួចផ្ដើមគំនិតបង្កើតអង្គការនេះ ក៏ប៉ុន្តែក្រសួងអប់រំយុវជន និងកីឡា បានបង្កើតបណ្ដាញគ្រប់គ្រងកុមារ ក្នុងគ្រប់ខេត្តទូទាំងប្រទេស ។ ក្រុមអភិបាលកុមារនេះមានភារកិច្ចចម្បងគឺ ផ្ដល់ការអប់រំ និងបណ្ដុះបណ្ដាលកុមារទាំងអស់ឱ្យក្លាយខ្លួនជាពលរដ្ឋល្អ ។

នៅតាមសាលារៀនមានចងក្រងជាក្រុមសិស្សតាមថ្នាក់នីមួយៗ ។ ក្រុមសិស្សានុសិស្សនេះ បង្កើតឡើងសំរាប់បំរើផលប្រយោជន៍សិស្ស សំរាប់សំរាល និងសំរួលទុក្ខធុរៈរបស់សិស្ស និងសំរាប់ធ្វើការទាក់ទងរវាងសិស្ស និងគ្រូ ។

**១១៤-** ប្រទេសកម្ពុជាក៏ដូចជាប្រទេសដ៏ទៃទៀតដែរ បានជ្រើសរើសថ្ងៃទី ១ មិថុនា ជាថ្ងៃបុណ្យទិវាកុមារ ។ ពេលនោះថ្វីត្បិតតែមានការរៀបចំឡើងដោយស្ថាប័នណាមួយក្ដី ក៏នៅតាមទីសាធារណៈគេឃើញកុមារមកជួបជុំគ្នាដើរដង្ហែរក្បួនដោយសន្តិវិធី ប្រកបដោយបដា ពាក្យស្លោក បង្ហាញអំពីអាទិភាពរបស់ខ្លួនក្នុងសង្គមដែរ ។

**១១៥-** ក៏ប៉ុន្តែដោយកុមារខ្មែរមានភាពពំនាក់អាស្រ័យច្រើនជាមួយគ្រួសារ អាណាព្យាបាល សាលារៀន ការរៀបចំចងក្រងក្រុមកុមារទៅតាមគំនិតផ្ដួចផ្ដើមផ្ទាល់របស់កុមារមិនទាន់មានឡើយ ។ ក្រុមកុមារទាំងអស់ ត្រូវរឋិតនៅក្រោមការគ្រប់គ្រង និងតម្រែតម្រង់របស់មនុស្សចាស់ទាំងអស់ ។ ម្យ៉ាងទៀតកុមារភាគច្រើនបំផុត ពុំទាន់យល់ដឹងអំពីសិទ្ធិរបស់ខ្លួនឡើយ ។

**ឆ~ ការការពារសិទ្ធិឯកជនរបស់កុមារ** ( អនុសញ្ញាមាត្រា១៦ )

~ **បរិបទច្បាប់**

**១១៦-** រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា :

មាត្រា៣៨ : ច្បាប់រ៉ាប់រងមិនឱ្យមានការរំលោភលើរូបរាងកាយបុគ្គលណាមួយឡើយ ។ ច្បាប់ការពារជីវិត កិត្តិយស និងសេចក្ដីថ្លៃថ្នូររបស់ប្រជាពលរដ្ឋ ។

មាត្រា៤០ : ...ការរក្សាសិទ្ធិមិនឱ្យរំលោភលើលំនៅឋាន និងអាថិកំបាំងនៃការឆ្លើយឆ្លងតាមលិខិត តាមសារទូរលេខ ទូរពុម្ព ទូរគមន៏ និងទូរស័ព្ទត្រូវបានធានា ។

ច្បាប់ព្រហ្មទណ្ឌក្នុងសម័យអន្តរកាល :

មាត្រា៦៣ : ការបរិហាកេរ្តិ៍ និងការជេរប្រមាថ

១- គ្រប់ការពោលអះអាង ឬគ្រប់ការទំលាក់កំហុសដោយអសុទ្ធចិត្តនូវអំពើកំណត់ណាមួយ ដែលប៉ះពាល់ ដល់កិត្តិយស ឬកេរ្តិ៍ឈ្មោះរបស់បុគ្គលឯកជន អំពើដែលនាំឱ្យកើតសៅហ្មងដល់ជននោះ គឺចាត់ជាការបរិហាកេរ្តិ៍ ។ ការផ្សាយដោយផ្ទាល់ ឬផ្សាយបន្តនូវការពោលអះអាងនោះ ឬការទំលាក់កំហុសនោះត្រូវមានទោស ទោះបីសំដៅទៅលើជនណាមួយដោយមិនចេញឈ្មោះជាក់លាក់ក៏ដោយ ប៉ុន្តែភិនភាគបានបញ្ជាក់ច្បាស់តាមន័យក្នុងសុន្ទរកថាតាមសម្រែក តាមការគំរាមកំហែងតាមការសរសេរ ឬតាមការបោះពុម្ពតាមផ្ទាំងបដា ឬប័ណ្ណប្រកាស តាមការផ្សាយសោតទស្សន ដែលជាប់ចោទ ។ គ្រប់ការពោលអះអាង ឬការទំលាក់កំហុសដែលអ្នកនិពន្ធ អ្នកសារពតិមាន អ្នកទទួលខុសត្រូវខាងការផ្សាយ អ្នកទទួលខុសត្រូវខាងបោះពុម្ពផ្សាយនាយកកម្មវិធីដែលដឹងថាមិនពិតហើយនៅតែផ្សាយ បោះពុម្ពផ្សាយ សរសេរ ឬផ្សព្វផ្សាយក្នុងបំណងបំផ្លាញបុគ្គលសាធារណៈណាមួយ អំពើដែលនាំឱ្យកើតសៅហ្មងដល់ជននោះ គឺជាបរិហាកេរ្តិ៍ ។

២- គ្រប់ពាក្យជេរប្រមាថធ្ងន់ៗ ពាក្យមើលងាយ ឬពាក្យជេរដែលគ្មានការទំលាក់កំហុសទៅលើអំពើណាមួយ គឺជាការជេរប្រមាថ ។

៣- ការបរិហារកេរ្តិ៍ ឬការជេរប្រមាថ ប្រព្រឹត្តឡើងតាមមធ្យោបាយណាមួយ ដែលមានចែងក្នុងមាត្រា៩៥ នឹងត្រូវផ្តន្ទាទោសដាក់គុកពី៨ថ្ងៃ ទៅ១ឆ្នាំហើយត្រូវពិន័យជាប្រាក់ពី១.000.000៛ ទៅ១0.000.000៛ ឬត្រូវផ្តន្ទាទោសមួយ នៃទោសទាំងពីរនេះក៏បាន ។

៤- ម្យ៉ាងទៀតក្នុងករណីដែលមានការផ្តន្ទាទោសអំពីអំពើណាមួយ ដែលមានចែងក្នុងកថាខ័ណ្ឌខាងលើ តុលាការអាចបញ្ជាឱ្យបិទផ្សាយសេចក្តីសំរេចរបស់ខ្លួន នៅទីកន្លែងទាំងឡាយដែលតុលាការនឹងបញ្ជាក់ដោយឱ្យជនជាប់ទោសទទួលបន្ទុកចេញសោហ៊ុយ ហើយតុលាការអាចចុះផ្សាយសាលក្រមនេះក្នុងសារពត៌មានមួយឬច្រើន ដោយឱ្យជនជាប់ទោសទទួលបន្ទុកចេញសោហ៊ុយរហូតដល់កំរិតច្រើនបំផុត១0.000.000៛។ បណ្តឹងអាជ្ញាដែល ទាក់ទងនឹងបទមជ្ឈឹមដែលមានចែងក្នុងមាត្រានេះ អាចធ្វើឡើងបានតាមរយៈគ្រប់សមាគមន៍ដែលតាំងឡើងតាមវិធាន ដែលកំណត់ដោយក្រុមប្រឹក្សាជាតិជាន់ខ្ពស់ដោយដាក់ពាក្យបណ្តឹងជាភាគីរដ្ឋប្បវេណីជូនរដ្ឋអាជ្ញាមានសមត្ថកិច្ច ។

៥- ក្នុងករណីណាក៏ដោយ និយោជក អ្នកបោះពុម្ព ក្រុមហ៊ុនបោះពុម្ពផ្សាយ ឬក្រុមហ៊ុនផ្សព្វផ្សាយត្រូវទទួលខុសត្រូវរួមក្នុងការសងជម្ងឺចិត្តផ្សេងៗ ដែលអាចនឹងត្រូវផ្តល់ឱ្យជនរងគ្រោះម្នាក់ ឬច្រើន នាក់ ។

មាត្រា៩៧ : អំពើរំលោភលើសិទ្ធិបុគ្គល

គ្រប់ភ្នាក់ងារសារធារណៈរួមទាំងភ្នាក់ងារនគរបាល និងយោធិនដែលរំលោភ ដោយមិនរួញរាទៅលើសិទ្ធិបូរណភាពបុគ្គល និងភាពមិនអាចរំលោភបាននៃលំនៅដ្ឋានដែលត្រូវបានការពារដោយបទ បញ្ញត្តិនេះនឹងត្រូវផ្តន្ទាទោសដាក់គុកពី១ឆ្នាំ ទៅ៥ឆ្នាំ ។

មាត្រា២0 : ការឆែកឆេរក្នុងផ្ទះ

១- ក្នុងករណីបទល្មើសជាក់ស្តែង នគរបាលអាចធ្វើការឆែកឆេរ ។

២- ការឆែកឆេរទាំងនេះ ត្រូវធ្វើនៅចំពោះមុខជនជាប់សង្ស័យ និងសាក្សី២នាក់ហើយអាចធ្វើបានសាក្សី គួរយកអ្នកនៅជិតខាង ឬអ្នកម្ចាស់ផ្ទះ ។

៣- បើមិនមែនជាបទល្មើសដែលទាក់ទងជាក់ស្តែងទេ ការរឹបអូសទាំងឡាយត្រូវមានសេចក្តីអនុញ្ញាតិពីចៅក្រមណាមួយនៃតុលាការពាក់ព័ន្ធ ឬពីរដ្ឋអាជ្ញា។ ការឆែកឆេរទាំងនេះអាចធ្វើបានតែក្នុងចន្លោះម៉ោង៦ព្រឹក ទៅម៉ោង៦ល្ងាច ហើយបើអាចធ្វើបានការឆែកឆេរទាំងនេះត្រូវធ្វើនៅចំពោះមុខជនជាប់សង្ស័យ និងចំពោះមុខសាក្សី២នាក់ ដែលជ្រើសយកពីក្នុងចំណោមសមាជិកគ្រួសារជនជាប់សង្ស័យ។ ភស្តុតាងទាំងឡាយណាដែលបានមកដោយរំលោភនឹងមាត្រានេះ មិនអាចយកជាការបានឡើយក្នុងពិធីកាត់សេចក្តី។

~ **ការអនុវត្ត**

**១១៧-** រដ្ឋាភិបាលតែងតែចាត់ទុកកុមារជា " ទំពាំងស្នងឬស្សី " ជាសសរទ្រូងនៃប្រទេសជាតិជា " ក្រុមស្រទាប់មនុស្សដែលមានអភ័យឯកសិទ្ធិ "។ ក្រៅពីផ្តល់សិទ្ធិដល់កុមារក្នុងការសិក្សាទាំងអស់គ្នា ក្រៅពីបង្កើតស្ថាប័នគាំពារមាតា និងទារកក្រៅពីការជួយផ្គត់ផ្គង់ដល់កុមារគ្មានទីពឹង រដ្ឋាភិបាលបានយកចិត្តទុកដាក់ការពារសិទ្ធិឯកជនស្របច្បាប់ដល់កុមារថែមទៀត ។

**១១៨-** ក៏ប៉ុន្តែទង្វើទាំងនេះមិនមែនមានន័យថា កុមារទាំងអស់ទូរទាំងប្រទេសទទួលគ្រប់គ្នានោះទេ។ នៅគ្រួសារខ្លះ នៅកន្លែងខ្លះ ជាពិសេសនៅតំបន់អសន្តិសុខ កុមារនៅតែទទួលការគម្រាមកំហែងដដែល។ កុមារភាគខ្លះត្រូវទទួលការជេរប្រមាថ ឬវាយ

ដំពីសំណាក់ឪពុកម្តាយពីគ្រូបង្រៀន ។ល ។ ហើយមកដល់ពេលនេះមិនទាន់មានច្បាប់ណាមួយដែលដាក់វិធានការតឹងរឹងដល់ការរំលោភលើរាងកាយរបស់កុមារនៅឡើយ ។

ម្យ៉ាងទៀតភាពអាស្រូវរបស់កុមារក៏ត្រូវប្រព័ន្ធការផ្សាយ " សារពត៌មាន " ខ្លះៗមិនទាន់លាក់បំបាំងនៅឡើយក៏ប៉ុន្តែមានសារពត៌មានខ្លះ បានគិតគូរដល់រឿងនេះ ដូចជាការបិទមុខក្នុងរូបថតដែលចុះក្នុងទំព័រកាសែត ។ល ។

**១១៩-** ក្នុងការពិនិត្យរោគរបស់កុមារក្រសួងសុខាភិបាល បានធ្វើការហាមដល់គ្រូពេទ្យមិនឱ្យផ្សព្វផ្សាយនូវអាថិកំបាំងនៃសភាពជម្ងឺដែលប៉ះពាល់ដល់អនាគតរបស់កុមារ ដល់អ្នកដទៃដឹងក្រៅពីអាណាព្យាបាលឡើយ ។

ក្នុងការជំនុំជំរះកាត់សេចក្តីរឿងរំលោភសេពសន្ថវៈលើកុមារ តុលាការបានបើកសវនាការជាសម្ងាត់នៅពេលសួរដេញដោល ឬស៊ើបអង្កេត ។

## ៥- <u>សិទ្ធិរួចពីទារុណកម្ម ឬអំពើឃោរឃៅ បន្ទាបបន្ថោក ឬដាក់ទណ្ឌកម្ម</u> ( អនុសញ្ញាមាត្រា៣៧ )

### - <u>បរិបទច្បាប់</u>

**១២០-** នៅរាជាណាចក្រកម្ពុជា ពុំបានចែងច្បាប់ស្តីពីការហាមប្រាមលើការវាយដំកូនចៅឡើយ ។

**១២១-** រាជាណាចក្រកម្ពុជា ជាភាគីហត្ថលេខីមួយ ដែលបានទទួលយកអនុសញ្ញាប្រឆាំងទារុណកម្ម ឬការប្រព្រឹត្តទាំងឡាយណា ដែលឃោរឃៅអមនុស្សធម៌ ឬដែលនាំឱ្យបាត់បង់តម្លៃជាមនុស្ស ។

**១២២-** <u>រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា</u> :

មាត្រា៣២ : ជនគ្រប់រូបមានសិទ្ធិរស់រានមានជីវិត មានសេរីភាព និងមានសន្តិសុខផ្ទាល់ខ្លួន ។

មាត្រា៣៨ : " ជនជាប់ចោទណាក៏ដោយត្រូវទុកជាមនុស្សឥតទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ " ។

មាត្រា៤៨ : រដ្ឋធានារក្សាការពារសិទ្ធិរបស់កុមារ ដែលមានចែងក្នុងអនុសញ្ញាស្តីពីកុមារ ជាពិសេសសិទ្ធិមានជីវិតរស់នៅសិទ្ធិទទួលការអប់រំរៀនសូត្រ សិទ្ធិត្រូវទទួលបានការគាំពារក្នុងស្ថានការណ៍មានសង្គ្រាម និងការការពារប្រឆាំងនឹងអាជីវកម្មសេដ្ឋកិច្ច ឬកាមគុណលើកុមារ ។

រដ្ឋគាំពារប្រឆាំងនឹងការងារទាំងឡាយដែលអាចធ្វើឱ្យខូចដល់ការអប់រំ និងការរៀនសូត្ររបស់កុមារ ឬដែលនាំឱ្យអន្តរាយដល់សុខភាព ឬសុខុមាលភាពរបស់កុមារ ។

**១២៣-** <u>ច្បាប់ព្រហ្មទណ្ឌសម័យអន្តរកាល</u> :

មាត្រា១២ : ការគ្រប់គ្រងជនជាប់ឃុំ

១- គ្មានជនជាប់ឃុំណាម្នាក់ត្រូវទទួលទណ្ឌកម្ម ឬការប្រព្រឹត្តទាំងឡាយណាដែលឃោរឃៅ អមនុស្សធម៌ ឬនាំឱ្យបាត់បង់តម្លៃជាមនុស្ស ឬក៏ត្រូវគេវាយដំ និងធ្វើទារុណកម្មឡើយ ។ ជនជាប់ឃុំម្នាក់ៗ ត្រូវបានទទួលការថែទាំតាមវិធីពេទ្យត្រឹមត្រូវ ។ អ្នកទោសទាំងឡាយមិនត្រូវបានគេចង ឬដាក់ឱ្យនៅឯកោម្នាក់ឯង ទោះស្ថិតក្នុងការឃុំខ្លួន បណ្តោះអាសន្នក្តី ឬត្រូវបានកាត់ទោសរួចហើយក្តី ។ ទោះក្នុងករណីណាក៏ដោយ គ្រួសារអ្នកជាប់ឃុំ ឬគ្រួសារអ្នកទោស មិនត្រូវមានគេយាយីដោយសារតែការប្រព្រឹត្តរបស់ជននោះឡើយ ។

២- ការចាប់ខ្លួន និងការឃុំខ្លួន ត្រូវតែគោរពតាមបទដ្ឋានអប្បបរមានៃបទវិន័យ សំរាប់គ្រប់គ្រងអ្នកជាប់ឃុំ ព្រមទាំងត្រូវគោរពតាមគោលការណ៍ជាមូលដ្ឋានសំរាប់ការពារអ្នកទោស ដែលអង្គការសហប្រជាជាតិបានអនុម័ត ។

មាត្រា១៣ : ការចាប់ខ្លួន និងការឃុំខ្លួន

១- គ្មានជនណាម្នាក់ ត្រូវបានគេឃុំខ្លួនលើសពី៤៨ម៉ោង ដោយមិនបានបញ្ជូនទៅចៅក្រម តាមរយៈបណ្តឹងរបស់រដ្ឋអាជ្ញាឡើយ ។ ក្នុងករណីណាដែលពុំអាចគោរពតាមថេរៈវេលានេះបាន ដោយសារស្ថានភាពនៃការដឹកជញ្ជូនក្នុងតំបន់នីមួយៗ នោះគេអាចបន្ថែមបាននៅពេលវេលាចាំបាច់ សំរាប់តែដឹកនាំអ្នកជាប់ឃុំឃាំងនេះ ទៅជូនចៅក្រម តាមមធ្យោបាយយ៉ាងឆាប់ដែលអាចធ្វើបាន ។

២- រដ្ឋអាជ្ញាសុំឱ្យចៅក្រមចោទប្រកាន់ ព្រមទាំងជាយថាហេតុឃុំខ្លួនជនជាប់សង្ស័យក្រោយពីបានពិនិត្យសំនុំរឿងពីនគរបាល ដោយរៀបរៀងដីកាសន្និដ្ឋានមួយទុកជាសេចក្តីផ្តើមចោទ យោងតាមអង្គហេតុជាក់ស្តែង និងដែលកំណត់បទល្មើសតាមច្បាប់ឱ្យស្របទៅតាមបទបញ្ញត្តិព្រហ្មទណ្ឌនេះ ។

៣- ក្នុងខណៈនោះដោយផ្អែកលើសេចក្តីសំរេចដែលមានចែងមូលហេតុ ចៅក្រមអាចសំរេចថា :

- ត្រូវចោទប្រកាន់ជនជាប់សង្ស័យដោយឱ្យឃុំឃាំង ឬមិនឱ្យឃុំឃាំង
- ឱ្យដោះលែងជនជាប់សង្ស័យ ដោយចាត់ទុកថាភ័ស្តុតាងនៃពិរុទ្ធភាពមិនគ្រប់គ្រាន់
- សំរេចឱ្យបន្តការស៊ើបអង្កេត ដោយមិនប្រាប់ឈ្មោះជនជាប់សង្ស័យ ។

៤- ក្នុងរយៈពេលយ៉ាងច្រើន៤៨ម៉ោងដូចគ្នានេះ ក្រោយការចាប់ខ្លួនហើយ ជាយថាហេតុត្រូវបានពន្យាថេរៈវេលាចាំបាច់ក្នុងការដឹកនាំដូចបានចែងនៅវគ្គទី១ ទីប្រឹក្សាត្រូវបានទទួលសំនុំរឿង ដែលទាក់ទងក្នុងការចោទប្រកាន់ចំពោះជនជាប់សង្ស័យ ។

មាត្រា៣១ : ឃាដកម្មគិតទុកជាមុន

១- ជនណាដែលសម្លាប់ ឬ ប៉ុនប៉ងសម្លាប់ជនណាម្នាក់ទៀត ក្រោយពីបានគិតទុកជាមុននូវបទឧក្រិដ្ឋរបស់ខ្លួន ឬដោយបានរៀបចំការពួនស្ទាក់ ឬដែលបានសម្លាប់ ឬប៉ុនប៉ងសម្លាប់ជនណាម្នាក់ទៀត ក្នុងពេលដែលខ្លួនប្រព្រឹត្តចោរកម្ម ឬរំលោភសេពសន្ថវៈ ត្រូវជាប់ទោសពីបទឧក្រិដ្ឋធ្វើមនុស្សឃាដទុកជាមុន ហើយត្រូវផ្តន្ទាទោសដាក់គុកជាបទឧក្រិដ្ឋ ពី១០ ទៅ២០ឆ្នាំ ។

២- ការគិតទុកជាមុន គឺគម្រោងធ្វើឡើងមុនអំពើបៀតបៀនទៅលើរូបបុគ្គលណាមួយ ។ ការពួនស្ទាក់គឺការឃ្លាំចាំបុគ្គលណាម្នាក់ក្នុងរយៈពេលមួយដើម្បីប្រព្រឹត្តហឹង្សាទៅលើបុគ្គលនោះ ។

មាត្រា៤១ : អំពើបង្ករបួសដោយចេតនា :

ជនណាវាយតប់បណ្តាលឱ្យមានរបួស ដែលនាំឱ្យពិការជាអចិន្ត្រៃយ៍ ឬពិការបណ្តោះអាសន្នក្នុងរយៈពេល លើសពី ៦ខែ ដោយចេតនាត្រូវមានទោសពីបទបង្ករបួសដោយចេតនាហើយត្រូវផ្តន្ទាទោសដាក់គុកពី១ឆ្នាំ ទៅ៥ឆ្នាំ ។

- បើពិការភាពបណ្តោះអាសន្ននោះតិចជាង៦ខែ នោះត្រូវកំណត់ផ្តន្ទាទោសដាក់គុកជននោះ គឺ ពី៦ខែ ដល់ ២ឆ្នាំ ។
- បើគ្មានពិការភាពទេ ទោសដែលត្រូវកំណត់ផ្តន្ទា គឺដាក់គុក គឺពី២ខែ ដល់១ឆ្នាំ ។
- បើការវាយតប់នោះធ្វើឡើងដោយប្រើអាវុធប្រភេទណាមួយ ក៏រិតទោសត្រូវទ្វេមួយជាពីរ ។

ទោសប្រហារជីវិតត្រូវបានលុបចោលនៅប្រទេសកម្ពុជា ( មាត្រា៦៧ ច្បាប់ព្រហ្មទណ្ឌអន្តរកាល )

មាត្រា៦៨ : ស្ថានសំរាលទោស និងគ្រាប្រណីចំពោះអនីតិភាព :

១- ចៅក្រមទាំងឡាយត្រូវគិតដល់ស្ថានសំរាលទោស ដើម្បីបញ្ចុះទោសរហូតដល់ក្រោមអប្បបរមានៃទោសដែលមានចែងនៅក្នុងបទបញ្ញត្តិនេះ ហើយជាអាទិភាពគឺ :

. យុវភាពនៃអ្នកជាប់ទោស

. ប្រវត្តិរូបផ្ទាល់នៃអ្នកជាប់ទោស ដែលមានលក្ខណៈអាចឱ្យបន្ថយភាពទទួលខុសត្រូវរបស់ខ្លួន

. ស្ថានភាពចិត្តសាស្ត្រ ឬសរសៃប្រសាទនៃអ្នកត្រូវចោទ ដោយមានសញ្ញាប័ត្របញ្ជាក់ពីគ្រូពេទ្យខាងចិត្តសាស្ត្រ

. កាលៈទេសៈនៃអំពើឧក្រិដ្ឋ ឬមជ្ឈឹមដែលបណ្តាលឱ្យអ្នកជាប់ទោសមានប្រតិកម្មដោយខានពុំបាន ។

២- ចំពោះជនជាប់ចោទដែលមានអាយុតិចជាង១៨ឆ្នាំ ទណ្ឌកម្មដែលមានក្នុងបណ្តាមាត្រាមុនៗ ត្រូវកាត់បន្ថយពាក់កណ្តាល នេះដោយមិនគិតដល់លក្ខន្តិកៈអនុគ្រោះផ្សេងៗលើសពីនេះទៀត ដែលមាននៅក្នុងបទដ្ឋានកំណត់ដោយរចនាសម្ព័ន្ធរដ្ឋបាលដែលមានសព្វថ្ងៃ ។

**១២៤-** ច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ :

មាត្រា១១៦: ចែងថា ឪពុកម្តាយមិនត្រូវធ្វើបាបកូនរបស់ខ្លួន កូនប្រសា កូនចិញ្ចឹម ឬកូនរបស់ប្តី ឬ ប្រពន្ធមុនឡើយ ។

~ **ការអនុវត្ត**

**១២៥-** រដ្ឋាភិបាលព្រះរាជាណាចក្រកម្ពុជាប្រឆាំងដាច់ខាត លើការធ្វើទុក្ខបុកម្នេញលើរូបរាងកាយបុគ្គល ជាពិសេសទៅលើកុមារ ។ ចំពោះគ្រូបង្រៀនក៏ត្រូវហាមឃាត់មិនឱ្យវាយកុមារផងដែរ ។

**១២៦-** ក៏ប៉ុន្តែ នៅមានចំនុចខ្លះមិនទាន់បានធានាសុវត្ថិភាពដល់កុមារនៅឡើយ ជាពិសេសតំបន់អសន្តិសុខ និងនៅតាមគ្រួសារខ្លះ (ការធ្វើទុក្ខទោសកុមារក្នុងន័យប្រៀនប្រដៅ) ។ នៅកន្លែងទទួលកុមារទណ្ឌិតមានការបង្អែរបង្អង់មិនព្រមបញ្ជូនសំណុំរឿងឱ្យតុលាការសំរេចបានរួសរាន់ ។

**១២៧-** ក្រសួងយុត្តិធម៌នឹងរៀបចំឱ្យបានយ៉ាងឆាប់ជាមួយក្រសួងពាក់ព័ន្ធ ដើម្បីដោះស្រាយបញ្ហាដែលទាក់ទងទៅនឹងតុលាការកុមារ និងមជ្ឈមណ្ឌលសំរាប់អប់រំកុមារទណ្ឌិត ឱ្យមានវិជ្ជាជីវៈផ្សេងៗ ហើយមានអនាគតល្អ ។

*

*   *

## V. បរិយាកាសគ្រួសារ និងកិច្ចថែទាំផ្សេងៗទៀត

**១២៨-** សង្គ្រាមបានធ្វើឱ្យរចនាសម្ព័ន្ធសង្គមកម្ពុជាបែកបាក់ខ្ទេចខ្ទាំ និងទន់ខ្សោយ អ្នកដែលទទួលគ្រោះមហន្តរាយនេះធ្ងន់ជាងគេគឺស្ត្រី និងកុមារ ។

**ក~ ការណែនាំចំពោះមាតាបិតា** (អនុសញ្ញាមាត្រា៥)

~ **បរិបទច្បាប់**

**១២៩-** រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា :

មាត្រា៤៧ : មាតាបិតា មានភារៈកិច្ចចិញ្ចឹមថែរក្សា និងអប់រំកូនឱ្យក្លាយទៅជាពលរដ្ឋល្អ ។

~ **ការអនុវត្ត**

**១៣០-** តាមប្រពៃណីទំនៀមទំលាប់ និងព្រះពុទ្ធសាសនា មាតាបិតា គឺជាអ្នកចិញ្ចឹមថែរក្សា និងអប់រំបណ្តុះបណ្តាលកូន កសាងអនាគតឱ្យកូន ហើយរក្សាកិត្តិយសវង្សត្រកូលទុកឱ្យកូនទៀតផង ។ ភារៈកិច្ចនេះត្រូវធ្វើដោយមេត្តាករុណា និងព្រហ្មវិហារធម៌ ។

**១៣១-** ប្រជាពលរដ្ឋកម្ពុជាបានខិតខំធ្វើខ្លួនជាមាតាបិតាល្អ ទៅតាមសមត្ថភាព លទ្ធភាពធនធានដែលខ្លួនគេមាន ប៉ុន្តែតាមការប៉ាន់ប្រមាណរបស់អង្គការយូនីសេហ្វនៅក្នុងឆ្នាំ១៩៩៤ កុមារប្រហែល២សែននាក់កំពុងតែស្ថិតនៅក្នុងភាពទន់ខ្សោយងាយនឹង

រងគ្រោះ ដោយគ្រួសារពុំមានលទ្ធភាពក្នុងការចិញ្ចឹមថែទាំអប់រំឱ្យបានសមស្រប ព្រោះខ្លះជាកុមារក្នុងគ្រួសារមានជីវភាពក្រីក្រលំបាក និងខ្វះចំណេះដឹង។ កត្តានេះហើយធ្វើឱ្យគ្រួសារមួយចំនួនខ្វះការទទួលខុសត្រូវលើកូន ដូចជាការចេញទៅប្រកបការងាររបស់គ្រួសារខ្លះទាំងប្តីប្រពន្ធ ទុកចោលឱ្យកូនរស់នៅជាមួយជីដូនចាស់ ឬផ្ញើទុកជាមួយអ្នកជិតខាង។ គ្រួសារខ្លះទៀតបានទុកកូនច្បងឱ្យនៅជួយថែរក្សាប្អូន ឬជួយប្រកបរបររកស៊ី។ ម្យ៉ាងទៀតស្ត្រីជាមេគ្រួសារចំនួន២០% (ឯកសារក្រសួងផែនការ ឆ្នាំ១៩៩៥) ហើយ១/២៣៧ នៃប្រជាពលរដ្ឋខ្មែរទាំងមូលជាជនពិការ បញ្ហាទាំងនេះជាបន្ទុកមួយធ្ងន់ថែមទៀតដល់កុមារ។ ដោយសារមានអសន្តិសុខក្នុងតំបន់ខ្លះ មានប្រជាជនផ្លាស់ប្តូរទីលំនៅជាញឹកញាប់ ម្ល៉ោះហើយការថែទាំបីបាច់កុមារធ្វើមិនបានជិតដល់ និងសមស្របឡើយ។

## ខ~ **<u>ការទទួលខុសត្រូវរបស់មាតាបិតា</u>** ( អនុសញ្ញាមាត្រា១៨ )

### ~ **<u>បរិបទច្បាប់</u>**

**១៣២-** <u>រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា</u> :

មាត្រា៤៧ : មាតាបិតាមានកាតព្វកិច្ចថែរក្សា និងអប់រំកូនឱ្យទៅជាពលរដ្ឋល្អ ។

មាត្រា៧៣ : រដ្ឋយកចិត្តទុកដាក់ឱ្យមានទារកដ្ឋាន និងឧបត្ថម្ភនារីដែលមានកូនច្រើន ហើយឥតទីពឹង ។

**១៣៣-** <u>ច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ</u> :

មាត្រា១១៥ : ចែងពីការទទួលខុសត្រូវ និងពីការស្រឡាញ់របស់មាតាបិតាស្មើគ្នាចំពោះកូន ចិញ្ចឹមរក្សាអប់រំកូនឱ្យមានសីលធម៌ល្អ ស្រឡាញ់ការរៀនសូត្រ ស្រឡាញ់មាតុភូមិ និងពលកម្ម...។

មាត្រា១០៤-១០៥ : ចែងពីកូនឥតខាន់ស្លាដែលត្រូវបានទទួលស្គាល់ មានករណីកិច្ច និងសិទ្ធិដូចគ្នានឹងកូនមានខាន់ស្លាដែរ ។ ឪពុក ឬម្តាយត្រូវផ្តល់អាហារកិច្ចឱ្យកូននោះ ឬយកកូននោះទៅចិញ្ចឹមបីបាច់រក្សា ។

មាត្រា១១៤ : បានផ្តល់សិទ្ធិ និងកាតព្វកិច្ចដល់កូនចិញ្ចឹមដូចកូនមានខាន់ស្លាដែរ។

មាត្រា៦៨ ចែងថា : " ប្តីអាចសុំលែងប្រពន្ធដែលមានផ្ទៃពោះបាន លុះត្រាតែកូនកើតបានមួយឆ្នាំសិន "

មាត្រា៧២-៧៥ : ស្តីពីការផ្គត់ផ្គង់ថែរក្សា ការប្រាស្រ័យទាក់ទងជាមួយកូន នៅពេលម្តាយឪពុកលែងលះគ្នា។

**១៣៤-** <u>ច្បាប់ការងារ</u> :

មាត្រា១៦៥ : ចែងអំពីការឈប់សម្រាករបស់ម្តាយ ក្នុងពេលសម្រាលកូន។

មាត្រា១៧៧ : គ្មានក្មេងណាម្នាក់អាយុតិចជាង១៨ឆ្នាំ ភេទណាក៏ដោយ ដែលមិនទាន់ផុតពីការគ្រប់គ្រងរបស់ឪពុកម្តាយ ឬអាណាព្យាបាល អាចចុះកិច្ចសន្យាការងារដោយគ្មានការយល់ព្រមអំពីជនដែលខ្លួននៅក្រោមការគ្រប់គ្រងនោះទេ។

មាត្រា១៧៨-១៨៣ : ម្តាយមានសិទ្ធិបំបៅកូនក្នុងពេលម៉ោងធ្វើការ។ សហគ្រាសត្រូវបង្កើតទារកដ្ឋាន។

### ~ **<u>ការអនុវត្ត</u>**

**១៣៥-** ស្ត្រីជាបុគ្គលិករដ្ឋ និងបុគ្គលិកឯកជន មានសិទ្ធិឈប់សម្រាកលំហែមាតុភាពរយៈពេល៣ខែ ដោយមានប្រាក់បៀវត្សរ៍ និងសិទ្ធិចេញបំបៅកូនក្នុងម៉ោងធ្វើការ និងបានទទួលប្រាក់ឧបត្ថម្ភធានារ៉ាប់រងសង្គម ក្នុងពេលឆ្លងទន្លេថែមទៀត។ កុមារកំព្រាដែលជាកូនមន្ត្រីរាជការដែលទទួលមរណភាព ត្រូវបានរដ្ឋឧបត្ថម្ភថវិកាប្រចាំខែ។

**១៣៦-** ដើម្បីជួយដល់កុមារក្រីក្រ រដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល បានបង្កលក្ខណៈឱ្យគ្រួសារមួយចំនួនអាចមានមធ្យោបាយរកចំណូលផ្គត់ផ្គង់គ្រួសារដោយខ្លួនឯង ដូចជាកម្មវិធី ផ.ស.គ ជាដើម។ អង្គការខ្លះបានជួយដល់កុមារក្រីក្រដោយ

ធ្វើកម្មវិធីកូនធម៌ ឬធ្វើការបណ្តុះបណ្តាលវិជ្ជាជីវៈដល់ពួកគេ ។

**១៣៧-** មានរៀបចំកម្មវិធីផ្សព្វផ្សាយឱ្យមាតាបិតាយល់អំពីការថែទាំ និងការពារផលប្រយោជន៍កុមារ ដែលបានធ្វើឡើងតាមប្រព័ន្ធផ្សព្វផ្សាយដូចជា វិទ្យុ ទូរទស្សន៍ សៀវភៅ ។ល។ ប៉ុន្តែកំរិតនៃការយល់ដឹងរបស់ប្រជាជនអំពីសិទ្ធិរបស់កុមារនៅមិនទាន់ស៊ីជម្រៅ និងទូលំទូលាយនៅឡើយ ។ ដូច្នេះត្រូវតែបន្តធ្វើការឃោសនា អប់រំរៀនសូត្រតាមសហគមន៍ ឱ្យបានជ្រួតជ្រាប ។

**១៣៨-** ក្រសួងសុខាភិបាលបានធ្វើសេចក្តីព្រាងគោលនយោបាយពន្យាកំណើត ក្នុងគោលបំណងបន្ថយអត្រាស្លាប់របស់ មាតា និងទារកក្នុងព្រះរាជាណាចក្រកម្ពុជា និងលើកកំពស់គុណភាពជីវភាពគ្រួសារ ។ ផែនការនេះអាចបន្ថយអត្រាកំណើតឱ្យនៅតិចជាង២,៨% ។

**១៣៩-** ការខ្វះសេវាកម្មសង្គមដើម្បីជួយដល់កុមារក្នុងគ្រួសារក្រីក្រ កុមារពិការបានត្រូវរដ្ឋាភិបាល និងអង្គការពាក់ព័ន្ធ យកចិត្តទុកដាក់យ៉ាងខ្លាំង ។ ក្រសួងពាក់ព័ន្ធសំខាន់ៗកំពុងធ្វើផែនការរយៈពេលខ្លី (សំរាប់ឆ្នាំ ៩៥)និងរយៈពេលវែង (១៩៩៦-២000) ដើម្បីជម្រុញកិច្ចការទាំងនេះឱ្យបានសម្រេច ។

**គ.** **ការបំបែកពីមាតាបិតា** (អនុសញ្ញាមាត្រា៩)

**- បរិបទច្បាប់**

**១៤០-** ច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ :

មាត្រា២៧ : អំពីករណីដែលឪពុកម្តាយលែងលះគ្នា កូននៅជាកូនមានខាន់ស្លា សិទ្ធិ និងកាតព្វកិច្ចរបស់ឪពុកម្តាយ និងកូន នៅមានដដែល ។

មាត្រា៧២-៧៣ : សាលក្រមលែងលះគ្នាត្រូវសម្រេចអំពីអំណាចមេបា ដែលត្រូវប្រគល់ឱ្យទៅឪពុក ឬម្តាយ និងត្រូវសម្រេចពីការប្រាស្រ័យទាក់ទងរវាងឪពុកម្តាយនឹងកូននោះ ។ ការឱ្យទៅភាគីណាមួយរក្សាកូន ត្រូវសម្រេចតាមការយល់ព្រមនៃប្តីប្រពន្ធលែងលះគ្នាដើម្បីជាផលប្រយោជន៍របស់កូន ។ កូននៅបៅដោះត្រូវឱ្យទៅម្តាយ ។ បើមិនឯកភាពគ្នាទេតុលាការជាអ្នកសម្រេច ។

មាត្រា៧៥ : ភាគីដែលមិនបានរក្សាកូន មានសិទ្ធិសួរសុខទុក្ខកូន ។ សិទ្ធិរក្សាកូនអាចដកបើមានការប៉ះពាល់ដល់ផលប្រយោជន៍របស់កូន ។

មាត្រា១១៩ : ចែងអំពីអំណាចមេបា អាចដកទៅឱ្យអង្គការ ឬញាតិលោហិតណាមួយ ចំពោះឪពុកម្តាយដែលខ្វះខាតក្នុងការអប់រំកូន ប្រើអំណាចបង្ខំឱ្យកូនប្រព្រឹត្តបទល្មើសដែលប៉ះពាល់ដល់សង្គមវាយធ្វើបាបឥតប្រណី និងឪពុកម្តាយដែលប្រព្រឹត្តផ្ទុយពីសីលធម៌ បណ្តាលឱ្យមានឥទ្ធិពលអាក្រក់ដល់កូន ។

**១៤១-** លិខិតណែនាំរបស់ក្រសួងយុត្តិធម៌លេខ ៤៧៦ រប.៩៣ ចុះថ្ងៃ ០៩-០៩-៩៤ ស្តីពីការឱ្យដកកុមារចេញពីពន្ធនាគារយកទៅដាក់ទារកដ្ឋាន ។

**- ការអនុវត្ត**

**១៤២-** ការលែងលះប្តីប្រពន្ធនៅទីក្រុងមានច្រើនជាងនៅតាមបណ្តាខេត្ត ។ ក្នុងឆ្នាំ១៩៩៤ នៅទីក្រុងភ្នំពេញមាន ៧៩២ករណីត្រូវបានតុលាការសម្រេចរួចហើយ ហើយមាន ២៩៣២ករណីទៀតដែលមិនទាន់សំរេច ។ ផ្ទុយទៅវិញ នៅក្នុង៨ខេត្តមានតែ ១០៦ករណីប៉ុណ្ណោះ (តួលេខពីក្រសួងយុត្តិធម៌) ។ មានករណីជាច្រើនទៀតដែលគូវិវាទពុំបានប្តឹងដល់តុលាការ ។

**១៤៣-** តាមទំលាប់នៅពេលឪពុកម្តាយលែងលះគ្នា កុមាររស់នៅជាមួយម្តាយច្រើនជាងឪពុក ហើយពេលខ្លះម្តាយមិនអនុញ្ញាតឱ្យឪពុកជួបប្រាស្រ័យទាក់ទងជាមួយកូនឡើយ។ ក្នុងករណីដែលឪពុក ឬម្តាយលែងលះ ហើយរៀបការជាថ្មី ជីដូនជីតាជាអ្នកដើរតួសំខាន់ក្នុងការគ្រប់គ្រង ឬចិញ្ចឹមបីបាច់កុមារ។ មុនពេលសម្រេចសេចក្តីបែងចែកកូនឱ្យទៅនៅជាមួយឪពុក ឬម្តាយ ចៅក្រមតែងសួរចិត្តកូនថា តើចង់នៅជាមួយឪពុក ឬម្តាយ។ ទោះបីយ៉ាងនេះក៏ដោយ ចៅក្រមសម្រេចបែងចែកកូនដោយឈរលើមូលដ្ឋានគិតពីផលប្រយោជន៍របស់កូនដែរ ។

**១៤៤-** ការបំបែកកុមារ ដែលទទួលការធ្វើទុក្ខបុកម្នេញចេញពីគ្រួសារ នៅពុំទាន់អនុវត្តបាននៅឡើយ ដោយស្ថាប័នមានសមត្ថកិច្ចពុំទាន់ទទួលបានគោលការណ៍ណែនាំ ឬនីតិវិធីច្បាស់លាស់។

**១៤៥-** សព្វថ្ងៃនៅមានកុមាររស់នៅក្នុងពន្ធនាគារជាមួយម្តាយដែលជាពិរុទ្ធជន ព្រោះគាត់មិនចង់ឱ្យកូនឃ្លាតចេញពីខ្លួន។ ក្រសួងសង្គមកិច្ចកំពុងធ្វើគោលការណ៍ណែនាំ ដើម្បីផ្តល់សេវាកម្មសមស្រប និងមានប្រសិទ្ធភាពដើម្បីបំរើផលប្រយោជន៍របស់កុមារ ដូចជាការពិគ្រោះយោបល់ ការឧបត្ថម្ភដល់កុមារ ការជួយឱ្យកុមារបានមកសួរសុខទុក្ខម្តាយ ។ល។

សារាចរចុះថ្ងៃទី២២ ឧសភា ១៩៩៥ ស្តីពីការជូនដំណឹងដល់ស្ត្រីជាពិរុទ្ធជន និងទណ្ឌិតជាប់នៅពន្ធនាគារ ដែលមានកូន កំណត់ថា អធិការដ្ឋានសង្គមកិច្ចត្រូវតែទំនាក់ទំនងផ្ទាល់ជាមួយអាជ្ញាធរពន្ធនាគារ ហើយសហការជាមួយស្ត្រីទាំងនោះ ដើម្បីយកក្មេងដែលមានអាយុលើសពី ៦ខែ ចេញពីពន្ធនាគារ។ ម្តាយត្រូវតែអនុញ្ញាតឱ្យក្មេងបានផ្ទេរចេញទៅនៅកន្លែងផ្សេងតាមការយល់ព្រមរបស់អាជ្ញាធរពន្ធនាគារ។ ភ្នាក់ងារសង្គមកិច្ចត្រូវធ្វើការពិនិត្យម្តាយរបស់ក្មេងឱ្យបានទៀងទាត់ ឬនាំក្មេងឱ្យទៅជួបម្តាយរបស់គេតាមបទបញ្ជាផ្ទៃក្នុងរបស់ពន្ធនាគារ។

## ឃ. <u>ការជួបជុំគ្រួសារវិញ</u> (អនុសញ្ញាមាត្រា១០)

### - <u>បរិបទច្បាប់</u>

**១៤៦-** ច្បាប់អន្តោប្រវេសន៍បានត្រូវអនុម័តរួចហើយ ប៉ុន្តែពុំទាន់មានការអនុវត្ត ម្យ៉ាងទៀតពុំទាន់មានច្បាប់ចែងពីការធានាជួយកុមារឱ្យជួបជុំគ្រួសារនៅក្រៅប្រទេស ដែលធ្វើឡើងដោយមានកិច្ចព្រមព្រៀងរវាងប្រទេស និងប្រទេស។

### - <u>ការអនុវត្ត</u>

**១៤៧-** រដ្ឋធានាអនុញ្ញាតឱ្យកុមារចេញទៅរស់នៅជួបជុំគ្រួសារឯបរទេស។ រដ្ឋក៏បានសហការ និងជួយសម្រួលរាល់កម្មវិធី " ស្វែងរកគ្រួសារ " ឱ្យកុមារមាតុភូមិនិវត្តន៍ និងកុមារផ្លាស់ទីលំនៅ។

ពីឆ្នាំ១៩៨៩-១៩៩២ គណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ បានធ្វើការស្រាវជ្រាវឱ្យគ្រួសារដែលបែកគ្នានៅក្នុង និងក្រៅប្រទេសឱ្យបានជួបជុំគ្នាវិញចំនួន ៣៦០០គ្រួសារ ហើយកម្មវិធីនេះកំពុងតែបន្ត។

## ង. <u>ការជម្រុញឱ្យមានការថែទាំកុមារ</u> (អនុសញ្ញាមាត្រា២៧ , កថា.៤)

### - <u>បរិបទច្បាប់</u>

**១៤៨-** <u>ច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ</u> :

មាត្រា២៧ : ស្តីពីសិទ្ធិ និងកាតព្វកិច្ចរបស់ឪពុកម្តាយ និងកូនត្រូវមានដូចគ្នា ក្នុងករណីនៃឪពុកម្តាយលែងលះគ្នា។

មាត្រា៣៥,៣៩ និង៧៤ : ចែងអំពីការផ្គត់ផ្គង់ ការអប់រំបណ្តុះបណ្តាល និងការប្រាស្រ័យទាក់ទងឪពុកម្តាយ លែងលះគ្នា និងកូន។

- **ការអនុវត្ត**

**១៤៩-** ចំពោះការលែងលះដែលសម្រេចដោយសាលក្រមតុលាការ កូនបានទទួលការឧបត្ថម្ភតាមប្រការនៃការលែងលះ។ នៅតាមជនបទ ការលែងលះច្រើនតែដឹងឮត្រឹមតែរដ្ឋអំណាចភូមិ-ឃុំ។ ម្តាយច្រើនជាអ្នកទទួលបន្ទុកផ្គត់ផ្គង់ ថែទាំកូនតែម្នាក់ឯង និងមានការជួយជ្រោមជ្រែងពីក្រុមញាតិ។ ឪពុកខ្លះ ក៏បានទៅលេងកូនម្តងៗ និងបានផ្តល់សោហ៊ុយឱ្យកូនម្តងម្កាលដែរ។

**១៥០-** ពុំទាន់មាននីតិវិធានការណ៍ច្បាស់លាស់ដើម្បីបង្ខំឱ្យឪពុក ឬម្តាយដែលមិនបានជួយចិញ្ចឹមកូន ឱ្យផ្តល់ការផ្គត់ផ្គង់កូនឱ្យបានសមស្របនៅឡើយ ជាពិសេសឪពុកម្តាយនៅបរទេស។

**ច-** **កុមារឃ្លាតចេញពីបរិយាកាសគ្រួសារ** (អនុសញ្ញាមាត្រា២០)

- **បរិបទច្បាប់**

**១៥១-** រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា :

មាត្រា៤៨ : ចែងពីការគាំពារសិទ្ធិរស់រានមានជីវិត និងការគាំពារក្នុងស្ថានភាពសង្គ្រាមដល់កុមារ។

**១៥២-** ច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ :

មាត្រា១១៩ : ចែងពីការដកហូតកុមារពីឪពុកម្តាយ ដែលមានកំហុសប្រគល់ទៅឱ្យអង្គការ ឬញាតិណាមួយថែរក្សា។

**១៥៣-** សេចក្តីសំរេចលេខ៧៩. ចុះថ្ងៃទី២៣ មិថុនា ១៩៨៧ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីពីរបបគោលនយោបាយចំពោះទារកកំព្រា កុមារកំព្រា ជនអនាថាស្នាក់នៅក្នុងមជ្ឈមណ្ឌលរបស់រដ្ឋ ។

- **ការអនុវត្ត**

**១៥៤-** នៅក្នុងឆ្នាំ១៩៧៩ រដ្ឋបានប្រមូលកុមារកំព្រា និងកុមារគ្មានទីពឹងមកចិញ្ចឹមថែរក្សា។ ស្ថិតិឆ្នាំ១៩៨០ មានកុមារចំនួន ៥៥៤០នាក់ រស់នៅក្នុងមជ្ឈមណ្ឌលរដ្ឋ ។ ចំនួនកុមារកំព្រាក្នុងមជ្ឈមណ្ឌលបានថយចុះ ដោយកុមារមួយចំនួនវិលទៅរស់នៅជាមួយគ្រួសារវិញ ឯមួយចំនួនទៀតចេញទៅធ្វើការងារផ្សេងៗ។

នៅបំណាច់ឆ្នាំ១៩៩៤ កុមារនៅក្នុងមជ្ឈមណ្ឌលរបស់រដ្ឋមាន ២,០៤១នាក់។ អង្គការក្រៅរដ្ឋាភិបាល ចំនួន៦ បានទទួលចិញ្ចឹម និងបណ្តុះបណ្តាលកុមារកំព្រា និងកុមារអនាថាចំនួន ៦៦៨នាក់ នៅតាមមជ្ឈមណ្ឌលរៀងៗខ្លួន។ កុមារខាងលើជាកុមារកំព្រាឪពុកម្តាយ និងកុមារដែលជាកូនប្រជាជនក្រីក្រ ដែលឪពុកម្តាយគ្មានលទ្ធភាពចិញ្ចឹម និងកុមារអនាថា ។ នៅក្នុងឆ្នាំ១៩៩១ អង្គការយូនីសេហ្វ បានសហការជាមួយរដ្ឋអំណាចស្រុក ធ្វើការស្រង់ស្ថិតិកុមារកំព្រាដែលរស់នៅក្នុងសហគមន៍ក្នុងខេត្ត១១ បានចំនួន ៥៨,៤៩៨នាក់ ដែលកំព្រាទាំងឪពុកម្តាយ និង៧៧,២៣៤នាក់ ដែលកំព្រាឪពុក ឬម្តាយ។

**១៥៥-** មានកុមារអនាថាប្រហែល ៥,០០០ ទៅ ១០,០០០នាក់ (តួលេខយូនីសេហ្វ) រស់នៅក្នុងទីក្រុង និងតាមខេត្តមួយចំនួន។ ចំនួននេះផ្លាស់ប្តូរទៅតាមស្ថានភាពសេដ្ឋកិច្ច និងតាមរដូវ។

ការផ្តល់សេវាកម្មសង្គមដល់កុមារអនាថា និងកុមារកំព្រាតាមសហគមន៍មិនទាន់បានគ្រប់គ្រាន់នៅឡើយទេ គឺធ្វើទៅតាមលទ្ធភាព និងសមត្ថភាពរបស់រដ្ឋាភិបាល និងអង្គការអ្នកជួយឧបត្ថម្ភ។ ក្រសួងពាក់ព័ន្ធ និងអង្គការមួយចំនួនកំពុងរៀបចំកម្មវិធី និងកសាងផែនការបន្ថែមទៀត ដើម្បីបន្ថយចំនួនកុមារអនាថា។

**១៥៦-** មានកុមារប្រភេទខ្លះទៀតត្រូវចាកចេញពីគ្រួសារ ទៅរស់នៅជាមួយបងប្អូន និងតាមវត្តអារាម ខ្លះទៀតទៅស៊ីឈ្នួលបំរើគេ។ ពុំទាន់មានសេវាកម្មសង្គមដែលមានកម្មវិធីច្បាស់លាស់ផ្តល់ដល់កុមារទាំងនេះនៅឡើយ។

ដើម្បីលើកស្ទួយដល់ជីវភាពកុមារដែលរស់នៅក្នុងមណ្ឌលកុមារកំព្រា ក្រសួងសង្គមកិច្ចបានរៀបចំឱ្យមានគណៈកម្មការដែលមានការចូលរួមពីតំណាងអង្គការក្រៅរដ្ឋាភិបាល ក៏ប៉ុន្តែកិច្ចការនេះពុំទាន់ដំណើរការបានល្អនៅឡើយទេ ហើយក្រសួងសង្គមកិច្ចកំពុងរៀបចំឡើងវិញ។

**១៥៧-** ក្រសួងសង្គមកិច្ច បានទំនាក់ទំនងសហការជាមួយអង្គការក្រៅរដ្ឋាភិបាលមួយចំនួន បានដើរប្រមូលកុមារអនាថាយកទៅផ្គត់ផ្គង់ចិញ្ចឹមបីបាច់ថែរក្សាឱ្យរៀនសូត្រ។ ប៉ុន្តែក៏នៅមានកុមារមួយចំនួនមិនព្រមទទួលយកនូវកិច្ចការនេះឡើយ ដោយពួកគេគេចវេសពីការប្រមូលផ្តុំនេះ។ ក្រៅពីនេះក្រសួងសង្គមកិច្ចក៏បានសុំគោលការណ៍ពីរាជរដ្ឋាភិបាល ដើម្បីបញ្ចេញកុមារមួយចំនួនដែលហួសវ័យកុមារ ហើយខ្លះមានទាំងគ្រួសារទៀតឱ្យចេញពីមជ្ឈមណ្ឌលទៅរស់នៅតាមមូលដ្ឋាននានា តាមសមត្ថភាពរបស់ខ្លួន។ រដ្ឋលេខាធិការដ្ឋានកិច្ចការនារី ក៏បានដាក់ផែនការចុះអប់រំដល់មាតាបិតានៅតាមមូលដ្ឋាននានាឱ្យចេះថែរក្សាបុត្រធីតារបស់ខ្លួនកុំឱ្យដើរធ្វើក្មេងអនាថា។ ប៉ុន្តែប្រការទាំងអស់នេះអនុវត្តទីមិនទាន់បានប្រសិទ្ធភាពនៅឡើយ ដោយរដ្ឋខ្វះថវិកាជួយដល់កិច្ចការទាំងនេះ។

## ឆ- <u>**ការសុំកូនចិញ្ចឹម**</u> (អនុសញ្ញាមាត្រា២១)

### ~ <u>**បរិបទច្បាប់**</u>

**១៥៨-** <u>ច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ :</u>

មាត្រា១០៨ ដល់១១៤ : ចែងពីការសុំកូនដោយពលរដ្ឋកម្ពុជា និងបរទេស។ ឪពុក ឬម្តាយចិញ្ចឹម ត្រូវមានអាយុលើសពី២៥ឆ្នាំ ហើយអាយុលើសកុមារយ៉ាងតិច២០ឆ្នាំ។ កុមារត្រូវមានអាយុតិចជាង៨ឆ្នាំ។ គេអាចសុំកូនបានត្រឹម២នាក់ប៉ុណ្ណោះហើយ ត្រូវមានការព្រមព្រៀងពីឪពុកម្តាយ ឬអាណាព្យាបាល ឬរដ្ឋអំណាច ឃុំសង្កាត់ បើសិនជាកុមារត្រូវគេបោះបង់។ កិច្ចសន្យាត្រូវមានការបញ្ជាក់ពីរដ្ឋអំណាចឃុំ ឬសង្កាត់ កិច្ចសន្យាសុំកូនអាចបដិសេធបានតាមពាក្យសុំប្តឹងរបស់កូនចិញ្ចឹម ឬរបស់ជនទាំងឡាយ ឬរបស់អង្គការផ្សេងៗ។

មាត្រា៧ នៃសេចក្តីសំរេចលេខ៧៩ សសរ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ចុះថ្ងៃទី២៣ មិថុនា ១៩៨៧ ណែនាំពីការសុំកុមារកំព្រាទៅចិញ្ចឹមជាកូនដោយប្រជាជនកម្ពុជា។

**១៥៩-** លិខិតរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រីលេខ៥៤៩ ស.ជ.ណ.ផ.ក ចុះថ្ងៃទី២៥ មិនា ១៩៩១ ណែនាំពីការសុំកុមារកំព្រាទៅចិញ្ចឹមដោយជនបរទេស។ អ្នកសុំត្រូវមានលិខិតអនុញ្ញាតឱ្យសុំចិញ្ចឹមពីរដ្ឋរបស់ខ្លួន មានអាយុលើសពី២០ឆ្នាំ និងច្រើនជាងកុមារ២០ឆ្នាំ កុមារមានអាយុ៨ឆ្នាំចុះ មានសំបុត្រពេទ្យបញ្ជាក់ថាគ្មានកូននៅថ្ងៃក្រោយ លិខិតបញ្ជាក់ពីលទ្ធភាពហិរញ្ញវត្ថុ សំបុត្រថ្កោលទោស កិច្ចសន្យាថានឹងផ្ញើរពត៌មានពីកូន។

### ~ <u>**ការអនុវត្ត**</u>

**១៦០-** ប្រជាជនកម្ពុជាពុំនិយមសុំកូនឡើយ ដោយគ្រួសារនិមួយៗមានកូន ឬមានសមាជិកច្រើនរួចទៅហើយ។ ឪពុក ម្តាយចិញ្ចឹមមួយចំនួនបានទុកកុមារដូចជាកូនបង្កើត។ ប៉ុន្តែក៏មានការយកកុមារមកបំរើការងារខ្លួនក្នុងផ្ទះ ដោយពុំសូវគិតគូរដល់ផលប្រយោជន៍របស់កុមារដែរ។

មានការសុំកូនចិញ្ចឹមខ្លះ ពុំបានធ្វើកិច្ចសន្យាអ្វីទេ គឺដឹងឮត្រឹមតែក្រុមគ្រួសារសាច់ញាតិ ហើយធ្វើការចុះបញ្ជីជាតិ ឬចុះក្នុងប័ណ្ណគ្រួសារជាកូនតែម្តង។

**១៦១-** ការសុំកុមារកំព្រាជាកូនចិញ្ចឹមដោយប្រជាជនកម្ពុជា ឬជនបរទេស បានអនុវត្តតាមគោលការណ៍របស់រដ្ឋ។ ពីឆ្នាំ ១៩៨៧ ដល់ ១៩៩៤ កុមារកំព្រាចំនួន១៦៣នាក់ បានទៅរស់នៅឯប្រទេសក្រៅ។

ឪពុកម្ដាយចិញ្ចឹមបរទេសមួយចំនួន បានផ្ញើរលិខិត និងរូបថតដើម្បីបង្ហាញពីស្ថានភាពរស់នៅរបស់កុមារ ជូនដល់មជ្ឈ-មណ្ឌលទារក។ នៅឆ្នាំ១៩៩២ តំណាងក្រសួងសង្គមកិច្ច០២រូប បានទៅធ្វើទស្សនកិច្ចតាមដានកុមារដែលគ្រួសារអាមេរិកកាំង បានសុំទៅចិញ្ចឹមចំនួន៥០នាក់។

ការតាមដានកុមារដែលសុំចិញ្ចឹមនៅក្នុងប្រទេស បានធ្វើមួយដងមួយកាលនៅទីក្រុង ឬពេលខ្លះកុមារត្រូវបាននាំយកមកមជ្ឈមណ្ឌល ដើម្បីបង្ហាញពីការរីកចំរើនរបស់គេ។

**១៦២-** ដំណើរការសុំកូនចិញ្ចឹមនៅក្នុងប្រទេសកម្ពុជា ពុំទាន់បានរៀបរយឱ្យមានលក្ខណៈប្រសើរនៅឡើយទេ។ ពេលខ្លះមានការរអាក់រអួល ទម្រង់បែបបទមិនសូវច្បាស់លាស់សំរាប់ការសុំកូនក្នុងស្រុក ម្យ៉ាងទៀតប្រព័ន្ធតាមដានស្ថានភាពគ្រួសារចិញ្ចឹម និងតាមដានស្ថានភាពកុមារដែលត្រូវបានសុំចិញ្ចឹមនៅខ្សោយ។ រដ្ឋកំពុងរៀបចំកែលំអច្បាប់សុំកូនឡើងវិញ រួមទាំងទម្រង់បែបបទផ្សេងៗ។

## ៥. <u>**ការបញ្ជូនកុមារខុសច្បាប់ និងការមិនវិលត្រឡប់របស់កុមារ**</u> (អនុសញ្ញាមាត្រា១១)

**១៦៣-** ជនកម្ពុជាគ្រប់រូបត្រូវសុំការអនុញ្ញាតដើម្បីចេញទៅបរទេស ប៉ុន្តែការនាំកុមារចេញតាមព្រំដែនដើម្បីទៅរស់នៅប្រទេសក្រៅ នៅតែមានសកម្មភាពជាស្ទាត់កំបាំងនៅឡើយ។ ពុំទាន់មានវិធានការណ៍ជាក់លាក់ដើម្បីទប់ទល់នឹងបញ្ហាដែលត្រូវឪពុកឬម្ដាយនាំចេញទៅបរទេស ដោយពុំបានឯកភាពគ្នាដែរ (ឧ. ឪពុកជាជនបរទេស ម្ដាយជាខ្មែរ)។

**១៦៤-** ក្រសួងយុត្តិធមិបានធ្វើសេចក្តីព្រាងច្បាប់រដ្ឋប្បវេណីថ្មី ដែលមានចែងអំពីបញ្ហាបែងចែកកូន នៅពេលដែលឪពុក ឬម្ដាយដែលជាជនបរទេស ហើយត្រូវលែងលះគ្នាតាមអំណាចសាលក្រមរបស់តុលាការ។

## ឈ. <u>**ការរំលោភ និងការមិនយកចិត្តទុកដាក់ចំពោះកុមារ**</u> ( អនុសញ្ញាមាត្រា១៩ និង៣៩ )

### . <u>**បរិបទច្បាប់**</u>

**១៦៥-** <u>ច្បាប់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា :</u>

មាត្រា៤៨ : រដ្ឋធានារក្សាការពារសិទ្ធិទទួលការអប់រំរៀនសូត្រ ការការពារប្រឆាំងនឹងអាជីវកម្មសេដ្ឋកិច្ច ឬ កាមគុណលើកុមារ ប្រឆាំងនឹងការងារទាំងឡាយដែលអាចធ្វើឱ្យខូចដល់ការអប់រំ និងការរៀនសូត្ររបស់កុមារ នាំឱ្យអន្តរាយដល់សុខភាព ឬសុខុមាលភាពរបស់កុមារ។

**១៦៦-** <u>ច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ :</u>

មាត្រា២-៤ និង ២៣ : ស្ដីពីការហាមឃាត់ដាច់ខាតនូវអាពាហ៍ពិពាហ៍ ដែលគួរស្រករនៅក្មេងពេក អាពាហ៍ពិពាហ៍ដោយបង្ខិតបង្ខំ អំពើដែលមានឧបសគ្គដល់សេរីភាពនៃអាពាហ៍ពិពាហ៍។ ភាគីម្ខាងមិនអាចបង្ខំឆន្ទៈរបស់ភាគីម្ខាងទៀតបានឡើយ។ គ្មាននរណាមួយអាចបង្ខំបុគ្គលឱ្យរៀប ឬរារាំងមិនឱ្យរៀបអាពាហ៍ពិពាហ៍បានឡើយ បើអាពាហ៍ពិពាហ៍នោះបានរៀបតាមក្បួនខ្នាតដែលមានចែងក្នុងច្បាប់ ។ អាពាហ៍ពិពាហ៍ត្រូវទុកជាមោឃៈ កាលបើសហព័ន្ធណាម្នាក់ដឹងថាខ្លួនត្រូវគេចាប់បង្ខំឱ្យរៀបអាពាហ៍ពិពាហ៍។

មាត្រា១១៩ និង១២០ : ចែងថា អាចនឹងត្រូវដកហូតអំណាចមេបា ចំពោះឪពុកម្ដាយដែលមានកំហុសដូចជា ខ្វះខាតក្នុងការអប់រំ ប្រើអំណាចរំលោភទៅលើកូនដោយប្រើឧបាយកលផ្សេងៗ វាយធ្វើបាបកូនឥតត្រាប្រណី ឪពុកម្ដាយប្រព្រឹត្តផ្ទុយនឹងសីលធម៌ដែលបណ្តាលឱ្យមានឥទ្ធិពលអាក្រក់ដល់កូន។ អំណាចមេបាអាចនឹងសម្រេចដកហូតបានលុះត្រាតែមានពាក្យប្ដឹងពីអង្គការរដ្ឋ អង្គការមហាជន ព្រះរាជអាជ្ញាអមតុលាការ ឬសាច់ញាតិណាមួយនៃឪពុកម្ដាយ។

**១៦៧-** ជាទូទៅ នៅប្រទេសកម្ពុជាពុំដែលមានកូនប្ដឹងពីឪពុកម្ដាយ ដែលវាយធ្វើបាបខ្លួននោះឡើយ លើកលែងតែក្នុងករណីដែលកូននោះត្រូវរងគ្រោះដល់បាត់បង់ជីវិត នោះទើបមានសាច់ញាតិ ឬរដ្ឋអំណាចប្ដឹងតែម្ដង។ ករណីចុងក្រោយនេះគឺមានតិចតួចបំផុត ហើយក៏ជាករណីដែលកើតឡើងដោយអចេតនាតែប៉ុណ្ណោះ។

**១៦៨-** <u>ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធីព្រហ្មទណ្ឌ</u> (អ៊ុនតាក់) :

មាត្រា៤២ : ស្ដីពីការផ្ដន្ទាទោសដល់ជនដែលបានបៀតបៀនកេរ្ដិ៍ខ្មាស់អ្នកដទៃ ដោយត្រូវទទួលទោស១ឆ្នាំ ទៅ៣ឆ្នាំ ក្នុងករណីដែលពុំទាន់បានដល់ទីជម្រៅទទួលទោសទ្វេមួយជាពីរ បើធ្វើដោយអំពើហឹង្សា ហើយជនរងគ្រោះមានអាយុតិចជាង ១៦ឆ្នាំ ឬអ្នកប្រព្រឹត្តជាអ្នកមានអំណាចលើជនរងគ្រោះ។ ត្រូវទទួលទោសពី២ ទៅ៦ឆ្នាំ ចំពោះជនដែលបានអូសទាញអនីតិជនដើម្បីធ្វើពេស្យាចារ ឬធ្វើអាជីវកម្មពេស្យាចារលើអនីតិជន។

## ~ <u>ការអនុវត្ត</u>

**១៦៩-** នៅកម្ពុជា ការវាយកូនដើម្បីប្រៀនប្រដៅនៅតាមគ្រួសារគឺជារឿងធម្មតា ប៉ុន្តែក្នុងករណីដែលកុមារត្រូវគ្រួសារវាយធ្វើបាបធ្ងន់ធ្ងរ ឬគាបសង្កត់ដោយអំពើណាមួយ ពេលខ្លះបានទទួលអន្តរាគមន៍ពីរដ្ឋអំណាច ឬអ្នកជិតខាង ប៉ុន្តែពេលខ្លះទៀតពុំបានទទួលការជួយពីអ្នកណាឡើយ ក្នុងករណីចាំបាច់ខ្លះកុមារត្រូវជីដូនជីតា យកទៅចិញ្ចឹម ឬបញ្ជូនទៅមជ្ឈមណ្ឌលសង្គ្រោះ។

កុមារក្នុងវ័យសិក្សាប្រហែលមួយភាគបីប៉ុណ្ណោះ បានឆ្លងផុតបឋមសិក្សា ព្រោះគ្រួសារពុំសូវបានយកចិត្តទុកដាក់ជួយជំរុញ និងតាមដានការរៀនសូត្ររបស់កូន ឬខ្វះការថែទាំ គិតគូជិតដល់លើសុខុមាលភាពកុមារ បណ្ដាលឱ្យកុមារទៅជាក្មេងអនាថា ដើរសុំទាន កកាយសំរាម មានជំងឺផ្សេងៗប៉ះពាល់ដល់អាយុជីវិតកុមា ។ល។

**១៧០-** នៅមានសកម្មភាពយកកុមារដែលមានវ័យក្មេងទៅបំរើតាមគ្រួសារ ឬយកទៅលក់ធ្វើជាពេស្យាចារទុកឱ្យជួយធ្វើការរកស៊ីចិញ្ចឹមគ្រួសារ (ឯកសារអង្គការយូនីសេហ្វបានបង្ហាញថា៣៦% នៃកុមារអនាថា បានឃ្លាតពីគ្រួសារ ៤៨% ធ្វើការដើម្បីជួយគ្រួសារ)។

**១៧១-** រដ្ឋ និងអង្គការក្រៅរដ្ឋាភិបាល បានសហការគ្នាជួយកុមារអនាថាមួយចំនួនឱ្យរស់នៅក្នុងជម្រកបណ្ដោះអាសន្ន និងមានកម្មវិធីអប់រំរៀនសូត្រ ឬបញ្ជូនទៅគ្រួសារវិញ។

តំណាងអង្គការខ្លះបានចុះទាក់ទងដល់ឪពុកម្ដាយឱ្យយល់ពីសេចក្ដីត្រូវការរបស់កុមារហើយឈប់ធ្វើបាបកុមារ នៅពេលគេត្រឡប់មករស់នៅក្នុងផ្ទះវិញ ។

ច្បាប់ វិធានការ ឬកម្មវិធីនានា ដើម្បីជួយគាំទ្រដល់កុមារដែលស្ថិតក្នុងស្ថានភាពខាងលើ នៅមិនទាន់គ្រប់គ្រាន់ ។ រដ្ឋ និងអង្គការនានាបាននឹងកំពុងធ្វើសេចក្ដីព្រាងច្បាប់ ស្ដីពីការលុបបំបាត់ការរកស៊ីនាំកុមារទៅជួញដូរដោយលួចលាក់ និងទៅឱ្យធ្វើពេស្យាចារ។ ទន្ទឹមនឹងនេះ គណៈកម្មការ **ECPAT** មានន័យថាបញ្ឈប់កុមារពេស្យាចារតាមទេសចរណ៍នៅអាស៊ីកំពុងធ្វើសកម្មភាពអប់រំតាមរូបភាព ឬផ្ទាល់មាត់ ដើម្បីលុបបំបាត់ការធ្វើពេស្យាចារលើកុមារ។

## ៧. <u>ការពិនិត្យតាមដានកុមារដែលដាក់ឱ្យគេថែរក្សា</u> (អនុសញ្ញាមាត្រា២៥)

**១៧២-** ស្ថានភាពរបស់កុមារដែលរស់នៅក្នុងមជ្ឈមណ្ឌលរដ្ឋ និងអង្គការក្រៅរដ្ឋាភិបាល បានត្រូវត្រួតពិនិត្យតាមផ្នែករៀងៗខ្លួន និងធ្វើរបាយការណ៍ជូនក្រសួងសង្គមកិច្ច។ ប៉ុន្តែការចុះពិនិត្យជាក់ស្ដែង ធ្វើបានទៀងទាត់ខាងផ្នែកអង្គការ និងធ្វើតាមបណ្ដាថ្នាក់ខេត្ត ប៉ុន្តែពុំបានទៀងទាត់ពីថ្នាក់ក្រសួងដោយខ្វះមធ្យោបាយគ្រប់បែបយ៉ាង។ ការផ្ដល់របាយការណ៍យឺតយ៉ាវអាក់អួលដោយប្រព័ន្ធទំនាក់ទំនងនៅខ្សោយ លទ្ធភាពនៅមានកម្រិត និងប្រែប្រួលតាមស្ថានការណ៍សន្តិសុខក្នុងប្រទេស ឬក្នុងតំបន់។

**១៧៣-** រដ្ឋពុំទាន់មានកម្មវិធីដាក់កុមារដែលស្ថិតក្នុងស្ថានភាពលំបាកជាពិសេស ទៅរស់នៅក្រោមអាណាព្យាបាលរបស់គ្រួសារណាមួយដែលមានលក្ខណៈសមស្រប និងមនុស្សធម៌នៅឡើយទេ។ ប៉ុន្តែអង្គការក្រៅរដ្ឋាភិបាលមួយចំនួនបានចាប់ផ្តើមអនុវត្តកម្មវិធីនេះ ដោយបានធ្វើការតាមដានទៀងទាត់។

ក្រសួងសង្គមកិច្ច កំពុងរៀបចំពង្រឹងការត្រួតពិនិត្យតាមដានស្ថានភាពកុមារ ដែលរស់នៅតាមមជ្ឈមណ្ឌលនានា ឱ្យបានប្រសើរឡើងថែមទៀត និងកំពុងធ្វើគោលការណ៍ណែនាំស្តីពីការតាមដានស្ថានភាពកុមារ ដែលត្រូវគេសុំយកទៅចិញ្ចឹមទាំងក្នុង និងក្រៅប្រទេសឱ្យសមស្របតាមច្បាប់សុំកូន ។

*

*   *

# VI. **សុខភាពមូលដ្ឋាន និង សុខុមាលភាព**

********

## ក. <u>ការរស់រានមានជីវិត ការអភិវឌ្ឍ និងកំរិតជីវភាព (មាត្រា៦ កថាខ័ណ្ឌ២)</u>

### ~ <u>បរិបទច្បាប់</u>

**១៧៤-** <u>រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា</u> :

មាត្រា៧២ : សុខភាពរបស់ប្រជារាស្ត្រត្រូវបានធានា ។ រដ្ឋយកចិត្តទុកដាក់ដល់ការការពារជម្ងឺ និង ព្យាបាលជម្ងឺ។ ប្រជារាស្ត្រក្រីក្រត្រូវបានទទួលការពិនិត្យរោគដោយឥតបង់ថ្លៃនៅតាមមន្ទីរពេទ្យ គិលានដ្ឋាន និងមន្ទីរសម្ភពសាធារណៈ។ រដ្ឋរៀបចំឱ្យមានគិលានដ្ឋាន និង មន្ទីរសម្ភពដល់ជនបទ ។

**១៧៥-** <u>គោលនយោបាយសុខាភិបាលជាតិ</u> :

រាជរដ្ឋាភិបាលកម្ពុជាទទួលស្គាល់ប្រព័ន្ធរក្សាសុខភាពពីរផ្នែក គឺផ្នែករដ្ឋ និង ឯកជន រដ្ឋយកចិត្តទុកដាក់ដល់ការអប់រំអនាម័យ ការបង្ការជម្ងឺជូនប្រជារាសស្ត្រដោយរៀបចំឱ្យមានគិលានដ្ឋាន និង មន្ទីរសម្ភពដល់ជនបទ ។ ត្រូវយកចិត្តទុកដាក់ជាពិសេសដល់សុខុមាលភាពរបស់មាតា និងកុមារ ដោយខិតខំបន្ថយអត្រាមរណៈរបស់កុមារឱ្យទាបបំផុត ។

### ~ <u>ការអនុវត្ត</u>

**១៧៦-** ដោយសារការទទួលស្គាល់សិទ្ធិរស់នៅ និងការយកចិត្តទុកដាក់ការរស់នៅ និងរីកចំរើនលូតលាស់របស់កុមារកម្ពុជាគ្រប់រូប ជានិច្ចជាកាលរាជរដ្ឋាភិបាលបានបន្តការជម្រុញសកម្មភាពគ្រប់គ្រងសុខភាពកុមារ និង មាតាយ៉ាងសកម្ម ក្នុងនោះមានផ្នែកប្រព័ន្ធចាត់តាំងគាំពារមាតា និង កុមារ រួមទាំងផ្នែកគ្រប់គ្រងកម្មវិធីសុខភាពមាតា និងទារកទៀតផង ។

**១៧៧-** នៅថ្នាក់ខេត្តមានផ្នែកសេវាគាំពារមាតា-ទារក និងសេវាព្យាបាលជម្ងឺកុមារ ២៦កន្លែង។

នៅថ្នាក់ស្រុកមានផ្នែកសេវាសំរាលកូន និងថែទាំទារកចំនួន១៦៤សេវា។ ក្រៅពីនេះផ្នែកគាំពារមាតា-ទារកស្រុកមានភារកិច្ចពិនិត្យគ្រោះថ្នាក់ផ្សេងៗនៃគភ៌ និងសំរាលកូន អប់រំសុខភាព និងអាហារូបត្ថម្ភ ពិគ្រោះមុនសំរាល ពន្យាកំណើត ពិគ្រោះជម្ងឺកុមារអាយុក្រោម ៥ឆ្នាំ កម្មវិធីពង្រីកការចាក់ថ្នាំបង្ការ តាមដានការលូតលាស់របស់កុមារ ។ល។

នៅថ្នាក់ឃុំមានគិលានដ្ឋាន១.២៦៧កន្លែង ជាជំនួយការក្នុងការអនុវត្តកម្មវិធីសុខភាពបឋម និងកម្មវិធីដទៃទៀត ទាក់ទងដល់សុខភាពមាតា និងកុមារ និងប្រជាជនទូទៅ ។

**១៧៨-** ទន្ទឹមនិងការអនុវត្តភារកិច្ចជំនាញ និងកម្មវិធីរបស់ខ្លួនខាងលើនេះ ប្រព័ន្ធគ្រប់គ្រងសុខភាពមាតា និងកុមារគ្រប់ថ្នាក់ នៅបានរួមចំណែកយ៉ាងសកម្មក្នុងការពន្យល់ណែនាំអប់រំ និងផ្សព្វផ្សាយដោយផ្ទាល់ អំពីខ្លឹមសារអប់រំខាងអនាម័យលំនៅដ្ឋាន អនាម័យការពារ និងទប់ស្កាត់ទាន់ពេលវេលានូវជម្ងឺរាតត្បាតកុមារ និងមាតា មានជម្ងឺអាសន្នរោគ គ្រុនឈាម គ្រុនចាញ់ របេង អេដស៍ ។ល ។ " របាយការណ៍របស់រាជរដ្ឋាភិបាលឆ្នាំ ១៩៩៤ " ។

**១៧៩-** ទោះបីមានការខិតខំយ៉ាងនេះក្តី ដោយសារកំរិតយល់ដឹងរបស់ប្រជាជននៅទាប សកម្មភាពអប់រំផ្សព្វផ្សាយ និង អនុវត្ត អនាម័យនៅកន្លែងខ្លះនៅខ្សោយ ពិសេសនៅតាមមូលដ្ឋានជនបទដាច់ស្រយាល ធ្វើឱ្យកំរិតអនាម័យក្នុងការរស់នៅ និងការថែទាំ សុខភាពប្រជាជនជាទូទៅនៅទាប ហើយអត្រាស្លាប់កុមារនៅមានចំនួនច្រើននៅឡើយ ។ តាមការស្រាវជ្រាវរបស់ UNICEF បានឱ្យដឹងថា កុមារ១១៧%ត្រូវស្លាប់ក្រោមអាយុ៥ឆ្នាំ ហើយក្នុងចំនួននេះទៀតមាន៣១% ស្លាប់មុនពេលកើត និង២៨% ស្លាប់ពេលកើត ។

**១៨០-** ក្នុងទិសដៅធានាឱ្យកាន់តែល្អប្រសើរលើការរស់នៅ និងការរីកចំរើនលូតលាស់របស់កុមារកម្ពុជា សំរាប់ពេលអនាគត រាជរដ្ឋាភិបាលបាន និងកំពុងអនុវត្តជាជំហានៗ នូវការងារមួយចំនួនបន្ថែមទៅលើការងារសេដ្ឋកិច្ចសង្គម ដូចខាងក្រោម:

- កំពុងសិក្សាវិភាគបន្ថែមនូវគម្រោងស្ថារហេដ្ឋារចនាសម្ព័ន្ធដែលត្រូវផ្តល់ថវិកាបន្ថែម
- កំពុងសិក្សាសំណង់មជ្ឈមណ្ឌលគាំពារមាតា និងទារក និងមន្ទីរពេទ្យសម្ពចំណុះ ២០០គ្រែ ជាមួយអង្គការ JICA ដែលមានគម្រោងថវិកាប្រមាណ ១៤ លានដុលាអាមេរិក ។

អង្គការទស្សនៈពិភពលោកអន្តរជាតិជួយកែលំអមន្ទីរពេទ្យកុមារជាតិ និងអង្គការមូលនិធិខ្មែរ-ស្វីស ជួយកែលំអមន្ទីរពេទ្យកុមារគន្ធបុប្ផ ដើម្បីឱ្យក្លាយទៅជាមន្ទីរពេទ្យកុមារទំនើប ។

- បន្តពង្រឹងការរៀបចំ និងការគ្រប់គ្រងសេវាគ្រប់គ្រងសុខភាពមាតា និងកុមារគ្រប់ថ្នាក់ ។
- បន្តអនុវត្តកម្មវិធីជាតិសំរាប់សុខភាពមាតានិងកុមារ ឱ្យកាន់តែមានគុណភាព និងប្រសិទ្ធភាពល្អ ។
- កែលំអនីតិក្រមនានាដែលទាក់ទងដល់សុខភាពមាតា និង កុមារ ដើម្បីដាក់ជូនរដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា អនុម័ត ។

<u>ប្រភព</u> : ក្រសួងសុខាភិបាល " របាយការណ៍សមិទ្ធិផលការងារសុខាភិបាល ឆ្នាំ ១៩៩៤ " ។

## ខ- <u>**កុមារពិការ**</u> ( អនុសញ្ញាមាត្រា ២៣)

### - <u>**បរិបទច្បាប់**</u>

**១៨១-** មាត្រា ៧៤ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា : "រដ្ឋជួយឧបត្ថមជនពិការ និងដល់គ្រួសារយុទ្ធជនដែលបានបូជាជីវិតដើម្បីប្រទេសជាតិ " ។

**១៨២-** គោលនយោបាយនៃរាជរដ្ឋាភិបាល ចុះថ្ងៃទី ២៩ ខែតុលា ឆ្នាំ១៩៩៣ : " ត្រូវពិនិត្យនិងយកចិត្តទុកដាក់ផ្គត់ផ្គង់ឧបត្ថម្ភចំពោះជនដែលរងគ្រោះដោយសារសង្គ្រាម ស្ត្រីមេម៉ាយ, ក្មេងកំព្រា, ជនពិការ... " ។

**១៨៣-** សេចក្តីសំរេចរបស់ក្រុមប្រឹក្សារដ្ឋមន្ត្រី នៃរដ្ឋកម្ពុជាលេខ ១៨.សសរ ចុះថ្ងៃទី ២០.១២.១៩៩០ ស្តីអំពីគោលការណ៍ស្តារ

លទ្ធភាពពលកម្ម បណ្តុះបណ្តាលវិជ្ជាជីវៈ និងដោះស្រាយការងារជូនជនពិការ ។

~ **ការអនុវត្ត**

**១៨៤-** កុមារពិការដែលបណ្តាលមកពីសង្គ្រាមវិនាសកម្មរ៉ាំរៃយូរឆ្នាំនៅកម្ពុជាមានចំនួនច្រើន។ តាមពតិមានទទួលបានឆ្នាំ១៩៩៤ នៅក្នុងព្រះរាជាណាចក្រកម្ពុជា មានជនពិការសរុបចំនួន ១២២.៧៤០នាក់ ដែលក្នុងចំនួននេះជនពិការ ដែលមានអាយុក្រោម ១៨ឆ្នាំ មានប្រមាណ៣២.០០០នាក់ ហើយកុមារអាយុតិចជាង១៥ឆ្នាំមាន ៤៣%នៃភាពពិការបណ្តាលមកពីប៉ូលីយ្យ (Polio), ១៦%ដោយជម្ងឺខួរក្បាល និង ២១%ដោយការកាត់ដៃជើង ។

**១៨៥-** ជនពិការចំនួនប្រមាណពី២០.០០០ ដល់៣០.០០០នាក់ ត្រូវបានរងគ្រោះដោយសារការផ្ទុះគ្រាប់មីន ។ ទោះបីរបាយការណ៍ដែលទទួលបានមានចំនួនតិចតួច ស្តីពីកុមាររងគ្រោះដោយសារគ្រាប់មីន នៅក្នុងព្រះរាជាណាចក្រកម្ពុជា យ៉ាងណាក្តីក៏ចំនួន នៃអ្នករងគ្រោះដោយសារគ្រាប់មីនទាំងអស់នេះ ត្រូវបានប្រមាណថាភាគច្រើនជាងគេ គឺជាមនុស្សស្ថិតក្នុងវ័យកុមារ ។

**១៨៦-** ដោយខ្វះមធ្យោបាយ និងថវិកា រដ្ឋពុំទាន់មានវិធានការដោយឡែកដើម្បីដោះស្រាយបញ្ហាកុមារពិការនេះឡើយ ដូចជាពុំទាន់មានកម្មវិធីសំរាប់ផ្តល់ចំណេះដឹង ឬក៏មុខវិជ្ជាជីវៈអ្វីសំរាប់អនាគតកុមារនេះទេ ។ ប៉ុន្តែគេអាចទៅសុំចុះឈ្មោះចូលរៀននៅតាមសាលាសាធារណៈ តាមលទ្ធភាពនៃពិការភាពរបស់ខ្លួនដែលអាចធ្វើបាន ។

សំណូមពរឱ្យអង្គការអន្តរជាតិនានា ពិសេសអង្គការសហប្រជាជាតិ ជួយដល់កុមារពិការកម្ពុជាដែលកំពុងតែទទួលរងគ្រោះជារៀងរាល់ថ្ងៃ ដោយសារគ្រាប់មីន ។

**១៨៧-** ចំពោះកុមារដែលត្រូវបាត់បង់ជីវិតដោយសារគ្រាប់មីនវិញ មានការលំបាកក្នុងការកំណត់ចំនួនឱ្យបានជាក់ស្តែងណាស់ ដោយសារនៅពេលមានគ្រោះថ្នាក់ផ្ទុះមីនម្តងៗ របួសធ្ងន់ធ្ងររបស់កុមារភាគច្រើនបណ្តាលឱ្យស្លាប់ភ្លាមៗនៅនឹងកន្លែង ឬមួយក៏ស្លាប់នៅពេលមុនដឹកទៅដល់មន្ទីរពេទ្យ ។ នៅខេត្តបាត់ដំបង ត្រូវបានគេស្រាវជ្រាវដឹងនៅតាមស្រុកមួយចំនួនដែលសំបូរគ្រាប់មីនបង្កប់ច្រើនជាងគេថា កុមារដែលស្លាប់ដោយសារផ្ទុះគ្រាប់មីនមានប្រមាណ ៦.៧% លើចំនួនសរុបនៃអ្នករងគ្រោះស្លាប់ ដោយសារគ្រាប់មីន ហើយក្នុងចំនួននោះមានក្មេងប្រុសៗប្រមាណ ៩០% ។

<u>ប្រភព</u> :
១- ក្រសួងសង្គមកិច្ចការងារ និងអតីតយុទ្ធជន (May 1994, American Red Cross, National Rehabilitation Seminar)
២- ការវិភាគស្ថានភាពស្ត្រី និងកុមារ
៣- ក្រសួងសុខាភិបាល
៤- " យូនីសែហ្វ នៅកម្ពុជា " ។

**១៨៨-** ចំពោះមុខស្ថានភាពពិការភាពដូចខាងលើនេះ រាជរដ្ឋាភិបាល បានសហការជាមួយអង្គការក្រៅរដ្ឋាភិបាលមួយចំនួនក្នុងនេះឆ្នាំ១៩៩៣ អង្គការ Handicap International បានរៀបចំ និងដំណើរការព្យាបាល និងកែទម្រង់រាងកាយដល់ជនរបួសនិងពិការនៅតាមខេត្ត និងក្នុងរាជធានីភ្នំពេញចំនួន ១៤កន្លែង។ រាជរដ្ឋាភិបាលបានសហការជាមួយអង្គការ FFAC ក្នុងការជួយថែទាំសុខភាព ហ្វឹកហាត់ចលនាដល់កុមារពិការ ដែលគ្មានទីពឹងនៅមជ្ឈមណ្ឌលកុមារកំព្រាគៀនឃ្លាំង ក្នុងរាជធានីភ្នំពេញ ។

**១៨៩-** ដើម្បីជៀសវាងគ្រោះថ្នាក់ ដោយសារបញ្ហាគ្រាប់មីននេះ រាជរដ្ឋាភិបាលបានចាត់វិធានការដោយឱ្យអង្គការ CMAC ធ្វើសកម្មភាពដោះគ្រាប់មីន ព្រមទាំងដាក់សញ្ញាសំគាល់នៅកន្លែងដែលមានគ្រាប់មីន ហើយបានផ្សព្វផ្សាយតាមវិទ្យុ ទូរទស្សន៍ និងប័ណ្ណប្រកាស ពន្យល់ណែនាំឱ្យប្រជាជនស្គាល់ពីសញ្ញាសំគាល់នានានៃគ្រាប់មីន។

## គ. __សុខភាព និងសេវាវេជ្ជសាស្ត្រ__ (អនុសញ្ញាមាត្រា ២៤)

### ~ __បរិបទច្បាប់__

**១៩០-** __រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា :__

មាត្រា៧៣ : រដ្ឋយកចិត្តទុកដាក់ចំពោះកុមារ និង មាតា។ រដ្ឋរៀបចំឱ្យមានទារកដ្ឋាន និងជួយឧបត្ថម្ភនារីដែលមានកូនច្រើនក្នុងបន្ទុកហើយឥតទីពឹង។

**១៩១-** __គោលនយោបាយសុខាភិបាលជាតិ :__

១- ធ្វើឱ្យប្រសើរឡើង និង ពង្រីកសេវាសុខាភិបាលបឋម តាមរយៈការពង្រឹងប្រព័ន្ធសុខាភិបាលស្រុក ដោយមានការចូលរួមពីសហគមន៍ និង មេដឹកនាំសាសនា។

២- ជម្រុញឱ្យមានអាហាររូបត្ថម្ភល្អ អនាម័យ និង អនុវត្តវិធីពន្យាកំណើតក្នុងគ្រួសារ ដើម្បីធានាសុខភាព និងសុខមាលភាពស្ត្រី និងកុមារ។

៣- បន្ថយអត្រាជម្ងឺឆ្លង ជាពិសេសជម្ងឺគ្រុនចាញ់ របេង គ្រុនឈាម រាគ ជម្ងឺផ្លូវដង្ហើម កាមរោគ និងជម្ងឺអេដស៍។

៤- ធ្វើឱ្យប្រសើរឡើងសេវាកម្មក្នុងមន្ទីរពេទ្យនៅភ្នំពេញ និងទីរួមខេត្ត ធានាសេវាកម្មខាងសង្គ្រោះបន្ទាន់ ចំពោះជម្ងឺធ្ងន់ និង គ្រោះថ្នាក់ផ្សេងៗ។

៥- ធានាកំរិតស្តង់ដាសមស្របខាងវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងថែទាំជម្ងឺដល់គ្រប់មូលដ្ឋានព្យាបាល។ លើកកំពស់សមត្ថភាពបុគ្គលិកសុខាភិបាលឱ្យទាន់សម័យ តាមរយៈការបណ្តុះបណ្តាលបន្ថែម។

៦- កែលំអរការផ្គត់ផ្គង់ និងបែងចែកឱសថសារវ័ន្ត សំភារៈបរិក្ខាពេទ្យដល់គ្រប់មន្ទីរពេទ្យសាធារណៈ ឱសថាល័យ និងគិលានដ្ឋាន ក្នុងព្រះរាជាណាចក្រកម្ពុជា។

៧- រៀបចំច្បាប់ដើម្បីគ្រប់គ្រង និងត្រួតពិនិត្យគុណភាពសេវាសុខាភិបាលឯកជន ទាំងផ្នែកវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និង ទន្តសាស្ត្រ។

### ~ __ការអនុវត្ត__

**១៩២-** ដើម្បីធានាបាននូវកំរិតសុខភាពឱ្យកាន់តែបានល្អប្រសើរ និងបង្កការងាយស្រួលក្នុងការព្យាបាលជម្ងឺ និងថែទាំសុខភាពប្រជាពលរដ្ឋជាពិសេសកុមារ រាជរដ្ឋាភិបាលបានរៀបចំដំណើរការប្រព័ន្ធសុខាភិបាលជាតិដោយមានសាលាបណ្តុះបណ្តាលពីរកន្លែង វិទ្យាស្ថាន៩កន្លែង រោងចក្រឱសថ១កន្លែង និងមន្ទីរពេទ្យ៨កន្លែង ដែលមានគ្រែចំនួន១.៨៦៦។ នៅថ្នាក់ខេត្តមានមន្ទីរសុខាភិបាលខេត្ត និងស្ថានីយ៍អនាម័យ២១ និងមន្ទីរពេទ្យខេត្ត២៦កន្លែង ដែលមានគ្រែសរុប៤.០៩០។ នៅថ្នាក់ស្រុកមានមន្ទីរពេទ្យស្រុក១៦៤កន្លែង ដែលមានគ្រែ៣.៩៣៥។ នៅថ្នាក់ឃុំមានគិលានដ្ឋាន១.២៦៧កន្លែង។ ឃុំដែលគ្មានគិលានដ្ឋាន ក៏មានបុគ្គលិក ២ ឬ ៣នាក់ប្រចាំការដែរ។

**១៩៣-** ក្នុងការថែទាំសុខភាពកុមារជាជំហានៗ រាជរដ្ឋាភិបាលបានដាក់ចេញនូវវិធានការយ៉ាងច្រើន ដែលក្នុងនោះមានជាអាទិ:

- ការចាក់ថ្នាំបង្ការជម្ងឺ ៦មុខ ដល់កុមារនៅតាមភូមិឃុំ :

| ឆ្នាំ | ចំនួនកុមារចំណុច | BCG | % | Polio លើកទី៣ | % | DTC លើកទី៣ | % | រ៉ូវ៉ាក់ | % |
|---|---|---|---|---|---|---|---|---|---|
| ១៩៩១ | ៣៣៧.៥១៨ | ១៨៨.៣២៤ | ៥៥ | ១៣២.៩៤៨ | ៣៨ | ១៣១.០៤២ | ៣៩ | ១៣១.១៩១ | ៣៨ |
| ១៩៩២ | ៣៤៣.៤១១ | ១៩០.៤០១ | ៥៦ | ១២២.៩៥៨ | ៣៦ | ១២១.១៩៦ | ៣៥ | ១៣១.៤១១ | ៣៨ |
| ១៩៩៣ | ៣៦៦.១០៤ | ២០៧.៦៩៦ | ៥៦ | ១៣០.៩៣៤ | ៣៦ | ១២៩.៤០២ | ៣៥ | ១៣២.៥០៣ | ៣៧ |
| ១៩៩៤ | ៣៨០.២០០ | ២៨៣.៥៥៨ | ៧៤ | ១៧២.៣៣៦ | ៤៥ | ១៧០.២៧៤ | ៤៤ | ១៧៨.៧៤៥ | ៤៧ |

- បានរៀបចំកម្មវិធីបំបាត់ជម្ងឺគ្រុនស្វិតដៃជើង នៅខេត្តកណ្ដាល និងរាជធានីភ្នំពេញ ដែលបានទទួលអត្រាគ្របដណ្ដប់លើសពី ៨០% លើកុមារអាយុតិចជាង ៥ឆ្នាំ។
- បានរៀបចំពង្រីងកម្មវិធីជាតិចាក់ថ្នាំបង្ការទិសដៅឆ្នាំ ១៩៩៤ ព្រមទាំងបានរៀបចំទិវាកំចាត់រោគគ្រុនស្វិតដៃ.ជើង ឱ្យបានគ្រប់ខេត្តនាដើមឆ្នាំ ១៩៩៥ ។

**១៩៤-** កំពុងសិក្សាគម្រោងដាក់ឱ្យអនុវត្តកម្មវិធីពន្យាកំណើតកូន នៅខេត្ត-ក្រុង១២កន្លែង : កណ្ដាល តាកែវ កំពង់ស្ពឺ ព្រៃវែង ស្វាយរៀង កំពង់ចាម កំពង់ឆ្នាំង ក្រចេះ បាត់ដំបង ពោធិសាត់ កំពត និងរាជធានីភ្នំពេញ ។

**១៩៥-** បានអប់រំណែនាំស្ត្រីមានផ្ទៃពោះ អំពីការថែទាំផ្ទៃពោះ និងទារក ។

-ស្ត្រីមានផ្ទៃពោះដែលមកពិគ្រោះបានកើនពី ៥៣% នាឆ្នាំ១៩៩៣ មកដល់ ៦៣% នាឆ្នាំ១៩៩៤។ ចំណែកស្ត្រីមានផ្ទៃពោះដែលបានចាក់ថ្នាំបង្ការតេតាណូសបានកើនពី ២៤% នាឆ្នាំ១៩៩៣ មកដល់ ៤៤% នាឆ្នាំ១៩៩៤។

**១៩៦-** ចំនួនកុមារពិនិត្យជម្ងឺបានកើនឡើង២ដង ចំនួនសំរាលកូននៅមន្ទីរពេទ្យបានកើន១២% បើប្រៀបធៀបនៅឆ្នាំ១៩៩៣។

**១៩៧-** បានបណ្ដុះបណ្ដាលឆ្មប និងបានអប់រំឆ្មបបុរាណអំពីអនាម័យសំរាលកូន និងការបញ្ជូនករណីស្ត្រីមានផ្ទៃពោះមានគ្រោះថ្នាក់ ។

**១៩៨-** ការបង្កើតប្រព័ន្ធពត៌មានអាចដឹងបានទាន់ពេល អំពីការរាតត្បាតនៃជម្ងឺឆ្លងនានា ដើម្បីធ្វើអន្តរាគមន៍ឱ្យមានប្រសិទ្ធភាព ដូចជាជម្ងឺគ្រុនឈាម និងជម្ងឺអាសន្នរោគ។

**១៩៩-** ជម្ងឺអេដស៍ជាជម្ងឺថ្មីមួយដែលរាជរដ្ឋាភិបាលបានយកចិត្តទុកដាក់យ៉ាងខ្លាំង។ គេយល់ឃើញថា នៅកម្ពុជាវិធីសំខាន់នៃការឃោសនាគឺទំនាក់ទំនងខាងផ្លូវភេទ។ ស្ត្រីទទួលគ្រោះថ្នាក់ជាពិសេសដោយហេតុថា ប្ដីរបស់គេបានរួមរក្ស និងទំនាក់ទំនងផ្លូវភេទជាញឹកញាប់ជាមួយស្រីពេស្យា។ ចំនួនពេស្យាចារបានកើនឡើងតាំងពីឆ្នាំ១៩៩១ ដែលតាមការសិក្សាស្រាវជ្រាវរបស់ក្រសួងសុខាភិបាលមាន៣៨% នៃពេស្យាចារមានរោគសញ្ញាជាវិជ្ជមាន។ ដើម្បីទប់ស្កាត់ការរីករាលដាលនេះ រាជរដ្ឋាភិបាលបានចេញសេចក្ដីសំរេចលេខ៣សសរ.ចុះថ្ងៃទី១១-១២-១៩៩៣ បង្កើតគណៈកម្មការអន្តរក្រសួងមួយ។ យើងបានការពារតាមរយៈការពិនិត្យអ្នកផ្ដល់ឈាម ការបណ្ដុះបណ្ដាលបុគ្គលិកសុខាភិបាលគ្រប់ជាន់ថ្នាក់ ការឃោសនាអប់រំមន្ត្រីរាជការប្រជារាស្ត្រតាមគ្រប់រូបភាព។ តាមការពិនិត្យរបស់ក្រសួងសុខាភិបាលបានឱ្យដឹងថា នៅប្រទេសកម្ពុជាបច្ចុប្បន្នមានមនុស្សប្រមានជា ៣០.០០០នាក់មានផ្ទុកមេរោគ HIV ហើយក្នុងនោះក៏មានកុមារ ប្រមាណជា...........ដែរ។ ការសិក្សាស្រាវ ជ្រាវនៅឆ្នាំ១៩៩៥ លើការប៉ាន់ស្មាននៃស្ត្រីមានផ្ទៃពោះបានបង្ហាញឱ្យឃើញថា ក្នុងចំនួននេះមាន៤% ដែលមានរោគសញ្ញាវិជ្ជមាន។ ការប្រៀបធៀបជាមួយបណ្ដា

ប្រទេសផ្សេងៗឃើញថា ១%នៃស្ត្រីមានផ្ទៃពោះ នៅតំបន់ទីក្រុងត្រូវមានរោគសញ្ញាវិជ្ជមាន។ ករណីទី១នៃកុមារមានជម្ងឺស៊ីដាត្រូវបានកើតមានឡើង។ ជម្ងឺស៊ីដាក៏ជាមហន្តរាយមួយយ៉ាងធំសំរាប់កុមារតាមចិញ្ចើមថ្នល់ដែលធ្វើពេស្យាចារ។ ក្នុងកិច្ចការពារជម្ងឺនេះ ក្រសួងសុខាភិបាលបានធ្វើការណែនាំឱ្យចេះប្រើស្រោមដើម្បីទប់ទល់នឹងការឆ្លងនៃមេរោគHIVនេះ។ ចំពោះការព្យាបាលពុំទាន់មានវិធានការទេ។

**២០០-** បានណែនាំកុមារឱ្យចេះខ្ពុលមាត់ ដុសធ្មេញដោយច្រាស និងចែកច្រាសដុសធ្មេញ និងអប់រំទន្តគិលានុបដ្ឋាកនៅតាមពេទ្យស្រុក។ សព្វថ្ងៃផ្នែកជម្ងឺមាត់ធ្មេញ យើងទើបមានគ្រូពេទ្យជំនាញ១នាក់ប៉ុណ្ណោះ សំរាប់បំរើប្រជារាស្ត្រ ៤០.០០០ នាក់។

**២០១-** ជម្ងឺពកក បណ្តាលមកពីកង្វះជាតិអ៊ីយ៉ូត ក៏មានចំនួនច្រើនគួរឱ្យកត់សំគាល់ដែរ។

**២០២-** ឯជម្ងឺងងឹតភ្នែកបណ្តាលមកពីកង្វះជីវជាតិ A និង បណ្តាលមកពីមូលហេតុផ្សេងៗ ក៏បានជួបប្រទះច្រើនដែរពិសេសលើកុមារ។ សព្វថ្ងៃរាជរដ្ឋាភិបាលបានមានវិធានការឱ្យបង្កើតគណៈកម្មការមួយ ដើម្បីស្រាវជ្រាវ និងការពារជម្ងឺនេះ (១៩៩៤, Healh Activities reprot )។ ការចាក់ថ្នាំបង្ការជម្ងឺ៦មុខដល់កុមារ ភ្នាក់ងារសុខាភិបាលចុះអនុវត្តដល់មូលដ្ឋានភូមិ ឃុំមានសន្ទុះលឿនជាងការព្យាបាល។ ក្នុងការធ្វើការអង្កេតលើបញ្ហាជម្ងឺនេះភ្នាក់ងារសុខាភិបាល ក៏បានចុះដល់មូលដ្ឋានដែរ លើកលែងតែកន្លែងអសន្តិសុខ។

**២០៣-** ក្នុងឆ្នាំ១៩៩៤នេះ រាជរដ្ឋាភិបាលបានបន្តអនុវត្តការងារកម្មវិធីទឹកស្អាតនៅតាមជនបទ ដោយបានជីកអណ្តូង និងតម្លើងស្នប់បានចំនួន ១.៧៧៥ អណ្តូង ឧបត្ថម្ភដោយអង្គការអ៊ុយនីសេហ្វ។ ទន្ទឹមនេះក៏បានអនុវត្តនូវការងារសុខភាពបឋមដោយសង់បង្គន់អនាម័យនិងទិសដៅ ... បង្គន់ជីវឧស្ម័នគំរូបាន ២០កន្លែង ឧបត្ថម្ភដោយអង្គការ LWS និង FAO ( 1994, Gouverment Activites Report )។

**២០៤-** ក្នុងន័យលើកកំពស់គុណភាពព្យាបាល ក្រសួងសុខាភិបាល បានអនុវត្តការងារដូចខាងក្រោម :

- បង្កើនគុណភាពលើកម្មវិធីត្រួតពិនិត្យជម្ងឺឆ្លងក្នុងមន្ទីរពេទ្យ (Infection control )
- បង្កើនគុណភាពលើការបណ្តុះបណ្តាលបុគ្គលិកសុខាភិបាល ខេត្ត, ស្រុក, ឃុំ ដើម្បីផ្សព្វផ្សាយក្បួនព្យាបាលជម្ងឺដែលជួបប្រទះញឹកញាប់។
- ពង្រីកការបំពាក់ឧបករណ៍ដល់មន្ទីរពេទ្យថ្នាក់កណ្តាល ខេត្ត, ស្រុក។
- ពង្រឹងការងារប្រព័ន្ធសង្គ្រោះបន្ទាន់ (SAMU) នៅមន្ទីរពេទ្យកាល់ម៉ែត្រ និងមន្ទីរពេទ្យព្រះកុសុមៈ។

**២០៥-** <u>ការងារសហប្រតិបត្តិការអន្តរជាតិ</u> :

- មុនឆ្នាំ១៩៩៤ : យើងមានអង្គការមនុស្សធម៌ និង អង្គការអន្តរជាតិចំនួនតែ ៥០ទេ ដែលជួយវិស័យសុខាភិបាល។
- ក្នុងឆ្នាំ១៩៩៤ : ចំនួនអង្គការអន្តរជាតិកើនដល់៨២អង្គការ។ ក្រសួងសុខាភិបាលបានបង្កើតឱ្យមានគណៈកម្មការសំរបសំរួលនៅថ្នាក់កណ្តាល “CoCom” និង ថ្នាក់ខេត្ត “Pro CoCom” ដើម្បីសំរបសំរួលជំនួយអន្តរជាតិឱ្យបានសមស្របតាមអាទិភាព និងគោលនយោបាយរបស់ក្រសួងសុខាភិបាល។ សព្វថ្ងៃកំពុងបង្កើតប្រព័ន្ធកត់ត្រាជំនួយអន្តរជាតិដើម្បីឱ្យដឹងពីសកម្មភាពថវិកា និង ទីកន្លែងរបស់អង្គការអន្តរជាតិ ដែលជួយវិស័យសុខាភិបាល។

**២០៦-** <u>ការលំបាក</u> :

- លើការពង្រឹងបណ្តាញគ្រប់គ្រងដោយប្រាក់បំណាច់របស់បុគ្គលិកពុំទាន់គ្រប់គ្រាន់ ។
- សំណង់អភិវឌ្ឍន៍ និងការបំពាក់ឧបករណ៍នៅកន្លែងមួយចំនួនមិនអាចធ្វើបានល្អ ដោយមូលហេតុអសន្តិសុខ។
- សេវាឯកជននៅតាមជនបទមិនទាន់មានការត្រួតពិនិត្យបានល្អ។

- ការអប់រំសុខភាព និងអនាម័យៈការយល់ដឹង និងការអនុវត្តន៍ជាក់ស្តែងរបស់ប្រជាជននៅទាប ។ កិច្ចសហការគ្នានៅធ្វើមិនទាន់បានល្អ ។

- ការប្រយុទ្ធជម្ងឺកាមរោគ និងអេដស៍ជួបការលំបាក ពិសេសការត្រួតពិនិត្យសុខភាពស្ត្រីពេស្យា ។

- ការចាក់ថ្នាំបង្ការនៅកន្លែងអសន្តិសុខ មិនអាចធ្វើបាន ។

- ការផ្សាយពាណិជ្ជកម្ម ឱសថ បារី ស្រាថ្នាំ មានភាពអនាធិបតេយ្យ ។

- ការព្យាបាល : នៅខ្វះអ្នកឯកទេស ។ អាគារពេទ្យ និងសំភារៈបរិក្ខាមិនទាន់មានលក្ខណៈសមស្រប និង តម្រូវការ ។  ខ្វះមធ្យោបាយបញ្ជូនអ្នកជម្ងឺ ។ ខ្វះឱសថព្យាបាល ដោយការនាំចូលមិនបានទាន់ពេលពេលវេលា ។

- ការចុះបេសកកម្មរបស់ភ្នាក់ងារទទួលបានប្រាក់ឧបត្ថម្ភតិចពេក(៥០០០រៀលក្នុង១ថ្ងៃក្នុងម្នាក់) មិនអាចធានាបានក្នុងការស្នាក់អាស្រ័យទេ ។

- សហប្រតិបត្តិការអន្តរជាតិ :

• អង្គការមួយចំនួនមិនព្រមផ្តល់ពត៌មានពីគម្រោងបន្តរបស់ខ្លួនឱ្យបានទាន់ពេលវេលា មុននឹងផុតអាណត្តិ ដែលនាំឱ្យមានការលំបាកដល់ការធ្វើផែនការ ។

• អង្គការមួយចំនួនបន្ថយមុខចំណាយខ្លះៗដោយចំពោះមុខ ថវិកាត្រូវចាយបានទទួលតែបន្តិចបន្តួច

• អង្គការខ្លះបានដកថយជំនួយដោយសារបញ្ហាអសន្តិសុខ ។ គំរោងថវិការសរុបជំនួយអង្គការមិនមែនរដ្ឋាភិបាលបានត្រូវកាត់បន្ថយប្រហែល ៣០% នៅឆ្នាំ ១៩៩៥ ។

- ការងារហិរញ្ញវត្ថុ : ការចំណាយជាក់ស្តែងនៅទាបជាងប្រទេសជិតខាង ៥ ឬ ៦ដង ។

- ការផ្គត់ផ្គង់ឱសថ : ជួបការលំបាកដោយជំនួយធនាគារពិភពលោក ឬធនាគារអាល្លឺម៉ង់ គេផ្តល់ឱ្យយើងយឺតយ៉ាវ ។ ថវិការជួសំរាប់ឱសថយើងយកមកប្រើមិនបាន ដោយក្រសួងហិរញ្ញវត្ថុឱ្យក្រសួងសុខាភិបាលរង់ចាំទូទាត់ជំនួយធនាគារពិភពលោក ។ ការផលិតឱសថអសកម្មដោយខ្វះទុន ។

**២០៧-** ការសន្និដ្ឋាន :

- លទ្ធផលបច្ចេកទេស និងគ្រប់គ្រងឆ្នាំ ១៩៩៤ ទទួលបានលទ្ធផលល្អជាងឆ្នាំ ១៩៩៣ ។ ការចាក់ថ្នាំបង្ការបានអនុវត្តសំរេចតាមកម្មវិធី ។ បានទប់ស្កាត់ទាន់ពេលវេលា និងមានប្រសិទ្ធភាពចំពោះជម្ងឺឆ្លងផ្សេងៗដូចជា គ្រុនឈាម រាគរូស រាគក្អួតខ្លាំង និងគ្រុនចាញ់ជាដើម ។ សេវាថែទាំ " ពិនិត្យ ពិគ្រោះ" និងព្យាបាលជម្ងឺ មានការរីកចំរើន ដោយធ្វើឱ្យអត្រាស្លាប់អ្នកជម្ងឺ ក្នុងមន្ទីរពេទ្យ "គ្រប់វិន័យ" ថយចុះពី៣,២% នាឆ្នាំ១៩៩៣ មកត្រឹម២,៥% នាឆ្នាំ១៩៩៤ ។ ក្រៅពីនេះការងារសហប្រតិបត្តិការអន្តរជាតិក៏អនុវតត្តបានល្អ ។ ឯការអភិវឌ្ឍប្រព័ន្ធពតិមាន និងការគ្រប់គ្រងសុខាភិបាល ក៏ទទួលបានលទ្ធផលគួរឱ្យកត់សំគាល់ដែរ ។

**២០៨-** ទិសដៅ :

- បន្តពង្រឹងការរៀបចំសេវាគ្រប់ថ្នាក់
- បន្តអនុវត្តកម្មវិធីជាតិទាំង ២២ ពិសេសកម្មវិធីជាតិទាក់ទង សុខភាពកុមារ និងមាតា
- លើកកំពស់គុណភាពអ្នកប្រកបវិជ្ជាជីវៈសុខាភិបាលទាំងបច្ចេកទេស និងមនសិកាតាមរយៈការអភិវឌ្ឍធនធានមនុស្ស
- សេវាទ្រទ្រង់ :

- សេវាកម្មឱសថ : សហការជាមួយសាធារណៈរដ្ឋប្រជាមានិតចិន ក្នុងការស្តារ និងអភិវឌ្ឍន៍រោងចក្រឱសថ
- បង្កើនចំនួនមជ្ឈមណ្ឌលផ្តល់ឈាមឱ្យមាននៅតាមខេត្ត ៣ទៀត
- ពង្រឹងសេវារថយន្តគិលានសង្គ្រោះ
- ដាក់ឱ្យអនុវត្តប្រព័ន្ធពតិមានថ្មីនៅទូទាំងប្រទេស ក្នុងដើមឆ្នាំ ១៩៩៥
- កែលំអ នីតិក្រមឱសថសាស្ត្រ វេជ្ជសាស្ត្រ
- បង្កើតវិទ្យាស្ថានសុខភាពសាធារណៈ ដោយសហការជាមួយ AID AB-ADB និង CTZ ។
- អភិវឌ្ឍប្រព័ន្ធគ្រប់គ្រងសុខាភិបាលដោយសហការជាមួយអង្គការសុខភាពពិភពលោក WHO.(ដកស្រង់ពី 1994, Health Activities report) .

## ឃ. <u>សន្តិសុខសង្គម និងសេវាថែទាំសុខភាពកុមារ</u> ( អនុសញ្ញាមាត្រា២៦ និង ១៨)

### ~ <u>បរិបទច្បាប់</u>

**២០៩-** <u>រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា</u> :

មាត្រា៧៣ : រដ្ឋយកចិត្តទុកដាក់ចំពោះកុមារ និងមាតា។ រដ្ឋរៀបចំឱ្យមានទារកដ្ឋាន និងជួយឧបត្ថម្ភនារីដែលមានកូនច្រើនក្នុងបន្ទុក ហើយឥតទីពឹង។

មាត្រា៧៥ : រដ្ឋចាត់ចែងឱ្យមានរបបសន្តិសុខសង្គមដល់កម្មករ និង និយោជិក។

" សេចក្តីណែនាំរបស់ក្រសួងផែនការលេខ១៣០០.ផក.បព. ចុះថ្ងៃទី ១២-៧-៨២ ស្តីពីពេលម៉ោងធ្វើការ និងពេលឈប់សំរាកការងាររបស់កម្មាភិបាល បុគ្គលិក កម្មករ និង សេចក្តីណែនាំលេខ ២៩១.ផក.បព ចុះថ្ងៃទី ១១-២-៨៣ ស្តីពីគោលនយោបាយធានារ៉ាប់រងសង្គមសំរាប់កម្មាភិបាល បុគ្គលិក កម្មករ " ។

### ~ <u>ការអនុវត្ត</u>

**២១០-** ដើម្បីធានាឱ្យមានសន្តិសុខសង្គម រួមទាំងកិច្ចធានារ៉ាប់រងសង្គមផង ក្នុងឆ្នាំ១៩៩៤នេះ រាជរដ្ឋាភិបាលបានបន្តយ៉ាងយកចិត្តទុកដាក់ក្នុងការអនុវត្តការងារធានារ៉ាប់រងសង្គមដល់កុមារ ឪពុកម្តាយកុមារ និងជួយឧបត្ថម្ភ ជីវភាពតាមគ្រួសាររបស់កុមារយ៉ាងសកម្មដោយបាន :

- ឧបត្ថម្ភកូនកំព្រាពីសពមន្ត្រីរាជការ យោធា និង នគរបាលបាន ៣៦៩ នាក់
- សង្គ្រោះទារកកំព្រាដែលគេបានបោះបង់ចោលបាន ៧០ នាក់
- ដោះស្រាយជនអនាថាបាន ១៣២នាក់ និង ចូលរួមឧបត្ថម្ភប្រជារាស្ត្ររងគ្រោះដោយគ្រោះធម្មជាតិបានប្រមាណជាង ៣០.០០០ គ្រួសារ។
- បណ្តុះបណ្តាលមន្ត្រីសង្គមកិច្ច តាមរយៈការចូលរួមក្នុងអង្គសិក្ខាសាលាទាំងក្នុង និងក្រៅប្រទេស។
- ពាក់តែងប្រកាស និងសេចក្តីជូនដំណឹង ដើម្បីណែនាំ និងផ្សព្វផ្សាយច្បាប់ការងារ គោលការណ៍នានា និងធ្វើអធិការកិច្ច តាមសហគ្រាសនានាក្នុងន័យបំពេញតួនាទីដោះស្រាយការងារជូនប្រជាជន។
- ធ្វើទំនាក់ទំនងជាមួយអង្គការអន្តរជាតិនានាឱ្យជួយលើការងារបណ្តុះបណ្តាលមុខវិជ្ជាជីវៈព្រៃកញ្ចៅ និង បានជួយដោះស្រាយគោលនយោបាយចំពោះជនពិការ តាមរយៈការងារស្តារលទ្ធភាពពលកម្ម ផលិតឧបករណ៍សិប្បនិម្មិត។
- អនុវត្តកម្មវិធីស្បៀងជាលក្ខណៈគ្រួសារបាន ៩.៦៦៧គ្រួសារ ក្នុងភូមិ ១៩៩ ឃុំ ៤៧ ស្រុក ២៦ និងខេត្ត ១៤។

- ជីកអណ្តូងទឹកបាន ២៥០ ជីកស្រះបាន ៣.៥០១ ក្នុងនោះរួចជាស្ថាពរបានចំនួន ១.១០៥ស្រះ ។ ជីកស្រះចិញ្ចឹមត្រី (100ម x 100) បាន ១៩កន្លែង។
- បើកវគ្គបំពាក់បំប៉នកសិករឱ្យចេះសាងសង់ និងប្រើប្រាស់បង្កន់ជីវឧស្ម័នគំរូបាន ២០កន្លែង។

" ជំនួយអង្គការLWS(Lutheran World Service) និងFAO (The food and Agricultural Organisatoin)"

- ជួយឧបត្ថម្ភដល់សមាជិក ផ.ស.គ. " ផលិតស្បៀងតាមគ្រួសារ " នូវគ្រាប់ពូជបន្លែ និងចបកាប់ចំនួន៦.៩០០ ផ្លែ។
- អនុវត្តកម្មវិធីទុនអភិវឌ្ឍន៍គ្រួសារបានចំនួន ២.០៣៩ គ្រួសារ សំរាប់របរសិប្បកម្មកែច្នៃ ផលិតកម្មលក់ដូរតូចតាច និងផ្នែកកសិកម្ម។
- ជួយផ្តល់កំលាំងអូសទាញដល់គ្រួសារក្រីក្រក្នុងការងារកសិកម្មបានចំនួន២.០០០នឹម និងបានជួយឧបត្ថម្ភគ្រឿងឧបភោគបរិភោគ ដូចជាអង្ករ សារ៉ុង ក្រមា សំលៀកបំពាក់ផ្សេងៗទៀត ដល់ស្ត្រីមេម៉ាយ ស្ត្រីក្រីក្រ ចំនួន៣២០ គ្រួសារ និងកុមារកំព្រា ៧០នាក់ទៀត។
- ផ្តល់មធ្យោបាយសំភារៈសាងសង់ និងបណ្តុះបណ្តាលដល់មជ្ឈមណ្ឌលអភិវឌ្ឍន៍ និងតាក់តែងច្បាប់ការពារសិទ្ធិស្ត្រី និងកុមារបណ្តុះបណ្តាលផ្នែកភាសា និងបច្ចេកទេសជំនាញការងារដល់មន្ត្រីរាជការក្នុងក្របខ័ណ្ឌកិច្ចការនារី ។
- បណ្តុះបណ្តាលវិជ្ជាជីវៈ " កាត់ដេរ អ៊ុតសក់ ត្បាញកន្ទេល ត្បាញសំពត់ " ដើម្បីដោះស្រាយមុខរបរអាជីវកម្ម បង្កើនប្រភពចំណូល លើកកំពស់កំរិតរស់នៅរបស់គ្រួសារឪពុកម្តាយ កុមារ ក្នុងសង្គមជាតិ (1994, Grovernment Activities) ។

**២១១-** លើផ្នែកសុខភាពសតិអារម្មណ៍ ជាជំហានដំបូងក្រសួងសុខាភិបាល បានរៀបចំដំណើរការសេវាជម្ងឺផ្លូវចិត្ត (Psychiatric services) មួយកន្លែងជាបណ្តោះអាសន្ន នៅក្នុងមន្ទីរពេទ្យសម្តេចព្រះសីហនុវ៉ាននៅភ្នំពេញ។

**២១២-** លើផ្នែកសន្តិសុខកម្មករ : ច្បាប់ការងារចុះថ្ងៃទី ១១. ៨. ១៩៩២ ត្រង់ជំពូក២ ផ្នែកទី៣ មាត្រា២០ និងជំពូក៨ ចាប់ពីមាត្រា២២៤ ដល់២៥១ និងជំពូក៩ ចាប់ពីមាត្រា២៤២ ដល់២៥១ បានដាក់ចេញវិធានការអនាម័យ និងការការពារសន្តិសុខដល់និយោជិក និងអ្នកស៊ីឈ្នួល។ ឯជំពូក៦ ផ្នែកទី៨ ចាប់ពីមាត្រា១៦៩ ដល់១៨៣ ក៏បានចែងអំពីសន្តិសុខកុមារក្រោមអាយុ ១៦ឆ្នាំ ក្រោមអាយុ១៨ឆ្នាំ និងស្ត្រីជាអ្នកស៊ីឈ្នួល។ ឯសកម្មភាពអនុវត្តន៍ជាក់ស្តែងកំពុងដំណើរការជាជំហានៗ។

**២១៣-** ដើម្បីការពារសន្តិសុខ សុវត្ថិភាព សុខភាពដល់ប្រជាពលរដ្ឋទូទៅ ក្នុងការប្រើប្រាស់ឱសថឱ្យបានត្រឹមត្រូវស្របទៅតាមបែបបទវេជ្ជសាស្ត្រ រាជរដ្ឋាភិបាលបានរៀបចំគម្រោងច្បាប់ស្តីពីឱសថ ដែលរដ្ឋសភាជាតិបានអនុម័តកាលពីថ្ងៃទី៩ ខែឧសភា ឆ្នាំ ១៩៩៦។

**២១៤-** លើផ្នែកអនាម័យសិក្សា ក្រុមគ្រូពេទ្យបានពិនិត្យកាយសម្បទាឱ្យដល់កុមាររៀនថ្នាក់ដំបូង មត្តេយ្យសាលា និងបឋមសិក្សា និងបានផ្តល់ឱសថសំរាប់គិលានសង្គ្រោះនៅតាមសាលា។ អនាម័យសិក្សាត្រូវបានធ្វើនៅតាមសាលាជាមួយនឹងការបញ្ចូលទៅក្នុងកម្មវិធីសិក្សាកំរិតបឋម អំពីសុខភាព ការហាត់ប្រាណ អនាម័យខ្លួនប្រាណ និងបរិស្ថាន (1994, Health Activies report) ។

**២១៥-** ក្នុងក្របខ័ណ្ឌកម្មវិធីការងារអាហារូបត្ថម្ភ ក្រសួងសុខាភិបាល បានសហការជាមួយអង្គការហេឡែនឃិល័រ (Hellen Keller) អន្តរជាតិ បើកវគ្គមីក្រូសារជាតិអា ជីវជាតិA បាន១០វគ្គ នៅតាមខេត្ត១៨កន្លែង សំរាប់សិក្ខាកាម៣០នាក់ ក្នុងរយៈពេលពី ៣-៤ថ្ងៃ ក្នុងមួយវគ្គៗ។

**២១៦-** លើការងារទារដ្ឋាន ក្រសួងសុខាភិបាលបានសហការជាមួយរដ្ឋលេខាធិការដ្ឋានកិច្ចការនារី និងដំណាងអង្គការ UNICEF ចូលរួមឧទ្ទេសមនាមក្នុងវគ្គសិក្សាបណ្តុះបណ្តាលអ្នកគ្រូទារកដ្ឋាន និងអ្នកគ្រប់គ្រងទារកដ្ឋានបាន៣វគ្គ សិក្ខាកាម៩៣នាក់ រយៈពេលពី២ ទៅ ៣សប្តាហ៍ ក្នុងមួយវគ្គៗ (1994, Health Activities report) ។

**២១៧-** <u>លើផ្នែកសេវាថែទាំកុមារ</u> :

- ក្នុងឆ្នាំ ១៩៩២ រាជរដ្ឋាភិបាលបានរៀបចំនិងពង្រឹងការងារគ្រប់គ្រងកុមារ ប្រមាណ ២.០០០នាក់ នៅតាមមណ្ឌលថែទាំ និងចិញ្ចឹមកុមារកំព្រា២៤កន្លែង ក្នុងនោះនៅរាជធានីភ្នំពេញមាន៩កន្លែង ដែលបានទទួលចិញ្ចឹមកុមារទៅតាមប្រភេទនីមួយៗ :

- ទារកដ្ឋានសង្គ្រោះទារកកំព្រា ដែលត្រូវគេបោះបង់ចោល និងកុមារអាយុក្រោម ៨ឆ្នាំ
- កូឡាបទី១ និងកូឡាបទី ៣ ចិញ្ចឹមកុមារកំព្រាអាយុពី ៨ឆ្នាំឡើងទៅ
- កូឡាបទី៤ សំរាប់ជនអនាថា ចាស់ជរា ស្ត្រីមេម៉ាយមានកូនច្រើន ជនពិការ និងក្មេងដែលរើសបានតាមចិញ្ចើមថ្នល់
- មណ្ឌលកោះរំដួលសំរាប់ការអប់រំកែប្រែស្ត្រីពេស្យា

**២១៨-** មកដល់ដំណាច់ឆ្នាំ១៩៩៤ កុមារកំព្រា និងកុមារដែលឪពុកម្តាយគ្មានលទ្ធភាពចិញ្ចឹមមានចំនួនច្រើន ប៉ុន្តែក្នុងនេះបានប្រមូលផ្តុំក្នុង ២០មជ្ឈមណ្ឌលរបស់រដ្ឋមានកុមារចំនួន ២.០៤១នាក់ និងក្នុង៦មជ្ឈមណ្ឌលរបស់អង្គការNGO មានកុមារចំនួន ៦៦៨នាក់។ ក្នុងការផ្គត់ផ្គង់ជីវភាពថែទាំសុខភាពកុមារកំព្រាទាំងនេះ រដ្ឋបានកំណត់របបគោលនយោបាយសមស្របទៅតាមលទ្ធភាព និងស្ថានភាពវិវត្តនៃសេដ្ឋកិច្ចជាតិ។ មកដល់ខែកក្កដា ឆ្នាំ១៩៩៤នេះ កុមារទាំងនោះនៅតែត្រូវបានឧបត្ថម្ភពីរាជរដ្ឋា-ភិបាលប្រចាំខែនូវទឹកប្រាក់ :

- កុមារា ១នាក់ : ១២.០០០ រៀល ។
- កុមារី ១នាក់ : ១៣.០០០ រៀល ។

**២១៩-** ចំពោះកុមារកំព្រាដែលបានអនុញ្ញាតឱ្យចេញពីមជ្ឈមណ្ឌលដោយស្របច្បាប់ ត្រូវបានរដ្ឋឧបត្ថម្ភក្នុងការផ្គត់ផ្គង់ជីវភាពជំហានដំបូងចំនួន៤ខែ នៃទឹកប្រាក់ឧបត្ថម្ភប្រចាំខែ។ ដោយឡែក រាជរដ្ឋាភិបាលបានបង្កើតជំរកបណ្តោះអាសន្នមួយកន្លែងទៀតនៅរាជធានីភ្នំពេញ សំរាប់ទទួលជនអនាថារស់នៅតាមចិញ្ចើមថ្នល់ដោយគ្មានទីពឹង ដែលក្នុងនោះមានជនអនាថាពិការ និងស្ត្រីព្រមទាំងកូនរបស់គេ ដែលសរុបទាំងអស់មានចំនួន១៣០នាក់ (ស្ថិតិខែ៨-១៩៩៤, ក្រសួងសង្គមកិច្ច) ដើម្បីផ្គត់ផ្គង់ជីវភាព អប់រំ ថែទាំសុខភាព បណ្តុះបណ្តាលវិជ្ជាជីវៈ និងបង្កលក្ខណៈឱ្យមានមុខរបរ ឬទៅរស់នៅតាមមូលដ្ឋាន។

**២២០-** ក្រៅពីថវិការរដ្ឋផ្តល់ឱ្យប្រចាំខែ កុមារទាំងនេះត្រូវបានរាជរដ្ឋាភិបាលបង្កលក្ខណៈងាយស្រួលដល់អង្គការជាតិ អង្គការអន្តរជាតិ និងសប្បុរសជន ឱ្យចូលមកជួយឧបត្ថម្ភជាសំភារៈ ថវិកា ដល់មជ្ឈមណ្ឌលនានាបន្ថែមទៀត។ ក្នុងឆ្នាំ១៩៩៤មានអង្គការអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាលចំនួន ២២អង្គការ បានជួយដល់វិស័យសង្គមកិច្ច។

**២២១-** <u>ការលំបាក</u> :

- មន្ត្រីសង្គមកិច្ចភាគច្រើនមិនទាន់មានមុខជំនាញ
- គ្រួសារខ្មែរភាគច្រើនមិនបានគិតពីផែនការសំរាប់ជីវភាពរស់នៅ
- ផ្ទៃដីកសិកម្មមិនអាចពង្រីកឱ្យបានទូលាយ ដោយបញ្ហាអសន្តិសុខ និងគ្រាប់មីន

- បញ្ហារកការងារធ្វើសំរាប់យុវជនដែលចេញពីមជ្ឈមណ្ឌលកុមារកំព្រា
- ជំនួយអង្គការអន្តរជាតិ និងអង្គការ NGO នៅមានកំរិត
- មិនទាន់រៀបចំឱ្យមានគោលនយោបាយទូលំទូលាយដល់កុមារ ស្ថិតក្នុងស្ថានភាពលំបាកតាមគ្រួសារ
- បៀវត្សមន្ត្រីរាជការបំរើការងារកុមារនៅទាប
- ខ្វះមធ្យោបាយ សំភារៈ សំរាប់បំរើឱ្យការងារកុមារ ។ ( ប្រភពពីក្រសួងសង្គមកិច្ច)

**២២២-** ទិសដៅការងារដែលនឹងធ្វើនៅពេលខាងមុខ :

- ជម្រុញការលើកស្ទួយកំរិតជីវភាពរស់នៅខាងសេដ្ឋកិច្ចសង្គមកិច្ច និងវប្បធម៌ដល់ប្រជារាស្ត្រជនបទ ដើម្បីបង្ខិតឱ្យជិតគ្នានូវគំលាតរវាងអ្នកក្រ និងអ្នកមាន ។

- រៀបចំគម្រោងសាងសង់មជ្ឈមណ្ឌលស្ត្រី ក្នុងការអភិវឌ្ឍនៅខេត្តកំពង់ចាម បាត់ដំបង តាកែវ កោះកុង និង ពោធិសាត់ ។

- រៀបចំគំរោងសាងសង់ទារកដ្ឋាននៅរដ្ឋលេខាធិការដ្ឋានកិច្ចការនារី និងនៅមជ្ឈមណ្ឌលអភិវឌ្ឍន៍ក្នុងខេត្តកំពង់ស្ពឺ ។

- ជួយឧបត្ថម្ភស្ត្រីមានដើមទុនអាចប្រកបមុខរបរតូចតាចបាន

- ជួយផ្តល់ជំនួយផ្សេងៗដល់ស្ត្រីដែលគ្មានទីលំនៅ និងស្ត្រីដែលជួបប្រទះនឹងសភាវៈអាក្រក់ ។

- ពង្រឹងការអភិវឌ្ឍសេវាកម្មសង្គមកិច្ច ដោយពង្រឹងការអភិវឌ្ឍធនធានមនុស្ស ការអភិវឌ្ឍកម្មវិធី និងរិះរកមធ្យោបាយប្លែកៗដើម្បីមានថវិកា និងធនធានផ្សេងៗ ។

- កសាងគោលការណ៍ផ្សេងៗ ដើម្បីអនុវត្តច្បាប់ការងារ ការធ្វើអធិការកិច្ចលើស្ថាប័នពាក់ព័ន្ធ ។

- ជម្រុញការងារគ្រប់គ្រងឧបត្ថម្ភ ដោះស្រាយ និងបណ្តុះបណ្តាលវិជ្ជាជីវៈដល់ជនពិការ និងគ្រួសារជនពលី (1994, Gouverment Activities report) ។

## ខ-　**កំរិតជីវភាពរស់នៅ**　( អនុសញ្ញាមាត្រា២៧)

### ~ **បរិបទច្បាប់**

**២២៣-** រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា :

មាត្រា៥២ : បានបន្ថែមនៅចុងឃ្លាថា " រដ្ឋយកចិត្តទុកដាក់ជាអទិភាពចំពោះជីវភាពរស់នៅ និងសុខុមាលភាពរបស់ប្រជាពលរដ្ឋ " ។

មាត្រា៦៣ : រដ្ឋយកចិត្តទុកដាក់គ្រប់គ្រងទីផ្សារ ជួយឱ្យជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ មានកំរិតសមរម្យ " ។

### ~ **ការអនុវត្ត**

**២២៤-** សង្គ្រាមវិនាសកម្មជាងពីរទសវត្សនៅកម្ពុជា ពិសេសការបំផ្លិចបំផ្លាញធ្ងន់ធ្ងរនូវទ្រព្យសម្បត្តិ និងអាយុជីវិតមនុស្ស ពីឆ្នាំ១៩៧០ ដល់១៩៧៥ បានជះឥទ្ធិពលយ៉ាងខ្លាំងក្លាដល់កំរិតជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា ពិសេសលើផ្នែកសុខភាព និងជីវភាពរស់នៅរបស់ប្រជាជនកម្ពុជា ។ សេវាសុខាភិបាលពេលនោះបានចុះថយយ៉ាងទាប បើប្រៀបធៀបទៅនឹងប្រទេសជិតខាងកម្ពុជា ។ សុខភាពកុមារ និងប្រជាពលរដ្ឋទូទៅចុះទ្រុឌទ្រោមយ៉ាងខ្លាំង ។ អាយុកាលរំពឹងទុកជាមធ្យមមានកំរិត៤៥ឆ្នាំ ពីឆ្នាំ១៩៦០ ដល់ឆ្នាំ១៩៦៥ បានធ្លាក់ចុះមកត្រឹម៣៥ឆ្នាំ ក្នុងបណ្តាឆ្នាំពី ១៩៧០ ដល់ឆ្នាំ១៩៧៥ ដែលជាអាយុកាលមានកំរិតទាបបំផុតនៅក្នុងពិភពលោក ។ ប៉ុន្តែអាយុកាលរំពឹងទុកជាមធ្យមនេះ មានការប្រែប្រួលឡើងវិញបន្តិចម្តងៗពីទាបមកខ្ពស់ចាប់ពី

ក្រោយឆ្នាំ ១៩៧៩ មកដល់បច្ចុប្បន្ននេះដែលមានប្រមាណ៤៩,៧ឆ្នាំ ហើយអត្រាកំណើតប្រជាជនអាចលើសពី៤០ភាគ ១.000 ដែលជាចំនួនច្រើនបើប្រៀបធៀបទៅនឹងបណ្តាប្រទេសក្នុងទ្វីបអាស៊ី (World Bank November 1993) ។

- <u>ការប្រែប្រួលផ្នែកជីវភាព និងសុខភាពរស់នៅ</u> :

**២២៥-** សេចក្តីត្រូវការថាមពល បានមកពីចំណីអាហារប្រចាំថ្ងៃគិតជាមធ្យម២.៦00កាឡូរី សំរាប់មនុស្សពេញវ័យ "គ្រប់វ័យ" ដែលក្នុងនោះជាតិសាច់៥៥ក្រាម កាល់ស្យូមពី ៤00 ទៅ ៥00ម.ក្រ ជាតិដែក បុរស៩ម.ក្រ ស្ត្រី២៨ម.ក្រ ជីវជាតិអា៧៥0ម.ក្រ និង ជីវជាតិសេ ជាពិសេសបុរស៣0ម.ក្រ (Ministry of Health) ។

**២២៦-** ការអង្កេតក្នុងតំបន់ផ្សេងៗក្នុងប្រទេស បានបង្ហាញឱ្យឃើញជុំវិញអត្រាពី៤% ទៅ៨% នៃកុមារដែលមានអាយុមុនវ័យសិក្សា ត្រូវបានខ្វះចំណីអាហារធ្ងន់ធ្ងរជាមួយនឹងលក្ខណៈវិនិច្ឆ័យមួយអំពីទម្ងន់សំរាប់កំពស់នៅក្រោមអត្រា៨0% [Edc 93 CONCERN,91, MSFHB 91, MPIC 91] UNICEF ។

**២២៧-** ជាង៥0% នៃក្មេងនៅតាមជនបទ នៅតែបៅដោះក្នុងអាយុ ២ឆ្នាំ។ ការផ្តាច់ដោះដោយមូលហេតុគ្មានទឹកដោះ ៧៦.៤% ឯការបំបៅដោះនៅក្រោយអាយុ ២ថ្ងៃ ៥៦,៧% (UNICEF 1994) ។

**២២៨-** នៅឆ្នាំ ១៩៩៣ កំណើតមានទម្ងន់ក្រោម២.៥00ក្រ : ចំនួន១៨% ប្រហាក់ប្រហែលទៅនឹងឆ្នាំ១៩៨៩ : ១៧% [MOH-89] UNICEF ។

**២២៩-** បញ្ហាចំបងខាងអាហាររូបត្ថម្ភនៅកម្ពុជា ដែលកំពុងកើតមានលើស្ត្រី និងកុមារគឺ កង្វះចំណីអាហារ ជាតិសាច់ និងថាមពល និងកង្វះវីតាមីនអា ជាតិដែក និងជាតិអ៊ីយ៉ូត (MOH, 1994) ។

**២៣0-** អាំងស៊ីដង់នៃទារកដែលមានទម្ងន់តិចនៅពេលកើត បង្ហាញពីស្ថានភាពអាហារូបត្ថម្ភដល់កុមារ បណ្តាលមកពីការតមអាហារមិនត្រឹមត្រូវ ចំណីអាហារមួយចំនួនត្រូវហាមឃាត់នៅពេលមានគភ៌ ការងារធ្ងន់ធ្ងរ និង អត្រាឈឺខ្ពស់ដោយសារជម្ងឺ ក្រពះពោះវៀន ដង្កូវព្រូន និងគ្រុនចាញ់។ ក្នុងឆ្នាំ ១៩៩៨ មាន១៦% នៃកុមារក្រោម៥ឆ្នាំ ខ្វះចំណីអាហារកំរិតល្មម និង ៣% កំរិតធ្ងន់។ ថ្មីៗនេះកង្វះអាហាររ៉ាំរ៉ៃនៅកម្ពុជាត្រូវបានរកឃើញ២២% លើកុមារអាយុក្រោម៥ឆ្នាំ នៅរាជធានីភ្នំពេញ និង៣២% នៅតំបន់ផ្សេងៗទៀត។

**២៣១-** ឯកង្វះវីតាមីនអា បានបង្ហាញឱ្យឃើញប្រេវ៉ាឡង់នៃករណីជម្ងឺខ្វាក់មាន់ក្នុងក្រុមមនុស្សអាយុក្រោម៦ឆ្នាំ មានកំរិតខ្ពស់ដូចជានៅតាកែវ ១១% រតនៈគីរី ២១,១% កោះកុង ៥,២% និងពោធិសាត់ ១៥%។

**២៣២-** ជម្ងឺពកកបណ្តាលមកពីកង្វះជាតិអ៊ីយ៉ូត បានបង្ហាញពីប្រេវ៉ាឡង់នៃចំនួនប្រជាជនជាទូទៅ១១% ដែលក្នុងនេះ៨៨% ជាស្ត្រី ( National Health Development plan ) ។

**២៣៣-** តាមការអង្កេតស្រាវជ្រាវធ្វើនៅភ្នំពេញ បានបង្ហាញពីប្រាក់ចំណូលសំរាប់សមាជិកម្នាក់ៗក្នុងគ្រួសារ ក្នុងមួយឆ្នាំ ប្រមាណ ១៥៤ដុល្លាអាមេរិក តិចជាងប្រាក់ចំណាយក្នុងមួយឆ្នាំប្រមាណ១៧៣ដុល្លាអាមេរិក ដែលក្នុងនេះ ការសន្និដ្ឋានចំណាយលើការថែទាំសុខភាពកុមារជាមធ្យមប្រចាំឆ្នាំប្រមាណ១៧.៥0ដុល្លាអាមេរិក (SEEC-1993-1994-UNICEF)។ ២៤% នៃគ្រួសារនៅភ្នំពេញ និង ៤0% នៅតំបន់ជនបទ ត្រូវបានចាត់ទុកថារស់នៅក្រោមជីវភាពក្រីក្រយ៉ាងខ្លាំង (ប្រភព : UNICEF) ។

**២៣៤-** ចាប់ពីឆ្នាំ១៩៩២ ដល់១៩៩៤ រដ្ឋបានឧបត្ថម្ភដល់ប្រជាជនលើផ្នែកសុខភាពសំរាប់១នាក់ ក្នុង១ឆ្នាំ ពី0.៦0ដុល្លា អាមេរិកក្នុងឆ្នាំ១៩៩២ និង0.៨0ដុល្លាអាមេរិកក្នុងឆ្នាំ១៩៩៣ មកដល់ត្រឹម២.២0ដុល្លាអាមេរិកក្នុងឆ្នាំ ១៩៩៤។ បើប្រៀបធៀប

ទៅនឹងប្រទេសជិតខាងនៅឆ្នាំ១៩៩១ សំរាប់ប្រជាជនម្នាក់ ត្រូវបានទទួលការឧបត្ថម្ភពីរដ្ឋប្រចាំឆ្នាំ ឡាវ៤ដុល្លាអាមេរិក វៀតណាម៥.២ដុល្លាអាមេរិក និងថៃ១៥.២ដុល្លាអាមេរិក ឃើញថាកំរិតថែទាំសុខភាព សំរាប់ប្រជាជនកម្ពុជានៅទាបជាងប្រទេសទាំងនេះយ៉ាងច្រើន (1994, Health Activities report) ។

**២៣៥-** ផ្អែកតាមស្ថានភាពប្រវត្តិសាស្ត្រ នយោបាយ ជីវភាព និង សុខភាពខាងលើនេះ អាចសន្និដ្ឋានបានថាកំរិតជីវភាពរស់នៅបច្ចុប្បន្នរបស់ប្រជាជនកម្ពុជា ពិសេសកុមារ ជាទូទៅនៅទាបបើប្រៀបធៀបទៅនឹងប្រទេសនានាក្នុងតំបន់ និងភូមិភាគ។ មូលហេតុជាអទិភាពបណ្តាលមកពីកត្តាច្រើនយ៉ាង ដែលក្នុងនោះគួរឱ្យចាប់អារម្មណ៍ខ្លាំង គឺដោយសារប្រទេសជាតិទើបឆ្លងផុតពីគ្រោះសង្គ្រាមបែកបាក់ វិនាសកម្មរ៉ាំរ៉ៃយូរឆ្នាំ ឯការស្តារ និងអភិវឌ្ឍន៍ប្រទេសជាតិឡើងវិញ ក្រោយពេលបញ្ចប់សង្គ្រាម ទើបត្រូវបានដំណើរការក្នុងរយៈពេលជំហានដំបូង ស្របពេលដែលមានជួបវិបត្តិផ្ទួនៗនៃគ្រោះធម្មជាតិ " ទឹកជំនន់ រាំងស្ងួត " ជារៀងរាល់ឆ្នាំ ។

**២៣៦-** កំរិតជីវភាពមួយសមរម្យ នឹងអាចធានាបានដល់ការរីកចំរើនលូតលាស់ផ្នែករាងកាយ សតិបញ្ញា ស្មារតី សីលធម៌ និងសង្គមរបស់កុមារ និងត្រូវរីកចំរើនទៅមុខដោយត្រូវបោះជំហានយ៉ាងយឺតក្នុងរយៈពេលច្រើនឆ្នាំតទៅទៀត គួបផ្សំនឹងកំលាំងជាតិទាំងមូលត្រូវបានផ្សះផ្សារឹងមាំ ព្រមជាមួយនឹងការបន្តជួយឧបត្ថម្ភគាំទ្រយ៉ាងពេញទំហឹងពីសហគមអន្តរជាតិនានា ដែលមិនអាចខ្វះបាន ទាំងកំលាំងកាយចិត្ត និង សំភារៈ ។

# VII. ការអប់រំ ការលំហែ និងសកម្មភាពវប្បធម៌

**I- ការអប់រំ បញ្ចូលទាំងការអប់រំវិជ្ជាជីវៈ និងការណែនាំ** ( ( អនុសញ្ញាស្តីពីសិទ្ធិកុមារ មាត្រា ២៨ )

**ក. បរិបទច្បាប់**

**២៣៧-** រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣ :

មាត្រា៤៦ : " រដ្ឋ និងសង្គមយកចិត្តទុកដាក់បង្កលក្ខណៈឱ្យនារីដែលគ្មានទីពឹងបានទទួលការឧបត្ថម្ភ ដើម្បីមានមុខ របរមានលទ្ធភាពព្យាបាលជម្ងឺ ឱ្យកូនទៅរៀន......."។

មាត្រា៤៨ : " រដ្ឋធានាការពារសិទ្ធិរបស់កុមារដែលមានចែងក្នុងអនុសញ្ញាស្តីពីកុមារ ជាពិសេសសិទ្ធិមានជីវិតរស់នៅ សិទ្ធិ ទទួលការអប់រំរៀនសូត្រ......"។

មាត្រា៦៦ : " រដ្ឋកសាងប្រព័ន្ធអប់រំមួយពេញលេញ និងឯកភាពនៅទូទាំងប្រទេស ដែលធានាឱ្យបាននូវគោល ការណ៍សេរីភាពខាងសិក្សាធិការ និងសមភាពក្នុងការអប់រំ ដើម្បីឱ្យប្រជាពលរដ្ឋគ្រប់រូបមានភ័ព្វសំណាងគ្រប់គ្រាន់ស្មើគ្នាក្នុងការកសាងជីវិត" ។

មាត្រា៦៨ : " រដ្ឋផ្តល់ការអប់រំផ្នែកបឋមសិក្សា និងមធ្យមសិក្សានៅសាលារៀនសាធារណៈ សំរាប់ប្រជាពលរដ្ឋគ្រប់រូបដោយឥតបង់ថ្លៃ។ ប្រជាពលរដ្ឋត្រូវបានទទួលការអប់រំយ៉ាងតិច ៩ឆ្នាំ....."។

**២៣៨-** ក្រឹតច្បាប់លេខ៣០ក្រ.ច. របស់ក្រុមប្រឹក្សារដ្ឋមន្ត្រី ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ ចុះថ្ងៃទី២០ ខែវិច្ឆិកា ១៩៨៦ ( ជំពូកទី ២ មាត្រា ៣):

"សាលារៀនបឋមសិក្សាមានភារកិច្ចទទួលកុមារ ដែលមានអាយុ៦ឆ្នាំឡើងទៅឱ្យចូលរៀន ហើយខិតខំធ្វើយ៉ាងណាជម្រុញសិស្សទាំងនោះឱ្យរៀនចប់ភូមិសិក្សានេះ" ។

(ជំពូកទី ២ មាត្រា៤ នៃក្រឹត្យច្បាប់ដដែល) : " សាលាមធ្យមសិក្សាកំរិត១ មានភារកិច្ចបណ្តុះបណ្តាលសិស្សានុសិស្សឱ្យមានសមត្ថភាពបំពេញមុខរបរណាមួយ សំដៅធ្វើឱ្យសិស្សដែលរៀនចប់មធ្យមសិក្សាកំរិ១ អាចចេញទៅបំពេញការងារបង្កបង្កើនផល.... អាចបន្តការសិក្សាកំរិត២ចំណេះទូទៅ សាលាមធ្យមសិក្សាឯកទេស សាលាបណ្តុះបណ្តាល វិជ្ជាជីវៈ " ។

(ជំពូក ២, មាត្រា៥ នៃក្រឹត្យច្បាប់ដដែល): " សាលាមធ្យមសិក្សាកំរិត២ មានភារកិច្ចបណ្តុះបណ្តាលសិស្សានុសិស្សមួយផ្នែកដែលរៀនចប់មធ្យមសិក្សាកំរិត១ ឱ្យក្លាយជាសិស្សដែលមានកំរិតចេះដឹង និងសម្បទាសមស្របតាមមុខជំនាញ វិទ្យាសាស្ត្រ និងបច្ចេកទេសដែលរដ្ឋត្រូវការឱ្យបន្តការសិក្សានៅឧត្តមសិក្សាតាមផែនការបណ្តុះបណ្តាលរបស់រដ្ឋ " ។

**២៣៩-** សេចក្តីសំរេចលេខ៤២.សសរ. ស្តីអំពីអាហារូបករណ៍ និងរបបឧបត្ថម្ភអន្តេវាសិក រប់ក្រុមប្រឹក្សារដ្ឋមន្ត្រី ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩១ (ប្រការ១): "កំណត់អាហារូបករណ៍ប្រចាំខែដល់សិស្ស និងនិស្សិតសុទ្ធសាធ ដែលបានសិក្សានៅតាមគ្រឹះស្ថានឧត្តមសិក្សា និងសិក្សាឯកទេស...." ។

អាហារូបករណ៍នេះអនុវត្តតែក្នុងរយៈពេលដែលសិស្ស និស្សិតកំពុងសិក្សាដោយគោរពវិន័យបានល្អ និងខិតខំប្រឹងប្រែងរៀនសូត្របានលទ្ធផលល្អ" ។

(ប្រការ៤ នៃសារាចរនេះដដែល): " លក្ខ័ណ្ឌក្នុងការផ្តល់អាហារូបករណ៍ដល់សិស្ស និស្សិត កំណត់ដូចតទៅ :

១- កូនរបស់យុទ្ធជន កម្មាភិបាល កម្មករ និងពលករពលី

២- សិស្សនិសិត្សដែលរៀនពូកែឆ្នើម

៣- កូនរបស់យុទ្ធជន

៤- កូនកំព្រាឪពុកម្តាយ

៥- កូនជនជាតិភាគតិច នៅតំបន់ព្រៃភ្នំដាច់ស្រយាល

៦- កូនកសិករក្រ

៧- កូនកម្មាភិបាល បុគ្គលិក កម្មករដ្ឋ ដែលឪពុកម្តាយមានជីវភាពរស់នៅជួបការលំបាកពិតប្រាកដ ។

**២៤០-** សេចក្តីសំរេចលេខ១៨១.សសរ.ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩០ របស់ក្រុមប្រឹក្សារដ្ឋមន្ត្រីស្តីពីគោលការណ៍ស្តារលទ្ធភាពពលកម្ម បណ្តុះបណ្តាលវិជ្ជាជីវៈ និង ដោះស្រាយការងារជូនជនពិការ ( ប្រការ ៨) ។

"បណ្តាសាលាចំណេះទូទៅ និង សាលាបណ្តុះបណ្តាលមុខវិជ្ជាជីវៈឯកទេស និងមុខជំនាញ ត្រូវទទួលជនពិការឱ្យចូលរៀនតាមលទ្ធភាព និងសមត្ថភាពរបស់គេ " ។

បច្ចុប្បន្ននេះមានអង្គការមួយចំនួនបានសហការជាមួយរដ្ឋាភិបាលបង្កើតថ្នាក់រៀនសំរាប់កុមារពិការ ដូចជា:

- អង្គការគ្រួសារថ្មី បើកសាលារៀនសំរាប់កុមារពិការភ្នែក មានចំនួន ២៨នាក់
- អង្គការ FFAC បើកមណ្ឌលអប់រំកុមារពិការនៅគៀនឃ្លាំង
- អង្គការNGOមួយចំនួនដែលធ្វើការជាមួយកុមារអនាថា បានបង្កើតកម្មវិធីអប់រំអក្ខរកម្ម អនាម័យ និងផ្តល់វិជ្ជាជីវៈដល់កុមារមួយចំនួនដែលមានបំណងកែប្រែខ្លួន ។

## ខ. <u>មត្តេយ្យសិក្សា និងការអប់រំចំណេះទូទៅ</u>

### . <u>ការអនុវត្ត ចំណុចខ្សោយ និងទិសដៅ</u>

**២៤១-** ក្នុងឆ្នាំសិក្សា ១៩៩៣-១៩៩៤នេះ ចំនួនកុមារមត្តេយ្យកើនឡើងជាងឆ្នាំមុនៗ។ ជារួមកុមារពី ៣ឆ្នាំ ទៅ ៥ឆ្នាំ ចូលរៀនបាន៧,១៦% នៃចំនួនកុមារទាំងអស់ទូទាំងប្រទេស កុមារអាយុ៥ឆ្នាំចំនួន១៥% នៃចំនួនកុមារទាំងអស់ បានចូលកាន់តុមត្តេយ្យសិក្សា។ (របាយការណ៍បូកសរុប និងវាយតម្លៃសភាពការណ៍អប់រំឆ្នាំសិក្សា ១៩៩៣-១៩៩៤)។

**២៤២-** ថ្វីត្បិតតែក្នុងឆ្នាំនេះ ការចូលរៀននៅសាលាមត្តេយ្យរបស់កុមារពីអាយុ៣-៥ឆ្នាំ មានចំនួនគួរឱ្យចាប់អារម្មណ៍ ក៏ដោយក៏យើងសង្កេតឃើញថា នៅមានចំណុចខ្សោយជាច្រើនក្នុងវិស័យនេះ។

- អត្រានៃការចូលរៀននៅមានកំរិតទាបនៅឡើយ បើប្រៀបធៀបទៅនឹងចំនួនកុមារដែលគ្រប់អាយុចូលមត្តេយ្យ ។
- ការសិក្សានៅមានភាពមិនទៀងទាត់នៅឡើយ ដោយសារបញ្ហាជីវភាពគ្រួសារ ជាពិសេសកូនអ្នកស្រែចំការនៅតាមតំបន់ជនបទដាច់ស្រយាល។
- បច្ចេកទេសគរុកោសល្យ នៅមានកំរិតទាបនៅឡើយ។
- សហគមន៍ និងឪពុកម្តាយខ្វះការយល់ដឹងពីសារៈសំខាន់ នៃការអប់រំផ្នែកមត្តេយ្យ ដែលជាមូលដ្ឋានគ្រឹះដល់ការអភិវឌ្ឍកុមារ។
- ខ្វះអាគារសិក្សា និងគ្រូផ្នែកមត្តេយ្យ ភាគច្រើនតែងតែយកគ្រូបឋមមកបង្រៀន ដែលជាហេតុបណ្តាលឱ្យការសិក្សាផ្នែកមត្តេយ្យមានលក្ខណៈជាថ្នាក់បឋម។
- ខ្វះខាតឯកសាររៀន, បង្រៀន និងសំភារៈរៀន បង្រៀន។
- ខ្វះទំនាក់ទំនងរវាងសាលា និងសហគមន៍ ជាពិសេសជាមួយឪពុកម្តាយ អាណាព្យាបាលសិស្សក្នុងការជម្រុញឱ្យបញ្ជូនកូនចៅបានទទួលការសិក្សានៅមត្តេយ្យសាលា។
- មិនទាន់មានប្រព័ន្ធស្ថិតិឱ្យបានត្រឹមត្រូវ និងសមស្របតាមលក្ខណៈបច្ចេកទេស ក្នុងការធ្វើសំរង់ពតិមានពីកុមារដែលដល់វ័យសិក្សានៅសាលាមត្តេយ្យ។

<u>ទិសដៅទៅអនាគត:</u>

**២៤៣-** ដើម្បីដោះស្រាយបញ្ហានេះ ក្រសួងអប់រំយុវជននិងកីឡាព្រះរាជាណាចក្រកម្ពុជា មានទិសដៅដូចតទៅនេះ :

- ធ្វើសំរង់ស្ថិតិកុមារអាយុក្រោម ៦ឆ្នាំឱ្យបានច្បាស់លាស់ត្រឹមត្រូវ ដោយរួមសហការជាមួយអាជ្ញាធរមូលដ្ឋាន។
- ពង្រឹងគុណភាពបច្ចេកទេសគរុកោសល្យ វិធីសាស្ត្របង្រៀន ដើម្បីឱ្យកុមារបានត្រៀមខ្លួនជាស្រេចក្នុងការចូលរៀននៅបឋមសិក្សា តាមរយៈការធ្វើវិក្រិត្យការគ្រូមត្តេយ្យ។ ក្នុងការងារនេះ ក្រសួងអប់រំ យុវជន និងកីឡា ក៏ត្រូវការជំនួយឧបត្ថម្ភពីអង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាលផងដែរ។
- ផ្សព្វផ្សាយពីសារៈសំខាន់ផ្នែកមត្តេយ្យជូនសាធារណៈជនឱ្យបានយល់ដឹង ។
- បង្កើតសមាគមមាតបិតាសិស្ស ដើម្បីទ្រទ្រង់ការសិក្សានៅសាលាមត្តេយ្យ។
- បង្កើនទំនាក់ទំនងរវាងសាលា និងសហគមន៍ ជាពិសេសជាមួយឪពុកម្តាយ ឬអាណាព្យាបាលសិស្សក្នុងការជម្រុញឱ្យបញ្ជូនកូនចៅចូលរៀននៅសាលាមត្តេយ្យ។
- កែលំអកម្មវិធីសិក្សានៅមត្តេយ្យសាលា ឱ្យបានសមស្របតាមនិយាមអន្តរជាតិ ដោយរៀនសូត្រស្រាវជ្រាវកម្មវិធីសិក្សាខាងផ្នែកនេះពីប្រទេសនានា ជាពិសេសប្រទេក្នុងតំបន់ដែលវិស័យនេះកំពុងតែលូតលាស់ខ្លាំង។
- លើកទឹកចិត្ត និងជម្រុញគ្រូមត្តេយ្យ ឱ្យចេះផលិតសំភារៈរៀន បង្រៀន (teaching aids) ដោយប្រើប្រាស់ធនធានដែលមូលដ្ឋានខ្លួនមាន។

- ជម្រុញការពង្រីកសាលាមត្តេយ្យឯកជន និងមត្តេយ្យក្រៅប្រព័ន្ធ។
- ជម្រុញការប្រកួតប្រជែងរវាងមត្តេយ្យសិក្សាសាធារណៈ និងមត្តេយ្យសិក្សាឯកជន។
- ពង្រីកសហការជាមួយអង្គការអន្តរជាតិនានា និងអង្គការមិនមែនរដ្ឋាភិបាលក្នុងការកែលំអប្រព័ន្ធ និងលើកកំពស់មត្តេយ្យសិក្សា។

**២៤៤-** ជាគោលការណ៍ ការសិក្សានៅចំណេះទូទៅក្នុងព្រះរាជាណាចក្រកម្ពុជា ជាការសិក្សាសេរីដោយឥតបង់ថ្លៃ។ សាលារៀនទទួលសិស្សដែលគ្រប់វ័យសិក្សា ឱ្យចូលកាន់តុសិក្សាដោយមិនគិតពីសញ្ជាតិ ភេទ ជំនឿសាសនា។

ក្នុងឆ្នាំសិក្សា ១៩៩៣-១៩៩៤នេះ សិស្សដែលមានអាយុ ៦ឆ្នាំឡើងទៅ មានចំនួន ៨៣% ក្នុងនោះសិស្សស្រី ៤៤,៨៣% បានចូលរៀន ។ នៅមធ្យមសិក្សាកំរិត១ និងកំរិត២ មានសិស្សសរុបទាំងអស់ ២៨៥,៧៧៩នាក់។ (របាយការណ៍បូកសរុប និងវាយតម្លៃ សភាពការណ៍អប់រំ ឆ្នាំសិក្សា ១៩៩៣-១៩៩៤)។

**២៤៥-** ក្នុងការចូលរួមចំណែកលើកស្ទួយគុណភាពអបរំ និងក្នុងការកែប្រែប្រព័ន្ធអប់រំផ្នែកចំណេះទូទៅ អង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាលមួយចំនួន ជាអាទិ៍អង្គការ យូនីសេហ្វ យូណេស្កូ ធនាគារអភិវឌ្ឍន៍អាស៊ី អង្គការរ៉េដបាណា។ល។ បានផ្តល់ជាសំភារៈ និងបច្ចេកទេសសំរាប់ឱ្យការងារនេះមានដំណើរទៅមុខ។ អង្គការយូនីសែហ្វ និងរ៉េដបាណា បានចូលរួមក្នុងការពង្រឹងពង្រីកកម្រងសាលា (School cluster) ដោយជួយសាងសង់ និងជួសជុលអាគារសិក្សា បំពាក់សំភារៈបរិក្ខារដល់សាលាក្នុងកម្រង។ ធនាគារអភិវឌ្ឍអាស៊ីជួយទាំងបច្ចេកទេស និងសំភារៈភាគច្រើនដល់មធ្យមសិក្សា។

អង្គការយូនីសេហ្វ យូណេស្កូ ធនាគារអភិវឌ្ឍអាស៊ី កំពុងតែជួយទាំងផ្នែកបច្ចេកទេស និងសំភារៈក្នុងការកែប្រែកម្មវិធីសិក្សាថ្មី និងក្នុងការតាក់តែងសៀវភៅសិក្សាថ្មី ឱ្យសមស្របទៅតាមនិយាមអន្តរជាតិ ដែលមានគម្រោងថានឹងបញ្ចប់នៅដំណាច់ឆ្នាំ ១៩៩៥នេះ។

**២៤៦-** ថ្វីត្បិតតែរាជរដ្ឋាភិបាល បានខិតខំប្រឹងប្រែងឱ្យការសិក្សាអប់រំនៅប្រទេសកម្ពុជា ឈានជើងទៅមុខឱ្យទាន់ប្រទេសជឿនលឿននានា ជាពិសេសឱ្យទាន់ប្រទេសក្នុងតំបន់ក៏ដោយ ហើយថ្វីត្បិតតែមានជំនួយទាំងបច្ចេកទេសពីរដ្ឋាភិបាល បរទេស អង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាលមួយចំនួនធំក៏ដោយ ក៏ការសិក្សាអប់រំផ្នែកចំណេះទូទៅនៅព្រះរាជាណាចក្រកម្ពុជា នៅតែជួបឧបសគ្គជាច្រើន។

- ថវិការសំរាប់វិស័យអប់រំឆ្នាំ ១៩៩៤មានតែ ១ភាគ១២ នៃថវិកាជាតិទាំងមូល។ កង្វះខាតថវិកានេះជាដើមចមមួយដ៏សំខាន់ដែលធ្វើឱ្យគុណភាពអប់រំមិនទាន់បានលើកកំពស់។
- ថវិកានេះមួយភាគធំសំរាប់ចាយតែលើបុគ្គលិកសិក្សាដែលមានចំនួនប្រហែល៨ម៉ឺននាក់ ឯថវិកាចំណាយសំរាប់សាងសង់អាគារមានតិចតួចណាស់។

  (របាយការណ៍បូកសរុប និងវាយតម្លៃសភាពការណ៍អប់រំ ឆ្នាំសិក្សា ១៩៩៣-១៩៩៤)។
- អាគារសិក្សានៅខ្វះច្រើនជាង១៥,០០០បន្ទប់។ ការខ្វះខាតអាគារនេះមិនអាចឱ្យសាលារៀនអនុវត្តកម្មវិធីសិក្សាពីរពេលបាន។ ម្យ៉ាងទៀតកង្វះខាតអាគារ និងបន្ទប់សិក្សានេះ បណ្តាលឱ្យចំនួនសិស្សច្រើនហួសក្នុងមួយថ្នាក់ៗ ជាពិសេសនៅក្នុងទីក្រុងធំៗ កន្លែងខ្លះសមាសមាត្រគ្រូសិស្សមានរហូតដល់ទៅ ១/៨០។
- ខ្វះសំភារៈរៀន និងបង្រៀន "សៀវភៅអានមានកំរិត"
- ជីវភាពគ្រូបង្រៀនមានសភាពដុនដាប។ ជីវភាពទន់ខ្សោយនេះហើយ ដែលបណ្តាលឱ្យមានការទាវវិភាគទាន ឬការជម្រិតយកលុយពីមាតាបិតាសិស្ស និងពីសិស្សនៅតាមសាលាមួយចំនួន ជាពិសេសសាលានៅទីក្រុងធំៗ ។

ម្យ៉ាងទៀតដោយសារកង្វះខាតជីវភាពនេះភាគច្រើនគ្រូបង្រៀននៅតាមជនបទ ត្រូវបង្ខំចិត្តប្រកបអាជីវកម្មទី២ "លក់ដូររត់ម៉ូតូឌុប ធ្វើស្រែចំការ....." ។ ការបែកអារម្មណ៍ធ្វើការ២-៣មុខនេះហើយ ជាហេតុបណ្តាលឱ្យបង្រៀនមិនចប់កម្មវិធីសិក្សា ឱ្យមានការត្រួតថ្នាក់ច្រើនរហូតដល់៦០% នៅថ្នាក់ទី១ និងជាពិសេសធ្វើឱ្យគុណភាពសិក្សាធ្លាក់ចុះ។ (សេចក្តីកំណត់ហេតុ MEMO របស់នាយកដ្ឋានផែនការ ក្រសួងអប់រំ ថ្ងៃទី២៨ ខែមករា ឆ្នាំ១៩៩៥)។

- ការប្រមូលសិស្សដែលគ្រប់វ័យសិក្សា ឱ្យចូលរៀនមិនធ្វើឡើងបានស្មើៗគ្នាទេ។ នៅតាមទីក្រុងធំៗ សិស្សចូលរៀនមានអត្រា៩៥% នៅតំបន់ដាច់ស្រយាលនៅតំបន់ភ្នំមានតែ៤០% ប៉ុណ្ណោះ។ ចំពោះជនជាតិភាគតិចនៅភូមិភាគឥសានឃើញ មានតែ ៥% នៃកុមារជនជាតិភាគតិច ដែលបានចូលរៀន។
- ថ្វីត្បិតតែក្នុងឆ្នាំសិក្សា១៩៩៣-១៩៩៤នេះ អត្រាបោះបង់ការសិក្សាធ្លាក់ចុះមកនៅត្រឹមតែជាង១% (ឆ្នាំសិក្សា ១៩៩២-១៩៩៣ ជាង៥%)ក៏ដោយ ក៏នៅតំបន់ខ្លះជាពិសេសតំបន់អសន្តិសុខ ការបោះបង់ការសិក្សានៅមានសន្ទុស្សន៍គួរឱ្យព្រួយបារម្ភ។ (របាយការណ៍បូកសរុប និងវាយតម្លៃសភាពការណ៍អប់រំ ឆ្នាំសិក្សា១៩៩៣-១៩៩៤)។ គេបានពិនិត្យឃើញថា កុមារដែលបោះបង់សាលា និងត្រួតថ្នាក់មានប្រហែល៤០%នៃសិស្ស ថ្នាក់ទី១ និងមាន ១៥%នៃសិស្សថ្នាក់ទី៥ (១៩៩២-១៩៩៣)។
- តាមការអង្កេតទទួលបានលទ្ធផលថា គ្រួសារនិមួយៗចំណាយយ៉ាងតិច ១២៣.០០០រៀល ក្នុងមួយឆ្នាំសំរាប់កូនម្នាក់ៗរៀននៅបឋមសិក្សា។ ឧបត្ថម្ភឱ្យសាលា៤៨% ទិញសៀវភៅមើលនឹងសរសេរ៨% រៀនឈ្នួលបន្ថែម ២១,២% និងចំណាយផ្សេងៗ ៤,៩% (របាយការណ៍របស់អង្គការក្រៅរដ្ឋាភិបាល)។

## គ. **ការអប់រំក្រៅប្រព័ន្ធ** (Non Formal Education)

**២៤៧-** ដោយយល់ឃើញថាអនក្ខរភាព ជាឧបសគ្គដ៏ធំធេងក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងអភិវឌ្ឍន៍សតិបញ្ញា មនុស្សដោយចង់រំដោះប្រជាពលរដ្ឋឱ្យរួចផុតពីការអន្តរាយ ដែលបណ្តាលមកពីគ្រោះអវិជ្ជាក្នុងគោលបំណងបន្តកិច្ចការនេះពីសម័យសង្គមរាស្ត្រនិយម រដ្ឋាភិបាលជាណាចក្រកម្ពុជាបានយកចិត្តទុកដាក់យ៉ាងមុតមាំ ក្នុងការជម្រុញចលនាអប់រំមនុស្សចាស់យ៉ាងពេញទំហឹង។ ការបង្កើតការអប់រំក្រៅប្រព័ន្ធនេះ មានគោលបំណងម្យ៉ាងទៀតគឺបំរើដល់ការសិក្សាទាំងអស់គ្នា និងម្យ៉ាងក្នុងគោលបំណងត្រង់យកសិស្សានុសិស្សដែលបោះបង់ការសិក្សា ឬគ្មានលទ្ធភាពសិក្សានៅសាលាចំណេះទូទៅ ដោយខ្វះថវិកាសំរាប់ចំណាយក្នុងការសិក្សានេះ។

មកទល់សព្វថ្ងៃនេះមានថ្នាក់អក្ខរកម្មចំនួន១០៩ និងមានសិស្សអក្ខរកម្មចំនួន២.៨៣២នាក់ ក្នុងនោះមានស្រីចំនួន៩៧១នាក់។ ក្នុងចំនួនអ្នកដែលឆ្លងរួចពីគ្រោះមិនចេះអក្សរចំនួន១០៣៤នាក់ ក្នុងនោះមានស្រី៩៧១នាក់ ។

**២៤៨-** ក្នុងការងារបំពេញវិជ្ជាតាមកម្មវិធីសមមូល សាលាបំពេញវិជ្ជាក្រៅម៉ោងធ្វើការទទួលបានសិក្ខាកាមទាំងអស់១២.៨២២នាក់ និងមធ្យមសិក្សាកំរិត១ ចំនួន១.៤៦៦នាក់ និង មធ្យមសិក្សាកំរិត២ ចំនួន១១.៣៥៦នាក់។ (របាយការណ៍បូកសរុប និងវាយតម្លៃសភាពការណ៍អប់រំឆ្នាំសិក្សា ១៩៩៣-១៩៩៤)។

ពិនិត្យជារួម ការងារអក្ខរកម្មមានការប្រែប្រួលតែនៅកន្លែងណាដែលមានការឧបត្ថម្ភពីអង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាលតែប៉ុណ្ណោះ។ កន្លែងដទៃទៀតដែលខ្វះការឧបត្ថម្ភ នៅតែជួបការលំបាកស្មុគ្រស្មាញដដែល។

ម្យ៉ាងទៀតចំពោះការបំពេញវិជ្ជាតាមកម្មវិធីសមមូល រហូតមកដល់ពេលនេះមានការស្រុតចុះយ៉ាងខ្លាំង ដោយសារកង្វះខាតថវិកាសំរាប់ផ្គត់ផ្គង់បុគ្គលិកបង្រៀន កម្មវិធីសិក្សា និងសៀវភៅសិក្សាមិនទាន់ឆ្លើយតបនឹងតម្រូវការ។

ដូច្នេះហើយទើបរដ្ឋាភិបាលមានទិសដៅដូចតទៅ :

- ធ្វើការជំរឿនអនក្ខរជនឡើងវិញ។
- បង្កើតគណៈកម្មាធិការជាតិអប់រំសំរាប់ទាំងអស់គ្នា។
- រៀបចំប្រែក្លាយសាលាបំពេញវិជ្ជារៀបរយ ឱ្យទៅជាមជ្ឈមណ្ឌលអភិវឌ្ឍន៍ការងារអប់រំក្រៅប្រព័ន្ធ ។
- រៀបចំសិក្ខាសាលាជាតិ ស្តីពីការងារអក្ខរកម្ម ។
- រៀបចំកម្មវិធីអក្ខរកម្មវិជ្ជាជីវៈ។
- កសាងឯកសារបណ្តុះបណ្តាល តាមកម្មវិធីអប់រំសំរាប់ទាំងអស់គ្នា នៅតំបន់អាស៊ី-ប៉ាស៊ីហ្វិក សំរាប់បុគ្គលិកបំពេញវិជ្ជាដើម្បីការអភិវឌ្ឍ ។
- បន្តសហការជាមួយរដ្ឋលេខាធិការដ្ឋានកិច្ចការនារី ក្នុងការពង្រីកចលនាអក្ខរកម្មនារី ។
- បន្តសហការជាមួយអង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាលសំរាប់ការងារអភិវឌ្ឍន៍ ការអប់រំក្រៅប្រព័ន្ធ

## II- <u>**គោលបំណងនៃការអប់រំ**</u> (មាត្រា ២៩នៃអនុសញ្ញា)

~ <u>**បរិបទច្បាប់**</u>

**២៤៩-** <u>ច្បាប់រដ្ឋធម្មនុញ្ញ</u> :

មាត្រា៤៧ : " មាតាបិតាមានកាតព្វកិច្ចចិញ្ចឹមថែរក្សា និងអប់រំកូនឱ្យទៅជាពលរដ្ឋល្អ។ កូនមានករណីកិច្ច ចិញ្ចឹម និងបីបាច់ថែរក្សាមាតាបិតា ដែលចាស់ជរាតាមទំនៀមទំលាប់ខ្មែរ "។

មាត្រា៤៨ : "រដ្ឋគាំពារប្រឆាំងនឹងការងារទាំងឡាយដែលអាចធ្វើឱ្យខូចដល់ការអប់រំ និងការរៀនសូត្ររបស់ កុមារ..."។

មាត្រា៦៧ : រដ្ឋអនុវត្តកម្មវិធីសិក្សា និងគោលការណ៍គរុកោសល្យទំនើប រាប់ចូលទាំងបច្ចេកវិទ្យា និងភាសាបរទេស។

មាត្រា៥៩ : "រដ្ឋត្រូវរក្សាការពារបរិស្ថាន និង តុល្យភាពនៃភោគទ្រព្យធម្មជាតិ ..... " ។ មាត្រាទាំងអស់ក្នុងជំពូក ៣ ស្តីអំពីសិទ្ធិ និងករណីយកិច្ចរបស់ប្រជាពលរដ្ឋខ្មែរ ។

**២៥០-** លិខិតលេខ ១៦២១ អ.រ.វសវ. ចុះថ្ងៃទី ២១ ខែតុលា ១៩៩២ របស់រដ្ឋមន្ត្រីក្រសួងអប់រំ ស្តីពីការបង្រៀនសិទ្ធិមនុស្ស បទ ឧក្រិដ្ឋនៃការប្រល័យពូជសាសន៍ ការបំបាត់រាល់ទំរង់ប្រឆាំងនឹងនារីភេទ សុភាវធម៌ ច្បាប់ចរាចរ សុខភាព និង ចំណីអាហារ។

**២៥១-** លិខិតលេខ ២១ E.RELEX ចុះថ្ងៃ ១២ តុលា ១៩៩៣ ស្តីពីការសិក្សាសិទ្ធិមនុស្សនៅតាមគ្រឹះស្ថានបឋមសិក្សា និង មធ្យមសិក្សា ការកែគុណភាពគ្រូបង្រៀន ក្នុងការបង្រៀនមុខវិជ្ជានេះ ការតាក់តែងសៀវភៅសិក្សាអំពីសិទ្ធិមនុស្ស ។

- <u>**ការអនុវត្ត ចំណុចខ្សោយ និងទិសដៅ**</u>

**២៥២-** ទិសដៅចំបងរបស់រដ្ឋាភិបាល គឺឱ្យប្រជាពលរដ្ឋខ្មែរទាំង២ភេទ មានចំណេះចេះដឹងជ្រៅជ្រះ និងមានឯករាជ្យភាព ក្នុងការប្រកបរបរចិញ្ចឹមជីវិត និងមានចំណេះដឹងបច្ចេកវិទ្យាទំនើបក្នុងការស្តាបនាប្រទេសជាតិ។ ដូច្នេះហើយរដ្ឋាភិបាលបានបង្កើតក្នុងរង្វង់ក្រសួងអប់រំ វិទ្យាស្ថានស្រាវជ្រាវ ដែលមានភារកិច្ចស្រាវជ្រាវរាវរកវិធីសាស្ត្រនានា ដើម្បីឱ្យមានការអភិវឌ្ឍខាងវិស័យអប់រំ ខាងផ្នែកវិទ្យាសាស្ត្រសង្គម និងវិទ្យាសាស្ត្រធម្មជាតិ។ ដោយសហការជាមួយអង្គការយូនីសេហ្វ អង្គការយូណេស្កូ និងអង្គការមិនមែនរដ្ឋាភិបាលផ្សេងទៀត វិទ្យាស្ថាននេះ មានការរៀបចំកម្មវិធីសិក្សាថ្មី និពន្ធសៀវភៅសិក្សាថ្មី គិតគូយ៉ាងណាធ្វើឱ្យផ្នែកសិក្សាអប់រំបានរីកចំរើនឡើង ប្រកបដោយគុណភាព និងប្រសិទ្ធភាព ។

**២៥៣-** នៅឆ្នាំ ១៩៨៥ មានការកែទម្រង់កម្មវិធីសិក្សា ដើម្បីបំពេញសេចក្តីត្រូវការរបស់សិស្សានុសិស្ស និងឆ្លើយតបតាមសំនូមពររបស់សហគមន៍ ។ កម្មវិធីសិក្សាថ្មីឆ្នាំ ១៩៨៥នេះ ធ្វើឡើងស្របពេលនឹងការកែទម្រង់ប្រព័ន្ធសិក្សាពី១០ឆ្នាំ "ឆ្នាំ១៩៧៩" មក១១ឆ្នាំ ។

វត្ថុបំណងកម្មវិធីសិក្សាថ្មីនេះគឺ :

- បង្កើតឱ្យបានឆាប់រហ័សនូវធនធានមនុស្ស
- ធ្វើឱ្យយល់ច្បាស់ពីករណីយកិច្ចពលរដ្ឋ
- ផ្តល់ចំណេះដឹងចាំបាច់សំរាប់បំរើជីវភាពសង្គម
- ផ្តល់ចំណេះដឹងមូលដ្ឋានដល់សិស្សានុសិស្សក្នុងកំរិតបឋមសិក្សា ។

**២៥៤-** ទោះជាមានកំណែទម្រង់កម្មវិធីថ្មីនេះក៏ដោយ ក៏កម្មវិធីនេះនៅមានចំនុចខ្វះខាតច្រើន ដែលត្រូវកែលំអថែមទៀតដូចជាកង្វះខាតទំនាក់ទំនងគ្នា និងពីភាពបន្តគ្នាពីផ្នែកមួយទៅផ្នែកមួយ ពីមេរៀនមួយទៅមេរៀនមួយពីកំរិតមួយទៅកំរិតមួយទៀត ។ ដូច្នេះ ក្នុងរវាងឆ្នាំ១៩៩១-១៩៩៥ ក្រសួងអប់រំ យុវជន និងកីឡា បានចាប់ផ្តើមការកែលំអគុណភាព និងការត្រួតពិនិត្យ អភិវឌ្ឍន៍កាលវិភាគសិក្សា ការកែលំអបណ្តុះបណ្តាលគ្រូបង្រៀន ។

ថ្វីត្បិតតែមានការរៀបចំបណ្តាញដើម្បីលើកស្ទួយគុណភាពសិក្សាអប់រំក៏ដោយ ក៏បណ្តាញទាំងនោះនៅមានការខ្វះខាតច្រើនខាងផ្នែកបរិមាណ និងគុណភាព ។ កង្វះខាតទាំងនោះមាន :

- កង្វះខាតថវិកាសំរាប់ស្រាវជ្រាវរកយុទ្ធវិធី ឬវិធីណាមួយសមស្របសំរាប់ឱ្យការអប់រំនៅស្រុកខ្មែរបានឈានដល់ការអភិវឌ្ឍទាន់ប្រទេសនានាក្នុងតំបន់ ។
- កង្វះខាតបុគ្គលិកបច្ចេកទេសក្នុងការស្រាវជ្រាវតាមប្រធានបទនិមួយៗ ។
- កង្វះខាងសំភារៈ ឯកសារសំរាប់បំរើការស្រាវជ្រាវ ។

ដើម្បីសំរេចបំណងនេះ ក្រសួងអប់រំយុវជន និងកីឡា រួមសហការជាមួយអង្គការយូនីសេហ្វ បង្កើតជាគណៈកម្មការសមត្ថភាពគ្រូបង្រៀន គណៈកម្មការសមត្ថភាពសិស្សលើផ្នែកគណិតវិទ្យា និង ភាសា តាំងតែពីបឋមសិក្សារហូតដល់មធ្យមសិក្សា ក្នុងការងាររៀបចំកែទម្រង់កម្មវិធីសិក្សានេះ ក៏មានអង្គការយូណេស្កូ និង ADB ចូលរួមផងដែរ ។

ក្នុងកម្មវិធីនេះ មានរៀបចំបញ្ចូលការសិក្សាអំពីសិទ្ធិមនុស្ស បរិស្ថាន ចំណីអាហារ ច្បាប់ចរាចរ សីលធម៌ ពលរដ្ឋវិទ្យា ដើម្បីឱ្យសិស្សានុសិស្សស្គាល់ច្បាស់អំពីទីតាំងតួនាទីរបស់ខ្លួនក្នុងសង្គម និងធ្វើជាអ្នកមានអត្ថប្រយោជន៍សំរាប់សង្គម ហើយថ្មីៗនេះ ក្រសួងអប់រំ យុវជន និងកីឡា កំពុងតែរៀបចំបញ្ចូលក្នុងកម្មវិធីសិក្សាអំពីជម្ងឺអេដស៍បន្ថែមទៀត ។

## III- <u>ការលំហែ វិស្សមកាល និង សកម្មភាពវប្បធម៌</u> " អនុសញ្ញាមាត្រា៣១ "

~ **<u>បរិបទច្បាប់</u>**

**២៥៥-** <u>រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ ១៩៩៣</u> :

មាត្រា ៣៥ : " ប្រជាពលរដ្ឋខ្មែរទាំង២ភេទ មានសិទ្ធិចូលរួមយ៉ាងសកម្មក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ប្រទេសជាតិ " ។

មាត្រា ៦៥ :".....រដ្ឋយកចិត្តទុកដាក់ដល់វិស័យអប់រំកាយ និង កីឡា ដែលជាសុខុមាលភាពរបស់ប្រពលរដ្ឋខ្មែរគ្រប់រូប"

មាត្រា ៦៩ : " រដ្ឋមានកាតព្វកិច្ចថែរក្សា និង ពង្រីកវប្បធម៌ជាតិ " ។

~ **<u>ការអនុវត្ត</u>**

**២៥៦-** ដោយមានការខ្វះខាតសំភារៈ និងទុនវិនិយោគ បច្ចុប្បន្ននេះការលំហែសំរាកកាយរបស់កុមារ និងសកម្មភាពវប្បធម៌របស់ពួកគេនៅមិនទាន់បានប្រព្រឹត្តទៅបានល្អ និងបានគ្រប់តំបន់នៅឡើយ ថ្វីត្បិតតែក្រសួងអប់រំយុវជន និងកីឡាបានពង្រាយគណៈកម្មការយុវជន និងកីឡាដល់មូលដ្ឋានជនបទក៏ដោយ ។ ក្នុងសាលារៀននីមួយៗ គេឃើញតែមានការហាត់ប្រាណ និង លេងកីឡាបន្តិចបន្តួចតាមកាលវិភាគសិក្សាប៉ុណ្ណោះ ។ ជួនកាលគេឃើញមានការប្រកួតកីឡារវាងថ្នាក់និងថ្នាក់ ឬរវាងសាលា និងសាលាផងដែរ តែសកម្មភាពនេះមិនទាន់បានផុលផុសនៅឡើយទេ ។

**២៥៧-** ជារួបរាងសាលានីមួយៗ បានបង្កើតជាគណៈកម្មការសិស្ស ដែលមានតាមថ្នាក់នីមួយៗ ក្នុងគោលបំណងការពារផលប្រយោជន៍សិស្ស តែគណៈកម្មការនេះជាពិសេសក្រុមកុមារនៅបឋមសិក្សាមិនទាន់មានលក្ខណៈឯករាជ្យនៅឡើយទេ ព្រោះកិច្ចការភាគច្រើនឋិតនៅក្រោមការបង្គាប់បញ្ជារបស់សាលារៀន ។

**២៥៨-** តាមសាលាខ្លះ ជាពិសេសនៅរាជធានីភ្នំពេញ មានការបង្ហាត់បង្រៀនកុមារឱ្យចេះរបាំ និងសិល្បៈជាតិ ក៏ប៉ុន្តែកម្មវិធីសិល្បៈនេះមិនបានសាយភាយគ្រប់ច្រកល្ហកទូទាំងប្រទេសនៅឡើយ ។ ថ្វីត្បិតតែតាមប្រព័ន្ធឃោសនាខ្លះៗបានបង្កើតឱ្យមាន " នាទីកុមារ " ក៏ដោយ ។

**២៥៩-** នៅឆ្នាំ ១៩៩៤នេះ ក្រុមអង្គការ "គ្រួសារថ្មី" បានយកពិពរណ៍របស់ខ្លួនទៅតាំងបានចំនួន១៤ខេត្ត គេឃើញមានកុមារភាគច្រើនក្នុងចំណោមអ្នកមកទស្សនាពិព័រណ៍នេះ ។

**២៦០-** ប្រទេសកម្ពុជា ជាប្រទេសមួយដែលសំបូរទៅដោយរមណីដ្ឋានប្រវត្តិសាស្ត្រ និងប្រាសាទបូរាណដែលជាព្រលឹង និងតម្លៃវប្បធម៌ជាតិ តែប្រជាពលរដ្ឋខ្មែរភាគច្រើន ជាពិសេសកុមារមិនទាំងស្គាល់ទីតាំងពិតប្រាកដរបស់សម្បត្តិវប្បធម៌ទាំងនេះឡើយ ថ្វីត្បិតតែនៅក្នុងតំបន់ដែលគេរស់នៅពោរពេញទៅដោយវត្ថុទាំងនេះក៏ដោយ ។ដោយសារហេតុនេះហើយ ទើបតាមរយៈសៀវភៅសិក្សាក្តី តាមរយៈទស្សនៈកិច្ចសិក្សា ដែលសាលាមួយបានរៀបចំក្តីកុមារអាចបានស្គាល់ខ្លះៗអំពីវប្បធម៌របស់ជាតិខ្លួន ។

ដោយសារថវិកាសំរាប់ការអប់រំមានស្តួចស្តើង "មួយភាគដប់ពីរនៃថវិកាជាតិទាំងមូល" ការរៀបចំហេដ្ឋារចនាសម្ព័ន្ធសំរាប់ការលំហែរបស់សិស្សានុសិស្សមិនទាន់បានធ្វើនៅឡើយ ។

---

## VIII. វិធានការការពារពិសេស

✵✵✵✵✵✵

**ក.** <u>**កុមារក្នុងស្ថានភាពអាសន្ន**</u>

**១.** <u>**កុមារភៀសខ្លួន**</u> ( អនុសញ្ញាមាត្រា ២២)

**.** <u>**បរិបទច្បាប់**</u> :

**២៦១-** រាជរដ្ឋាភិបាលកម្ពុជាបាលផ្តល់សច្ចាប័នលើអនុសញ្ញាស្តីអំពីជនភៀសខ្លួន និងពិធីសារស្តីពីស្ថានភាពនៃជនភៀសខ្លួន ( ១៩៩២) ។

**២៦២-** រដ្ឋពុំទាន់បានតាក់តែងច្បាប់ទាក់ទងនឹងការងារជនភៀសខ្លួននៅឡើយទេ ។

**.** <u>**ការអនុវត្ត**</u>

២៦៣- នៅក្នុងឆ្នាំ១៩៩៤ ជនភៀសខ្លួន៧៥នាក់ បានចូលមករស់នៅក្នុងកម្ពុជា ដោយមានអន្តរាគមពីអគ្គស្នងការជនភៀសខ្លួននៃអង្គការសហប្រជាជាតិ ក្នុងនោះមានកុមារអាយុក្រោម១៥ឆ្នាំ ចំនួន៦នាក់ ( ១៥ កញ្ញា ១៩៩៥ ) ។

២. **កុមារស្ថិតក្នុងស្ថានភាពជំលោះសព្វាវុធ** ( អនុសញ្ញាមាត្រា ៣៨)

- **បរិបទច្បាប់** :

២៦៤- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា :

មាត្រា៤៨ : រដ្ឋាធានារក្សាការពារសិទ្ធិដែលមានចែងក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារ ជាពិសេសសិទ្ធិមានជីវិតរស់នៅ សិទ្ធិទទួលការអប់រំរៀនសូត្រ សិទ្ធិត្រូវបានទទួលការគាំពារក្នុងស្ថានការណ៍មានសង្គ្រាម ។ ប្រទេសកម្ពុជាបានចូលជាសមជិកនៃអនុសញ្ញា ៤ នៅទីក្រុង Genève ។

២៦៥- អនុស្សរណៈស្តីពីកិច្ចព្រមព្រាងត្រីភាគីជាមួយរាជរដ្ឋាភិបាលថៃ អគ្គស្នងការដ្ឋានសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន និង ក្រុមប្រឹក្សាជាន់ខ្ពស់កម្ពុជា ចុះហត្ថលេខា ២១-១១-១៩៩១ នៅទីក្រុងភ្នំពេញ ស្តីពីការធ្វើមាតុភូមិនិវត្តន៍របស់ជនភៀសខ្លួន និង ជនផ្លាស់ទីលំនៅកម្ពុជាមកពីប្រទេសថៃ ។

២៦៦- ច្បាប់ស្តីពីកាតព្វកិច្ចការពារមាតុភូមិរបស់អតីតរដ្ឋកម្ពុជាបានចែងថា " ពលរដ្ឋភេទប្រុសដែលមានអយុចាប់ពី១៨ឆ្នាំ ដល់ ៣០ឆ្នាំ ដោយពុំប្រកាន់ជំនឿសាសនា ជនជាតិ និងឋានៈក្នុងសង្គម ត្រូវចូលបំរើក្នុងកងទ័ពតាមការកំណត់របស់ច្បាប់នេះ " ។ ចំពោះក្មេងដែលមាន អាយុក្រោម១៨ឆ្នាំ គឺមិនអនុញ្ញាតិឱ្យចូលបំរើក្នុងកងទ័ពទេ ។

- **ការអនុវត្ត**

- កុមារមាតុភូមិនិវត្តន៍ :

២៦៧- តាមកិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីស និងក្រោមការជួយឧបត្ថម្ភពីអគ្គស្នងការសហប្រជាជាតិទទួលបន្ទុកជនភៀសខ្លួន គណៈកម្មាធិការកាកបាទក្រហមអន្តរជាតិ អង្គការនានា ប្រជាពលរដ្ឋខ្មែរប្រមាណ៣៧០.០០០នាក់ ដែលក្នុងនោះមានកុមារចំនួនប្រហែល១៨០.០០០នាក់ ( ៥០ % ) បានធ្វើមាតុភូមិនិវត្តន៍ ។

ការវិលត្រលប់មកកាន់ប្រទេសជាតិជាថ្មីនេះប្រជាពលរដ្ឋខ្លះត្រូវបានបែកគ្រួសារដែលក្នុងនោះមានកុមារ កំព្រាគ្មានទីពឹងប្រហែល៣០០នាក់ ។ ក្រសួងសង្គមកិច្ចរួមសហការជាមួយអង្គការមិនមែនរដ្ឋាភិបាលមួយចំនួនបានទទួលយកកុមារឱ្យទៅរស់នៅក្នុងមជ្ឈមណ្ឌលកុមារសង្គ្រោះ ។ កុមារទាំងនេះបានទទួលការឧបត្ថម្ភរាល់តម្រូវការចាំបាច់ និងទទួលបានការបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីឱ្យពួកគេអាចដោះស្រាយជីវភាពបានដោយខ្លួនឯង ។

២៦៨- អង្គការកាកបាទក្រហមអន្តរជាតិ បានខិតខំស្រាវជ្រាវរកគ្រួសារដែលបែកបាក់គ្នា ។ ចាប់ពីឆ្នាំ ១៩៨៩ ដល់ ១៩៩២ ជាលទ្ធផល៣៦០០គ្រួសារ បានជួបជុំគ្នាវិញ ហើយការងារស្រាវជ្រាវនេះ នៅបន្តដំណើរការទៅទៀត ។

២៦៩- ចំពោះកុមារដែលមានឪពុកម្តាយ ឬអាណាព្យាបាលគេត្រូវបញ្ជូនឱ្យទៅនៅស្រុកកំណើតវិញ ដោយបានទទួលការឧបត្ថម្ភជាផ្ទះសំបែង ដីធ្លី និងបានចូលរៀនក្នុងសាលានានាដូចកុមារក្នុងស្រុកដែរ ។

- កុមារកំព្រា និងកុមារបោះបង់ចោលៈ

២៧០- សង្គ្រាមជាង ២០ឆ្នាំនៅកម្ពុជាបានសន្សល់ទុកកុមារកំព្រាប្រហែល១/១៣ បាត់ឪពុក ឬម្តាយ ។ ក្នុងចំនួននេះមាន១/២ ជាកុមារកំព្រាទាំងឪពុកទាំងម្តាយ ។ ក្នុងនេះដែលហៅថាកុមារកំព្រា គឺកុមារដែលបាត់បង់ឪពុក ឬម្តាយ ឬកុមារដែលត្រូវបាន

ឪពុក ម្ដាយបោះបង់ចោល ។ កុមារមួយចំនួនធំរស់នៅតាមសហគមន៍ ។ កុមារខ្លះបានរស់នៅក្នុងគ្រួសារធូរធា ហើយបានទទួលការឧបត្ថម្ភសមស្រប ។ ប៉ុន្តែកុមារខ្លះមានជីវភាពលំបាកតោកយ៉ាក ខ្លះទៀតមិនត្រូវបានគេចាត់ទុកជាសមាជិកក្នុងគ្រួសារទេ គឺត្រូវធ្វើការគ្រប់បែបយ៉ាងដូចជា ដើរស៊ីឈ្នួលគេ ជួយធ្វើស្រែចំការ លក់ដូរ ឬដើរសុំទានជាដើម ។

**២៧១-** ប្រឈមមុខនិងបញ្ហាអសន្តិសុខ បញ្ហាសេដ្ឋកិច្ចនិងបញ្ហាសង្គម រដ្ឋបានប្រមូលកុមារចំនួន៩៧៤០នាក់ ឱ្យរស់នៅក្នុងមជ្ឈមណ្ឌល ទាំង ២៩ របស់រដ្ឋ ( ប្រភព : ក្រសួងសង្គមកិច្ចការងារ និងអតីតយុទ្ធជនឆ្នាំ ១៩៨១ ) ។

ទន្ទឹមនឹងនេះដែរ រដ្ឋបានអំពាវនាវឱ្យអង្គការនានាជួយឧបត្ថម្ភដល់កុមារក្រៅមជ្ឈមណ្ឌលទៀតផង ។ កុមារក្នុងមជ្ឈមណ្ឌលបានទទួលការអប់រំបណ្ដុះបណ្ដាលឱ្យក្លាយជាពលរដ្ឋល្អ ជាអ្នកមានសមត្ថភាពធ្វើការងារ ជាក់ស្ដែងកុមារ៩២៤នាក់បានចូលបំរើការងាររដ្ឋ ៥៩នាក់ចូលបំរើការងារឯកជន ២៣៣៨នាក់ ចេញទៅរស់នៅជាមួយគ្រួសារវិញ ។

បច្ចុប្បន្ននេះ ក្នុងមជ្ឈមណ្ឌលរដ្ឋមានកុមារចំនួន ២០៤១នាក់ និងក្នុងមជ្ឈមណ្ឌលរបស់អង្គការក្រៅរដ្ឋាភិបាលមាន ៦៦៨នាក់ ។ ថ្វីត្បិតតែចំនួនកុមារក្នុងមជ្ឈមណ្ឌលបានថយចុះ ប៉ុន្តែកុមារកំព្រា និងកុមារបោះបង់ចោល មានកើតឡើងជាបន្តបន្ទាប់ដោយបញ្ហាអសន្តិសុខ និងបញ្ហាសេដ្ឋកិច្ច ។

តាមការប៉ាន់ប្រមាណរបស់អង្គការអ៊ុយនីសែហ្វ មានកុមារអនាថាប្រហែល៥០០០ ទៅ១០.០០០នាក់ក្នុងទូទាំងប្រទេសត្រូវបានឪពុកម្ដាយបោះបង់ចោល ។

**២៧២-** កុមារអនាថាក្នុងក្រុងភ្នំពេញ ភាគច្រើនមកពីខេត្តនានា ។ កុមារទាំងនោះជូនកាលមកជាមួយគ្រួសារ ឬបងប្អូន ជួនកាលរត់ចេញពីផ្ទះដោយសារតែភាពក្រីក្រពេក ឬក៏បណ្ដាលមកពីអំពើហឹង្សាក្នុងគ្រួសារ ។ ជីវភាពកុមារទាំងនោះស្ថិតនៅក្នុងភាពគ្រោះថ្នាក់ និងដុនដាបជាទីបំផុត ។ ប្រឈមមុខនឹងស្ថានភាពបែបនេះ រដ្ឋបានទទួលឱ្យស្នាក់នៅ និងទទួលការអប់រំរៀនសូត្រក្នុងមជ្ឈមណ្ឌលបណ្ដោះអាសន្នរបស់រដ្ឋ និងរបស់អង្គការ ។ ចំពោះគ្រួសារអនាថា រដ្ឋបានបង្កើតគណៈកម្មាធិការអន្តរក្រសួង ដោយបានសហការជាមួយអង្គការជាតិ និងអង្គការក្រៅរដ្ឋាភិបាលដើម្បីដោះស្រាយរឿងនេះ ហើយកម្មវិធីការងារ នឹងត្រូវធ្វើបន្តទៀតដើម្បីធានាថាជនទាំងនេះ និងកុមារអាចរស់នៅ បានក្នុងស្ថានភាពនឹងន់ ។

- កុមារយុទ្ធជន :

**២៧៣-** កុមារយុទ្ធជនដែលមានអាយុតិចជាង១៨ឆ្នាំ មិនត្រូវបានរកឃើញចំនួនច្បាស់លាស់ទេ ។ ប៉ុន្តែមានករណីមួយដែលកុមារបានភូតកុហក់ពីអាយុរបស់ខ្លួន ដើម្បីឱ្យបានចូលបំរើកងទ័ពដោយចង់បានប្រាក់ខែ (របាយការណ៍ឧត្តមស្នងការជនភៀសខ្លួន នៃសហប្រជាជាតិ) ។ ដោយឡែកនៅក្នុងតំបន់កម្ពុជាប្រជាធិបតេយ្យ កុមារយុទ្ធជនប្រហែលជាមានច្រើនព្រោះបញ្ហាកំណែនដែលធ្វើឡើងដោយក្រុម កម្ពុជាប្រជាធិបតេយ្យគេតែងតែចាត់ទុកថាជាការធម្មតា ។

- កុមារភៀសសឹក

**២៧៤-** ក្នុងមួយខែៗចំនួនជនភៀសសឹកមានប្រហែល៥០.០០០នាក់ ដែលត្រូវចេញពីផ្ទះដើម្បីគេចពីគ្រោះថ្នាក់នៃការប៉ះទង្គិចអាវុធ ។ កុមារដែលរស់នៅក្នុងតំបន់នោះត្រូវបង្ខំចិត្តរត់ចោលផ្ទះ ចោលសាលារៀន ហើយគេទាំងនោះបានទទួលតែការឧបត្ថម្ភជំនួយផ្នែកខាងប្រដាប់ប្រដាសំរាប់ស្នាក់នៅ និងចំណីអាហារតែប៉ុណ្ណោះ ។

## ខ- <u>កុមារទំនាស់នឹងច្បាប់</u>

### ១- <u>កុមារ និង ភាពយុត្តិធម៌</u> (អនុសញ្ញាមាត្រា៤០)

#### - <u>បរិបទច្បាប់</u>

២៧៥- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាៈ

មាត្រា៣៨ : ច្បាប់ហាមឃាត់មិនឱ្យមានការរំលោភបំពានលើរូបរាងកាយបុគ្គលណាមួយឡើយ ។ ច្បាប់ការពារជីវិត កិត្តិយស និង សេចក្តីថ្លៃថ្នូររបស់ប្រជាពលរដ្ឋ ។

មាត្រា៣៩ : ប្រជាពលរដ្ឋខ្មែរមានសិទ្ធប្តឹងបរិហារ ប្តឹងតវ៉ា ប្តឹងទារសំណងជួសជុលការខូចខាតបណ្តាលមកពីអំពើខុសច្បាប់ របស់អង្គការរដ្ឋ របស់អង្គការសង្គម និងរបស់បុគ្គលិករបស់អង្គការទាំងនោះ ។

២៧៦- នីតិវិធីព្រហ្មទណ្ឌរបស់ក្រសួងយុត្តិធម៌ឆ្នាំ១៩៩៣ មាត្រា៧៦ ចែងពីការចាត់តាំងដោយឯកឯងនូវមេធាវីដែលធ្វើដោយប្រធាន តុលាការក្នុងករណី :

- ជនរងគ្រោះជាអនីតិជនគ្មានទីពឹង
- ជនជាប់ចោទជាអនីតិជនគ្មានទីពឹង

ក្រៅពីនេះកុមារក៏មានសិទ្ធិដូចជាមនុស្សធំដែរ ក្នុងនីតិវិធីតុលាការ ហើយនីតិវិធីនេះចែងលំអិតក្នុងរបាយការណ៍ ស្តីពីសិទ្ធិស៊ីវិល និងនយោបាយ ។

~ **ការអនុវត្ត**

២៧៧- ច្បាប់រដ្ឋពុំទាន់មានចែងពីការកំរិតអាយុរបស់កុមារ ក្នុងការទទួលខុសត្រូវលើបទឧក្រិដ្ឋដែលកុមារបានប្រព្រឹត្តនៅឡើយ ។

មកដល់ពេលនេះ ប្រទេសកម្ពុជាមិនទាន់មានច្បាប់ពិសេសសំរាប់កុមារដែលប្រព្រឹត្តខុសច្បាប់នៅឡើយ ។ ការអនុវត្តកន្លងមក គឺផ្អែកលើច្បាប់ព្រហ្មទណ្ឌអ៊ុនតាក់ និងច្បាប់នីតិវិធីព្រហ្មទណ្ឌរបស់រដ្ឋកម្ពុជាឆ្នាំ១៩៩៣ ។ ក្រសួងយុត្តិធម៌កំពុងរៀបចំធ្វើច្បាប់ដែលទាក់ទងដល់កុមារប្រព្រឹត្តបទល្មើស និង បង្កើតតុលាការសំរាប់ការពារកុមារប្រព្រឹត្តបទល្មើស ។

២៧៨- ចំពោះកុមារអនាថាមួយចំនួនដែលបានប្រព្រឹត្តអំពើលួច ឆក់ អបាយមុខ បន្ទាប់ពីបានទទួលការអប់រំពីភ្នាក់ងារមានសមត្ថកិច្ច ហើយបានត្រូវដោះលែងឱ្យមានសេរីភាពវិញ ។

២~ **កុមារដែលត្រូវដកហូតសេរីភាព** (អនុសញ្ញាមាត្រា៣៧)

~ **បរិបទច្បាប់**

២៧៩- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាច្រកម្ពុជា :

មាត្រា៣២ : ទោសប្រហារជីវិតមិនមានឡើយ ។

មាត្រា៣៨ : ....ការបង្ខិតបង្ខំ ការធ្វើបាបលើរូបរាងកាយ ឬប្រព្រឹត្តកម្មណាមួយដែលបន្ថែមទម្ងន់ទណ្ឌកម្មអនុវត្តន៍ចំពោះជនជាប់ឃុំឃាំង ឬជាប់ពន្ធនាគារ ត្រូវហាមឃាត់មិនឱ្យធ្វើឡើយ ។ អ្នកដៃដល់អ្នករួមប្រព្រឹត្ត និងអ្នកសមគំនិតត្រូវទទួលទោស តាមច្បាប់ ។

២៨០- ច្បាប់ព្រហ្មទណ្ឌអ៊ុនតាក់ :

មាត្រា១៤ : អនីតិជនអាយុតិចជាង១៣ឆ្នាំ មិនត្រូវជាប់ឃុំឃាំងជាបណ្តោះអាសន្នទេ ។ អនីតិជនដែលមានអាយុពី១៣ទៅ១៨ឆ្នាំ មិនត្រូវជាប់ឃុំឃាំងជាបណ្តោះអាសន្នលើសពី១ខែទេ ។ រយៈពេលនេះអាចទ្វេឡើងជា២ បើសិនជាមានការចោទប្រកាន់ពីបទឧក្រិដ្ឋណាមួយ ។

២៨១- អនុក្រិត្យលេខ១៧អនក្រ. ស្តីពីតួនាទីភារកិច្ចរបស់មជ្ឈមណ្ឌលយុវនីតិសម្បទា ។ មជ្ឈមណ្ឌលនេះមានភារកិច្ចទទួលយកកុមារទណ្ឌិតអាយុពី៧ ដល់១៧ឆ្នាំ ហើយធ្វើការអប់រំឡើងវិញ ។ មជ្ឈមណ្ឌលនេះស្ថិតនៅក្រោមអាណាព្យាបាលរបស់ក្រសួង

យុវនីតិសម្បទា ។

~ **ការអនុវត្ត**

**២៨២-** ក្នុងគោលបំណងដាក់កុមារដែលប្រព្រឹត្តបទល្មើសឱ្យនៅដោយឡែកពីអ្នកទោសមនុស្សចាស់ ឱ្យបានសមស្របតាមបទបញ្ជា ចាំបាច់សំរាប់គ្រប់គ្រងអ្នកទោសនៃសហប្រជាជាតិ និងក្នុងគោលដៅផ្តត់ផ្គង់ អប់រំ ផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈដល់កុមារទាំងនោះឱ្យក្លាយជាមនុស្សល្អ ហើយបញ្ជូនគេឱ្យទៅរស់នៅជាមួយគ្រួសារក្នុងសហគមន៍វិញ រដ្ឋកំពុងរៀបចំមជ្ឈមណ្ឌលមួយដើម្បី ធ្វើនីតិសម្បទាដល់កុមារប្រព្រឹត្តបទល្មើស ។ មជ្ឈមណ្ឌលនេះចាប់ដំណើរការនៅថ្ងៃទី២៨ ខែកក្កដា ឆ្នាំ១៩៩៥ ។ នៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ១៩៩៦ មជ្ឈមណ្ឌលបានទទួលទាំងអស់១៤៧ កុមារ( មាន១នាក់ ជាកុមារី) កុមារ៥៨នាក់បានចាកចេញហើយ ។ ក្នុងនេះមាន៥នាក់ ជាពិរុទ្ធជន ចំណែកកុមារផ្សេងទៀតត្រូវបានឃាត់ខ្លួន និងនាំមកមជ្ឈមណ្ឌលដោយនគរបាល ។ កុមារទាំងនេះអាយុតិចបំផុត ១០ឆ្នាំ ។ ភាគច្រើននៃ កុមារទាំងនេះគឺជាចោរ ហើយមួយចំនួនជាពេស្យាចារ ។ ( របាយការណ៍របស់មជ្ឈមណ្ឌល : ២០-២-១៩៩៦) ។ មជ្ឈមណ្ឌលនេះអាចទទួលបានក្មេងចំនួន១០០នាក់ ។

មានគ្រូពេទ្យម្នាក់ដែលផ្តល់ឱ្យដោយក្រសួងសុខាភិបាល និងមន្ត្រីក្រសួងយុត្តិធម៌មួយនាក់បានចូលរួមបំរើការនៅទីនេះ ព្រមទាំងមាន គណៈកម្មការសំរាប់ពិនិត្យពីលក្ខណៈសម្បត្តិរបស់កុមារ ក្រោយពីការអប់រំ ដើម្បីបញ្ចេញពីមជ្ឈមណ្ឌល ឬក៏ទុកតទៅទៀត ។

៣~ **ការផ្តន្ទាទោសអនីតិជន** ( អនុសញ្ញាមាត្រា៣៧ នៃអនុសញ្ញា)

~ **បរិបទច្បាប់**

**២៨៣-** រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា :

មាត្រា៣២ : ទោសប្រហារជីវិតមិនមានឡើយ ។

មាត្រា៣៨ : ....ការបង្ខិតបង្ខំ ការធ្វើបាបលើរូបរាងកាយ ឬប្រព្រឹត្តកម្មណាមួយដែលបន្ថែមទម្ងន់ទណ្ឌកម្មអនុវត្តន៍ចំពោះជនជាប់ឃុំឃាំង ឬជាប់ពន្ធនាគារ ត្រូវហាមឃាត់មិនឱ្យធ្វើឡើយ ។ អ្នកដែដល់ អ្នករួមប្រព្រឹត្ត និងអ្នកសមគំនិតត្រូវទទួលទោសតាមច្បាប់ ។

**២៨៤-** ច្បាប់ព្រហ្មទណ្ឌអន្តរកាល :

មាត្រា៦៨ : ស្ថានសំរាលទោស និងត្រាប្រណីចំពោះអនីតិជន

១ : ចៅក្រមទាំងឡាយត្រូវគិតដល់ស្ថានសំរាលទោស ដើម្បីបញ្ចុះទោសរហូតដល់ក្រោមអប្បរមានៃទោសដែលមាន ចែងក្នុងបទបញ្ញត្តិនេះ ហើយជាអាទិ៍គឺ :

- យុវភាពនៃអ្នកជាប់ទោស
- ប្រវត្តិរូបផ្ទាល់នៃអ្នកជាប់ទោស ដែលមានលក្ខណៈអាចឱ្យបន្ថយភាពទទួលខុសត្រូវរបស់ខ្លួន
- ស្ថានភាពចិត្តសាស្ត្រ ឬសសៃប្រសាទនៃអ្នកត្រូវចោទ ដោយមានសញ្ញាប័ត្របញ្ជាក់ពីគ្រូពេទ្យខាងសសៃប្រសាទ ឬគ្រូពេទ្យខាងចិត្តសាស្ត្រ
- កាលៈទេសៈនៃអំពើឧក្រិដ្ឋ ឬមជ្ឈិម ដែលបណ្តាលឱ្យអ្នកជាប់ទោសមានប្រតិកម្មដោយខានពុំបាន ។

២ : ចំពោះជនជាប់ចោទដែលមានអាយុតិចជាង១៨ឆ្នាំ ទណ្ឌកម្មដែលមានក្នុងមាត្រាមុនៗ ត្រូវកាត់បន្ថយពាក់កណ្តាល នេះដោយមិនទាន់គិតដល់លក្ខខ័ណ្ឌអនុគ្រោះផ្សេងៗ លើសពីនេះទៀតដែលមាននៅក្នុងបទដ្ឋានកំណត់ ដោយរចនាសម្ព័ន្ធរដ្ឋបាលដែលមានសព្វថ្ងៃ ។

- **ការអនុវត្ត**

**២៨៥-** យោងតាមមាត្រានៃរដ្ឋធម្មនុញ្ញ ទោសប្រហារជីវិតពុំមានទេ ក៏ប៉ុន្តែពុំមានច្បាប់ហាមមិនឱ្យកាត់ទោសដាក់ពន្ធនាគារអស់មួយជីវិតដែរ ។

## គ. កុមារដែលស្ថិតនៅក្រោមការកេងប្រវ័ញ្ចផ្នែកសេដ្ឋកិច្ច

### ១. កុមារពលករ (អនុសញ្ញាមាត្រា ៣២)

- **បរិបទច្បាប់**

**២៨៦-** រដ្ឋធម្មនុញ្ញ :

មាត្រា ៤៨-២ : រដ្ឋគាំពារប្រឆាំងនឹងការងារទាំងឡាយដែលអាចធ្វើឱ្យខូចដល់ការអប់រំ និងការរៀនសូត្ររបស់កុមារ ឬដែលនាំឱ្យអន្តរាយដល់សុខភាព ឬសុខុមាលភាពរបស់កុមារ ។

**២៨៧-** ច្បាប់ការងារ :

មានមាត្រាជាច្រើនចែងអំពីការងាររបស់កុមារ : មាត្រា ១២. ១៣. ៤៦. រហូតដល់ ៥៥. ៦០. ៦៨. ១០០. ដល់ ១០៣. ១៤៧. ១៦៦. ដល់ ១៨៣. ១៩៦. ២១៥. ២១៨. ដល់ ២២២. ២៧៣. និង ២៧៤ ។

មាត្រា ១៧០ : ក្មេងប្រុសអាយុតិចជាង១៨ឆ្នាំ និងស្ត្រីទាំងក្មេងទាំងចាស់អាយុប៉ុន្មានក៏ដោយ មិនអាចប្រើឱ្យធ្វើការនៅអណ្តូងរ៉ែ ឬការយករ៉ែ ឬយកថ្មក្នុងដីឡើយ ។

មាត្រា១៧១ : ក្មេងអាយុតិចជាង ១៨ឆ្នាំ ក៏មិនអាចប្រើឱ្យធ្វើការពេលយប់ក្នុងសហគ្រាសដឹកជញ្ជូនអ្នកដំណើរ........។

មាត្រា១៧៣ : ក្មេងទាំងពីរភេទអាយុតិចជាង១៦ឆ្នាំ មិនអាចឱ្យចូលធ្វើការជាអ្នកស៊ីឈ្នួលនិយោជិក ជាង ឬកូនជាងក្នុងសហគ្រាសណាមួយទេ ទោះប្រភេទណាក៏ដោយ ។ ក៏ប៉ុន្តែត្រូវលើកលែងនូវគ្រឹស្ថានណាដែលមានប្រើសុទ្ធតែសមាជិក នៃគ្រួសារក្រោម អំណាចឪពុកម្តាយក្តី អ្នកអាណាព្យាបាលក្តី ។

- **ការអនុវត្ត**

**២៨៨-** ព្រះរាជាណាចក្រកម្ពុជាមិនខុសពីបណ្តាប្រទេសមួយចំនួននៅក្នុងតំបន់ដែលកំពុងអភិវឌ្ឍ និងប្រទេសដែលទើបចាប់ផ្តើមតម្រង់ទិសសេដ្ឋកិច្ចរបស់ខ្លួនទៅរកសេដ្ឋកិច្ចទីផ្សារឡើយ ។ ភាពក្រីក្រតោកយ៉ាកជាពន់ពេករបស់ប្រជាពលរដ្ឋ កំណើនយ៉ាងឆាប់រហ័សនូវចំនួនប្រជាជន អសន្តិសុខដោយអន្ទើនៅតាមតំបន់ជនបទដាច់ស្រយាល ការផ្លាស់ប្តូរទីលំនៅជាប្រចាំដោយសារប្រពៃណី និងអសន្តិសុខ ឱកាសស្វែងរកការងារនៅតំបន់ទីក្រុងសំខាន់ៗនៃប្រទេស កម្រិតនៃការយល់ដឹងរបស់ឪពុកម្តាយអំពីតម្លៃ និងផលប្រយោជន៍នៃការសិក្សានៅមានកម្រិតទាប ឬគ្មានសោះតែម្តង ស្របពេលដែលគោលនយោបាយ និងការអនុវត្តគោលនយោបាយស្តីពីការអប់រំគ្រប់កម្រិតសិក្សា ពុំទាន់មានលក្ខណៈសកលកម្ម និងទំនើបកម្ម ការអប់រំ និងការបណ្តុះបណ្តាលពុំទាន់ឆ្លើយតបទៅនឹងតម្រូវការនៃទីផ្សារ ហើយនិងជម្រុញការអនុវត្តច្បាប់ពុំទាន់មានប្រសិទ្ធភាពបាន និងកំពុងបន្តធ្វើឱ្យមានការកើនឡើងនៃចំនួនកុមារដែលមានវ័យក្មេងទៅៗចូលរួម និងពាក់ព័ន្ធនៅក្នុងសកម្មភាពផ្គត់ផ្គង់សេដ្ឋកិច្ចគ្រួសារ ទាំងនៅក្នុងបរិបទគ្រួសារ និងសង្គមជំនួសឱ្យការទៅសាលារៀន ។

**២៨៩-** ប្រជាជនកម្ពុជាភាគច្រើនជីវភាពខ្វះខាត ដូច្នេះកុមារត្រូវជួយធ្វើការងារផ្សេងៗ ដើម្បីសំរាលបន្ទុកគ្រួសារ ។ កុមារក្នុងគ្រួសារក្រីក្រ ជាពិសេសគ្រួសារស្ត្រីមេម៉ាយមានកូនច្រើន កុមារត្រូវជួយរកកំរៃដើម្បីចិញ្ចឹមគ្រួសារ ដូចជាជួយធ្វើស្រែចំការ ស៊ីឈ្នួលលីគវ៉ាន់ ។ល។ ហើយកុមារខ្លះទៀតលះបង់ការសិក្សា ដើរសុំទាន ឬកកាយសំរាម។ តាមរបាយការណ៍អង្កេតរបស់ ADB, UNDP និងវិទ្យាស្ថានជាតិ នៃក្រសួងផែនការបានរកឃើញថា កុមារចាប់ពីអាយុ១០ឆ្នាំឡើងទៅត្រូវបានបង្ខំឱ្យជួយធ្វើ

ការ។ មានកុមារតែ២,៤% នៃចំនួនទូទាំង ប្រទេសប៉ុណ្ណោះ ដែលមិនត្រូវបានបង្ខំឱ្យធ្វើការ (របាយការណ៍អ៊ុយនីសេហ្វ Chidren and women situation analysist ) ។

**២៩០-** ដោយការមិនមានការយល់ដឹង និងអើពើចំពោះស្ថានការណ៍គ្រោះថ្នាក់នេះ ឪពុកម្តាយ អាណាព្យាបាល និងកុមារខ្លួនឯងផ្ទាល់មិនបានយកចិត្តទុកដាក់ចាប់អារម្មណ៍ ជួយចូលរួមចំណែកការពារ និងដោះស្រាយបញ្ហាពលកម្មកុមារឡើយ។ ការទទួលខុសត្រូវរបស់ស្ថាប័នរដ្ឋាភិបាលទៀតសោត ជាពិសេសក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន ដែលមានតួនាទីនាំមុខក្នុងការការពារ និងដោះស្រាយបញ្ហានេះ ក៏ស្ថិតនៅក្នុងស្ថានភាពមួយមានកម្រិត អាស្រ័យដោយការខ្វះខាតធនធានចាំបាច់មួយចំនួន ដូចជាកង្វះខាតពត៌មានជាមូលដ្ឋាន កង្វះខាតមន្ត្រីបុគ្គលិកដែលបានទទួលការបណ្តុះបណ្តាលជំនាញជាក់ស្តែង ការខ្វះខាតដ៏ធ្ងន់ធ្ងរនូវថវិកាសម្ភារៈសំរាប់ដំណើរការ។

**២៩១-** ជាមួយនិងកិច្ចខិតខំសហការ និងសហប្រត្តិការជាមួយឯកត្តជន សមាគមន៍ អង្គការក្រៅរដ្ឋាភិបាល និងក្រុមសហគមបាន និងកំពុងធ្វើឱ្យបញ្ហាធ្ងន់ធ្ងរមួយចំនួនត្រូវបានដោះស្រាយ ប៉ុន្តែមិនទាន់គ្រប់គ្រាន់ និងមានប្រសិទ្ធភាពខ្ពស់នៅឡើយអាស្រ័យដោយការយល់ដឹង និងពត៌មាននា ស្តីពីពលកម្មកុមារនៅមានការខ្វះខាត។

**២៩២-** ដោយមើលឃើញពីទំហំគ្រោះថ្នាក់ដ៏ធ្ងន់ធ្ងរនៃបញ្ហាពលកម្មកុមារ រាជរដ្ឋាភិបាល ដែលមានក្រសួងសង្គមកិច្ច ការងារ និង អតីតយុទ្ធជន ជាតំណាង បានចាត់ទុកបញ្ហាការពារ និងលុបបំបាត់ពលកម្មកុមារជាការអាទិភាពមួយរបស់ខ្លួន។

ដើម្បីឱ្យការងារនេះកាន់តែមានប្រសិទ្ធភាពខ្លាំងក្លាថែមទៀតនោះ រាជរដ្ឋាភិបាលដែលមានក្រសួងសង្គមកិច្ចការងារ និងអតីតយុទ្ធជន ជាតំណាង បានស្នើសុំអង្គការការងារអន្តរជាតិ(ILO) បង្កើតផ្នែកពលកម្មកុមារ ប្រចាំខុទ្ទកាល័យរដ្ឋលេខាធិការ ធ្វើការពង្រឹង តួនាទីរបស់ក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន ក្នុងការការពារនិងប្រឆាំងការប្រើប្រាស់ពលកម្មកុមារក្នុងប្រទេសកម្ពុជា។

**២៩៣-** នៅក្នុងខែមករា ឆ្នាំ១៩៩៦ ផ្នែកពលកម្មកុមារបានចាប់ដំណើរការកម្មវិធីសាកល្បងរបស់ខ្លួន។ នៅក្នុងអាណត្តិនៃឆ្នាំទីមួយ នៃការអនុវត្តកម្មវិធីសកម្មភាពស្តីពីការពង្រឹងតួនាទីរបស់ក្រសួងសង្គមកិច្ចការងារ និងអតីយុទ្ធជន ដែលជាដៃគូសំខាន់ទីមួយ ក្នុងការការពារ និងប្រឆាំងការប្រើប្រាស់ពលកម្មកុមារក្នុងប្រទេសកម្ពុជា ដោយផ្តោតយកចិត្តទុក ដាក់លើសកម្មភាពចំបងចំនួនបីគឺ :

១- ការបង្កើតការយល់ដឹង និងការកសាងសមត្ថភាពស្តីពីពលកម្មកុមារនៅក្នុងក្រសួងសង្គមកិច្ចការងារ និងអតីតយុទ្ធជន។

២- ការបង្កើនសមត្ថភាពដល់បណ្តាដៃគូសំខាន់ៗរបស់កម្មវិធីអន្តជាតិ ស្តីពីការលុបបំបាត់ពលកម្មកុមារ (ជាពិសេសអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក) ក្នុងការកសាង ការគ្រប់គ្រង និង ការវាយតម្លៃកម្មវិធីសកម្មភាពពលកម្មកុមារ និង

៣- ការអភិវឌ្ឍផែនការសកម្មភាពដើម្បីឆ្លើយតប និងការពារបញ្ហាពលកម្មកុមារនៅក្នុងប្រទេសកម្ពុជា។

**២៩៤-** តាមរយៈសកម្មភាពដែលត្រូវបានអនុវត្តដោយផ្នែកពលកម្មកុមារនៅក្នុងស្រុកប្រទេសកម្ពុជា ចាប់តាំងពីខែមករា ឆ្នាំ១៩៩៦ រហូតមកដល់ថ្ងៃនេះ បាននិងកំពុងធ្វើឱ្យមានការប្រែប្រួលដ៏ល្អប្រសើរមួយ ដល់ការបង្កើនការយល់ដឹង និងការកសាងសមត្ថភាព ស្តីពីបញ្ហាពលកម្មកុមារដល់ដៃគូសំខាន់ៗរបស់ខ្លួន។

លើសពីនេះទៅទៀត ទោះបីក្រសួងសង្គមកិច្ចការងារ និងអតីតយុទ្ធជនដែលជាដៃគូសំខាន់ទីមួយ ក្នុងការអនុវត្ត កម្មវិធីគំរូនេះ នៅជួបប្រទះការខ្វះខាតប្រភពធនធានចាំបាច់មួយចំនួន ដូចដែលបានគូសបញ្ជាក់ខាងលើក៏ដោយ ក៏កិច្ចសហការ និងសហប្រតិបត្តិការរវាងក្រសួងសង្គមកិច្ចការងារ និងអតីតយុទ្ធជន និងអង្គការILO/IPEC និងធ្វើឱ្យស្ថានភាពរបស់កុមារ កម្ពុជា មានការអភិវឌ្ឍរីកចំរើនក្នុងពេលអនាគត ។

## ២. ការប្រើគ្រឿងញៀន (អនុសញ្ញាមាត្រា ៣៣)

### ~ បរិបទច្បាប់

**២៩៥-** ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធី (អ៊ុនតាក់) :

មាត្រា៣៩ : ជនដែលប្រព្រឹត្តបទល្មើសត្រូវផ្តន្ទាទោសពី៥ ទៅ១៥ឆ្នាំ ចំពោះការផលិត ការដឹកជញ្ជូន ការនាំចូល នាំចេញ រក្សាទុក ជំនួន ការផ្ទេរសម្បត្តិ ការប្រើប្រាស់រុក្ខជាតិមានជាតិពុល គ្រឿងញៀន និងគ្រឿងស្រវឹង ដែលមានរាយក្នុង បញ្ជីរបស់សហប្រជាជាតិ ។

មាត្រា៦៥ : ជនដែលប្រើប្រាស់ផ្ទាល់ខ្លួននូវជាតិពុល គ្រឿងញៀន ឬសារជាតិទាក់ទិន នឹងសរសៃប្រសាទ ត្រូវផ្តន្ទាទោសដាក់ គុកពី១ខែ ទៅ ១ឆ្នាំ ។

### ~ ការអនុវត្ត

**២៩៦-** នៅប្រទេសកម្ពុជា ការប្រើគ្រឿងញៀនដូចជា កញ្ឆា អាភៀន មានតិចតួច រដ្ឋបានចាត់វិធានការទប់ស្កាត់ការប្រើប្រាស់ និងអំពីរត់ពន្ធគ្រឿងញៀន ។ ភាពដែលគួរឱ្យកត់សំគាល់នៅកម្ពុជា គឺការជក់បារី និងការហូរចូលបារីពីបរទេសជាច្រើនលើសលប់ ។ កុមារមួយចំនួន ជាពិសេសកុមារអនាថា និងកុមារនៅតាមជនបទច្រើនតែជក់បារី ។

## ៣. ការជួញដូរ ការកេងប្រវ័ញ្ច និងការរំលោភខាងផ្លូវភេទ

### ~ បរិបទច្បាប់

**២៩៧-** រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា :

មាត្រា៤៦ : អំពើលក់ដូរមនុស្ស អំពើអាជីវកម្មពេស្យាកម្ម និងអំពើអាសអាភាសដែលប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់ នារីត្រូវហាមឃាត់ ។

**២៩៨-** ច្បាប់ព្រហ្មទណ្ឌ និងនីតិវិធី (អ៊ុនតាក់) :

មាត្រា៤២ : ស្តីពីការផ្តន្ទាទោសដល់ជនដែលបៀតបៀនដល់កេរ្តិ៍ខ្មាស់អ្នកដទៃ.... ។

កថាខ័ណ្ឌ ៣ បានចែងថា : នឹងត្រូវផ្តន្ទាទោសដាក់គុកពី២ឆ្នាំ ទៅ៦ឆ្នាំ ចំពោះជនណាដែលល្បួងអូសទាញ ឬបង្វែង គំនិតអនីតិជន ដើម្បីធ្វើពេស្យាចារ ឬធ្វើអាជីវកម្មពេស្យាចារលើអនីតិជន ទោះបីមានការព្រមព្រៀងក៏ដោយ ។

**២៩៩-** ច្បាប់ស្តីពីការបង្ក្រាបអំពើពង្រត់ និងលក់ដូរមនុស្ស និងអំពើធ្វើអាជីវកម្មលើមនុស្ស (១៦ មករា ១៩៩៦) ច្បាប់នេះ បានផ្តន្ទា ទោសដាក់គុកចំពោះជនណាប្រព្រឹត្តអំពើពង្រត់ និងលក់ដូរមនុស្ស ឬយកទៅធ្វើពេស្យាចារ ចំពោះជនជាមេអណ្តើក និងចំពោះជនប្រព្រឹត្ត អនាចារ ។ បើជនរងគ្រោះជាអនីតិជន ការដាក់ទណ្ឌកម្មកាន់តែធ្ងន់ជាង ។

### ~ ការអនុវត្ត

**៣០០-** តាមរបាយការណ៍របស់ការិយាល័យស្នងការនគរបាលព្រហ្មទណ្ឌបានឱ្យដឹងថា ការទទួលពាក្យបណ្តឹងពីការបាត់ក្មេង ប្រមាណ ៥ករណី ក្នុង១ខែ ហើយក្នុងឆ្នាំ១៩៩៤ បានរកឃើញមកវិញតែ២នាក់ប៉ុណ្ណោះ ។

**៣០១-** តាមការសង្កេតនៅរាជធានីភ្នំពេញដោយអង្គការអភិវឌ្ឍនារីនៅឆ្នាំ១៩៩៤ បានឱ្យដឹងថា ក្នុងចំណោមនារីពេស្យាចារ ៣៩៨នាក់ ៣៥%ជាស្ត្រី អាយុពី១៥ ទៅ១៨ឆ្នាំ ហើយ៤៣% ត្រូវឪពុកម្តាយលក់ឱ្យធ្វើពេស្យា ដើម្បីដោះបំណុលគេ ឬត្រូវគេឆបោកយកទៅលក់ (របាយការណ៍វិភាគរបស់យូនីសេហ្វ ១៩៩៤)។

**៣០២-** តាមការអង្កេតរបស់នគរបាល និងមជ្ឈមណ្ឌលសិទ្ធិមនុស្សសហប្រជាជាតិ និងអង្គការសិទ្ធិមនុស្សនានា បានឱ្យដឹងថា មានការជួញដូរកុមារ ហើយបញ្ជូនចេញទៅប្រទេសជិតខាងតាមព្រំដែន (របាយការណ៍វិភាគរបស់យូនីសេហ្វ ឆ្នាំ១៩៩៤)។

**៣០៣-** មានសកម្មភាពពេស្យាកម្មម្យ៉ាងទៀតបានចាប់ផ្តើមមានឡើងនៅកម្ពុជា គឺការល្បួង និងការចាប់យកកុមារទៅប្រព្រឹត្តពេស្យាកម្មជាមួយភ្ញៀវ ជាពិសេសគឺកុមារា។

ដើម្បីជួយដល់កុមារពេស្យាចារ និងរាំងខ្ទប់កុំឱ្យកុមារធ្លាក់ក្នុងអំពីពេស្យាកម្ម រដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាល បានសហការគ្នាលើកម្មវិធីជួយដល់កុមារអនាថា ដើម្បីឱ្យបានរស់នៅក្នុងមជ្ឈមណ្ឌលបណ្តោះអាសន្ន និងទទួលការអប់រំបណ្តុះបណ្តាលឱ្យកុមារយល់អំពីការត្រូវលះបង់អំពើមិនល្អដែលគេបានប្រព្រឹត្ត ហើយទន្ទឹមនេះដែរ អង្គការមួយចំនួនជួយឱ្យកុមារចេញផុតពីបនពេស្យាចារ ហើយមករស់ នៅក្នុងមជ្ឈមណ្ឌល។

ដោយមានការគាំទ្រពីរដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាលមួយចំនួនបានបង្កើតកម្មវិធីECPAT ដើម្បីធ្វើឱ្យមានការយល់ដឹង និងដើម្បីប្រឆាំងការធ្វើពេស្យាកម្ម ជាមួយកុមារតាមរបៀបទេសចរណ៍ ឬតាមប្រការផ្សេងៗទៀត។

## ឃ. <u>**កុមារជាជនជាតិភាគតិច**</u> (អនុសញ្ញាមាត្រា ៣០)

### - <u>**បរិបទច្បាប់**</u>

**៣០៤-** រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា :

មាត្រា៣១ : ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និងករណីកិច្ចដូចគ្នាទាំងអស់ ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សំបុរ ភេទ ភាសា ជំនឿ សាសនា និន្នាការនយោបាយ ដើមកំណើត ជាតិ ឋានៈ សង្គម ធនធាន ឬស្ថានភាពឯទៀតឡើយ។

### - <u>**ការអនុវត្ត**</u>

**៣០៥-** នៅកម្ពុជាមានជនជាតិភាគតិច៧៥.០០០នាក់ ដែលមាន១៦ជនជាតិ និងប្រើភាសារផ្សេងៗគ្នា។ ជនជាតិទាំងនេះមានសិទ្ធិសេរីភាព ដូចមានចែងក្នុងមាត្រា៣១ នៃរដ្ឋធម្មនុញ្ញ។

ដោយជនជាតិភាគតិចច្រើនរស់នៅក្នុងតំបន់ព្រៃភ្នំ តំបន់ដាច់ស្រយាលដែលលក្ខណៈភូមិសាស្ត្រមិនអំណោយផល ការធ្វើស្រែការទំនាក់ទំនង និងសន្តិសុខក៏ពុំទាន់ធានាបាន ដូច្នេះការអភិវឌ្ឍតំបន់នេះមានភាពយឺតយ៉ាវយ៉ាងខ្លាំង។ ប្រជាជនមានជីវភាពក្រលំបាក និងពុំបានទទួលការអប់រំរៀនសូត្រគ្រប់គ្រាន់ដើម្បីទទួលនូវការរីកចំរើនថ្មីៗឱ្យបានសមស្រប។ ម្យ៉ាងទៀតជំនឿសាសនាផ្សេងៗ បានគ្របដណ្តប់យ៉ាងខ្លាំងលើចិត្តគំនិតរបស់ប្រជាជនទាំងនេះ ដែលជាកត្តាមួយរារាំងក្នុងការទទួលយកចំណេះដឹងតាមបែបវិទ្យាសាស្ត្រទំនើប (ពេលឈឺ មានការបន់ស្រន់ មិនសូវមានជំនឿថ្នាំពេទ្យ...។ ដូច្នេះហើយកុមារជនជាតិភាគតិច ពុំបានចូលសាលារៀនគ្រប់ៗគ្នាទេ ក៏រិតបណ្តុះបណ្តាលនៅទាប។ ការថែទាំសុខភាពកុមារពុំសូវបានជិតដល់ការទទួលការឧបត្ថម្ភផ្សេងៗមានតិចតួច។

រដ្ឋាភិបាលកំពុងយកចិត្តទុកដាក់រៀបចំផែនការអភិវឌ្ឍគ្រប់វិស័យ នៅតាមតំបន់ព្រៃភ្នំ ដែលសំបូរជនជាតិភាគតិច។

# IX. សេចក្តីសន្និដ្ឋាន (យោបល់រួម)

*****

៣០៦- ការអនុវត្តនានារបស់ប្រទេសកម្ពុជាលើអនុសញ្ញាស្តីពីសិទ្ធិកុមារ នយោបាយរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបង្ហាញ ពីការទទួលស្គាល់របស់ប្រទេសកម្ពុជា ទៅលើសិទ្ធិរបស់មនុស្សជាទូទៅ និងមួយអន្លើ ទៅលើសិទ្ធិកុមារ ។

៣០៧- នេះមិនមែនជាការមួយដែលថ្មីសុទ្ធសាធសម្រាប់ប្រទេស ឬប្រជាពលរដ្ឋខ្មែរទេ។ ប្រពៃណីទំនៀមទម្លាប់បានអប់រំប្រជាពលរដ្ឋយើងឱ្យចេះគោរពគ្នា សង្គ្រោះគ្នាក្នុងគ្រាអាសន្ន និងជួយគ្នាទៅវិញទៅមក ជាពិសេសឱ្យចេះសន្តោសអត់ឱនដល់អ្នកដែលមានភាពទន់ខ្សោយ ក្នុងនោះមានស្ត្រី កុមារ និងមនុស្សចាស់ជរា។ល។ ម្យ៉ាងទៀតថ្វីត្បិតតែការទទួលស្គាល់អនុសញ្ញាអន្តរជាតិនានារបស់ក្រុមប្រឹក្សាជាតិជាន់ខ្ពស់កម្ពុជា ទើបតែចុះហត្ថលេខានៅឆ្នាំ១៩៩២នេះក៏ដោយ ក៏ការងារសង្គ្រោះជនរងគ្រោះជាពិសេសកុមារដែលស្ថិតនៅក្នុងភាព មានអាសន្ន បានអនុវត្តន៍ជាហូរហែ តាំងពីសម័យមុនសង្គ្រាមមកម្លេះ។

៣០៨- សាលារៀនក្តី មន្ទីរពេទ្យក្តី សេវាកម្មសាធារណៈផ្សេងៗទៀតក្តី បើកទ្វារចំហរសម្រាប់បំពេញសេចក្តីត្រូវការរបស់ប្រជាពលរដ្ឋគ្រប់ប្រភេទ គ្រប់សញ្ជាតិ ដោយអត់បង់ថ្លៃ ហើយការងារនេះបន្តដំណើររហូតមកដល់សព្វថ្ងៃ។

៣០៩- ក៏ប៉ុន្តែសេវាកម្មទាំងនេះមិនបានធ្វើឡើង ឬបំរើបានគ្រប់តំបន់ គ្រប់គ្នានោះទេ ដោយសារតែប្រទេសកម្ពុជាត្រូវទទួលរងគ្រោះ ដោយសង្គ្រាមស៊ីវិលជាងម្ភៃឆ្នាំមកនេះ។ ហេដ្ឋារចនាសម្ព័ន្ធជាតិ មានសាលារៀន ផ្ទះពេទ្យ ផ្លូវថ្នល់..... ត្រូវខ្ទេចខ្ទាំគ្មានសល់។ ការខ្ទេចខ្ទាំការបំផ្លេចបំផ្លាញនេះហើយដែលធ្វើឱ្យការអប់រំប្រជាពលរដ្ឋ ជាពិសេសស្ត្រីនិងកុមារឱ្យយល់ស្គាល់អំពីសិទ្ធិរបស់ខ្លួនដែលប្រទះនឹងការលំបាក។ លំបាកមួយទៀត គឺការត្រួតពិនិត្យលើការអនុវត្ត និងការអនុវត្តសិទ្ធិមនុស្សនៅប្រទេសកម្ពុជា។ ការលំបាកបណ្តាលមកពីជាង២០ឆ្នាំនេះ ប្រជាពលរដ្ឋខ្មែរទោះជាស្ថិតនៅក្នុងសង្គ្រាមក្តី ក្នុងសន្តិភាពក្តី ត្រូវស្ថិតនៅដាច់ឆ្ងាយពីរង្វង់នៃការជឿនលឿន ផ្នែកផ្នត់គំនិត និងក្រមសីលធម៌។ នៅមានប្រជាពលរដ្ឋខ្មែរជាច្រើននាក់ បានកើតឡើងចំពេលដែលស្រុកទេសកំពុងជួបនឹងវិបត្តិធ្ងន់ធ្ងរម្ល៉ោះហើយការបិទទ្វារជិត ឬបិទទំនាក់ទំនង និងពិភពលោកខាងក្រៅ ក្នុងរយៈកាលនៃរបបប្រល័យពូជសាសន៍ ជាកត្តាមួយដ៏សំខាន់ដែលទាក់ទងដល់ការគោរពសិទ្ធិមនុស្ស ជាពិសេសសិទ្ធិកុមារនេះ។

៣១០- បច្ចុប្បន្ននេះយើងមានរាជរដ្ឋាភិបាល ដែលទទួលការគាំទ្រដ៏កុះករពីសំណាក់ប្រជាពលរដ្ឋខ្មែរ មានការទទួលស្គាល់ពីសំណាក់អន្តរជាតិ ទោះបីជាមានការរំខានតាមតំបន់ខ្លះដោយសារក្រុមខ្មែរក្រហមក៏ដោយ ក៏រាជរដ្ឋាភិបាលខិតខំប្រឹងប្រែងធ្វើយ៉ាងណាឱ្យការអនុវត និងការគោរពសិទ្ធិមនុស្ស នៅប្រទេសកម្ពុជា មានការលូតលាស់ដូចប្រទេសប្រជាធិបតេយ្យដទៃទៀតដែរ។

៣១១- ការនេះអាចធ្វើបានក៏អាស្រ័យជំនួយទាំងផ្លូវគំនិត និងផ្លូវសម្ភារៈមកដល់ប្រទេសកម្ពុជាពីសំណាក់សហគមអន្តរជាតិផងដែរ ។

៣១២- សេដ្ឋកិច្ចលូតលាស់ ជីវភាពសម្បូររុងរឿង ជាកត្តាសំខាន់សំរាប់ឱ្យមនុស្សងាកមករកសីលធម៌ អំពើល្អ និងមករកការគោរពគ្នាទៅ វិញ ទៅមក ជាពិសេសគោរពសិទ្ធិរបស់មនុស្សជាតិដូចគ្នា មិនថាចាស់ ក្មេង បុរស ស្ត្រី ជាតិណា សាសន៍ណាឡើយ ។

# ឧបសម្ព័ន្ធ

១- ច្បាប់ការងារ ១៩៩២

២- ច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ ១៩៨៩

៣- ច្បាប់ព្រហ្មទណ្ឌអន្តរកាល ១៩៩៣

៤- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣

៥- អនុក្រិត្យលេខ ១៧ ចុះថ្ងៃទី១៨ ខែមេសា ឆ្នាំ១៩៩៤ ស្តីពីមុខងារ ភារកិច្ច និងរចនាសម្ព័ន្ធរបស់មជ្ឈមណ្ឌល យុវនីតិសម្បទា

៦- អនុក្រិត្យលេខ៨៣ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៥ ស្តីពីការបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ

៧- សេចក្តីណែនាំលេខ៤៧៤ ចុះថ្ងៃទី២ ខែកក្កដា ឆ្នាំ១៩៩៥ របស់ក្រសួងមហាផ្ទៃ ស្តីពីការបង្កើតសមាគម

៨- សេចក្តីប្រកាសអនុវត្តសេចក្តីសំរេចលេខ១៨១ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩០

៩- អនុក្រិត្យលេខ៣០ ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ១៩៨៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ

១០- ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ១៩៩៣

១១- ច្បាប់ស្តីពីការបង្ក្រាបអំពើពង្រត់ និងលក់ដូរមនុស្ស និងអំពើធ្វើអាជីវកម្មលើមនុស្ស (១៦ កុម្ភៈ, ១៩៩៦)

~~~~~~~~~~~~~~~
~~~~~~~~~~~~~~~

# វិធានការអនុវត្តន៍ទូទៅ

*( មាត្រា ៤ ៤២ និង ៤៤ កថាខ័ណ្ឌនៃអនុសញ្ញា )*

***សំនួរទី១ :*** *យោងតាមពត៌មានដែលបានកំណត់ក្នុងកថាខ័ណ្ឌ១ ដល់១១ នៃរបាយការណ៍ដំបូងរបស់ប្រទេសកម្ពុជា សូមបញ្ជាក់ថាតើមានការសិក្សាណាមួយត្រូវបានធ្វើឡើង សំដៅពិនិត្យច្បាប់ជាតិទាំងអស់ឡើងវិញ ឬទេ? ជាពិសេសច្បាប់ទាក់ទងនឹងវិស័យយុត្តិធម៌សំរាប់កុមារការ ថែរក្សាកុមារដោយគ្រួសារ និង ការចុះបញ្ជីអត្រានុកូលដ្ឋាន ដោយពិចារណាទៅលើភាពស្របទៅតាមបទបញ្ញត្តិ និងគោលការណ៍នៃ អនុសញ្ញាសិទ្ធិកុមារ។ សូមបញ្ជាក់បន្ថែមនូវច្បាប់ថ្មីៗផ្សេងទៀតដែលទាក់ទងទៅនឹងសិទ្ធិកុមារ ដែល ចូលជាធរមានតាំងពីពេលបញ្ជូនរបាយការណ៍ ។*

**ចម្លើយ :**

**<u>ច្បាប់ និងអនុក្រឹត្យថ្មីៗ ដែលបានទទួលការអនុម័ត</u>**

បន្ទាប់ពីការរៀបចំ និង ការបញ្ជូនរបាយការណ៍ស្តីពីការអនុវត្តអនុសញ្ញាសិទ្ធិកុមារ ច្បាប់មួយចំនួនដែលពាក់ព័ន្ធទៅនឹង សិទ្ធិកុមារ បានត្រូវអនុម័តដូចមានខាងក្រោម :

| | | |
|---|---|---|
| ១- | ច្បាប់អន្តោប្រវេសន៏ | អនុម័តថ្ងៃទី ២៦ សីហា ១៩៩៤ |
| ២- | ច្បាប់ស្តីពីរបបសារពត៌មាន | អនុម័តថ្ងៃទី ១៨ កក្កដា ១៩៩៥ |
| ៣- | ច្បាប់ស្តីពីការបង្រ្កាបល្បែងស៊ីសង | អនុម័តថ្ងៃទី ៩ មករា ១៩៩៦ |
| ៤- | ច្បាប់ស្តីពីការបង្រ្កាបអំពើចាប់ពង្រត់ និង លក់ដូរមនុស្ស និងអំពើធ្វើអាជីវកម្មលើមនុស្ស | អនុម័តថ្ងៃទី ១៦ មករា ១៩៩៦ |
| ៥- | ច្បាប់ស្តីពីសញ្ជាតិ | អនុម័តថ្ងៃទី ២០ សីហា ១៩៩៦ |
| ៦- | ច្បាប់ស្តីពីការត្រួតត្រាពិនិត្យគ្រឿងញៀន | អនុម័តថ្ងៃទី ៩ វិច្ឆិកា ១៩៩៦ |
| ៧- | ច្បាប់ស្តីពីការងារ | អនុម័តថ្ងៃទី ១០ មករា ១៩៩៧ |
| ៨- | ច្បាប់ស្តីពីលក្ខន្តិកៈទូទៅចំពោះយោធិននៃកងយោធពលខេមរភូមិន្ទ | អនុម័តថ្ងៃទី ១៥ កញ្ញា ១៩៩៧ |
| ៩- | ច្បាប់ស្តីពីការរំលូតកូន | អនុម័តថ្ងៃទី ៦ តុលា ១៩៩៧ |
| ១០- | ច្បាប់ស្តីពីការហាមប្រើប្រាស់គ្រាប់មីនគ្រប់ប្រភេទប្រឆាំងមនុស្ស | អនុម័តថ្ងៃទី ២៨ មេសា ១៩៩៩ |
| ១១- | ច្បាប់ស្តីពីការអនុម័ត យល់ព្រមលើអនុសញ្ញាស្តីពីការហាម ការប្រើប្រាស់ ការរក្សាទុក ការផលិត និង ការផ្ទេរគ្រាប់មីនប្រឆាំងមនុស្ស និង ការបំផ្លាញគ្រាប់មីន | អនុម័តថ្ងៃទី ១៨ ឧសភា ១៩៩៩ |
| ១២- | អនុសញ្ញា ILO លេខ ១៣៨ ស្តីពីអាយុអប្បបរមាសំរាប់ការអនុញ្ញាតិឱ្យធ្វើការងារ | ផ្តល់សច្ចាប័ន ខែ កក្កដា ឆ្នាំ ១៩៩៩ |

បន្ថែមលើនេះទៀត នៅមានអនុក្រឹត្យមួយចំនួនដូចជា :

| | | |
|---|---|---|
| ១- | អនុក្រឹត្យលេខ ៧៤ ស្តីពីសៀវភៅ | អនុម័តថ្ងៃទី ០៤ វិច្ឆិកា ១៩៩៧ |
| ២- | អនុក្រឹត្យលេខ ៧៣ ស្តីពីសៀវភៅស្នាក់នៅ | អនុម័តថ្ងៃទី ០៤ វិច្ឆិកា ១៩៩៧ |

ច្បាប់ និង អនុក្រឹត្យទាំងអស់ខាងលើមាននៅក្នុងឧបសម្ព័ន្ធ ដែលអមមកជាមួយឯកសារនេះ។

**ការពិនិត្យច្បាប់ឡើងវិញ**

ទាក់ទងនឹងការពិនិត្យច្បាប់ឡើងវិញ អគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ(ក.ជ.ក.ក) បានគាំទ្រ និង ចូលរួមមតិយោបល់ក្នុងការសិក្សាប្រៀបធៀបច្បាប់ជាតិទៅនឹងអនុសញ្ញាស្តីពីសិទ្ធិកុមារ ដែលធ្វើដោយអង្គការជំនួយផ្នែកច្បាប់នៃកម្ពុជាក្នុងឆ្នាំ ១៩៩៨ ។ មតិយោបល់ និង អនុសាសន៍ជាច្រើនបានត្រូវលើកឡើងនៅក្នុងសៀវភៅ " **ច្បាប់កម្ពុជា និង អនុសញ្ញាស្តីពីសិទ្ធិកុមារ** " ដែលក្នុងនោះមានលើកឡើងផងដែរនូវចំណុច : ការចុះបញ្ជីអត្រានុកូលដ្ឋាន ( ជំពូក**ឃ** ស្តីពីសិទ្ធិពលរដ្ឋ និងសេរីភាព ទំព័រ ៦២-៦៦ )អាណាព្យាបាល ( ជំពូក**ខ** ស្តីពីបរិយាកាសគ្រួសារ និងការបីបាច់ថែរក្សាចំលាស់ ទំព័រ ១១៦-១១៩ )ផ្នែកយុត្តិធម៌យុវវ័យ ( ជំពូក**ជ** ចំណុច ២ ស្តីពីកុមារដែលរំលោភច្បាប់ ទំព័រ ១៦២-១៧០ )។

ក្រសួងយុត្តិធម៌កំពុងធ្វើសេចក្តីព្រាងក្រមថ្មី គឺក្រមរដ្ឋប្បវេណី និង ក្រមនីតិវិធីរដ្ឋប្បវេណី ដោយមានជំនួយបច្ចេកទេស និង ហិរញ្ញវត្ថុពីអង្គការ JICA។ សេចក្តីព្រាងក្រមនេះ នឹងត្រូវបញ្ចប់នៅឆ្នាំ ២០០២។ ក្រមទាំងពីរនេះ នឹងគ្របដណ្តប់ទៅលើផ្នែកសុំកូន ផ្នែកអាណាព្យាបាលភាព មធ្យោបាយថែរក្សាចំលាស់ គ្រួសារ ការលែងលះ និង ការចុះបញ្ជីជាតិ។ ក្នុងពេលថ្មីៗនេះ ក្រសួងយុត្តិធម៌បានស្នើទៅគណៈរដ្ឋមន្ត្រី ដើម្បីសុំការសំរេចលើសេចក្តីព្រាងក្រមនីតិវិធីព្រហ្មទណ្ឌ ហើយក្រសួងក៏បានធ្វើសេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មីរួចហើយ ដែលកំពុងតែពិនិត្យឡើងវិញ។ សេចក្តីព្រាងក្រមទាំងពីរនេះ គ្របដណ្តប់បញ្ហាមួយចំនួន ទាក់ទងទៅនឹងវិស័យយុត្តិធម៌យុវវ័យ។

សេចក្តីព្រាងក្រមព្រហ្មទណ្ឌគ្របដណ្តប់លើបញ្ហាដូចមាន :

- មាត្រា ៤០២ : ការផ្តល់ទឹកស្រវឹងដល់អនីតិជន
- មាត្រា ៤១៥ : ការរំលោភទំនុកចិត្តលើអនីតិជន
- មាត្រា ៤១៧ : ការទិញលក់អនីតិជន
- មាត្រា ៤១៨ : ការនាំពង្រត់អនីតិជន
- មាត្រា ៤២២ : ការអូសទាញអនីតិជនឱ្យចូលពេស្យាចារ
- មាត្រា ៤២៧ : ការប្រព្រឹត្តអំពើអានាចារ្យលើអនីតិជន
- មាត្រា ៤២៩ និង ៤៣១ : បទអាស្រូវភាសចំពោះមុខនៃអនីតិជន
- មាត្រា ៤៣២ : ការបៀតបៀនកេរ្តិ៍ខ្មាសដល់អនីតិជន
- មាត្រា ៤៣៣ និង ៤៣៤ : ការរំលោភសេពសន្ថវៈលើអនីតិជន
- មាត្រា ៤៤៩ : ការចុះបញ្ជីអត្រានុកូលដ្ឋាននៃទារក
- មាត្រា ៤៥០ និង ៤៥៣ : ការបោះបង់ចោលក្មេង
- មាត្រា ៤៥៤ : ការលួចប្តូរទារក
- មាត្រា ៤៥៥ : ការបង្អត់អាហារទារក
- មាត្រា ៤៥៦ : ការបង្ខំអនីតិជនឱ្យធ្វើការ
- មាត្រា ៤៥៧ : ការមិនឱ្យកុមារទៅសាលារៀន
- មាត្រា ៤៦២ : ការមិនព្រមបង់អាហារកិច្ចចិញ្ចឹមកូនមានអាយុមិនទាន់គ្រប់ការ
- មាត្រា ៤៨៣ : ការចំលងជំងឺអេដស៍ ឬ ជំងឺឆ្លងតាមការសេពសន្ថវៈចំពោះអនីតិជន

ទោះបីជាសេចក្តីព្រាងក្រមស្តីពីនីតិវិធីព្រហ្មទណ្ឌពុំបានកំណត់អំពីនីតិវិធី និងតុលាការពិសេសសំរាប់កិច្ចការកុមារក៏ដោយ ក៏សេចក្តីព្រាងនេះ តម្រូវឱ្យមានអ្នកមានវិជ្ជាជីវៈ ដើម្បីដោះស្រាយបញ្ហាទាក់ទងនឹងកុមារដែរ ។

សេចក្តីព្រាងច្បាប់សុំកូន ត្រូវបានរៀបចំឡើងដោយក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ដោយមានជំនួយបច្ចេកទេសពី អង្គការយូនីសេហ្វ និង**OHCHR**។ សេចក្តីព្រាងច្បាប់នេះ ស្របទៅនឹងអនុសញ្ញាស្តីពីសិទ្ធិកុមារ និង អនុសញ្ញាទីក្រុងឡាអេ ស្តីពីកិច្ចការពារកុមារ និង កិច្ចសហប្រតិបត្តការ ទាក់ទងនឹងសុំកូនអន្តរប្រទេស ថ្វីត្បិតប្រទេសកម្ពុជាមិនទាន់បានចូលជាសមាជិកនៅឡើយក៏ដោយ។ សេចក្តីព្រាងនេះនឹងត្រូវបញ្ចប់ ហើយនឹងដាក់ជូនគណៈរដ្ឋមន្ត្រីពិនិត្យក្នុងឆមាសទី១ ឆ្នាំ២០០០ នេះ ។

រាជរដ្ឋាភិបាលក៏កំពុងពិចារណាផងដែរ អំពីការផ្តល់សច្ចាប័នលើអនុសញ្ញា ILO លេខ ១៨២ ឆ្នាំ ១៩៩៩ ពាក់ព័ន្ធទៅនឹងការហាមប្រាមនឹងការលុបបំបាត់ជាបន្ទាន់នូវទំរង់ធ្ងន់ធ្ងរនៃពលកម្មកុមារ ព្រមទាំងអនុសញ្ញាក្រុងឡាអេ ឆ្នាំ១៩៨០ ស្តីពីទិដ្ឋភាពស៊ីវិលនៃការពង្រត់កុមារជាអន្តរជាតិ ។

ដើម្បីធានាឱ្យសេចក្តីព្រាងក្រមដែលបានពោលខាងលើ ក៏ដូចជាសេចក្តីព្រាងច្បាប់ផ្សេងៗទៀត ស្របទៅនឹងស្មារតីនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ នឹងបង្កើតអនុគណៈកម្មការមួយ ដើម្បីចូលរួមពិនិត្យសេចក្តីព្រាងក្រម និងច្បាប់ទាំងនោះ ហើយជូនយោបល់ដើម្បីឱ្យមានការពិនិត្យឡើងវិញ។ អាស្រ័យហេតុនេះ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ នឹងត្រូវការចាំបាច់នូវជំនួយបច្ចេកទេសពីអង្គការអន្តរជាតិនានា ជាពិសេសអង្គការយូនីសេហ្វ និងឧត្តមស្នងការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា ។

***សំនួរទី២ :*** ***សូមផ្តល់ព័ត៌មានបន្ថែមទៀតអំពីលទ្ធផលនៃកិច្ចសហការសម្របសម្រួល និងការងារត្រួតពិនិត្យ តាមដាននៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ជាពិសេសអំពីលទ្ធផលនៃកិច្ចសហការសម្របសម្រួលជាមួយអាជ្ញាធរថ្នាក់ខេត្ត និងថ្នាក់មូលដ្ឋាន ។***

**ចម្លើយ :**

**<u>ការងារសម្របសម្រួល</u>**

រាជរដ្ឋាភិបាលបានប្រគល់សមត្ថកិច្ចឱ្យក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារបំពេញភារកិច្ចដោយផ្ទាល់ :

ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ធ្វើការងារសម្របសម្រួលជាមួយក្រសួង ស្ថាប័នរដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាល និង អង្គការអន្តជាតិដែលពាក់ព័ន្ធ។ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ រៀបចំកសាងឯកសារជាតិ ផែនការជាតិ គោលនយោបាយជាតិ របាយការណ៍នានា និង រៀបចំពិធីមួយចំនួនដែលទាក់ទងទៅនឹងកិច្ចការកុមារដូចជា ទិវាកុមារអន្តរជាតិ ឬបុណ្យខួបនៃអនុសញ្ញាស្តីអំពីសិទ្ធិកុមារជាដើម ។

ខាងក្រោមនេះ ជាឧទាហរណ៍ស្តីពីកិច្ចការរបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ :

- កម្មវិធីជួយកុមារនៅក្នុងសហគមន៍ បានធ្វើឡើងនៅក្នុងខេត្តចំនួន៨ ដែលមានកម្មវិធីសកម្មភាពអភិវឌ្ឍន៍សង្គមក្នុងសហគមន៍ដែលឧបត្ថម្ភដោយអង្គការយូនីសេហ្វ។ ការងារនេះត្រូវបានសម្របសម្រួលដោយ គណៈកម្មការអភិវឌ្ឍថ្នាក់ខេត្ត ដឹកនាំ ដោយក្រសួងអភិវឌ្ឍន៍ជនបទ ដែលជាសមាជិកក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ។
- ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ បានសហការសម្របសម្រួលឱ្យមានកិច្ចស្វាគមន៍ និងគាំទ្រយ៉ាងកក់ក្តៅពីអាជ្ញាធរ និង ស្ថាប័នសង្គមកិច្ចថ្នាក់ខេត្ត ដល់ព្យុះហយាត្រាពិភពលោកប្រឆាំងនឹងពលកម្មកុមារ នៅក្នុងខេត្តដែលក្បួននោះបាន

ឆ្លងកាត់ ។

- អង្គមេទ្ទិញ ដើម្បីអបអរសាទរទិវាកុមារអន្តរជាតិ ១ មិថុនា ឆ្នាំ ១៩៩៩ រៀបចំឡើងដោយមានការចូលរួមពីសំណាក់កុមារ និង ឧបត្ថម្ភគាំទ្រដោយក្រសួងនានា នៃរាជរដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាល និង ផ្នែកឯកជន ។
- ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ បានបង្កើតអនុគណៈកម្មាពលកម្មកុមារ និងទំរង់នៃការកេងប្រវ័ញ្ចផ្សេងៗទៀតមកលើកុមារ ( ដោយប្រកាសលេខ ០៣ ចុះថ្ងៃទី ២៣ ខែ កញ្ញា ឆ្នាំ ១៩៩៧ ) ។ អនុគណៈកម្មានេះ បានធ្វើការសំរបសំរួលកម្មវិធីបណ្តុះបណ្តាលអធិការការងារខេត្ត ក្រុង ចំនួន៩ ព្រមទាំងបានធ្វើការសំរបសំរួល បើកវគ្គបណ្តុះបណ្តាល ស្តីពីពលកម្មកុមារ និង ការងារអធិការកិច្ចនៅក្នុង ខេត្ត ក្រុង ចំនួន ៩ ។
- ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ បានរៀបចំធ្វើផែនការប្រាំឆ្នាំ ប្រឆាំងការជួញដូរ និង កេងប្រវ័ញ្ចផ្លូវភេទលើកុមារ ដែលជាការងារបន្តពីសន្និសីទនៃទីក្រុងស្តុកខុលម៍ ។ ការងារនេះបានធ្វើឡើងដោយមានការចូលរួមមតិយោបល់ពីតំណាងក្រសួងពាក់ព័ន្ធ អង្គការក្រៅរដ្ឋាភិបាល និង អង្គការអន្តរជាតិនានា ។ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ បានរៀបចំសន្និសីទជាតិ ដែល មានតំណាងមកពីគ្រប់ខេត្តចូលរួម ( អភិបាល ឬ អភិបាលរង ) ទទួលស្គាល់ផែនការនេះជាផ្លូវការ ។ នៅខែមិនា ឆ្នាំ ២០០០ អង្គប្រជុំគណៈរដ្ឋមន្ត្រីបានអនុម័តលើផែនការនេះ ។ សេចក្តីប្រកាសរបស់រាជរដ្ឋាភិបាល ( លេខ ០១ ស.ប្រ.ក ចុះថ្ងៃទី ៦ ខែមេសា ឆ្នាំ២០០០ ) បានចែងយ៉ាងច្បាស់អំពីភារកិច្ចទទួលខុសត្រូវនៃក្រសួងពាក់ព័ន្ធក៏ដូចជាយន្តការសំរបសំរួលរបស់ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ និង ការត្រួតពិនិត្យតាមដានការអនុវត្តផែនការ ។
- ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារនឹងបង្កើតអនុគណៈកម្មការមួយ ដើម្បីជំរុញ សំរបសំរួល និង ត្រួតពិនិត្យតាមដានការអនុវត្តន៍ផែនការជាតិ៥ឆ្នាំ ប្រឆាំងការជួញដូរ និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ។ បណ្តាញការងារនៅថ្នាក់ខេត្ត និង ថ្នាក់ក្រុង នឹងត្រូវរៀបចំឡើង ។
- ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ បានសហការល្អជាមួយគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា ដើម្បីសំរបសំរួល និង ដើម្បីធានា ឱ្យមានការការពារជាសកល និង ជាក់ស្តែងនូវបញ្ហាសិទ្ធិមនុស្សនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

## <u>**ការខារត្រួតពិនិត្យតាមដាន**</u>

អគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍ នៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ធ្វើការពិនិត្យតាមដាន ជានិច្ចកាលលើសារពតិមានលើរបាយការណ៍ឯកសាររបស់ក្រសួង និងអង្គការពាក់ព័ន្ធ ព្រមទាំងបានធ្វើការអង្កេតថ្នាក់ជាតិមួយស្តីពីការជួញដូរផ្លូវភេទ ។ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារក៏បានរៀបចំផងដែរ នូវរបាយការណ៍ជាច្រើនផ្ញើរទៅអង្គការសហប្រជាជាតិ ដូចជាគណៈកម្មាធិការសិទ្ធិ មនុស្សនៃអង្គការសហប្រជាជាតិដើម[១] ។

ទោះបីសកម្មភាពទទួលបានលទ្ធផលទាំងនេះក៏ដោយ ក៏ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ចាំបាច់ត្រូវបង្កើនសមត្ថភាព និង កិច្ចប្រឹងប្រែងដើម្បីអនុវត្តអាណត្តិរបស់ខ្លួនឱ្យកាន់តែប្រសើរឡើង ហើយត្រូវការជំនួយបច្ចេកទេស និងកិច្ចគាំទ្រផ្នែកហិរញ្ញវត្ថុពីបណ្តាប្រទេស និង ពីអង្គការអន្តរជាតិបន្ថែមទៀត ។

---

[១] *-របាយការណ៍លើសំនួរ ការជួញដូរកេងប្រវ័ញ្ចផ្លូវភេទលើកុមារទៅ ECPAT ១៩៩៧ -របាយការណ៍ឆ្លើយតបសំណួរទៅនឹងផែនការសកម្មភាពស្តុកខុលម៍ ១៩៩៨ -របាយការណ៍របស់ប្រទេសកម្ពុជា ស្តីពីការចាប់ពង្រត់ និងការរំលោភបំពានលើកុមារទៅអង្គការសហប្រជាជាតិ ១៩៩៩ -របាយការណ៍ ស្តីពីការគាំពារ និង អភិវឌ្ឍន៍កុមារតូចនៅកម្ពុជាទៅ អាស៊ាន ២០០០ ។*

***សំនួរទី៣ :*** ***សូមបញ្ជាក់អំពីវិធានការអនុវត្តដែលបានប្រកាន់យក ដើម្បីអភិវឌ្ឍសន្ទស្សន៍ និងប្រមូលទិន្នន័យដែលមិនទាន់បានសរុប ស្តីពីស្ថានភាពកុមារនៅកន្លែងផ្សេងៗគ្នា ជាពិសេសក្រុមកុមារងាយរងគ្រោះ រួមមាន កុមាររស់នៅ និង/ឬ ធ្វើការតាមចិញ្ចើមថ្នល់ កុមារដែលរងគ្រោះដោយការរំលោភលើរាងកាយ និងផ្លូវភេទ កុមារដែលរងគ្រោះដោយគ្រឿងញៀន កុមារជាម្តាយដែលមានវ័យជំទង់ កុមារប្រព្រឹត្តិខុសច្បាប់ កុមាររងគ្រោះដោយការជួញដូរផ្លូវភេទ កុមារពិការ និងកុមារជនជាតិភាគតិច។ ជាបន្ថែមទៀតសូមអធិប្បាយអំពីវិសាលភាពនៃសន្ទស្សន៍ និងទិន្នន័យទាំងនេះដែលពេលបច្ចុប្បន្នត្រូវយកទៅប្រើប្រាស់ ដើម្បីធ្វើគោលនយោបាយ និងកម្មវិធីសំដៅឱ្យការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារប្រកបដោយប្រសិទ្ធិភាព ។***

**ចម្លើយ :**

ប្រទេសកម្ពុជា មានប្រព័ន្ធប្រមូលពតិមានផ្សេងៗគ្នាតាមក្រសួងនិមួយៗ។ ទោះយ៉ាងណាក៏ដោយ ក៏ប្រព័ន្ធទាំងនេះមិនទាន់សុក្រឹត្យនៅឡើយ។ ហើយនេះជាមូលហេតុដែលរាជរដ្ឋាភិបាល មានបំនងរៀបចំកែលំអឱ្យប្រព័ន្ធពតិមានកាន់តែល្អប្រសើរឡើង ។ ទិន្នន័យទាំងឡាយមិនបានដាក់តាមក្រុមជាក់លាក់ជានិច្ចកាលនោះទេ ។

ប្រព័ន្ធសំខាន់ៗដើម្បីប្រមូលទិន្នន័យ និង អភិវឌ្ឍន៍សន្ទស្សន៍មានដូចតទៅ :

- *ក្រសួងអប់រំ យុវជន និង កីឡា* : បានបង្កើតប្រព័ន្ធប្រមូលទិន្នន័យរបស់ខ្លួនហៅថា *មជ្ឈមណ្ឌលប្រព័ន្ធពតិមានគ្រប់គ្រងអប់រំ (EMIS)*។ ទិន្នន័យទាំងឡាយត្រូវបានប្រមូលពីថ្នាក់ស្រុក និងខេត្ត។ បញ្ជីសំនួរទាក់ទងនឹងប្រធានបទជាក់លាក់ណាមួយត្រូវបានរៀបចំ និងបញ្ជូនទៅគ្រប់សាលាដើម្បីបំពេញ ហើយបញ្ជូនមកក្រសួងវិញ។ បន្ទាប់មកពតិមានត្រូវបញ្ចូលក្នុងកុំព្យូទ័រ និងត្រូវធ្វើការវិភាគ។ ក្នុងករណីពតិមានមិនច្បាស់លាស់ក្រសួងបញ្ជូនបុគ្គលិកម្នាក់ឱ្យចុះទៅយកពតិមានបន្ថែម។ ប្រព័ន្ធផ្តល់ពតិមានអំពីស្ថានភាពទូទៅ ការសិក្សារបស់សិស្ស ចំនួនសិស្ស ចំនួនគ្រូ និងសាលា ក៏ដូចជាសំភារៈសិក្សា។ ពតិមាននេះ ត្រូវបាននាយកដ្ឋានផែនការរបស់ក្រសួងយកទៅប្រើប្រាស់ក្នុងការងាររដ្ឋបាល វិភាគផែនការ តាមដាន និង បានប្រមាណទៅលើសកម្មភាពអប់រំក្នុងទូទាំងប្រទេស។ លទ្ធផលនៃការប្រមូលទិន្នន័យនេះ ជួយឱ្យក្រសួងរកឃើញនូវការខ្វះខាតក្នុងការអនុវត្ត ផែនការអប់រំកន្លងមក ដូច្នេះក្រសួងអាចរៀបចំផែនការអភិវឌ្ឍសំរាប់ឆ្នាំបន្ទាប់ ក៏ដូចជាសកម្មភាពបន្ទាន់ នៅពេលដែលចាំបាច់។ សេចក្តីសង្ខេបនៃរបាយការណ៍ចុងក្រោយ ផ្អែកតាមមជ្ឈមណ្ឌលប្រព័ន្ធពតិមានគ្រប់គ្រងអប់រំ មានភ្ជាប់ជាមួយរបាយការណ៍នេះ ។
- *ក្រសួងសុខាភិបាល :* មានប្រព័ន្ធពតិមានមួយរបស់ខ្លួនដែលហៅថា *មជ្ឈមណ្ឌលប្រមូលពតិមានសុខាភិបាល* (HIS)។ ពតិមានត្រូវប្រមូលពីភូមិ ឃុំ ស្រុក មកខេត្ត រួចប្រមូលមកថ្នាក់ក្រសួង។ បច្ចុប្បន្នប្រព័ន្ធពតិមានត្រូវបានក្រសួងសុខាភិបាលប្រើប្រាស់នៅគ្រប់លំដាប់ថ្នាក់ សំរាប់គ្រប់គ្រងការងារធ្វើផែនការ តាមដាន និងវាយតំលៃសកម្មភាពសុខាភិបាល ព្រមទាំងសំរាប់ការបែងចែកធនធាន រាប់បញ្ចូលទាំងឱសថ និងថវិកាទៀតផង។ ថ្នាក់កណ្តាលនឹងចុះអភិបាលដល់មណ្ឌលសុខភាពក្នុងខេត្តទាំងអស់ដើម្បីពង្រីកដំនើរការប្រព័ន្ធ ។ ក្រសួងនឹងធ្វើការបណ្តុះបណ្តាលអំពីវិធីសាស្ត្រ ក្នុងការបញ្ចូលទិន្នន័យទៅក្នុងប្រព័ន្ធកុំព្យូទ័រដល់អ្នកទទួលខុសត្រូវប្រព័ន្ធពតិមាននៅក្នុងខេត្តមួយចំនួន ។ នាពេលថ្មីៗ ក្រសួងបានកែលំអប្រព័ន្ធពតិមានសុខាភិបាល ដោយសំរេចនូវគំរូរបាយការណ៍ប្រចាំខែ និងរបាយការណ៍ប្រកាសអាសន្នថ្មីៗ ហើយនិងគ្រោងដាក់ប្រើនៅឆ្នាំ២000នេះ។ សេចក្តីសង្ខេបរបាយការណ៍ចុងក្រោយផ្អែកតាមមជ្ឈមណ្ឌលប្រមូលពតិមានសុខាភិបាល មានភ្ជាប់ជាមួយរបាយការណ៍នេះ ។

- ក្រៅពីក្រសួងពីរខាងលើ មានវិទ្យាស្ថានជាតិស្ថិតិមួយដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់*ក្រសួងផែនការ* ។ ក្រសួងផែនការមានបណ្តាញពីថ្នាក់កណ្តាលដល់ឃុំ ។ ការប្រមូលទិន្នន័យ និងពត៌មានធ្វើឡើងក្នុងបំណងដើម្បីធ្វើការងារគ្រប់គ្រងផែនការ វិភាគ តាមដាន និងវាយតំលៃសកម្មភាពសេដ្ឋកិច្ចសង្គមនៅក្នុងប្រទេសទាំងមូល។ រៀងរាល់ឆ្នាំវិទ្យាស្ថាននេះបានធ្វើការអង្កេតប្រជាសាស្ត្រ (លទ្ធផលចុងក្រោយភ្ជាប់នៅក្នុងឧបសម្ព័ន្ធ)។ បន្ថែមទៀតវិទ្យាស្ថានបានធ្វើជំរឿនប្រជាជនបានចំនួន ២លើកមកហើយ ។

- ការសិក្សាស្រាវជ្រាវសុខភាពប្រជាសាស្ត្រ (DHS) បានធ្វើឡើងដោយសហការរវាង ក្រសួងផែនការ និងក្រសួងសុខាភិបាល : ក្នុងរយៈពេល១៧ខែ ដើម្បីត្រួតពិនិត្យតាមដាន និងវាយតំលៃលើលទ្ធផលដែលសំរេចបានឆ្ពោះទៅរកគោលដៅឆ្នាំ ១៩៩៦-២០០០ នៃគោលនយោបាយជាតិក្នុងវិស័យសុខាភិបាល ។
- ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា : បានប្រមូលទិន្នន័យជាទៀតទាត់ពីមជ្ឈមណ្ឌលកុមារកំព្រានានារបស់រដ្ឋ និងរបស់អង្គការក្រៅរដ្ឋាភិបាល ។
- ក្រសួងយុត្តិធម៌ : ទទួលពត៌មានបានតាមរយៈរបាយការណ៍ និងសាលក្រមរបស់តុលាការ និងអយ្យការខេត្ត ក្រុង។
- ក្រសួងមហាផ្ទៃ : ទទួលពត៌មានបានតាមរយៈរបាយការណ៍របស់នាយកដ្ឋានជំនាញ និងបណ្តាស្នងការនគរបាលខេត្ត ក្រុងទាំង ២៤ ក្នុងប្រទេស ដើម្បីចាត់វិធានការ និង ចាត់ចែងការងារទប់ស្កាត់ ។
- ក្រសួងការពារជាតិ : បានធ្វើអង្កេតបញ្ហាកុមារក្នុងជួរកងទ័ព ដោយសហការណ៍ជាមួយអង្គការយូនីសេហ្វ។ ចំពោះសំនួរដែលបានលើកឡើង ទាក់ទងកុមារងាយរងគ្រោះ មានការអង្កេតតាមទ្រង់ទ្រាយតូចៗជាច្រើនដែលភាគច្រើន ធ្វើឡើងដោយអង្គការក្រៅរដ្ឋាភិបាល ឬអង្គការអន្តរជាតិនានា។ ពុំមានប្រព័ន្ធច្បាស់លាស់ក្នុងការប្រមូលទិន្នន័យពាក់ព័ន្ធនឹងបញ្ហានេះ ។
- ក្រសួងកិច្ចការនារី និង អតីតយុទ្ធជន : ទទួលពត៌មានពីនាយកដ្ឋានជំនាញ និង មន្ទីរកិច្ចការនារីខេត្ត-ក្រុងទាំង២៤ ដើម្បីធ្វើការងារទប់ស្កាត់ការជួញដូរផ្លូវភេទ ។

***សំនួរទី៤ :*** ***សូមផ្តល់ពត៌មានបន្ថែមអំពីការបង្កើតនូវការអនុវត្ត និងសមិទ្ធិផលនៃកម្មវិធីសកម្មភាពជាតិសំរាប់ឆ្នាំ ១៩៩៨-២០០០ និងពន្យល់តើផែនការនេះផ្សារភ្ជាប់ទៅនឹងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម (១៩៩៦-២០០០) យ៉ាងដូចម្តេច? ។ សូមផ្តល់ពត៌មានបន្ថែមទៀតអំពីការអនុវត្តមាត្រា ៤ នៃអនុសញ្ញាដែលមានចែងអំពីការកំនត់ធនធាន"បង្កើនជាអតិបរិមា...ធនធានដែលអាចប្រើប្រាស់"សំរាប់ការងារសិទ្ធិកុមារ ពិសេសក្នុងវិស័យសុខាភិបាល សុខុមាលភាព អប់រំ និងវិធានការការពារពិសេស ។***

**ចម្លើយ :**

**កម្មវិធីសកម្មភាពជាតិដើម្បីកុមារ (១៩៩៨-២០០០)**

កម្មវិធីសកម្មភាពដើម្បីកុមារនៅកម្ពុជា (១៩៩៨-២០០០) គឺជាឯកសារមួយដែលរៀបចំដោយការប្រមូលផ្តុំនូវគោលនយោបាយរបស់ក្រសួងជំនាញមកចងក្រងធ្វើជាឯកសារជាតិមួយឡើង ដើម្បីងាយស្រួលធ្វើការត្រួតពិនិត្យតាមដាន និងវាយតំលៃពីស្ថានភាពកុមារនៅកម្ពុជា។ គោលនយោបាយរបស់ក្រសួងជំនាញទាំងនោះ មានលក្ខណៈស្របទៅនឹងផែនការអភិវឌ្ឍសេដ្ឋកិច្ចសង្គមរួចទៅហើយ ដូចនេះកម្មវិធីសកម្មភាពជាតិដើម្បីកុមារនៅកម្ពុជា គឺជាឯកសារដែលស្របទៅនឹងផែនការអភិវឌ្ឍន៍

សេដ្ឋកិច្ចសង្គម។ ក.ជ.ក.ក. នឹងទទួលបានរបាយការណ៍វាយតំលៃលើគោលដៅ ១៩៩៦-២០០០ នៅចុងឆ្នាំ ២០០២។ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ធ្វើការប្រមូលទិន្នន័យ ប្រមូលសទ្ធស្សន៍តាមរយៈរបាយការណ៍របស់ក្រសួងជំនាញ អង្គការក្រៅរដ្ឋាភិបាល អង្គការអន្តរជាតិ នឹងធ្វើការសិក្សាស្រាវជ្រាវផង ដើម្បីតាមដានការអភិវឌ្ឍស្ថានភាពកុមារនៅក្នុងប្រទេស ។

**ទទួលបានថវិកា**

- ថវិកាដែលរាជរដ្ឋាភិបាលបានផ្តល់ឱ្យក្រសួងសុខាភិបាលនៅឆ្នាំ១៩៩៩ មាន៧,៧៩ភាគរយ នៅឆ្នាំ២០០០ថវិកានេះបានកើនឡើងដល់ ៩,២០ ភាគរយ ។
- ថវិកាដែលរាជរដ្ឋាភិបាលបានផ្តល់ឱ្យក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា នៅឆ្នាំ ១៩៩៩ មាន១,៦ភាគរយ នៅឆ្នាំ២០០០ ថវិកានេះមានតែ១,១ភាគរយ ត្រូវនឹង២៦,៩០០លានរៀល ដោយឡែកថវិកាសំរាប់កុមារកំព្រាក្នុងមជ្ឈមណ្ឌលរដ្ឋាភិបាលមាន ៨៤៥,៥ លានរៀល ។
- ថវិកាដែលរាជរដ្ឋាភិបាលបានផ្តល់ឱ្យក្រសួងអប់រំ យុវជន និង កីឡា នៅឆ្នាំ ១៩៩៩ មាន៨,៣ភាគរយ នៅឆ្នាំ ២០០០ ថវិកានេះនឹងមានការកើនឡើងដល់ ១៣,៩២ភាគរយ ។
- ថវិកាដែលរាជរដ្ឋាភិបាលបានផ្តល់ឱ្យក្រសួងយុត្តធម៌នៅឆ្នាំ ១៩៩៩ មាន ០,៥២ ភាគរយនៅឆ្នាំ ២០០០ ថវិកានេះនឹងមាន ការកើនឡើងដល់ ០,៥៣ ភាគរយ ។
- ថវិកាដែលរាជរដ្ឋាភិបាលបានផ្តល់ឱ្យក្រសួងកិច្ចការនារី និង អតីតយុទ្ធជន នៅឆ្នាំ ១៩៩៩ មាន ០,០១ ភាគរយ នៅឆ្នាំ ២០០០ ថវិកានេះនឹងមានការកើនឡើងដល់ ២,៤៦ ភាគរយ ។
- ថវិកាដែលរាជរដ្ឋាភិបាលបានផ្តល់ឱ្យក្រសួងវប្បធម៌ និង វិចិត្រសិល្បៈនៅឆ្នាំ ១៩៩៩ មាន ០,២៥ ភាគរយ ដែលក្នុងនោះសំរាប់សកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ (ដែលមានសិស្សរៀនអាយុពី៨ឆ្នាំ ទៅ១៨ឆ្នាំ) មាន២៤ ភាគរយ នៃថវិកាក្រសួង។ នៅឆ្នាំ ២០០០ ថវិការបស់ក្រសួងកើនឡើងដល់ ០,៥០ ភាគរយ ។

## និយមន័យកុមារ

*( មាត្រា ១ នៃអនុសញ្ញា )*

***សំនួរទី៥ :*** ***សូមផ្តល់ពត៌មានបន្ថែមអំពីអាយុតាមផ្លូវច្បាប់សំរាប់ការព្រមព្រៀងការរួមភេទ សូមបញ្ជាក់ផងដែរថា តើរដ្ឋជាភាគីកំពុងគិតគូរដល់ ការកំណត់អាយុតាមផ្លូវច្បាប់ជាអប្បរមាសំរាប់ការទទួលខុសត្រូវបទព្រហ្មទណ្ឌដែរឬទេ ?***

**ចម្លើយ :**

**អាយុតាមផ្លូវច្បាប់សំរាប់ការយល់ព្រមរួមភេទ :**

ពុំទាន់មានការកំណត់ដោយច្បាប់អំពីសិទ្ធិរួមភេទសំរាប់កុមារក្រៅពីមាត្រា១១៨ នៃច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ ។ ទោះយ៉ាងនេះក្តី មាត្រា ៤៣៤ នៃសេចក្តីព្រាងក្រមព្រហ្មទណ្ឌចែងថា :

បើសេវនកិច្ចនោះប្រព្រឹត្តិលើស្ត្រី ឬ បុរសអនីតិភាពអាយុតិចជាង១៣ឆ្នាំ ដោយមានសេចក្តីស្ម័គ្រគ្មានការបង្ខំ គ្មានអំពើហឹង្សា ឬ គ្មានឧបាយកលទុច្ចរិតទេ ពិរុទ្ធជនត្រូវមានទោសឧក្រិដ្ឋថ្នាក់ទី ១ ។

**<u>អាយុតាមផ្លូវច្បាប់សំរាប់ទទួលខុសត្រូវបទព្រហ្មទណ្ឌ :</u>**

ពុំមានការកំណត់ពីអាយុអប្បបរមាដើម្បីទទួលខុសត្រូវបទព្រហ្មទណ្ឌទេ។ មាត្រា ១៤ ច្បាប់ព្រហ្មទណ្ឌអន្តរកាលគ្រាន់តែកំណត់ពីអាយុអប្បរមានៃការឃុំខ្លួនជាបណ្តោះអាសន្នតែប៉ុណ្ណោះ។ ក៏ប៉ុន្តែក្រសួងយុត្តិធមិមានចែងបញ្ហានេះនៅក្នុងមាត្រា ៨១ នៃសេចក្តីព្រាងក្រមព្រហ្មទណ្ឌ ដែលមានខ្លឹមសារដូចតទៅ :

មនុស្សជាប់ចោទដែលគេជឿច្បាស់ថា វាជាពិរុទ្ធជនហើយ តែមានអាយុតិចជាង១៣ឆ្នាំ ក្នុងខណ:ដែលវាប្រព្រឹត្តិបទល្មើសនោះ តុលាការត្រូវប្រមាណថា វាមិនទាន់ដឹងខុសត្រូវ និង មិនត្រូវឱ្យវាទទួលខុសត្រូវទេ ។

ជននោះត្រូវបានផុតពីការចោទប្រកាន់ផុតទោសពៃរ៍ទាំងអស់ ប៉ុន្តែតុលាការត្រូវសំរេចថាឱ្យជននោះនៅក្រោមការឧបត្ថម្ភ ការសង្គ្រោះ ការត្រួតត្រា ការអប់រំ ឬ ការកែខ្លួនណាមួយ ក្នុងថេរវេលាដែលមានកំណត់ ។

## <u>គោលការណ៍ទូទៅ</u>

*( មាត្រា ២ ៣ ៦ និង ១២ នៃអនុសញ្ញា )*

***សំនួរទី៦ : សូមផ្តល់ពត៌មានបន្ថែមស្តីពីវិធានការតាមផ្លូវច្បាប់ និងវិធានការផ្សេងៗក្រោមយុត្តាធិការនៃរដ្ឋជាភាគី ដើម្បីធានាថា កុមារទាំងអស់គ្មានការរើសអើងផ្សេងៗ និងអាចទទួលនូវសិទ្ធិដែលចែងក្នុងអនុសញ្ញានេះ សូមផ្តល់ពត៌មានបន្ថែម អំពីវិធានការដែលប្រកាន់យកដើម្បីលុបបំបាត់ការប្រតិបត្តិ ការរើសអើងប្រឆាំងនឹងកុមារ និង ក្រុមកុមារជនជាតិ ។***

**ចម្លើយ :**

ពុំទាន់មានច្បាប់ថ្មីស្តីអំពីការមិនរើសអើង ត្រូវបានអនុម័តនោះទេ។ ដូច្នេះពតិមានដែលបានដាក់ជូននៅក្នុងរបាយការណ៍កន្លងមកនេះនៅជាសុពលភាពជាធម្មតា ។

ក្នុងការអនុវត្តជាក់ស្តែងពុំមានការហាមឃាត់លើការប្រើប្រាស់ភាសាផ្សេងពីភាសាខ្មែរ ការប្រារព្ធបុណ្យទានតាមវប្បធម៌ដោយឡែកនានា ការប្រតិបត្តិសាសនា ការគោរពប្រពៃណី និងការបើកសាលារៀនសំរាប់ជនជាតិភាគតិច ដូចជាសាលារៀនចិនជាដើម។ ក្រសួងអប់រំ យុវជន និង កីឡា បានផ្តល់ឱកាសស្មើៗគ្នាដល់កុមារា កុមារី នៃជនជាតិភាគតិច ដែលដល់អាយុចូលសាលានៅទូទាំងប្រទេសឱ្យបញ្ចប់បឋមសិក្សា និងទទួលបាននូវការអប់រំមូលដ្ឋានរយ:ពេល៩ឆ្នាំ នៅមធ្យមសិក្សា។ ក្រសួងសុខាភិបាលបើកយុទ្ធនាការផ្តល់វ៉ាក់សាំង ប្រឆាំងជំងឺគ្រុនស្វិតដៃជើង និងជីវជាតិអាដល់កុមារអាយុក្រោម៥ឆ្នាំ នៅទូទាំងប្រទេស ក្នុងនោះរួមទាំងតំបន់ដាច់ស្រយោលទៀតផង។ ជាលទ្ធផលកុមារចំនួន៩៥ភាគរយ ទទួលបានដំណក់ថ្នាំបង្ការជំងឺគ្រុនស្វិតដៃជើង និង ជីវជាតិអា។ ក្រសួងកិច្ចការនារីបង្កើតកម្មវិធីអក្ខរកម្ម សំដៅធ្វើឱ្យកុមារីទទួលបានការសិក្សាស្មើនឹងកុមារា ។

***សំនួរទី៧ : តាមខ្លឹមសារមាត្រា៦ និង៣៩ នៃអនុសញ្ញា សូមផ្តល់ពត៌មានស្តីពីវិធានការប្រកាន់យកដើម្បី ផ្តល់នូវការព្យាបាល និងជំនួយផ្សេងៗ ដើម្បីធ្វើឱ្យប្រសើរឡើងចំពោះកុមារទាំងឡាយដែលរងគ្រោះដោយ***

*៥.ចូរលោកគ្រូ អ្នកគ្រូ ស្វែងរកបន្ថែមផងដែរ អំពីវិធានការលុបបំបាត់ចំការមីន នៅក្នុងទឹកដីនៃរដ្ឋភាគី ដែលជាឧបសគ្គដល់ជីវិតកុមារនាពេលបច្ចុប្បន្ន ។*

**ចម្លើយ :**

**<u>អំពីគ្រាប់មីន</u>**

ប្រទេសកម្ពុជាបានផ្តល់សច្ចាប័នលើសន្ធិសញ្ញាទីក្រុងអូតាវ៉ា នៅថ្ងៃទី២៣ ខែមិថុនា ឆ្នាំ ១៩៩៩ (កាលបរិច្ឆេទដែលព្រះមហាក្សត្រឡាយព្រះហស្ថលេខា) ហើយបានអនុម័តច្បាប់ជាតិមួយហៅថា ច្បាប់ស្តីពីការហាមប្រើប្រាស់គ្រាប់មីនគ្រប់ប្រភេទប្រឆាំងនឹងមនុស្ស នៅថ្ងៃ ២៨ ខែមេសា ឆ្នាំ ១៩៩៩ ហើយព្រះមហាក្សត្របានឡាយព្រះហស្ថលេខានៅថ្ងៃទី ២៨ ខែឧសភា ឆ្នាំ ១៩៩៩ ។ ប្រធានក្រុមប្រឹក្សាភិបាលនៃមជ្ឈមណ្ឌលកំចាត់មីនកម្ពុជា ទទួលបន្ទុកពិនិត្យតាមដានលើការអនុវត្តច្បាប់ និងសន្ធិសញ្ញានេះ រួមទាំងការរកឱ្យឃើញ និង ការបំផ្លាញចោលនូវគ្រាប់មីនដែលស្តុកទុក ។

ក្រុមយុទ្ធនាការលុបបំបាត់គ្រាប់មីនកម្ពុជា ធ្វើការត្រួតពិនិត្យតាមដានផងដែរនូវការគោរពសន្ធិសញ្ញា និងកំពុងធ្វើរបាយការណ៍ប្រចាំឆ្នាំ ជូនក្រុមយុទ្ធនាការលុបបំបាត់គ្រាប់មីនអន្តរជាតិ ដើម្បីធ្វើការផ្សព្វផ្សាយ ការត្រួតពិនិត្យតាមដានកន្លែងមានគ្រាប់មីន ។

ទន្ទឹមនឹងទិដ្ឋភាពផ្នែកច្បាប់ដូចបានរៀបរាប់ខាងលើ នៅមានសកម្មភាពជាច្រើនទៀត ដែលកំពុងប្រព្រឹត្តិទៅនៅក្នុងប្រទេសកម្ពុជា ដើម្បីដោះស្រាយបញ្ហាដែលជាកេរ្តិ៍ដំណែលគ្រាប់មីន ។ សកម្មភាពទាំងនោះ អនុវត្តដោយរាជរដ្ឋាភិបាល និង អង្គការក្រៅរដ្ឋាភិបាលមួយចំនួនមាន :

- មជ្ឈមណ្ឌលកំចាត់មីនកម្ពុជា(CMAC) គឺជាស្ថាប័នជាតិមួយដែលត្រូវបានបង្កើតឡើងដោយព្រះរាជាក្រឹត្យ ដើម្បីអនុវត្ត និងសំរបសំរួលសកម្មភាពមីននៅកម្ពុជា។ សកម្មភាពរបស់CMAC រួមមាន ការស្រាវជ្រាវចំការមីន ការដាក់ផ្លាកសញ្ញាមីន ការបោសសំអាតគ្រាប់មីនមិនទាន់ផ្ទុះ និងសកម្មភាពទាក់ទងនឹងការយល់ដឹងអំពីគ្រាប់មីន។ ដើម្បីកំណត់អំពីវិសាលភាពនៃបញ្ហាកើតចេញពីគ្រាប់មីន ពេលថ្មីៗនេះCMAC បានធ្វើការប្រកាសអំពីការអង្កេតថ្នាក់ជាតិមួយស្តីពីគ្រាប់មីន និង គ្រាប់មិនទាន់ផ្ទុះ ដែលរកឃើញនូវផលអាក្រក់ និង ផលប៉ះពាល់ លើសេដ្ឋកិច្ចសង្គម ។
- អង្គការបោសសំអាតមីនដើម្បីមនុស្សធម៌ (MAG) និងអង្គការហាលូត្រាស (Halo Trust ) គឺជាអង្គការក្រៅរដ្ឋាភិបាលនៃប្រទេសអង់គ្លេស ដែលចូលរួមយ៉ាងសកម្មក្នុងសកម្មភាពកំចាត់មីន រួមមានការធ្វើអង្កេតការបោសសំអាតមីន និងការផ្សព្វផ្សាយឱ្យយល់ដឹងអំពីមីន (មានតែអង្គការ MAG ប៉ុណ្ណោះ) ។
- ដោយមានជំនួយបច្ចេកទេសពីអង្គការជនពិការអន្តរជាតិ (Handicap International) សមាគមជាតិកាកបាទក្រហមកម្ពុជាធ្វើការយ៉ាងសកម្ម គ្រប់គ្រងទិន្នន័យស្តីពីឧប្បត្តិហេតុ ឬ គ្រោះថ្នាក់បង្ករដោយគ្រាប់មីន។ ទិន្នន័យនេះត្រូវបានប្រើប្រាស់ដើម្បីផែនការ ការត្រួតពិនិត្យ និងវាយតំលៃពីសកម្មភាពកំចាត់មីន ។

ដោយមានកុមារជាច្រើនកំពុងតែរស់នៅ និង ចំរើនវ័យនៅក្នុងបរិដ្ឋានមួយប្រកបដោយគ្រាប់មីន ជាតំរូវការឱ្យមានការអប់រំ ណែនាំអំពីគ្រោះថ្នាក់នៃគ្រាប់មីនដល់កុមារទាំងនោះ។ អាស្រ័យហេតុនេះ ដើម្បីបង្កើននូវនិរន្តភាពនៃការងារនេះ អង្គការយូនីសេហ្វ និង MAG បានផ្តួចផ្តើមនូវគំរោងការងារមួយ ដោយសហការជាមួយក្រសួងអប់រំ យុវជន និង កីឡា ធ្វើការបញ្ចូលការអប់រំពីគ្រោះថ្នាក់នៃគ្រាប់មីនទៅក្នុងកម្មវិធីសិក្សា ហើយផ្តល់អាទិភាពទៅលើស្រុកដែលមានបញ្ហាមីន។ អង្គការ

ក្រៅរដ្ឋាភិបាលមួយចំនួនកំពុងសហការជាមួយអង្គការក្រៅរដ្ឋាភិបាល ដែលធ្វើសកម្មភាពកំចាត់មីនធ្វើផែនការអភិវឌ្ឍន៍សកម្មភាព ដោយភ្ជាប់ទាក់ទងនឹងសកម្មភាពកំចាត់មីន សំដៅធ្វើឱ្យប្រសើរបំផុតនូវលទ្ធផលនៃការបោសសំអាតមីន ។

**<u>កុមារជនរងគ្រោះដោយជំលោះប្រដាប់អាវុធ</u> :**

ជនរងគ្រោះដោយជំលោះប្រដាប់អាវុធរួមមាន កុមារពិការ កុមាររងគ្រោះដោយសង្គ្រាម កុមារបំរើក្នុងជួរកងទ័ព និង កុមារដែលរស់នៅក្នុងតំបន់មានជំលោះប្រដាប់អាវុធ ដែលទីនោះធនធានសង្គមត្រូវធ្លាក់ទៅក្នុងសភាពដុនដាប ដោយសារតែការប្រយុទ្ធគ្នា ។ កុមារពិការ គឺមិនរាប់បញ្ចូលត្រឹមតែកុមារជាជនរងគ្រោះដោយសារមីនប៉ុណ្ណោះទេ តែរាប់បញ្ចូលកុមារពិការទាំងអស់ឯទៀតដែរ (កុមារកើតជំងឺស្វិតដៃជើង ដោយសារតែផលវិបាកនៃកង្វះការចាក់ថ្នាំបង្ការ ដែលបណ្តាលមកពីសេវាសុខភាពមិនអាចដំណើរការបាន នាក់ឡុងពេលមានជំលោះប្រដាប់អាវុធ) ។

ជំនួយដល់កុមារពិការរួមមាន ការស្តារកាយសម្បទា ការងារនេះត្រូវចំណាយយ៉ាងច្រើន ព្រោះថាកុមារត្រូវការជាទៀងទាត់នូវអវៈយវៈសិប្បនិម្មិតថ្មី និង ការកែសំរួលអវៈយវៈទៅតាមការលូតលាស់របស់កុមារ ។

ការធ្វើកាយសម្បទាតែម្យ៉ាងពុំទាន់គ្រប់គ្រាន់នោះទេ។ គំរោងការមួយចំនួនត្រូវបានអភិវឌ្ឍន៍ ដើម្បីបង្កើនការទទួលបាននូវសេវាជាមូលដ្ឋាន ដូចជាការអប់រំសុខភាព និងការអប់រំនៅក្នុងសាលា។ ការអង្កេតថ្មីៗនេះ បង្ហាញឱ្យឃើញថាកុមារពិការតិចជាង២៥ភាគរយ បានចូលសាលារៀន។ ទោះជាយ៉ាងណាក៏ដោយ រាជរដ្ឋាភិបាលក៏ដូចជាអង្គការក្រៅរដ្ឋាភិបាលនៅតែត្រូវផ្តោតការយកចិត្តទុកដាក់ថែមទៀតលើបញ្ហាទាំងនេះ ។

ដើម្បីកែលំអស្ថានភាពកុមារដែលរងគ្រោះដោយជំលោះប្រដាប់អាវុធ រាជរដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាលនានា មិនត្រឹមតែផ្តោតការយកចិត្តទុកដាក់ទៅលើកុមារជាជនរងគ្រោះផ្ទាល់នោះទេ។ ប៉ុន្តែក៏បានយកចិត្តទុកដាក់ផងដែរទៅលើកុមារដែលមានឪពុកម្តាយជាជនពិការហើយពុំមានលទ្ធភាពផ្គត់ផ្គង់កូន។ ជាចាំបាច់ត្រូវជួយឪពុកម្តាយជាជនពិការ ដោយធ្វើការស្តារកាយសម្បទា និង ធ្វើឱ្យគេទទួលបាននូវការបណ្តុះបណ្តាលវិជ្ជាជីវៈ ការរកចំណូល និង ការផ្តល់ឥណទាន ។

អង្គការក្រៅរដ្ឋាភិបាលជាច្រើនសហការជាមួយ ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ដើម្បីផ្តល់ជំនួយដល់ជនរងគ្រោះដោយសារគ្រាប់មីន និង ជនពិការផ្សេងៗទៀត។ សកម្មភាពទាំងនោះមានការស្តារកាយសម្បទា ការបណ្តុះបណ្តាលវិជ្ជាជីវៈ ការពិគ្រោះយោបល់ ការធ្វើសេវាបញ្ជូន និង ការបង្កើនចំណូលក្នុងគ្រួសារ ។ សកម្មភាពទាំងនេះសំរបសំរួលដោយក្រុមប្រឹក្សាសកម្មភាពជនពិកា(DAC) ដែលជាអង្គការពាក់កណ្តាលស្វយ័តមួយមានសមាសភាពមកពីក្រសួងពាក់ព័ន្ធ អង្គការក្រៅរដ្ឋាភិបាល និងសមាគមន៍ជនពិការ។ សកម្មភាពទាំងឡាយដែលទាក់ទងទៅនឹងការកំចាត់មីន ទាមទារឱ្យមានការផ្តល់មូលនិធិរយៈពេលយូរ ព្រោះថា ជាអកុសលប្រទេសកម្ពុជាត្រូវដោះស្រាយបញ្ហាគ្រាប់មីន និងបញ្ហាជនរងគ្រោះដោយសារគ្រាប់មីនក្នុងរយៈពេលច្រើនឆ្នាំទៅមុខទៀត ។

**<u>កុមារក្នុងជួរកងទ័ព</u>**

តាមរយៈក្រុមប្រឹក្សារំសាយកងកំលាំងប្រដាប់អាវុធ រាជរដ្ឋាភិបាលកម្ពុជាមានសុច្ឆន្ទៈ បានរំសាយកុមារយោធាទាំងអស់ (អាយុក្រោម១៨ឆ្នាំ) ចេញពីជួរកងទ័ព ហើយអនុវត្តតាមច្បាប់ជាធរមាន ដែលហាមមិនឱ្យអនីតិជនចូលបំរើកងទ័ព។ កុមារយោធាត្រូវបានចាត់ទុកជាក្រុមពិសេសដែលត្រូវរំសាយ ហើយការយកចិត្តទុកដាក់ដោយឡែក ដែលគួរផ្តល់ឱ្យពួកគេគឺការឧបត្ថម្ភគាំទ្រផ្នែកស្មារតី ។

# សិទ្ធិពលរដ្ឋ និង សេរីភាព

*( មាត្រា ៧, ៨, ១៣, ១៧ និង ៣៧ ( ក ) )*

***សំនួរទី៨ :*** ***សូមផ្តល់ព័ត៌មានបន្ថែមអំពីវិធានការណ៍ដែលប្រកាន់យក ដើម្បីធានាថាកុមារទាំងអស់បានត្រូវចុះបញ្ជីជាតិ បន្ទាប់ពីកើតមកភ្លាម រួមទាំងកុមារនៅតំបន់ភ្នំ (ខ្មែរលើ) កុមារគ្រួសារក្សេសក៏ កុមារជាជនភៀសខ្លួន និង កុមារមិនមានសញ្ជាតិខ្មែរ (ឧ.កុមារជនជាតិវៀតណាម) ?***

**ចម្លើយ :**

បញ្ហាទំនាស់នយោបាយ និងប្រដាប់អាវុធគឺជាកត្តាធ្វើឱ្យការគ្រប់គ្រងផ្នែករដ្ឋបាលពុំទាន់មានប្រសិទ្ធិភាពពេញលេញនៅទូទាំងប្រទេស រួមទាំងការចុះបញ្ជីអត្រានុកូលដ្ឋាន។ ពុំទាន់មានច្បាប់ ឬវិធានណាមួយដែលធានាថា កុមារទាំងអស់បានត្រូវចុះបញ្ជីអត្រានុកូលដ្ឋាន បន្ទាប់ពីកើតមកភ្លាមទេ។ បញ្ហានេះប៉ះពាល់ទៅនឹងកុមារជាទូទៅ គឺមិនមែនតែលើកុមារនៃក្រុមជនជាតិភាគតិចនោះទេ ។ យ៉ាងនេះក្តី ការចុះបញ្ជីអត្រានុកូលដ្ឋានបានអនុវត្តជាបណ្តើរៗនៅក្នុងទីក្រុង-ខេត្ត និងទីប្រជុំជនមួយចំនួន ទោះពុំទាន់ជាកាតព្វកិច្ចក៏ដោយ ។

សេចក្តីព្រាងក្រមរដ្ឋប្បវេណី នឹងកំណត់ការចុះបញ្ជីជាតិកាតព្វកិច្ច ប៉ុន្តែប្រទេសកម្ពុជានឹងត្រូវការជំនួយបច្ចេកទេស ក៏ដូចជាជំនួយផ្សេងៗទៀត ដើម្បីអនុវត្តបទបញ្ញត្តិនេះ ។

មាត្រា៤៤៩ នៃសេចក្តីព្រាងក្រមព្រហ្មទណ្ឌ បានបញ្ញត្តិការមិនចុះបញ្ជីអត្រានុកូលដ្ឋានកុមារដែលទើបនឹងកើតឱ្យទៅជាកំហុសព្រហ្មទណ្ឌ ។

បន្ថែមលើនេះទៀត ក្រសួងមហាផ្ទៃកំពុងធ្វើសេចក្តីព្រាងអនុក្រឹត្យស្តីពីការគ្រប់គ្រងសៀវភៅគ្រួសារ ដែលក្នុងនោះមានការនិយាយពីការចុះបញ្ជីជាតិដែលជាកាតព្វកិច្ច ។

***សំនួរទី៩ :*** ***សូមបង្ហាញ អំពីវិធានការដែលប្រកាន់យក ដោយអនុលោមទៅតាមមាត្រា៧ កថាខ័ណ្ឌ២ នៃអនុសញ្ញា ដើម្បីធានានូវសិទ្ធិរបស់កុមារក្នុងការទទួលបាននូវសញ្ជាតិមួយជាពិសេស នៅក្នុងករណីដែលទីនោះ កុមារមិនបានចុះបញ្ជីជាតិជាប្រជាជននៃប្រទេសនោះ ?***

**ចម្លើយ :**

ប្រទេសកម្ពុជាបានអនុម័តច្បាប់ ស្តីពីសញ្ជាតិនៅឆ្នាំ ១៩៩៦ ។

មាត្រា ៤ ចែងថា :

១ - ត្រូវបានសញ្ជាតិខ្មែរទោះបីកើតនៅទីណាក៏ដោយ :

- កូនមានខាន់ស្លា ដែលកើតមកពីឪពុក ឬ ម្តាយមានសញ្ជាតិខ្មែរ ឬ
- កូនឥតមានខាន់ស្លា ដែលកើតមកពីឪពុក ឬ ម្តាយមានសញ្ជាតិខ្មែរទទួលស្គាល់ ឬ
- កូនដែលឪពុក ម្តាយមិនទទួលស្គាល់ កាលបើតុលាការបានចេញសាលក្រមថា កូននោះពិតជាកើតពីឪពុក ឬ ម្តាយដែលមានសញ្ជាតិខ្មែរ ។

២- ត្រូវបានសញ្ជាតិខ្មែរ ដោយកើតនៅក្នុងព្រះរាជាណាចក្រកម្ពុជា :

ក- កូនដែលកើតពីឪពុក និង ម្តាយបរទេសដែលកើត និង រស់នៅស្របច្បាប់ក្នុងព្រះរាជាណាចក្រកម្ពុជា ។

ខ- កូនដែលកើតពីឪពុក និង ម្តាយមិនស្គាល់ និងកូនទើបនឹងកើតដែលគេរើសបាននៅក្នុងព្រះរាជាណាចក្រកម្ពុជាត្រូវចាត់ទុកថា កើតក្នុងព្រះរាជាណាចក្រកម្ពុជា ។

ដូច្នេះពុំមានបញ្ញត្តិជាក់លាក់ទាក់ទងនឹងភាពគ្មានសញ្ជាតិនោះទេ ។

***សំនួរទី១០ : សូមផ្តល់ព័ត៌មានបន្ថែម ស្តីពីវិធានការណ៍ដែលបានប្រកាន់យក ដើម្បីបង្ការអំពើឃោរឃៅ ធ្វើទុក្ខទោស និងការរំលោភបំពានរបស់នគរបាលមកលើកុមារ ?***

***ចម្លើយ :***

ចំពោះករណីមាននគរបាលណាម្នាក់ បានប្រព្រឹត្តិអំពើឃោរឃៅ និងធ្វើទុកទោសទៅលើកុមារណាម្នាក់ដែលត្រូវបានចាប់ខ្លួន ឬ ឃាត់ខ្លួនក្នុងបទល្មើសព្រហ្មទណ្ឌនោះ ឪពុក ម្តាយ អាណាព្យាបាល សាច់ញាតិ និងមេធាវីនៃកុមារ មានសិទ្ធិប្តឹងចំពោះនគរបាលដែលបានប្រព្រឹត្តិខុសឆ្គងទៅតុលាការ ( ផ្អែកតាមច្បាប់ព្រហ្មទណ្ឌអន្តរកាល ) ។

ចំពោះការរំលោភបំពានលើកុមារ ពុំទាន់មានបញ្ញត្តិច្បាប់ដោយឡែកសំរាប់បញ្ហានេះទេ ហេតុនេះហើយបទបញ្ញត្តិព្រហ្មទណ្ឌត្រូវយកមកអនុវត្ត បើការរំលោភបំពាន បំពេញបាននូវនិយមន័យនៃបទល្មើសព្រហ្មទណ្ឌណាមួយនោះ។ បញ្ហានេះកើតមានឡើង ប៉ុន្តែជនដែលប្រព្រឹត្តិអំពើរំលោភបំពានលើកុមារពុំទាន់ត្រូវបានបញ្ជូនទៅតុលាការឡើយ។ ហើយបទបញ្ញត្តិដែលទាក់ទងទាំងនោះ ពុំដែលត្រូវបានយកទៅប្រើប្រាស់ទេ ។

ទោះជាយ៉ាងនេះក៏ដោយ ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារត្រង់មាត្រាទី១១៩ និងមាត្រាបន្ទាប់មកទៀតបានបញ្ញត្តិពីការដកហូតអំណាចមេបាក្នុងករណីមានការរំលោភបំពានលើកុមារ ។

## <u>បរិយាកាសគ្រួសារ និង កិច្ចថែទាំផ្សេងៗទៀត</u>

*( មាត្រា ៥ ១៨ កថាខ័ណ្ឌ ១ និង ២ ៩ ១០ ២៧ កថាខ័ណ្ឌ៤ ២០ ២១ ១១ ១៩ ៣៩ និង ២៥ )*

***សំនួរទី១១ : សូមផ្តល់ព័ត៌មានបន្ថែមស្តីពីការត្រួតពិនិត្យតាមដានស្ថានភាពកុមារ ដែលត្រូវដាក់នៅក្នុងមជ្ឈមណ្ឌល ឬ ដាក់នៅកន្លែងថែទាំផ្សេងៗទៀត និងការលំបាកដែលមជ្ឈមណ្ឌលទាំងនោះប្រឈមមុខព្រមទាំងព័ត៌មានស្តីពីការពិនិត្យជាប្រចាំលើការងារថែទាំនៅក្នុងមជ្ឈមណ្ឌលខ សូមពន្យល់ថា តើរដ្ឋជាភាគីបានគិតគូរអំពីការធ្វើច្បាប់ស្តីពីការថែរក្សាដោយអាណាព្យាបាលចិញ្ចឹម ដែលត្រូវបានគេរាយការណ៍ថាបញ្ហានេះកើតនៅក្នុងប្រទេសកម្ពុជា ?***

***ចម្លើយ :***

***<u>កុមារនៅតាមមណ្ឌល</u> :***

មជ្ឈមណ្ឌលសំរាប់កុមារត្រូវដំណើរការដោយរដ្ឋាភិបាល ឬដោយអង្គការក្រៅរដ្ឋាភិបាល។ នៅទូទាំងប្រទេសមានមណ្ឌល ដែលគ្រប់គ្រងដោយរាជរដ្ឋាភិបាលចំនួន ២២។ បន្ថែមលើនេះ រាជរដ្ឋាភិបាលគ្រប់គ្រងមជ្ឈមណ្ឌល២ នៅភ្នំពេញគឺមជ្ឈមណ្ឌលយុវនីតិសម្បទា និងមជ្ឈមណ្ឌលស្ត្រីវ័យក្មេងមានវិបត្តិ ហើយរដ្ឋាភិបាលក៏គ្រប់គ្រងមជ្ឈមណ្ឌលសំរាប់កុមារត្រូវគេជួញដូរ ហើយដែលត្រូវធ្វើមាតុភូមិនិវត្តន៍ មណ្ឌលស្នាក់នៅបណ្តោះអាសន្នសំរាប់កុមារអនាថានៅប៉ោយប៉ែត និងមណ្ឌលទទួលកុមារត្រូវគេជួញដូរ ដែលធ្វើមាតុភូមិនិវត្តន៍ស្ថិតនៅខេត្តបាត់ដំបង។ ជាទូទៅមណ្ឌលដែលដំណើរការដោយអង្គការក្រៅរដ្ឋាភិបាល

ពុំសូវមានបញ្ហាកើតឡើងទេ។ ផ្ទុយទៅវិញថវិកាដែលផ្តល់ដោយរដ្ឋាភិបាលសំរាប់មជ្ឈមណ្ឌលនៅមានកំរិតទាបនៅឡើយ។ ហេតុនេះមជ្ឈមណ្ឌលត្រូវជួបប្រទះការខ្វះខាត គ្រឿងបរិក្ខាប្រើប្រាស់សំរាប់ការស្នាក់នៅរបស់កុមារ ។

## មណ្ឌលកុមារកំព្រាគ្រប់គ្រងដោយរដ្ឋាភិបាល

ក្រោយពីការដួលរលំនៃរបបខ្មែរក្រហម កុមារទាំងឡាយដែលត្រូវរកឃើញថា គ្មានអ្នកបីបាច់ថែរក្សាបឋម ឬមានតែឪពុក ឬម្តាយតែម្នាក់ដែលនៅរស់ ត្រូវបានយកទៅឱ្យរស់នៅក្នុងមជ្ឈមណ្ឌលកុមារកំព្រារបស់រដ្ឋាភិបាល។ ពេលនោះពុំមានទំរង់បែបបទច្បាស់លាស់សំរាប់ការយកកុមារទៅដាក់នៅទីនោះទេ។ គេដឹងថា នៅក្នុងចំណោមកុមារនៅក្នុងមជ្ឈមណ្ឌលទាំងនោះកុមារមួយចំនួន (មិនច្រើនទេ) មានទាំងឪពុក ទាំងម្តាយ ឬមានម្តាយនៅរស់។ បច្ចុប្បន្ននេះកុមារក្នុងមជ្ឈមណ្ឌលទទួលបានប្រាក់ឧបត្ថម្ភប្រចាំខែចំនួន៤0000 រៀល (ប្រហាក់ប្រហែលនឹងប្រាក់ខែមន្ត្រីរដ្ឋាភិបាលថ្នាក់ទាប) ពីរាជរដ្ឋាភិបាល (ប្រហែល US$ ១០) ។

បន្ថែមលើនេះមជ្ឈមណ្ឌលកុមារកំព្រារបស់រដ្ឋាភិបាលទាំងអស់ ទទួលមូលនិធិពីអង្គការក្រៅរដ្ឋាភិបាលនានា លើកលែងតែមជ្ឈមណ្ឌលយុវនីតិសម្បទា ដែលបានទទួលជំនួយឧបត្ថម្ភតិចតួចម្តងម្កាល ។

បញ្ហាចម្បងមួយទៀតរបស់មជ្ឈមណ្ឌលកុមារកំព្រានៃរដ្ឋាភិបាលគឺថា កុមារជាច្រើនដែលក្លាយទៅជាមនុស្សពេញវ័យ (មានខ្លះបានរៀបអាពាហ៍ពិពាហ៍ និង មានកូន មិនព្រមចាកចេញពីមជ្ឈមណ្ឌល ពួកគេអះអាងថា ពួកគេមានសិទ្ធស្នាក់អាស្រ័យនៅក្នុងមណ្ឌល )។ រាជរដ្ឋាភិបាលបានផ្តល់ជំនួយដល់ពួកគេ ដូចមានប្រាក់ អង្ករ និង ថ្លៃដីសំរាប់សង់ផ្ទះ។ ទោះជាយ៉ាងនេះក៏ដោយ ក៏ពួកគេភាគច្រើនវិលមកមជ្ឈមណ្ឌលវិញ ដោយលើកហេតុផលថា ដីនៅឆ្ងាយពេក ហើយពួកគេពុំអាចរកចំណូលបានទេ បើគេតាំងទីលំនៅ នៅទីនោះ ។

រដ្ឋាភិបាលមានផងដែរនូវមជ្ឈមណ្ឌលសង្គ្រោះទារក សំរាប់ទទួលយកកុមារ (ទារក ) អាយុក្រោម៦ឆ្នាំ ដែលត្រូវគេបោះបង់ចោលចាប់ពីឆ្នាំ ១៩៩៦ ដល់ឆ្នាំ ២000 នៅក្នុងមជ្ឈមណ្ឌលចំនួនកុមារផ្ទុកមេរោគអេដស៍កើនឡើងពី ១៧ ទៅ ៣៥ នាក់ ហើយចំនួនកុមារពិការកើនឡើងពី ២១ ទៅ ៥៦នាក់ ។ បច្ចុប្បន្នមជ្ឈមណ្ឌលប្រឈមមុខនឹងកង្វះបុគ្គលិកមានសមត្ថភាព និងកង្វះខាតថវិកាដើម្បីថែរក្សាកុមារទាំងនេះ។

ចំពោះការត្រួតពិនិត្យតាមដាន មានការិយាល័យមួយនៅចំណុះនាយកដ្ឋានសុខុមាលភាពកុមារ នៃក្រសួងសង្គមកិច្ចការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ដែលត្រូវបានប្រគល់ភារកិច្ចឱ្យត្រួតពិនិត្យមជ្ឈមណ្ឌលកុមារកំព្រារបស់រដ្ឋាភិបាល ព្រមទាំងមជ្ឈមណ្ឌលដែលគ្រប់គ្រងដោយអង្គការក្រៅរដ្ឋាភិបាល។ មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទាខេត្ត ក្រុង ធ្វើការត្រួតពិនិត្យស្ថានភាពកុមារ ដែលរស់នៅក្នុងមជ្ឈមណ្ឌលកុមារកំព្រារបស់រដ្ឋាភិបាលនៅក្នុងខេត្ត-ក្រុង ដែលជាសមត្ថកិច្ចរបស់ខ្លួនជាទៀងទាត់ ។

មន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ខេត្ត-ក្រុង ផ្ញើរបាយការណ៍តាមកំណត់ជាទៀងទាត់មកនាយកដ្ឋានសុខុមាលភាពកុមារ។ នាយកដ្ឋាននេះ បានរៀបចំនូវប្រព័ន្ធជាក់លាក់មួយស្តីពីរបៀបកសាងឯកសារ។ មជ្ឈមណ្ឌលនានារបស់រដ្ឋាភិបាល ត្រូវអនុវត្តទៅតាមប្រព័ន្ធខាងលើនេះ។ កិច្ចការទាំងនោះរួមមាន ការបើកនូវសំនុំករណីសំរាប់កុមារម្នាក់ៗ និង ការផ្ញើពត៌មានទៅនាយកដ្ឋានសុខុមាលភាពកុមារ ។

## មជ្ឈមណ្ឌលគ្រប់គ្រងដោយអង្គការក្រៅរដ្ឋាភិបាល :

មជ្ឈមណ្ឌលកុមារដែលគ្រប់គ្រងដោយអង្គការក្រៅរដ្ឋាភិបាលភាគច្រើន ជាមជ្ឈមណ្ឌលសំរាប់កុមារអនាថា និងកុមារក្រីក្រគ្មានទីពឹង។ នាយកដ្ឋានសុខុមាលភាពកុមារ មានភារកិច្ចត្រួតពិនិត្យមជ្ឈមណ្ឌលទាំងនេះ ដូចជាមជ្ឈមណ្ឌលរបស់រដ្ឋាភិបាលដែរ។ អង្គការក្រៅភិបាលទាំងនេះ ត្រូវបានតំរូវឱ្យធ្វើអនុស្សរណៈនៃការយោគយល់គ្នាជាមួយនឹងក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា និងតំរូវឱ្យធ្វើរបាយការណ៍មួយឆ្នាំ២ដងយ៉ាងតិចបំផុត។ មន្ត្រីក្រសួង និងមន្ទីរសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទាខេត្ត ក្រុង បានចុះទៅពិនិត្យមជ្ឈមណ្ឌលកុមារដែលគ្រប់គ្រងដោយអង្គការក្រៅរដ្ឋាភិបាលក្នុងស្រុក រួចហើយណែនាំ ឱ្យអង្គការក្រៅរដ្ឋាភិបាលនោះ ធ្វើការផ្តល់នូវសេវាឱ្យកាន់តែប្រសើរជាងមុនដល់កុមារ។ ចំពោះអង្គការក្រៅរដ្ឋាភិបាលណាដែលពុំបានកែលំអសេវារបស់ខ្លួន ក្រសួងសង្គមកិច្ច បានស្នើសុំយោបល់ឱ្យបិទមជ្ឈមណ្ឌល ហើយយកកុមារដែលនៅមជ្ឈមណ្ឌលនោះទៅដាក់មជ្ឈមណ្ឌលកុមារកំព្រារដ្ឋាភិបាល និងមជ្ឈមណ្ឌលអង្គការក្រៅរដ្ឋាភិបាលផ្សេងទៀត។ ក្រៅពីកិច្ចការទាំងនោះ នាយកដ្ឋានសុខុមាលភាពកុមារបានធ្វើការសំរបសំរួលការប្រជុំពិគ្រោះយោបល់នានាទៀតផង ។

ក្រុមគាំទ្រ និងត្រួតពិនិត្យតាមដានដែលស្ថិតនៅថ្នាក់កណ្តាលនៃក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ធ្វើការបណ្តុះបណ្តាល និងត្រួតពិនិត្យតាមដានសេវាដល់កុមារដែលត្រូវធ្វើសមាហរណកម្មមកពីមជ្ឈមណ្ឌលគ្រប់គ្រងដោយអង្គការក្រៅរដ្ឋាភិបាល ។ នៅពេលថ្មីៗនេះ មានកុមារ និង ស្ត្រីប្រហែល ១៨០០នាក់ ដែលត្រូវបានគេជួញដូរ ឬរស់នៅតាមចិញ្ចើមថ្នល់ ឬជាជនរងគ្រោះដោយការរំលោភផ្សេងៗ។ ជនទាំងនោះត្រូវបានសង្គ្រោះ និងផ្តល់នូវសេវាធ្វើឱ្យមានលំនឹងអារម្មណ៍ ដោយអង្គការក្រៅរដ្ឋាភិបាលមួយចំនួន និងត្រូវបានធ្វើសមាហរណកម្មទៅក្នុងគ្រួសាររបស់គេវិញ ឬនៅក្នុងសហគមដើម ។ ពួកគេទាំងនោះត្រូវមន្ត្រីសង្គមកិច្ចធ្វើការតាមដានមួយខែម្តង ។

## ការពិនិត្យឡើងវិញនូវការដាក់កុមារឱ្យរស់នៅក្នុងស្ថាប័នតាមការកំណត់ជាទៀងទាត់ :

ការពិនិត្យឡើងវិញជាទៀងទាត់ គឺជាសមត្ថកិច្ចរបស់មជ្ឈមណ្ឌល ។ ពុំមានការពិនិត្យពីស្ថាប័នខាងក្រៅទេ ។

## ការថែរក្សាដោយអាណាព្យាបាលចិញ្ចឹម

ខុសប្លែកពីបណ្តាប្រទេសមួយចំនួន កម្ពុជាមិនទាន់បានរៀបចំឡើងនូវប្រព័ន្ធស្តីពីការដាក់ឱ្យកុមាររស់នៅតាមអាណាព្យាបាលចិញ្ចឹមឡើយ។ ក៏ប៉ុន្តែមានអង្គការក្រៅរដ្ឋាភិបាលមួយចំនួន បានធ្វើកិច្ចការនេះរួចមកហើយ ទោះបីជាពុំមានមូលដ្ឋានច្បាប់ក៏ដោយ ។

ចំពោះបញ្ហាកុមារពិការ ក្រុមប្រឹក្សាសកម្មភាពជនពិការ សំរបសំរួលជាមួយនាយកដ្ឋានសុខុមាលភាពកុមារ ធ្វើការសិក្សាស្រាវជ្រាវអំពីការយកកុមារពិការទៅដាក់ ឬឱ្យស្នាក់អាស្រ័យកន្លែងដូចបានបញ្ជាក់ខាងលើ។ ស្តែងចេញពីលទ្ធផលនៃការសិក្សាចំនួនពីរលើកយ៉ាងតិចស្តីអំពីផ្ទះជាក្រុម និងការថែរក្សាដោយមធ្យោបាយចំលាស់ កម្មវិធីសាកល្បងនានា កំពុងត្រូវបានអនុវត្តដោយសំរបជាមួយអង្គការក្រៅរដ្ឋាភិបាលមួយចំនួន។ មានអង្គការក្រៅរដ្ឋាភិបាលប្រហែលពីរទៅបី បានរៀបចំឱ្យមានការថែរក្សាកុមារពិការ ដោយមធ្យោបាយចំលាស់ក្នុងទ្រង់ទ្រាយតូច ។

ដោយមានកិច្ចសំរបសំរួលជាមួយនាយកដ្ឋានសុខុមាលកុមារ ក្រុមប្រឹក្សាសកម្មភាពជនពិការ បានស្នើសុំឱ្យអង្គការក្រៅរដ្ឋាភិបាល និងអង្គការអន្តរជាតិមួយចំនួន ជួយរៀបចំយុទ្ធសាស្ត្រសំរាប់ការថែរក្សា និងការផ្តល់ទីស្នាក់អាស្រ័យទៅដល់កុមារពិការ មានក្រុមការងារមួយផ្សេងទៀត ត្រូវបានបង្កើតដើម្បីរៀបចំគោលនយោបាយ និងផែនការយុទ្ធសាស្ត្រធ្វើសកម្មភាពសំរាប់កុមារដែលពុំបានទទួលការថែរក្សាបឋម។ តាមការប្រមើរមើល ពួកគេនឹងលើកយោបល់ស្នើសុំឱ្យមានច្បាប់ និងបទបញ្ជាសម

ស្របស្តីអំពីការថែរក្សាតាមមធ្យោបាយចំលាស់នានា។ នៅពេលអនាគត បញ្ហានេះនឹងត្រូវគ្របដណ្តប់ដោយបទបញ្ញត្តិ រដ្ឋប្បវេណី ដែលកំពុងតែធ្វើសេចក្តីព្រាង ។

***សំនួរទី១២ : សូមផ្តល់ពត៌មានបន្ថែមស្តីពីការពិចារណាតាមផ្លូវច្បាប់អំពីការទទួលខុសត្រូវរបស់មាតាបិតា រួមទាំងការទទួលស្គាល់ ការទទួលខុសត្រូវរួមគ្នារបស់ឪពុកម្តាយទាំងពីរនាក់ ក្នុងការចិញ្ចឹមបីបាច់ថែរក្សា និងធ្វើឱ្យមានការចំរើនលូតលាស់ដល់កុមារ និងការបង់ថ្លៃអាហារកិច្ច ៗ***

**ចម្លើយ :**

**<u>ការទទួលខុសត្រូវរបស់មាតាបិតា</u>**

មានតែច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារប៉ុណ្ណោះ ដែលចែងពីការទទួលខុសត្រូវរបស់មាតាបិតា ក្នុងការចិញ្ចឹមបីបាច់ថែរក្សា និងធ្វើឱ្យមានការរីចំរើនលូតលាស់ដល់កុមារ និងការបង់អាហារកិច្ច។ ពត៌មានដែលបានផ្តល់ជូននៅក្នុងរបាយការណ៍ដំបូងរបស់ប្រទេសកម្ពុជាជុំវិញបញ្ហានេះ នៅតែយកជាការបានដដែល ។

យោងតាមសេចក្តីប្រកាសរបស់រដ្ឋាភិបាល ស្តីពីវិធានការចាត់តាំងអនុវត្តន៍ផែនការជាតិ៥ឆ្នាំ ប្រឆាំងការជួញដូរ និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ចំណុច៧ រាជរដ្ឋាភិបាលបានអំពាវនាវដល់មាតាបិតា អាណាព្យាបាល ត្រូវយកចិត្តទុកដាក់ពិនិត្យតាមដានសកម្មភាពបុត្រធីតា ហើយធ្វើការណែនាំជាប្រចាំកុំឱ្យធ្លាក់ចូលក្នុងអំពើអបាយមុខ ។

**<u>ការបង់អាហារកិច្ច</u> :**

ទាក់ទងនឹងការលែងលះ ជាញឹកញាប់ចៅក្រមជំនុំជំរះ តែងតែសំរេចឱ្យមានការបង់អាហារកិច្ច។ ក៏ប៉ុន្តែច្បាប់នៅមានចន្លោះប្រហោងច្រើនជុំវិញបញ្ហានេះ ។

ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារចែងថា :

- មាត្រា៧៤ : ឪពុក ឬ ម្តាយដែលលែងលះគ្នា ត្រូវជួយផ្គត់ផ្គង់ ជួយបីបាច់រក្សា ជួយផ្តល់សោហ៊ុយ អប់រំ និងរៀនសូត្រដល់កូន តាមលទ្ធភាពរបស់ខ្លួន ។
- មាត្រា ៧៨ ចែងថា : ការមិនព្រមបង់អាហារកិច្ចដូចបានចែងខាងលើនេះ ចាត់ទុកជាបទល្មើសព្រហ្មទណ្ឌដែលនឹងត្រូវផ្តន្ទាទោសតាមច្បាប់ជាធរមាន បើកាលណាមានភស្តុតាងបញ្ជាក់ថា ជនដែលត្រូវផ្តល់អាហារកិច្ចនោះមិនស្មោះត្រង់។ ក៏ប៉ុន្តែច្បាប់ព្រហ្មទណ្ឌបច្ចុប្បន្ន គឺច្បាប់ព្រហ្មទណ្ឌអន្តរកាល ពុំបានបញ្ចូលកំហុសបង់អាហារកិច្ចឱ្យទៅបទល្មើសព្រហ្មទណ្ឌទេ ហេតុនេះមាត្រា៧៨ នៃច្បាប់អាពាហ៍ពិពាហ៍និង គ្រួសារពុំអាចអនុវត្តបានឡើយ ។

ទោះជាយ៉ាងនេះ សេចក្តីព្រាងក្រមព្រហ្មទណ្ឌថ្មីមាត្រា៤៦២ ចែងថា ឈ្មោះណាដែលមានសាលក្រមជំនុំជំរះ កាត់សេចក្តីជាស្ថាពរហើយ ឬ ជាបណ្តោះអាសន្នថា ឱ្យចេញថ្លៃអាហារកិច្ចចិញ្ចឹមប្រពន្ធ និង កូនអាយុមិនទាន់គ្រប់ការ ឪពុកម្តាយ ឬញាតិលោហិត ហើយទុកឱ្យហួសកំណត់ជាង៣ខែ ដោយចេតនាមិនបានចេញថ្លៃអាហារកិច្ចទេ ឈ្មោះនោះត្រូវទុកជាបានបោះបង់ចោលគ្រួសារត្រូវផ្តន្ទាទោសថ្នាក់មជ្ឈិម ។

# សុខភាពមូលដ្ឋាន និង សុខុមាលភាព

*( មាត្រា ៦ កថាខ័ណ្ឌ ២ មាត្រា ២៣, ២៤, ២៦ និង ១៨ កថាខ័ណ្ឌ ៣ និង មាត្រា ២៧ កថាខ័ណ្ឌ ១៣ )*

***សំនួរទី១៣ : សូមផ្តល់ពត៌មានបន្ថែម ស្តីពីការអនុវត្តគោលនយោបាយសុខាភិបាលជាតិ ជាពិសេសអំពីវិធានការដែលធ្វើឱ្យប្រសើរឡើងនូវសេវាសុខភាពបឋម និងសេវាបង្ការសុខភាពនៅថ្នាក់ខេត្ត និងថ្នាក់មូលដ្ឋាន។ សូមផ្តល់ពត៌មានបន្ថែមទៀតដែរ អំពីយុទ្ធសាស្ត្រនានា ដែលប្រកាន់យកដើម្បីដោះស្រាយបញ្ហាអត្រាមរណៈរបស់មាតា ជាពិសេសអំពីដំណាក់កាលអនុវត្តដើម្បីបង្កើនការយល់ដឹងអំពីសារៈសំខាន់នៃការថែរក្សា និងពិនិត្យផ្ទៃពោះមុនពេលសំរាល ។***

**ចំលើយ :**

## ពត៌មានថ្មីៗស្តីពីស្ថានភាពសុខាភិបាល

កម្ពុជាជាប្រទេសស្ថិតនៅក្នុងចំណោមប្រទេសនានាក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិច ដែលមានកំរិតគុណភាពសុខាភិបាលទាបទោះបីជាប្រព័ន្ធសុខាភិបាលស្ថិតក្នុងដំណាក់កាលអភិវឌ្ឍន៍គួរឱ្យកត់សំគាល់ក៏ដោយ ។ អត្រាមរណៈនៃកុមារអាយុក្រោម១ឆ្នាំ មាន ៨៩ភាគពាន់នៃទារកកើតរស់ ។ អត្រាមរណៈកុមារអាយុក្រោម៥ឆ្នាំ មាន១១៥ភាគពាន់ នៃទារកកើតរស់ ។ មរណៈភាពរបស់កុមារបណ្តាលពីមូលហេតុចម្បងនានាដែលក្នុងនោះរួមមាន ជំងឺរាគ ជំងឺផ្លូវដង្ហើម ជំងឺគ្រុនឈាម កង្វះអាហាររូបត្ថម្ភធ្ងន់ធ្ងរ ដោយមានការទាក់ទងនឹងជំងឺផ្សេងៗទៀត ជំងឺកញ្ជ្រិល និងជំងឺដែលអាចបង្ការបានផ្សេងទៀត ។ ជារៀងរាល់ឆ្នាំកុមារ ១០.០០០នាក់ឆ្លងមេរោគ HIV ពីម្តាយ ហើយការឆ្លងពីម្តាយទៅកូន នៅពេលចាប់កំណើតមានចំនួន ៣០០០នាក់ ។ កុមារអាយុក្រោម៥ឆ្នាំចំនួន៣៣% មានបញ្ហាកង្វះអាហាររូបត្ថម្ភធ្ងន់ធ្ងរ កុមារក្រោមទំងន់មានចំនួន៥៣% និងកុមារខ្លះទៀត ប្រឈមមុខនឹងកង្វះជាតិអ៊ីយ៉ូត ដែលបណ្តាលឱ្យកើតជំងឺពកក និងធ្វើឱ្យមានការយឺតយ៉ាវដល់ការលូតលាស់ខាងបញ្ញា ។ មួយចំនួនទៀត ប្រឈមមុខនឹងកង្វះជីវជាតិអា ដែលអាចបណ្តាលឱ្យមានជំងឺខ្វាក់មាន់ ជំងឺស្ងួតភ្នែក និងជំងឺខ្វាក់ភ្នែក ។

ប្រជាជនចំនួន ២៩% ទទួលបានទឹកស្អាត និង ១៥% ទទួលបាននូវគ្រឿងប្រដាប់សំរាប់អនាម័យជាទូទៅ ។

## ការអនុវត្តគោលនយោបាយជាតិសុខាភិបាល

+ *គោលនយោបាយជាតិសុខាភិបាល*

គោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងវិស័យសុខាភិបាលផ្តល់អាទិភាពលើ :

- ការផ្តល់សេវាសុខភាពជាមូលដ្ឋានដល់ប្រជាជនគ្រប់រូប និង ដោយមានការចូលរួមពីសហគមន៍
- ការធ្វើវិមជ្ឈការក្នុងការគ្រប់គ្រងរដ្ឋបាល និង ហិរិញ្ញវត្ថុ
- ការអភិវឌ្ឍធនធានមនុស្ស
- បង្កលទ្ធភាពប្រកួតប្រជែងទាំងសេវាឯកជន ទាំងសេវាសាធារណៈ ដោយឈរលើមូលដ្ឋានបច្ចេកវិទ្យា និងសីលធម៌ វិជ្ជាជីវៈ ។
- ពង្រីកការយល់ដឹងរបស់ប្រជារាស្ត្រស្តីអំពីគុណសម្បត្តិរបស់អ្នកផ្តល់សេវា និងរបៀបរបបរស់នៅដែលធានាសុខភាព ។
- ការពង្រីកនីតិក្រមសុខាភិបាល

- ផ្តល់អាទិភាពប្រយុទ្ធនឹងជំងឺ សុខភាពស្ត្រី និង ទារក និងការពិនិត្យលទ្ធភាពក្នុងការថែទាំជំងឺរ៉ាំរ៉ៃ មនុស្សចាស់ និងជនពិការ សុខភាព ផ្លូវចិត្តមាត់ ធ្មេញ និង ភ្នែក ។
- ការពង្រឹងប្រព័ន្ធពតិមានសុខាភិបាល ។

\+ *គោលបំណង និង ទិសដៅនៃការអភិវឌ្ឍវិស័យសុខាភិបាល*

គោលបំណងរួមរបស់ក្រសួងសុខាភិបាល គឺលើកកំពស់សុខភាពប្រជារាស្ត្រ ដើម្បីរួមចំណែកដល់ការអភិវឌ្ឍវិស័យសេដ្ឋកិច្ចសង្គម និងការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា ។

ទិសដៅរបស់ក្រសួងសុខាភិបាល គឺលើកកំពស់សីលធម៌ និងលទ្ធភាពប្រើប្រាស់សេវាជាសារវ័ន្តដែលមានគុណភាព ប្រសិទ្ធិភាពខ្ពស់ និង តំលៃទាប ដើម្បីធានានិរន្តភាពនៃកិច្ចដំណើរការសេវា និងការពារអ្នកក្រីក្រ ។

\+ *យុទ្ធសាស្ត្រចំបង*

ដើម្បីឈានទៅសំរេចគោលបំណង និង ទិសដៅខាងលើនេះ ក្រសួងសុខាភិបាលបានកំណត់យុទ្ធសាស្ត្រសំខាន់៧ ដូចខាងក្រោមនេះ :

- លើកកំពស់សុខភាពស្ត្រី និង កុមារតាមរយៈការផ្តល់នូវ សេវាថែទាំព្យាបាលជាសារវ័ន្តដល់ស្ត្រីគ្រប់រូប ដូចជា សេវាពិនិត្យថែទាំមុនពេល និងក្រោយពេលសំរាលចំពោះស្ត្រីមានផ្ទៃពោះ ការសំរាលកូន សេវាសុខភាពបន្តពូជ រួមមានសេវាពន្យាកំណើត អាហាររូបត្ថម្ភ សុវត្ថិភាពពេលសំរាលកូន ការអនុវត្តអនាម័យផ្ទាល់ខ្លួន និងគ្រួសារ ។
- ជំរុញការចាក់វ៉ាក់សាំង និង អត្រាគ្របដណ្តប់នៃការថែរក្សាព្យាបាលដល់កុមារ ។
- កាត់បន្ថយអាំងស៊ីដង់នៃជំងឺឆ្លង ដូចជា ជំងឺគ្រុនចាញ់ ជំងឺគ្រុនឈាម ជំងឺរបេង ជំងឺរាគរូស ជំងឺផ្លូវដង្ហើម ជំងឺកាមរោគ ជាពិសេសគឺ ជំងឺអេដស៍ ។
- លើកកំពស់ការគ្របដណ្តប់នៃសេវាសាធារណៈឱ្យមានគុណភាព និងប្រសិទ្ធភាពខ្ពស់ដល់ប្រជារាស្ត្រគ្រប់រូប និង គ្រប់ទីកន្លែងតាមរយៈ ការផ្តល់សំនុំសកម្មភាពអប្បបរិមានៅមណ្ឌលសុខភាព និង សំណុំសកម្មភាពបង្គ្រប់នៅមន្ទីរពេទ្យបង្អែក ។
- លើកកំពស់សមត្ថភាពបុគ្គលិកក្រសួងសុខាភិបាលរបស់រដ្ឋាភិបាលដើម្បីទ្រទ្រង់ និងធានានូវប្រសិទ្ធិភាពនៃប្រព័ន្ធសុខាភិបាល តាមរយៈការធ្វើផែនការ ការកែលំអកម្មវិធីបណ្តុះបណ្តាលជាមូលដ្ឋាន និងពង្រីកការបណ្តុះបណ្តាលបន្តដល់បុគ្គលិកសុខាភិបាល ទាំងផ្នែកបច្ចេកទេសគ្លីនិក និង ការងារគ្រប់គ្រង ។
- ធានាឱ្យការផ្គត់ផ្គង់ឱសថ សំភារៈបរិក្ខារ ក្នុងវិស័យសាធារណៈសមស្រប តាមតំរូវការជាក់ស្តែងនៃប្រព័ន្ធ។ ការផ្តល់សេវាថែទាំសុខភាព តាមរយៈការកែទំរង់ប្រព័ន្ធបែងចែកឱសថ ពង្រឹងការគ្រប់គ្រង និងការប្រើប្រាស់ឱសថ សំភារៈបរិក្ខាឱ្យទទួលបានផលល្អ ។
- លើកកំពស់សមត្ថភាពបច្ចេកវិជ្ជា គុណភាព និងសមត្ថភាពគ្រប់គ្រងនៃសេវាមន្ទីរពេទ្យបង្អែកទូទាំងប្រទេស ក្នុងនោះ មានទាំងការពង្រឹងនូវប្រព័ន្ធបញ្ជូនជំងឺមានប្រសិទ្ធភាព ។

- ជំរុញឱ្យមានការចូលរួមយ៉ាងពេញលេញរបស់ឯកជន ក្នុងការផ្តល់សេវាសុខភាពជូនប្រជារាស្ត្រ តាមរយៈការលើកទឹកចិត្ត និងត្រួតពិនិត្យសេវាឯកជនឱ្យក្លាយទៅជាដៃគូមួយពិតប្រាកដរបស់ក្រសួងសុខាភិបាល ។
- លើកកំពស់ការយល់ដឹងរបស់ប្រជាជន ស្តីអំពីគុណសម្បត្តិសេវាគ្រប់ប្រភេទទាំងក្នុងវិស័យឯកជន និងវិស័យសាធារណៈ។ បង្កលក្ខណៈឱ្យប្រជាជនយល់ និង អនុវត្តរបៀបរស់នៅដែលមានអនាម័យ ។
- ពង្រឹងការអនុវត្តច្បាប់នានា ដែលទាក់ទងនឹងវិស័យសុខាភិបាល ឱ្យកាន់តែមានប្រសិទ្ធភាព ដោយជំរុញឱ្យមានការចូលរួមសហការអនុវត្តពីស្ថាប័នពាក់ព័ន្ធផ្សេងៗជាមួយគ្នានឹងការតែងច្បាប់ថ្មីៗ យោលទៅតាមតំរូវការជាក់ស្តែងនៃការអភិវឌ្ឍ និងពង្រឹងច្បាប់ និងបទដ្ឋានស្តីពីសេវាវេជ្ជសាស្ត្រ អនាម័យ ចំណីអាហារ អាជីវកម្ម ឱសថ បារី ។ល។
- លើកកំពស់ការគ្រប់គ្រងសុខាភិបាលតាមរយៈ ការកែទំរង់ប្រព័ន្ធសុខាភិបាល ដែលមានកំនត់តួនាទីបណ្តាថ្នាក់ឱ្យច្បាស់លាស់ ការធ្វើវិមជ្ឈការសមស្រប ការសាកល្បងគំរូនានាស្តីពីហិរញ្ញប្បទានសុខាភិបាល ការសំរបសំរួលជំនួយការកសាងផែនការ ការតាមដាន និងការវាយតំលៃ ។
- លើកកំពស់ការអភិវឌ្ឍគោលនយោបាយ ការសិក្សាស្រាវជ្រាវ និង ការពង្រីកប្រព័ន្ធពត៌មានសុខាភិបាល ។

+ *<u>សកម្មភាពដែលបានអនុវត្ត</u>*

ក្រសួងសុខាភិបាលបានចាប់ផ្តើមមានសកម្មភាពនេះតាំងពីឆ្នាំ១៩៨៦ ហើយមានសកម្មភាពទូទាំងប្រទេស។ នៅឆ្នាំ១៩៩៩ សកម្មភាពទាំងនេះរួមមានការចាក់វ៉ាក់សាំងបង្កាជំងឺតេតាណូសដល់ស្ត្រីមានផ្ទៃពោះបាន២២% នៃចំនួនស្ត្រីមានផ្ទៃពោះទាំងអស់ និង ស្ត្រីដែលអាចមានផ្ទៃពោះពីអាយុ១៥ឆ្នាំ-៤៥ឆ្នាំ។ ក្រសួងសុខាភិបាលបានបើក វគ្គបណ្តុះបណ្តាលបុគ្គលិកថ្នាក់ស្រុកមកពីខេត្តចំនួន១៥ បាន៣វគ្គ ព្រមទាំងធ្វើការបោះពុម្ពផ្សព្វផ្សាយ និង ចែកចាយនូវសំភារៈ ឬ ឯកសារអប់រំដល់ខេត្ត-ក្រុងទៀតផង ។

សកម្មភាពលុបបំបាត់ជំងឺតេតាណូសលើទារក ចាប់ផ្តើមតាំងពីឆ្នាំ១៩៩៧ ដោយយកខេត្តកំពត និងខេត្តកណ្តាលសំរាប់ធ្វើការសាកល្បង។ ដោយផ្តោតលើការពង្រីកគុណភាពនៃការស្រង់ពត៌មានពីភាពសាំតេតាណូសលើទារក និងការពង្រីកប្រព័ន្ធរបាយការណ៍ស្តីអំពីទារកកើតរស់ហើយស្លាប់ទៅវិញមុន២៨ថ្ងៃ។ ការចុះស្រាវជ្រាវគ្រប់ករណីទារកកើតរស់ហើយស្លាប់ទៅវិញមុន២៨ថ្ងៃ និងវិធានការទប់ទល់ផ្សេងៗទៀត នៅកន្លែងដែលមានតេតាណូសលើទារក។ ការងារនេះមានការបណ្តុះបណ្តាលជាបណ្តើរៗ ហើយត្រូវចាប់ផ្តើមអនុវត្តពីឆមាសទី ២ឆ្នាំ ១៩៩៨ និង បន្តរហូតដល់សព្វថ្ងៃ។ គ្រប់ករណីដែលបានរាយការណ៍ និង ចុះស្រាវជ្រាវឃើញសង្ស័យថាមានតេតាណូសលើទារកនោះ ថ្នាក់ខេត្ត ស្រុក បានចុះធ្វើយុទ្ធនាការអប់រំសុខភាព និងចាក់ថ្នាំបង្ការដល់ស្ត្រីដែលមានអាយុពី១៥-៤៥ឆ្នាំ ក្នុងភូមិ ស្រុកនោះ ។

ក្រសួងសុខាភិបាល បានអនុវត្តសកម្មភាពបន្តក់ថ្នាំបង្ការជំងឺគ្រុនស្វិតដៃជើងរហូតដល់តំបន់ដាច់ស្រយាល ដែលបានទទួលលទ្ធផលគួរជាទីពេញចិត្ត ដោយកុមារអាយុក្រោម៥ឆ្នាំ មាន ៩៥% ទទួលបានថ្នាំការពារជំងឺគ្រុនស្វិតដៃជើង។ លើសពីនេះទៅទៀតតាមការស្រាវជ្រាវបានបង្ហាញឱ្យឃើញថា គ្រប់តំបន់ក្នុងប្រទេសកម្ពុជា ការចំលងវីរុសប៉ូលីយូ ត្រូវបានកាត់ផ្តាច់ចាប់ពីខែមិនា ឆ្នាំ១៩៩៨។ ដូចនេះ បច្ចុប្បន្នប្រទេសកម្ពុជាស្ថិតនៅក្នុងដំណាក់កាលចុងក្រោយនៃការលុបបំបាត់ជំងឺគ្រុនស្វិតដៃជើង។ សកម្មភាពស្រាវជ្រាវរកករណីនៃការផ្ទុះជំងឺកញ្ជ្រឹលតាមរយៈប្រព័ន្ធស្រាវជ្រាវករណីជំងឺខ្វិនទន់អវៈយវៈនៅឆ្នាំ១៩៩៩ នេះជួយបង្កើនអត្រាគ្របដណ្តប់ នៃការចាក់ថ្នាំបង្ការជំងឺកញ្ជ្រឹលលើកុមារអាយុ៩ខែ ដល់អាយុ៥ឆ្នាំ។ សកម្មភាពនេះ បានសាកល្បងក្នុងខេត្តទាំង ៦ សំរាប់ធ្វើការតាមដានរាល់ការផ្ទុះឡើងនៃជំងឺកញ្ជ្រឹល។

គ្រុនឈាម ជាជំងឺមួយដែលមានលក្ខណៈឆ្លង និងរាតត្បាត និងមានកើតជាប្រចាំនៅប្រទេសកម្ពុជា ហើយការរាតត្បាតកើតមានឡើងជាទ្រង់ទ្រាយធំរាល់២ ឬ៣ឆ្នាំម្តង។ ការរាតត្បាតធំចុងក្រោយកើតមាននៅឆ្នាំ១៩៩៨ ដែលក្នុងនោះមានករណីចំនួន១៦,២៦៩ នាក់ និង មានស្លាប់ចំនួន៤៧៥ នាក់។ នៅឆ្នាំ១៩៩៩ នេះ ពុំមានការរាតត្បាតជាទ្រង់ទ្រាយធំទេ ។ តាមរបាយការណ៍ក្នុងរយៈពេល៩ខែ ដើមឆ្នាំ មានករណីជំងឺ១.២៧២នាក់ និងស្លាប់២២ នាក់។ អត្រាស្លាប់បានថយចុះពី២,៩២% នៅឆ្នាំ១៩៩៨ មក១,៧៨% នៅឆ្នាំ១៩៩៩។ ទោះបីស្ថានការណ៍នៃជំងឺគ្រុនឈាមមិនធ្វើឱ្យមានការព្រួយបារម្ភក៏ដោយ ក៏ក្រសួងសុខាភិបាលនៅតែខិតខំយកចិត្តទុកដាក់យ៉ាងខ្លាំងក្លា ដើម្បីទប់ស្កាត់ការរាតត្បាតនៃជំងឺនេះ។ ក្រសួងសុខាភិបាលបានសហការជាមួយអាជ្ញាធរមូលដ្ឋាន និងអង្គការពាក់ព័ន្ធមួយចំនួនប្រយុទ្ធយ៉ាងស្វិតស្វាញតាមរយៈការឃោសនាអប់រំ ការបាញ់ថ្នាំ សំលាប់មូស និង ចែកអាល់បេតដាក់ក្នុងពាងទឹកជាដើម ដែលធ្វើឱ្យការរាតត្បាតនៃជំងឺគ្រុនឈាមមានការថយចុះ ។

ជាមួយគ្នានេះដែរ ក្រសួងសុខាភិបាលនៅមានសកម្មភាពជាច្រើនដូចជា :

- ការប្រយុទ្ធនឹងជំងឺឆ្លង
- ការប្រយុទ្ធនឹងជំងឺគ្រុនចាញ់
- ការប្រយុទ្ធនឹងជំងឺដង្កូវក្នុងពោះវៀន
- ការប្រយុទ្ធនឹងជំងឺអាសន្នរោគ
- ការប្រយុទ្ធនឹងជំងឺអេដស៍ និង កាមរោគ
- ការប្រយុទ្ធនឹងជំងឺរបេង ហង់សិន ដែលមានទាក់ទងនៅនឹងកុមារ ព្រមទាំងទទួលជោគជ័យជាបណ្តើរៗ។

មានសកម្មភាពផ្តល់ជីវជាតិអាតាមរយៈកម្មវិធីបណ្តក់ថ្នាំបង្ការជំងឺគ្រុនស្វិតដៃជើង៣ពេលក្នុង១ឆ្នាំ បានទទួលលទ្ធផលរហូតតំបន់ដាច់ស្រយាលបាន ៩៥% ។ បញ្ចូលជាតិអ៊ីយ៉ូតទៅក្នុងអំបិលសំរាប់ប្រើប្រាស់នៅតាមទីក្រុង និង នៅតាមខេត្តនានា ។ បើកវគ្គបណ្តុះបណ្តាលស្តីពីអាហារូបត្ថម្ភ កង្វះជីវជាតិអា កង្វះជាតិដែក កង្វះជាតិអ៊ីយ៉ូត លើកុមារអាយុក្រោម៥ឆ្នាំ ដល់៤ស្រុកក្នុងខេត្តតាកែវ និង ១ស្រុកក្នុងខេត្តកំពង់ធំ។ សកម្មភាពបញ្ចូលជាតិដែក ដើម្បីលុបបំបាត់ជំងឺស្លេកស្លាំងនៃស្ត្រីមានផ្ទៃពោះមិនទាន់ បានអនុវត្ត ដោយកង្វះផ្នែកថវិកា និង កង្វះធនធានមនុស្ស ។

ក្រសួងអភិវឌ្ឍន៍ជនបទ បានធ្វើការចុះអប់រំសុខភាពអនាម័យ និង ការប្រើប្រាស់ទឹកស្អាតដល់អ្នកភូមិឃុំ ពិសេសដល់ស្ត្រី និងកុមារនៅក្នុងខេត្តចំនួន១៧ ដើម្បីឱ្យយល់ដឹងពីអនាម័យរាងកាយ អនាម័យទឹក អនាម័យលំនៅដ្ឋាន អនាម័យអាហារ ការសាងសង់បង្គន់ ការប្រើប្រាស់ និង ថែទាំបង្គន់អនាម័យ អនាម័យបរិស្ថាន ។ សាងសង់បង្គន់អនាម័យតាមគ្រួសារបានចំនួន ១០.០០០ ក្នុងខេត្តទាំង១៥។ មានអង្គការជាច្រើនបានជួយជីកអណ្តូងទឹកជូនប្រជាជននៅតាមភូមិ។ នៅឆ្នាំ១៩៩៥ សហគមន៍អឺរ៉ុប បានជួយជីកអណ្តូងជាច្រើនដល់ខេត្តចំនួន ៦ (កំពង់ឆ្នាំង កំពង់ចាម កំពង់ស្ពឺ ព្រៃវែង ស្វាយរៀង និង តាកែវ ) នៅឆ្នាំ ១៩៩៩ រដ្ឋាភិបាលប្រជាមានិតចិន បានផ្តល់អណ្តូងស្នប់ចំនួន៥០០។ ធនាគារអភិវឌ្ឍអាស៊ី ធនាគារពិភពលោកបណ្តាអង្គការក្រៅរដ្ឋាភិបាល និង សប្បុរសជនក្រៅប្រទេសជាច្រើនទៀត បានផ្តល់អំណោយអណ្តូងស្នប់មួយចំនួន ។

## ផ្នែកសេវាសុខភាពបឋម និងសេវាបង្ការសុខភាពបឋមថ្នាក់ខេត្ត និងថ្នាក់មូលដ្ឋាន :

រាជរដ្ឋាភិបាលកំពុងពិនិត្យលើសេចក្តីព្រាងច្បាប់ចំនួនពីរគឺ សេចក្តីព្រាងច្បាប់អនាម័យ សេចក្តីព្រាងច្បាប់ស្តីពីចំណីអាហារ។ ការងារអប់រំសុខភាពបឋម និងអនាម័យ ជាមូលដ្ឋានគន្លឹះក្នុងការបង្កើនការយល់ដឹង និងការចូលរួមរបស់ប្រជាជនគ្រប់រូបដើម្បីអនុវត្តវិធានការនានា រួមទាំងអនាម័យបុគ្គល អនាម័យបរិស្ថានរស់នៅដើម្បីទប់ស្កាត់ ឬបង្ការជំងឺផ្សេងៗ ជាពិសេសជំងឺឆ្លង។ ការងារនេះធ្វើឡើងដោយក្រសួងជំនាញ តាមរយៈប្រព័ន្ធពតិមានចំរុះ ដែលក្រសួងជំនាញខិតខំផលិតសំភារៈអប់រំសំរាប់

ចែកចាយដល់អង្គភាពសុខាភិបាលខេត្ត-ក្រុង បណ្តាក្រសួងស្ថាប័ន ព្រមទាំងបណ្តាញឃោសនាផ្សេងៗទៀត។ មានការអប់រំដោយផ្ទាល់មាត់ ធ្វើឡើងដោយបុគ្គលិកសុខាភិបាល និង មន្ត្រីស្ម័គ្រចិត្ត ។ មានការបណ្តុះបណ្តាលតាមរយៈសិក្ខាសាលា និង វគ្គបណ្តុះបណ្តាលផ្សេងៗជាច្រើន។ រាជរដ្ឋាភិបាលពង្រីកការចាក់ថ្នាំបង្ការដល់តំបន់ដាច់ស្រយាល ដោយបានទទួលនូវអត្រាគ្របដណ្តប់ជាទីពេញចិត្ត ។

ថ្វីត្បិតតែរាជរដ្ឋាភិបាលទទួលបាននូវលទ្ធផលគួរជាទីកត់សំគាល់ក៏ដោយ ក៏រាជរដ្ឋាភិបាលទទួលស្គាល់ថា នៅមានការខ្វះខាតមួយចំនួនដោយបញ្ហាជំងឺចេះកើនឡើង ឯលទ្ធភាពដោះស្រាយនៅមានកំរិត ។

- ការប្រើប្រាស់ប្រព័ន្ធពត៌មានចំរុះសំរាប់ការងារ នៅពុំទាន់បានទូលំទូលាយដល់ថ្នាក់ស្រុក និង ទូទាំងប្រទេស ។
- ការប្រើប្រាស់សេវាសុខភាពសាធារណៈ នៅមានកំរិតនៅឡើយ ។
- ចំណេះដឹងរបស់ប្រជាជននៅមានកំរិត ។

**យុទ្ធសាស្ត្រនានាដើម្បីដោះស្រាយបញ្ហាអត្រាមរណៈនៃមាតា :**

អត្រាមរណៈរបស់មាតាមានចំនួន ៤៧៣នាក់ ក្នុងទារកកើតរស់ ១០០.០០០ នាក់ ។ មូលហេតុចម្បងនៃការស្លាប់ ច្រើនបណ្តាលមកពីផលវិបាកនៃការរំលូត ជំងឺព្រាយក្រឡាភ្លើង និង ការធ្លាក់ឈាម ។ អត្រាស្ត្រីមានផ្ទៃពោះ ដែលផ្ទុកមេរោគហ៊ីវមាន ៣% ។ ក្រសួងសុខាភិបាល បានរបាយការណ៍ថា ស្ត្រីប្រមាណ ៣៤% ប៉ុណ្ណោះ ដែលបានសំរាលកូនដោយបុគ្គលិកដែលមានការបណ្តុះបណ្តាលត្រឹមត្រូវ ហើយក្រៅពីនោះ សំរាលដោយឆ្មបបុរាណគ្មានការបណ្តុះបណ្តាលដោយខ្វះការថែទាំជាសារវ័ន្ត ផ្ទែកសម្ភពនៅតាមស្រុក ។ រាជរដ្ឋាភិបាលទទួលស្គាល់បញ្ហា ហើយខិតខំរិះរកយុទ្ធសាស្ត្រ ដើម្បីកាត់បន្ថយនូវអត្រាមរណៈនេះ ដោយផ្តោតទៅលើការអភិវឌ្ឍគោលនយោបាយ ផែនការ ការស្រាវជ្រាវ ព្រមទាំងការបណ្តុះបណ្តាល និងអភិបាលកិច្ចតាមមូលដ្ឋានសុខាភិបាលគ្រប់លំដាប់ថ្នាក់ ។

ការអភិវឌ្ឍសំភារៈសំរាប់អប់រំសុខភាព និង ពិធីសារថែទាំ និង ផ្តល់សេវានៅតាមមណ្ឌលសុខភាព និង មន្ទីរពេទ្យក្នុងទូទាំងប្រទេសដូចជា :

- ការថែទាំមុនពេលសំរាលដោយបង្កើនអត្រាគ្របដណ្តប់នៃការត្រួតពិនិត្យមុនពេលសំរាល ឱ្យបានយ៉ាងហោចពីរដងសំរាប់ស្ត្រីមានផ្ទៃពោះម្នាក់ ក្នុងរយៈពេលនៃការមានផ្ទៃពោះព្រមទាំងផ្តល់វ៉ាក់សាំងសំរាប់ការពារជំងឺតេតាណូស។
- បង្កើនសកម្មភាពនៃការស្រាវជ្រាវរកស្ត្រីមានផ្ទៃពោះមានបញ្ហា ហើយបញ្ជូនទៅកាន់មន្ទីរពេទ្យដើម្បីតាមដាន និង ថែទាំ ជៀសវាងការមានគ្រោះថ្នាក់នៅពេលសំរាល ។
- ការសំរាលត្រូវធ្វើឡើងដោយមន្ត្រីសុខាភិបាលដែលមានការបណ្តុះបណ្តាលត្រឹមត្រូវ ។
- ពង្រីកសកម្មភាពនៃសេវាពន្យាកំណើត ព្រមទាំងសេវាសុខភាពបន្តពូជដល់ស្ត្រីគ្រប់រូបចាប់ពីអាយុ១៥ ឆ្នាំ៤៥ ឆ្នាំ ។
- បណ្តុះបណ្តាលដល់បុគ្គលិកសុខាភិបាលជាទៀងទាត់ រួមនឹងសកម្មភាពចុះអភិបាល ដើម្បីលើកកំពស់សមត្ថភាពបច្ចេកទេស និង គុណភាពសេវា ។

***សំនួរទី១៤ :*** ***ទាក់ទងនឹងសុខភាពរបស់មនុស្សវ័យជំទង់ សូមផ្តល់ពត៌មានបន្ថែម អំពីវិធានការដែលរដ្ឋជាភាគីបានប្រកាន់យក ដើម្បីផ្តល់ពត៌មានអំពីសុខភាពបន្តពូជដល់កុមារ និងមនុស្សវ័យជំទង់ រួមទាំងពត៌មាន***

***ដែលទាក់ទងទៅនឹងកិច្ចបង្ការ និងការថែទាំជំងឺHIV/AIDs និងជំងឺកាមរោគទាំងក្នុងនិងក្រៅសាលារៀន ។ សូមផ្តល់ពត៌មានបន្ថែមអំពីវិធានការអនុវត្ត ដើម្បីបង្កើនការយល់ដឹងអំពីផលមិនល្អនៃការឆាប់រៀបអាពាហ៍ពិពាហ៍វ័យក្មេងពេក ដែលបញ្ហានេះត្រូវគេរាយការណ៍ថាកំពុង រីករាលដាលនៅទូទាំងប្រទេស ។***

**ចម្លើយ :**

**<u>មេរោគហ៊ីវ និង ជំងឺអេដស៍</u> :**

នៅតំបន់អាស៊ីអគ្នេយ៍ ប្រទេសកម្ពុជាកំពុងប្រឈមមុខនឹងការរីករាលដាលយ៉ាងឆាប់រហ័សបំផុតនៃមេរោគហ៊ីវ និង ជំងឺអេដស៍។ តាមការប៉ាន់ប្រមាណទុកជាមុនរបស់អង្គការសុខភាពពិភពលោក កុមារអាយុក្រោម១៥ឆ្នាំ ចំនួនជាង ១៥.០០០ នាក់ នឹងមានផ្ទុកមេរោគហ៊ីវនៅចុងឆ្នាំ ២០០០ នេះ ហើយកុមារជិត ៨.០០០ នាក់ នឹងមានជំងឺអេដស៍។ កុមារកំព្រាអាយុក្រោម ១៥ ឆ្នាំ ដែលបន្សល់ទុកដោយសារមេរោគហ៊ីវ និង ជំងឺអេដស៍ នឹងមានចំនួន ៣០.០០០ នាក់ ក្នុងឆ្នាំ ២០០០ និងអាចកើនឡើងដល់ ៦០.០០០ នាក់ ក្នុងឆ្នាំ ២០០២ ។

**<u>ការផ្តល់ពត៌មាន ស្តីអំពីសុខភាពបន្តពូជដល់កុមារ និងមនុស្សជំទង់ ជាពិសេសអំពីហ៊ីវ និងអេដស៍</u>**

ប្រទេសកម្ពុជាបានបង្កើតអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ តាមរយៈព្រះរាជក្រិត្យលេខ ន.ស.រ.ក.ត.០៩៩.០១ ចុះថ្ងៃទី ០៤ ខែមេសា ឆ្នាំ ១៩៩៩ ។ អាជ្ញាធរជាតិមានសមាសភាពមកពីក្រសួងផ្សេងៗ និង មានតំណាងមកពីអាជ្ញាធរមូលដ្ឋាន ។ អាជ្ញាធរជាតិបានរៀបចំគោលនយោបាយជាតិ និងយុទ្ធសាស្ត្រជាអាទិភាព ដើម្បីបង្ការមេរោគហ៊ីវ និងជំងឺអេដស៍ និងត្រួតពិនិត្យចាប់ពីឆ្នាំ ១៩៩៩-២០០៤ ។ ( សូមមើលឧបសម្ព័ន្ធដែលភ្ជាប់មកជាមួយ ) ។

គោលនយោបាយជាតិ និង យុទ្ធសាស្ត្រជាអាទិ៍គឺ : រចនាសម្ព័ន្ធគ្រប់គ្រងមេរោគហ៊ីវ ជំងឺអេដស៍ គ្រប់គ្រង និងស្វែងរកថវិកា អប់រំ នឹងផ្តល់ពតិមានសុខភាពស្តីពីមេរោគហ៊ីវ ជំងឺអេដស៍ កិច្ចបង្ការទប់ស្កាត់ និងគ្រប់គ្រងថែទាំអ្នកផ្ទុកមេរោគហ៊ីវ ជំងឺអេដស៍ ។ ផ្អែកតាមគោលនយោបាយទាំងនោះមាន :

- គ្រប់ស្ថាប័នជាតិ ខេត្ត ក្រុង និងអាជ្ញាធរ ត្រូវធានាធ្វើយ៉ាងណាដើម្បីឱ្យមន្ត្រីរាជការ និងប្រជាពលរដ្ឋបានទទួលនូវពតិមានជាអតិបរមា ស្តីពីគ្រោះថ្នាក់នៃមេរោគហ៊ីវ និង ជំងឺអេដស៍ និង វិធានការបង្ការទប់ស្កាត់ ។
- កម្មវិធីអេដស៍ត្រូវបញ្ចូលទៅក្នុងកម្មវិធីជាតិដទៃទៀត ដែលស្ថិតនៅក្នុងការគ្រប់គ្រងរបស់រដ្ឋ និង ឯកជន ។
  - ឧ- កម្មវិធីប្រយុទ្ធនឹងជំងឺអេដស៍របស់ក្រសួងសុខាភិបាល ត្រូវបញ្ចូលទៅក្នុងកម្មវិធីជាតិគាំពារមាតា និងទារក កម្មវិធីជាតិសុខភាពបឋម កម្មវិធីជាតិកំចាត់ជំងឺរបេង កម្មវិធីជាតិកំចាត់ជំងឺគ្រុនចាញ់ ។ល។ ឱ្យមានទំនាក់ទំនងស៊ីសង្វាក់ គ្នា ។
- ក្រសួងអប់រំ យុវជន និងកីឡា ត្រូវបញ្ចូលកម្មវិធីអប់រំសុខភាពស្តីពីជំងឺអេដស៍ ទៅក្នុងកម្មវិធីសិក្សានានា នៅគ្រប់កំរិតទាំងអស់ តាមប្រធានបទសមស្រប ។
- ក្រសួងធម្មការ និង កិច្ចការសាសនា ព្រមទាំងអង្គការសាសនានានា ត្រូវបញ្ចូលកម្មវិធីផ្សព្វផ្សាយពីជំងឺអេដស៍ទៅដល់សាសនិកទាំងអស់ ។
- អត្ថបទនៃការអប់រំជំងឺអេដស៍ ត្រូវតែធ្វើឡើងក្នុងក្របខ័ណ្ឌគោរពនូវប្រពៃណី និងទំនៀមទំលាប់របស់ខ្មែរសមស្របទៅនឹងស្ថានភាពជីវភាពរស់នៅបច្ចុប្បន្ន ប៉ុន្តែមិនអភិរក្សពេកទេ ។

- ទប់ស្កាត់ការផ្សព្វផ្សាយនូវពត៌មានណាដែលនាំឱ្យប្រជាពលរដ្ឋមានការភ័ន្តច្រឡំពីជំងឺអេដស៍។ រាជរដ្ឋាភិបាលបានប្រកាន់យកវិធានការមួយចំនួន ដើម្បីបញ្ឈប់ និងបង្ការមេរោគហ៊ីវ ជំងឺអេដស៍ ។
- ក្រសួងអប់រំ យុវជន និងកីឡា បានបញ្ចូលប្រធានបទ មេរោគហ៊ីវ ជំងឺអេដស៍ ជំងឺកាមរោគទៅក្នុងកម្មវិធីសិក្សាផ្នែបឋមសិក្សា (ថ្នាក់ទី៦) ផ្នែកមធ្យមបឋមភូមិ (ថ្នាក់ទី៩)។ លោកគ្រូ អ្នកគ្រូបានត្រូវបណ្តុះបណ្តាល អំពីប្រធានបទនេះ ដូច្នេះគាត់អាចយល់ដឹងបានល្អ និង អាចពន្យល់ដល់សិស្ស ។
- នៅក្រៅសាលា កុមារអាចយល់ដឹងតាមរយៈប្រព័ន្ធផ្សព្វផ្សាយពត៌មានចំរុះ (ផ្ទាំងរូបភាព សៀវភៅផ្នត់ ស្គត ចំរៀងឆាកកំប្លែង...) ។
- អង្គការក្រៅរដ្ឋាភិបាលមួយចំនួន ជាពិសេសអង្គការដែលធ្វើការងារកុមារអនាថា ប្រើវិធីសាស្ត្រ " កុមារអប់រំកុមារ "
- មានការអប់រំអំពីការមិនរើសអើងជាមួយអ្នកមានមេរោគហ៊ីវ ជំងឺអេដស៍ ជំងឺកាមរោគ ដោយធ្វើឱ្យកុមារមនុស្សពេញវ័យ មើលឃើញច្បាស់ពីការមិនឆ្លងជំងឺអេដស៍ ( ដោយក្រុមការងារអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ )។
- ដើម្បីទាក់ទាញមតិគាំទ្រ និងធ្វើឱ្យមានការយល់ពីផលវិបាកនៃការឆ្លងជំងឺអេដស៍ ពីការបង្ការជំងឺអេដស៍ក្រុមតុក្កតារបស់ក្រុមហ៊ុនស្រោមអនាម័យលេខ១ និងសិល្បៈល្ខោនស្បែក បានទៅលេងជូនសាធារណៈជននៅទីធ្លាសាធារណៈ។ ឯការសម្តែងមួយចំនួនទៀតធ្វើឡើងដោយកុមារដែលជាសិល្បករ ។
- ក្រសួងកិច្ចការនារី និង អតីតយុទ្ធជន បានបញ្ចូលកម្មវិធីអប់រំសុខភាពបន្តពូជ និង HIV , AIDs , STDs ទៅក្នុងកម្មវិធី ផ្សព្វផ្សាយពត៌មានចំរុះ ។

**ផលវិបាកវិជ្ជមាននានានៃការឆាប់រៀបអាពាហ៍ពិពាហ៍ពេក :**

ទោះជាគេដឹងថា មានការរៀបអាពាហ៍ពិពាហ៏ក្នុងវ័យក្មេងពេក ជាពិសេសនៅតំបន់ជនបទ ក៏ពុំទាន់មានការអង្កេតណាមួយបានធ្វើនៅឡើយ។ អាស្រ័យហេតុនេះ គឺជាការពិបាកនឹងយល់ដឹងអំពីវិសាលភាពនៃបញ្ហាថា តើការរៀបអាពាហ៍ពិពាហ៍នោះរីករាលដាលយ៉ាងណា ហើយអ្នកដែលឆាប់រៀបអាពាហ៍ពិពាហ៍នោះមានអាយុប៉ុន្មានឆ្នាំ។ ពុំទាន់មានវិធានការណាមួយដែលត្រូវបានប្រកាន់យកទាក់ទងនឹងបញ្ហានេះទេ ។

***សំនួរទី ១៥ : យោងទៅនឹងចំនួនកុមារពិការដែលមានកំរិតខ្ពស់នៃប្រទេសជាភាគី សូមផ្តល់ពត៌មានបន្ថែមទៀត អំពីវិធានការដែលប្រកាន់យក សំដៅអនុវត្តយុទ្ធសាស្ត្រជាតិសំរាប់ភាពពិការ និងដើម្បីជំរុញការស្តារកាយសម្បទា និងធ្វើសង្គមសមាហរណកម្មកុមារទាំងនេះ។ សូមផ្តល់ផងដែរនូវពត៌មានដែលទាក់ទងទៅនឹងច្បាប់ជាងមេដែលទាក់ទងនឹងកិច្ចការពារកុមារពិការ។***

**ចម្លើយ :**

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា បានបង្កើតក្រុមប្រឹក្សាសកម្មភាពជនពិការតាមប្រកាសលេខ៣០៨ ស.ក.ប.យ ចុះថ្ងៃទី ២៩ ខែតុលា ឆ្នាំ ១៩៩៩ ដែលដឹកនាំដោយក្រសួង។ ក្រុមប្រឹក្សាសកម្មភាពជនពិការមានសមាសភាពតំណាងក្រសួង អប់រំ យុវជន និងកីឡា ក្រសួងសុខាភិបាល អង្គការក្រៅរដ្ឋាភិបាលដែលពាក់ព័ន្ធ និងអង្គការជនពិការកម្ពុជា។ ក្រុមប្រឹក្សានេះមានទស្សនៈធ្វើឱ្យបុគ្គលគ្រប់រូប និងសង្គមទទួលស្គាល់ថា ជនពិការមានសិទ្ធិស្មើគ្នា និងមានកាតព្វកិច្ចដូចប្រជាពលរដ្ឋទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជា។ គណៈកម្មាការកុមារពិកានៃក្រុមប្រឹក្សាសកម្មភាពជនពិការ និងក្រសួងអប់រំ យុវជន និង កីឡា កំពុងផ្តួចផ្តើមអភិវឌ្ឍន៍គោលនយោបាយ និងគោលការណ៍ក្នុងវិស័យអប់រំ ដើម្បីផ្តល់ឱកាសឱ្យកុមារពិការគ្រប់រូប បានទទួលនូវការសិក្សាអប់រំ និង បានចូលរួមក្នុងសង្គមដូចកុមារដទៃទៀត ។

កម្មវិធីជាច្រើនបានធ្វើឡើងដោយកិច្ចសហការរវាង អង្គការក្រៅរដ្ឋាភិបាលធ្វើការងារក្នុងវិស័យជនពិការ ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា និងក្រសួងសុខាភិបាល ដើម្បីស្តារកាយសម្បទា និងបណ្តុះបណ្តាលដល់ជនពិការរួមទាំងកុមារពិការផង តាមមជ្ឈមណ្ឌលស្តារសម្បទា និងធ្វើការអប់រំដល់មាតាបិតាឱ្យចេះ ព្យាបាលកូនពិការ រួមជាមួយសម្ភារៈជំនួយផ្សេងៗ ដោយមានការចូលរួមពីសហគមន៍ ។

សេចក្តីព្រាងច្បាប់ស្តីពីការការពារសិទ្ធិ ជនពិកាត្រូវបានរៀបចំឡើងដោយក្រុមការងារ នៃអង្គការជនពិកាកម្ពុជាដោយមានជំនួយពីការិយាល័យនៃឧត្តមស្នងការសិទ្ធិមនុស្ស នៃអង្គការសហប្រជាជាតិ និងមានការចូលរួមផ្តល់មតិពីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា បច្ចុប្បន្នកំពុងតែត្រូវបានពិនិត្យដោយនាយកដ្ឋានស្តារលទ្ធភាពពលកម្ម នៃក្រសួងសង្គមកិច្ច រួមជាមួយនឹងគណៈកម្មការមួយ ដែលមានសមាភាពជាតំណាងមកពីក្រសួងពាក់ព័ន្ធ និងអង្គការក្រៅរដ្ឋាភិបាលនានា។ សេចក្តីព្រាងនេះនឹងត្រូវពិនិត្យនៅពេលខាងមុខ។

## ការអប់រំ ការលំហែ និងសកម្មភាពវប្បធម៌

*( មាត្រា ២៨ ២៩ និង មាត្រា ៣១ )*

***សំនួរទី១៦ :*** ***យោងទៅតាមប្រព័ន្ធអប់រំរបស់រដ្ឋជាភាគី សូមបញ្ជាក់អំពីវិធានការប្រកាន់យក ដើម្បីអនុវត្តបទបញ្ញត្តិនៃអនុសញ្ញាដែលកំណត់ពីកាតព្វកិច្ចរបស់រដ្ឋជាភាគី ដែលការសិក្សានៅបឋមសិក្សា ជាកាតព្វកិច្ចមិនបង់ថ្លៃចំពោះកុមារទាំងអស់ ។ សូមបញ្ជាក់បន្ថែមអំពីវិធានការអនុវត្ត ដើម្បីផ្តល់មធ្យោបាយអប់រំឱ្យបានគ្រប់គ្រាន់ ដើម្បីធានាថាមានគ្រូដែលមានសមត្ថភាព មានសៀវភៅសិក្សា និងសំភារៈឧបទេសគ្រប់គ្រាន់នៅក្នុងប្រព័ន្ធសាលារៀន ។ ដោយឡែកសូមបញ្ជាក់ សូមបញ្ជាក់បន្ថែមនូវពត៌មានអំពីវិធានការអនុវត្ត ដែលធានាថាក្រុមជនងាយរងគ្រោះ ដែលបញ្ជាក់នៅក្នុងរបាយការណ៍បានចូលរៀននៅសាលា និងមានវិធានការលើកទឹកចិត្ត ដល់អ្នកចូលរៀនទៀងទាត់ និងកាត់បន្ថយអត្រាបោះបង់សាលារៀន ជាពិសេសចំពោះកុមារី និងកុមារាមិនមែនជនជាតិខ្មែរ ។***

**ចម្លើយ :**

- **ការអប់រំ ការលំហែ និងសកម្មភាពវប្បធម៌**

ដោយមកពីភាពក្រីក្រ ខ្វះខាតកំលាំងពលកម្មក្នុងគ្រួសារ និងកំរិតយល់ដឹងទាប ប្រជាជនមួយចំនួនគិតថា ការអប់រំមិនទាន់ជាតំរូវការចាំបាច់សំរាប់គាត់ និងគ្រួសារគាត់ឡើយ ។ អាស្រ័យហេតុនេះ ក្រសួងអប់រំ យុវជន និងកីឡា ពុំទាន់អាចនឹងបង្កើតច្បាប់ដោយឡែក ដាក់ការអប់រំចំណេះទូទៅមូលដ្ឋាន ៩ ឆ្នាំ ជាកាតព្វកិច្ចដល់ប្រជាពលរដ្ឋបាន ។ ការអប់រំនៅបឋមសិក្សាពុំមានលក្ខណៈជាកាតព្វកិច្ចតាមផ្លូវច្បាប់ នោះឡើយ ។

តាមការអង្កេត " *អំពីការអប់រំ* " របស់នាយកដ្ឋានផែនការ នៃក្រសួងអប់រំ យុវជន និងកីឡា និងអង្គការ **CARE** អន្តរជាតិនៅខែកក្កដា ឆ្នាំ១៩៩៨ បង្ហាញថា អ្នកបានទទួលអប់រំចប់ត្រឹមបឋមសិក្សា មិនបានធ្វើការប្រែប្រួលក្នុងការរកប្រាក់ចំណូលឡើយ បើប្រៀបធៀបទៅនឹងអ្នកដែលមិនបានទទួលការអប់រំសោះ។ ប៉ុន្តែអ្នកដែលបានបញ្ចប់ការសិក្សាត្រឹមកំរិតមធ្យមសិក្សាបឋមភូមិតែងតែទទួលបាននូវប្រាក់ចំនួលខ្ពស់ជាងអ្នកដែលបានបញ្ចប់ការសិក្សាត្រឹមតែកំរិតបឋម ។

ក្រសួងអប់រំ យុវជន និងកីឡា បាននឹងកំពុងយកចិត្តទុកដាក់បង្កឱកាសស្មើគ្នាដល់កុមារា-កុមារី នៅគ្រប់តំបន់គ្រប់ជនជាតិ ស្ថិតនៅក្នុងវ័យសិក្សាឱ្យបានចូលរៀនគ្រប់ៗគ្នា ចប់បឋមសិក្សា និង ឈានទទួលការអប់រំមូលដ្ឋាន ៩ ឆ្នាំ ។

ការសិក្សានៅកម្ពុជា គឺជាការសិក្សាឥតបង់ថ្លៃ។ ដោយរដ្ឋមានការលំបាកខាងថវិកានោះ គេសង្ឃឹមតិចតួចណាស់ថា នៅក្នុងអនាគតដ៏ខ្លីនេះរដ្ឋអាចនឹងធានាដល់កុមារគ្រប់ៗរូប បានទទួលឱកាសស្មើៗគ្នាក្នុងការទទួលការអប់រំ៩ឆ្នាំ។ បណ្តាញសេវាអប់រំ និង ភាពឃ្លាតគ្នារវាងសាលារៀននៅទីក្រុង និង នៅជនបទដាច់ស្រយាល ក៏នៅជាបញ្ហានៅឡើយ ។

ថវិកាជាតិសំរាប់ផ្នែកអប់រំ គឺបានធានាផ្គត់ផ្គង់តែប្រាក់បៀវត្សមន្ត្រីអប់រំ ( គ្រូបង្រៀន និងមន្ត្រីគ្រប់គ្រងអប់រំ) ហើយនឹងមានថវិកាបន្តិចបន្តួចទៀតសំរាប់ចំណាយបុព្វហេតុថ្នាក់កណ្តាល និងថ្នាក់ខេត្តតែប៉ុណ្ណោះ។ នៅឆ្នាំ១៩៩៨ ចំណាយសរុបនៃថវិកាជាតិ សំរាប់អប់រំមានចំនួន១៤៧ពាន់លានរៀល ស្មើនឹង១០.៣% នៃថវិកាជាតិទាំងមូល ឬប្រហាក់ប្រហែលនឹង១.៥% នៃផលទុនក្នុងស្រុកសរុប (GDP)។ ផ្ទុយទៅវិញថវិកាឆ្នាំ១៩៩៧ មាន៨.១ នៃថវិការដ្ឋ ប៉ុន្តែនៅឆ្នាំ១៩៩៩ គំរោងចំណាយថវិការបស់ជាតិមកលើវិស័យអប់រំយុវជន និងកីឡា មាន៨.៣% បើគិតជាសាច់ប្រាក់ គឺមានការកើនឡើងបន្តិច១៤៩.៥ ពាន់លានរៀល។ នៅឆ្នាំ២០០០នេះ គំរោងចំណាយរបស់ថវិកាជាតិមកវិស័យអប់រំ មានការកើនឡើង ១៨៣.១៧០ពាន់លាន រៀលស្មើនឹង ១៣.៩២% នៃថវិការដ្ឋ ។ ជាការពិត ថវិកាជាតិដែលផ្តល់នេះនៅតែទាប ជាងតំរូវការជាក់ស្តែងរបស់ក្រសួងឆ្ងាយណាស់ ។

ការសិក្សាមួយធ្វើដោយក្រសួងអប់រំ យុវជន និង កីឡា បានបង្ហាញថា កម្ពុជាជាប្រទេសមួយក្នុងចំណោមប្រទេសនានាលើសកលលោកដែលប្រជាជន និងសហគមន៍របស់ខ្លួនបានចំណាយធនធានច្រើនសំរាប់ការអប់រំ។ នេះអាចបណ្តាលមកពីប្រទេសជាតិបានឆ្លងកាត់របបចំឡែកមួយក្នុងសតវត្សទី២០នេះ និងជាទឹកចិត្តផ្ទាល់របស់ប្រជាជនផងដែរ ព្រោះប្រជាជនកម្ពុជាកាន់ព្រះពុទ្ធសាសនា ។

ក្នុងដំណើរការរបស់សាលារៀន សហគមន៍តាមរយៈសមាគមមាតាបិតាសិស្ស ឬហៅថាសមាគមទ្រទ្រង់សាលារៀននៅតែជួយរួមចំណែកដល់ការចំណាយចរន្ត និងការចំណាយសំរាប់សកម្មភាពកីឡា និងសិល្បៈថែមទៀតដោយដើរតួជាអ្នកប្រមូលទុនសំរាប់សាលារៀន។ មកដល់ឆ្នាំសិក្សា១៩៩៨-១៩៩៩ នេះសាលារៀនបឋមសិក្សា មានចំនួន៥.១៥៦ អនុវិទ្យាល័យចំនួន ៣៥៥ និងវិទ្យាល័យចំនួន១៣២។ ក្នុងចំនួនសាលាបឋមសិក្សាទាំង៥.១៥៦ សាលារៀនចំនួន៥១.៧ភាគរយ មានគ្រប់កំរិតថ្នាក់នៃបឋមសិក្សា (ថ្នាក់ទី១ ដល់ ថ្នាក់ទី៦) កុមារដែលមានលំនៅដ្ឋានឆ្ងាយពីសាលាបឋមសិក្សាមានគ្រប់កំរិតថ្នាក់មានការលំបាកក្នុងការបន្តការរៀនសូត្រឱ្យបានចប់បឋមសិក្សា ហើយកុមារខ្លះ ក៏បានក្លាយទៅជាមុខសញ្ញានៃការបោះបង់ការសិក្សា ។ នៅមធ្យមសិក្សាវិញ ស្រុកចំនួន២៨ ទៀត ពុំទាន់មានអនុវិទ្យាល័យ ជាហេតុធ្វើឱ្យកុមារអាយុ១២-១៤ ឆ្នាំ មួយចំនួនពិសេសកុមារីមិនអាចបន្តការសិក្សាទៅមធ្យមសិក្សាបានឡើយ។ ជាគោលការណ៍ក្រសួងជំរុញឱ្យសាលាបង្គោលនៃកំរងពង្រីកឱ្យទៅជាអនុវិទ្យាល័យ ដើម្បីផ្តល់ឱកាសឱ្យកុមារបានទទួលការអប់រំ ៩ ឆ្នាំ ។ ផលធៀបសិស្សគ្រូនៅបឋមសិក្សាទូទាំងប្រទេស គឺ ៤៨.១ ដែលមានន័យថាគ្រូមួយនាក់ត្រូវបង្រៀនសិស្ស ៤៨.១នាក់។ តែនៅតាមទីក្រុងផលធៀបនេះថយចុះត្រឹម៣៧នាក់ ចំពោះគ្រូបឋមសិក្សាមួយនាក់។ កង្វះបន្ទប់រៀនមានភាពធ្ងន់ធ្ងរនៅតាមទីក្រុង( ៨៧.៣ ក្នុងមួយថ្នាក់) ដែលសាលារៀនមួយចំនួនត្រូវបង្ខំចិត្តបង្រៀន ៣ វេន ក្នុងមួយថ្ងៃ ។

ដោយសារសេវាអប់រំ និង ភាពឃ្លាតគ្នារវាងសាលារៀនទីក្រុង និងសាលារៀន ជនបទដាច់ស្រយាលរាជរដ្ឋាភិបាលបានយកចិត្តទុកដល់គ្រូបង្រៀន ដែលរហូតមកដល់ឆ្នាំ២០០២ នេះ បានតំឡើងប្រាក់បៀវត្សបាន៦០% បានបន្ថែមប្រាក់គរុកោសល្យបាន ៦ លើកស្មើនឹងប្រាក់៥៣ពាន់ ទៅ៥៥ពាន់រៀល ទៅតាមប្រភេទកាំប្រាក់ ។ ចំពោះមន្ត្រីអប់រំដែលទើបចេញថ្មី ហើយស្ម័គ្រចិត្តទៅបំរើការងារនៅតំបន់ដាច់ស្រយាលបានទទួលប្រាក់ឧបត្ថម្ភ ពេលចេញដំណើរសំរាប់សំភារៈប្រើប្រាស់ ស្មើនិងទឹកប្រាក់ ៦០ដុល្លា

អាមេរិក។ ចំពោះគ្រូបង្រៀនដែលកំពុងបង្រៀននៅតំបន់វាលរាប ហើយស្ម័គ្រចិត្តទៅបង្រៀន ឬបំរើការងារនៅតំបន់ដាច់ស្រយាលក៏បានផ្តល់សោហ៊ុយធ្វើដំណើរពីរដង (ទៅ-មក) ក្នុងមួយឆ្នាំសារពើពន្ធសំរាប់ ទៅលេងស្រុកកំណើត ។

ក្នុងបរិបទថ្មីរបស់ប្រទេសជាតិក្រសួងអប់រំ យុវជន និងកីឡា បានបន្តកែលំអប្រព័ន្ធអប់រំ កែទំរង់កម្មវិធីសិក្សាតាក់តែងសៀវភៅសិក្សាថ្មី បំប៉នសមត្ថភាពជាថ្មីដល់គ្រូបង្រៀន ដើម្បីត្រៀមលក្ខណៈផ្តើមអនុវត្តប្រព័ន្ធអប់រំ១២ឆ្នាំ (៦+៣+៣) នៅក្នុងឆ្នាំសិក្សា ១៩៩៦-១៩៩៧។ ប្រព័ន្ធអប់រំថ្មីបានបង្កើនម៉ោងសិក្សាសំរាប់គ្រប់កំរិតថ្នាក់នៃបឋមសិក្សា ។

ការចូលសិក្សា និងការចូលរួមក្នុងការអប់រំ ជាទូទៅអត្រានៃការសិក្សានៅមានកំរិតទាបនៅឡើយ ហើយលទ្ធផលនៃការសិក្សា ឬប្រសិទ្ធភាពផ្ទៃក្នុងនៃការអប់រំវិញនោះក៏មានកំរិតកាន់តែទាបខ្លាំងទៅទៀត ដែលនាំឱ្យមានការខាតបង់ខ្ពស់លើផ្នែកហិរញ្ញវត្ថុសំភារៈបរិក្ខា និង ពេលវេលា ដែលក្រសួងអប់រំយុវជន និងកីឡា កំពុងប្រឈមដោះស្រាយជាជំហាន១ ។

អាំងឌីកាទ័រអប់រំជំរើសឆ្នាំសិក្សា ១៩៩៨-១៩៩៩

| | |
|---|---|
| អត្រារួមចូលរៀនថ្មី | ១០៣.៣% |
| អត្រាពិតចូលរៀនថ្មី | ៦២.៤% |
| អត្រារួមនៃការសិក្សា | ៨៩.៧% |
| អត្រាពិតនៃការសិក្សា | ៧៨.៣% |

តាមកម្មវិធីថ្មីប្រព័ន្ធអប់រំនៅកម្ពុជា មានរូបភាពប្រហាក់ប្រហែលនឹងការអប់រំនៅប្រទេសនានាក្នុងតំបន់ ដែលក្រសួងសង្ឃឹមថា នឹងអាចកាត់បន្ថយអត្រាត្រួតថ្នាក់របស់សិស្សតាមរយៈការបន្ថែមម៉ោងសិក្សា។ ប៉ុន្តែការអនុវត្តប្រព័ន្ធ១២ឆ្នាំនេះ អត្រាត្រួតថ្នាក់របស់សិស្សថ្នាក់ទីមួយនៅតែមានកំរិតខ្ពស់នៅឡើយ (៤០,៩ភាគរយ) ហើយអត្រាឡើងថ្នាក់ទីមួយក៏មានត្រឹមតែ ៤៨,៤ភាគរយប៉ុណ្ណោះ។ ជាទូទៅនៅបឋមសិក្សាអត្រាត្រួតថ្នាក់ទីមួយមានសភាពធ្ងន់ធ្ងរជាងគេ។ នៅក្នុងឆ្នាំសិក្សា ១៩៩៧-១៩៩៨ ការបោះបង់សិក្សានៅទូទាំងប្រទេស ក៏មានអត្រាខ្ពស់ជាពិសេសការបោះបង់នៅថ្នាក់ទី១ ទី២ ទី៣ នៃបឋមសិក្សា (១០,៧% ១៤,0% ១៤,១%) ។គេមានការព្រួយបារម្ភថា កុមារនឹងក្លាយ ទៅជាអនក្ខរជនវិញបាន ។

ស្ថិតិអប់រំឆ្នាំសិក្សា ១៩៩៨-៩៩ បង្ហាញថា អត្រាពិតនៃការសិក្សានៅបឋមសិក្សាទូទាំងប្រទេសមាន៧៨,៣% មានន័យថាកុមារអាយុ៦-១១ឆ្នាំ ចំនួន២១,៧% ទៀត មិននៅរៀនក្នុងបឋមសិក្សាឡើយ។ ចំនួន២១,៧% នេះ គឺមានកុមារប្រមាណ៤សែននាក់ ដែលក្នុងនោះ កុមារមួយភាគរៀនបានត្រឹមតែថ្នាក់ ទី១ -ទី២ -ទី៣ -ទី៤ ឬទី៥ ហើយបោះបង់សាលារៀនដោយមូលហេតុផ្សេង១ជាអាទិ៍ កង្វះសាលាបឋមសិក្សាមានគ្រប់កំរិតថ្នាក់។ ការជំរុញឱ្យសាលាបឋមសិក្សាមានគ្រប់កំរិតថ្នាក់ ជាអទិភាពមួយដែលក្នុងនេះត្រូវរៀបចំគោលការណ៍បង្រៀនថ្នាក់គួបនៅតំបន់ឆ្ងាយ១។ ការបោះបង់ការសិក្សា នៅថ្នាក់ទាប១ ដែលអាចកុមារក្លាយជាអនក្ខរជនវិញ ក៏មានអត្រាខ្ពស់ដែរ។ យ៉ាងហោចណាស់ កុមារត្រូវរៀនចំថ្នាក់ទី៤ ឬទី៥ ទើបអាចជៀសវាងគ្រោះ "ភ្លេចអក្សរ" បាន ។នៅតំបន់ដាច់ស្រយាលអត្រាពិតនៃការសិក្សាមានកំរិតទាបជាង ៥០ភាគរយ។

- **<u>កុមារដែលមិនមែនជាជនជាតិខ្មែរ</u> :**

រាជរដ្ឋាភិបាលក៏បានយកចិត្តទុកដាក់ផងដែរ និងផ្តល់លទ្ធភាពដល់សហគមន៍ជនជាតិភាគតិចបានបើកសាលារៀនសមស្របទឹងជំនឿសាសនារបស់ជនជាតិរបស់គេ។ កុមារជនជាតិភាគតិចជាច្រើនដែលនិយាយភាសាខ្មែរ បានចូលរៀនសាលាសាធារណៈ។

• **កុមារី :**

ស្ថិតិនៃមជ្ឈមណ្ឌលប្រព័ន្ធពត៌មានគ្រប់គ្រងអប់រំឆ្នាំ១៩៩៩ បានបង្ហាញថា ក្នុងចំណោមសិស្សបឋមសិក្សាទូទាំងប្រទេស ២.០៩៤.០០០ នាក់ សិស្សជាកុមារីមានចំនួនតែ ៩៥៦.០៨៤នាក់ ប៉ុណ្ណោះ ។

កុមារីនៅជនបទងាយនឹងបោះបង់ចោលការសិក្សាណាស់ ដោយព្រោះតែទំលាប់រស់នៅបែបបុរាណទុកដាក់កូនស្រីឱ្យនៅជិតខ្លួន ។ ហេតុនេះកុមារីភាគច្រើនពុំបានទៅសាលារៀន ឬក៏បោះបង់ចោលសាលារៀនតាំងតែពីឆ្នាំទី១-ទី២-ទី៣-ទី៤ ឬ ទី៥ តាមសំនូមពររបស់ឪពុកម្តាយ ឬក៏ពុំមានឱកាសនឹងទៅសាលារៀនបាន ដោយជាប់រវល់មើលថែរក្សាប្អូនតូចៗ ជំនួស ម្តាយ ឬ ទៅចូលរួមក្នុងពលកម្មនៅតាមស្រែចម្ការ ឬក៏ពលកម្មកុមារធ្ងន់ធ្ងរផង។ ការសង្កេតមួយស្តីពីការសិក្សាអប់រំរបស់កុមារីធ្វើឡើងក្នុងឆ្នាំ១៩៩៨ ដោយក្រសួងអប់រំ យុវជន និងកីឡា និងអង្គការក្រៅរដ្ឋាភិបាលCARE។ លទ្ធផលនៃការអង្កេតនេះភ្ជាប់ជូនក្នុងឧបសម្ព័ន្ធ ។

គោលនយោបាយអប់រំ និងកំណែទំរង់សំខាន់ៗ ទោះបីក្រសួងអប់រំយុវជន និង កីឡា ពុំទាន់មានច្បាប់អប់រំដោយឡែកក៏ដោយ ក្រសួងបានយោងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា កំណត់នយោបាយសំខាន់ចំនួន ៤ គឺ :

- សកលកម្មការអប់រំចំនេះទូទៅមូលដ្ឋាន ៩ ឆ្នាំ និងអក្ខរកម្មវិជ្ជាជីវៈ
- ទំនើបកម្ម និងកំណែលំអគុណភាពអប់រំ តាមរយៈការកែទំរង់ប្រកបដោយប្រសិទ្ធភាព
- ផ្សារភ្ជាប់ការអប់រំ-បណ្តុះបណ្តាលទៅនឹងតំរូវការទីផ្សារពលកម្ម និងសង្គម ស្តារ និងអភិវឌ្ឍន៍ ផ្នែកយុវជន និង កីឡា នៅក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធអប់រំ ។

ក្នុងបរិបទនៃការអនុវត្តគោលនយោបាយ ក្រសួងបាននឹងកំពុងយកចិត្តទុកដាក់ :

- បង្កឱកាសស្មើគ្នាដល់កុមារ និងកុមារីគ្រប់តំបន់ គ្រប់ជនជាតិ ស្ថិតក្នុងវ័យសិក្សាឱ្យបានចូលរួមគ្រប់ៗគ្នាចប់ បឋមសិក្សា និងឈានទទួលការអប់រំមូលដ្ឋាន៩ឆ្នាំ ក្នុងន័យនេះ ក្រសួងជំរុញឱ្យសាលាបឋមសិក្សាចំនួន៧៥% មានគ្រប់កំរិតថ្នាក់ (ថ្នាក់ទី១ដល់ថ្នាក់ទី៦) សំរាប់ភូមិសិក្សាទី១ ឬបឋមសិក្សាក្នុងរយៈពេល៥ឆ្នាំទៅមុខ នេះនឹងឱ្យអនុវត្តបង្រៀនថ្នាក់គួបនៅតំបន់ចំនួនកុមារតិច។ បច្ចុប្បន្ននេះសាលាបឋមសិក្សាចំនួន៤៨.៣ភាគរយ ពុំមានគ្រប់កំរិតថ្នាក់នៃបឋមសិក្សាឡើយទេ។ រៀងរាល់ឆ្នាំសិក្សាបើសាលាបឋមសិក្សា២៥០ បង្កើនឱ្យមានគ្រប់កំរិត (ដល់ទី៦) នោះ នៅឆ្នាំ២០០៤ យើងមានសាលាបឋមសិក្សាចំនួន៧៥ភាគរយ មានគ្រប់កំរិតថ្នាក់ បឋមសិក្សា ។

ឯនៅមធ្យមសិក្សាវិញ ស្រុកចំនួន២៨ទៀត ពុំទាន់មានអនុវិទ្យាល័យ ជាហេតុធ្វើឱ្យកុមារអាយុ១២ឆ្នាំ ទៅ១៤ឆ្នាំ មួយចំនួន ពិសេសកុមារីមិនអាចបន្តការសិក្សានៅមធ្យមសិក្សាបានឡើយ។ ជាគោលការណ៍ក្រសួងជំរុញឱ្យសាលាបង្គោលនៃកំរងពង្រីកឱ្យទៅជាអនុវិទ្យា ល័យ ដើម្បីផ្តល់ឱកាសឱ្យកុមារបានទទួលការអប់រំបាន៩ឆ្នាំ ។

- រិះរកវិធានការជំរុញឱ្យមានការប្រែប្រួលប្រសិទ្ធភាពអប់រំ ដូចជាការបង្កើនសមត្ថភាពវិជ្ជាជីវៈរបស់គ្រូបង្រៀនការបង្កើនម៉ោងសិក្សា ការផ្តល់សៀវភៅសិក្សាគ្រប់គ្រាន់ ការអនុវត្តវិធីសាស្ត្រទំនើបៗ ការរៀបចំអធិការកិច្ចកំណែទំរង់វាយតម្លៃនៃការសិក្សាតាមបែបថ្មី គួបផ្សំជាមួយនឹងការពង្រីកកិច្ចចូលរួមរបស់សហគមន៍ជាមួយសាលារៀន។
    - ស្តាបនាហេដ្ឋារចនាសម្ព័ន្ធ និង កសាងសាលារៀនថ្មីៗថែមទៀត។ ក្រសួងអប់រំ យុវជន និងកីឡា នឹងបន្តរៀបចំឱ្យមានអនុវិទ្យាល័យនៅតាមសាលារៀនបង្គោលនៃកំរងសាលា ។

+ អភិវឌ្ឍផ្នែករងសំខាន់ផ្សេងទៀត : ស្របជាមួយនឹងកិច្ចប្រឹងប្រែងទាំងនេះ ក្រសួងអប់រំ យុវជន និង កីឡា នឹងអភិវឌ្ឍន៍ផ្នែករង សំខាន់ៗផ្សេងទៀត ដែលរួមមានមធ្យមសិក្សាទុតិយភូមិ ការអប់រំក្រៅប្រព័ន្ធចម្មតាការអប់រំដល់ក្រុមជនងាយរងគ្រោះ ឧត្តមសិក្សា ការអប់រំបច្ចេកទេស និង ការបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីស្រូបយកយុវជន យុវនារី ឱ្យបានបន្តការសិក្សានៅថ្នាក់ខ្ពស់ ឬទទួលបានបំណិនបច្ចេកទេសទៅតាមចំណង់ចំនូល ចិត្ត និង កោសល្យរៀងៗខ្លួន ។

+ ពង្រឹងការគ្រប់គ្រង និងការងាររដ្ឋបាល នៅគ្រប់លំដាប់ថ្នាក់ ដើម្បីបង្កើនប្រសិទ្ធភាព និងភាពស័ក្តិ នៅក្នុងការកសាងផែនការអប់រំការងារគ្រប់គ្រង និងអធិការកិច្ចតាមរយៈកម្មវិធីអភិវឌ្ឍន៍ធនធានមនុស្ស។ ថ្នាក់ ក្រសួង និងខេត្ត បានទទួលនូវឧបករណ៍ ទំនើបខ្លះៗយកទៅប្រើប្រាស់។ ឯកសារមូលដ្ឋានមួយចំនួនបានកែលំអនឹងដាក់ឱ្យប្រើប្រាស់ជាបណ្តើរៗនូវថ្នាក់ក្រសួង ខេត្ត ស្រុក និងសាលារៀនបង្គោល។ ទន្ទឹមគ្នានេះ ក្រសួងក៏បានរៀបចំវចនាសម្ព័ន្ធអប់រំ និងផ្តើមសនិទានកម្មមន្ត្រីគ្រប់គ្រងអប់រំសំដៅឈានទៅរៀបចំការគ្រប់គ្រងអប់រំបែបវិមជ្ឈការ ។

<u>*បើកថ្នាក់អក្ខរកម្មវិជ្ជាជីវៈ*</u> និង ធ្វើយុទ្ធនាការប្រឆាំងគ្រោះមិនចេះអក្សរ និងគ្រោះភ្លេចអក្សរតាមរយៈការពង្រឹងគណៈកម្មការសំរបសំរួលថ្នាក់ខេត្ត/ស្រុក។

ស្តារ និងអភិវឌ្ឍន៍ផ្នែកយុវជន និង កីឡាក្នុង និង ក្រៅប្រព័ន្ធអប់រំ ។

ពិតមែនតែក្រសួងអប់រំ យុវជន និង កីឡា មានការស្រាវជ្រាវពុំបានច្បាស់លាស់ ក្រោយពីអនុវត្តន៍កម្មវិធីសិក្សាថ្មីនៅឡើយក៏ក្រសួងមានវត្តបំនងកែទំរង់កម្មវិធីសិក្សាដោយ :

- បង្កើនសមត្ថភាពសិស្សដោយពង្រីកការយល់ដឹងអ្វីៗនៅជុំវិញគេ និង សមត្ថភាពដោះស្រាយបញ្ហាប្រចាំថ្ងៃរបស់គេ
- សំរបទៅតាមបច្ចុប្បន្ន នៃនិន្នាការរបស់វិស័យអប់រំតាមរយៈការពង្រឹងការងារ គ្រប់គ្រងអប់រំនៅគ្រប់ថ្នាក់ពិសេសថ្នាក់សាលារៀន ដើម្បីឱ្យសាលារៀនមានលទ្ធភាពពង្រីកភាពម្ចាស់ការ ក្នុងការអភិវឌ្ឍ (វិមជ្ឈការ) ។
- កាត់បន្ថយការបង់ខាតការសិក្សា ដោយកាត់បន្ថយអត្រាត្រួតថ្នាក់ និងអត្រាបោះបង់ការសិក្សាតាមរូបភាពផ្សេងៗដែលក្រសួងកំណត់ជាផ្លូវការ ។
- ខិតខំពង្រីកសេវាបណ្តុញអប់រំ បង្កើនសាលាបឋមសិក្សាឱ្យមានគ្រប់កំរិតថ្នាក់នៃបឋមសិក្សា និងបង្កើនអនុវិទ្យាល័យនៅតាមសាលាបង្គោលនៃកំរងសាលា ។

ជាមួយនឹងការកែទំរង់សិក្សា រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់លើកទឹកចិត្តគ្រូបង្រៀន ដោយតម្លើងបន្ថែមប្រាក់គរុកោសល្យដែលមានមកដល់ឆ្នាំ ២០០០នេះ គឺស្មើនឹងទឹកប្រាក់ ៥៣០០០រៀល ទៅ ៥៥៣០០រៀល ទៅតាមប្រភេទកាំប្រាក់ និង បានតំឡើងប្រាក់បៀវត្ស បាន៦០ភាគរយ ។

## <u>វិធានការការពារពិសេស</u>

*( មាត្រា២២ ៣០ ៣២ ៤០ )*

***សំនួរទី១៧ :*** ***តាមខ្លឹមសារមាត្រា២២ សូមផ្តល់ព័ត៌មានបន្ថែមអំពីវិធានការដែលប្រកាន់យក ដែលក្នុងនោះរួមមានវិធានការផ្លូវច្បាប់ផង ដើម្បីការពារសិទ្ធិរបស់កុមារដែលរស់នៅតែឯង កុមារស្វែងរកសិទ្ធិជ្រកកោន***

*និងកុមារជាជនភៀសខ្លួន។ សូមផ្តល់ផងដែរនូវព័ត៌មានបន្ថែម អំពីវិធានការអនុវត្តដើម្បីអនុញ្ញាតឱ្យមានការចុះបញ្ជីជាតិតាមផ្លូវច្បាប់ ចំពោះកុមារនៃគ្រួសារជនភៀសខ្លួន ។*

**ចម្លើយ :**

ដូចបានបញ្ជាក់នៅក្នុងរបាយការណ៍ស្រាប់ ប្រទេសកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីជនភៀសខ្លួន និងពិធីសារទាក់ទងនឹងអនុសញ្ញានេះ។ រហូតមកទល់ពេលនេះ ពុំទាន់មានច្បាប់ទាក់ទងនឹងការងារជនភៀសខ្លួនទេ។ ក៏ប៉ុន្តែក្នុងពេលកន្លងមករដ្ឋាភិបាលជាតិបណ្តោះអាសន្នកម្ពុជា បានចេញសេចក្តីសំរេចជូនដំណឹងលេខ២៥ ចុះថ្ងៃទី១៣ សីហា ឆ្នាំ១៩៩៣ ជំរុញឱ្យអភិបាលខេត្ត-ក្រុងយកចិត្តទុកដាក់បែងចែកដីធ្លីឱ្យជនមាតុភូមិនិវត្ត ក្រោយពីការបញ្ចប់ការឧបត្ថម្ភស្បៀងពីអង្គការ UNHCR ។

នៅប្រទេសកម្ពុជា ស្នងការជាន់ខ្ពស់របស់ អ.ស.ប សំរាប់ជនភៀសខ្លួន គឺជាប្រភពតែមួយដែលផ្តល់ការការពារ និងជំនួយឧបត្ថម្ភសង្គមដល់ជនភៀសខ្លួន។ ស្នងការជាន់ខ្ពស់របស់ អ.ស.ប សំរាប់ជនភៀសខ្លួន (UNHCR) បានលើកទឹកចិត្តរាជរដ្ឋាភិបាលធ្វើយ៉ាងណា ដាក់បញ្ហាទាក់ទិននឹងជនភៀសខ្លួនឱ្យទៅជាច្បាប់។ មានសេចក្តីព្រាងអនុក្រិត្យមួយស្តីអំពីជនភៀសខ្លួនត្រូវបានព្រាងឡើង ហើយបច្ចុប្បន្ន កំពុងរង់ចាំសេចក្តីសំរេចរបស់រាជរដ្ឋាភិបាល ។

តាំងតែពីពេលចាប់ផ្តើមកម្មវិធីកំនត់ឋានៈជនភៀសខ្លួនរហូតមកទល់ពេលនេះ មានករណីកុមារជាជនភៀសខ្លួនចំនួន៤ ឬ ៥នាក់ប៉ុណ្ណោះ នៅក្នុងប្រទេសកម្ពុជា។ កុមារទាំងនោះមានឪពុកម្តាយមកជាមួយ ហើយពួកគេពុំមែនកើតនៅក្នុងប្រទេសកម្ពុជាទេ។ ហេតុនេះហើយ ពុំមានឧទាហរណ៍ពីការអនុវត្តជាក់ស្តែង ឬបទពិសោធន៍ទាក់ទងនឹងការចុះបញ្ជីជាតិ និងទាក់ទងនឹងនីតិជន ដែលមានតែម្នាក់ ឯងក្នុងនាមជាបុគ្គលជនភៀសខ្លួននៅកម្ពុជានោះទេ ។

ជនភៀសខ្លួនទាំងឡាយដែលត្រឡប់មកកម្ពុជាវិញ មានសេរីភាពជ្រើសរើសគោលដៅសំរាប់តាំងទីលំនៅនៅកន្លែងណាមួយ ដែលស្ថិតនៅក្នុងប្រទេស។ រីឯជនភៀសខ្លួនត្រលប់មកវិញ ដែលជាកុមាររងគ្រោះពីជម្លោះប្រដាប់អាវុធកន្លងមកហើយពុំមានអ្នកបីបាច់ថែរក្សា ត្រូវបានកម្មវិធីមាតុភូមិនិវត្តនរបស់UNHCR ចាត់ទុកថា ជាជនរងគ្រោះដែលត្រូវទទួលនូវការជួយឧបត្ថម្ភផ្នែកសង្គម និងការបណ្តុះបណ្តាលវិជ្ជាជីវៈដែលបានផ្តល់ និងបណ្តុះបណ្តាលដោយផ្ទាល់ដោយស្ថាបនាជាដៃគូអនុវត្តន៍របស់ UNHCR ។

***សំនួរទី១៨ :*** *សូមផ្តល់ព័ត៌មានបន្ថែមអំពីវិធានការដើម្បីរៀបចំអនុម័តច្បាប់ ពិសេសស្តីអំពីកុមារប្រព្រឹត្តិទំនាស់នឹងច្បាប់ ជាពិសេសគឺថាកុមារដែលត្រូវចោទប្រកាន់ ឬជាប់ចោទថា បានបំពានច្បាប់ព្រហ្មទណ្ឌយ៉ាងហោចណាស់ ក៏មានការធានាដូចខាងក្រោម ដោយគូសបញ្ជាក់ពីការធានាបន្ថែមដ៏សមស្របផ្សេងៗត្រូវបានផ្តល់ដល់កុមារ :*

*i. ចាត់ទុកថាឥតកំហុស រហូតដល់ពេលណាដែលពិរុទ្ធភាពរបស់កុមារ ត្រូវបានកំណត់តាមច្បាប់ ។*

*ii. ទទួលបានព័ត៌មានជាបន្ទាន់ (បញ្ជាក់ពេលវេលា គឺតែពេលវេលាកំណត់ដោយច្បាស់) និងដោយផ្ទាល់ ស្តីពីបទចោទចំពោះខ្លួន បើសិនជាពុំនោះសោតទទួលតាមរយៈអាណាព្យាបាលស្របច្បាប់របស់ខ្លួន ហើយនឹងទទួលបាននូវជំនួយច្បាប់ ឬជំនួយក្នុងទម្រង់ផ្សេងៗទៀតក្នុងការរៀបចំ និងដាក់ចេញនូវមធ្យោបាយ ការការពារខ្លួន*

*iii. មិនត្រូវបានទទួលការបង្ខិតបង្ខំធ្វើជាសាក្សី ឬ ឱ្យទទួលសារភាពកំហុសឡើយ*

iv. *បើសិនជាត្រូវបានគេចាត់ទុកថា បានល្មើសនឹងច្បាប់ព្រហ្មទណ្ឌ កុមារអាចតវ៉ាសុំឱ្យពិនិត្យឡើងវិញនូវសេចក្តីសំរេចនេះ និងសុំឱ្យពិនិត្យឡើងវិញនូវរាល់វិធានការឯទៀត ដែលបានធ្វើឱ្យកើតជាសេចក្តីសំរេចបែបនេះ នៅមុខអាជ្ញាធរមានសមត្ថកិច្ចថ្នាក់លើដែលឯករាជ្យ និងមិនលំអៀង ឬ ស្ថាប័នតុលាការដែលមានសមត្ថកិច្ច ដែលយោងតាមលំនាំច្បាប់*

v. *មានអ្នកបកប្រែដោយឥតគិតថ្លៃ ជួយដល់កុមារបើសិនកុមារមិនយល់ ឬ មិនចេះនិយាយភាសាដែលគេប្រើប្រាស់*

vi. *ត្រូវគោរពសិទ្ធិឯកជនរបស់កុមារនៅរាល់តំណាក់កាលនៃនីតិវិធី ។*

**ចម្លើយ :**

ទោះបីជាពុំទាន់មានច្បាប់ពិសេសទាក់ទងនឹងកុមារប្រព្រឹត្តិល្មើសច្បាប់ក៏ដោយ ក៏មានការធានាត្រូវបានបញ្ញតិរួចមកហើយនៅក្នុងបច្ចុប្បន្ន។ បទបញ្ញតិទាំងនោះមានខ្លះនិយាយចំៗបញ្ហាកុមារ ហើយក៏មានបទបញ្ញតិទូទៅ ស្តីអំពីការជំនុំជំរះប្រកបដោយយុត្តិធមិសំរាប់ជនគ្រប់រូប ក្នុងនោះក៏មានកុមារផងដែរ។ រីឯសេចក្តីព្រាងក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌក៏ផ្តល់នូវការធានាដែលមានលក្ខណៈជាទូទៅដែរ ។

i - *<u>ចាត់ទុកជាឥតទោសកំហុស រហូតដល់ពេលណាដែលពិរុទ្ធភាពរបស់កុមារ ត្រូវកំណត់សមស្របតាមច្បាប់ :</u>*

- មាត្រា ៣៨នៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជាចែងថា :
  ជនជាប់ចោទណាក៏ដោយ ត្រូវទុកជាមនុស្សឥតទោស ដរាបណាតុលាការ មិនទាន់កាត់ទោសជាស្ថាពរ។
- មាត្រា ២៥ ច្បាប់ព្រហ្មទណ្ឌអន្តរកាលចែងថា :
  គ្រប់ជនដែលគេសង្ស័យ គ្រប់ជនជាប់ពិរុទ្ធ គ្រប់ជនជាប់ចោទ ត្រូវទទួលការសន្មតជាមុនថា គ្មានកំហុសជាដាច់ខាត។
- ប្រការ១ នៃប្រកាសលេខ ២១៧ប្រ.ក របស់ក្រសួងមហាផ្ទៃ ចុះថ្ងៃទី៣១-មិនា-១៩៩៨ កំណត់និយមន័យនៃពាក្យពិរុទ្ធដូចតទៅ:

  *<u>ពិរុទ្ធជន</u>* : គឺជាជនដែលតុលាការមិនទាន់កាត់ទោស ហើយត្រូវសន្មតថា *<u>ជាជនគ្មានកំហុស</u>* អាចជាជនជាប់សង្ស័យ ឬ ជាជនជាប់ចោទ ក្នុងការប្រព្រឹត្តិបទល្មើសណាមួយ ហើយត្រូវបានឃុំខ្លួនក្នុងមន្ទីរឃុំឃាំងស្របច្បាប់តាមអំណាចដីកា រងចាំការសំរេចបន្ថែមពីតុលាការ ។

- បន្ថែមលើនេះទៀត ក្រសួងយុត្តិធមិ បានអះអាងជាថ្មីទៀតនូវគោលការណ៍នេះ ក្នុងបុព្វកថានៃសេចក្តីព្រាងក្រមនីតិវិធីព្រហ្មទណ្ឌ ។
  ក្រុមនេះបញ្ចូលគោលការណ៍សច្ចធាណ៍នីរទោស ។
- មាត្រា ១ នៃក្រមនេះចែងថា :
  បណ្តឹងអាជ្ញា មានគោលបំណងពិនិត្យអត្ថិភាពនៃបទល្មើស បង្ហាញឱ្យឃើញពិរុទ្ធភាពនៃជនល្មើស និងផ្តន្ទាទោសជននេះតាមច្បាប់កំណត់ ។

ii - *ទទួលបានពត៌មានជាបន្ទាន់ (បញ្ជាក់ពេលវេលាក៏តែពេលវេលាកំណត់ដោយច្បាប់) និងដោយផ្ទាល់ស្តីពីបទចោទចំពោះខ្លួន បើសិនជាពុំនោះសោតទទួលតាមរយៈអាណាព្យាបាលស្របច្បាប់របស់ខ្លួន ហើយនឹងទទួលបាននូវជំនួយច្បាប់ ឬជំនួយក្នុងទម្រង់ផ្សេងៗទៀត ក្នុងការរៀបចំ និង ដាក់ចេញនូវមធ្យោបាយការការពារខ្លួន ។*

- មាត្រា ៧៥នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ (២៨-១-១៩៩៣) ចែងថា :

នៅពេលជនជាប់ចោទចូលខ្លួនជាលើកដំបូង ចៅក្រមស៊ើបអង្កេតត្រូវសួរកត់ត្រាអំពីអត្តសញ្ញាណរបស់ជននោះ ប្រាប់អំពីអំពើដែលចោទប្រកាន់ទៅលើជននោះ ហើយទទួលការរាយការណ៍បន្ទាប់ពីបានប្រាប់ជននោះ អំពីសិទ្ធិរបស់ខ្លួនដែលអាចឆ្លើយ ឬ មិនទាន់ឆ្លើយដោយគ្មានមេធាវី ឬអ្នកការពារសិទ្ធិដែលខ្លួនជ្រើសរើស ឬដែលត្រូវតែងតាំងដោយឯកឯង ។

- មាត្រា ១៣ កថាខ័ណ្ឌ ៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ដែលកំណត់ពីការចាប់ខ្លួន និង ការឃុំខ្លួនចែងថា : ក្នុងខណៈនោះ ដោយផ្អែកលើសេចក្តីសំរេចដែលមានចែងមូលហេតុ ចៅក្រមអាចសំរេចថា :
  + ត្រូវចោទប្រកាន់ជនជាប់សង្ស័យ ដោយឱ្យឃុំឃាំង ឬ មិនឱ្យឃុំឃាំង
  + ឱ្យដោះលែងជនជាប់សង្ស័យ ដោយចាត់ទុកថាភស្តុតាងនៃពិរុទ្ធ ភាពមិនគ្រប់គ្រាន់

- មាត្រា ១០ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាលចែងថា :

១-សិទ្ធិពឹងពាក់មេធាវី ឬ ទីប្រឹក្សា ត្រូវបានធានាជូនជនគ្រប់រូបដែលជាប់ចោទពីបទមជ្ឈិម ឬបទឧក្រិដ្ឋ ។

២-ទោះបីបទល្មើសនោះធ្ងន់ស្រាលយ៉ាងណាក៏ដោយ គ្មានជនណាម្នាក់ត្រូវជាប់ឃុំឃាំងនៅលើទឹកដីកម្ពុជាលើសពីរយៈពេល៤៨ម៉ោង ដោយគ្មានបានទទួលជំនួយពីទីប្រឹក្សា ពីមេធាវី ឬ ពីអ្នកតំណាងដែលបទបញ្ញត្តិនេះបានអនុញ្ញាតឡើយ ។

- មាត្រា ១៧ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ដែលចែងពីសិទ្ធិពិនិត្យសំណុំរឿងដោយមេធាវីកំណត់ថា :

១- ប្រសិនបើចៅក្រមសំរេចថា ចាំបាច់ត្រូវស៊ើបអង្កេតបន្ថែមទៀត តាមលំដាប់លំដោយនៃការស៊ើបអង្កេតនេះ ទីប្រឹក្សារបស់ជនជាប់ចោទ ត្រូវតែបានទទួលដំណឹងជាបន្ទាន់ អំពីភស្តុតាងថ្មីៗទៀត ប្រឆាំងនឹងកូនក្តីរបស់ខ្លួន។

២- ទីប្រឹក្សាមានសិទ្ធិពិនិត្យសំណុំរឿងអ្នកជាប់ចោទ ដោយគ្រាន់តែស្នើសុំជាលាយល័ក្ខអក្សរ នៅគ្រប់ដំណាក់កាលនៃនីតិវិធី ហើយអាចទទួលបានពីចៅក្រម នូវគ្រប់លទ្ធផលដែលបានមកអំពីការស៊ើបអង្កេតអំពីសេចក្តីរាយការណ៍របស់អ្នកជំនាញការ ឬ អំពីសវនកម្មដែលខ្លួនយល់ថា មានប្រយោជន៍ក្នុងការការពារកូនក្តីរបស់ខ្លួន ។

- មាត្រា ៧៦ ស្តីពីនីតិវិធីព្រហ្មទណ្ឌចែងថា :

នៅពេលចូលខ្លួនជាលើកដំបូងនេះ ក្រោយពីបានបញ្ជាក់អំពីអត្តសញ្ញាណ និងក្រោយពីបានទទួលដំណឹងអំពីអំពើដែលខ្លួនត្រូវជាប់ចោទប្រកាន់ប្រសិនបើជនជាប់ចោទជំរាបចៅក្រមអង្កេតថា : ខ្លួនសុំជ្រើស រើសមេធាវីមួយ ឬ ថាខ្លួនសុំឱ្យរដ្ឋចាត់តាំងមេធាវីមួយដើម្បីការពារខ្លួននោះ ចៅក្រមស៊ើបអង្កេតថា ត្រូវផ្អាកការសួរយកចម្លើយសិន ហើយត្រូវហៅក្នុងរយៈពេលដ៏ខ្លីជាទីបំផុតនូវមេធាវីនោះ មកស្តាប់ការសួរយកចម្លើយលើជនជាប់ចោទដែលនឹងធ្វើនៅចំពោះមុខមេធាវីនោះ ។

ការចាត់តាំងដោយឯកឯង នូវមេធាវីត្រូវធ្វើដោយប្រធានតុលាការក្នុងករណី ដូចតទៅ :

- ជនរងគ្រោះជាអនីតិជនគ្មានទីពឹង

- ជនជាប់ចោទជាអនីតិជនគ្មានទីពឹង
- ជនជាប់ចោទជាមនុស្ស គ ថ្លង់ មនុស្សខ្វាក់ ឬ ជាជនមានវិបត្តិស្មារតី
- ជនជាប់ចោទត្រូវជាប់ចោទពីបទប្រព្រឹត្តបទឧក្រិដ្ឋណាមួយ ហើយខ្លួនគ្មានលទ្ធភាពអាចពឹងអ្នកជួយ ការពារខ្លួនបាន។

ក្នុងករណីផ្សេងពីករណីដូចមានលើកខាងលើនេះ ចៅក្រមស៊ើបអង្កេតអាចសួរយកចម្លើយជនជាប់ចោទបាន កាលណា ជននេះសុខចិត្តការពារខ្លួនដោយខ្លួនឯង ។

ចំពោះការទាក់ទងគ្នារវាងអនីតិជន និង ឪពុកម្តាយរបស់គេ ប្រការទី៤ ចំនុច១ នៃប្រកាសលេខ ២១៧ ចុះថ្ងៃទី៣១ ខែ មិនា ឆ្នាំ១៩៩៨ របស់ក្រសួងមហាផ្ទៃបានចែងថា :

អ្នកទោសទាំងអស់ត្រូវបានអនុញ្ញាតឱ្យផ្តល់ពត៌មានទៅគ្រួសារ ឬ សាច់ញាតិរបស់ខ្លួនអំពីការជាប់ពន្ធនាគារ

សេចក្តីព្រាងក្រមនីតិវិធីព្រហ្មទណ្ឌ ដែលរៀបចំដោយក្រសួងយុត្តិធម៌ កំណត់ពីការធានាចំពោះអនីតិជនដូចតទៅ :

- មាត្រា៨៨ មិនឱ្យពន្យាពេលនៃការឃាត់ខ្លួនអនីតិជនអាយុតិចជាង១៦ឆ្នាំ ក្នុងរយៈពេល៤៨ម៉ោងរបស់នគរបាល ។

  អនីតិជនអាយុតិចជាង១៣ឆ្នាំ មិនឱ្យឃាត់ខ្លួនដល់កំណត់៤៨ម៉ោង លើកលែងតែជាប់សង្ស័យពី បទឧក្រិដ្ឋ។
- មាត្រា៩២ ការឃាត់ខ្លួនអនីតិជន មន្ត្រីនគរបាល តុលាការ ត្រូវជូនពត៌មានដល់ឪពុកម្តាយ អ្នកតំណាងស្របច្បាប់ ឬ អ្នកទទួលភារកិច្ចលើអនីតិជន ។
- មាត្រា១៣១ ជនជាប់ចោទជាអនីតិជន ត្រូវតែមានមេធាវីជានិច្ច ។
- មាត្រា១៨៧ អនីតិជនអាយុតិចជាង១៣ឆ្នាំ មិនអាចត្រូវដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបានទេ ។

***iii-*** ***<u>មិនត្រូវបានទទួលការបង្ខិតបង្ខំឱ្យធ្វើជាសាក្សី ឬ ឱ្យទទួលសារភាពកំហុសឡើយ :</u>***

មាត្រា១២៥ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ គួបផ្សំជាមួយនឹងមាត្រាទី ៣៨ នៃរដ្ឋធម្មនុញ្ញ និងមាត្រា ២៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល អាចចាត់ទុកថាជាការផ្តល់នូវការធានាទាក់ទងនឹងបញ្ហាខាងលើ ។

- មាត្រា ១២៥ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ :

ភស្តុតាងនៃបទល្មើសព្រហ្មទណ្ឌ អាចធ្វើបានដោយប្រើគ្រប់មធ្យោបាយទាំងអស់ ដើម្បីញ៉ាំងចៅក្រម ឱ្យជឿបាន ឧទាហរណ៍ ដូចជាដោយការទទួលសារភាព ដោយចំលើយសាក្សីឆ្លើយសមហេតុផល និងជាក់ច្បាស់ ដោយការពិនិត្យគ្រប់មុខសញ្ញាដោយកោសល្យវិច្ច័យ ឬ ដោយមធ្យោបាយត្រឹមត្រូវតាមច្បាប់ដទៃទៀត ដូចជាការទៅពិនិត្យដល់ទីកន្លែង.... ។ល។

តុលាការព្រហ្មទណ្ឌ ដើម្បីពង្រឹងជំនឿរបស់ខ្លួន អាចពិនិត្យទៅលើគ្រប់ឯកសារទាំងអស់ដែលបានដាក់មកឱ្យសួរដេញដោលនៅពេលសវនាការ និងដាក់ឱ្យសួរតទល់រវាងគូភាគី និងរវាងមេធាវីដើម្បីចេញសាលក្រម។ ចៅក្រមមិនត្រូវផ្អែកជំនឿរបស់ខ្លួនទៅលើការដឹងឮផ្ទាល់ខ្លួនបានទទួលក្រៅពីសវនាការតុលាការឡើយ ។

- មាត្រា ៣៨ នៃរដ្ឋធម្មនុញ្ញចែងថា :

ការទទួលសារភាពដែលកើតឡើងពីការបង្ខិតបង្ខំតាមផ្លូវកាយក្តី តាមផ្លូវចិត្តក្តី មិនត្រូវទុកជាភស្តុតាងនៃពិរុទ្ធភាពទេ ។

- មាត្រា ២៤ កថាខ័ណ្ឌទី ៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាលចែងថា :

បណ្តាពាក្យសារភាពរបស់ជនជាប់ចោទទាំងឡាយ ដែលមិនស៊ីសង្វាក់គ្នាទៅនឹងដើមកំណើតនៃភស្តុតាងទេនោះ ទោះក្នុងករណីណាក៏ដោយ មិនអាចទុកជាមូលដ្ឋានសំរាប់ផ្តន្ទាទោសបានឡើយ.... ។

- មាត្រា ២៩៩ នៃសេចក្តីព្រាងក្រមនីតិវិធីព្រហ្មទណ្ឌចែងថា :

ការសារភាពក៏ដូចជាវិធិដទៃទៀតនៃភស្តុតាងដែរ ត្រូវដាក់ជូនតុលាការធ្វើការថ្លឹងថ្លែង។ ចំលើយដែលទទួលក្រោមការបង្ខិតបង្ខំខាងរូបកាយ ឬ ផ្លូវចិត្តនោះគ្មានតំលៃជាភស្តុតាងទេ ។

ភស្តុតាងមិនអាចបានមកពីការឆ្លើយឆ្លងរវាងជនជាប់ចោទ និង មេធាវីរបស់ខ្លួនទេ ។

iv - *<u>បើសិនជាត្រូវបានគេចាត់ទុកថា បានល្មើសនឹងច្បាប់ព្រហ្មទណ្ឌ កុមារអាចតវ៉ាសុំឱ្យពិនិត្យឡើងវិញនូវសេចក្តីសំរេច នេះ និងសុំឱ្យពិនិត្យឡើងវិញនូវរាល់វិធានការឯទៀត ដែលបានធ្វើឱ្យកើតជាសេចក្តីសំរេចបែបនេះ នៅមុខអាជ្ញាធរមានសមត្ថកិច្ចថ្នាក់លើ ដែលឯករាជ្យ និងមិនលំអៀង ឬ ស្ថាប័នតុលាការដែលមានសមត្ថកិច្ច ដែលយោងតាមលំនាំច្បាប់</u> :*

- មាត្រា ១០៩ នៃរដ្ឋធម្មនុញ្ញចែងថា :

អំណាចតុលាការ ជាអំណាចឯករាជ្យ ។

អំណាចតុលាការ ធានារក្សាអនាគត និង ការពារសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ ។

អំណាចតុលាការ គ្របដណ្តប់ទៅលើរឿងក្តីទាំងអស់ រួមទាំងរឿងក្តីរដ្ឋបាលផង ។

អំណាចតុលាការនេះ ត្រូវប្រគល់ឱ្យតុលាការកំពូល និង សាលាជំនុំជំរះក្តីគ្រប់ផ្នែក និង គ្រប់ជាន់ថ្នាក់ ។

- មាត្រា ២៩ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាលចែងថា :

ជនដែលត្រូវបានជំនុំជំរះរួចហើយក្តី អាចដោយខ្លួនឯង ឬតាមរយៈទីប្រឹក្សា ឬមេធាវីសុំឱ្យសើរើពិនិត្យរឿងក្តីសារជាថ្មី បើសិនជាយល់ថាខ្លួនត្រូវគេផ្តន្ទាទោសក្នុងមូលដ្ឋានគំនិត មតិ សេចក្តីថ្លែងការណ៍ ការដែលខ្លួនជាប់ ឬមិនជាប់ពូជសាសន៍ ជាតិពន្ធ សាសនា នយោបាយ និងសង្គម ។

- មាត្រា ៤ កថាខ័ណ្ឌ ៣ និង ៤ កំណត់ពីសិទ្ធិប្តឹងឧទ្ធរណ៍ ( ឯកសារជាភាសាអង់គ្លេស កថាខ័ណ្ឌ ៤ និង ៥) :

៣ : បណ្តាភាគីដែលមានទាក់ទិនក្នុងរឿងក្តីនេះ ភាគីរដ្ឋប្បវេណី <u>ទណ្ឌិត</u> ឬ ទីប្រឹក្សារបស់ភាគីទាំងសង្ខាង រដ្ឋអាជ្ញាអាចប្តឹងឧទ្ធរណ៍ពីសេចក្តីសំរេចរបស់សាលាដំបូងនានា ក្នុងរយៈពេលពីរខែ ចាប់ពីថ្ងៃដែលចៅក្រមប្រកាសសាលក្រមនោះ បើសិនជាសាលក្រមនោះធ្វើឡើងចំពោះមុខសាមីខ្លួន ហើយបន្ថែមពេលបណ្តឹងជំទាស់ ១៥ ថ្ងៃ ថែមទៀតបើការកាត់ទោសនេះធ្វើឡើងដោយគ្មានសាមីខ្លួន ។ សាលក្រមចំពោះមុខ គឺធ្វើឡើងដោយមានវត្តមានជនជាប់ចោទក្នុងពេលជំនុំជំរះ ពុំនោះសោតទេនឹងទុកដូចជាការកាត់ក្តីមិនចំពោះមុខ ។

៤ : សាលាឧទ្ធរណ៍ជំនុំជំរះ ទាំងអង្គច្បាប់ ទាំងអង្គហេតុ ។

- មាត្រា ៥ ច្បាប់ព្រហ្មទណ្ឌអន្តរកាល ក៏កំណត់ផងដែរនូវសមត្ថកិច្ចតុលាការកំពូល :

..........................................................................................................................

ក- តុលាការនេះជាតុលាការជំនុំជំរះអង្គច្បាប់

ខ- តុលាការនេះអាចទទួលពាក្យបណ្តឹងកែតំរូវចំពោះសេចក្តីសំរេចរបស់សាលាឧទ្ធរណ៍ ពីអគ្គរដ្ឋអាជ្ញា ជនជាប់ទោស ភាគីរដ្ឋប្បវេណី ឬទីប្រឹក្សារបស់គេក្នុងរយៈពេលពីរខែ ចាប់ពីថ្ងៃដែលចេញសាលដីកាជំនុំជំរះ បើសាលដីកានោះធ្វើឡើងចំពោះមុខ ហើយនឹងបន្ថែមពេលបណ្តឹងជំទាស់ ១៥ថៃមទៀត បើសាលដីកានេះធ្វើឡើងដោយមិនចំពោះមុខ។ សាលដីការចំពោះមុខ គឺធ្វើឡើងដោយមានវត្តមានជនជាប់ចោទក្នុងពេលជំនុំជំរះពុំនោះទេនឹងទុកដូចជាមិនចំពោះមុខ ។

- មាត្រា ១៤ កថាខ័ណ្ឌ ២ និង ៣ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល :

២ : ជនជាប់ចោទមានសិទ្ធិសុំចៅក្រមឱ្យដោះលែងខ្លួនតាមរយៈខ្លួនឯងផ្ទាល់ ឬតាមរយៈទីប្រឹក្សារបស់ខ្លួន។ ក្នុងរយៈពេល ៥ ថ្ងៃ ចៅក្រមត្រូវឆ្លើយតាមដីកាដែលមានថែងមូលហេតុ ។

៣ : ក្នុងរយៈពេល ៥ ថ្ងៃ ក្រោយពីដីកានោះមកជនជាប់ចោទ ភាគីរដ្ឋប្បវេណី ឬ ទីប្រឹក្សារបស់ភាគីទាំងសង្ខាង ឬ រដ្ឋអាជ្ញា អាចសុំឧទ្ធរណ៍ពីសេចក្តីសំរេចរបស់ចៅក្រម។ ក្នុងរយៈពេល១៥ថ្ងៃ សាលាឧទ្ធរណ៍ត្រូវសំរេចលើពាក្យសុំឧទ្ធរណ៍ទាំងឡាយដែលទាក់ទិនក្នុងរឿងឃុំខ្លួននេះ ។

- ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ បានចែងអំពីសិទ្ធិប្តឹងឧទ្ធរណ៍ ក្នុងរយៈពេលពីរខែគត់ គិតពីថ្ងៃប្រកាសសាលក្រម (មាត្រាទី១៩៥)។ មាត្រា១៥៦ ទៅ២០៥ កំណត់ពីនីតិវិធីទាក់ទងនឹងសាលាឧទ្ធរណ៍ ហើយមាត្រា២០៦ ទៅ២៣៦ កំណត់ពីនីតិវិធីទាក់ទងនឹងតុលាការកំពូល ។
- សេចក្តីព្រាងក្រមនីតិវិធីព្រហ្មទាណ្ឌមានចែងផងដែរ អំពីសិទ្ធិក្នុងការប្តឹងឧទ្ធរណ៍ ។
- មាត្រា ១៨៥ និង ៣៦២ ចែងអំពីសិទ្ធិជនជាប់ចោទក្នុងការសុំឱ្យដោះលែងឱ្យនៅក្រៅឃុំបានគ្រប់វេលា ។ ក្នុងករណីចៅក្រមស៊ើបអង្កេតមិនសំរេចក្នុងរយៈពេល ៥ថ្ងៃ ជនជាប់ចោទអាចប្តឹងផ្ទាល់ទៅសភាស៊ើបសួរ ដែលសំរេចជំនួសចៅក្រមស៊ើបសួរ ។
- មាត្រា១៩០ ១៩២ ២៣២ ២៣៧ ចែងអំពីសិទ្ធិរបស់ជនជាប់ចោទក្នុងការប្តឹងអំពីសេចក្តីសំរេចរបស់ចៅក្រមស៊ើបអង្កេត ។

*V-* *<u>ទទួលបានដោយឥតគិតថ្លៃនូវជំនួយរបស់អ្នកបកប្រែ បើសិនជាកុមារមិនអាចស្តាប់បាន ឬមិនអាចនិយាយភាសាដែលត្រូវប្រើ :</u>*

- ច្បាប់ស្តីពីនីតិវិធីជំនុំជំរះផ្នែកព្រហ្មទណ្ឌចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៨៩ ចែងថា :
- មាត្រា៥ : ភាសាដែលត្រូវប្រើចំពោះមុខតុលាការគឺភាសាខ្មែរ។ ប៉ុន្តែសាលាជំរះក្តីធានាឱ្យពលរដ្ឋដែលជាជនជាតិភាគតិចប្រើភាសា និងអក្សររបស់ខ្លួនបាន ។
- មាត្រា២៤ : អ្នកបកប្រែភាសា ត្រូវមានវត្តមាននៅពេលសវនាការ តាមលិខិតអញ្ជើញរបស់តុលាការ ហើយត្រូវបំពេញភារកិច្ចរបស់ខ្លួនឱ្យបានល្អ។ ក្នុងករណីដែលអ្នកបកប្រែភាសាបកបង្ខុសដោយចេតនានោះ ត្រូវបញ្ជូនខ្លួនទៅតុលាការជំនុំជំរះ ។
- មាត្រា ៥០ : (ស្រដៀងគ្នានឹងមាត្រាទី ១៣៦ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ) ។
- មាត្រា ១៣៦ នៃច្បាប់ស្តីនីតិវិធីព្រហ្មទណ្ឌចែងថា :

បើជនជាប់ចោទ ឬ សាក្សីជាមនុស្ស គ ថ្លង់ ប៉ុន្តែចេះសរសេរអក្សរនោះ ក្រឡាបញ្ជីត្រូវសរសេរសំណួរ និង ការកត់សំគាល់ផ្សេងៗឱ្យទៅជនជាប់ចោទ ឬសាក្សីគថ្លង់នោះ ដើម្បីឱ្យឆ្លើយមកវិញដោយលាយលក្ខ័អក្សរ។ បើជនគ ថ្លង់

មិនចេះសរសេរអក្សរ ចៅក្រមត្រូវតែងតាំងដោយឯកឯងនូវជនម្នាក់ដែលមានទំលាប់ទាក់ទងមនុស្ស គ ថ្លង់ ដោយកាយវិការ ដើម្បីធ្វើជាអ្នកបកប្រែ ។

- នៅក្នុងតុលាការភ្នំពេញ មានអ្នកបកប្រែភាសាចិន និង ភាសាវៀតណាមដែលត្រូវបានតែងតាំងដោយក្រសួងយុត្តិធម៌ ។ ចំពោះខេត្តក្រុងឯទៀតក៏តុលាការតែងតែរកអ្នកបកប្រែក្នុងករណីចាំបាច់ ។
- សេចក្តីព្រាងក្រមនីតិវិធីព្រហ្មទណ្ឌ ដែលរៀបចំដោយក្រសួងយុត្តិធម៌ ក៏មានចែងអំពីបញ្ហាអ្នកបកប្រែ :

  + មាត្រា ១៣២ : ក្នុងករណីចាំបាច់ចៅក្រមស៊ើបសួរត្រូវហៅរកអ្នកបកប្រែ ។

  + មាត្រា ១៤៣ : ចៅក្រមស៊ើបអាចហៅរកអ្នកបកប្រែដើម្បីស្តាប់ចំលើយសាក្សី ។
- មាត្រា ២៧៤,២៧៥ និង ២៧៦ : កំណត់ឱ្យព្រះរាជអាជ្ញាកោះហៅអ្នកបកប្រែចូលរួមសវនាការ ។
- មាត្រា ៣០៧ : ក្នុងករណីចាំបាច់ ប្រធានអាចហៅរកអ្នកបកប្រែ ។

***vi*** ***ជីវិតឯកជនរបស់កុមារត្រូវបានគោរពទាំងស្រុង នៅក្នុងគ្រប់ដំណាក់នៃនីតិវិធី :***

- មាត្រា ៤០ នៃរដ្ឋធម្មនុញ្ញចែងថា :

សេរីភាពក្នុងការដើរឆ្ងាយជិត និងតាំងទីលំនៅក្នុងស្ថានភាពស្របច្បាប់របស់ ប្រជាពលរដ្ឋត្រូវបានគោរព។ ប្រជាពលរដ្ឋខ្មែរអាចចេញទៅតាំងទីលំនៅ នៅប្រទេសក្រៅ ឬអាចវិលត្រឡប់មកវិញបាន។

ការរក្សាសិទ្ធិមិនឱ្យរំលោភលើលំនៅដ្ឋាន និង អាថិកំបាំងនៃការឆ្លងឆ្លើយតាមលិខិត តាមសារទូរលេខ ទូរពុម្ព ទូរគមន៍ និង តាមទូរស័ព្ទ ត្រូវបានធានា ។
ការឆែកឆេរលំនៅដ្ឋាន សំភារៈ វត្ថុ និង លើរូបបុគ្គល ត្រូវធ្វើឱ្យស្របនឹងបញ្ញត្តិច្បាប់ ។

- មាត្រា ២០ ច្បាប់ព្រហ្មទណ្ឌអន្តរកាលចែងថា :

ក្នុងករណីបទល្មើសជាក់ស្តែងនគរបាលអាចធ្វើការឆែកឆេរ។ ទាំងនេះត្រូវធ្វើនៅចំពោះមុខជនជាប់សង្ស័យ និងសាក្សីពីរនាក់ ហើយបើអាចធ្វើបានសាក្សី គួរយកអ្នកជិតខាង ឬ អ្នកម្ចាស់ផ្ទះ ។

បើមិនមែនជាបទល្មើសដែលគេទាន់ជាក់ស្តែងទេ ការរឹបអូសទាំងឡាយត្រូវមានសេចក្តីអនុញ្ញាតអំពីចៅក្រមណាមួយនៃតុលាការពាក់ព័ន្ធ ឬ ពីរដ្ឋអាជ្ញា ។ ការឆែកឆេរទាំងនេះអាចធ្វើបានតែក្នុងចន្លោះម៉ោង ៦ ព្រឹក ទៅម៉ោង ៦ ល្ងាច ។ ហើយបើអាចធ្វើបានការឆែកឆេរទាំងនេះ ត្រូវធ្វើនៅចំពោះមុខជនជាប់សង្ស័យ និង ចំពោះមុខសាក្សី ពីរនាក់ដែលជ្រើសយកពីក្នុងចំណោមសមាជិកគ្រួសារជនជាប់សង្ស័យ។ ភស្តុតាងទាំងឡាយណា ដែលបានមកដោយរំលោភនឹងមាត្រានេះ មិនអាចយកជាការបានឡើយ ក្នុងពិធីកាត់សេចក្តី ។

- មាត្រា ២២ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាលចែងថា :

១- ការមិនបានគោរពតាមនីតិវិធីដែលចែងក្នុងមាត្រា១០ ទៅមាត្រា២១ នាំឱ្យដោះលែងជនជាប់ចោទឱ្យមានសេរីភាពជាបន្ទាន់ ប្រសិនបើការខុសឆ្គងនោះ ធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំងដល់សិទ្ធិនៃការការពារ។ ការប្រគល់សេរីភាពជាបន្ទាន់នេះ អាចធ្វើឡើងតាមសេចក្តីសុំរបស់ទីប្រឹក្សានៃជនជាប់ចោទ ឬមន្ត្រីដែលមានការអនុញ្ញាតនៃផ្នែករដ្ឋបាលស៊ីវិលផ្នែកសិទ្ធិមនុស្ស ឬផ្នែកនគរបាលស៊ីវិលរបស់អ៊ុនតាក់។ ដល់ថ្ងៃដែលបទបញ្ញត្តិនេះបាន

ចូលជាធរមានជនជាប់ឃុំឃាំង ឬជាប់ពន្ធនាគារទាំងអស់ ត្រូវមានសំនុំរឿងសមស្របតាមលក្ខន្តិកៈនៃបទបញ្ញត្តិនេះ សំរាប់ត្រួតពិនិត្យជាបន្ទាន់ពីសំណាក់ ចៅក្រម រដ្ឋអាជ្ញា ឬ ភ្នាក់ងារដែលមានការអនុញ្ញាតរបស់អ៊ុនតាក់។ បើគ្មានសំនុំរឿងបែបនេះទេ ជនទាំងនោះនឹងត្រូវបានដោះលែងឱ្យមានសេរីភាព តាមសេចក្តីសុំរបស់ទីប្រឹក្សាមន្ត្រី ដែលមានការអនុញ្ញាតនៃផ្នែករដ្ឋបាលស៊ីវិល ផ្នែកសិទ្ធិមនុស្ស ឬផ្នែកនគរបាលស៊ីវិលរបស់អ៊ុនតាក់ ចៅក្រម ឬ រដ្ឋអាជ្ញា ។

២- ការរំលោភពីសំណាក់ភ្នាក់ងារសាធារណៈលើសិទ្ធិបុគ្គល ដូចមានចែងក្នុងមាត្រា១០ ទៅមាត្រា២១ នៃបទបញ្ញត្តិនេះ នឹងត្រូវផ្តន្ទាទោសតាមមាត្រា ៥៧ ។

- មាត្រា ៥៧ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាលចែងថា :

គ្រប់ភ្នាក់ងារសាធារណៈរួមទាំងភ្នាក់ងារនគរបាល និងយោធិន ដែលរំលោភដោយមិនរួញរាទៅលើសិទ្ធិបូរណ-ភាពបុគ្គល និង ភាពមិនអាចរំលោភបាននៃលំនៅដ្ឋាន ដែលត្រូវបានការពារដោយបទបញ្ញត្តិនេះ និងត្រូវផ្តន្ទា ទោសដាក់គុកពី ១ ឆ្នាំ ទៅ ៥ ឆ្នាំ ។

- សេចក្តីព្រាងក្រមព្រហ្មទណ្ឌក៏មានបទបញ្ញត្តិជាច្រើនដែលទាក់ទងនឹងសិទ្ធិឯកជននេះ។ ក្រមនោះកំណត់ពីការសំងាត់នៃការស៊ើបអង្កេត (មាត្រា២៦) ដាក់បទបញ្ញត្តិលើការឆែកឆេរ (មាត្រា ៨៣ ១០៤ ១៤៧ និង២០៨) និងចែងអំពីការសំងាត់នៃការសន្ទនារវាងជនដែលត្រូវឃាត់ខ្លួន និង មេធាវីរបស់ជននោះ ។

***សំនួរទី១៩ :*** ***ចំពោះស្ថានភាពកុមារដែលបាត់បង់សេរីភាព សូមផ្តល់ព័ត៌មានអំពីបន្ថែមស្ថានភាពកុមារដែលត្រូវបានឃុំខ្លួននៅកន្លែងផ្សេងៗ ក្រៅអំពីមជ្ឈមណ្ឌលយុវនីតិសម្បទា (ភ្នំពេញ) និងដោយអនុវត្តតាមមាត្រា ៣៧ ៤០ និង ៣៩ នៃអនុសញ្ញា ជាពិសេសផ្តោតទៅលើ :***

- ***ការបំបែកកុមារចេញពីមនុស្សពេញវ័យ***
- ***ការឃុំខ្លួនបណ្តោះអាសន្ន***
- ***ឱកាសសំរាប់ទាក់ទងជាមួយគ្រួសារ***
- ***ការត្រួតពិនិត្យមើលនូវលក្ខខ័ណ្ឌនានាក្នុងស្ថានភាពនៅក្នុងមណ្ឌលឃុំខ្លួន***
- ***ការធានានានា សំដៅធ្វើឱ្យប្រាកដនូវការពិនិត្យមើលឡើងវិញជាទៀតទាត់ លើការយកកុមារទៅដាក់នៅទីនោះ***
- ***នីតិវិធីធ្វើពាក្យបណ្តឹងក្នុងករណីមានធ្វើទុក្ខទោស***
- ***ការសិក្សា ការអប់រំសុខភាព និង គ្រឿងសំភារៈប្រើប្រាស់នានា***
- ***ការអប់រំសុខភាព និងមធ្យោបាយផ្សេងៗទៀត សូមផ្តល់ព័ត៌មានបន្ថែមទៀតនូវព័ត៌មានបន្ថែមស្តីអំពីមធ្យោបាយចំលាស់ដែលកំពុងមានអត្ថិភាពនានា និង ដែលជំនួសការដកហូតសេរីភាព ។***

**ចម្លើយ :**

- *<u>កុមារដែលត្រូវឃុំខ្លួននៅតាមទីកន្លែងនានា ក្រៅពីមណ្ឌលយុវនីតិសម្បទា</u> :*

ផ្អែកតាមទិន្នន័យរបស់ក្រសួងមហាផ្ទៃនៅក្នុងខែមេសា ឆ្នាំ២០០០នេះ មានកុមារចំនួន៩៥នាក់ ដែលស្ថិតនៅក្នុងពន្ធនាគារ។ នៅក្នុងនោះកុមារាមាន៩០នាក់ ហើយកុមារី៥នាក់។ កុមារទាំងនោះមានអាយុចាប់ពី១៣ ទៅ១៧ ឆ្នាំ។ ក្នុង

ចំណោមនោះ កុមារ៥៩នាក់ ជាពិរុទ្ធជន ហើយ៤០នាក់ ជាទណ្ឌិតដែលត្រូវផ្តន្ទាទោសដាក់ពន្ធគារ។ ទោសពន្ធនាគារដែលដាក់ទៅលើកុមារជាទណ្ឌិតទាំងនោះ គឺអាស្រ័យដោយសាលក្រមរបស់តុលាការ ។

- *ស្ថានភាពពន្ធនាគារ :*

ពន្ធនាគារភាគច្រើន ជាពន្ធនាគារចាស់ហើយមួយចំនួនមានអាយុកាលតាំងពីសម័យអាណានិគមបារាំង។ ប្រាក់ឧបត្ថម្ភសំរាប់អ្នកជាប់ពន្ធគារម្នាក់ៗគឺ១000 រៀល ក្នុងមួយថ្ងៃ (១$ = ៣៨00 ៛)។

- *ការប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការដោះស្រាយបញ្ហាពន្ធនាគារ :*

ដោយមានជំនួយពីប្រទេសអូស្ត្រាលី ក្រសួងមហាផ្ទៃបានប្រឹងប្រែងធ្វើឱ្យស្ថានភាពពន្ធនាគារ មានភាពប្រសើរឡើង។ ជាលទ្ធផលពន្ធនាគារថ្មីមួយ ត្រូវបានស្ថាបនាឡើងហើយបទបញ្ជាថ្មីៗមួយចំនួនក៏ត្រូវបានអនុវត្ត ។

- *ការបំបែកកុមារចេញពីមនុស្សពេញវ័យ :*

ប្រកាសលេខ ២១៧ ប្រ.ក ចុះថ្ងៃទី៣១ ខែមិនា ឆ្នាំ១៩៩៨ របស់ក្រសួងមហាផ្ទៃស្តីពីការគ្រប់គ្រងពន្ធនាគារ ដែលមានភ្ជាប់ជូនជាមួយនៅក្នុងឧបសម្ព័ន្ធ បានកំណត់បទបញ្ជាលើការទទួលយកចូលពន្ធគារ និងលក្ខខណ្ឌនានានៃពន្ធនាគារ។ ប្រកាសនេះចែងអំពីការដាក់អ្នកទោសស្រី និងអ្នកទោសបុរសឱ្យនៅដាច់ដោយឡែកពីគ្នា។ ការដាក់អ្នកទោសដែលជាអនីតិជនអាយុក្រោម១៨ឆ្នាំ ឱ្យនៅដាច់ដោយឡែកពីអ្នកទោសដែលមានវ័យចាស់ និងការដាក់ទណ្ឌិតឱ្យនៅដោយឡែកពី ពិរុទ្ធជន ។ល។

ក្នុងការអនុវត្តជាក់ស្តែងដោយសារហេដ្ឋារចនាសម្ព័ន្ធនៅអន់ថយ អ្នកទោសវ័យក្មេងពុំអាចត្រូវបានបំបែកចេញពីអ្នកទោសវ័យចាស់ជានិច្ចជាកាលនោះទេ។ ទោះយ៉ាងនេះក្តី បច្ចុប្បន្នក្រសួងមហាផ្ទៃកំពុងចូលរួមក្នុងការកែទំរង់ពន្ធនាគារ។ ពន្ធនាគារថ្មីមួយនៅជាយក្រុងភ្នំពេញ ត្រូវបានស្ថាបនារួចជាស្រេចនាពេលថ្មីៗនេះ ដែលមានអាគារដោយឡែកសំរាប់ដាក់អ្នកទោសស្រី និងអ្នកទោសកុមារ ។ ចំពោះពន្ធគារខេត្តវិញ អ្នកទោសវ័យក្មេងនៅតែត្រូវដាក់ជាមួយអ្នកទោសវ័យចាស់នៅឡើយ។

- *ការឃុំខ្លួនបណ្តោះអាសន្ន :*

មាត្រា១២ នៃច្បាប់អ៊ុនតាក់ បានបញ្ញត្តិថាការចាប់ខ្លួន និងការឃុំខ្លួន ត្រូវតែគោរពតាមបទដ្ឋានអប្បបរិមានៃបទវិន័យសំរាប់គ្រប់គ្រងអ្នកជាប់ឃុំ ព្រមទាំងត្រូវគោរពតាមគោលការណ៍ជាមូលដ្ឋានសំរាប់ការពារអ្នកទោស ដែលអង្គការសហប្រជាជាតិបានអនុម័ត ។

មាត្រា ១៤ កថាខ័ណ្ឌ ៥ នៃច្បាប់អ៊ុនតាក់ចែងថា :

អនីតិជនអាយុតិចជាង ១៣ឆ្នាំ មិនត្រូវជាប់ឃុំឃាំងបណ្តោះអាសន្ន។ អនីតិជនដែលមានអាយុ១៣ ឆ្នាំ ទៅ១៨ ឆ្នាំ មិនត្រូវជាប់ឃុំឃាំងជាបណ្តោះអាសន្នលើសពី ១ខែទេ។ រយៈពេលនេះអាចទ្វេរឡើងជាពីរ បើសិនជាមានការចោទប្រកាន់ពីបទឧក្រិដ្ឋណាមួយ ។

ជំពូកទី១១ នៃសេចក្តីព្រាងក្រមនីតិវិធីព្រហ្មទណ្ឌកំណត់ពីបទបញ្ញត្តិ ដែលទាក់ទងនឹងការឃុំខ្លួនបណ្តោះអាសន្ន។ ក្រមនេះចែងពីគោលការណ៍ដែលថា ជនជាប់ចោទត្រូវតែមានសេរីភាព ហើយការឃុំខ្លួនបណ្តោះអាសន្នធ្វើឡើងតែក្នុងករណីចាំបាច់តែប៉ុណ្ណោះ (មាត្រា ១៧២ ដល់ ១៧៤)។ មាត្រា ១៨០ ធ្វើការហាមឃាត់មិនឱ្យមានការឃុំបណ្តោះអាសន្ននូវអនីតិជនអាយុតិចជាង១៣ឆ្នាំ។ ចំពោះអនីតិជនអាយុ១៣ឆ្នាំយ៉ាងតិច នឹងត្រូវជាប់ចោទពីបទឧក្រិដ្ឋ ការឃុំខ្លួនបណ្តោះអាសន្នមិនអាចលើសពី៦ខែបានទេ កាលណាអនីតិជននោះអាយុតិចជាង១៦ឆ្នាំ (មាត្រា១៨១)។ បើអនីតិជនត្រូវចោទពីបទមជ្ឈឹមថេរៈវេលា

ឃុំខ្លួនបណ្ដោះអាសន្នមិនអាចលើសពី ៤ ខែបានទេ បើអាយុតិចជាង១៦ឆ្នាំ និងមិនលើសពី៦ខែទេ បើអនីតិជនអាយុ១៦ឆ្នាំ យ៉ាងតិចដល់ ១៨ឆ្នាំ ( មាត្រា ១៨២ ) ។

- *ឱកាសទាក់ទងជាមួយគ្រួសារ :*

ប្រកាសលេខ ២១៧ ប្រ.ក ចុះថ្ងៃទី៣១ ខែមិនា ឆ្នាំ១៩៩៨ របស់ក្រសួងមហាផ្ទៃស្ដីពីការគ្រប់គ្រងពន្ធនាគារដែលមានភ្ជាប់មកជាមួយនៅក្នុងឧបសម្ព័ន្ធ កំណត់បទបញ្ញាលើការទទួលយកពន្ធនាគារ និង លក្ខខណ្ឌនានានៃពន្ធនាគារ ។ ប្រកាសនេះចែងពីការអនុញ្ញាតឱ្យមានការទាក់ទងគ្នារវាងអ្នកទោស និង គ្រួសាររបស់គេចំនួនពីរដងក្នុងសប្ដាហ៍ ។

- *ការត្រួតពិនិត្យមើលនូវលក្ខខណ្ឌនានាក្នុងស្ថាប័នទាំងនោះ :*

ប្រកាសដូចពោលខាងលើ ក៏មានចែងពីការត្រួតពិនិត្យកន្លែងឃុំខ្លួនទាំងនោះផងដែរ ។ ជនដែលអាចត្រួតពិនិត្យពន្ធនាគាររួមមាន តំណាងព្រះមហាក្សត្រ សមាជិករដ្ឋសភា រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ជនទាំងឡាយដែលទទួលបានការអនុញ្ញាតពីក្រសួង មហាផ្ទៃ ចៅក្រម ព្រះរាជអាជ្ញា អភិបាលខេត្ត-ក្រុង ព្រមទាំងជនណាម្នាក់ ឬ អង្គការណាមួយដែលបានទទួលការអនុញ្ញាតជាលាយល័ក្ខអក្សរពីប្រធាននាយកដ្ឋានពន្ធនាគារ ។ ជាទូទៅព្រះរាជអាជ្ញា ធ្វើការត្រួតពិនិត្យពន្ធ-នាគារពីរដងក្នុងមួយសប្ដាហ៍ ។

សារាចរលេខ ០១១ ស.រ របស់ក្រសួងមហាផ្ទៃ ស្ដីពីការគ្រប់គ្រង និងត្រួតពិនិត្យពន្ធនាគារស៊ីវិល ព្រះរាជាណាចក្រកម្ពុជាចុះថ្ងៃទី៣១ ខែមិនា ឆ្នាំ១៩៩៨ ចែងអំពីសិទ្ធិអំណាចរបស់អភិបាលខេត្ត-ក្រុង ក្នុងការត្រួតពិនិត្យពន្ធនាគារខេត្ត-ក្រុងក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ព្រមទាំងសិទ្ធិអំណាចក្នុងការទទួលពាក្យបណ្ដឹងពីជនដែលជាប់ពាក់ព័ន្ធក្នុងប្រតិបត្តិការពន្ធនាគារស៊ីវិលតាមដែនសមត្ថកិច្ចរបស់ខ្លួន ហើយលើករឿងទាំងនេះ ទៅអគ្គនាយកនៃនាយកដ្ឋានរដ្ឋបាល និង នាយកដ្ឋានពន្ធនាគារ ។

ក្រៅពីនេះ នៅមានបទបញ្ញាជាច្រើនទៀត ទាក់ទងនឹងពន្ធនាគារដូចដែលមានចង្អុលបង្ហាញក្នុងឯកសារនៃតារាងនិតិវិធីពន្ធនាគារ ដែលភ្ជាប់ជូនមកជាមួយក្នុងឧបសម្ព័ន្ធ ។

ឯសេចក្ដីព្រាងក្រមនីតិវិធីព្រហ្មទណ្ឌ ចែងពីការចាត់តាំង និងរបបផ្ទៃក្នុងពន្ធនាគារ និងមជ្ឈមណ្ឌលឃុំខ្លួននានាដែល នឹងកំណត់ដោយប្រកាសរបស់ក្រសួង ។ ក្រមនេះក៏ចែងផងដែរ ពីការធ្វើអធិការកិច្ចពន្ធនាគារជាប្រចាំ ដោយអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ប្រធានសភា ស៊ើបសួរព្រះរាជអាជ្ញា និង ចៅក្រមស៊ើបសួរ ។

- *ការធានាសំដៅធ្វើឱ្យប្រាកដនូវការពិនិត្យឡើងវិញជាទៀងទាត់ លើការយកកុមារទៅដាក់ :*

យោងតាមក្រមនីតិវិធីព្រហ្មទណ្ឌថ្មី ជនជាប់ចោទអាចប្ដឹងឧទ្ធរណ៍ពីការឃុំខ្លួនបណ្ដោះអាសន្នបាន ( មាត្រា ១៨៥ ) ។

មាត្រាទី១៦៩ នៃសេចក្ដីព្រាងក្រមព្រហ្មទណ្ឌចែងថា ទណ្ឌិតជាអនីតិជនមានអាយុតិចជាង១៨ ឆ្នាំ អាចទទួលសេរីការមានល័ក្ខខ័ណ្ឌបានជាដរាប ទោះបីក្មេងនោះបានរងទោសចំនួនប៉ុន្មានក៏ដោយ ។ ឯមាត្រា ១៨០ ចែងថា អនីតិជនអាយុតិចជាង១៨ឆ្នាំ អាចទទួលបានការលោះលាទោស ឬ ការបន្ថយទោសដោយគ្មានលក្ខខណ្ឌ ។

- *នីតិវិធីធ្វើបណ្ដឹងក្នុងករណីមានការធ្វើទុក្ខទោស :*

ក្រសួងមហាផ្ទៃពុំបានទទួលរបាយការណ៍ពីករណីអ្នកទោសវ័យក្មេង ត្រូវរងនូវការធ្វើទុក្ខទោសនៅពន្ធនាគារនេះទេ ។ ប្រសិនបើឪពុកម្ដាយកុមារទាំងនោះ ជួបហេតុការណ៍ដែលកូនរបស់គេត្រូវបានធ្វើទុក្ខទោស គេអាចដាក់ពាក្យប្ដឹងទៅតុលាការ ។

- *ការសិក្សាអប់រំ សុខភាព និង គ្រឿងសំភារៈប្រើប្រាស់ :*

ប្រកាសលេខ២១៧ ចុះថ្ងៃទី៣១ ខែមិនា ឆ្នាំ១៩៩៨ របស់ក្រសួងមហាផ្ទៃស្តីពីការគ្រប់គ្រងពន្ធនាគារ ចែងពីការទទួលយកអ្នកទោសចូលនឹងលក្ខខ័ណ្ឌនៃពន្ធនាគារ រួមទាំងសិទ្ធិរបស់អ្នកទោស ការទទួលបាននូវការសិក្សាអប់រំ ការទទួលបាននូវការថែរក្សាសុខភាព និង គ្រឿងសំភារៈនានា ។

ក៏ប៉ុន្តែដោយសារការខ្វះខាតធនធាន ទោះបីជាពន្ធនាគារខ្លះមានកន្លែងសំរាប់ពិនិត្យ និងព្យាបាលជំងឺ តែមានថ្នាំពេទ្យតិចតួចបំផុត។ បើអ្នកទោសវ័យក្មេងឈឺ ឪពុកម្តាយត្រូវចេញថ្លៃថ្នាំ។ ក្នុងករណីដែលចៅក្រមអនុញ្ញាតិឱ្យយកអ្នកទោសវ័យក្មេងទៅមន្ទីរពេទ្យនោះ អាជ្ញាធរពន្ធនាគារជាអ្នកទទួលបន្ទុកដោះស្រាយបញ្ហានេះ ។

- *<u>មធ្យោបាយចំលាស់ដែលកំពុងមានអត្ថិភាពហើយដែលប្រើជំនួសការដកហូតសេរីភាព :</u>*

ពុំមានមធ្យោបាយចំលាស់ក្រៅពីការដកហូតសេរីភាពនោះទេ តែមានការពិន័យជាជំនួស ។

***សំនួរទី២០ :*** ***សូមផ្តល់ព័ត៌មានបន្ថែមទៀត ស្តីពីវិធានការអនុវត្តដែលបានសន្យាដើម្បីបង្ការ និងប្រឆាំងការបំពាបំពានតាមផ្លូវភេទ ការជួញដូរ និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ រួមមានពេស្យាចារ រូបភាពអាសអាភាស និងទេសចរណ៍ផ្លូវភេទ សូមផ្តល់ព័ត៌មានបន្ថែមផងដែរ អំពីកិច្ចព្រមព្រៀងទ្វេភាគីតំបន់ និងពហុភាគី ដែលពាក់ព័ន្ធ ដែលបានធ្វើ ឬដែលបានចូលជាសមាជិក ដែលក្នុងនោះមានវិស័យនានា ស្តីពីកិច្ចសហប្រតិបត្តិការក្នុងវិស័យយុត្តិធម៌ និងសហប្រតិបត្តិការក្នុងចំណោមមន្ត្រីអនុវត្តច្បាប់សំដៅ ធ្វើឱ្យមានកិច្ចបង្ការ និងប្រឆាំងការបញ្ជូនខុសច្បាប់មិនត្រលប់មកវិញ ការជួញដូរភេទលើកុមារ និងជួញដូរដើម្បីគោលបំណងផ្សេងៗទៀតខ សូមបញ្ជាក់បន្ថែមអំពីការអនុវត្តផែនការជាតិ៥ឆ្នាំប្រឆាំងការជួញដូរផ្លូវភេទលើកុមារ ដែលបានប្រកាសនៅខែកក្កដា ឆ្នាំ១៩៩៩ ខ***

**ចម្លើយ :**

## I. វិធានការបង្ការទប់ស្កាត់ និងប្រយុទ្ធប្រឆាំងនឹងការរំលោភបំពានតាមផ្លូវភេទ ការចាប់ពង្រត់ និងជួញដូរលើកុមារ

ក្នុងការទប់ស្កាត់ និងប្រឆាំងការជួញដូរផ្លូវភេទលើកុមារ ប្រទេសកម្ពុជាមានច្បាប់ បទញ្ញត្តិ ផែនការជាតិ និងកម្មវិធីផ្សេងៗ ។

### ១- <u>ផែនការ និង សេចក្តីប្រកាសរបស់រាជរដ្ឋាភិបាល</u> :

◆ ផែនការជាតិ ៥ឆ្នាំប្រឆាំងការជួញដូរ និង កេងប្រវ័ញ្ចផ្លូវភេទលើកុមារ បានទទួលការអនុម័តពីអង្គប្រជុំគណៈរដ្ឋមន្ត្រីនាថ្ងៃ១៧ ខែមិនា ឆ្នាំ២០០០។ ក្រោយពីការប្រារព្ធសន្និសីទឆ្នាំ១៩៩៦ នៅទីក្រុងស្តុកខុលម៍ ដែលចូលរួមដោយគណៈប្រតិភូជាន់ខ្ពស់របស់កម្ពុជា ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារបានរៀបចំផែនការនេះ ដោយមានការពិគ្រោះយោបល់នឹងអង្គការអន្តរជាតិនានាដែលពាក់ព័ន្ធ ក៏ដូចជាអាជ្ញាធរខេត្តជាច្រើនទៀត ។ ផែនការជាតិនេះមាន ភ្ជាប់ជូននៅក្នុងឧបសម្ព័ន្ធ ។

ផែនការជាតិនេះមានកម្មវិធីធំៗ ៤ គឺ :

*<u>កិច្ចបង្ការទប់ស្កាត់</u> :*

មានគោលដៅ៣ យុទ្ធសាស្ត្រ៦ និងសកម្មភាពមួយចំនួន ដើម្បីបង្ការទប់ស្កាត់កុមារពីការត្រូវគេជួញដូរ នឹងពីការធ្លាក់ខ្លួនទៅក្នុងអំពើពេស្យាចារ ដោយធ្វើការលើកកំពស់ការយល់ដឹងដល់សង្គមជាតិកម្ពុជាទាំងមូលតាមរយៈសិក្ខាសាលា ការផ្សព្វផ្សាយតាមប្រព័ន្ធពត៌មានចំរុះ ការបញ្ចូលក្នុងកម្មវិធីសិក្សាក្នុង និងក្រៅប្រព័ន្ធ និងតាមបណ្ណាល័យ

ចល័តនូវ សិទ្ធិកុមារ ច្បាប់ ល្បិចកិច្ចកលរបស់ជនខិលខូច សារធាតុញៀន គ្រោះថ្នាក់នៃការធ្វើការជួញដូរកេងប្រវ័ញ្ចផ្លូវភេទ។ បំផុសសហគមន៍ឱ្យចេះថែរក្សាការពារកូនចៅ តាមភូមិ ឃុំ ស្រុក ដោយមានប្រព័ន្ធតាមដានដល់មូលដ្ឋាន ។

*កិច្ចការពារ :*

មានគោលដៅ៤ យុទ្ធសាស្ត្រ៨ និងសកម្មភាពមួយចំនួន ធ្វើឱ្យប្រសើរឡើងនូវក្របខណ្ឌការងារច្បាប់ ទម្លាប់ធ្វើការពិនិត្យឡើងវិញនូវច្បាប់ដែលទាក់ទងទៅនឹងកុមារ ព្រមទាំងរៀបចំច្បាប់ ឬបញ្ញត្តិបន្ថែមទៀតដើម្បីការពារកុមារ។ ពង្រឹងការអនុវត្តច្បាប់ និងយន្តការដែលមានស្រាប់ និងបង្កើតឱ្យមានអង្គភាពពិសេស ដើម្បីបង្ក្រាបសកម្មភាពជួញដូរក៏ដូចជា ការប្រយុទ្ធប្រឆាំងនឹងការប្រើប្រាស់រូបភាពអាសអាភាស ព្រមទាំងធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធទទួលពាក្យបណ្ដឹង។ ការបណ្ដុះបណ្ដាលផ្សេងៗ ត្រូវធ្វើឡើងសំរាប់មន្ត្រីតុលាការ យោធា ប៉ូលីស និងអាជ្ញាធរមានសមត្ថកិច្ច។ បង្កើតអនុគណៈកម្មការ គ.ជ.ក.ក. ធ្វើការពិនិត្យតាមដាន និង ជំរុញការអនុវត្តផែនការ ។

*ការស្ដារ និង អភិវឌ្ឍន៍សមត្ថភាព :*

មានគោលដៅ២ យុទ្ធសាស្ត្រ៤ និងសកម្មភាពផ្សេងៗ ជួយកុមាររងគ្រោះដែលត្រូវបានសង្គ្រោះឱ្យមានជំរកបណ្ដោះអាសន្នក្នុងរយៈពេលខ្លី ផ្ដល់សេវាព្យាបាលសុខភាព ផ្ដល់សេវាអន្តរាគមន៍ ផ្នែកសង្គមចិត្តសាស្ត្រផ្ដល់ការអប់រំបណ្ដុះបណ្ដាលវិជ្ជាជីវៈ អប់រំសីលធម៌ ។ល។

*សមាហរណកម្មទៅក្នុងសហគមន៍ :*

មានគោលដៅ២ យុទ្ធសាស្ត្រ៥ និងសកម្មភាពផ្សេងៗដើម្បីបញ្ជូនកុមារ ដែលត្រូវបានសង្គ្រោះឱ្យទៅរស់នៅក្នុងសង្គម ដោយជួយរកការងារសមស្របឱ្យកុមារធ្វើ ឬផ្ដល់លទ្ធភាពឱ្យកុមារអាចរកស៊ីចិញ្ចឹមជីវិត ដោយខ្លួនឯង ព្រមទាំង ធ្វើការតាមដានបន្តលើកុមារ ដែលបានសង្គ្រោះ។

◆ រាជរដ្ឋាភិបាលកម្ពុជាបានចេញសេចក្ដីប្រកាសលេខ ០១ ស ប្រ ក ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ២០០០ ស្ដីពីដាក់ការចាត់តាំង អនុវត្តន៍ផែនការជាតិ៥ឆ្នាំប្រឆាំងការជួញដូរ និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ ដោយបានកំណត់ភារកិច្ចរបស់ក្រសួង ស្ថាប័ន អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ សហគមន៍ទាំងមូលដើម្បីឱ្យផែនការជាតិនេះត្រូវបានអនុវត្ត ដោយពិតប្រាកដ ។ ទន្ទឹមនេះដែរ ក្រសួង ស្ថាប័ន អាជ្ញាដែនដីគ្រប់លំដាប់ថ្នាក់ ត្រូវធ្វើការផ្សព្វផ្សាយផែនការជាតិ ហើយធ្វើផែនការអនុវត្តជាក់ស្ដែងតាមស្ថាប័ននីមួយៗ ព្រមទាំងធ្វើរបាយការណ៍តាមជំហានៗមក ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារដើម្បីបូកសរុបជូន រាជរដ្ឋាភិបាល ។

## ២. ច្បាប់ បទបញ្ញា និង ការអនុវត្ត

បន្ថែមលើច្បាប់ស្ដីពីការបង្ក្រាបអំពើពង្រាត់ និង លក់ដូរមនុស្ស និង អំពើធ្វើអាជីវកម្មលើមនុស្ស មានសារាចរ សេចក្ដីសំរេច និង លិខិតណែនាំមួយចំនួនទៀត ដែលធ្វើឡើងដោយរាជរដ្ឋាភិបាល និង ក្រសួងជំនាញ ដូចមាន:

- រាជរដ្ឋាភិបាលបានចេញសារាចរ និង សេចក្ដីសំរេច :
  - លេខ ០៩ សរ ចុះថ្ងៃទី២៦ ធ្នូ ១៩៩៧ ស្ដីពី ភារកិច្ចធំៗក្នុងការទប់ស្កាត់ការរំលោភលើផ្លូវភេទ ការកេងប្រវ័ញ្ច ឬជួញដូរ ស្ត្រី និង កុមារ ឱ្យធ្វើពេស្យាចារ និងការទប់ស្កាត់អំពើហឹង្សាលើស្ត្រីភេទ ។

- ❈ លេខ ០៣ ចុះថ្ងៃទី ១៨ កុម្ភៈ ១៩៩៩ ស្តីពីការពង្រឹងកិច្ចការការពារសន្តិសុខ និង សណ្តាប់ធ្នាប់សាធារណៈនៅ ក្នុងព្រះរាជាណាចក្រកម្ពុជា ដែលក្នុងនោះមានចែងអំពីការចាប់ពង្រត់លើស្ត្រី និងកុមារ ។
- ❈ លេខ ១៣ ស.រ.ណ.ន. ចុះថ្ងៃទី ២៩ កញ្ញា ១៩៩៩ ស្តីពីការពង្រឹង និង ពង្រីក ចលនាការងារប្រឆាំងនឹងការជួញដូរស្ត្រី និងកុមារ ។
- ❈ លេខ ១៤ ស.ស.រ. ចុះថ្ងៃទី ២៩ ខែកុម្ភៈ ឆ្នាំ២០០០ ស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួងបង្រ្កាបការធ្វើអាជីវកម្មបញ្ចាំង និងលក់កាសែតវីដេអូរអាសអាភាសក្នុងព្រះរាជាណាចក្រកម្ពុជា ។

- ក្រសួងយុត្តិធម៌បានធ្វើការណែនាំដល់តុលាការ និងព្រះរាជាអាជ្ញាអមតុលាការ ខេត្ត ក្រុង អំពីការអនុវត្តច្បាប់ខាងលើ ( តាមលិខិតលេខ១១៤០ ចុះថ្ងៃទី ១៦ តុលា ឆ្នាំ១៩៩៦) ។

- ◆ **ការប្រឆាំងនឹងការប្រើប្រាស់រូបភាពអាសអាភាស :**

- ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ បានចេញ :

  សារាចរណែនាំលេខ ០៤ ចុះថ្ងៃទី ០៥ សីហា ១៩៩៦ ស្តីពីការបញ្ចាំង និងការធ្វើអាជីវកម្មភាពយន្ត និង វីដេអូ :

  - ❈ បានហាមដាច់ខាតការលក់ ជួល ឬ បញ្ចាំងវីដេអូដោយគ្មានទិដ្ឋាការឬ មានលក្ខណៈឃោរឃៅអាសអាភាស ។
  - ❈ លិខិតលេខ ៧៦ សណ ចុះថ្ងៃទី ២៩ មករា ១៩៩៧ ហាមប្រាមដល់ម្ចាស់រោងវីដេអូមួយចំនួន ឱ្យបញ្ឈប់សកម្មភាពបញ្ចាំង វីដេអូអាសអាភាស ។

- ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈបានសហការជាមួយក្រសួងមហាផ្ទៃ ធ្វើការទប់ស្កាត់ការនាំចូល វប្បធម៌ពាលាអាវ៉ាសែ កាសែត វីដេអូ និង ទស្សនាវដ្តីអាសអាភាស ។

- ក្រសួងពត៌មានបានចេញសារាចរណែនាំ លេខ៣៧ /៩៩ ចុះថ្ងៃទី ១៤ មករា ១៩៩៩ ហាមស្ថានីយ៍ទូរទស្សន៍ និងទូរទស្សន៍ ខ្សែកាបទាំងអស់ មិនឱ្យបញ្ចាំងដាច់ខាតនូវឈុតរំលោភ និង អាសអាភាសដែលមាននៅក្នុងសាច់រឿងវីដេអូ។ ហាមស្លៀកពាក់ ខើចពេក និងធ្វើឱ្យស្រើបស្រាលហួសហេតុ ក្នុងការសំដែងសិល្បៈទាំងឡាយ ហើយបានសំនូមពរឱ្យកាត់បន្ថយការបញ្ចាំង ខ្សែវីដេអូដែលមានភាពសាហាវឃោឃៅ និងហាមមិនឱ្យកុមារទៅចូលរួមសំដែងក្នុងកម្មវិធីគ្មានការអប់រំ ដែលជះឥទ្ធិពលដល់កុមារទូទៅ ។

- ◆ **ការប្រឆាំងពេស្យាចារកុមារតាមវិស័យទេសចរណ៍ :**

- ក្រសួងទេសចរណ៍បានធ្វើលិខិតហាម មិនឱ្យយកទីតាំងអាជីវកម្ម សេវាកម្មវិស័យទេសចរណ៍ ធ្វើជាកន្លែងបនល្បែង ពេស្យាចារ ប្រើគ្រឿងញៀន បញ្ចាំងវីដេអូអាសអាភាសផ្ទុយនឹងច្បាប់រដ្ឋ ( លិខិតលេខ ១៦ សជណ ចុះថ្ងៃទី ១២ កុម្ភៈ ១៩៩៩ ) ។

- សាលាក្រុងភ្នំពេញ បានធ្វើការណែនាំ ដល់ម្ចាស់អាជីវកម្ម សណ្ឋាគារ ផ្ទះសំណាក់ ផ្ទះម៉ាស្សា ខារ៉ាអូខេ រង្គសាលឌីស្កូតែក ទូទាំងរាជធានី សូមឱ្យចូលរួមបំពេញភារកិច្ចសង្គម ដោយមិនឱ្យភ្ញៀវអាយុក្រោម ១៨ឆ្នាំចូលក្នុងហាងរបស់ខ្លួន លើកលែងតែមានការអនុញ្ញាតិពីមាតាបិតា និង អាណាព្យាបាល ។ ក្នុងលក្ខណៈមិនគោរពតាមសាលាក្រុងនឹងមានវិធានការផ្អាក អាជីវកម្មរយៈពេល ១ខែ ( សេចក្តីជូនដំណឹង លេខ ៦០ សជណស ចុះថ្ងៃទី ០៩ មិថុនា ១៩៩៩) ។

- ក្រសួងទេសចរណ៍ បានសហការជាមួយអង្គការទស្សនៈពិភពលោក អង្គការ ECPAT កម្ពុជារៀបចំសិក្ខាសាលាជូន ដល់ម្ចាស់សណ្ឋាគារ ម្ចាស់ភ្នាក់ងារទេសចរណ៍ ឱ្យយល់ដឹងអំពីសិទ្ធិកុមារ និង បញ្ហាពេស្យាចារ កុមារតាមវិស័យទេសចរណ៍ ហើយរកវិធីសាស្ត្រដើម្បីទប់ស្កាត់ ។

- ដើម្បីសំរេចបាននូវគោលដៅប្រឆាំងពេស្យាចារកុមារក្នុង វិស័យទេសចរណ៍ក្រសួងទេសចរណ៍សហការជាមួយអង្គការទស្សនៈពិភពលោក ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ រៀបចំយុទ្ធសាស្ត្រជាតិប្រឆាំងនឹងពេស្យាចារកុមារក្នុងវិស័យទេសចរណ៍។ សេចក្តីព្រាងកម្មវិធី និងយុទ្ធសាស្ត្រ កំពុងត្រូវកសាងឡើងដោយមានការជួយជ្រោមជ្រែងពីអង្គការ ECPAT អូស្ត្រាលី ។

- **ការបង្ក្រាបការជួញដូរភេទប្រទំពួលើកុមារ** :

- កន្លងមកក្រសួងមហាផ្ទៃមានវិធានការឱ្យកងកំលាំងសកម្មចុះអនុវត្តវិធានការជាក់ស្តែងក្នុងមូលដ្ឋាន ដើម្បីធ្វើការស៊ើបអង្កេត ផ្ទះបន កន្លែងម៉ាស្សា ខារ៉ាអូខេ ក្លឹបកំសាន្ត សណ្ឋាគារ ភោជនីយដ្ឋាន ដោយធ្វើការតាមដានមុខសញ្ញាដែលសង្ស័យពីបទជួយដូរមនុស្ស។ ទន្ទឹមនេះដែរ ក្រសួងបានណែនាំបណ្តាកំលាំងនគរបាលច្រកទ្វារទូទាំងប្រទេសឱ្យយកចិត្តទុកដាក់ត្រួតពិនិត្យតាមច្រកទ្វារ ធានារកឱ្យឃើញការជួញដូរមនុស្សទៅក្រៅប្រទេសដូចជា ច្រកទ្វារតំបន់ខាងកើត ( បាវិត ) តំបន់ពាយ័ព្យ ( ប៉ោយប៉ែត ) តំបន់នារតី ( ស្រែ អំបិល និង បាក់ខ្លង) ។ល។

- ចាប់ពីឆ្នាំ ១៩៩៦ ដល់ ១៩៩៨ សមត្ថកិច្ចប៉ូលីសបានបង្ក្រាបបទល្មើសបានចំនួន ៧២លើក ចាប់ជនល្មើសបានចំនួន ៥៧នាក់ បញ្ជូនទៅតុលាការ ។ ចំនួនស្រីលក់ខ្លួនដែលបានរំដោះចេញពីផ្ទះបន មាន៦៩៣នាក់ ជនជាតិខ្មែរចំនួន ៤៤២នាក់ និងវៀតណាម ចំនួន២៥១នាក់ ក្នុងនោះកុមារមានចំនួន ១៣៥នាក់ ហើយ ១០០នាក់ ជាជនជាតិខ្មែរ ចាប់ជនល្មើសបានចំនួន ៤៦នាក់ បញ្ជូនទៅតុលាការ។ ថ្មីៗនេះមានការឃុំខ្លួនជនបរទេស ២រូប ដែលបានបំពារបំពានលើកុមារនៅក្នុងខេត្តសៀមរាប ។

## ៣- <u>យន្តការ សំរាប់កិច្ចសហការ និងការសម្របសម្រួល</u> :

- អនុគណៈកម្មការនៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារមួយ នឹងត្រូវបង្កើតឡើងនៅចុងឆមាសទី២ ឆ្នាំ២០០០ ដើម្បីធ្វើការងារត្រួតពិនិត្យតាមដាន និងជំរុញការអនុវត្តផែនការជាតិ។ អនុគណៈកម្មការនេះនឹងដឹកនាំដោយអនុប្រធាន ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារដែលជារដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ ហើយមានសមាជិកជាមន្ត្រីជាន់ខ្ពស់មកពីក្រសួងជំនាញមួយចំនួន ។
- ក្រសួងមហាផ្ទៃកំពុងរៀបចំបង្កើតការិយាល័យ២ គឺការិយាល័យបង្ក្រាបសកមមភាពចាប់ពង្រត់ជួញដូរភេទ ដែលមានតួនាទីធ្វើការងារបង្ក្រាបការចាប់ពង្រាត់ជួញដូរមនុស្ស រួមទាំងការងារជួញដូរផ្លូវភេទលើកុមារ និងការិយាល័យការពារអនីតិជន ដែលមានតួនាទីការពារកុមារពីការរំលោភបំពានផ្សេងៗ ។

- អាជ្ញាធរក្រុងព្រះសីហនុបានបង្កើតគណៈកម្មាការការពារសិទ្ធិកុមារ ដែលមានសមាសភាពជាតំណាងមន្ទីរពាក់ព័ន្ធក្នុងក្រុង (សេចក្តីសំរេចរបស់ក្រុងឆ្នាំ១៩៩៩)។ អាជ្ញាធរខេត្តបាត់ដំបង និង បន្ទាយមានជ័យបានបង្កើតគណៈកម្មការអន្តរផ្នែកដើម្បីការពារសិទ្ធិកុមារ។ គណៈកម្មការនេះ ដឹកនាំដោយអភិបាលខេត្តរងប្រធានមន្ទីរសង្គមកិច្ចខេត្តជាអនុប្រធានអចិន្ត្រៃយ៍ ហើយមានសមាជិកជាប្រធានមន្ទីរជំនាញផ្សេងៗទៀត និងអង្គការក្រៅរដ្ឋាភិបាល ។ គណៈកម្មការចែកចេញជាក្រុម ការងារធ្វើការតាមផ្នែកនីមួយៗ ។ កន្លងមកការជួយសង្គ្រោះនារីពីផ្ទះបនធ្វើឡើង

ដោយកិច្ចសហការរវាងប៉ូលីស ក្រសួង ពាក់ព័ន្ធ និង អង្គការក្រៅរដ្ឋាភិបាល ។

- ក្រសួងកិច្ចការនារី និង អតីតយុទ្ធជន ត្រូវបានចាត់តាំងដោយរាជរដ្ឋាភិបាលកម្ពុជា ដើម្បីដឹកនាំការចូលរួមរបស់ប្រទេសកម្ពុជា ក្នុងកិច្ចផ្តួចផ្តើមប្រយុទ្ធប្រឆាំងនឹងការចាប់ពង្រត់ និង ជួញដូរភេទលើស្ត្រី និង កុមារក្នុងតំបន់ដោយមានការឧបត្ថម្ភពីអង្គការសហប្រជាជាតិ។ គំរោងដែលបានព្រាងឡើងមានឈ្មោះថាការប្រឆាំងរាល់រូបភាពជួញដូរស្ត្រី និងកុមារនៅកម្ពុជា គឺធ្វើការងារពង្រីកធនធានមនុស្ស និងសមត្ថភាពកម្មវិធីរបស់ក្រសួងកិច្ចការនារី និង អតីតយុទ្ធជន ដោយធ្វើឱ្យប្រសើរឡើងនូវចំនេះដឹងខាងច្បាប់ បញ្ហាសេដ្ឋកិច្ចសង្គម ដែលទាក់ទងនឹងការជួញដូរ អ្នកដែលទទួលការបណ្តុះបណ្តាលមានមន្ត្រី រាជរដ្ឋាភិបាល និងអាជ្ញាធររដ្ឋាភិបាលគ្រប់កំរិត។
- ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា សហការជាមួយអង្គការ អាសប៉េកា អាហ្វីស៊ីប គ្រួសារថ្មី យុវជនបំពេញបេសកកម្ម មិត្តសំឡាញ់ អង្គការទស្សនៈពិភពលោក អង្គការសុខសប្បាយ មជ្ឈមណ្ឌលសង្រ្គោះស្ត្រីមានវិបត្តិកម្ពុជា មជ្ឈមណ្ឌលការពារសិទ្ធិកុមារកម្ពុជា មជ្ឈមណ្ឌលសង្គ្រោះបន្ទាន់សំរាប់ស្ត្រីវ័យក្មេង ជួយរំដោះការពារ និងបណ្តុះបណ្តាលជំនាញ និងអប់រំផ្លូវចិត្តដល់កុមាររងគ្រោះ ។

ក្រសួងសង្គមកិច្ចក៏បានបង្កើតផងដែរនូវមជ្ឈមណ្ឌលស្ត្រីវ័យក្មេងមានវិបត្តិ ដែលមានទីតាំងនៅភ្នំពេញ ។

- មានពេលខ្លះក្រសួងកិច្ចការនារី និង អតីតយុទ្ធជនបានសហការជាមួយក្រសួងមហាផ្ទៃ ជួយរំដោះនារីរងគ្រោះពីផ្ទះបន ព្រមទាំងបញ្ជូននារីទាំងនោះទៅមជ្ឈមណ្ឌលនីតិសម្បទារបស់អង្គការក្រៅរដ្ឋាភិបាល ។
- បណ្តាញការងាររបស់អន្តរអង្គការមួយ បានត្រូវបង្កើតឡើងដោយអង្គការក្រៅរដ្ឋាភិបាលមានឈ្មោះថា ក្រុមការងារប្រឆាំងការជួញដូរកេងប្រវ័ញ្ចផ្លូវភេទ (WACSE)។ បណ្តាញនេះមានតួនាទីធ្វើការទាក់ទាញមតិគាំទ្រ និងធ្វើឱ្យមានការយល់ដឹងដល់រដ្ឋអំណាចមូលដ្ឋាន និងនគរបាល។ ក្រុមការងារនេះ ធ្វើការប្តូរយោបល់ និងបទពិសោធន៍ ព្រមទាំងសម្របសម្រួលសកម្មភាពនានា ។
- បណ្តាញការងារអន្តរអង្គការមួយទៀត មានឈ្មោះថាគណៈកម្មការធ្វើសកម្មភាព ប្រឆាំងនឹងការកេងប្រវ័ញ្ចលើកុមារ (ACCE) ធ្វើការងារសហការជាមួយនគរបាល ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ទាំងនៅក្នុងថ្នាក់កណ្តាល នៅថ្នាក់ខេត្ត ជួយរំដោះនារីរងគ្រោះ តាមពិនិត្យស្ថានភាពគ្រួសារជនរងគ្រោះផ្តល់សេវាចិត្តសាស្ត្រនៅក្នុងមជ្ឈមណ្ឌល សង្គ្រោះ ធ្វើសមាហរណកម្មជនរងគ្រោះ ។

## II~ ពាក់ព័ន្ធនៅនឹងកិច្ចសហការទ្វេភាគី :

ប្រទេសកម្ពុជាពុំទាន់មានកិច្ចព្រមព្រៀងទ្វេភាគី ឬ ពហុភាគីស្តីពី បញ្ហាពេស្យាចារកុមារ និងការជួញដូរកុមារនៅឡើយទេ។ ប៉ុន្តែយោងតាមកំណត់ហេតុនៃកិច្ចប្រជុំលើកទីពាររបស់គណៈកម្មការចំរុះសហប្រតិបត្តិការទ្វេភាគីរវាងព្រះរាជាណាចក្រកម្ពុជា និងព្រះរាជាណាចក្រថៃ ពីថ្ងៃទី ៣១ មករា ដល់ ១ កុម្ភៈ ឆ្នាំ២០០០ ដែលមានចែងអំពីបត្យាប័ន និងការបង្រ្កាបការរត់ពន្ធគ្រឿងញៀន និង ការជួយដូរខុសច្បាប់។ នេះជាចំណុចចាប់ផ្តើមនៃការឈានទៅរកកិច្ចសហប្រតិបត្តិការផ្នែកតុលាការ។

ទោះយ៉ាងនេះក្តី អង្គការអន្តរជាតិទេសន្តរប្រវេសន៍ (**IOM**) បានសហការជាមួយរដ្ឋាភិបាល យូនីសេហ្វ និងអង្គការក្រៅរដ្ឋាភិបាល ធ្វើកម្មវិធីសមាហរណកម្មស្ត្រី និងកុមាររងគ្រោះដោយការជួញដូរនៅក្នុងតំបន់ (កម្ពុជា ថៃ វៀតណាម) តាំងពីឆ្នាំ ១៩៩៦ ដែលបានជួយស្ត្រី និង កុមារចំនួន៦០០នាក់ ក្នុងដំណាក់កាលដំបូង និង ក្នុងឆ្នាំ១៩៩៩ ១៤៦នាក់ ត្រលប់ពីប្រទេសថៃ ហើយកុមារីវៀតណាម ៦រូប បានបញ្ជូនទៅវៀតណាមវិញ ។

ក្នុងឆ្នាំ១៩៩៩ ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា និង IOM បានបង្កើតមជ្ឈមណ្ឌលសហប្រតិបត្តិការ និងចងក្រងឯកសារ ដើម្បីការងារមាតុភូមិនិវត្តន៍ និងសមាហរណកម្ម។ ក្រសួងបានសហការជាមួយអង្គការក្រៅរដ្ឋាភិបាល ក្រសួងសង្គមកិច្ចថៃ កម្មវិធីសមាហរណកម្មរយៈពេល៣ឆ្នាំ ។

## III. ការអនុវត្តផែនការជាតិ៥ឆ្នាំ :

ផែនការជាតិដូចបានពោលខាងលើ ត្រូវបានអនុម័តដោយគណៈរដ្ឋមន្ត្រីនាពេលថ្មីៗនេះ។ សកម្មភាពមួយចំនួនត្រូវបានអនុវត្តន៍មុនពេលបញ្ចូលទៅក្នុងផែនការនេះ ហើយសកម្មភាពថ្មីផ្សេងទៀតត្រូវបានបញ្ចូលនៅក្នុងផែនការនេះផងដែរ។ ក្រោយពីវិធានការ និង យន្តការសំរបសំរួល ដូចពោលរួចមកហើយ នៅមានសកម្មភាពមួយចំនួនទៀតដែលមានជាអាទិ៍ :

### ១. សេវាសង្គម :

- បច្ចុប្បន្នមានមជ្ឈមណ្ឌលមួយកន្លែងនៅភ្នំពេញ ដែលគ្រប់គ្រងដោយរដ្ឋាភិបាល និងទទួលថវិកាពីអង្គការយូនីសេហ្វ។ មានមជ្ឈមណ្ឌលមួយចំនួនរបស់អង្គការក្រៅរដ្ឋាភិបាល ដែលទទួលថវិកាពីខាងក្រៅប្រទេសនៅ ក្នុងក្រុងភ្នំពេញ និង តាមខេត្ត។
- ក្រសួងសុខាភិបាលសហការជាមួយអង្គការជំនាញមួយចំនួន បានផ្តល់ការអប់រំ នឹង បានថែទាំសុខភាព ដល់នារីដែលរកស៊ីផ្លូវភេទ ក្នុងតំបន់ជាច្រើននៅក្នុងទីក្រុង និងខេត្តមួយចំនួន ។
- ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន មានកម្មវិធីអក្ខរកម្ម បណ្តុះបណ្តាលវិជ្ជាជីវៈចំពោះនារីក្រីក្រឱ្យមានជំនាញប្រកបរបររកស៊ីនៅក្នុងខេត្តចំនួន៨ (កើនដល់១៩ខេត្ត) ដោយសហការជាមួយអង្គការក្រៅរដ្ឋាភិបាល។ ព្រមទាំងថ្មីៗ នេះមានកម្មវិធីការទប់ស្កាត់រាល់ទំរង់នៃអំពើជួញដូរស្ត្រី និងកុមារនៅកម្ពុជាឆ្នាំ ២០០០- ២០០៣ ។

### ២. ការធ្វើឱ្យយល់ដឹង និង ការទាក់ទាញមតិគាំទ្រ :

- អនុសញ្ញាស្តីពីសិទ្ធិកុមារ និងបញ្ហាកុមារ បានត្រូវផ្សព្វផ្សាយឱ្យយល់ដឹងដល់មន្ត្រីរាជការ និងសាធារណជនតាមរយៈសិក្ខាសាលាជាច្រើនលើក និងតាមប្រព័ន្ធផ្សព្វផ្សាយពតិមានចំរុះ ដែលរៀបចំដោយក្រុមប្រឹក្សាជាតិដើម្បីកុមារ និងក្រសួងពាក់ព័ន្ធ អង្គការក្រៅរដ្ឋាភិបាល និងអង្គការអន្តរជាតិ ។
- ក្រសួងអប់រំ យុវជន និងកីឡា បានបញ្ចូលសិទ្ធិកុមារ ការរំលោភផ្លូវភេទ ពលកម្មកុមារ ទៅក្នុងកម្មវិធីសិក្សាក្នុងកម្មវិធីសិក្សាក្នុង និងក្រៅប្រព័ន្ធ ។
- តាមរយៈកម្មវិធីសកម្មភាពសហគមន៍ ដើម្បីអភិវឌ្ឍសង្គម ដែលផ្តួចផ្តើមឡើងដោយអង្គការយូនីសេហ្វប្រជាជននៅតាមភូមិនៃខេត្តមួយចំនួនបានយល់ដឹងអំពីសិទ្ធិកុមារ គ្រោះថ្នាក់ដែលទាក់ទងទៅនឹងកុមារដែលត្រូវគេចាប់ពង្រត់ និងពេស្យាចារកុមារ ។
- ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន បានបញ្ចូលបញ្ហាពេស្យាចារកុមារនេះទៅក្នុងកម្មវិធីពន្យាកំណើត អក្ខរកម្មប្រឆាំងនឹងអំពើ ហឹង្សាក្នុងគ្រួសារ ក្នុងគោលបំណងឱ្យសហគមន៍យល់ដឹងអំពីរឿងនេះ។

### ៣. ការពង្រីកសមត្ថភាពស្ថាប័ន និងមន្ត្រី :

ទាក់ទងទៅនឹងបញ្ហាចាប់ពង្រាត់កុមារ និង ពេស្យាចារកុមារ សកម្មភាពកសាងសមត្ថភាពផ្សេងៗ បានធ្វើឡើងចំពោះមន្ត្រីតាមក្រសួងនានា ក៏ដូចជាអង្គការក្រៅរដ្ឋាភិបាល ។

- ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា បានធ្វើការបណ្តុះបណ្តាលមន្ត្រីរបស់ខ្លួនតាមរយៈសិក្ខាសាលាបណ្តុះបណ្តាលក្នុង និងក្រៅប្រព័ន្ធទស្សនៈកិច្ចសិក្សា ការចូលរួមប្រជុំតាមមូលដ្ឋានតំបន់ និងអន្តរជាតិ ការរៀបចំការសិក្សាស្រាវជ្រាវ និងការធ្វើអង្កេតការចូលរួមប្រជុំ និង ពិភាក្សាជាមួយអន្តរអង្គការ ការបញ្ជូនមនុស្សទៅធ្វើការតាមអង្គការ។ ដោយមានជំនួយ និងការគាំទ្រពីអង្គការយូនីសេហ្វ ក្រសួងបានបណ្តុះបណ្តាល មន្ត្រីថ្នាក់ខេត្ត និង ស្រុកអំពីការត្រួតពិនិត្យតាមដាន និង សមាហរណកម្ម កុមាររងគ្រោះដោយការជួញដូរ និង កេងប្រវ័ញ្ចផ្លូវភេទ ។

- ដោយមានជំនួយពីប្រទេសអូស្ត្រាលី ក្រសួងមហាផ្ទៃ បានបើកវគ្គបណ្តុះបណ្តាលជាច្រើនដល់មន្ត្រីប៉ូលីស។ ហើយនៅពេលជាមួយគ្នានោះ ក្រសួងបានសហការជាមួយអង្គការ IOM ទស្សនៈពិភពលោក យូនីសេហ្វ សង្គ្រោះកុមារន័រវេស្សន៍ និង UNCOHCRC រៀបចំកម្មវិធី២ ឆ្នាំដើម្បីបង្កើនសមត្ថភាពនគរបាល ចៅក្រមស៊ើបអង្កេត និងព្រះរាជអាជ្ញាដើម្បីស៊ើបអង្កេត ករណីកេងប្រវ័ញ្ចផ្លូវភេទលើកុមា រួមទាំងការជួយសង្គ្រោះជនរងគ្រោះ ការអភិវឌ្ឍន៍ប្រព័ន្ធបញ្ជូនកុមារ ចាប់ជនល្មើស និងការផ្តួចផ្តើមឱ្យមានទូវនីតិវិធីតុលាការ។ កម្មវិធីនេះបានធ្វើពិធីប្រកាសនៅខែមិនា ឆ្នាំ២000 ។

- ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន សហការជាមួយ IOM ធ្វើកម្មវិធីអភិវឌ្ឍធនធានមនុស្ស និងពង្រីកសមត្ថភាពរៀបចំកម្មវិធីទប់ស្កាត់អំពើជួញដូរ ដោយធ្វើឱ្យមន្ត្រីយល់ដឹងអំពីច្បាប់ ការផ្សព្វផ្សាយពតិមាន និងគោលនយោបាយ ។

ការជួញដូរកេងប្រវ័ញ្ចផ្លូវ ភេទលើកុមារជាបញ្ហាលំបាកស្មុគ្រស្មាញ ដែលជំពាក់ជំពិនយ៉ាងធ្ងន់ធ្ងរជាមួយនឹងបញ្ហាសេដ្ឋកិច្ច ការអប់រំ វប្បធម៌ និងបញ្ហាជាច្រើនទៀត។ ការប្រយុទ្ធប្រឆាំងនឹងបញ្ហានេះទាមទារនូវពេលវេលាវែងឆ្ងាយមួយ និងអនុវត្តនូវវិធានការទាំងឡាយទៅតាមដំណាក់ការផ្សេងៗខុសៗ គ្នា ។

ដើម្បីឱ្យការអនុវត្តផែនការទទួលបានជោគជ័យ ទាមទារឱ្យមានកិច្ចគាំទ្រ ទំនុកបំរុងពីសហគមន៍អន្តរជាតិ ទាំងផ្នែកបច្ចេកទេស ក៏ដូចជាថវិកាយ៉ាងពេញទំហឹងផងដែរ ។

ឧត្តមស្នងការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស

សេចក្តីសង្កេតចុងក្រោយរបស់គណៈកម្មាធិការស្តីពីសិទ្ធិកុមារ

Cambodia.02/06/2000.CRC/C/15/Add.128

( សេចក្តីសង្កេតចុងក្រោយ.អនុសាសន៍ )

CRC/C/15/Add.128
ថ្ងៃទី២ ខែមិថុនា ឆ្នាំ២០០០

# គណៈកម្មាធិការស្តីពីសិទ្ធិកុមារ
# សម័យប្រជុំលើកទី២៤
# ការពិចារណាលើរបាយការណ៍ដាក់ជូនដោយរដ្ឋភាគី
# ផ្អែកតាមមាត្រា៤៤ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ

សេចក្តីសង្កេតចុងក្រោយ

របស់គណៈកម្មាធិការស្តីពីសិទ្ធិកុមារ : ប្រទេសកម្ពុជា

**១-** គណៈកម្មាធិការស្តីពីសិទ្ធិកុមារ បានពិចារណាលើរបាយការណ៍ដំបូងរបស់ប្រទេសកម្ពុជា (CRC/C/11/Add.16) ដែលដាក់ជូនកាលពីថ្ងៃទី១៨ ខែធ្នូ ឆ្នាំ១៩៩៧ នៅក្នុងសម័យប្រជុំលើកទី៦២៩ និងទី៦៣០របស់ខ្លួន (សូមមើលឯកសារលេខ CRC/C/SR.៦២៩-៦៣០) ដែលប្រព្រឹត្តិទៅនៅថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០០ ហើយនាសម័យប្រជុំលើកទី៦៤១ ដែលប្រព្រឹត្តិទៅនៅថ្ងៃទី២ ខែមិថុនា ឆ្នាំ២០០០ គណៈកម្មាធិការបានអនុម័តនូវសេចក្តីសង្កេតចុងក្រោយរបស់ខ្លួនដូចតទៅ :

## ក- <u>សេចក្តីផ្តើម</u>

**២-** គណៈកម្មាធិការសូមស្វាគមន៍រដ្ឋភាគីកម្ពុជា ដែលបានបញ្ជូនរបាយការណ៍ដំបូង ដោយអនុវត្តទៅតាមគោលការណ៍ណែនាំអំពីការធ្វើរបាយការណ៍ និងដែលបានបញ្ជូនរបាយការណ៍លាយលក្ខណ៍អក្សរឆ្លើយតបនឹងបញ្ជីសំណួរ ( ជជ្រ.ជ.ឈ ។ជា ។១ ) ។ គណៈកម្មាធិការ បានទទួលការលើកទឹកចិត្តតាមរយៈការសន្ទនាប្រកបដោយន័យស្ថាបនាដែលបានធ្វើជាមួយគណៈប្រតិភូរដ្ឋភាគីកម្ពុជា និងសូមស្វាគមន៍ចំពោះការឆ្លើយតបទៅនឹងការស្នើ និងអនុសាសន៍នានាដែលបានលើកឡើងក្នុងពេលពិភាក្សា។ គណៈកម្មាធិការក៏សូមស្វាគមន៍ផងដែរ ចំពោះវត្តមានរបស់គណៈប្រតិភូជាន់ខ្ពស់ ដែលមានការចូលរួមពាក់ព័ន្ធផ្ទាល់ក្នុងការអនុវត្តអនុសញ្ញាស្តីពី សិទ្ធិកុមារដែលញ៉ាំងឱ្យគណៈកម្មាធិការវាយតម្លៃបានពេញលេញលើស្ថានភាពសិទ្ធិកុមារក្នុងប្រទេសជាភាគី ។

## ខ- <u>ទិដ្ឋភាពវិជ្ជមាន</u>

**៣-** គណៈកម្មាធិការសូមស្វាគមន៍ប្រទេសកម្ពុជា ដែលជារដ្ឋភាគីមួយនៃឧបករណ៍អន្តរជាតិសំខាន់ៗចំនួន៦ ដែលផ្តល់នូវកិច្ចការពារសិទ្ធិមនុស្ស ហើយក៏ស្វាគមន៍ផងដែរចំពោះការផ្តល់សច្ចាប័ន (១៩៩៩) លើអនុសញ្ញាស្តីពីការហាមប្រាមការប្រើប្រាស់ការរក្សាទុក ការផលិត និងការផ្ទេរគ្រាប់មីនប្រឆាំងមនុស្ស និងការបំផ្លាញគ្រាប់មីនដែលរដ្ឋភាគីបានធ្វើ ។

៤- គណៈកម្មាធិការសូមស្វាគមន៍រដ្ឋភាគី ដែលបានបញ្ចូលវិធានទាក់ទងនឹងការការពារសិទ្ធិនានាដែលមានចែងនៅក្នុងអនុសញ្ញាស្តីពី សិទ្ធិកុមារ ទៅក្នុងរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ របស់ខ្លួន ( មាត្រា៤៨) ។

៥- គណៈកម្មាធិការសូមស្វាគមន៍ផងដែរ ចំពោះអនុស្សារណៈនៃការយោគយល់គ្នា រវាងរាជរដ្ឋាភិបាលកម្ពុជា និងការិយាល័យនៃឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស (១៩៩៦) ដែលបង្កើតឱ្យមានកម្មវិធីជំនួយបច្ចេកទេស និងសេវាទីប្រឹក្សាអំពីសិទ្ធិមនុស្សរួមទាំងសិទ្ធិកុមារ ។

៦- គណៈកម្មាធិការសូមស្វាគមន៍ចំពោះវិធានការណ៍នានាដែលរដ្ឋភាគីប្រកាន់យក សំដៅប្រយុទ្ធប្រឆាំងនឹងបញ្ហាពលកម្មកុមារដូចជាការផ្តល់សច្ចាប័ននៅឆ្នាំ១៩៩៩ លើអនុសញ្ញា ILO លេខ១៣៨ ស្តីពីអាយុអប្បបរមាសំរាប់ការអនុញ្ញាតិឱ្យធ្វើការងារ និងការចុះហត្ថលេខាលើអនុស្សារណៈនៃការយោគយល់គ្នារវាងរាជរដ្ឋាភិបាលកម្ពុជា និងកម្មវិធីអន្តរជាតិលុបបំបាត់ពលកម្មកុមារ (IPEC) របស់អង្គការពលកម្មអន្តរជាតិ(ILO) នាឆ្នាំ១៩៩៧ ។

៧- គណៈកម្មាធិការសូមស្វាគមន៍ ចំពោះការចូលរួមរបស់រាជរដ្ឋាភិបាល ក្នុងការរៀបចំរបាយការណ៍ដំបូងរបស់រដ្ឋភាគីក៏ដូចជាការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារ ។

## គ- កត្តា និងការលំបាកដែលរារាំងវឌ្ឍនភាពក្នុងការអនុវត្តអនុសញ្ញា

៨- គណៈកម្មាធិការធ្វើការកត់សំគាល់ដោយមានការព្រួយបារម្ភថា រដ្ឋភាគីប្រឈមមុខនឹងការលំបាកដ៏ច្រើនក្នុងការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារ ជាពិសេសលំបាកដោយសារកេរ្តិ៍ដំណែលជាងម្ភៃឆ្នាំនៃអំពើប្រល័យពូជសាសន៍ ជម្លោះប្រដាប់អាវុធ និងអស្ថេរភាពនយោបាយ ក៏ដូចជាភាពឯកោដែលរដ្ឋភាគីបានទទួលរងអស់រយៈពេលជាច្រើនឆ្នាំ។ គណៈកម្មាធិការកត់សំគាល់ផងដែរថា ស្ថានភាពសេដ្ឋកិច្ចសង្គមដ៏សែនលំបាករបស់រដ្ឋភាគី ធ្វើឱ្យមានផលប៉ះពាល់ដល់ក្រុមជនដែលងាយរងគ្រោះបំផុតក្នុងនោះមានទាំងកុមារផង និងរារាំងដល់ការទទួលសិទ្ធិរបស់ពួកគេ ។

## ឃ- បញ្ហាចំបងៗនៃការព្រួយបារម្ភ និងអនុសាសន៍

### ឃ-១ វិធានការណ៍អនុវត្តទូទៅ

អំពីច្បាប់ :

៩- ទោះជាដឹងថា ក្របខ័ណ្ឌច្បាប់នៃរដ្ឋភាគីគ្របដណ្តប់បទបញ្ញត្តិមួយចំនួននៃអនុសញ្ញា ហើយការប្រឹងប្រែងនានាក្នុងការធ្វើសេចក្តីព្រាងច្បាប់ថ្មីត្រូវបានធ្វើឡើងក៏ដោយ ក៏គណៈកម្មាធិការនៅមានការព្រួយបារម្ភដែរថា ច្បាប់ក្នុងស្រុកនៅតែស្ថិតនៅក្នុងស្ថានភាព ត្រូវពិនិត្យមើលឡើងវិញ ហើយច្បាប់ដែលអនុម័តថ្មីត្រូវតែគោរពទាំងស្រុងទៅតាមអនុសញ្ញាស្តីពីសិទ្ធិកុមារ ។ រីឯកង្វះខាតនៃការ អនុវត្តន៍ច្បាប់ដែលចូលជាធរមាន ហើយក៏ជាបញ្ហាមួយនៃការព្រួយបារម្ភផងដែរ ។

**១០- គណៈកម្មាធិការស្នើសូមឱ្យមានការពិនិត្យមើលឡើងវិញនូវច្បាប់ដែលចូលជាធរមាន ដោយធ្វើយ៉ាងណាឱ្យច្បាប់ទាំងនោះស្របទៅនឹងបទបញ្ញត្តិទាំងអស់នៃអនុសញ្ញា ជាពិសេសស្របទៅនឹងគោលការណ៍ទូទៅនៃអនុសញ្ញា( មាត្រា២-៣-៦និង១២) ។ ត្រូវមានការយកចិត្តទុកដាក់ជាពិសេសដល់ការចុះបញ្ជីជាតិ ត្រួសារការថែទាំចម្លាស់ និងយុត្តិធមិយុវវ័យ។ គណៈកម្មាធិការស្នើបន្ថែមទៀតឱ្យរដ្ឋភាគី បញ្ចូលបញ្ហាដែលបារម្ភនានាទាក់ទងនឹងសិទ្ធិកុមារទៅក្នុងដំណើរការធ្វើសេចក្តីព្រាងច្បាប់នាពេល បច្ចុប្បន្ន និងអនាគត ជាពិសេសសេចក្តីព្រាងក្រមរដ្ឋប្បវេណី សេចក្តីព្រាងក្រមព្រហ្មទ័ណ្ឌ និងសេចក្តីព្រាងក្រមនីតិវិធីព្រហ្មទ័ណ្ឌ។ អាស្រ័យហេតុនេះ គណៈកម្មាធិការសូមលើកទឹកចិត្តដល់រដ្ឋភាគីសូមឱ្យបន្តស្វែងរកជំនួយបច្ចេកទេសពីបណ្តាអង្គការនានាដូចជា**

**ការិយាល័យ នៃឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស និងអង្គការយូនីសេហ្វជាដើម ។**

<u>ការសម្របសម្រួល</u> :

**១១-** គណៈកម្មាធិការស្វាគមន៍ចំពោះការបង្កើត ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ( ក.ជ.ក.ក) ដែលទទួលបន្ទុកសម្របសម្រួលការអនុវត្តអនុសញ្ញា ក៏ប៉ុន្តែគណៈកម្មាធិការសូមសំដែងនូវការព្រួយបារម្ភ អំពីការផ្ដល់លទ្ធភាពនូវមានកម្រិតដល់ ក.ជ.ក.ក ក្នុងការបំពេញនូវអណត្តិរបស់ខ្លួនឱ្យបានពេញលេញ ។ ដោយឡែកមានការព្រួយបារម្ភអំពីការដែល ក.ជ.ក.ក ខ្វះខាតធនធានមនុស្ស និងធនធានហិរញ្ញវត្ថុក្នុងការបំពេញអណត្តិរបស់ខ្លួនឱ្យមានប្រសិទ្ធភាពនៅក្នុងទឹកដីនៃរដ្ឋជាភាគីទាំងមូល ។

**១២- គណៈកម្មាធិការស្នើសូមឱ្យរដ្ឋភាគីចាត់វិធានការណ៍មានប្រសិទ្ធភាព រួមទាំងវិធានការណ៍តាមរយៈ កិច្ចសហប្រតិបត្តិការអន្តរជាតិ ដើម្បីពង្រឹងតួនាទីរបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ (ក.ជ.ក.ក) សំដៅធ្វើឱ្យប្រាកដនូវការសម្របសម្រួលការអនុវត្តន៍អនុសញ្ញានៅថ្នាក់ជាតិ ថ្នាក់តំបន់ និងនៅតាមមូលដ្ឋាន។ ត្រូវមានការប្រឹងប្រែងច្រើនថែមទៀតសំដៅផ្ដល់ឱ្យ ក.ជ.ក.ក នូវធនធានមនុស្ស និងធនធានហិរញ្ញវត្ថុជាដុំកំភួន និងធានាឱ្យមានកិច្ចសហការ និងការសម្របសម្រួលកាន់តែជិតស្និទ្ធជាងមុនជាមួយនឹងអង្គការក្រៅរដ្ឋាភិបាលនានា ដែលធ្វើការក្នុងវិស័យសិទ្ធិកុមារ ។**

<u>ការត្រួតពិនិត្យតាមដាន</u> :

**១៣-** គណៈកម្មាធិការសូមសំដែងនូវការព្រួយបារម្ភ អំពីសមត្ថភាពនូវមានកម្រិតរបស់រដ្ឋភាគីក្នុងការត្រួតពិនិត្យតាមដាន ការអនុវត្តន៍អនុសញ្ញា និងអំពីអវត្តមាននៃយន្តការឯករាជ្យមួយដើម្បីទទួល និងដោះស្រាយបណ្ដឹងរបស់កុមារដែលជាប់ទាក់ទិននឹងការរំលោភបំពានសិទ្ធិទាំងឡាយរបស់គេដែលមានចែងនៅក្នុងអនុសញ្ញា ។

**១៤- គណៈកម្មាធិការស្នើសូមឱ្យរដ្ឋភាគី គិតគូរដល់ការបង្កើតយន្តការឯករាជ្យមួយ (ឧទាហរណ៍អំបូតស្មែនសម្រាប់កិច្ចការកុមារ) ដើម្បីត្រួតពិនិត្យតាមដានការអនុវត្តអនុសញ្ញា និងធ្វើការងារទាក់ទងនឹងបណ្ដឹងរបស់កុមារដែលប្ដឹងពីករណីនៃការរំលោភបំពាន សិទ្ធិរបស់ពួកគេ តាមរបៀបមួយដែលជាមិត្តរបស់កុមារ និងដែលកុមារងាយស្រួលយល់ឆាប់រហ័ស ព្រមទាំងមានប្រសិទ្ធភាព និងដើម្បីផ្ដល់នូវឧបាស្រ័យ(ដំណោះស្រាយ)នានា ចំពោះការរំលោភបំពានទាំងនោះ។ គណៈកម្មាធិការស្នើបន្ថែមទៀត ឱ្យរដ្ឋភាគីធ្វើយុទ្ធនាការ លើកកំពស់ការយល់ដឹង សំដៅបង្កលក្ខណៈងាយស្រួលឱ្យកុមារប្រើប្រាស់ប្រកបដោយប្រសិទ្ធភាពនូវយន្តការបែបនោះ ។**

<u>ការប្រមូលទិន្នន័យ</u> :

**១៥-** គណៈកម្មាធិការស្វាគមន៍ចំពោះវិធានការណ៍ដែលរដ្ឋភាគីប្រកាន់យក ក្នុងវិស័យប្រមូលទិន្នន័យដូចជា ប្រព័ន្ធពតិមានគ្រប់គ្រង អប់រំ(EMIS) និងប្រព័ន្ធពតិមានសុខាភិបាល ។ ទោះជាបែបនេះក្ដី ក៏នៅមានការបារម្ភអំពីការខ្វះខាតយន្តការប្រមូលទិន្នន័យមួយ ដែលប្រកបទៅដោយបរិមាណនិងគុណភាពមានលក្ខណៈជាខ្សែសង្វាក់ទូលំទូលាយ និងត្រូវបានចាត់ជាក្រុមជាក់លាក់សំរាប់វិស័យទាំង ឡាយដែលអនុសញ្ញាត្រូវអនុវត្តលើក្នុងនោះរួមមាន ការរំលោភបំពាន ឬ ការប្រព្រឹត្តឃោរឃៅលើកុមារកុមារជាក្រុមជនជាតិភាគ តិច កុមារី កុមារនៅជនបទ និង កុមារជាជនរងគ្រោះដោយការលក់ ការជួញដូរ និងអំពើរពេស្យាចារ ។

**១៦- គណៈកម្មាធិការស្នើសូមឱ្យរដ្ឋភាគីបន្តអភិវឌ្ឍ និងពង្រឹងប្រព័ន្ធប្រមូលទិន្នន័យរបស់ខ្លួនដើម្បីបញ្ចូលវិស័យទាំងអស់ ដែលគ្របដណ្ដប់ដោយអនុសញ្ញា។ ប្រព័ន្ធនោះត្រូវរាប់បញ្ចូលកុមារទាំងអស់ដែលមានអាយុក្រោម១៨ឆ្នាំ និងសង្កត់ធ្ងន់ ជាពិសេសទៅលើកុមារជាក្រុមជនរងគ្រោះ ដោយយកធ្វើជាមូលដ្ឋាននៃការប៉ាន់ប្រមាណវឌ្ឍនភាពដែលទទួលបាននៅក្នុងការធ្វើឱ្យសិទ្ធកុមារក្លាយជាការពិត និងដើម្បីជួយរៀបចំគោលនយោបាយសំដៅធ្វើឱ្យមានការអនុវត្តកាន់តែប្រសើរឡើងនូវបទបញ្ញត្តិនៃ**

**អនុសញ្ញា។ អាស្រ័យហេតុនេះ គណៈកម្មាធិការសូមលើកទឹកចិត្តដល់រដ្ឋភាគីសូមឱ្យស្វែងរកជំនួយពីអង្គការអន្តរជាតិ ជាពិសេស អង្គការយូនីសេហ្វជាដើម ។**

ការបែងចែកថវិការសំរាប់ប្រើប្រាស់ (មាត្រា៤ នៃអនុសសញ្ញាស្តីពីសិទ្ធិកុមារ):

**១៧-** គណៈកម្មាធិការដឹងថា ហេដ្ឋារចនាសម្ព័ន្ធ និងសេវាសង្គមរបស់រដ្ឋភាគីត្រូវបំផ្លិចបំផ្លាញដោយសារផលវិបាកនៃសង្គ្រាម ជាច្រើនទសវត្សក៏ពិតមែនហើយ ក៏ប៉ុន្តែ គណៈកម្មាធិការសូមសំដែងនូវសេចក្តីព្រួយបារម្ភរបស់ខ្លួនចំពោះការយកចិត្តទុកដាក់ពុំបានគ្រប់គ្រាន់ លើបទបញ្ញត្តិនានានៃអនុសញ្ញាត្រង់មាត្រា ៤ ដែលចែងពីការលៃទុកបែងចែកឱ្យប្រើប្រាស់នូវ " ក៏រិតអតិបរិមានៃ (.....) ធនធានដែលខ្លួនមាន " ។

**១៨- គណៈកម្មាធិការស្នើសូមឱ្យរដ្ឋភាគីផ្តល់អាទិភាព និងធ្វើឱ្យប្រាកដថា ខ្លួនបែងចែកនូវក៏រិតអតិបរមានៃធនធាន ដែលខ្លួនមានសំរាប់វិស័យសុខាភិបាល អប់រំ និងសេវាសង្គមដើម្បីកុមារ ហើយជាពិសេសយកចិត្តទុកដាក់ដល់កិច្ចការពារកុមារ ដែលស្ថិតនៅក្នុងក្រុមជនងាយរងគ្រោះ និងក្រុមដែលគេពុំសូវទឹកនាដល់។ អាស្រ័យហេតុនេះ គណៈកម្មាធិការ សូមលើកទឹកចិត្តដល់រដ្ឋភាគី សូមឱ្យបន្តនិងជំរុញឱ្យមានសហប្រតិបត្តិការបើកទូលាយជាមួយសហគមន៍អន្តរជាតិ ជាពិសេសក្នុងក្របខ័ណ្ឌកិច្ចសម្របសម្រួល នៃក្រុមពិគ្រោះយោបល់នៃប្រទេសផ្តល់ជំនួយដល់កម្ពុជា។**

**ការផ្សព្វផ្សាយអនុសញ្ញាស្តីពីសិទ្ធិកុមារ**

**១៩-** ទោះជាដឹងថា មានការប្រកាន់យកនូវវិធានការដើម្បីបង្កើនការយល់ដឹងជាទូទៅពីគោលការណ៍ និងបទបញ្ញត្តិនៃអនុសញ្ញា ដូចជា ការបញ្ចូលប្រធានបទអនុសញ្ញា ទៅក្នុងកម្មវិធីសិក្សាតាមសាលារៀនក៏ដោយ ក៏គណៈកម្មាធិការយល់ឃើញថាចាំបាច់ត្រូវតែពង្រឹងវិធានការទាំងនេះ។

**២០- គណៈកម្មាធិការស្នើសូមឱ្យរដ្ឋភាគី ពង្រឹងការប្រឹងប្រែងរបស់ខ្លួន ក្នុងការផ្សព្វផ្សាយគោលការណ៍ និងបទបញ្ញត្តិនៃអនុសញ្ញាដែលជាវិធានការមួយសំដៅធ្វើឱ្យមានការយល់ដឹងអំពីសិទ្ធិកុមារដល់សង្គម។ ត្រូវផ្តល់សារៈសំខាន់ជាពិសេសដល់ការផ្សព្វផ្សាយអនុសញ្ញាក្នុងចំណោមក្រុមជនជាតិភាគតិច ទាំងនៅតាមតំបន់ជនបទ និងតំបន់ដាច់ស្រយាល។ គណៈកម្មាធិការ សូមលើកទឹកចិត្តដល់រដ្ឋភាគី សូមឱ្យគិតគូរដល់ការស្វែងរកជំនួយបច្ចេកទេសពីចំណោមអង្គការនានា ដូចជាអង្គការយូនីសេហ្វ និងការិយាល័យនៃឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សជាដើម។**

**ការហ្វឹកហ្វឺនអ្នកមានវិជ្ជាជីវៈ**

**២១-** គណៈកម្មាធិការស្វាគមន៍ចំពោះការប្រឹងប្រែងរបស់រដ្ឋភាគី ក្នុងការផ្តល់ការហ្វឹកហ្វឺនដល់អ្នកមានវិជ្ជាជីវៈដែលធ្វើការជាមួយកុមារ និងធ្វើការដើម្បីកុមារ ដោយសហការគ្នាជាមួយការិយាល័យនៃឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស និងអង្គការយូនីសេហ្វ។ ទោះយ៉ាងនេះក្តី គណៈកម្មាធិការយល់ឃើញថា ចាំបាច់ត្រូវតែអភិវឌ្ឍន៍ កម្មវិធីបច្ចុប្បន្ននេះបន្តទៀតដើម្បីឱ្យអ្នកមានវិជ្ជាជីវៈគ្រប់ក្រុមទទួលការហ្វឹកហ្វឺន។

**២២- គណៈកម្មាធិការសូមលើកទឹកចិត្តដល់រដ្ឋភាគី ឱ្យបន្តការអនុវត្តការអប់រំដែលមានលក្ខណៈជាប្រព័ន្ធ និងកម្មវិធីហ្វឹកហ្វឺនស្តីអំពីបទបញ្ញត្តិនានានៃអនុសញ្ញា ដល់អ្នកមានវិជ្ជាជីវៈគ្រប់គ្រាន់ដែលធ្វើការជាមួយកុមារ និងធ្វើការដើម្បីកុមារ ជាពិសេសសមាជិកសភា ចៅក្រម មេធាវី មន្ត្រីទទួលបន្ទុកអនុវត្តន៍ច្បាប់ មន្ត្រីរាជការស៊ីវិល អ្នកធ្វើនៅសាលាក្រុង បុគ្គលិកបំរើការនៅតាមស្ថានប័ន ឬមន្ទីរឃុំឃាំងកុមារនានា គ្រូបង្រៀន បុគ្គលិក សុខាភិបាល រួមទាំងអ្នកចិត្តវិទ្យា និងបុគ្គលិកសង្គមកិច្ច។**

**សំរាប់កិច្ចការនេះ គេអាចបន្តស្នើសុំជំនួយបច្ចេកទេស ពីចំណោមអង្គការនានាដូចជាការិយាល័យ នៃឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស និង អង្គការយូនីសេហ្វជាដើម។**

ឃ.២. និយមន័យកុមារ

**២៣-** គណៈកម្មាធិការមានការបារម្ភ អំពីការពុំមាននិយមន័យកុមារតាមផ្លូវច្បាប់ឱ្យបានច្បាស់លាស់ នៅក្នុងច្បាប់របស់រដ្ឋភាគី។ ដោយឡែកក៏មានការបារម្ភអំពីការពុំមានការកំណត់អាយុជាអប្បរមាតាមផ្លូវច្បាប់សំរាប់ការយល់ព្រមរួមភេទ និងអាយុជាអប្បរមាតាមផ្លូវច្បាប់សំរាប់ការទទួលខុសត្រូវព្រហ្មទណ្ឌផងដែរ។

**២៤- ដោយផ្អែកតាមគោលការណ៍ និងបទបញ្ញត្តិនៃអនុសញ្ញា គណៈកម្មាធិការស្នើសូមឱ្យរដ្ឋភាគី បញ្ចូលនិយមន័យកុមារទៅក្នុងច្បាប់របស់ខ្លួន។ គណៈកម្មាធិការស្នើបន្ថែមឱ្យរដ្ឋភាគីយកចិត្តទុកដាក់ គិតគូរដល់ការដាក់បញ្ចូលនូវបទញ្ញត្តិទាក់ទងនឹងអាយុជាអប្បរមាសំរាប់ការទទួលខុសត្រូវព្រហ្មទណ្ឌ និងអាយុជាអប្បរមាសំរាប់ការយល់ព្រមរួមភេទ ទៅក្នុងដំណើរការធ្វើសេចក្តីព្រាងច្បាប់ថ្មីរបស់ខ្លួន។ លើសពីនេះទៅទៀត គណៈកម្មាធិការស្នើរសូមឱ្យរដ្ឋភាគី ពង្រឹងការអនុវត្តច្បាប់ទាក់ទង នឹងអាយុជាអប្បរមារសំរាប់ការរៀបអាពាហ៍ពិពាហ៍។**

ឃ.៣.គោលការណ៍ទូទៅ

**២៥-** គណៈកម្មាធិការដឹងថា រដ្ឋភាគីបានប្រកាន់យកនូវវិធានការមួយចំនួន ដោយដាក់បញ្ចូលគោលការណ៍ទូទៅនៃអនុសញ្ញាទៅក្នុងច្បាប់ក្នុងស្រុករបស់ខ្លួន ក៏ប៉ុន្តែ នៅមានការបារម្ភចំពោះភាពពុំគ្រប់គ្រាន់នៃវិធានការទាំងនេះ។

**២៦- គណៈកម្មាធិការស្នើសូមឱ្យដាក់បញ្ចូលគោលការណ៍ទូទៅនៃអនុសញ្ញា [គឺសិទ្ធិដែលមិនអាចរើសអើងបាន (មាត្រា២) ផលប្រយោជន៍ដ៏ល្អបំផុតរបស់កុមារ (មាត្រា៣) សិទ្ធិមានជីវិត សិទ្ធិក្នុងការរស់រាន និង ការចំរើនលូតលាស់ (មាត្រា៦) និង សិទ្ធិកុមារក្នុងការទទួបាននូវការគោរពដល់ទស្សនៈរបស់ខ្លួន (មាត្រា១២)] ទៅក្នុងច្បាប់ទាំងអស់ ដែលមានការទាក់ទង និង មានផលប៉ះពាល់ដល់កុមារ និងត្រូវបានយកទៅពិចារណានៅក្នុងការធ្វើសេចក្តីសំរេចតាមផ្លូវរដ្ឋបាល និងតាមផ្លូវតុលាការក៏ដូចជា នៅក្នុងគោលនយោបាយ និងកម្មវិធី ទាំងអស់ដែលទាក់ទងនឹងកុមារ។ ត្រូវពង្រឹងការលើកកំពស់ការយល់ដឹង ក្នុងចំណោមសាធារណៈជនជាទូទៅរួមមានសហគមន៍ និងមេដឹកនាំសាសនា នានាហើយក៏ត្រូវពង្រឹងកម្មវិធីអប់រំស្តីពីការអនុវត្តគោលការណ៍ទាំងនេះ សំដៅកែប្រែការយល់ឃើញជាប្រពៃណីថា កុមារជាកម្មវត្ថុនៃសិទ្ធិ ហើយមិនមែនជាប្រធានបទនៃសិទ្ធិនោះទេ។**

ការមិនរើសអើង

**២៧-** យោងតាមមាត្រា២ នៃអនុសញ្ញា គណៈកម្មាធិការសូមសំដែងការបារម្ភអំពីលំនាំនានានៃការរើសអើងឈរលើមូលដ្ឋានភេទ ដើមកំណើតជាតិពន្ធ ស្ថានភាពមានមេរោគអេដស៍-ជម្ងឺអេដស៍ និងពិការភាព។ ការបារម្ភជាពិសេសនោះ គឺរដ្ឋធម្មនុញ្ញ (១៩៩៣) របស់រដ្ឋភាគី ដែលចែងតែអំពីសិទ្ធិរបស់ពលរដ្ឋខ្មែរ។

**២៨- គណៈកម្មាធិការស្នើសូមឱ្យរដ្ឋភាគីធ្វើឱ្យប្រាកដថា កុមារគ្រប់រូបទទួលបាននូវសិទ្ធិទាំងអស់ ដែលមានចែងនៅក្នុងអនុសញ្ញាដោយពុំមានការបែងចែក។ គណៈកម្មាធិការស្នើបន្ថែមទៀត ឱ្យរដ្ឋភាគីប្រកាន់យកនូវវិធានការដ៏មានប្រសិទ្ធភាពនានាដើម្បីបំបាត់ការរើសអើងប្រឆាំងនឹងកុមារ ជាពិសេសគឺ ការទទួលបាននូវការសិក្សាអប់រំ។ ចាំបាច់ត្រូវមានការប្រឹងប្រែងដើម្បីបំបាត់ការរើសអើងប្រឆាំងនឹងកុមាររស់នៅ និង/ឬ ធ្វើការតាមចិញ្ចើមថ្នល់ កុមារក្រុមជនជាតិភាគតិច ជាពិសេសកុមារដែលមានដើមកំណើតជនជាតិវៀតណាម។ បន្ថែមលើនេះទៀត គណៈកម្មាធិការសូមសំដែងការគាំទ្រដល់អនុសាសន៍របស់គណៈកម្មា**

**ធិការសិទ្ធិមនុស្ស ដែលបានដាក់ជូនរដ្ឋភាគីក្នុងឆ្នាំ១៩៩៩ (CCPR/C/79/Add.108,para.17) និងអនុសាសន៍របស់គណៈកម្មាធិការលុបបំបាត់ ការរើសអើងពូជសាសន៍ដែលបានដាក់ជូនរដ្ឋភាគីក្នុងឆ្នាំ១៩៩៨ (CERD/C/304/Add.54, para. 11-13 ) ។**

**ឃ.៤.** សិទ្ធិពលរដ្ឋ និង សេរីភាព

**ការចុះបញ្ជីជាតិ**

**២៩-** ទាក់ទងនឹងការអនុវត្តមាត្រា៧ នៃអនុសញ្ញា គណៈកម្មាធិការសូមសំដែងការបារម្ភអំពី ការចុះបញ្ជីជាតិដែលពុំមានលក្ខណៈជាកាតព្វកិច្ច ហើយជាផលវិបាក កុមារដែលកើតមកភ្លាម មិនមែនសុទ្ធតែត្រូវបានចុះបញ្ជីជាតិទាំងអស់គ្នានោះទេ ។

**៣០- គណៈកម្មាធិការស្នើសូមឱ្យរដ្ឋភាគី ពិនិត្យមើលច្បាប់ជាតិរបស់ខ្លួនឡើងវិញ ឱ្យស្របទៅតាមគោលការណ៍ និងបទបញ្ញត្តិនៃអនុសញ្ញា ដើម្បីធ្វើឱ្យការចុះបញ្ជីជាតិកុមារគ្រប់រូបក្លាយជាកាតព្វកិច្ច គ្មានការរើសអើងអ្វីទាំងអស់។ កុមារមានកំណើតពីជនជាតិដែលមិនមែនជាពលរដ្ឋខ្មែរ ដោយមិនគិតទៅដល់ស្ថានភាព តាមផ្លូវច្បាប់របស់ពួកគេ ឬមានកំណើតពីជនភៀសខ្លួនកាលបើបានកើតនៅក្នុងទឹកដីកម្ពុជា ត្រូវតែបានចុះបញ្ជីជាតិជាដរាប ទោះបីជាគេពុំមានសិទ្ធិទទួលសញ្ជាតិខ្មែរ ក៏ដោយ។ គណៈកម្មាធិការស្នើសូមជាបន្ថែមទៀត ឱ្យរដ្ឋភាគី ចាត់នូវវិធានការដ៏មានប្រសិទ្ធភាព ដើម្បីអនុវត្តន៍អនុក្រឹត្យដែល មានរួចមកហើយ (លេខ:៧៤) ស្តីពីសៀវភៅគ្រួសារ និងអនុក្រឹត្យ(លេខ:៧៣) ស្តីពីសៀវភៅស្នាក់នៅ ដែលបានបង្កើតក្នុងឆ្នាំ១៩៩៧ ជាពិសេសគឺធ្វើឱ្យប្រាកដថា កុមារទាំងអស់ដែលមិនបានចុះបញ្ជីជាតិនៅពេលចាប់កំណើតត្រូវបានចុះបញ្ជីជាតិ។ ក្រៅពីនេះគណៈកម្មាធិការស្នើសូមឱ្យរដ្ឋភាគិ បើកយុទ្ធនាការលើកកំពស់យល់ដឹង ដើម្បីធានាថាកុមារគ្រប់រូបត្រូវបានចុះបញ្ជីជាតិនៅពេលចាប់កំណើត។ ក្នុងន័យនេះ គណៈកម្មាធិការសូមលើកទឹកចិត្តដល់រដ្ឋភាគី ក្នុងការពិនិត្យដល់ការស្វែងរកកិច្ច សហប្រតិបត្តិការអន្តរជាតិ ក្នុងចំណោមអង្គការនានាដូចជា អង្គការយូនីសេហ្វ និង បណ្តាញអង្គការអន្តរជាតិផ្សេងៗទៀត។**

**សញ្ជាតិ**

**៣១-** គណៈកម្មាធិការសូមសំដែងការបារម្ភដែរថា ច្បាប់ស្តីពីសញ្ជាតិ (អនុម័តឆ្នាំ១៩៩៦) របស់រដ្ឋភាគីអាចនឹងនាំឱ្យមានការរើសអើងប្រឆាំងនឹងកុមារដែលមិនមែនជាជនជាតិខ្មែរពីកំណើត និង អាចផ្ទុយនឹងស្មារតី នៃអនុសញ្ញាត្រង់មាត្រា ៧ ដែលអាចបណ្តាលឱ្យកុមារជាច្រើន ដែលកើតនៅក្នុងប្រទេសកម្ពុជាដូចជា កុមារក្រុមជនជាតិភាគតិចជាដើមក្លាយទៅជាគ្មានសញ្ជាតិ។

**៣២- គណៈកម្មាធិការស្នើសូមឱ្យមានការពិនិត្យមើលឡើងវិញ នូវច្បាប់ស្តីពីសញ្ជាតិរបស់រដ្ឋភាគី ដោយធ្វើឱ្យអនុលោមទៅតាមអនុសញ្ញា ដើម្បីសំដៅលុបបំបាត់មូលដ្ឋានរើសអើងដែលអាចមាន និងដើម្បីបំបាត់ទាំងស្រុង និងបង្ការបញ្ហាកុមារគ្មានសញ្ជាតិ។**

សិទ្ធិចូលរួមរបស់កុមារ

**៣៣-** ទាក់ទងនឹងសិទ្ធិចូលរួមរបស់កុមារ គណៈកម្មាធិការសូមសំដែងការបារម្ភអំពីវិធានការពុំទាន់គ្រប់គ្រាន់ដែលរដ្ឋភាគីបានអនុវត្តន៍ ជាពិសេសគឺ ជំរុញការចូលរួមរបស់កុមារនៅក្នុងគ្រួសារ សហគមន៍ សាលារៀន និង នៅក្នុងស្ថាប័នសង្គមដទៃទៀត ក៏ដូចជាធ្វើឱ្យប្រាកដ នូវការទទួលបានប្រកបដោយប្រសិទ្ធភាព នូវសេរីភាពជាមូលដ្ឋានរបស់ពួកគេ ដែលក្នុងនោះរួមមានសេរីភាពក្នុងការមានមតិ សេរីភាពក្នុងការសំដែងមតិ និងសេរីភាពក្នុងការចូលរួមជាមួយសមាគម។

**៣៤- យោងតាមមាត្រា១២-១៧ នៃអនុសញ្ញា គណៈកម្មាធិការស្នើសូមឱ្យរដ្ឋភាគី ចាត់វិធានការនានាជាបន្ថែមទៀត ដែលក្នុងនោះរួមមានការកែទំរង់ច្បាប់ ដើម្បីជំរុញការចូលរួមរបស់កុមារនៅក្នុងគ្រួសារ សាលារៀន និងនៅក្នុងស្ថាប័នសង្គមដទៃទៀត**

**ព្រមទាំងការទទួលបានប្រកបដោយប្រសិទ្ធភាពនូវសេរីភាពជាមូលដ្ឋានរបស់ពួកគេ ដែលក្នុងនោះ រួមមានសេរីភាព ក្នុងការមានមតិ សេរីភាពក្នុងការសំដែងមតិ និងសេរីភាពក្នុងការចូលរួមជាមួយសមាគម។ ចាំបាច់ត្រូវបង្កើនការលើកកំពស់ការយល់ដឹងដល់សាធារណៈជន អំពីសិទ្ធិចូលរួមរបស់កុមារនៅតាមគ្រួសារ សហគមន៍ ស្ថាប័ន និង សាលារៀន។**

<u>សិទ្ធិទទួលបានព័ត៌មានសមស្រប</u>

**៣៥-** គណៈកម្មាធិការមានការបារម្ភអំពីការខ្វះខាតច្បាប់ ដែលសំដៅការពារកុមារពីព័ត៌មាន ដែលបណ្តាលឱ្យមានការអន្តរាយ និងសម្ភារៈដែលធ្វើឱ្យអន្តរាយដល់សុខុមាលភាព និងការអភិវឌ្ឍរបស់កុមារ ព្រមទាំងខ្វះខាតច្បាប់ដែលសំដៅផ្តល់ការធានា ការទទួលបានពតិមានសមស្រប។

**៣៦- យោងតាមមាត្រា១៧ នៃអនុសញ្ញា គណៈកម្មាធិការស្នើរសូមឱ្យរដ្ឋភាគី អនុម័តច្បាប់ពិសេស ដើម្បីការពារកុមារ ពីពតិមានដែលបណ្តាលឱ្យមានការអន្តរាយជាពិសេសពី កម្មវិធីទូរទស្សន៍ និងខ្សែភាពយន្តដែលបង្ហាញអំពីភាពសាហាវ ឃោរឃៅ និងអាសអាភាស និងដើម្បីធានាការទទួលបានព័ត៌សមស្រប។ គណៈកម្មាធិការស្នើបន្ថែមទៀតឱ្យរដ្ឋភាគីយកចិត្តទុកដាក់ពិចារណាចំពោះអនុសាសន៍របស់គណៈកម្មាធិការ ដែលបានពីទិវាពិភាក្សាជាទូទៅ (១៩៩៦) របស់ខ្លួនស្តីអំពី "កុមារ និងប្រព័ន្ធឃោសនា" (CRC/C/57) ។**

**ឃ.៥.** <u>បរិយាកាសគ្រួសារ និង ការថែរក្សាចំលាស់</u>

<u>កុមារដែលត្រូវបានឃ្លាតចេញពីមជ្ឈដ្ឋានគ្រួសារ</u>

**៣៧-** គណៈកម្មាធិការមានការបារម្ភអំពី ការរីករាលដាល នៃការយកកុមារទៅដាក់នៅក្នុងមជ្ឈមណ្ឌលសង្គ្រោះ ឬ ផ្ទះកុមារក្រៅពីថែរក្សាចំលាស់ប្រភេទផ្សេងៗដូចជាការថែរក្សាដោយគ្រួសារចិញ្ចឹម និងការសុំកុមារយកធ្វើជាកូនចិញ្ចឹម។ គណៈកម្មាធិការព្រួយបារម្ភផងដែរអំពីការខ្វះខាតនូវបទបញ្ញាសំរាប់ការប្រព្រឹត្តទៅរបស់មណ្ឌលទាំងនេះ និងអំពីការកើនឡើងនូវចំនួនកុមារកំព្រា ដោយសារការរាតត្បាតនៃមេរោគអេដស៍-ជម្ងឺអេដស៍ និង វិធានការដោះស្រាយស្ថានភាពនេះនៅមានកំរិត។

**៣៨- គណៈកម្មាធិការស្នើសូមឱ្យរដ្ឋភាគី ចាត់វិធានការដ៏មានប្រសិទ្ធភាពតាមរយៈ ការផ្តល់ការពិគ្រោះយោបល់ និងកម្មវិធីតាមសហគមន៍ សំដៅលើកដំកើងគ្រួសារដែលជាមជ្ឈដ្ឋានដ៏ល្អបំផុតសំរាប់កុមារ ដើម្បីពង្រឹងឱ្យឪពុកម្តាយបីបាច់ ថែរក្សាកុមារក្នុងគោលបំណងបញ្ចៀសការដាក់កុមារទៅក្នុងមជ្ឈមណ្ឌលសង្គ្រោះកុមារនានា។**

**៣៩- គណៈកម្មាធិការស្នើសូមឱ្យរដ្ឋភាគី អភិវឌ្ឍគោលនយោបាយ និង បទបញ្ញាទាក់ទងនឹងស្ថាប័ននានា ដែលគ្រប់គ្រងកុមារ និង រាល់ទំរង់បែបបទទាក់ទងនឹងការថែរក្សាចំលាស់។ ស្នើសូមឱ្យមានការពង្រឹង និងពង្រីងសេវាសង្គមឱ្យបានដល់កុមារជាច្រើន ជាពិសេសកុមារកំព្រាដោយសារការរាតត្បាតនៃមេរោគអេដស៍-ជម្ងឺអេដស៍ និងសូមឱ្យអភិវឌ្ឍទំរង់ផ្សេងៗនៃការថែរក្សាចំលាស់ ដូចជាការថែរក្សាដោយអណាព្យាបាលចិញ្ចឹមជាដើម។ គណៈកម្មាធិការស្នើបន្ថែមទៀតឱ្យ មានការបែងចែកធនធានមនុស្ស និងហិរញ្ញវត្ថុគ្រប់គ្រាន់សំរាប់គោលបំណងទាំងនេះ។ ទាក់ទងនឹងបញ្ហានេះគណៈកម្មាធិការ ស្នើផងដែរឱ្យរដ្ឋភាគីស្វះស្វែងរកជំនួយហិរញ្ញវត្ថុ និងបច្ចេកទេស។**

<u>សុំកូន</u>

**៤០-** គណៈកម្មាធិការបានដឹងអំពីការប្រឹងប្រែងរបស់រដ្ឋភាគី ក្នុងការធ្វើសេចក្តីព្រាងច្បាប់សុំកូនអន្តរប្រទេស ដោយសម្របទៅតាមស្មារតីនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ និងអនុសញ្ញាក្រុងឡាអេឆ្នាំ១៩៩៣ ស្តីពីការការពារកុមារ និងសហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេស។ ប៉ុន្តែគណៈកម្មាធិការនៅតែមានការបារម្ភថា ច្បាប់ជាធរមានស្តីពីសុំកូនក្នុងស្រុក ពុំទាន់ស្របនឹងស្មារតី

នៃអនុសញ្ញា ហើយជាញឹកញាប់មិនមានការគោរព ទៅតាមនីតិវិធីស្ដុំកូនជាធរមាន និងមានសេចក្ដីរាយការណ៍មកថានីតិវិធីទាំងនេះញាំញីទៅដោយការស៊ីសំណូក និង ការរំលោភបំពាន។ គណៈកម្មាធិការមានការបារម្ភផងដែរ អំពីការរីករាលដាលនៃស្ដុំកូនដែលប្រព្រឹត្តទៅក្រៅផ្លូវការ និងពុំស្របច្បាប់។

**៤១- គណៈកម្មាធិការសូមលើកទឹកចិត្តភាគី ឱ្យបន្តដំណើរការរៀបចំធ្វើច្បាប់ស្ដុំកូនអន្តរប្រទេស និងធ្វើកំនែទំរង់ច្បាប់ជាធរមាន ដែលទាក់ទងនឹងស្ដុំកូនក្នុងស្រុក។ ចំពោះបញ្ហានេះ គណៈកម្មាធិការចាប់អារម្មណ៍លើឆន្ទៈរបស់របស់រដ្ឋភាគី ដែលគិតគូទៅដល់ការចូលជាសមាជិកនៃអនុសញ្ញាក្រុងឡាអេឆ្នាំ១៩៩៣ ស្ដីពីការការពារកុមារ និងសហប្រតិបត្តិការទាក់ទងនឹងស្ដុំកូនអន្តរប្រទេស ហើយសូមលើកទឹកចិត្តដល់រដ្ឋភាគី ឱ្យធ្វើកិច្ចការនេះ។ លើសពីនេះទៅទៀត គណៈកម្មាធិការ ស្នើសូមឱ្យរដ្ឋភាគីពង្រឹងសម្ថភាពការិយាល័យស្ដុំកូនរបស់ខ្លួន។ រដ្ឋភាគីអាចស្វែងរកជំនួយអន្តរជាតិពីបណ្ដាអង្គការនានា អង្គការយូនីសេហ្វ។**

<u>ការរំលោភបំពាន និង អំពើឃោរឃៅលើកុមារ</u>

**៤២-** មានការបារម្ភពីកង្វះខាតការយល់ដឹង អំពីវិសាលភាព និងផលវិបាកដែលនាំឱ្យអន្តរាយដោយអំពើឃោរឃៅ និងអំពើរំលោភបំពានលើកុមារ ដែលក្នុងនោះមាន ការរំលោភបំពានតាមផ្លូវភេទទាំងក្នុងនិងក្រៅរង្វង់គ្រួសារ អំពីកង្វះខាតធនធានហិរញ្ញវត្ថុ និងធនធានមនុស្សដើម្បីបង្ការទប់ស្កាត់ និងប្រយុទ្ធប្រឆាំងនឹងការរំលោភបំពានលើកុមារ និងកង្វះខាតវិធានការថែរក្សា និងវិធានការស្ដារនីតិសម្បទារួមមាន ឧបករណ៍ ទីកន្លែង កម្មវិធី សកម្មភាព ដើម្បីជួយកុមាររងគ្រោះដោយការរំលោភ។

**៤៣- ផ្អែកតាមមាត្រានៃអនុសញ្ញាភ្ជាប់ពីមាត្រា១៩ ដល់៣៩ គណៈកម្មាធិការស្នើសូមឱ្យរដ្ឋភាគី ចាត់វិធានការណ៍ដ៏មានប្រសិទ្ធភាពរួមមាន ការបង្កើតកម្មវិធីដែលមានប្រធានបទចំរុះ ព្រមទាំងវិធានការណ៍ថែរក្សា និងវិធានការណ៍ស្ដារនីតិសម្បទាដើម្បីបង្កាទប់ស្កាត់ និងប្រយុទ្ធប្រឆាំងនឹងការរំលោភបំពានលើកុមារ និងអំពើឃោរឃៅលើកុមារ នៅក្នុងរង្វង់គ្រួសារនៅតាមសាលា តាមស្ថាប័ននានា និងនៅក្នុងសង្គមជាទូទៅ។ ក្នុងចំណោមកិច្ចការឯទៀតៗ គណៈកម្មាធិការស្នើសូមឱ្យមានការពង្រឹងការអនុវត្តច្បាប់ដែលទាក់ទងនឹងបទល្មើសព្រហ្មទ័ណ្ឌ ឱ្យមាននីតិវិធីដែលសមល្មមនឹងប្រើការបាន ហើយដែលកុមារងាយស្រួលយល់ និងពង្រឹងយន្តការដោះស្រាយ បណ្ដឹងស្ដីពីការរំលោភបំពានកុមារ ដើម្បីឱ្យកុមារទទួលបានយ៉ាងឆាប់រហ័សនូវភាពយុត្តិធម៌ ហើយចៀងវាងនូវនិទណ្ឌភាពរបស់ជនល្មើស។ គណៈកម្មាធិការសូមលើកទឹកចិត្តដល់រដ្ឋភាគីឱ្យពិចារណា ដល់ការស្វែងរកកិច្ចសហប្រតិបត្តិការអន្តរជាតិពីបណ្ដាអង្គការនានា អង្គការយូនីសេហ្វ និងអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិ ។**

ឃ.៦- <u>សុខភាពមូលដ្ឋាន និងសុខុមាលភាព</u>

<u>សិទ្ធិរស់រាន និងការអភិវឌ្ឍ</u>

**៤៤-** គណៈកម្មាធិការសូមស្វាគមន៍ ចំពោះគំនិតផ្ដួចផ្ដើមធ្វើកិច្ចសហប្រតិបត្តិការអន្តរជាតិលើ "ការពង្រឹងប្រព័ន្ធ សុខាភិបាល" របស់ក្រសួង សុខាភិបាល និងទីភ្នាក់ងារមួយចំនួននៃប្រព័ន្ធសហប្រជាជាតិ (WHO, UNICEF, UNDP និងUNFPA) ដែលសំដៅកសាងសមត្ថភាពរដ្ឋាភិបាលឡើង វិញនៅក្នុងវិស័យចាក់ ឬបន្តក់ថ្នាំបង្កា និងការលុបបំបាត់ ជម្ងឺស្វិតដៃជើង និងការអភិវឌ្ឍកម្មវិធីជាតិដើម្បីការធ្វើឱ្យមានភាពស៊ាំទប់ទល់នឹងជម្ងឺ។ ទោះជាយ៉ាងនេះក្ដី ក៏នៅមានការបារម្ភអំពីអត្រាមរណៈរបស់ទារក និងអត្រាមរណៈរបស់កុមារអាយុក្រោម៥ឆ្នាំនៅក្នុងប្រទេសរបស់ រដ្ឋភាគី ដែល ស្ថិតក្នុងចំណោមកម្រិតខ្ពស់បំផុតនៅក្នុងតំបន់ ។ កង្វះអាហារូបត្ថម្ភរបស់កុមារ ក៏ជាបញ្ហាដែលគួរឱ្យ បារម្ភផងដែរ ។

**៤៥-** គណៈកម្មាធិការស្នើសូមឱ្យរដ្ឋភាគី លើកយកបញ្ហាជម្ងឺ និងមរណភាពរបស់កុមារមកដោះស្រាយ ដោយយកចិត្តទុកដាក់វិធីសាស្ត្រចំរុះផ្នែក ដែលគិតគូរដល់បញ្ហាអនក្ខរកម្មធ្ងន់ធ្ងរ ការផ្គត់ផ្គង់ទឹកពុំសមស្រប និងអសន្តិសុខស្បៀង ដែលជាមូលហេតុ

នៃជម្ងឺកុមារ។ ត្រូវតែរកឱ្យឃើញនូវតំបន់ជាអាទិភាព ដោយផ្អែកទៅលើទិន្នន័យមូលដ្ឋានដែលប្រមូលបានតាមការស្រាវជ្រាវដ៏ប្រុងប្រយ័ត្ន និងទូលំទូលាយ។ យុទ្ធសាស្ត្រនេះ ត្រូវតែគិតគូរទៅដល់បញ្ហាដែលថាមានការត្រួតពិនិត្យគ្រប់គ្រាន់ទៅលើផ្នែកដែលមិនមែនជារបស់រដ្ឋ។ ហើយក៏ត្រូវតែគិតគូរផង ដែរទៅដល់សេចក្តីត្រូវការ ជាពិសេសរបស់សហគមន៍ដែលនៅដាច់ឆ្ងាយពីគេឯង។ ជាបន្ថែមទៀតនេះ គណៈកម្មាធិការស្នើសូមឱ្យ មានវិធានការណ៍ត្រឹមត្រូវសម្រាប់បង្កើតឱ្យមានផ្នែកថែទាំសុខភាពបឋមមួយដ៏មានប្រសិទ្ធភាព ហើយវិធានការណ៍នេះ រួមបញ្ចូលទាំងយុទ្ធសាស្ត្រលើកទឹកចិត្ត ដល់ការស្វែងរកការថែទាំជម្ងឺកុមារ ។ ក្នុងគោលដៅនេះ គណៈកម្មាធិការសូមលើកទឹកចិត្តដល់រដ្ឋភាគី ឱ្យបន្តធ្វើការងារដោយសហការជាមួយទីភ្នាក់ងារអន្តរជាតិនានា។

<u>កុមារទទួលរងផលប៉ះពាល់ ឬឆ្លងមេរោគ HIV/AIDS</u>

**៤៦-** ទោះដឹងថា រដ្ឋភាគីបានចាត់វិធានការណ៍នានាដើម្បីបង្កា និងថែរក្សាអ្នកឆ្លងមេរោគ HIV/AIDS ក៏គណៈកម្មាធិការនៅមានការបារម្ភយ៉ាងខ្លាំង ដោយនៅក្នុងរដ្ឋភាគីមានការឆ្លងមេរោគ HIV/AID កើនឡើងយ៉ាងឆាប់រហ័សបំផុតក្នុងតំបន់ហើយកុមារស្ថិតក្នុងចំណោមក្រុមដែលងាយទទួលរង ផលប៉ះពាល់ជាងគេ ជាពិសេសតាមរយៈការឆ្លងពីម្តាយទៅកូន ។

**៤៧-** គណៈកម្មាធិការស្នើសូមឱ្យរដ្ឋភាគី បន្តចាត់វិធានការណ៍ដ៏មានប្រសិទ្ធភាព ដើម្បីបង្កាមេរោគ HIV/AIDS រួមមានការលើកកំពស់ការយល់ដឹង និងយុទ្ធនាការអប់រំជាដើម។ គណៈកម្មាធិការស្នើសុំជាបន្ថែមទៀត ឱ្យរដ្ឋភាគីយកចិត្តទុកដាក់ផងដែរទៅលើអនុសាសន៍របស់គណៈកម្មាធិការ ដែលបានអនុម័តកាលពីទិវាពិភាក្សាទូទៅរបស់ខ្លួនស្តីអំពី "កុមាររស់នៅក្នុងពិភពលោកមួយដែលមានមេរោគ HIV/AIDS " (CRC/C/80) ។ សូមឱ្យរដ្ឋភាគីបន្តស្នើសុំជំនួយអន្តរជាតិលើផ្នែកបច្ចេកទេសពីបណ្តាអង្គការនានាដូចជា UNICEF, WHO និង UNAIDS ។

<u>កុមារពិការ</u>

**៤៨-** គណៈកម្មាធិការសូមសំដែងនូវការបារម្ភយ៉ាងជ្រាលជ្រៅដែរថា ដោយសារតែផលវិបាកដ៏យូរអង្វែងនៃជម្លោះប្រដាប់អាវុធរដ្ឋភាគីស្ថិតក្នុង ចំណោមប្រទេសក្នុងពិភពលោកដែលមានអត្រាពិការភាពខ្ពស់បំផុត។ ទាក់ទងនឹងបញ្ហានេះ គណៈកម្មាធិការកត់សំគាល់ថា សេវាដ៏ច្រើនបំផុត សម្រាប់កុមារពិការត្រូវបានផ្តល់ដោយអង្គការក្រៅរដ្ឋាភិបាល (NGOs) ដែលត្រូវការចាំបាច់នូវធនធានថវិកាដើម្បីទ្រទ្រង់សេវាថែទាំ និងស្តារកាយ សម្បទាដែលមានកម្រិតខ្ពស់ នាពេលបច្ចុប្បន្ននេះ ។

**៤៩-** យោងតាមវិធានបទដ្ឋានស្តីអំពីការធ្វើឱ្យជនពិការមានសមភាពនូវឱកាស ( សេចក្តីសម្រេចចិត្តលេខ : ៤៨/៩៦ របស់មហាសន្និបាត) និងអនុសាសន៍របស់គណៈកម្មាធិការ ដែលបានអនុម័តកាលពីទិវាពិភាក្សាទូទៅរបស់ខ្លួនស្តីអំពីកុមារពិការ (CRC/C/69) គណៈកម្មាធិការស្នើសូមឱ្យរដ្ឋភាគី ធ្វើការដោយសហការជិតស្និទ្ធ និងគាំទ្រដល់សកម្មភាពដែលអនុវត្តដោយអង្គការក្រៅរដ្ឋាភិបាលធ្វើការក្នុងវិស័យនេះ ដើម្បីអភិវឌ្ឍកម្មវិធីបង្កា ពិការភាពឱ្យបានមុន ដោយកំណត់បាននូវមូលហេតុដែលធ្វើឱ្យពិការ។ ស្នើសូមឱ្យអនុវត្តវិធានការណ៍ផ្សេងៗ ជំនួសការយកកុមារពិការទៅដាក់ក្នុងមជ្ឈមណ្ឌល ធ្វើយុទ្ធនាការលើកកំពស់ការយល់ដឹងដើម្បីកាត់បន្ថយភាពរើសអើងជនពិការ។ បង្កើតកម្មវិធីអប់រំពិសេស និងមជ្ឈមណ្ឌល និងលើកទឹកចិត្ត ការបញ្ចូលកុមារពិការទៅក្នុងប្រព័ន្ធអប់រំ និងក្នុងសង្គម។ រៀបចំឱ្យមានការត្រួតពិនិត្យតាមដានគ្រប់គ្រាន់លើមជ្ឈមណ្ឌល ឯកជនសម្រាប់កុមារពិការ ។ គណៈកម្មាធិការស្នើទៀតឱ្យរដ្ឋភាគី ស្វែងរកកិច្ចសហប្រតិបត្តិការលើផ្នែកបច្ចេកទេសដើម្បីបណ្តុះបណ្តាលបុគ្គលិកមានវិជ្ជាជីវៈធ្វើការជាមួយ និងធ្វើការដើម្បីកុមារពិការ ។

<u>សិទ្ធិក្នុងការទទួលការថែទាំសុខភាព និងសេវាសុខាភិបាល</u>

**៥០-** មានការបារម្ភពីបញ្ហាដែលថា ការទទួលបាននូវសេវាសុខភាពរបស់កុមារនៅមានកម្រិត ជាពិសេសមានការខ្វះខាតបុគ្គលិកពេទ្យ និងបុគ្គលិកសុខាភិបាលសាធារណៈ ក៏ដូចជាមណ្ឌលសុខភាពបឋម ជាពិសេសគឺនៅតំបន់ជនបទ។ សូមសំដែងផងដែរនូវការបារម្ភអំពីតម្លៃដ៏ខ្ពស់ដែលត្រូវ ចំណាយលើការថែទាំសុខភាព និងឱសថ ជាហេតុបណ្តាលឱ្យគ្រួសារជាច្រើនជំពាក់បំណុលគេ និងកាន់តែមានភាពក្រីក្រទៅ ។

**៥១-** គណៈកម្មាធិការស្នើសុំឱ្យមានការកែលំអ និងពង្រីកការទទួលសេវាថែទាំសុខភាព និងឱសថ ដើម្បីធានាឱ្យកុមារនៃគ្រួសារអ្នកក្រីក្រ និង កុមារនៃក្រុមដែលពុំសូវបានគេអើពើទទួលបានសេវាទាំងនេះ ។

<u>សុខភាពមនុស្សវ័យជំទង់</u>

**៥២-** គណៈកម្មាធិការសូមសំដែងនូវការបារម្ភពីអត្រាដ៏ខ្ពស់នៃមរណភាពរបស់មាតា អំពីការដែលមនុស្សវ័យជំទង់ពុំបានទទួលឱ្យបានគ្រប់គ្រាន់នូវការអប់រំពីសុខភាពផ្លូវភេទ និងការបន្តពូជ និងសេវាផ្តល់យោបល់ទាំងក្នុង និងក្រៅប្រព័ន្ធសាលា និងអំពីការប្រើប្រាស់មធ្យោបាយពន្យាកំណើតនៅមានកម្រិតទាប។ គណៈកម្មាធិការក៏មានការបារម្ភផងដែរ ពីការមិនយកចិត្តទុកដាក់គ្រប់គ្រាន់លើបញ្ហាសុខភាពផ្លូវចិត្តរបស់មនុស្សវ័យជំទង់ ។

**៥៣-** គណៈកម្មាធិការស្នើសូមឱ្យរដ្ឋភាគី ធ្វើការសិក្សាក្រោមប្រធានបទចំរុះដ៏ទូលំទូលាយមួយ ដើម្បីស្វែងយល់ពីវិសាលភាពនៃបញ្ហាសុខភាពរបស់មនុស្សវ័យជំទង់ ក្នុងនោះរួមទាំងសុខភាពផ្លូវចិត្តផង ដើម្បីនឹងយកធ្វើជាមូលដ្ឋានមួយសម្រាប់លើកកំពស់គោលនយោបាយសុខភាពមនុស្សវ័យជំទង់ និងពង្រឹងការអប់រំសុខភាពបន្តពូជ។ គណៈកម្មាធិការស្នើសូមផងដែរ ឱ្យមានការខិតខំបន្ថែមទៀត ដើម្បីអភិវឌ្ឍសេវាផ្តល់ការពិគ្រោះយោបល់ ដែលកុមារងាយស្រួលយល់ព្រមទាំងការថែរក្សា និងគ្រឿងសម្រួលការធ្វើឱ្យមានសតិសម្បទាមនុស្សវ័យជំទង់ឡើងវិញ ។

ឃ.៧- <u>ការអប់រំ ការលំហែ និងសកម្មភាពវប្បធម៌</u>

**៥៤-** ទទួមនឹងការស្វាគមន៍ដល់ការប្រឹងប្រែងនាបច្ចុប្បន្នរបស់រដ្ឋភាគី ក្នុងការធ្វើឱ្យប្រព័ន្ធអប់រំរបស់ខ្លួនប្រសើរឡើងដោយសហការជាមួយទីភ្នាក់ងារអន្តរជាតិនានា។ គណៈកម្មាធិការនៅមានការបារម្ភ ចំពោះការអប់រំនៅបឋមសិក្សាដែលពុំមានលក្ខណៈជាកាតព្វកិច្ច។ បើទោះជាផលធៀបនៃការចុះឈ្មោះចូលរៀនមានកម្រិតខ្ពស់គួរសម ពុំមានភាពប្រាកដថាមានការទទួលបានស្មើៗគ្នានូវការអប់រំប្រកបដោយគុណភាព ដោយសារការខ្វះ ខាតសាលារៀននៅតាមតំបន់ជនបទ និងតំបន់ដាច់ស្រយាល។ មានការបារម្ភពីភាពខុសគ្នារវាងភេទទាំង២ ក្នុងការចូលរៀននៅសាលា។ មានការបារម្ភពីអត្រាដ៏ខ្ពស់នៃការត្រួតថ្នាក់ និងការបោះបង់ការសិក្សា និងពីបញ្ហាដែលថាមួយភាគធំនៃកុមារក្រុមជនជាតិភាគតិចពុំបានទទួលការសិក្សាអប់រំតាមទម្រង់ណាមួយនោះទេ។

**៥៥-** គណៈកម្មាធិការស្នើសូមឱ្យរដ្ឋភាគី បន្តចាត់វិធានការណ៍ដ៏មានប្រសិទ្ធភាព ដើម្បីធ្វើឱ្យបឋមសិក្សាប្រព្រឹត្តទៅដោយឥតបង់ថ្លៃ និងមានលក្ខណៈជាកាតព្វកិច្ចចំពោះកុមារគ្រប់រូប។ បង្កើនអត្រាចុះឈ្មោះចូលរៀន និងកាត់បន្ថយអត្រាបោះបង់ ការសិក្សា និងការត្រួតថ្នាក់។ បង្កើនឱកាសចូលសាលារៀន ជាពិសេសចំពោះកុមារក្រីក្រ កុមារី កុមារ ក្រុមជនជាតិភាគតិច និងកុមាររស់នៅតាមតំបន់ដាច់ស្រយាល។ គណៈកម្មាធិការ ស្នើបន្ថែមទៀតឱ្យរដ្ឋភាគី បន្តចាត់វិធានការណ៍ធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធអប់រំរបស់ខ្លួនដោយការបង្កើនថវិកាដោយឡែកសម្រាប់ផ្នែកសិក្សាអប់រំ ផ្តល់ការបណ្តុះបណ្តាលលើកកំពស់ជំនាញគ្រូបង្រៀនធ្វើឱ្យកម្មវិធីសិក្សាកាន់តែមានទំនាក់ទំនងនឹងសេចក្តីត្រូវការរបស់កុមារ ពង្រីកឱកាសទទួលបាននូវការបណ្តុះបណ្តាលវិជ្ជាជីវៈ និងអប់រំក្រៅប្រព័ន្ធដែលរួមមាន កម្រិតមត្តេយ្យសិក្សា និងមធ្យមសិក្សា និងបង្កើតប្រព័ន្ធវាយតម្លៃមួយដើម្បីវាស់ស្ទង់ប្រសិទ្ធភាពប្រព័ន្ធអប់រំ ។

## ឃ-៨ វិធានការការពារពិសេស

### កុមារជាជនភៀសខ្លួន

**៥៦-** គណៈកម្មាធិការសូមសំដែងនូវការបារម្ភពីការខ្វះខាតក្របខ័ណ្ឌច្បាប់ដើម្បីការពារកុមារដែលនៅតែម្នាក់ឯង កុមារស្វែងរកសិទ្ធិជ្រកកោន និង កុមារជាជនភៀសខ្លួន។

**៥៧**-គណៈកម្មាធិការស្នើសុំឱ្យរដ្ឋភាគី ចាត់វិធានការចាំបាច់ដើម្បីរៀបចំបង្កើតឱ្យមានច្បាប់ ដើម្បីការពារសិទ្ធិកុមារជាជនភៀសខ្លួន ដោយធ្វើឱ្យស្របទៅតាមស្មារតីនៃបទដ្ឋានអន្តរជាតិដែពាក់ព័ន្ធ និងអភិវឌ្ឍនីតិវិធីធ្វើឱ្យមានការជួបជុំគ្រួសារមួយដើម្បីជួយកុមារជាជនភៀសខ្លួនដែលអាចត្រូវបំបែកចេញពីគ្រួសាររបស់។ ទាក់ទងនឹងកិច្ចការនេះរដ្ឋអាចស្វែងរកជំនួយបច្ចេកទេសពីស្នងការជាន់ខ្ពស់នៃអង្គការសហប្រជាជាតិទទួលបន្ទុកជនភាសខ្លួន ។

### កុមាររងគ្រោះដោយជំលោះប្រដាប់អាវុធ

**៥៨-** ទោះជាគណៈកម្មាធិការស្វាគមន៏ដល់ការអនុម័តច្បាប់ដែហាមឃាត់មិនឱ្យជ្រើសយកកុមារ អាយុក្រោម១៨ឆ្នាំចូលបំរើកងទ័ព និងស្វាគមន៏ឆន្ទៈរបស់រដ្ឋភាគីក្នុងការរំសាយពីជួរកងទ័ព នូវទាហានក្រោមអាយុកំណត់ដែកនៅសេសសល់ ក៏គណៈកម្មាធិការសំដែងនូវការបារម្ភពីការពុំមានវិធានការគ្រប់គ្រាន់ ដើម្បីធ្វើឱ្យប្រាកដឡើងនូវការធ្វើសមាហរណកម្មទៅក្នុងសង្គម និងការស្តារលទ្ធភាពផ្នែករាងកាយនៃអតីតកុមារយោធា។ គណៈកម្មាធិការសំដែងនូវការបារម្ភផងដែរពីចំនួនគ្រាប់មីនដ៏ច្រើនដែលត្រូវបានកប់នៅក្នុងទឹកដីនៃរដ្ឋភាគី នៅកំឡុងពេលមានជំលោះប្រដាប់អាវុធកន្លងមក ដែលបង្ហាញឱ្យឃើញពីការគំរាមគំហែងដល់អាយុជីវិតកុមារ ។

**៥៩-** គណៈកម្មាធិការស្នើសូមឱ្យរដ្ឋភាគី ចាត់វិធានការដ៏មានប្រសិទ្ធភាព ដើម្បីធ្វើឱ្យប្រាកដពីការរកឱ្យឃើញនូវ អត្តសញ្ញាណការរំសាយទ័ព និងការស្តារលទ្ធិភាពផ្នែកចិតសាស្រ្ត និងការធ្វើសមាហរណកម្មកុមារយោធាទៅក្នុងសង្គម និងដើម្បីធ្វើយុទ្ធនាការលើកកំពស់កាយល់ដឹងដល់មន្រ្តី យោធា ក្នុងគោលបំណងបង្ការកុំឱ្យមានការជ្រើសយកកុមារឱ្យចូលបំរើកងទ័ពតទៅទៀត ។ គណៈកម្មាធិការស្នើបន្ថែមទៀត ឱ្យរដ្ឋភាគីបន្តការស្តានីតិសម្បទា និងសមាហរណកម្មយោធាដែលមាន អាយុក្រោមការកំណត់ដោយសហការជាមួយអង្គការយូនីសេហ្វ ។

**៦០-** ទាក់ទងនិងបញ្ហាគ្រាប់មីន គណៈកម្មាធិការស្នើសូមឱ្យរដ្ឋភាគី បង្កើនថវិកាសំរាប់ការដោះមីនក្នុងតំបន់ដែលជំលោះប្រដាប់អាវុធត្រូវបានបញ្ចប់ និងសូមឱ្យធ្វើយុទ្ធនាការលើកកំពស់ការយល់ ដើម្បីបង្ការគ្រោះថ្នាក់ដែលកើតឡើងដោយសារគ្រាប់មីន។ ក្រៅពីនេះ គណៈកម្មាធិការស្នើសូមឱ្យរដ្ឋភាគី បន្តធ្វើការលប់បំបាត់គ្រាប់មីន ដោយសហការជាមួយទីភ្នាក់ងារអន្តរជាតិនានា។

### ការកេងប្រវ័ញ្ចផ្នែកសេដ្ឋកិច្ច

**៦១-** គណៈកម្មាធិការសូមសំដែងនូវការបារម្ភ អំពីបញ្ហាដែលមានកុមារជាច្រើនពាក់ព័ន្ធនឹងសកម្មភាពពលកម្មជារួមមាន ផ្នែកក្រៅផ្លូវការ ផ្នែកកសិកម្ម និងបរិបទគ្រួសារ។ គណៈកម្មាធិការក៏បារម្ភផងដែរ ពីការពង្រឹងពុំទាន់គ្រប់គ្រាន់នូវការអនុវត្តច្បាប់ការងារជាធរមាន។

**៦២-** គណៈកម្មាធិការស្នើសុំឱ្យរដ្ឋភាគី ពង្រឹងកាអនុវត្តបទបញ្ញត្តិច្បាប់ការងារដែលទាក់ទងនឹងអាយុអប្បរមាដើម្បីចូលធ្វើការឱ្យមានការបណ្តុះបណ្តាល និងផ្តល់មធ្យោបាយដល់អធិការការងារដើម្បីត្រួតពិនិត្យពលកម្មកុមារ និងមានការដាក់ទណ្ឌកម្មដល់ជនរំលោភបំពានច្បាប់។ គណៈកម្មាធិការស្នើបន្ថែមទៀត ឱ្យរដ្ឋភាគីចាត់វិធានការដ៏មានប្រសិទ្ធភាពដើម្បីអនុម័តច្បាប់ក្នុងស្រុកសំដៅការពារកុមារពីទំរង់គ្រោះថ្នាក់នានានៃការងារ។ គណៈកម្មាធិការសូមកោតសសើរដល់រដ្ឋភាគីដែលគិតគូទៅលើ

ការឱ្យសច្ចាប័នអនុសញ្ញា ILO ថ្មី លេខៈ១៨២ ពាក់ព័ន្ធទៅនឹងការហាមប្រាម និងការលុបបំបាត់ជាបន្ទាន់នូវទំរង់ធ្ងន់ធ្ងរនៃពលកម្មកុមារ(១៩៩៩) និង សូមលើកទឹកចិត្តដល់ការផ្តល់សច្ចាប័ន ។

ការកេងប្រវ័ញ្ច និង ការជួញដូរផ្លូវភេទ

**៦៣-** ទោះជាគណៈកម្មាធិការរដ្ឋភាគី ដែលបានអនុវត្តច្បាប់ពិសេសដើម្បីប្រយុទ្ធប្រឆាំនិងការកេងប្រវ័ញ្ចផ្លូវភេទ និងផែនការជាតិ៥ឆ្នាំប្រឆាំងការជួញដូរ និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ(២០០០-២០០៤) និងវិធានការផ្សេងៗទៀតដែលទាក់ទងនឹងវិស័យនេះក៏ពិតមែន ក៏ប៉ុន្តែ គណៈកម្មាធិការក៏សូមសំដែងការព្រួយបារម្ភពីការរីករាលដាលនៃបាតុភាពបេស្យាចារកុមារការលក់ និងការជួញដូរកុមារ ការពុំអនុវត្តច្បាប់ថ្មីទាក់ទិននឹងបញ្ហានេះឱ្យបានពេញលេញ និងកង្វះខាតអ្នកដែលបានទទួលការហ្វឹកហ្វឺន និងស្ថាប័នសំរាប់ការស្តារសម្បទាជនរងគ្រោះដោយការកេងប្រវ័ញ្ចបែបនោះ ។

**៦៤-**គណៈកម្មាធិការស្នើសូមឱ្យរដ្ឋភាគី ពិនិត្យមើលច្បាប់របស់ខ្លួនឡើងវិញដើម្បីពង្រឹងច្បាប់នោះ ហើយទន្ទឹមនោះជំរុញឱ្យអនុវត្តបានពេញលេញច្បាប់បច្ចុប្បន្នដែលប្រឆាំងការកេងប្រវ័ញ្ចផ្លូវភេទ ឱ្យអនុវត្តយ៉ាងពេញលេញនូវផែនការជាតិ៥ឆ្នាំ ស្នើសូមឱ្យមានការលៃទុកនូវធនធានហិរញ្ញវត្ថុ និងធនធានមនុស្សឱ្យបានគ្រប់គ្រាន់សំរាប់អនុវត្តផែនការជាតិ៥ឆ្នាំស្នើសូមឱ្យពង្រឹងពង្រីកសេវាសង្គមសំរាប់ស្តារសម្បទាកុមាររងគ្រោះពីការកេងប្រវ័ញ្ចផ្លូវភេទ ឱ្យមានការចោទប្រកាន់ជនល្មើសច្បាប់ និងឱ្យមានការពង្រឹងកិច្ចសហប្រតិបត្តិការទ្វេរភាគី ជាពិសេសជាមួយប្រទេសជិតខាង និងបង្កើននូវការត្រួតពិនិត្យតាមព្រំដែន។ គណៈកម្មាធិការស្នើសុំឱ្យរដ្ឋភាគីសែងរកជាបន្តទៅទៀតនូវជំនួយបច្ចេកទេសពីបណ្តាអង្គការនានា ដែលក្នុងនោះមានដូចជាការិយាល័យ នៃឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស និងអង្គការយូនិសេហ្វជាដើម ។

ការគ្រប់គ្រងកិច្ចការយុត្តិធម៌យុវវ័យ

_**៦៥-** ចំពោះស្ថានភាពកុមារប្រព្រឹត្តល្មើសច្បាប់ គណៈកម្មាធិការសូមសំដែងនូវការបារម្ភ អំពីការពុំមានច្បាប់ គោលនយោបាយ និង កម្មវិធិដោយឡែកសំរាប់វិស័យនេះ។ ការបារម្ភពីសេចក្តីរាយការណ៍នានា ស្តីពីការឃុំខ្លួនកុមារក្នុងពន្ធនាគារជាមួយមនុស្សពេញវ័យ ស្ថានភាកុមារដែលត្រូវពន្យាការឃុំខ្លួន ដោយពុំមានការចោទប្រកាន់តាមផ្លូវតុលាការ និងពុំទទួលបាននូវមេធាវី ឬ ដោយពុំបានបញ្ជូលទៅតុលា និងការបារម្ភពីសេចក្តីរាយការណ៍ដែលចោទប្រកាន់ពីករណីកុមារត្រូវទទួលរងការវាយដំ និងអំពើឃោរឃៅ។

**៦៦-**ផ្អែកតាមមាត្រា៣៧-៣៩ និង៤០នៃអនុសញ្ញា និងបទដ្ឋានសហប្រជាជាតិផ្សេងៗទៀតដែលពាក់ព័ន្ធនេះដូចជា វិធានជាអប្បរិមាសំរាប់គ្រប់គ្រងវិស័យយុត្តិធមយុវវ័យ (វិធានក្រុងប៉េងកាំង) គោលការណ៍ណែនាំរបស់សហប្រជាជាតិដើម្បី បង្ការទោសកម្មកុមារ (គោលការណ៍ណែនាំក្រុងរីយ៉ាត) និងវិធានសហប្រជាជាតិដើម្បីការពារកុមារដែលត្រូវដកហូតសេរីភាពគណៈកម្មាធិការស្នើសូមឱ្យរដ្ឋភាគីបង្កើនប្រព័ន្ធយុត្តិធម៌មួយសំរាប់កុមារ ដោយប្រកាន់យកគោលការណ៍ និង បទបញ្ញត្តិនៃអនុសញ្ញា ព្រមទាំងឧបករណ៍ និងវិធានអន្តរជាតិទាំងឡាយដែលពាក់ព័ន្ធនឹងកិច្ចការនេះមកពិចាណា។ គណៈកម្មាធិការស្នើបន្ថែមទៀតឱ្យរដ្ឋភាគីអភិវឌ្ឍគោលនយោបាយដ៏ទូលំទំលាយមួយ និងកម្មវិធីទាក់ទិន និងស្ថានភាព កុមារប្រព្រឹត្តិអំពើល្មើសច្បាប់ ដោយយកចិត្តទុកដាក់ជាពិសេស លើស្ថានភាពកុមារដែលត្រូវបានដកហូតសេរីភាព និងកិច្ចបង្ការយុវទោសកម្ម។ បន្ថែមទៀត គណៈកម្មាធិការស្នើសូមឱ្យរដ្ឋភាគីពិចារណាដល់ការស្វែងរកជំនួយបច្ចេកទេសពីបណ្តាអង្គការនានា ការិយាល័យនៃឧត្តមស្នងការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្ស មជ្ឈមណ្ឌលបង្ការបទល្មើសព្រហ្មទណ្ឌឧក្រិដ្ឋកម្មអន្តរជាតិ អង្គការយូនីសេហ្វ និងបណ្តាញអន្តរជាតិអំពីយុត្តិធម៌យុវវ័យ តាមរយៈក្រុមសំរបសំរួលការងារយុត្តិធម៌យុវវ័យ ។

ការផ្សព្វផ្សាយរបាយការណ៍ទាក់ទងនឹងការអនុវត្តន៍អនុសញ្ញា( មាត្រាទី៤៤)

**៦៧-** ចុងបញ្ចប់នេះ ដោយយោងទៅលើមាត្រា៤៤ កថាខ័ណ្ឌ ៦ នៃអនុសញ្ញា គណៈកម្មាធិការស្នើសូមឱ្យធ្វើយ៉ាងណាឱ្យរបាយការណ៍ដំបូង និងរបាយការណ៍លាយលក្ខណ៍អក្សរឆ្លើយតបសំនួរដែលរដ្ឋភាគីបញ្ជូនមកគណៈកម្មាធិការបានដល់ដៃសាធារណៈជនជាទូទៅយ៉ាងទូលំទូលាយ ហើយការផ្សព្វផ្សាយរបាការណ៍ដែលគណៈកម្មាធិការបានពិចារណានោះគឺមានការធ្វើគួបផ្សំជាមួយនឹងកំណត់ហេតុសង្ខេបនានា ដែលពាក់ព័ន្ធ និងសេចក្តីសង្កេតចុងក្រោយដែលគណៈកម្មាធិការបានអនុម័ត។ ការចែកចាយឯកសារឱ្យបានទូលំទូលាយយ៉ាងនេះ ញុំាងឱ្យមានការជជែកពិភាក្សា និងការយល់ដឹងអំពីអនុសញ្ញាការអនុវត្ត និងការពិនិត្យតាមដានក្នុងរង្វង់រាជរដ្ឋាភិបាល រដ្ឋសភា និងសាធារណៈជនជារួមទាំង អង្គការក្រៅរដ្ឋាភិបាលដែលពាក់ព័ន្ធ។

១- តាមការអញ្ជើញរបស់លោកស្រីប្រធានអង្គប្រជុំ លោក **អ៊ុំម សិទ្ធី** លោក **នូ ភារិទ្ធិ** និងលោកស្រី **ចន្ទ័ ហារ៉ានវឌ្ឍី** បាន អញ្ជើញមកកាន់តុរបស់គណៈកម្មាធិការ ។

២- លោក **អ៊ុំម សិទ្ធី** (កម្ពុជា) បានមានប្រសាសន៍ថា ប្រទេសរបស់លោកបានឱ្យសច្ចានុម័តលើអនុសញ្ញាស្តីពីសិទ្ធិកុមារ ទាំងស្រុកហើយក្នុងឆ្នាំ ១៩៩២ ហើយក៏ជាភាគីចំពោះសិទ្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិសំខាន់ៗផ្សេងទៀតផងដែរ ។ របាយការណ៍ដំបូងដែលកំពុងពិនិត្យពិចារណានេះ ត្រូវបានធ្វើពង្រាងឡើងដោយគណៈកម្មាធិការថ្នាក់ក្រសួង ដោយសហការជាមួយអង្គការក្រៅរដ្ឋាភិបាលនានា និង អង្គការសហប្រជាជាតិ ។

៣- ប្រទេសកម្ពុជាត្រូវបានបំផ្លិចបំផ្លាញដោយសង្គ្រាម ការកាប់សំលាប់ និងវិបត្តិអស់បីទស្សវត្សរ៍ ។ ហេដ្ឋារចនាសម្ព័ន្ធរបស់ប្រទេសមានមិនគ្រប់គ្រាន់ ហើយហួសសម័យទៀត ។ គ្រាប់មីននៅតែញាំញីតំបន់នានាមួយចំនួនក្នុងប្រទេស ។ បញ្ញវ័ន្តជាច្រើនបានស្លាប់បាត់បង់ជីវិតនៅពេលដែលពួកខ្មែរក្រហមកាន់កាប់អំណាច ហើយប្រទេសមានការខ្វះខាតជាខ្លាំងនូវធនធានមនុស្ស ដែលមានជំនាញ ។

៤- ទោះបីប្រឈមមុខជាមួយនឹងឧបសគ្គទាំងនេះក៏ដោយ កិច្ចខិតខំជាច្រើនត្រូវបានធ្វើឡើងដើម្បីអនុវត្តតាមអនុសញ្ញា ។ ក្នុងវិស័យនីតិកម្មវិញ ឧទាហរណ៍ច្បាប់ស្តីពីការបង្ក្រាបការចាប់ជំរិតការជួញដូរ និងអាជីវកម្មលើមនុស្សដែលត្រូវបានអនុម័តក្នុងឆ្នាំ ១៩៩៦ បាននាំទៅរកការចាប់ខ្លួន និងកាត់ទោសឈ្មួញជួញដូរមនុស្សជាច្រើនមកហើយ ។ ក្រសួងយុត្តិធម៌បានធ្វើសេចក្តីព្រាងច្បាប់មួយស្តីពីនីតិវិធីព្រហ្មទ័ណ្ឌ និងច្បាប់ព្រហ្មទ័ណ្ឌដោយដាក់បញ្ចូលនូវបទបញ្ញត្តិទាំងឡាយដែលទាក់ទង និងយុត្តិធម៌អនីតិជន ហើយបានកំណត់ការចាប់ផ្តើមទទួលខុសត្រូវខាងបទព្រហ្មទ័ណ្ឌនៅអាយុ១៨ឆ្នាំ ។ ច្បាប់រដ្ឋប្បវេណីថ្មី និងច្បាប់ស្តីពី នីតិវិធីរដ្ឋប្បវេណីថ្មី ក៏ត្រូវបានគ្រោងដាក់បញ្ចូលនូវផ្នែកជាច្រើន ដែលនីតិកម្មនៅតែមិនទាន់មានចែងនៅឡើយដូចជាការចុះបញ្ជីកំណើត និងការដាក់កុមារឱ្យនៅក្នុងការចិញ្ចឹមបីបាច់ថែរក្សារបស់គ្រួសារ ឬស្ថាប័ន ។ ក្រសួងសង្គមកិច្ចបានធ្វើពង្រាងច្បាប់មួយ ស្តីពីការសុំកូនមកចិញ្ចឹមជាអន្តរជាតិ ដែលសមស្របទៅតាមអនុសញ្ញាស្តីពីសិទ្ធិកុមារ និងអនុសញ្ញាទីក្រុងឡាអេ ស្តីពីការការពារកុមារ និងកិច្ចសហប្រតិបត្តិទាក់ទងនឹងការសុំកូនមកចិញ្ចឹមអន្តរប្រទេស ការឱ្យសច្ចាប័នទៅលើអនុសញ្ញានេះ កំពុងតែស្ថិតនៅក្នុងការពិនិត្យពិចារណានៅឡើយ ។ ប្រទេសកម្ពុជាក៏បានឱ្យសច្ចាប័នផងដែរ លើអនុសញ្ញាលេខ១៣៨ របស់អង្គការពលកម្មអន្តរជាតិ ។

៥- ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ត្រូវបានង្កើតឡើងក្នុងឆ្នាំ ១៩៩៥ ដើម្បីសំរបសំរួលសកម្មភាពនានារបស់រដ្ឋាភិបាល និងពិនិត្យមើលលើការអនុវត្តអនុសញ្ញា ។ ទោះបីជាមានការខ្វះខាតបុគ្គលិក និង ធនធានយ៉ាងណាក៏ដោយក្រុមប្រឹក្សាជាតិដើម្បីកុមារ បានធ្វើរបាយការណ៍មួយចំនួនស្តីពីស្ថានភាពរបស់កុមារ ។ ក្រុមប្រឹក្សានេះក៏បានធ្វើពង្រាងផែនការ ៥ ឆ្នាំ ដើម្បីប្រយុទ្ធប្រឆាំងនឹងការធ្វើអាជីវកម្មខាងផ្លូវភេទលើកុមារ ដែលនឹងត្រូវដាក់ឱ្យចូលជាធរមានដោយក្រសួងទាំងអស់ ។ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារនឹងទទួលបន្ទុកលើការសំរបសំរួល និង ការអនុវត្តតាមដានបន្ត ។

៦- ប្រទេសកម្ពុជាបានបង្កើតឡើងនូវប្រពន្ធ័ប្រមូលពត៌មាន ជាពិសេសក្នុងផ្នែកសុខាភិបាល និងអប់រំ ដែលទទួលបានថវិកា ទោះបីជាមានចំនួនតិចតួចនៅឡើយក៏ដោយ ប៉ុន្តែបានកើនឡើងយ៉ាងច្រើន ។ ប្រទេសបានកំពុងជួបប្រទះនូវបញ្ហាសុខភាពនៅឡើយតាមការស្ទង់មតិ ។ អត្រាមរណៈក្នុងចំណោមទារក ម្តាយ និង កុមារក្រោមអាយុ ៥ឆ្នាំ នៅតែមានកំរិតខ្ពស់ណាស់នៅឡើយ ហើយជំងឺអេដស៍បានកំពុងរាលដាលយ៉ាងឆាប់រហ័ស ។ នៅក្នុងវិស័យអប់រំការខ្វះសាលារៀន បានធ្វើឱ្យមានការលំបាកក្នុងការអនុវត្តនូវគោលនយោបាយសិក្សាដែលខានមិន បានហើយអត្រាឈប់រៀន និងចំនួនសិស្សដែលរៀនត្រួតថ្នាក់មានកំរិតខ្ពស់ ។ ពលកម្មកុមារ អាជីវកម្មការជួញដូរខាងផ្លូវភេទលើកុមារ និងយុត្តិធម៌អនីតិជន គឺសុទ្ធតែជាបញ្ហានៃការព្រួយបារម្ភរបស់រដ្ឋាភិបាល ។

៧- ប្រទេសកម្ពុជាមានការខ្វះខាតយ៉ាងខ្លាំងនូវធនធានមនុស្ស និងហិរញ្ញវត្ថុហើយត្រូវការជាចំបាច់នូវជំនួយបច្ចេកទេសពីស្ថាប័នអង្គការសហប្រជាជាតិ និងទីភ្នាក់ងារជំនាញផ្សេងៗ។ រដ្ឋាភិបាលមានបំណងដើម្បីធ្វើអ្វីៗគ្រប់យ៉ាង ដែលខ្លួនអាចធ្វើបានដើម្បីអនុវត្តតាមអនុសញ្ញា និងធានាជូនគណៈកម្មាធិការថា ឱវាទ និងអនុសាសន៍របស់គណៈកម្មាធិការ នឹងត្រូវបានយកមកពិចារណា។

៨- <u>លោកស្រី **Tigerstedt-Tahtela**</u> បានអង្កេតឃើញថា ប្រទេសកម្ពុជាបានអនុវត្តគោលការណ៍ណែនាំរបស់គណៈកម្មាធិការក្នុងការធ្វើរបាយការណ៍របស់ខ្លួន និងក្នុងការឆ្លើយតបជាលាយលក្ខ័អក្សរ ហើយរបាយការណ៍នេះមានលក្ខណៈផ្លូវការពេកប៉ុន្តែការឆ្លើយតបជាលាយលក្ខ័អក្សរដោយបានលើកឡើងនូវច្បាប់ និងគោលនយោបាយជាច្រើន បានផ្តល់ឱ្យនូវគោលគំនិតដ៏ច្បាស់លាស់ជាង ថាតើអនុសញ្ញាត្រូវបានអនុវត្តក្នុងប្រទេសកម្ពុជាដោយវិធីណា។ ប៉ុន្តែវាហាក់ដូចជាថាកុមារមិនត្រូវបានដាក់បញ្ចូលក្នុងការរៀនចំរបាយការណ៍ដំបូងនេះឡើយ ។

៩- ការសំរបសំរួល និងការតាមដានបន្តមើលអនុសញ្ញា គឺជាការទទួលខុសត្រូវដ៏សំខាន់បំផុត និងទីមួយរបស់រដ្ឋាភិបាល ប៉ុន្តែសង្គមស៊ីវិលគួរត្រូវបានចូលពាក់ពន្ធ័ផងដែរ ពីព្រោះវាអាចជាកត្តាសត្យានុម័តជាងផង ហើយមានលក្ខណៈទិតៀនច្រើនជាងដែរ ។ តើជាក់ស្តែងការអនុវត្តអនុសញ្ញាត្រូវបានតាមដានមើលបន្តដោយរបៀបណា ហើយតើក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារបានដើរតួនាទីអ្វីខ្លះក្នុងដំណើរការនេះ? ។ ក្រសួង និងអង្គការអន្តរជាតិជាច្រើន មានតំណាងក្នុងក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ហើយលោកស្រីមានការងឿងឆ្ងល់ថាតើផែនការ និងគំរោងការផ្សេងៗដែលបានអនុម័តហើយត្រូវបានសំរបសំរួលក្នុងការអនុវត្តជាក់ស្តែងយ៉ាងណា។ តើកម្ពុជាមានផែនការណាមួយដើម្បីបើកអនុការិយាល័យ ទទួលបន្ទុកចាត់ការបណ្តឹងកុមារ **(Children's ombudsman )** ដែរឬទេ ?

១០- លោកស្រីមានការងឿងឆ្ងល់ថា តើក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ មានបានពិនិត្យមើលឱ្យបានទៀងទាត់នូវវិធានការដែលបានចាត់ឡើងដោយអនុលោមទៅតាមផែនការជាតិ ៣ ឆ្នាំសំរាប់កុមារ និងផែនការនៃសកម្មភាព ៥ ឆ្នាំ ប្រឆាំងនឹងអាជីវកម្មផ្លូវភេទដែរឬ។ តើអាជ្ញាធរកម្ពុជាមានបានគិតដល់ការផ្លាស់ទៅប្រើប្រព័ន្ធ នៃផែនការផ្លាស់ប្តូរចុះឡើយនាពេលអនាគតដែរទេ ដើម្បីឱ្យពួកគេអាចចាប់ផ្តើមធ្វើការវាយតំលៃបាន នៅពេលដែលកម្មវិធីទាំងឡាយកំពុងស្ថិតនៅក្នុងដំណើរការនោះ? ។

១១- <u>លោក **Fulci**</u> បានសួរថា តើមានកិច្ចខិតខំនានាកំពុងត្រូវបានធ្វើឡើងដើម្បីនាំអ្នកទាំងឡាយ ដែលទទួលខុសត្រូវចំពោះអំពើ ប្រល័យពូជសាសន៍ ដែលធ្វើឱ្យកុមារជាច្រើនទទួលរងនូវការឈឺចាប់នេះ ទៅកាត់ទោសដែរឬទេ ។

១២- របាយការណ៍របស់កម្ពុជា មិនបានផ្តល់នូវពត៌មានណាមួយស្តីពីការបណ្តុះបណ្តាល ដែលត្រូវបានធ្វើឡើងដោយអ្នកជំនាញធ្វើការជាមួយកុមារឡើយ។ គេហាក់បីដូចជាបានធ្វើតិចតួចណាស់ ដើម្បីឱ្យសង្គមស៊ីវិល អង្គការក្រៅរដ្ឋាភិបាល និងកុមារខ្លួនឯងបានចូលពាក់ព័ន្ធក្នុងសកម្មភាពទាំងឡាយដើម្បីការពារកុមារ។ ប្រព័ន្ធសារពត៌មាន ហាក់ដូចជាមិនបានពាក់ព័ន្ធឱ្យបានជិតដល់ណាស់ណាទេ ក្នុងការផ្សាយពត៌មានស្តីពីអនុសញ្ញា ហើយកុមារហាក់ដូចជាមិនមានចំពោះដឹងឱ្យបានច្រើនអំពីអនុសញ្ញា ឬ គោលការណ៍ណែនាំរបស់អនុសញ្ញា ។ តើគណៈប្រតិភូអាចផ្តល់ពត៌មានបន្ថែមស្តីពីចំនុចទាំងនេះបានទេ ?

១៣- គណៈកម្មាធិការស្តីពីការលុបបំបាត់ចោលការរើសអើងពូជសាសន៍ បានរាយការណ៍អំពីការរើសអើង និងអំពើហឹង្សាដ៏ធ្ងន់ធ្ងរប្រឆាំងនឹងប្រជាពលរដ្ឋវៀតណាមជាច្រើន ដែលកំពុងរស់នៅប្រទេសកម្ពុជា។ ដូចជាមានគេនិយាយថាមានផាសុខុបករណ៍តិចតួចណាស់ សំរាប់កុមារជនជាតិវៀតណាមរៀនភាសាខ្មែរ។ ដោយឈរលើគោលការណ៍នៃការមិនរើសអើងដែលមានចែងក្នុងមាត្រា ២ នៃអនុសញ្ញា តើវិធានការណ៍អ្វីខ្លះកំពុងត្រូវបានចាប់ឡើង ដើម្បីធ្វើឱ្យកុមារទាំងអស់មានលទ្ធភាពដើម្បីអនុវត្តនូវសិទ្ធិ

ដែលពួកគេបានទទួលតាមរយៈអនុសញ្ញា ដោយមិនគិតពីដើមកំណើត ជាតិពន្ធុរបស់ពួកគេនោះ ? ។

១៤- លោកស្រី **Mokhuane** បានស្នើសុំពត៌មានបន្ថែមអំពីមុខងារខាងការសំរបសំរួលរបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ តើមុខងារនេះដំណើរការនៅថ្នាក់ខេត្ត ឬថ្នាក់មូលដ្ឋានយ៉ាងដូចម្តេច? តើរដ្ឋសភាមានបានទទួលរបាយការណ៍ណាមួយ អំពីការងារទាំងនេះទេ ហើយប្រសិនបើបានតើមកពីណា : ក្រសួងសង្គមកិច្ច ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ឬអភិបាលខេត្ត ? តើមានផែនការណាមួយដើម្បីបង្កើតឱ្យមានអនុការិយាល័យ ទទួលបន្ទុកចាត់ការបណ្តឹងកុមារ **(Children's ombudsman)** ដែរឬទេ? ក្រសួងនីមួយៗហាក់ដូចជាទទួលខុសត្រូវចំពោះការធ្វើសេចក្តីព្រាងច្បាប់ ដែលគ្របដណ្តប់តែលើវិស័យការងារផ្ទាល់របស់ខ្លួន ដោយគ្មានការសំរបសំរួលជាក់ស្តែងណាមួយក្នុងចំណោមក្រសួងនានាឡើយ ។ ទំនាក់ទំនងដ៏សំខាន់មួយនោះ គឺគេត្រូវធ្វើច្បាប់ឱ្យមានលក្ខណៈរលូនទាំងមូល ហើយធ្វើឱ្យបញ្ហាទាំងអស់ ដែលមានចែងក្នុងអនុសញ្ញា មានប្រទាក់ក្រឡាទាំងអស់គ្នាបានកំពុងបាត់ហើយ ។

១៥- វាហាក់ដូចជាមានការចង់បានដូចគ្នាមួយនូវការសំរបសំរួលក្នុងការប្រមូលទិន្នន័យ ដែលហាក់ដូចជាបានធ្វើដាច់តែឯងដោយក្រសួងផ្សេងៗ ។ វានឹងជាការមួយប្រកបដោយប្រយោជន៍ ដើម្បីឱ្យមានយន្តការប្រមូលទិន្នន័យគំរូមួយដើម្បីគ្របដណ្តប់លើផ្នែកទាំងអស់ដែលមានចែងនៅក្នុងអនុសញ្ញា ។

១៦- តើថវិកាក្នុងចំនួនប៉ុន្មានដែលត្រូវបានទុកសំរាប់ចំណាយលើកុមារ ដែលស្ថិតក្នុងស្ថានភាពមានគ្រោះថ្នាក់? អ្នកណាគេជាអ្នកកំណត់អាទិភាពថវិកា-ក្រសួង ឬអាជ្ញាធរខេត្ត? ។ អង្គហេតុដែលថាប្រាក់បៀវត្សរ៍របស់គ្រូបង្រៀនមិនត្រូវបានគេដំឡើងឱ្យទោះបីជាថវិកាមានចំនួនកើនឡើងក៏ដោយនោះ ទំនងមានគ្រោះថ្នាក់ដល់សីលធម៌នាពេលអនាគត តើរដ្ឋមានគោលបំណងដើម្បីដោះស្រាយបញ្ហានេះយ៉ាងណា ?

១៧- លោក **Rabah** ចង់ដឹងថាហេតុអ្វីបានជាវាហាក់ដូចជាមានកិច្ចសហប្រតិបត្តិការ និងការសំរបសំរួលដ៏តិចតួចណាស់រវាងរដ្ឋាភិបាល និងអង្គការការក្រៅរដ្ឋាភិបាលក្នុងប្រទេសកម្ពុជា ហើយតើរឿងនោះពិតប្រាកដយ៉ាងណា? តើអង្គការក្រៅរដ្ឋាភិបាលមានបានចូលរួមដោយផ្ទាល់ ឬដោយប្រយោជន៍នៅក្នុងការរៀបចំរបាយការណ៍ដំបូងនេះទេ ? តើមានគោលនយោបាលជាក់ស្តែងណាមួយស្តីពីសិទ្ធិកុមារក្នុងប្រទេសកម្ពុជាដែរឬទេ? តើមានមជ្ឈការនៃសេវាកម្មសំរាប់កុមារកម្ពុជានៅខាងក្រៅក៏ដូចជានៅខាងក្នុងទីក្រុងធំដែរឬទេ ?

១៨- លោកមានការងឿងឆ្ងល់ថា ហេតុអ្វីបានជាមានការកំណត់អាយុដែលអាចរៀបការបានសំរាប់ស្ត្រីគឺ១៨ឆ្នាំ និងសំរាប់បុរសគឺ២០ឆ្នាំ។ លោកបានស្នើសុំពត៌មានបន្ថែមស្តីពីមាត្រា១៧៧ នៃច្បាប់ការងារដែលក្នុងនេះ កុមារអាយុក្រោម១៨ឆ្នាំ អាចធ្វើការបានប្រសិនបើមានការយល់ព្រមពីឪពុកម្តាយ ឬអាណាព្យាបាលរបស់ខ្លួន។ ជាចុងក្រោយនេះគណៈកម្មាធិការមិនបានទទួលពត៌មានអំពីប្រាក់បៀវត្សរ៍អប្បបរិមាសំរាប់ចូលបំរើក្នុងជួរកងកំលាំងប្រដាប់អាវុធឡើយ ហើយវានឹងជាការមានប្រយោជន៍ក្នុងការដឹងអំពីបញ្ហានេះ ។

១៩- លោក **Doeuk** បានសួរថាតើរដ្ឋាភិបាលកម្ពុជាមានបំណង ដើម្បីតាមដានពិនិត្យមើលបន្តលើរបកគំហើញដែលបានមកពីការសិក្សាស្រាវជ្រាវដែលធ្វើឡើងដោយក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ដែលបានបង្ហាញថាពុំមានបទបញ្ញត្តិណាត្រូវបានធ្វើឡើងនៅក្នុងនីតិកម្មដើម្បីបំរើឱ្យដល់ការពិនិត្យតាមដានបន្តលើការអនុវត្តអនុសញ្ញាឡើយ ហើយថាតើវានឹងជាការសមស្រប ដែរឬទេ ដើម្បីព្រាងច្បាប់ស្តីពីកុមារជាទូទៅមួយ និងដើម្បីបង្កើតឡើងនូវក្រុមការងារថ្នាក់ជាតិមួយដើម្បីបំរើឱ្យគោលបំណងនេះ ។

២០- ពាក់កណ្តាលនៃថវិកាជាតិហាក់ដូចជាត្រូវបានចំណាយវិស័យការពារ និងសន្តិសុខដែលបានធ្វើឱ្យខូចប្រយោជន៍ដល់ វិស័យផ្សេងទៀត។ តើរដ្ឋាភិបាលអាចកែសំរួលស្ថានភាពនោះឱ្យបានសមស្របដែរឬទេ? ម្យ៉ាងទៀតចំនួនប្រាក់ដែលត្រូវចំណាយលើសកម្មភាពផ្សេង១មួយចំនួន ហាក់ដូចជាមានចំនួនតិចជាងចំនួនដែលបានគ្រោងពីដំបូង។ លោកចង់ឱ្យមានការបំភ្លឺអំពីបញ្ហានេះ ។

២១- តើផែនការសកម្មភាពជាតិសំរាប់កុមារ ដែលហាក់ដូចជាការប្រមូលផ្តុំនៃវិធានការទាំងឡាយ ដែលបានចាត់ឡើងដោយក្រសួងផ្សេង១ដើម្បីធ្វើឱ្យមានការងារស្រួលជាង ក្នុងការពិនិត្យមើល និងវាយតំលៃលើស្ថានភាពរបស់កុមារមានគោលបំណងអ្វីខ្លះ? តើមានគោលបំណងជាទូទៅ ឬការរីកចំរើនណាមួយដែលនឹងអាចធ្វើឱ្យគណៈកម្មាធិការមានលទ្ធភាពអាចវាយតំលៃលើភាពជឿនលឿននៃផែនការនេះទាំងមូលដែរឬទេ ?

២២- <u>លោកស្រី **Rilantono**</u> បានសង្កត់ធ្ងន់លើសេចក្តីត្រូវការជាចាំបាច់ឱ្យមានការសំរបសំរួលក្នុងចំណោមសកម្មភាពទាំងឡាយនៃក្រសួងផ្សេង១ដែលបានពង្រីកសមត្ថកិច្ចរបស់ខ្លួនដល់កុមារ និងលើសេចក្តីត្រូវការជាចាំបាច់ដើម្បីធ្វើឱ្យក្រសួងទាំងឡាយក៏ដូចជាសាធារណៈជនទូទៅបានយល់ដឹងអំពីអនុសញ្ញាដែរ។ រចនាសម្ព័ន្ធមូលដ្ឋានជាប្រភេទនៃការប្រមូលផ្តុំតាមភូមិ និងជាប្រពៃណីដែលមាននៅក្នុងប្រទេសក្នុងប្រទេសអាស៊ី និងអាចជាមធ្យោបាយដ៏ល្អមួយក្នុងការផ្សព្វផ្សាយឱ្យមានការយល់ដឹងអំពីអនុសញ្ញាក្នុងប្រទេសកម្ពុជា ប្រសិនបើរចនាសម្ព័ន្ធទាំងនេះមាននៅទីនោះស្រាប់នោះ។ តើកម្ពុជាមានបានបង្កើតឡើងនូវកម្មវិធីបណ្តុះបណ្តាលជាតិសំរាប់បណ្តុះបណ្តាលបុគ្គលិកជំនាញនានា ដូចជាអ្នកជំនាញការច្បាប់ និងគ្រូបង្រៀនដោយសារថា កម្ពុជាខ្វះខាតនូវបុគ្គលិកមានសមត្ថភាពនោះ ? ។

២៣- <u>លោកស្រីប្រធាន</u> បានសួរថាតើរដ្ឋាភិបាលកម្ពុជាកំណត់យ៉ាងដូចម្តេចក្នុងការផ្សព្វផ្សាយអនុសញ្ញា និងថាតើកម្ពុជាអាចជំនះការលំបាកទាំងឡាយដែលចោទឡើងដោយតំរិយាបទជាប្រពៃណីរបស់ខ្លួនចំពោះគោលការណ៍ដែលថា កុមារត្រូវបានគ្រប់គ្រងដោយច្បាប់ ។

២៤- លោកស្រីមានការសោកស្តាយថា ការឆ្លើយតបជាលាយលក្ខ័អក្សរពុំបានចង្អុលបង្ហាញឱ្យឃើញអំពីអាយុតាមផ្លូវច្បាប់ ដែលអនុញ្ញាតយល់ព្រមឱ្យរួមភេទបានទេ ដោយហេតុថាការចូលជាប់ពាក់ពន្ធ័របស់អនីតិជនក្នុងអំពើពេស្យាចារ្យ គឺជាបញ្ហាដ៏សំខាន់មួយនៅក្នុងតំបន់ ។ តើមាត្រា ៤៣៤ នៃច្បាប់ព្រហ្មទណ្ឌ័គ្រប់គ្រាន់ដើម្បីធានាឱ្យមានការការពារចំពោះកុមារដែរ ឬទេ ?

២៥- <u>លោកស្រី ចន្ទ័ ហាវ៉ានវឌ្ឍី</u> (កម្ពុជា) បានមានប្រសាសន៍ថា ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារទើបតែត្រូវបានបង្កើតឡើងនាពេលថ្មី១នេះទេគឺដូចដែលអនុសញ្ញាស្តីពីសិទ្ធិកុមារទើបតែបានចាប់អនុវត្តនោះដែរ។ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារបានកំពុងខិតខំយ៉ាងខ្លាំងខ្លាដើម្បីសំរបសំរួលសកម្មភាពទាំងឡាយ ដែលត្រូវបានរៀបចំឡើង ដើម្បីការពារកុមារពិនិត្យមើលការអនុវត្តលើកម្មវិធីទាំងនោះ និងពិនិត្យមើលដោយហ្មត់ចត់លើនីតិកម្មស្តីពីបញ្ហានោះ។ ក្រុមប្រឹក្សានេះមិនគ្រាន់តែសំរបសំរួលសកម្មភាពនានារបស់ក្រសួងផ្សេង១ទេ ប៉ុន្តែថែមទាំងសំរបសំរួលសកម្មភាពទាំងឡាយរបស់រដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាលផងដែរ។ ក្រុមប្រឹក្សាក៏ទទួលបន្ទុកផងដែរ ក្នុងការសំរបសំរួលសកម្មភាព និងការងារថ្នាក់ជាតិរបស់គណៈកម្មាធិការថ្នាក់មូល ដ្ឋាន និង ខេត្ត ដែលទទួលខុសត្រូវចំពោះបញ្ហារបស់កុមារ ។

២៦- ទោះបីជាប្រឈមមុខជាមួយការខ្វះនូវធនធានមនុស្ស និងធនធានសំភារៈក៏ដោយ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារមានលទ្ធភាពអាចបង្កើតឡើងបាននូវផែនការសកម្មភាពជាតិសំរាប់កុមារ។ ទំនាក់ទំនងរវាងអង្គការក្រៅរដ្ឋាភិបាល ស្ថាប័នរបស់រដ្ឋាភិបាល និងប្រពន្ធ័សារពត៌មាន បានផ្តល់ឱ្យក្រុមប្រឹក្សាជាតិដើម្បីកុមារនូវប្រភពពត៌មានមានដ៏មានតំលៃ។ ក្រុមប្រឹក្សានេះទទួលបន្ទុកពិនិត្យមើលលើស្ថាបន័របស់រដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាលនៅថ្នាក់ខេត្ត ហេតុដូច្នេះហើយទើបមានលទ្ធ

ភាពអាចដាក់អនុសាសន៍ជូនដល់រដ្ឋាភិបាល។ ក្រុមប្រឹក្សាបានធ្វើការសហការយ៉ាងជិតស្និទ្ធជាមួយអង្គការក្រៅរដ្ឋាភិបាល និងស្ថាប័នអន្តរជាតិនានាដូចជាអង្គការ **UNICEF** ផ្នែកឯកជន និងសង្គមស៊ីវិលជាដើម។ ក្រុមប្រឹក្សាបានធ្វើការស្ទង់មតិនៅ ក្នុងខេត្តនានាលើប្រធានបទ ដូចជាការធ្វើអាជីវកម្មខាងផ្លូវភេទលើកុមារជាដើម ។

២៧- លោកអ៊ុម សិទ្ធី (កម្ពុជា) បានសង្កត់ធ្ងន់លើតួនាទីក្នុងការសំរបសំរួលរបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ដែលរួមមានរដ្ឋមន្ត្រី និងរដ្ឋលេខាធិការចំនួនជាង១៨រូប បានចូលរួម ដែលមានការទទួលខុសត្រូវទាក់ទងនឹងស្ថានភាពរបស់កុមារ។ នៅពេលដែលក្រុមប្រឹក្សាធ្វើការពិនិត្យពិចារណាលើច្បាប់ជាធរមានហើយនោះ ក្រុមប្រឹក្សាអាចធ្វើអនុសាសន៍ជូនក្រុមប្រឹក្សារដ្ឋមន្ត្រី។ ដោយសារថាកម្ពុជាបានប្រឈមមុខជាមួយនឹងបញ្ហាដ៏ធំសម្បើម បន្ទាប់ពីជំលោះប្រដាប់អាវុធដែលបានអូសបន្លាយអស់រយៈពេលយ៉ាងយូរមក រដ្ឋាភិបាលត្រូវកំណត់ទិសដៅដើម្បីធ្វើការកសាងឡើងវិញលើគ្រប់ផ្នែកទាំងអស់ដោយចាប់ផ្តើមពីការកសាងនីតិកម្មទៅ ។ មានច្បាប់ចំនួនច្រើនជាង១២០ ត្រូវបានអនុម័ត្រតាំងពីឆ្នាំ ១៩៩៣មក ប៉ុន្តែនៅតែមានកិច្ចការជាច្រើនទៀត ដើម្បីធ្វើដើម្បីតាក់តែងច្បាប់ ដែលនឹងធានាដល់សុខុមាលភាពរបស់កុមារ និងប្រជាពលរដ្ឋទាំងមូល។ ហេតុដូច្នេះហើយក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ បានដើរតួនាទីយ៉ាងសំខាន់ជាអាយុជីវិត ហើយបានផ្តល់អនុសាសន៍ឱ្យអនុមត័ច្បាប់ប្រឆាំងនឹងការ ជួញដូរ និងអាជីវកម្មខាងផ្លូវភេទលើកុមារ ។

២៨- ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ធ្វើការយ៉ាងជិតស្និទ្ធជាមួយអង្គការក្រៅរដ្ឋាភិបាល ដែលមានចំនួនយ៉ាងហោចណាស់ចំនួន ៤០០ អង្គការ ហើយអង្គការចំនួនច្រើនជាង ២០ នៃអង្គការទាំងនេះធ្វើការជំនាញខាងសិទ្ធិមនុស្ស និងសិទ្ធិរបស់កុមារ។ នៅក្នុងការជួបជុំគ្នាមួយដែលរៀបចំដោយក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ អង្គការក្រៅរដ្ឋាភិបាលទាំងឡាយមានឱកាសដើម្បីពន្យល់បកស្រាយថា តើសកម្មភាពនានារបស់ពួកគេ ជួយបំពេញបន្ថែមឱ្យដល់កិច្ចខិតខំរបស់រាជរដ្ឋាភិបាលយ៉ាងដូចម្តេច ។

២៩- ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ក៏បានបំពេញការងារជាស្ថាប័នសំរាប់លើកតំកើងនូវការងារជាច្រើន ក្នុងនោះមានអនុសញ្ញាផងដែរ។ ក្រុមប្រឹក្សាបានខិតខំយ៉ាងខ្លាំងខ្លាដើម្បីដាស់មតិសាធារណៈ តាមរយៈការបង្កើតឱ្យមានមេរៀនសិក្សា និងសកម្មភាពផ្សេងៗ សំរាប់បំរើដល់អត្ថប្រយោជន៍របស់កុមារ ដូចជាការប្រារព្ធធ្វើទិវាកុមារអន្តរជាតិ ១ មិថុនា។ ចំពោះសំនួរទាក់ទិននឹងការពង្រឹងសមត្ថភាពបង្រៀន ការសំខាន់បំផុតគឺត្រូវធានាឱ្យមានការ ចូលរួមយ៉ាងសកម្មពីសំណាក់ឪពុកម្តាយ និងសហគមន៍នៅថ្នាក់មូលដ្ឋាន ។

៣០- ទស្សនៈដើម្បីបង្កើតឱ្យមានជាស្ថាប័នអនុការិយាល័យ ទទួលចាត់ការបណ្តឹងទាក់ទងនឹងកុមារ **(Children's Ombudsman )** គឺជាទស្សនៈប្រកបដោយភាពចាប់អារម្មណ៍យ៉ាងខ្លាំង ប៉ុន្តែកិច្ចការផ្សេងទៀត សុទ្ធតែបានចាត់ជាអាទិភាព ។

៣១- ជាតិពន្ធុខ្មែរមានចំនួន ៩៥ % នៃប្រជាពលរដ្ឋកម្ពុជា ប៉ុន្តែកុមារដែលមកពីក្រុមអប្បភាគជនចាមក្រុមអប្បភាគជន ផ្សេងៗ និងសហគមន៍ចិន និង វៀតណាម ពុំបានទទួលនូវការរើសអើងប្រឆាំងអ្វីមួយឡើយ ។

៣២- ការរំសាយនៃក្រុមប្រដាប់អាវុធចំនួន ៤ ក្រុម រាប់បញ្ចូលទាំងទាហានដែលជាកុមារបានចាប់ផ្តើមតាំងពីដំបូងមកម្ល៉ោះ ហើយជាកិច្ចការអាទិភាពមួយផងដែរ។ ការរំសាយកងទ័ពបានបន្តធ្វើក្នុងអត្រានៃទាហានចំនួន១០.០០០នាក់ ដែលត្រូវបានរំសាយក្នុងមួយឆ្នាំ ៗ ។ ឥឡូវនេះបញ្ហាស្ទើរតែត្រូវបានដោះស្រាយអស់ហើយ ។

៣៣- ទំហំនៃថវិកាសំរាប់វិស័យការពារ និងសន្តិសុខ ត្រូវបានកំណត់មួយផ្នែកទុកសំរាប់បំរើឱ្យការចំណាយផ្សេងៗនៅពេល ដែលក្រុមផ្សេងៗត្រូវបានធ្វើសមាហរណកម្ម។ ធនធានដែលមានតំលៃថ្លៃក៏ត្រូវបានទុកសំរាប់បំរើឱ្យសកម្មភាព នៃការរំសាយនានាដែលក្រៅពីការកាត់បន្ថយនូវចំនួនទ័ពបានពាក់ពន្ធ័នឹងការបណ្តុះបណ្តាល និងការរកការងារឱ្យធ្វើសំរាប់អតីតយោធា។ ទោះបីជា

យ៉ាងណាក៏ដោយ រដ្ឋាភិបាលបានប្តេជ្ញាចិត្តដើម្បីបង្កើនថវិកា សំរាប់បំរើឱ្យវិស័យសង្គមកិច្ច ដូចជាវិស័យសុខាភិបាល និងអប់រំជាដើម ។

៣៤- ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ បានផ្តល់ទឡ្ហីករណ៍ថាគណៈកម្មាធិការសកម្មភាពថ្នាក់ជាតិត្រូវធានាថាជនគ្រប់រូប អាចអនុវត្តសិទ្ធិទទួលបានការអប់រំរបស់គេបាន។ ការបង្កើតថវិកាសំរាប់វិស័យអប់រំត្រូវបានគ្រោងទុកសំរាប់ឆ្នាំ២០០០ និង២០០១។ វិធានការនានាត្រូវបានចាត់ឡើងតាំងពីឆ្នាំ១៩៩៣ មកដើម្បីធានាថាប្រាក់បៀវត្សរ៍របស់មន្ត្រីរាជការ ជាពិសេសគ្រូបង្រៀន ត្រូវបានបើកឱ្យ។ គ្រូបង្រៀនដែលមានចំនួនច្រើនជាងពាក់កណ្តាលនៃមន្ត្រីរាជការស៊ីវិលទាំងអស់ ក៏ទទួលបាននូវប្រាក់បំណាច់សំរាប់ការបង្រៀនផងដែរ។ ក្រៅពីការកែទំរង់រដ្ឋបាល ការធ្វើជំរឿនមន្ត្រីរាជការស៊ីវិលដោយប្រពន្ធ័កុំព្យូទ័រ បច្ចុប្បន្ននេះ កំពុងតែត្រូវបានដំណើរការ ។ ការតំឡើងប្រាក់បៀវត្សរ៍ ថែមទៀតសំរាប់គ្រូបង្រៀន ក៏ត្រូវបានគ្រោងធ្វើផងដែរ ។

៣៥- <u>លោក នូ ភារិទ្ធិ</u> (កម្ពុជា) បានមានប្រសាសន៍ថា អាយុដែលអាចរៀបអាពាហ៍ពិពាហ៍បាន គឺត្រូវបានកំណត់យកអាយុ១៨ ឆ្នាំសំរាប់ស្ត្រី និង ២០ឆ្នាំ សំរាប់បុរស ។ ស្ត្រីអាចរៀបការនៅអាយុតិចជាងនេះបាន (ឧទាហរណ៍ ប្រសិនបើពួកគេមានផ្ទៃពោះ) ដោយមានការឯកភាពយល់ព្រមពីឪពុកម្តាយរបស់ពួកគេ ។ អាយុអប្បបរិមាសំរាប់ចូលបំរើការងារនៅពេលបច្ចុប្បន្ននេះគឺ១៦ឆ្នាំ ប៉ុន្តែដោយឈរលើស្ថានភាពសេដ្ឋកិច្ចដ៏លំបាក និងវិសាលភាពនៃភាពអត់ឃ្លាន គេមានផែនការដើម្បីកាត់បន្ថយអាយុនេះ មកត្រឹម ១៤ ឆ្នាំ ដើម្បីឱ្យកុមារមានលទ្ធភាពអាចជួយក្រុមគ្រួសាររបស់ពួកគេបាន ។

៣៦- <u>លោកស្រីប្រធានអង្គប្រជុំ</u> បានអង្កេតឃើញថា គណៈប្រតិភូមិនទាន់បានឆ្លើយសំនួរស្តីពីលទ្ធផលនៃការសិក្សាស្រាវជ្រាវដោយធ្វើការប្រៀបធៀបរវាងច្បាប់ជាតិ និងអនុសញ្ញាថាតើការប្រមូលផ្តុំរស់នៅតាមប្រពៃណីអាចជួយផ្សព្វផ្សាយពាក្យពេចន៍របស់អនុសញ្ញាយ៉ាងណា ការសំរបសំរួលក្នុងចំណោមក្រសួងនានា។ អាយុតាមផ្លូវច្បាប់ ដែលអនុញ្ញាតិយល់ព្រមឱ្យរួមភេទ បាន និងអំពីឥរិយាបទជាប្រពៃណីចំពោះអនុសញ្ញា ។

៣៧- <u>លោកស្រី ចន្ទ័ ហារ៉ានវង្ស៊ី</u> (កម្ពុជា) បានមានប្រសាសន៍ស្តីពីប្រធានបទនៃច្បាប់ថា ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារបានអំពាវនាវសូមឱ្យក្រុមការងារពិសេសមួយ ដែលរួមមានតំណាងនានាមកពីផ្នែកឯកជន អង្គការក្រៅរដ្ឋាភិបាល អង្គការអន្តរជាតិ និងស្ថាប័នរបស់រដ្ឋាភិបាលត្រូវបានបង្កើតឡើងដើម្បីពិនិត្យពិចារណាលើច្បាប់ទាំងឡាយ ដែលបានព្រាងឡើងដោយក្រសួងដែលជាអ្នកបច្ចេកទេស និងធានាថាពួកគេបានដាក់បញ្ចូលសិទ្ធិកុមារចូលទៅក្នុងនោះដែរ។ អង្គការ **UNICEF** ត្រូវបានគេទាក់ទងអំពីការផ្តល់ហិរញ្ញប្បទានដល់សេវាកម្មនៃទីប្រឹក្សាច្បាប់ម្នាក់ ប៉ុន្តែធនធានហិរញ្ញវត្ថុចាំបាច់នោះនៅតែត្រូវរកនៅឡើយ ។

៣៨- ដោយសហការជាមួយអង្គការ **UNICEF** ក្រុមប្រឹក្សាជាតិកម្ពុជដើម្បីកុមារបានបង្កើតឡើងនូវកម្មវិធីនៃសកម្មភាពដើម្បីលើកតំកើងសិទ្ធិកុមារ ដែលត្រូវបានកំណត់នឹងធ្វើការពិចារណាអនុវត្តនៅក្នុងទីកន្លែងប្រមូលផ្តុំធំៗ និងក្នុងភូមិនានា។ ការផ្សព្វផ្សាយអំពីអនុសញ្ញាជាផ្នែកៗ ត្រូវបានធ្វើតាមរយៈការផ្សព្វផ្សាយតាមទូរទស្សន៍ផង តាមរយៈប៉ុស្តិ៍ឯកជនផង និងនៅក្នុងឱកាសបុណ្យផ្សេងៗផង ដូចជាទិវាកុមារអន្តរជាតិជាដើម។ យុទ្ធនាការមួយត្រូវបានចាប់អនុវត្តឡើង ដើម្បីធ្វើឱ្យប្រជាពលរដ្ឋមានការយល់ដឹងថែមទៀតអំពីអនុសញ្ញា និងអំពីបញ្ហានៃការជួញដូរខាងផ្លូវភេទលើកុមារ និង ពលកម្មកុមារ ។

៣៩- កិច្ចខិតខំនានាក៏កំពុងត្រូវបានធ្វើឡើងដើម្បីក្រើនរំលឹកដល់ និងដើម្បីអប់រំមន្ត្រីរាជការនៅគ្រប់ជាន់ថ្នាក់ ម្យ៉ាងដើម្បីលើកទឹកចិត្តពួកគេឱ្យយល់ដឹងឱ្យបានលើសពីទិដ្ឋភាពខាងបច្ចេកទេសសុទ្ធសាធ នៃការអនុវត្តនៃអនុសញ្ញា។ ក្រុមអ្នកស្ម័គ្រចិត្តបានកំពុងជួយកុមារនៅក្រោមកម្មវិធីជំនួយកសាងសមត្ថភាពសហគមន៍ ដែលត្រូវបានចាត់ចែងដំណើរការដោយនាយកដ្ឋានអភិវឌ្ឍន៍ជនបទ ដោយមានការគាំទ្រពីអង្គការ **UNICEF** ។

៤០- ពុំមានច្បាប់ណាមួយដែលកំណត់អំពីអាយុអប្បបរិមាដែលអនុសញ្ញាតិឱ្យមានសិទ្ធិរួមភេទបាននោះទេ ។

៤១- លោកស្រីប្រធានអង្គប្រជុំ បានអញ្ជើញគណៈកម្មាធិការឱ្យសួរសំណួរស្តីអំពីគោលការណ៍ទូទៅ សិទ្ធិ និងសេរីភាពពលរដ្ឋ ។

៤២- លោក **Doeuk** បានមានប្រសាសន៍ថា លោកស្នើសុំពត៌មានពិស្តារថែមទៀត ស្តីពីការចោទប្រកាន់អំពីការប្រព្រឹត្តិអំពើឃោរឃៅដោយនគរបាលលើកុមារអាណាថា និងកុមារដែលជាប់នៅក្នុងស្ថានីយនគរបាលមួយចំនួន និងអំពីវិធានការដែលត្រូវបានចាត់ឡើងដើម្បីទប់ទល់នឹងបញ្ហានេះ ។

៤៣- លោក **Fulci** បានស្នើសុំពត៌មានបន្ថែមទៀតអំពីស្ថានភាពរបស់កុលសម្ព័ន្ធតំបន់ភ្នំ។ ប្រភពខ្លះបានចោទប្រកាន់ថាកុមារចំនួន ៣ នាក់ត្រូវបានធ្វើទារុណកម្មនៅមជ្ឈមណ្ឌលនីតិសម្បទា លោកចង់ដឹងថាអ្វីខ្លះកំពុងត្រូវបានធ្វើឡើងដើម្បីធ្វើឱ្យនគរបាលផ្លាស់ប្តូរឥរិយាបទរបស់ពួកគេ។ លោកក៏ចង់ដឹងដែរថា តើនៅពេលណាទើបប្រតិបត្តិការខាងការបោសសំអាតមីនលើទឹកដីកម្ពុជានឹងត្រូវបានបញ្ចប់នោះ ។

៤៤- លោកស្រី **Tigerstedt-Tahtela** បានសួរថាតើពាក្យថា សញ្ជាតិ **(Nationality)** និងពលរដ្ឋ **(Citizenship)** មានន័យដូចម្តេចក្នុងប្រទេសកម្ពុជា។ លោកស្រីមានការងឿងឆ្ងល់ថា តើអ្នកណាគេក្រៅពីជនជាតិខ្មែរអាចចូលសញ្ជាតិកម្ពុជាបានហើយថាតើក្រុមជនជាតិវៀតណាមទាំងនោះត្រូវស្ថិតនៅក្នុងលក្ខណៈបែបណា។ គោលបំណងនៃការប្រឆាំងនឹងការរើសអើង គឺមិនមែនគ្រាន់តែដើម្បីធានាឱ្យមានការប្រព្រឹត្តិដោយស្មើភាពសំរាប់ទាំងអស់គ្នាប៉ុណ្ណោះទេ ប៉ុន្តែត្រូវតែផ្តល់ឱ្យមានការប្រព្រឹត្តិដោយយកចិត្តទុកដាក់ជាង ទៅលើក្រុមដែលចាញ់ប្រៀបគេដែរ។ លោកស្រីចង់ដឹងថាតើវិធានការអ្វីខ្លះកំពុងត្រូវបានចាត់ឡើងដើម្បីផ្លាស់ប្តូរឥរិយាបទនេះ និងដើម្បីបញ្ចប់ការអនុវត្ត ជាប្រពៃណីដែលមានការរើសអើងប្រឆាំងនឹងស្ត្រីក្មេងៗ ។

៤៥- ស្រី **Mokhuane** បានមានប្រសាសន៍ថា លោកស្រីគិតថា សំណួរនានាក្នុងថាខណ្ឌ័ទី ៦ នៃបញ្ជីបញ្ហាមិនត្រូវបានឆ្លើយឱ្យបានត្រឹមត្រូវទេ។ លោកស្រីមានចំងល់ថាតើរដ្ឋធម្មនុញ្ញ និងច្បាប់បានអនុញ្ញាតិឱ្យជនមិនមែនជាខ្មែរ ដែលទទួលរងនូវការរើសអើង ធ្វើការរកដំណោះស្រាយដែរឬទេ ហើយថាតើមានយុទ្ធនាការផ្តល់ពត៌មាន និងការផ្សព្វផ្សាយឱ្យមានការយល់ដឹងត្រូវបានធ្វើឡើងដើម្បីធានាថាបុគ្គលដែលផ្ទុកមេរោគអេដស៍ និងអ្នកជំងឺអេដស៍មិនត្រូវបានគេទុកចោល ដោយមិនបានទទួលអត្ថប្រយោជន៍អ្វីឡើយ។ លោកស្រីបានសួរថា តើកុលសម្ព័ន្ធតំបន់ភ្នំមានសិទ្ធិទទួលបានសេវាកម្មផ្នែកសង្គមកិច្ចទាំងអស់ដែរឬ ។

៤៦- លោកស្រីក៏មានចំងល់ផងដែរថា តើអត្ថប្រយោជន៍ដ៏ឧត្តុង្គឧត្តមរបស់កុមារត្រូវបានគិតគួរយ៉ាងដូចម្តេចនៅក្នុងបញ្ហាច្បាប់គ្រួសារ និងព្រហ្មទណ្ឌ ដូចជានៅពេលដែលបញ្ហានៃការថែទាំកុមារត្រូវបានដោះស្រាយនៅក្នុងដំណើរការក្តីនៃការលែងលះគ្នា ។ ហើយអ្វីខ្លះកំពុងត្រូវបានធ្វើឡើងទប់ស្កាត់ម្តាយដែលមានផ្ទុកមេរោគអេដស៍ កុំឱ្យចំលងមេរោគនេះទៅកាន់កូនរបស់ខ្លួន ។

៤៧- លោកស្រី **Rilantono** មានចំងល់ថាតើមានច្បាប់ណាមួយ ដែលបានបញ្ជាក់យ៉ាងច្បាស់អំពីសិទ្ធិរបស់កុមារក្នុងការបញ្ចេញមតិរបស់ខ្លួនដោយសេរីដែរឬទេ។ របាយការណ៍ បាននិយាយថា ជាក់ស្តែងកុមារបានសំដែងទស្សនៈរបស់ពួកគេនៅក្នុងថ្នាក់រៀនដោយការឆ្លើយទៅនឹងសំនួរ ដែលគ្រូរបស់ពួកគេបានសួរនៅពេលប្រជុំផ្សេងៗ តើនោះគឺជាពេលវេលាតែមួយគត់ដែលកុមារអាចសំដែងមតិរបស់ពួកគេឬ? តើពួកគេអាចបញ្ចេញទស្សនៈរបស់ពួកគេក្នុងរង្វង់គ្រួសារ ឬមួយតើវប្បធម៌កម្ពុជាតំរូវឱ្យពួកគេគោរពប្រតិបត្តិតាមតែចាស់ទុំរបស់ពួកគេ? ប្រសិនបើឪពុកម្តាយរបស់ពួកគេលែងលះគ្នាតើកុមារ ដែលមានវ័យលើសពីអាយុតំណត់ណាមួយអាចសំដែងការពេញចិត្តរបស់ខ្លួន ក្នុងការទៅរស់នៅជាមួយម្តាយ ឬឪពុករបស់ពួកគេបានដែរឬទេ ?

៤៨- លោក **Doek** បានសួរថានៅពេលណាដែលបញ្ញត្តិច្បាប់នៃច្បាប់រដ្ឋប្បវេណី និងច្បាប់ព្រហ្មទណ្ឌ ដែលតំរូវឱ្យមានការប្រកាសអំពីកុមារនៅពេលកើតនឹងចូលជាធរមាន ហើយអ្វីខ្លះនឹងត្រូវបានធ្វើនៅពេលនេះ ដោយហេតុថាកុមារត្រូវតែបានចុះ

បញ្ជីប្រសិនបើកុមារនោះត្រូវបានគេដាក់បញ្ចូលក្នុងគោលនយោបាយណាមួយ ឬដែលត្រូវបានគ្រប់គ្រងដោយវិធានការណាមួយ ដែលក្នុងនោះអាយុគឺជាលក្ខខណ្ឌ ។

៤៩- លោកស្រី **Tigertedt-Tahtela** បានសួរថាតើសៀវភៅគ្រួសារ និងសៀវភៅស្នាក់នៅដែលមាននិយាយក្នុង របាយការណ៍ គឺជាប្រភេទនៃឯកសារចុះបញ្ជីកុមារឬ? ។ តាមការឱ្យដឹងសៀវភៅនេះត្រូវបានចេញឱ្យសំរាប់ក្មេងកើតនៅក្នុងមន្ទីពេទ្យក្នុងក្រុងភ្នំពេញ។ តើការរៀបចំបែបនេះអាចត្រូវបានពង្រីកដល់ទីកន្លែង ទាំងឡាយផ្សេងទៀតក្នុងប្រទេសដែរឬទេ? ។ តើនឹងអាចមានលទ្ធភាពដើម្បីចុះបញ្ជីកំណើតក្នុងតំបន់ដាច់ស្រយាល នានាក្នុងប្រទេសដែរឬទេ? តើប្រទេសមានធនធានមនុស្សគ្រប់គ្រាន់ដើម្បីធ្វើកិច្ចការនេះដែរឬទេ ?

៥០- លោកស្រី **Mokhuane** បានមានប្រសាសន៍ថា លោកស្រីចង់ដឹងថាតើតាមការជាក់ស្តែងអាជ្ញាធរ និងមន្ត្រីសាធារណៈទាំងឡាយកំណត់អត្តសញ្ញាណ និងអាយុរបស់កុមារយ៉ាងដូចម្តេច សំរាប់បំរើឱ្យគោលបំណង ដូចជាក្នុងដំណើរការក្តីតាមផ្លូវច្បាប់យុត្តិធម៌អនីតិជន ឬការអប់រំជាដើម។ លោកស្រីមានចំងល់ថាតើទស្សនៈ របស់កុមារត្រូវបានគេយកមកពិចារណាដាក់ក្នុងការធ្វើផែនការសេវាកម្មដើម្បីឱ្យពួកគេបានទទួលប្រយោជន៍ និង ក្នុងការបង្កើតគោលនយោបានយ៉ាងដូចម្តេចដែរ? ។

អង្គប្រជុំសំរាកនៅម៉ោង ១២:២៥ នាទីល្ងាច ហើយចាប់ដំណើរការវិញនៅម៉ោង ១២:៣៥នាទីល្ងាច

៥១- លោកអ៊ឹម សិទ្ធី (កម្ពុជា) បានបញ្ជាក់ថាចំនួនថវិការរបស់រដ្ឋសំរាប់បំរើឱ្យវិស័យការពារ និងសន្តិសុខ មិនអាចត្រូវបានកាត់បន្ថយដោយគំហុកបានទេ ប៉ុន្តែការសន្សំប្រាក់ពីវិស័យនេះនឹងត្រូវបានតំរង់ទិសឆ្ពោះទៅវិស័យសង្គមកិច្ចហើយហេតុដូច្នេះក៏នឹងធ្វើឱ្យកុមារទទួលបានប្រយោជន៍ផងដែរ ។

៥២- ករណីនៃអំពីហោរឃៅដោយនគរបាល ពុំមែនចេញមកពីរដ្ឋាភិបាល ឬគោលនយោបាយរបស់នគរបាលទេ ប៉ុន្តែនោះគឺជាអំពើប្រព្រឹត្តឡើយដោយបុគ្គល។ អាជ្ញាធរបានកំពុងធ្វើកិច្ចខិតខំដ៏ធំសម្បើមដោយសហការជាមួយអង្គការក្រៅរដ្ឋាភិបាលយ៉ាងសកម្មដើម្បីបណ្តុះបណ្តាលមន្ត្រីនគរបាលនិងសមាជិកនៃសេវាកម្មសន្តិសុខឱ្យទទួលស្គាល់ និងគោរពសិទ្ធិមនុស្សច្បាប់ និងបទបញ្ញត្តិផ្សេងៗ ។

៥៣- វិធានការនានាកំពុងត្រូវបានចាត់ឡើងដើម្បីធ្វើឱ្យប្រសើរឡើងវិញ នូវការប្រព្រឹត្តិចំពោះជនល្មើសដែលជាអនីតិជន។ ពន្ធនាគារដែលមានសភាពទ្រុឌទ្រោមត្រូវបានកំទេចចោល ហើយពន្ធនាគារថ្មីជាច្រើនត្រូវបានសាងសង់ឡើយដោយមានជំនួយមួយផ្នែកមកពីអង្គការអន្តរជាតិ និង ប្រទេសផ្សេងៗមួយចំនួន ជាពិសេសប្រទេសអូស្រ្តាលី។ នៅក្នុងទីក្រុងភ្នំពេញអ្នកជាប់ឃុំក្មេងៗ ត្រូវបានដាក់ឱ្យនៅដោយឡែកពីមនុស្សចាស់។ មជ្ឈមណ្ឌលខ្លះសំរាប់ដាក់ជនល្មើសដែលជាអនីតិជន បានបំរើជាមជ្ឈមណ្ឌល សំរាប់ធ្វើការបណ្តុះបណ្តាលវិជ្ជាជីវៈ គោលបំណង់នេះគឺដើម្បីបង្កលក្ខណៈងាយស្រួលដល់អ្នកជាប់ឃុំ អាចវិលត្រឡប់ទៅកាន់ជីវភាពក្នុងសង្គមវិញបាន។ ស្ថានភាពឃុំឃាំងជនល្មើសជាអនីតិជននៅតាមខេត្តនៅតែមានលក្ខណៈមិនសូវល្អដូចនៅក្នុងទីក្រុងទេ ។

៥៤- រដ្ឋធម្មនុញ្ញ និងច្បាប់កម្ពុជាហាមឃាត់មិនឱ្យមានការរើសអើងពូជសាសន៍គ្រប់ប្រភេទ។ រដ្ឋធម្មនុញ្ញពិតជាបាននិយាយយោងទៅដល់ពាក្យថា "ប្រជាពលរដ្ឋខ្មែរ" ប៉ុន្តែការប្រើពាក្យនេះតាមពិតទៅមានន័យសំដៅលើក្រុមជាតិពន្ធទាំងអស់ដែររស់នៅក្នុងប្រទេសកម្ពុជា ដែលក្នុងនោះក៏មានប្រជាពលរដ្ឋអប្បរភាគ ជនអន្តោប្រាមមួយចំនួន ដែលរស់នៅភាគឦសាន្តនៃប្រទេសភាគច្រើននោះដែរ។ សមាជិកនៃក្រុមអប្បរភាពជនទាំងនោះគឺជាប្រជាពលរដ្ឋពេញសិទ្ធិ។ ពួកគេបានចុះឈ្មោះបោះឆ្នោត ហើយបានបោះឆ្នោតនៅក្នុងការបោះឆ្នោតចំនួន២លើក ចុងក្រោយនេះ។ ពួកគេបានទទួលជំនួយមកពីអង្គការក្រៅរដ្ឋាភិបាល និងរាជ

រដ្ឋាភិបាលកម្ពុជា។ មានសមាគមន៍នានាជាច្រើនបានកំពុងធ្វើការដើម្បីធ្វើឱ្យវប្បធម៌របស់ពួកគេរស់រានឡើងវិញ។ ក្រុមជនជាតិវៀតណាមបានរស់នៅក្នុងប្រទេសនេះជាយូរមកហើយៗពួកគេគឺជាប្រជាពលរដ្ឋកម្ពុជា ដូចអ្នកផ្សេងទៀតដែរ។ ជាអកុសលមានក្រុមអធិមុត្ត និង ក្រុមជ្រុលនិយមមួយចំនួន ហើយក៏មានគណបក្សនយោបាយខ្លះដែរ បានគាំទ្រដល់ការរើសអើងនេះ ។

៥៥- ក្រុមដែលទទួលបានការបណ្តុះបណ្តាលខាងការបោសសំអាតមីនយ៉ាងចំណាន បានចំពេញកិច្ចការដ៏ធំសម្បើម ដោយមានជំនួយពីជំនាញការបរទេស និងជំនួយឧបត្ថម្ភពីប្រទេសជាច្រើន។ បច្ចេកទេសចុងក្រោយបង្អស់នេះកំពុងត្រូវបានប្រើប្រាស់ក្នុងតំបន់ដាច់ស្រយាល ដើម្បីកំណត់រកតំបន់ដែលមានមីន ហើយផ្លាកសញ្ញាសំគាល់កំពុងត្រូវបានលើកឡើងដើម្បីសំគាល់តំបន់ដែលមានគ្រោះថ្នាក់ ។

៥៦- មានភាពខុសគ្នាជាច្រើនរវាងបុរស និងស្ត្រីនៅក្នុងប្រទេសកម្ពុជា ប៉ុន្តែពុំមានការរើសអើងឡើង។ នោះនឹងជេរបញ្ច្រាសទិសទៅនឹងគោលការណ៍ខន្តីដែលមានចែងក្នុងទ្រឹស្តីព្រះពុទ្ធ ដែលត្រូវបានគោរពប្រតិបត្តិយ៉ាងទូលំទូលាយនៅទូទាំងប្រទេស។ បញ្ហាទាំងឡាយកើតឡើងពីបញ្ហានៃឥរិយាបទ។ ឧទាហរណ៍ឪពុកម្តាយពុំអាចមើលឃើញហេតុផលណាសំរាប់កូនស្រីរបស់ពួកគេដើម្បីចូលរៀននៅសាលា ឬបន្តការសិក្សារបស់ពួកគេឡើង ដោយសារថាពួកគេនឹងត្រូវរៀបអាពាហ៍ពិពាហ៍។ ប៉ុន្តែស្ថានភាពនេះបានផ្លាស់ប្តូរហើយៗ កិច្ចខិតខំនានាកំពុងត្រូវបានធ្វើឡើងដើម្បីធ្វើឱ្យសហគមន៍ និងឪពុកម្តាយមានការយល់ដឹងអំពីសេចក្តីត្រូវការជាចាំបាច់ដើម្បីប្រព្រឹត្តចំពោះក្មេងស្រី ក្នុងលក្ខណៈដូចគ្នានឹងក្មេងប្រុសដែរ ។

៥៧- កម្ពុជាបានបង្កើតឡើងនូវអាជ្ញាធរមួយដើម្បីប្រយុទ្ធប្រឆាំងនឹងជំងឺអេដស៍ ដោយធ្វើការជាមួយក្រសួងពាក់ពន្ធ័ផ្សេងៗ។ វិធានការនានាត្រូវបានចាត់ឡើងដើម្បីផ្សព្វផ្សាយពត៌មានអំពីជំងឺនេះ ជាផ្នែកមួយនៃកម្មវិធីសិក្សានៅសាលារៀន និងដើម្បីបណ្តុះបណ្តាលគ្រូបង្រៀន។ ការបង្ការគឺជាការសំខាន់បំផុត។ ក្រសួងសុខាភិបាលបានកំពុងធ្វើកិច្ចសហប្រតិបត្តិការជាមួយអង្គការអន្តរជាតិនានា ក្នុងការនាំយកជំនួយទៅឱ្យស្ត្រីមានផ្ទៃពោះ ដែលមេរោគអេដស៍ និងទៅឱ្យកូនរបស់ពួកគេ ។

៥៨-កុមារមិនទាន់ក្លាយទៅជាពលរដ្ឋពេញសិទ្ធិនៅឡើយទេរហូតដល់អាយុ១៨ឆ្នាំ។ កម្ពុជាមិនទាន់មានវេទិកាសំរាប់កុមារនៅឡើយ ប៉ុន្តែមានកិច្ចប្រជុំជាច្រើនត្រូវបានធ្វើឡើង ហើយកុមារត្រូវបានអញ្ជើញឱ្យចូលរួមដើម្បីថ្លែងសន្ទរកថានៅក្នុងនោះ។ យោងទៅតាមប្រពៃណីកុមារត្រូវស្តាប់ចាស់ទុំ ប៉ុន្តែស្ថានភាពនេះបានកំពុងផ្លាស់ប្តូរ ហើយប្រជាពលរដ្ឋកម្ពុជាភាគច្រើនយល់ថាពួកគេត្រូវតែស្តាប់កុមារផងដែរ។

៥៩- ពុំទាន់មានច្បាប់ស្តីពីការចុះបញ្ជីកំណើតឱ្យបានត្រឹមត្រូវនៅឡើយទេ ការអនុវត្តដែលបានធ្វើកន្លងមក គឺធ្វើទៅតាមសារាចរណ៍ណែនាំរបស់ក្រសួងមហាផ្ទៃស្តីពីសៀវភៅគ្រួសារ។ បច្ចុប្បន្ននេះវិញ្ញាបនបត្រ័កំណើត ត្រូវបានចេញឱ្យទារកទើបកើតថ្មីៗនេះភាគច្រើន។ នៅខណៈពេលដែលពួកខ្មែរក្រហមកាន់កាប់អំណាច ឯកសារចុះបញ្ជីឈ្មោះប្រជាពលរដ្ឋភាពច្រើនត្រូវបានដុតបំផ្លាញចោល។ ប្រពន្ធ័ដែលត្រូវបានអនុវត្តពេលបច្ចុប្បន្ននៅទូទាំងប្រទេស គឺត្រូវរៀបចំសំណុំឯកសារ ដែលមានចុះលំនៅដ្ឋានជាក្រុមៗ ដោយមានឈ្មោះមេគ្រួសារ ភរិយា និងកូនរបស់ពួកគេ ព្រមទាំងមនុស្សផ្សេងទៀតដែលរស់នៅជាមួយផង។ ច្បាប់ស្តីពីការចុះបញ្ជីប្រជាពលរដ្ឋ ពិតជានឹងត្រូវបានអនុម័ត។ ប្រសិនបើឯកសារចុះបញ្ជីប្រជាពលរដ្ឋណាម្នាក់ ត្រូវបានបំផ្លាញអាយុរបស់គាត់ ត្រូវបានបញ្ជាក់ដោយការអះអាងដោយបុគ្គលដែលពាក់ពន្ធ័។ បញ្ហានៃការផ្លាស់ប្តូរអាយុដែលបានអះអាងនេះត្រូវតែធ្វើឡើងនៅចំពោះមុខតុលាការ។

៦០- អាជ្ញាធរបានយល់ដឹងអំពីតំលៃនៃសកម្មភាពក្រៅម៉ោងសិក្សាថា ជាមធ្យោបាយមួយក្នុងការធ្វើឱ្យការវិវត្តន៍របស់កុមារមានការរីកចំរើន។ មជ្ឈមណ្ឌលយុវជន កីឡា និងវប្បធម៌ ត្រូវបានបង្កើតឡើងហើយ ប៉ុន្តែបានប្រឈមមុខនឹងបញ្ហាជាច្រើន

ដោយសារតែការខ្វះនូវធនធាន ។ នៅគ្រប់កាលៈទេសៈទាំងអស់ ការចុះឈ្មោះកុមារចូលរៀនគឺនៅតែត្រូវបានចាត់ថាជាអាទិភាព ពីព្រោះកម្ពុជាពុំបានលាក់បាំងនូវអង្គហេតុដែលថា កុមារដែលមានអាយុត្រូវចូលរៀនចំនួនស្មើរតែ៤០០.០០០នាក់ មិនបានចូលសាលារៀនឡើយ ។

<u>អង្គប្រជុំត្រូវបានបញ្ចប់នៅម៉ោង ០១ :០០ នាទីល្ងាច ។</u>

*កំណត់ហេតុនេះ អាចត្រូវធ្វើការកែតំរូវបាន*

ការកែតំរូវទាំងឡាយត្រូវតែបានដាក់ជូនជាភាសាមួយក្នុងចំណោមភាសាផ្លូវការទាំងឡាយ ។ ការកែតំរូវត្រូវតែធ្វើឡើងក្នុងអនុស្សរណៈ ហើយត្រូវដាក់បញ្ចូលទៅក្នុងកំណត់ហេតុនោះ ។ ការកែតំរូវនេះ ត្រូវតែបានបញ្ជូនក្នុងរយៈពេល១ សប្តាហ៍ បន្ទាប់ពីកាលបរិច្ឆេទនៃឯកសារនេះ មកកាន់ផ្នែកបោះពុម្ពផ្សាយកំណត់ហេតុផ្លូវការ ដែលមានអាស័យដ្ឋានដូចខាងក្រោម :

The Official Record Editing Section,
room E.4108, Palais des Nations, Geneva.

ការកែតំរូវចំពោះកំណត់ហេតុជាផ្លូវការណាមួយ នៃកិច្ចប្រជុំសាធារណៈរបស់គណៈកម្មាធិការនៅឯសម័យប្រជុំនេះ នឹងត្រូវដាក់រួមបញ្ចូលទៅជាសៀវភៅមួយក្បាល ដែលនឹងត្រូវចេញផ្សាយភ្លាម១បន្ទាប់ពីសម័យប្រជុំត្រូវបានបញ្ចប់ហើយ ។

អង្គប្រជុំត្រូវបានបើកនៅម៉ោង ០៣:០៥នាទី រសៀល

ការពិនិត្យពិចារណាលើរបាយការណ៍នៃរដ្ឋជាភាគី (របៀបវារៈទី៤) (ត)

របាយការណ៍លើកដំបូងរបស់កម្ពុជា (ត) **(CRC/C/11/Add.16; CRC/C/Q/CAM/1;** ការឆ្លើយតបជាលាយលក្ខ័អក្សររបស់រាជរដ្ឋាភិបាលកម្ពុជាចំពោះសំនួរទាំងឡាយដែលបានលើកឡើងក្នុងបញ្ជី បញ្ហា (ឯកសារជាភាសាអង់គ្លេសតែមួយមុខដែលគ្មានសញ្ញានិមិត្តរូបត្រូវបានចែកចាយក្នុងអង្គប្រជុំ)) ។

១- តាមការអញ្ជើញរបស់ប្រធានអង្គប្រជុំគណៈប្រតិភូកម្ពុជាបានចូលទៅកាន់ទីកន្លែងប្រជុំរៀង១ខ្លួន នៅឯតុរបស់គណៈកម្មាធិការ ។

២- លោកស្រីប្រធានអង្គប្រជុំ បានអញ្ជើញសមាជិកនៃគណៈកម្មាធិការឱ្យចាប់ផ្តើមសួរសំនួរ ដែលទាក់ទងនឹងបរិស្ថាន គ្រួសារ និងការថែទាំដែលអាចជ្រើសរើសបាន សុខភាព សុខុមាលភាព និងការអប់រំជាមូលដ្ឋាន ព្រមទាំងសកម្មភាពលំហែកាយ និងវប្បធម៌ផ្សេង១ ។

៣- លោកស្រី **TIGERSTEDT-TAHTELA** បានមានប្រសាសន៍ថា គណៈប្រតិភូបានទទួលដឹងលឺនូវករណីមួយចំនួនស្តីពីអំពើឃោរឃៅរបស់នគរបាល ប៉ុន្តែបាននិយាយថាការប្រព្រឹត្តបែបនេះមិនត្រូវបានរាជរដ្ឋាភិបាលកម្ពុជាអនុសញ្ញាតិយល់ព្រមឡើយ ។ តើរាជរដ្ឋាភិបាលកម្ពុជាមិនមានការទទួលខុសត្រូវចំពោះសកម្មភាពរបស់នគរបាល និងអាជ្ញាធរពន្ធនាគារ និងអាជ្ញាធរផ្សេងទៀតដែរ ឬយ៉ាងណា ?

៤- ពត៌មានពិស្តារ ត្រូវបានគេផ្តល់មកឱ្យស្តីពីផែនការ និងយុទ្ធសាស្ត្រខាងសុខាភិបាល ។ ប៉ុន្តែលោកស្រីនៅតែឆ្ងល់ថាតើប្រជាពលរដ្ឋចំនួន៣៨% ដែលកំពុងរស់នៅក្រោមខ្សែបន្ទាត់នៃភាពក្រីក្រ បានទទួលនូវសេវាសុខាភិបាលដែរឬទេ ដោយយោងទៅលើការថែទាំ និងការព្យាបាលសុខភាពដែលមានតំលៃថ្លៃនោះ ។ លោកស្រីចង់ដឹងថាតើរដ្ឋាភិបាលកំពុងតែផ្តួចផ្តើមឱ្យមានសេវា បំរើសុខភាពដោយឥតគិតថ្លៃជូនដល់ប្រជាពលរដ្ឋក្រីក្រដែរ ឬទេ ។

៥- លោក **RABAH** បានមានប្រសាសន៍ថា គណៈកម្មាធិការបានទទួលដំណឹងថា ស្ថាប័នថែទាំកុមារត្រូវបានគ្រប់គ្រងដោយរាជរដ្ឋាភិបាល ឬដោយអង្គការក្រៅរដ្ឋាភិបាល ។ គាត់ចង់បាននូវពត៌មានបន្ថែមស្តីពីថាតើស្ថាប័នទាំងនោះ ត្រូវបានគ្រប់គ្រងយ៉ាងណា និងស្តីពីសហប្រតិបត្តិការរវាងរដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាលពាក់ព័ន្ធនឹងបញ្ហានេះ ។ គាត់ក៏មានការព្រួយបារម្ភអំពីស្ថានភាពរបស់កុមារ ដែលមិនត្រូវបានគេដាក់ចូលក្នុងស្ថាប័នទាំងនោះផងដែរ ។

៦- គាត់សូមទទួលស្វាគមន៍នូវពត៌មានបន្ថែមអំពីស្ថាប័ន ដែលផ្តល់ការថែទាំដោយឪពុកម្តាយធម៌ ។ តើមានឧបសគ្គទេ ដើម្បីបង្កើតនីតិកម្ម ដែលនឹងគ្រប់គ្រងនូវស្ថាប័នថែទាំដោយឪពុកម្តាយធម៌នេះ ដើម្បីផលប្រយោជន៍ដ៏ឧត្តុង្គឧត្តមរបស់កុមារ ? ។

៧- __លោកស្រី MOKHUANE__ បាននិយាយថា យោងទៅតាមប្រភពមួយចំនួនអធិការកិច្ចលើផាសុកូបករណ៍ខាងការថែទាំដែលអាចជ្រើសរើសយកបាន មិនត្រូវបានគេធ្វើឡើងឱ្យបានទៀតទាត់នោះទេ។ លោកស្រីនឹងមានសេចក្តីរីករាយ និងដឹងគុណប្រសិនបើបានទទួលនូវពត៌មានស្តីពីយន្តការផ្សេងៗ ដែលរាជរដ្ឋាភិបាល បានប្រើដើម្បីតាមដានមើលឱ្យបានទៀងទាត់នូវការថែរក្សាដែលអាចជ្រើសរើសបាននេះ រួមបញ្ចូលទាំងដំណើរការប្រព្រឹត្តទៅនៃទំនាក់ទំនងខាងការធ្វើសេចក្តីរាយការណ៍ ។

៨- __លោក DOEK__ បាននិយាយថាលោកមានសេចក្តីរីករាយ និងអរគុណប្រសិនបើបានទទួលពត៌មានបន្ថែមស្តីពីការសុំកូនមកចិញ្ចឹមឆ្លងប្រទេស ហើយបានសួរថាតើកម្ពុជាកំពុងតែគិតគូរឱ្យសច្ចានុមត័លើអនុសញ្ញាទីក្រុងឡាអេ ស្តីពីការការពារកុមារ និងសហប្រតិបត្តិការដែលពាក់ព័ន្ធនឹងការសុំកូនមកចិញ្ចឹមឆ្លងប្រទេសនេះដែរឬទេ។ យោងទៅតាមរបាយការណ៍ដំបូងរបស់កម្ពុជា **(CRC/C11/Add.16)** មានកុមារចំនួនតិចណាស់ ដែលត្រូវបានប្រជាពលរដ្ឋខ្មែរសុំយកមកចិញ្ចឹមធ្វើជាកូន។ ប៉ុន្តែការសុំកូនមកចិញ្ចឹមក្រៅផ្លូវការហាក់ដូចជាបានកើតមានឡើង។ គាត់មានការងឿងឆ្ងល់ថា តើការសុំកូនមកចិញ្ចឹមបែបនេះបានពាក់ព័ន្ធជាមួយកុមារចំនួនប៉ុន្មាននាក់ហើយ ហើយថាតើរាជរដ្ឋាភិបាលបានតាមដានមើលការសុំកូនមកចិញ្ចឹមមិនផ្លូវការនេះដែរឬ។ តើរាជរដ្ឋាភិបាលមានបានគិតគូរដល់ការបង្កើតឱ្យមានបទបញ្ញត្តិក្នុងរឿងនេះ ឱ្យមានប្រសិទ្ធភាពថែមទៀតដើម្បីជាផលប្រយោជន៍ដ៏ឧត្តុង្គឧត្តមដល់កុមារដែរឬទេ ? ។

៩- យោងទៅតាមរបាយការណ៍ ការដាក់ទណ្ឌកម្មលើរូបកាយដែលតែងតែមានឡើងក្នុងគ្រួសារ បានកើតឡើងយ៉ាងរាលដាលក្នុងប្រទេសកម្ពុជា ។ គាត់មានការងឿងឆ្ងល់ថា តើរដ្ឋាភិបាលមានគោលបំណងនឹងធ្វើការ សិក្សាស្រាវជ្រាវលើការរំលោភ និងការមិនយកចិត្តទុកដាក់លើការងារនៅថ្នាក់គ្រួសារជាពិសេសដោយសារថា ការមិនយកចិត្តទុកដាក់នេះ មានការពាក់ព័ន្ធយ៉ាងច្បាស់ទែងនឹងការបោះបង់ចោលនូវកុមារដែរឬយ៉ាង។ តើរាជរដ្ឋាភិបាលកម្ពុជាមានផែនការ ដើម្បីអប់រំឪពុកម្តាយ ស្តីពីអំពើហឹង្សាលើរូបរាងកាយដែលពួកគេបានប្រព្រឹត្ត ទៅលើកុមារ ឬដើម្បីហាមឃាត់នូវការដាក់ ទណ្ឌកម្មលើរូបរាងកាយដែរឬទេ ? ។

១០- __លោកស្រី RILANTONO__ បាននិយាយថា លោកស្រីមានការងឿងឆ្ងល់ជាខ្លាំងអំពីអត្រាមរណភាពរបស់ទារកដែលមានចំនួនចេះតែកើនឡើងនេះ ព្រោះថារាជរដ្ឋាភិបាលបានអនុវត្តប្រកបដោយជោគជ័យនូវកម្មវិធីចាក់ថ្នាំបង្ការជំងឺស្វិតដៃជើងរួចមកហើយ។ លោកស្រីមានការងឿងឆ្ងល់ថាតើវ៉ាក់សាំងទាំងឡាយត្រូវបានគេនាំចូលដែរឬ ហើយថាតើជំនួយត្រូវបានផ្តល់ឱ្យដោយមូលនិធិរបស់អង្គការសហប្រជាជាតិដើម្បីកុមារ **(UNICEF)** ឬអង្គការសុខភាពពិភពលោក **(WHO)** ក្នុងការទទួលបាននូវវ៉ាក់សាំងទាំងនេះដែរឬទេ?។ ដោយកត់សំគាល់ថាឧប្បត្តិហេតុជំងឺអេដស៍**(AIDs)** បានកំពុងកើនឡើង លោកស្រីបានស្នើរសុំពត៌មានបន្ថែម ស្តីពីផែនការយុទ្ធសាស្ត្រ ២ឆ្នាំ ដែលត្រូវបានអនុវត្តដោយមជ្ឈមណ្ឌលជាតិកំចាត់ហ៊ីវ **(HIV)** ហើយបានសួរថាតើមជ្ឈមណ្ឌលនេះរួមបញ្ចូលទាំងករណីនៃការប្រើថ្នាំញៀនដែរ ឬទេ ។ លោកស្រីក៏បានសួរអំពីការថែទាំដែលត្រូវផ្តល់ជូនដល់កុមារដែលឪពុកម្តាយរបស់គេមានផ្ទុកមេរោគហ៊ីវ ទាក់ទិនទៅនឹងបញ្ហានៃការចម្លងមេរោគនេះ ។

__កិច្ចប្រជុំត្រូវបានឈប់សំរាកនៅម៉ោង ០៣:១៥នាទីរសៀល ហើយបន្តវិញនៅម៉ោង ០៣:២៥នាទី រសៀល__

១១- __លោកស្រី HARANVADDEY__ (កម្ពុជា) បានបញ្ជាក់សារជាថ្មីថា រាជរដ្ឋាភិបាលកម្ពុជា មិនបានអនុញ្ញាតិឱ្យមានអំពើឃោរឃៅដោយនគរបាលឡើយ។ ស្ថានទូតអូស្ត្រាលីប្រចាំកម្ពុជា បានកំពុងជួយធ្វើការបណ្តុះបណ្តាលដល់មន្ត្រីនគរបាលក្នុងគោលបំណងដើម្បីពង្រឹងនូវសមត្ថភាពរបស់ពួកគេ ដើម្បីការពារកុមារប្រឆាំងនឹងអំពើហឹង្សា និងដើម្បីធានាថាសិទ្ធិរបស់កុមារត្រូវ

គោរព។ លើសពីនេះទៀត ក្រសួងមហាផ្ទៃបានចុះហត្ថលេខាលើកិច្ចព្រមព្រៀងមួយជាមួយអង្គការអន្តរជាតិនានា រួមមាន អង្គការ (UNICEF) អង្គការការងារអន្តរជាតិ (ILO) និងអង្គការអន្តរជាតិសំរាប់អន្តោប្រវេសន៍ (IOM) ស្តីពីការការពារកុមារ និងការបណ្តុះបណ្តាលនគរបាលក្នុងបញ្ហានៃសិទ្ធិរបស់កុមារ ។

១២- នាយកដ្ឋានព្រហ្មទណ្ឌនៃក្រសួងមហាផ្ទៃ កំពុងតែពិនិត្យមើលលើលទ្ធភាពនៃយន្តការមួយ សំរាប់ការការពារសិទ្ធិរបស់កុមារ ។ នាយកដ្ឋាននេះ នឹងបង្កើតឡើងនូវអង្គភាពមួយក្នុងពេលឆាប់ៗនេះ ដែលមានជំនាញក្នុងការពារកុមារប្រឆាំងនឹងការជួញដូរ ក្នុងការអនុវត្តតាមអនុសាសន៍ដែលមានផែនការសកម្មភាព៥ឆ្នាំ ប្រឆាំងនឹងការជួញដូរផ្លូវភេទលើកុមារ ដែលអភិវឌ្ឍន៍ឡើងដើម្បីឆ្លើយតបនឹងសន្និបាតនាទីក្រុងស្តុកខុលម៍ ។ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ (CNCC) នឹងអង្គការ (UNICEF) បានកំពុងតែធ្វើការរួមគ្នាជាមួយក្រសួងមហាផ្ទៃ ដើម្បីបង្កើតនូវការិយាល័យមួយសំរាប់ការពារសិទ្ធិកុមារ ដែលការិយាល័យនេះត្រូវបានរំពឹងថានឹងចាប់ផ្តើមដំណើរការក្នុងឆ្នាំ ២០០០ ។

១៣- ចូលដល់បញ្ហាសុខាភិបាល លោកស្រីបានមានប្រសាសន៍ថា រាជរដ្ឋាភិបាលកម្ពុជាបានទទួលស្គាល់នូវការខ្វះសេវាសុខាភិបាលឱ្យបានគ្រប់គ្រាន់នូវតាមសហគមន៍។ បញ្ហានេះទាក់ទងនឹងការលំបាកក្នុងការទទួលបានសារជាថ្មីនូវការផ្គត់ផ្គង់ថ្នាំពេទ្យច្រើនជាងការខ្វះខាតនូវបុគ្គលិក ។ ដូច្នេះហើយ រាជរដ្ឋាភិបាលបានផ្តោតទៅលើការអភិវឌ្ឍនូវផែនការ និងយុទ្ធសាស្ត្រនៃការកសាងសមត្ថភាព។ រដ្ឋាភិបាលស្វីសដោយមានការជួយឧត្ថម្ភដោយអង្គការក្រៅរដ្ឋាភិបាលបានកសាងនូវមន្ទីរពេទ្យដ៏ធំមួយ ដែលបានផ្តល់សេវាកម្មសំរាប់ជនក្រីក្រ ។

១៤- ឆ្លើយតបទៅលោក **RABAH** លោកស្រីបានមានប្រសាសន៍ថា ក្នុងករណីនៃស្ថាបន័ថែទាំកុមារ ដែលចាត់ចែងរួមគ្នាដោយរដ្ឋាភិបាលកម្ពុជា និងអង្គការក្រៅរដ្ឋាភិបាលរដ្ឋាភិបាលបានផ្តល់នូវបុគ្គលិក និងហិរញ្ញប្បទាន។ ដោយសារវិភាគទានរបស់ខ្លួនមានចំនួនត្រឹមតែប្រហែលជា១០ដុល្លា ក្នុងមួយខែប៉ុណ្ណោះ ដូច្នេះជំនួយឧបត្ថម្ភបន្ថែមទៀត ដោយអង្គការក្រៅរដ្ឋាភិបាលគឺត្រូវតែមានជាការចាំបាច់ ។ ស្ថាបន័ដែលគ្រប់គ្រង់ដោយអង្គការក្រៅរដ្ឋាភិបាលតែឯង ត្រូវបានផ្តល់បុគ្គលិក និង ហិរញ្ញប្បទាន ដោយអង្គការក្រៅរដ្ឋាភិបាលទាំងនោះ។ ក្នុងករណីខ្លះ កិច្ចខិតខំនៃអន្តរអង្គការក្រៅរដ្ឋាភិបាល ត្រូវរដ្ឋាភិបាលជួយឧបត្ថម្ភដែរ ។

១៥- ការថែទាំដោយប្រព័ន្ធឪពុកម្តាយធម៌ នៅមិនទាន់ត្រូវបានធ្វើឱ្យមាននិយត័នៅឡើយទេ។ ស្ថាបន័ដែលគ្រប់គ្រង់ដោយអង្គការក្រៅរដ្ឋាភិបាល បានធ្វើសេចក្តីរាយការណ៍ជូនទៅនាយកដ្ឋានសុខុមាលភាពកុមារ នៃក្រសួងសង្គមកិច្ចរៀងរាល់៣ខែម្តង ហើយនាយកដ្ឋានអធិការកិច្ចខេត្តក៏បានធ្វើសេចក្តីរាយការណ៍ជូននាយកដ្ឋានសុខុមាលភាពកុមារនេះផងដែរ។ ការិយាល័យថែទាំកុមារនៃនាយកដ្ឋានសុខុមាលភាពកុមារ ជាអ្នកទទួលបន្ទុកលើការពិនិត្យតាមដានមើលលើស្ថាបន័ទាំងអស់នោះ ។

១៦- ការសុំកូនចិញ្ចឹមអន្តរប្រទេសកើតមានឡើងច្រើនជាងការសុំកូនចិញ្ចឹមក្នុងស្រុកឆ្ងាយណាស់ ពីព្រោះជនបរទេសមានបំណងច្រើនជាងជនជាតិកម្ពុជាក្នុងការយកកុមារដែលមានពិការភាព ឬសូម្បីតែមានផ្ទុកមេរោគហ៊ីវក៏ដោយមកធ្វើជាកូនចិញ្ចឹម ហើយមានលទ្ធភាពប្រសើរជាងក្នុងការចេញប្រាក់សំរាប់ការព្យាបាលកុមារទាំងនោះ។ ពុំមានច្បាប់ស្តីពីការសុំកូនចិញ្ចឹមឡើយ ប៉ុន្តែនីតិវិធីបណ្តោះអាសន្នមានមកហើយ។ ការសិក្សាស្រាវជ្រាវនៅតាមគេហដ្ឋានត្រូវបានគេអនុវត្តធ្វើឡើងទៅលើជនដែលទំនង និងជាឪពុកម្តាយចិញ្ចឹមដែលត្រូវតែអនុវត្តលក្ខខណ្ឌមួយចំនួន ដែលទាក់ទងទៅនឹងដូចជាប្រាក់ចំណូល និងការមានភាពល្អជាដើម។ ការិយាល័យថែទាំកុមារ បានពិនិត្យមើលឡើងវិញទៅលើឯកសារទាំងនេះ មុនពេលបញ្ជូនទៅកាន់ក្រសួងសង្គមកិច្ច ដែលពឹងផ្អែកលើបទពិសោធន៍ពីស្ថាបន័ផ្សេងៗ និង អាជ្ញាធរក្រុង។ បន្តមកមន្ត្រីកម្ពុជាបានធ្វើដំណើរទៅសួរសុខទុក្ខកុមារ ដែលត្រូវបានសុំធ្វើជាកូនចិញ្ចឹមនៅឯបរទេស ដើម្បីធានាថាជាល័ក្ខខ័ណ្ឌទាំងអស់ត្រូវបានគេបំពេញ ពុំមានការសិក្សាស្រាវជ្រាវ ត្រូវបានធ្វើឡើងលើការដាក់ទណ្ឌកម្មលើរាងកាយនៅឡើយទេ។

១៧- លោក **SETHY** (កម្ពុជា) ដែលមានប្រសាសន៍ថា ការធ្វើឱ្យប្រសើរឡើងនានាត្រូវបានធ្វើឱ្យមាន ហើយក្នុងវិស័យ សុខាភិបាល រាប់បញ្ចូលទាំងគំរោងការអនាម័យសាធារណៈ ប៉ុន្តែថាកិច្ចខិតខំទាំងឡាយត្រូវបានកំរិតដោយឧបសគ្គខាងថវិកា។ ការថែទាំសុខាភាពដោយមិនយកថ្លៃ ត្រូវបានផ្តល់ឱ្យនៅទីជនបទ ប៉ុន្តែទោះជាមានជំនួយត្រូវបានផ្តល់ឱ្យរដ្ឋាភិបាលបរទេសនិងអង្គការក្រៅរដ្ឋាភិបាលក៏ដោយ ការផ្គត់ផ្គង់ថ្នាំពេទ្យឱ្យបានពេញលេញនៅតែជាបញ្ហាមួយដែលបានជួបប្រទះឥតឈប់ឈរ ។

១៨- អំពើហិង្សាក្នុងគ្រួសារមិនមែនជាបញ្ហាធំដុំនៅក្នុងប្រទេសកម្ពុជាទេ ថ្វីបើអំពើនេះពិតជាបានកើតមានមែនក៏ដោយ។ រដ្ឋាភិបាលបានព្យាយាមធ្វើឱ្យប្រជាពលរដ្ឋមានការយល់ដឹងពីបញ្ហានេះ តាមរយៈយុទ្ធនាការផ្សព្វផ្សាយតាមវិទ្យុ និង ទូរទស្សន៍ ។

១៩- កម្មវិធីចាក់ថ្នាំការពារដ៏ធំទូលាយមួយ ដែលផ្តោតទៅលើជំងឺ៦មុខ បានគ្របដណ្តប់លើកុមារទូទាំងប្រទេស ចំនួនច្រើនជាង ៧០%។ វាគឺជាការពិតដែលថាយុទ្ធនាកាប្រឆាំងជំងឺស្វិតដៃជើងដែលបានទទួលជោគជ័យ ប៉ុន្តែជាទូទៅរាជរដ្ឋាភិបាលកម្ពុជាពឹងផ្អែកយ៉ាងខ្លាំងទៅលើជំនួយពីខាងក្រៅ ដើម្បីនាំចូលនូវវ៉ាក់សាំងទាំងនោះ ។

២០- យុទ្ធនាការស្តីពីការទប់ស្កាត់ជំងឺអេដស៍ និងការប្រើប្រាស់ថ្នាំពន្យាកំណើតត្រូវបានធ្វើឡើងទូទាំងប្រទេស ហើយលទ្ធផលដែលបានអង្កេតឃើញពីសាធារណៈជន ពីការយល់ដឹងបានប្រសើរជាងមុនក្នុងបញ្ហានេះ។ ទាក់ទិននឹងការអប់រំស្តីពីការទប់ស្កាត់ជំងឺអេដស៍ គណៈកម្មការអន្តរក្រសួងមួយ ត្រូវបានបង្កើតឡើងដោយទទួលបន្ទុកលើប្រព័ន្ធអប់រំគ្រប់កំរិតទាំងអស់ រាប់បញ្ចូលទាំងសាលារៀននានានៅតំបន់ដាច់ស្រយាល ហើយសុខភាពបន្តពូជត្រូវបានណែនាំនៅក្នុងកម្មវិធីសិក្សារបស់សាលារៀនផងដែរ។ គ្រូបង្រៀនក៏ត្រូវបានទទួលការបណ្តុះបណ្តាលផងដែរ ស្តីពីការទប់ស្កាត់ជំងឺអេដស៍ ហើយយុវជនត្រូវបានគេចាត់ទុកថាជាក្រុមអាទិភាព ដែលត្រូវធ្វើការយកចិត្តទុកដាក់មុនគេផងដែរ ។

២១- ការប្រើប្រាស់ថ្នាំញៀន ជាពិសេសការប្រើនូវគ្រឿងញៀនចាក់តាមសសៃ ពុំមែនជាធំដុំនៅក្នុងប្រទេសកម្ពុជាទេ ប៉ុន្តែវាជាចាំបាច់ដើម្បីបង្កើនឱ្យមានការយល់ដឹងជាសាធារណៈនៅក្នុងបញ្ហានេះ។ កម្មវិធីដើម្បីការពារកុមារដែលម្តាយត្រូវឆ្លងមេរោគហ៊ីវត្រូវបានធ្វើឡើង ។

២២- លោកស្រីប្រធានអង្គប្រជុំ បានអញ្ជើញសមាជិកគណៈកម្មាធិការ ឱ្យសួរសំនួរទាក់ទងនឹងវិធានការការពារពិសេសនានា

២៣- លោកស្រី **MOKHUANE** បានមានប្រសាសន៍ថា ការយល់ដឹងអំពីថ្នាំពន្យាកំណើត គឺជាការមួយគួរឱ្យសរសើរ ប៉ុន្តែទោះបីយ៉ាងណាក៏ដោយវាមានសារៈសំខាន់ជាងនេះទៅទៀត គឺគេត្រូវផ្លាស់ប្តូរអាប្បកិរិយានានាឱ្យស្របទៅនឹងការយល់ដឹងនោះដែរ ។ លោកស្រីមានឆ្ងល់ថា តើការសិក្សាស្រាវជ្រាវទាំងឡាយស្តីពីការប្រើប្រាស់ថ្នាំពន្យាកំណើតដោយមនុស្សក្មេងៗត្រូវបានអនុវត្តន៍ឡើងហើយឬយ៉ាងណា។ រាជរដ្ឋាភិបាលបានថ្លែងថា សិទ្ធិទទួលបានសេវាកម្មសុខាភិបាលត្រូវបានធ្វើឱ្យប្រសើរឡើងហើយ ប៉ុន្តែលោកស្រីមានការងឿងឆ្ងល់អំពីគុណភាពសេវាកម្ម និងថាតើមានមនុស្សប៉ុន្មាននាក់ ដែលពិតជាបានទទួលប្រយោជន៍ពីសេវាកម្មទាំងនេះ។ តាមការបង្ហាញជារូបភាពវាបានចង្អុលបង្ហាញឱ្យឃើញថា ការបំបៅដោះចាប់ផ្តើមឡើងនៅដំណាក់កាលចុងក្រោយ នៅក្នុងអំឡុងពេលទារកភាព ហើយរួមជាមួយអាហារដែលធ្វើឱ្យខូចដល់សុខភាពមនុស្ស។ មានករណីជាច្រើនផងដែរ ស្តីពីជំងឺដែលអាចទប់ស្កាត់បាន ពិការភាព និងអាត្រាមរណភាពខ្ពស់របស់មាតានៅក្នុងប្រទេសកម្ពុជា។

២៤- ដោយសារការខ្វះខាតនូវថ្នាំពេទ្យ ប្រជាពលរដ្ឋងាកទៅរកថ្នាំបុរាណ ហើយលោកស្រីមានការងឿងឆ្ងល់ថា តើមានការផ្លាស់ប្តូរនូវទស្សនៈណាមួយ ត្រូវបានធ្វើឱ្យមានឡើងរវាងមន្ត្រីសុខាភិបាល និងគ្រូឱសថបុរាណដែរឬទេ។ ទាក់ទិននឹងសុខភាពខាងបរិស្ថាន មានប្រជាពលរដ្ឋចំនួន១៩% តែប៉ុណ្ណោះ ដែលទទួលបាននូវអនាម័យសមរម្យ ហើយលោកស្រីមានការងឿងឆ្ងល់ថា តើមានផែនការណាមួយដើម្បីធ្វើឱ្យស្ថានភាពនោះ បានប្រសើរឡើងដែរឬ។ គណៈកម្មាធិការបានទទួលពត៌មាន ដែលផ្ទុយនឹងការ

អះអាងរបស់រដ្ឋាភិបាល ដែលថាការប្រើប្រាស់ជាតិសុរាមិនមែនជាបញ្ហាដ៏ធំដុំនៅប្រទេសកម្ពុជាឡើយហើយ ដែលបានបង្ហាញថា ការប្រើប្រាស់ថ្នាំញៀនមានការកើនឡើង។ រាជរដ្ឋាភិបាលបានថ្លែងថា មានផែនការរួចជាស្រេចហើយដើម្បីប្រយុទ្ធប្រឆាំងនឹងការជួញដូរគ្រឿងញៀន ប៉ុន្តែផែនការនោះត្រូវបានអនុវត្តហើយឬនៅ ?

២៥- <u>លោក **DOEK**</u> បានមានប្រសាសន៍ថា លោកមានការខកចិត្តចំពោះ ការពិពណ៌នាអំពីការអប់រំថ្នាក់បឋមសិក្សានៅក្នុងការឆ្លើយតបជាលាយលក្ខ័អក្សររបស់រដ្ឋាភិបាល។ អត្រានៃការឈប់រៀនខ្ពស់ក្នុងថ្នាក់ទី១ ដល់ថ្នាក់ទី៣ មានន័យថា កុមារដែលមានវ័យត្រូវចូលរៀនចំនួន៥០០.០០០នាក់ មិនបានចូលរៀនទេ។ ការរីកចំរើនដែលនៅមិនទាន់គ្រប់គ្រាន់ ហាក់ដូចជាត្រូវបានធ្វើឱ្យកើតមានឡើង តាំងពីឆ្នាំ១៩៩៤មកម្លេះ។ ការអប់រំត្រូវបានចាត់ទុកថា ជាអាទិភាពខ្ពស់មួយក្នុងប្រទេសណាក៏ដោយ ទោះជាមានឧបសគ្គខាងហិរញ្ញវត្ថុ និងសេដ្ឋកិច្ចរារាំងក៏ដោយ។ រាជរដ្ឋាភិបាលបានទទួលស្គាល់នូវបញ្ហានេះ ប៉ុន្តែហាក់ដូចជាបានបោះបង់ចោលនូវក្តីសង្ឃឹម ដោយសារថាខ្វះនូវមូលនិធិ។ លោកចង់ដឹងថាតើមានការរីកចំរើនអ្វីខ្លះ ដែលគណៈប្រតិភូបានចាត់ទុកថា ប្រទេសកម្ពុជាបានធ្វើឱ្យសំរេចបានក្នុងរយៈពេល៥ឆ្នាំមុននេះ។ តើរាជរដ្ឋាភិបាលបានធ្វើអ្វីខ្លះ ដើម្បីសំរេចឱ្យបាននូវគោលបំណងខាងការអប់រំដ៏ច្រើន ដែលបានដាក់ចេញក្នុងកថាខ័ណ្ឌ១៩៥ នៃរបាយការណ៍លើកដំបូងរបស់កម្ពុជា?។ តើមានការគិតថា នឹងខ្ចីលុយពីធនាគាពិភពលោក ឬស្ថាប័នហិរញ្ញវត្ថុណាមួយដែរឬទេ ?

២៦- តើមានយន្តការដែលមានស្រាប់ ឬដែលបានគ្រោងទុកណាមួយ សំរាប់ការធ្វើឱ្យដំណើរការនៃអង្គការអន្តរជាតិជាច្រើនដែលកំពុងបំពេញការងារនៅប្រទេសកម្ពុជា ប្រព្រឹត្តទៅប្រកបដោយប្រសិទ្ធភាពដែរឬទេ បើតាមរបាយការណ៍ឱ្យដឹងអង្គការទាំងនោះបានបង្កឱ្យមានបញ្ហាខាងនិយត័កម្ម ដោយការខកខានមិនបានប្រាប់អាជ្ញាធរអំពីការបន្តនូវអាណត្តិរបស់ពួកគេជាថ្មី ?

២៧- ដោយលើកឡើងនូវរបាយការណ៍ខែ តុលា ឆ្នាំ ១៩៩៩ ស្តីពីការរំលោភសេពសន្ថវៈលើកុមារក្នុងប្រទេសកម្ពុជា និង របាយ-ការណ៍ស្តីពីការធ្វើអាជីវកម្មផ្លូវភេទលើកុមារ លោកបានស្នើឱ្យគណៈប្រតិភូធ្វើការផ្តល់មតិយោបល់លើបាតុភូតទាំងនោះ។ គោលបំណងដ៏សំខាន់មួយនៃសកម្មភាពរបស់រដ្ឋាភិបាលណាមួយ គឺត្រូវតែកំណត់អំពីតួនាទីរបស់ស្ថាប័នតុលាការ និងទីភ្នាក់ងារអនុវត្តច្បាប់នានា ដោយមានជំនួយពីអង្គការផ្សេងៗ។ តាមការអះអាងឱ្យដឹង ស្ថាបន័នៅកម្ពុជាទាំងនេះ មិនមានការឈឺឆ្អាល គ្មានការបណ្តុះបណ្តាល និងមិនមានការយល់ដឹងថា តើករណីបែបនេះគួរត្រូវដោះស្រាយដោយវិធីណាឡើយ។ សមាជិកនៃស្ថាបន័តុលាការ ត្រូវបានគេរាយការណ៍ថា ពួកគេចេញមុខក្នុងការទទួលសំណូកដើម្បីដោះស្រាយករណីនានាតាមប្រព័ន្ធក្រៅតុលាការ។ បើសិនជាមានបញ្ហាដូច្នេះមែន តើរាជរដ្ឋាភិបាលចាត់វិធានការអ្វីខ្លះ ដើម្បីធ្វើឱ្យស្ថាបន័តុលាការ និងទីភ្នាក់ងារអនុវត្តច្បាប់នានាមានគុណភាពបានប្រសើរនោះ ? ។

២៨- <u>លោក **FULCI**</u> បានសួរថា តើវិធានការខាងផ្លូវច្បាប់ និងវិធានការផ្សេងទៀតអ្វីខ្លះ ដែលរាជរដ្ឋាភិបាលបានចាត់ឡើងដើម្បីសំរេចឱ្យបាននូវកិច្ចការដ៏លំបាកក្នុងការរំសាយ និងការធ្វើសមាហរណកម្មនូវចំនួនដ៏ច្រើន នៃកុមារដែលជាយុទ្ធជន ហើយតើវិធានការទាំងនេះឱ្យមានផលប៉ះពាល់អ្វីខ្លះ។ លោកបានសូមឱ្យគណៈប្រតិភូធ្វើការអត្ថាធិប្បាយលើការអះអាង ដែលធ្វើឡើងក្នុងរបាយការណ៍មួយរបស់អង្គការក្រៅរដ្ឋាភិបាល ដែលថាកុមារអាយុចាប់ពី៧-១៧ឆ្នាំ ត្រូវបានអប់រំជាថ្មី នៅមជ្ឈមណ្ឌលយុវនីតិសម្បទាក្នុងទីក្រុងភ្នំពេញ ដែលជាការចង្អុលឱ្យឃើញថា កុមារអាយុ៧ឆ្នាំ ត្រូវទទួលខុសត្រូវខាងបទព្រហ្មទណ្ឌទៅហើយ។ អង្គការយូនីសេហ្វ បានរាយការណ៍អំពីករណីនៃកុមារដែលត្រូវបានឃុំឃាំងក្នុងពន្ធនាគារសំរាប់មនុស្សពេញវ័យក្នុងទីក្រុងភ្នំពេញ និងបាត់ដំបង ដោយគ្មានសេវាកម្មខាងសុខាភិបាល និងដោយពុំមានកម្មវិធីធ្វើសមាហរណកម្មសំរាប់ពួកគេទេនៅពេលដែលត្រូវបានដោះលែង។ វាហាក់បីដូចជាមានពត៌មានលេចឡើងថា ពួកគេជាច្រើនមិនទាំងត្រូវបានកាត់ឱ្យជាប់ទោសផង។ លោកសូមថ្លែងនូវអំណរគុណ និងដឹងគុណប្រសិនជាបានទទួលពត៌មានពិស្តារស្តីពីកិច្ចខិតខំរបស់កម្ពុជាក្នុងការគោរពតាម

មាត្រា៣៧ ៣៩ និង៤០ នៃអនុសញ្ញា និងស្តីពីវិធានការរបស់កម្ពុជាដើម្បីការពារកុមារ ដែលធ្វើការនិងកាត់បន្ថយពលកម្មកុមារនៅក្នុងប្រទេសកម្ពុជា។ តើកម្ពុជាបានថែរក្សាឱ្យមានទំនាក់ទំនងធ្វើខ្លះ ជាមួយអង្គការការងារអន្តរជាតិ (ILO) ទាក់ទិននឹងពលកម្មកុមារ ? តើកម្ពុជាមានបានគិតដល់ការឱ្យសច្ចាប័នលើអនុសញ្ញាស្តីពីអាយុអប្បបរមារបស់អង្គការការងារអន្តរជាតិ (ILO) ឆ្នាំ ១៩៩៣ ( លេខ ២៣៨) និង លើអនុសញ្ញាស្តីពីរូបភាពដ៏អាក្រក់បំផុតនៃពលកម្មកុមារឆ្នាំ ១៩៩៩ ( លេខ ១៨២) ដែរឬទេ ?

២៩- ទោះបីជាមានបញ្ហាដ៏ធ្ងន់ធ្ងរនៃការជួញដូរផ្លូវភេទលើកុមារក្នុងប្រទេសកម្ពុជាក៏ដោយ ពុំមានការសិក្សាស្រាវជ្រាវណាមួយត្រូវបានធ្វើឡើងលើប្រធានបទនេះទេ ។ រាជរដ្ឋាភិបាលហាក់ដូចជាស្ថិតនៅក្នុងជំហរមិនច្បាស់លាស់រវាងការបណ្តោយឱ្យមាន និងការទប់ស្កាត់កុំឱ្យមាន។ តើរាជរដ្ឋាភិបាលស្ថិតក្នុងជំហរណាមួយពិតប្រាកដ? ។ តើអាជ្ញាធរបានកំពុងចាត់វិធានការ អ្វីខ្លះដើម្បីការពារកុមារប្រឆាំងនឹងគ្រោះនៃការចាប់ពង្រត់ ចូល ទៅក្នុងបណ្តាញនៃការធ្វើអាជីវកម្មនោះ ។

៣០- <u>លោកស្រី **TIGGERSTEDT-TAHTELA**</u> បានកត់សំគាល់លើសេចក្តីថ្លែការណ៍របស់គណៈប្រតិភូ ដែលថាការរំលោភបំពានលើកុមារ ពុំមានចោទជាបញ្ហាឡើយក្នុងប្រទេសកម្ពុជា ទោះបីជាមានរបាយការណ៍នានា ដែលថាការដាក់ទណ្ឌកម្មលើរាងកាយនៅគេហដ្ឋានបានរីករាលដាលក៏ដោយ។ ដោយសារថាពុំមានការស្ទង់មតិស្តីពីការរំលោភបំពានលើកុមារនោះ ហេតុដូច្នេះហើយក្នុងឆ្នាំ១៩៩៦ អង្គការក្រៅរដ្ឋាភិបាលមួយបានធ្វើការស្ទង់មតិមួយលើអំពើហឹង្សាប្រឆាំងនឹងស្ត្រីភេទ ដែលការនោះ ក៏បានប៉ះពាល់ដល់កុមារផងដែរ។ ជាអកុសលមានតែមនុស្សពេញវ័យទេ ដែលត្រូវបានធ្វើការស្ទង់មតិ ប៉ុន្តែស្ត្រីដែលត្រូវបានរំលោភបំពានបានរាយការណ៍ថា ប្តីរបស់ពួកគេជារឿយៗតែងតែវាយធ្វើបាបកូន បន្ទាប់ពីបានប្រព្រឹត្តការវាយដំមកលើខ្លួនរួចមក។ អាជ្ញាធរគួរធ្វើសម្ភាសន៍ជាមួយកុមារ ដើម្បីប្រើប្រាស់បទពិសោធន៍ដែលពួកគេបានជួបប្រទះជាមូលដ្ឋានសំរាប់យុទ្ធនាការផ្សព្វផ្សាយឱ្យមានការយល់ដឹងតាមរយៈប្រព័ន្ធសារពតិមាន។ ការរាយការណ៍អំពីបទល្មើសដោយអ្នកជិតខាង ឬប្រពន្ធ ឬប្តី ក៏គួរត្រូវបានលើកទឹកចិត្តផងដែរ ដោយពុំចាំបាច់ផ្អែកលើទស្សនៈដែលថាត្រូវតែចាប់អ្នកប្រព្រឹត្តដាក់ពន្ធនាគារនោះទេ ប៉ុន្តែក្នុងគោលបំណងដើម្បីការពារគ្រួសារទាំងមូល ។

៣១- របាយការណ៍នេះឆ្លុះបញ្ចាំងឱ្យឃើញនូវរូបភាពជាអវិជ្ជមានណាស់ ដល់ស្ថានភាពនៃការអប់រំក្នុងប្រទេស ដោយបានសង្កត់ធ្ងន់ទៅលើកំហិតនៃថវិកាការអប់រំមានកំរិតអន់ថយ និងគំលាតកាន់តែធំនៃសាលានៅទីក្រុង និងជនបទ។ ទោះបីជា រាជរដ្ឋាភិបាលបានបង្កើតឡើងនូវគោលនយោបាយថ្មីនានាសំរាប់ការកែទំរង់ ហើយបានកំពុងធ្វើការដើម្បីលើកស្ទួយភាពសក្តិសិទ្ធិ និងប្រសិទ្ធភាពក្នុងការរៀបចំផែនការវិស័យអប់រំក៏ដោយ អត្រាសិស្សឈប់រៀនខ្ពស់បានបង្ហាញឱ្យឃើញថា ការសិក្សាដែលផ្តល់ឱ្យនោះមិនមានការទាក់ទាញចំណាប់អារម្មណ៍របស់សិស្សឡើយ។ ការប៉ុនប៉ងនានាអាចត្រូវបានធ្វើឡើង ដើម្បីដាក់បញ្ចូលនិសិស្សដែលមានអាយុច្រើនជាង(១២-១៨) នៅក្នុងការរៀបចំផែនការកម្មវិធីសិក្សា ក្នុងគោលបំណងដើម្បីរកឱ្យឃើញនូវប្រភេទនៃការអប់រំដែលពួកគេប្រាថ្នាចង់បាន និងដើម្បីស្វះស្វែងរកការផ្តល់មតិ យោបល់ពីគ្រូបង្រៀនអង្គការក្រៅរដ្ឋាភិបាល និងអង្គការផ្សេងទៀត ដែលមានទស្សនៈអំពីវិស័យអប់រំ ។

៣២- <u>លោកស្រី **RILANTONO**</u> ទទួលស្គាល់ថា ជាមួយនឹងការបែងចែកប្រាក់ចំនួនត្រឹមតែ៨% នៃថវិកាសរុបសំរាប់បំរើឱ្យវិស័យអប់រំ វាគឺជាការលំបាកក្នុងការផ្តល់សារៈសំខាន់ពិត១ ទៅឱ្យការអភិវឌ្ឍន៍ធនធានមនុស្សហើយដែលនោះគឺជាកត្តាចំបងនៃការអភិវឌ្ឍ ទោះបីក្នុងប្រទេសណាក៏ដោយ។ ការចេញថ្លៃអប់រំ ត្រូវតែបានផ្តល់ឱ្យអាចចាប់ពីអាយុដំបូងបំផុត និងគួររួមបញ្ចូលទាំងការអប់រំបឋមសិក្សា និងមធ្យមសិក្សាដែលខានមិនបាន។ តើអាហារូបករណ៍សំរាប់ការអប់រំនៅមធ្យមសិក្សាត្រូវបានផ្តល់ឱ្យដោយស្ថាប័នអន្តររដ្ឋាភិបាល ឬអង្គការក្រៅរដ្ឋាភិបាលដែរឬទេ? ។ ដោយហេតុថា របាយការណ៍បានផ្តោតលើការអប់រំក្រៅប្រព័ន្ធសំរាប់មនុស្សពេញវ័យ លោកស្រីមានការងឿងឆ្ងល់ថា តើមានសៀវភៅមេរៀនក្រៅ ប្រព័ន្ធសំរាប់កុមារ កុមារដែលឈប់រៀន

ហើយត្រូវការធ្វើការសំរាប់រយៈពេលពីរបីម៉ោងក្នុងមួយថ្ងៃដែរឬទេ។ លោកស្រីបានឱ្យជាអនុសាសន៍ថា ការអប់រំបែបនេះគួរត្រូវបានផ្តល់ឱ្យកុមារនៅថ្នាក់បឋមសិក្សា និងមធ្យមសិក្សាជាន់ទាប ។

៣៣- លោកស្រីស្នើសុំការពន្យល់អំពីភាពខុសគ្នារវាងកំរិតនៃការសិក្សារបស់កុមារា និងកុមារី ដែលហាក់ដូចជាបានស្ថិតនៅក្រោយគេបន្ទាប់ពីនាងបានឈានដល់អាយុ ១០ឆ្នាំទៅ ។ តើនោះកើតឡើងដោយសារឥរិយាបថរបស់ឪពុក ម្តាយឬ ? តើប្រព័ន្ធពតិមានខាងការគ្រប់គ្រងការអប់រំ បានផ្តល់ជាជំនួយអ្វីខ្លះដល់ការកែទំរង់គោលនយោបាយនៃការអប់រំនោះ ? ។
៣៤- លោកស្រីបានមានប្រសាសន៍ថា នៅខណៈពេលដែលលោកស្រីវាយតំលៃខ្ពស់ចំពោះការឆ្លើយតបដោយឥតលាក់ចំពោះសំណួរទី១៦ លោកស្រីមានការខកចិត្តចំពោះការមិនរវល់ក្នុងការទទួលខុសត្រូវរបស់រាជរដ្ឋាភិបាល ចំពោះសកម្មភាពលំហែរកាយ។ ដោយផ្អែកលើកំរិតនៃភាពក្រខ្សត់ជាទូទៅនៅក្នុងប្រទេស តើគណៈប្រតិភូមិនបានចាត់ទុកថាវាគឺជាការមិនសមរម្យចំពោះសហគមន៍ ដែលត្រូវបានគេស្នើឱ្យផ្តល់ហិរញ្ញប្បទាន ចេញពីហោប៉ៅរបស់ខ្លួនឯងដល់សកម្មភាពកំសាន្តនានាដែរឬទេ? ។

៣៥- តាមចំលើយចំពោះសំណួរទី ១២ ពុំមាននីតិកម្មថ្មីណាមួយដែលចែងអំពីការទទួលខុសត្រូវរបស់ឪពុកម្តាយ ចំពោះការចិញ្ចឹមបីបាច់ និងការអភិវឌ្ឍកុមារឡើយ។ ដោយសារថាអំពើហឹង្សាក្នុងគ្រួសារប៉ះពាល់ដល់ទំនាក់ទំនងនៅគ្រប់កំរិតនោះ លោកស្រីសង្ឃឹមថា អាជ្ញាធរនឹងពិចារណាភ្លាម១ ដើម្បីពិចារណារកវិធីផ្សេង១ដើម្បីលើកស្ទួយបរិយាកាសមួយ ប្រកបដោយសុភមង្គលនៅក្នុងគ្រួសារ ដូចដែលមានចែងក្នុងបុព្វកថានៃអនុសញ្ញា ។

៣៦- <u>លោក **RABAH**</u> បានមានប្រសាសន៍ថាតើចំនួនសិស្សឈប់រៀន និងចំនួនសិស្សរៀនត្រួតថ្នាក់ដ៏ខ្ពស់ដែល ភាពច្រើនជាកុមារី និងការផ្តល់ការអប់រំដែលមានកំរិតទាបនោះ អាចបណ្តាលមកពីការដែលប្រទេសនេះខ្វះគ្រូបង្រៀនឬ?។ ជំនាញដែលមានកំរិតរបស់គ្រូបង្រៀនក៏ប្រហែលជាអាចជាកត្តាមួយផងដែរ។ គេបានផ្តល់អនុសាសន៍ថា ប្រាក់បៀវត្សរ៍របស់គ្រូបង្រៀនគួរត្រូវបានដំឡើងឱ្យបាន១០០ដុល្លាអាមេរិក ក្នុងមួយខែ ដែលនេះនៅតែជាតួលេខមានកំរិតទាបណាស់នៅឡើយ។ លោកបានជំរុញឱ្យរដ្ឋាភិបាលខិតខំឱ្យបានខ្លាំងក្លាជាងមុន ដើម្បីលុបបំបាត់ចោលអំពើពុករលួយនៅក្នុងសាលារៀនកសាងសាលារៀនឱ្យបានច្រើនថែមទៀត និងផ្តល់សេវាកម្ម និង សំភារៈឱ្យបានច្រើនជាងមុន ។

៣៧- លោកមានអារម្មណ៍ខ្មើសក្នុងចិត្តចំពោះការពុំមានច្បាប់ដែលនឹងគ្រប់គ្រងនូវប្រព័ន្ធយុត្តិធម៌អនីតិជន និងការខ្វះចៅក្រមដែលមានជំនាញ។ លោកបានសួរថាតើមានជំនួយខាងផ្នែកច្បាប់សំរាប់អនិតិជននៅស្ថានីយ៍នគរបាល ឬនៅតុលាការដែរទេ តើមានអ្វីខ្លះបានកើតឡើងនៅក្នុងមជ្ឈមណ្ឌលយុវនីតិសម្បទា ហើយថាតើមជ្ឈមណ្ឌលនេះត្រូវបានបំរើការងារដោយមន្ត្រីផ្នែកតុលាការដែលទទួលបានការបណ្តុះបណ្តាលដែរទេ។ ដោយសារថា អង្គការយូនីសេហ្វ និងស្ថាប័នអង្គការសហប្រជាជាតិផ្សេងទៀត ស្ថិតនៅក្នុងជំហរដើម្បីជួយក្នុងការផ្តល់មូលនិធិនោះ កំហិតនៃថវិកានេះគឺមិនជាឧបសគ្គឡើយ។

៣៨- <u>លោកស្រីប្រធានអង្គប្រជុំ</u> បានសំដែងនូវការភ្ញាក់ផ្អើលដែលថា ទោះបីជាកម្ពុជាមានតំណាងនៅវេទិកាអប់រំពិភពលោកនៅទីក្រុងដាកាក៏ដោយ ការអប់រំនៅតែមិនមែនជាការខានមិនបាន។ តើនោះកើតឡើងដោយសារបញ្ហាមូលនិធិឬ? ប្រទេសកំពុងអភិវឌ្ឍន៏ជាច្រើន បានស្ថិតក្នុងស្ថានភាពដូចគ្នានេះ ប៉ុន្តែបានទទួលជោគជ័យក្នុងការរក្សាបាននូវកំរិតនៃការអប់រំ ដែលខានមិនបាននោះ ទោះបីជាការអប់រំមិនបានពង្រីកដល់កុមារទាំងអស់ក៏ដោយ ។

<u>កិច្ចប្រជុំបានព្យួរនៅម៉ោង ០៤:៣០នាទី ល្ងាច ហើយចាប់ដំណើរការវិញនៅម៉ោង ០៤:៤០នាទីល្ងាច</u>

៣៩- លោក **PHEARITH** (កម្ពុជា) បានមានប្រសាសន៍ថា នៅខណៈពេលដែលច្បាប់គ្រប់គ្រងប្រព័ន្ធយុត្តិធម៌អនីតិជននៅមិនទាន់មាននៅឡើយ អាជ្ញាធរបានកំពុងខិតខំខ្នះខ្នែងដើម្បីបង្កើតឱ្យមាននូវនីតិវិធីមួយ ដើម្បីចាត់ការទៅលើជនល្មើស ដែលជាអនីតិជន។ គណៈកម្មាធិការមួយត្រូវបានបង្កើតឡើងដើម្បីត្រួតពិនិត្យមើលការសួរចំលើយកុមារដោយនគរបាល ដោយរួមឪពុកម្តាយ គ្រូបង្រៀន ចៅក្រមមួយរូប អាជ្ញាធរមូលដ្ឋាន និងតំណាងនៃអង្គការក្រៅរដ្ឋាភិបាល ដែលពាក់ព័ន្ធគណៈកម្មាធិការនេះនឹងសំរេចថា តើវិធានការអ្វីដែលនឹងបំរើឱ្យប្រយោជន៍ដ៏ថ្លៃថ្លារបស់កុមារ។ នៅខណៈពេលដែលមជ្ឈមណ្ឌលយុវនីតិជនសម្បទាក្នុងទីក្រុងភ្នំពេញ ត្រូវបានគេប្រើប្រាស់នាពេលកន្លងមក ជាមជ្ឈមណ្ឌលឃុំឃាំង វាឥឡូវនេះបានក្លាយទៅជាមជ្ឈមណ្ឌលយុវនីតិសម្បទាហើយ ។ អាជ្ញាធរបានកំពុងតែធ្វើសហប្រតិបត្តិការដោយការផ្តល់នូវជំនួយផ្នែកច្បាប់ ហើយចៅក្រមកំពុងត្រូវបានបណ្តុះបណ្តាលលើនីតិវិធីកាត់ក្តីចំពោះករណីនានា ដែលទាក់ទងនឹងកុមារ។

៤០- ដោយមានជំនួយរបស់អង្គការយូនីសេហ្វ គណៈកម្មាធិការជាតិទទួលបន្ទុកការិសាយកងទ័ព បានកំពុងរៀបចំការបណ្តុះបណ្តាលសំរាប់កុមារដែលរងគ្រោះដោយសារជំលោះប្រដាប់អាវុធក្នុងប្រទេសកម្ពុជាប្រមាណជា៣០០ នាក់ ។ ដោយមានជំនួយរបស់រដ្ឋាភិបាលអូស្ត្រាលី អាជ្ញាធរកំពុងតែចាត់ចែងឱ្យជនល្មើសក្មេងៗនៅដាច់ដោយឡែកពីជនល្មើសពេញវ័យក្នុងទីក្រុង ភ្នំពេញ ហើយពន្ធនាគារទាំងឡាយត្រូវបានចុះពិនិត្យមើលម្តង ឬពីរដងក្នុងមួយសប្តាហ៍។ ការរែអង្កាសលុយកំពុងស្ថិតក្នុងដំណើរការ ដើម្បីផ្តល់នូវឧបករណ៍ដូចគ្នានេះនៅក្នុងខេត្តនានា ដូចជាខេត្តបាត់ដំបងជាដើម។ ដោយមានការជួយឧបត្ថម្ភគាំទ្ររបស់អង្គការការងារអន្តរជាតិ អនុគណៈកម្មាធិការនៃការគណៈកម្មាធិការជាតិកម្ពុជាដើម្បីកុមារ កំពុងរៀបចំការបណ្តុះបណ្តាលសំរាប់ក្រុមអធិការកិច្ចការងារនៅខេត្ត។ ខិតប័ណ្ណ និងសៀវភៅនានាត្រូវបានចែកជូនក្នុងគោលបំណងដើម្បីធ្វើឱ្យមានការយល់ដឹងជាសាធារណៈ អំពីបញ្ហាពលកម្មកុមារ ហើយវិធានការទាំងឡាយមានរួចជាស្រេចហើយ ដើម្បីធ្វើសមាហរណកម្ម កម្មករដែលជាកុមារចូលទៅក្នុងប្រព័ន្ធអប់រំ ។

៤១- លោក **SETHY** (កម្ពុជា) បានថ្លែងថា ឱសថបុរាណគឺជាផ្នែកមួយដ៏សំខាន់នៃកេរ្តិ៍ដំណែលរបស់កម្ពុជា ហើយថាមាននាយកដ្ឋានពិសេសមួយក្នុងក្រសួងសុខាភិបាល ដែលទទួលបន្ទុកលើកស្ទួយនូវឱសថបុរាណនេះ ។

៤២- ការអនុវត្តសិទ្ធិទទួលបានអប់រំ គឺជាកិច្ចការមួយសំរាបរយៈពេលយូរ ដែលត្រូវតែធ្វើឡើងក្នុងប្រទេសណាមួយក៏ដោយជាពិសេសនៅក្នុងប្រទេសដែលសាលាជាង៩០% ត្រូវបានបំភ្លេចបំផ្លាញ ហើយគ្រូជាង៨០% ត្រូវបានសំលាប់នៅក្រោមរបបខ្មែរក្រហម។ ភាគច្រើននៃសាលាដែលសេសសល់តិចតួចនោះត្រូវបានពួកខ្មែរក្រហម ជាទីកន្លែងសំរាប់ផ្ទុកអាវុធ ឬជាទីកន្លែងសំរាប់ធ្វើទារុណកម្ម។ ហេតុដូច្នេះហើយទើបរដ្ឋាភិបាលក្រោយត្រូវតែកសាងឡើងវិញនូវប្រព័ន្ធអប់រំពីបាតដៃទទេ។ ប្រជាពលរដ្ឋដែលអាចអាន ឬសរសេរបានស្ម័គ្រចិត្តធ្វើជាគ្រូបង្រៀន ហើយកិច្ចខិតខំនានាត្រូវបានធ្វើឡើងដើម្បីផ្តល់ឱ្យពួកគេនូវការបណ្តុះបណ្តាលឱ្យបានគ្រប់គ្រាន់។ ចាប់តាំងពីពេលនោះមកចំនួនគ្រូបង្រៀនបានកើតឡើងគួរឱ្យកត់សំគាល់ ហើយមជ្ឈមណ្ឌលបណ្តុះបណ្តាលគ្រូចំនួន១៨កន្លែង ត្រូវបានបង្កើតឡើងនូវតាមខេត្តនានា ។

៤៣- បច្ចុប្បន្ននេះមានសិស្សសាលា និងនិស្សិតជាទូទៅជាង២.៣លាននាក់ នៅក្នុងប្រព័ន្ធអប់រំ នោះជាចំនួនសមាមាត្រដ៏ធំសម្បើមមួយនៃចំនួនប្រជាពលរដ្ឋសរុបចំនួន១១លាននាក់។ ប៉ុន្តែរដ្ឋាភិបាលទទួលស្គាល់ថា មានកិច្ចការជាច្រើនទៀត ដែលត្រូវធ្វើ កុមារទាំងអស់ មិនសុទ្ធតែបានចុះឈ្មោះចូលរៀនទេ ហើយសាលាជាច្រើនត្រូវការធ្វើកសាងឡើងវិញ ដែលនោះនឹងត្រូវការនូវមូលនិធិជាច្រើន ។ គោលបំណងដ៏ធំបំផុតនោះគឺត្រូវផ្តល់ឱ្យកុមារទាំងអស់បានចូលរៀន។

៤៤- រដ្ឋាភិបាលបច្ចុប្បន្ននេះ បានកំពុងធ្វើការពិនិត្យឡើងវិញដោយសព្វមុខមួយលើគោលនយោបាយនៃការអប់រំ។ អង្គការជាច្រើនដូចជាអង្គការយូនីសេហ្វ និងទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិស៊ុយអែដ **(SIDA)** បានធ្វើការវិភាគទានគួរឱ្យកត់សំគាល់

មួយចំពោះការងារនៃការស្តារប្រព័ន្ធអប់រំឡើងវិញ ហើយលោកយល់ស្របជាមួយទស្សនៈរបស់កម្មាធិការ ដែលថាវាជាការមានសារៈសំខាន់ក្នុងការថែទាំទំនាក់ទំនងជាមួយម្ចាស់ជំនួយដូចនោះ ។ ធនាគារអភិវឌ្ឍអាស៊ី ក៏បានផ្តល់ឱ្យនូវប្រាក់កំចី ដើម្បីបង្កើតមជ្ឈមណ្ឌលបណ្តុះបណ្តាលគ្រូបង្រៀន ។ មូលនិធិពីធនាគារពិភពលោក បានកំពុងប្រើផ្តោតទៅលើការអប់រំថ្នាក់បឋមសិក្សា ។ កិច្ចការនេះកំពុងដំណើរការដើម្បីដាក់បញ្ចូលថ្នាក់ផ្សេងៗ ដែលនូវខ្វាត់ខ្វាយឱ្យចូលទៅក្នុងសាលាសមរម្យ និងដើម្បីធ្វើឱ្យម្តាយ និងសហគមន៍មានការពាក់ព័ន្ធជាទូទៅក្នុងដំណើរការនៃការអប់រំនេះ ។

៤៥- អាត្រាសិស្សឈប់រៀន និងរៀនត្រួតថ្នាក់ គឺជាការខ្វះខាតនូវធនធានមួយ ជាពិសេសសំរាប់ប្រទេសក្រីក្រដូចកម្ពុជានេះ ហើយការពិភាក្សានានាបច្ចុប្បន្ននេះកំពុងស្ថិតនៅក្នុងដំណើរការ ដោយមានការចូលរួមពីជំនាញការពាក់ព័ន្ធដើម្បីកែទំរង់កម្មវិធីសិក្សា ។ បន្ទាប់ពីបានចូលរួមក្នុងវេទិកាអប់រំពិភពលោកដែលធ្វើឡើងក្នុងទីក្រុងដាកា ក្នុងខែមេសា ឆ្នាំ២០០០ កម្ពុជាបានប្តេជ្ញាចិត្តដើម្បីអភិវឌ្ឍន៍ផែនការសកម្មភាពផ្ទាល់របស់ខ្លួន ដើម្បីបំរើឱ្យវិស័យអប់រំ ។ មជ្ឈមណ្ឌលប្រព័ន្ធពត៌មានស្តីពីការគ្រប់គ្រងវិស័យអប់រំ ត្រូវបានបង្កើតហើយ ដោយបានធ្វើការប្រមូល និងវិភាគទិន្នន័យស្តីពីការអប់រំ ។ រដ្ឋាភិបាលបានប្រើទិន្នន័យនោះដើម្បីធ្វើឱ្យខ្លួនមានលទ្ធភាព ដើម្បីឆ្លើយតបតាមតំរូវអប់រំរបស់សហគមន៍ក្នុងមធ្យោបាយប្រកបដោយប្រសិទ្ធភាពបំផុតដែលអាចធ្វើទៅបាន ។ បុព្វហេតុមួយដែលនាំឱ្យមាននូវអាត្រាឈប់រៀន និងរៀនត្រួតថ្នាក់ខ្ពស់នោះគឺដោយសារកំរិតនៃការលើកទឹកចិត្តក្នុងចំណោមគ្រូបង្រៀនមានកំរិតទាប ។ ថ្មីៗនេះរដ្ឋាភិបាលបានផ្តល់ឱ្យប្រាក់ឧបត្ថម្ភដល់គ្រូបង្រៀនមួយចំនួនហើយប្រាក់បៀវត្សជាមូលដ្ឋានរបស់ពួកមួយចំនួនទ្វេរដង នៃប្រាក់បៀវត្សមន្ត្រីរាជការស៊ីវិល ទោះជាយ៉ាងក៏ដោយប្រាក់បៀវត្សរ៍របស់គ្រូនូវតែមិនគ្រប់នៅឡើយ ។ នោះគឺជាបញ្ហាមួយដែលត្រូវលើកយកមកពិភាក្សាជាមួយម្ចាស់ជំនួយរបស់កម្ពុជា ។

៤៦- អាត្រាភាគរយនៃកុមារដែលចុះឈ្មោះចូលរៀនថ្នាក់មុនចូលបឋមសិក្សាមានចំនួនតិចតួចប៉ុណ្ណោះ ។ ប៉ុន្តែកម្ពុជាទទួលស្គាល់នូវសារៈសំខាន់នៃបញ្ហានេះ ហើយបានបង្កើតឡើងនូវគំរោងការរួមមួយក្នុងវិស័យនោះ ជាមួយម្ចាស់ជំនួយដូចជាអង្គការ **UNESCO** និង **UNICEF** ជាដើម ។

៤៧- ទោះបីជាសិទ្ធិទទួលបានការអប់រំដោយឥតគិតថ្លៃសំរាប់ទាំងអស់គ្នាសំរាប់រយៈពេល ៩ ឆ្នាំ មានចែងក្នុងរដ្ឋធម្មនុញ្ញក៏ដោយ វាគឺជាការពិតដែលថាពុំមាននីតិកម្មណា ដែលបញ្ជាក់ថាការអប់រំ គឺជាការខានមិនបានឡើយ ។ នោះដោយសារថានៅពេលដែលរដ្ឋធម្មនុញ្ញត្រូវបានអនុម័តឡើងក្នុងឆ្នាំ១៩៩៣ ពួកខ្មែរក្រហមនៅតែបានកាន់ កាប់តំបន់មួយចំនួននៃប្រទេសហើយដោយសារថាការខ្វះធនធាន នោះគឺជាការមួយដែលពុំអាចធ្វើឱ្យវាមាន លទ្ធភាពដើម្បីអនុវត្តនូវការប្តេជ្ញាចិត្តបែបនេះណាស់ ។ ហេតុដូច្នេះចាប់តាំងពីឆ្នាំ១៩៩៣មក រដ្ឋបានខិតខំយ៉ាងខ្លាំងក្លាដើម្បីសំរេចឱ្យបាននូវគោលបំណងដ៏សំខាន់បំផុតនោះគឺការផ្តល់នូវការអប់រំដោយ ឥតគិតថ្លៃសំរាប់ទាំងអស់គ្នា ប៉ុន្តែវាច្បាស់ណាស់ថាវាមានការធ្វើដំណើរលើកំណាត់ផ្លូវដ៏វែងឆ្ងាយមួយ ។

៤៨- <u>លោកស្រី **HARANVADDEY**</u> (កម្ពុជា) បានមានប្រសាសន៍ថា ពុំមានស្ថិតិស្តីពីទំហំនៃការធ្វើអាជីវកម្មខាងផ្លូវភេទលើកុមារទេ ប៉ុន្តែរដ្ឋាភិបាលបានទទួលស្គាល់ថា វាគឺជាបញ្ហាដ៏ធ្ងន់ធ្ងរមួយ ។ ការស្ទង់មតិមួយដែលធ្វើឡើងដោយក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារក្នុងឆ្នាំ១៩៩៨ បានរកឃើញថាពុំមានយន្តការច្បាស់លាស់សំរាប់ធ្វើការដោះស្រាយបញ្ហានេះនៅតាមខេត្តឡើយ ។ ទោះបីជាយ៉ាងណាក៏ដោយ រដ្ឋាភិបាលថ្មីៗនេះ បានអនុម័តផែនការសកម្មភាព៥ឆ្នាំ ដើម្បីប្រយុទ្ធប្រឆាំងនឹងការជួញដូរផ្លូវភេទលើកុមារ ដែលក្នុងផែនការនោះមានកម្មវិធីចំនួន៤ ផ្តោតលើការទប់ស្កាត់ការ ការពារការជាសះស្បើយឡើងវិញ និងសមាហរណកម្ម ។ កម្មវិធីនីមួយៗ រួមមានវត្ថុបំណង យុទ្ធសាស្ត្រ និង សកម្មភាពផ្សេងៗហើយបានបញ្ជាក់អំពីស្ថាប័នដែលជាអ្នកទទួលខុសត្រូវចំពោះសកម្មភាពនីមួយៗ និងធនធាននានាពីរដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាល ។ រដ្ឋាភិបាលបានជំរុញឱ្យស្ថាប័នរបស់រដ្ឋនានា ឪពុកម្តាយ និងសាធារណៈជនទូទៅដើម្បីចូលរួមក្នុងការអនុវត្តផែនការនេះ ហើយបានផ្តល់ជាអនុសាសន៍ថា ក្រុមប្រឹក្សាជាតិ

កម្ពុជាដើម្បីកុមារ គួរបង្កើតឡើងនូវអនុគណៈកម្មាធិការមួយដើម្បីលើកស្ទួយ និងតាមដានមើលការអនុវត្តនេះ។ ផែនការនេះមានលក្ខណៈប្រកបដោយអនុភាព និងទ្រង់ទ្រាយធំ ហើយការជួយឧបត្ថម្ភគាំទ្ររបស់សហគមន៍ អន្តរជាតិ និងជាសេចក្តីត្រូវការដើម្បីធ្វើឱ្យផែនការនេះអនុវត្តទៅប្រកបដោយប្រសិទ្ធភាព។ គោលបំណងមួយនៃផែនការនេះគឺត្រូវផ្តល់នូវការបណ្តុះបណ្តាលសំរាប់មន្ត្រីនគរបាល ចៅក្រម និងមន្ត្រីរាជការលើផ្នែកច្បាប់ទាក់ទងនឹងការធ្វើអាជីវកម្មខាងផ្លូវភេទលើកុមារ និងលើនិតិវិធីសំរាប់ចាត់ការលើរបាយការណ៍ស្តីពីការធ្វើអាជីវកម្មបែបនេះ។ ក្រសួងសង្គមកិច្ចបានដើរ តួនាទីយ៉ាងសំខាន់ក្នុងការធ្វើនីតិសម្បទាជនរងគ្រោះ និងធ្វើសមាហរណកម្មពួកគេចូលទៅក្នុងសង្គមវិញ។ កម្ពុជាបានធ្វើសហប្រតិបត្តិការជាមួយប្រទេសដ៏ទៃជាច្រើនលើបញ្ហា ទោះជាកម្ពុជាមិនទាន់បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងទ្វេភាគីផ្លូវការណាមួយក៏ដោយ។ កិច្ចសហប្រតិបត្តិការជាមួយប្រទេសផ្សេងទៀត ក៏កំពុងស្ថិតក្នុងដំណើរការដែរ ក្នុងគោលបំណងដើម្បីប្រយុទ្ធប្រឆាំងនឹងទេសចរណ៍ផ្លូវភេទដែលពាក់ព័ន្ធនឹងកុមារ។ ក្រសួងទេសចរណ៍កំពុងតែអភិវឌ្ឍន៍យុទ្ធសាស្ត្រមួយដើម្បីដោះស្រាយជាមួយបញ្ហានេះ ហើយបានកំពុងធ្វើការងារដើម្បីធ្វើឱ្យមានការយល់ដឹងស្តីពីបញ្ហានេះ ក្នុងចំណោមម្ចាស់គ្រឹះស្ថាននានា ដូចជា ម្ចាស់សណ្ឋាគារ ភោជនីយដ្ឋាន និងរង្គសាលជាដើម។

៤៩- បញ្ហានអក្ខរភាពរបស់មនុស្សពេញវ័យ គឺជាបញ្ហាដ៏ចំបងមួយ ហើយយុទ្ធនាមានការប្រឆាំងគ្រោះមិនចេះអក្សរ គឺជាផ្នែកមួយនៃយុទ្ធសាស្ត្រក្នុងការផ្តល់នូវការអប់រំសំរាប់ទាំងអស់គ្នា។ គំរោងការសាកល្បង ក៏ត្រូវបានបង្កើតឡើងដើម្បីផ្តល់នូវការអប់រំក្រៅប្រព័ន្ធ និងការបណ្តុះបណ្តាលលើជំនាញជាក់ស្តែង។ គណៈកម្មាធិការមួយ ដែលរួមមានតំណាងនានាមកពីក្រសួងផ្សេងៗត្រូវបានបង្កើតឡើងដើម្បីធ្វើការទំនាក់ទំនងជាមួយគណៈកម្មាធិការ នានានៅថ្នាក់មូលដ្ឋាន ក្នុងគោលបំណងដើម្បីអនុវត្តនូវយុទ្ធនាការ និង គំរោងការនានានោះ ។

៥០- ការអប់រំអំពីភេទ និងការប្រើប្រាស់ស្រោមអនាម័យ មិនមែនជាបញ្ហាងាយស្រួលដើម្បីដោះស្រាយឡើយ ដោយសារថាមនុស្សជាច្រើន ជាពិសេសចាស់ជំនាន់មុន យល់ឃើញថាវាគឺជាការលំបាកដើម្បីពិភាក្សាអំពីបញ្ហាបែបនេះ។ ប៉ុន្តែការអប់រំអំពីភេទ រួមបញ្ចូលទាំងការបង្រៀនអំពីជំងឺ **(HIV/AIDs)** ត្រូវបានដាក់បញ្ចូលទៅក្នុងកម្មវិធីសិក្សា ហើយប្រធានបទនេះត្រូវបានដាក់បញ្ចូលក្នុងកម្មវិធីបណ្តុះបណ្តាលគ្រូបង្រៀន។ វាជាការមានសារៈសំខាន់ដើម្បីលើកស្ទួយឱ្យមានការយល់ដឹង អំពីបញ្ហាសុខភាពខាងផ្លូវភេទ ក្នុងចំណោមមនុស្សពេញវ័យក៏ដូចជា ក្នុងចំណោមកុមារផងដែរ។ ដើម្បីបំរើឱ្យគោលបំណងនោះផ្ទាំងរូបភាពនានា ត្រូវបានបិទនៅពាសពេញផ្ទៃប្រទេស ដោយហេតុថាប្រជាពលរដ្ឋមួយភាគធំជាអក្ខរជន ផ្ទាំងរូបភាពនេះត្រូវបានចាត់ទុកជាមធ្យោបាយ មួយប្រកបដោយប្រសិទ្ធភាពដើម្បីបង្កើនឱ្យមានការយល់ដឹងអំពីបញ្ហា ។

៥១- <u>លោក **DOEK**</u> បានលើកឡើងវិញអំពីសំណួររបស់លោកស្តីពីតួនាទីរបស់តុលាការ និងទីភ្នាក់ងារអនុវត្តច្បាប់ក្នុងការដោះស្រាយករណីនៃការធ្វើអាជីវកម្មខាងផ្លូវភេទ ការរំលោភសេពសន្ថវៈ និងពេស្យាកម្ម។ យោងទៅតាមរបាយការណ៍មួយ មន្ត្រីនគរបាល១១រូប បន្ថែមពីលើមន្ត្រីរាជការស៊ីវិល និងមន្ត្រីរដ្ឋាភិបាលផ្សេងទៀត ត្រូវបានចោទប្រកាន់ពីបទរំលោភសេពសន្ថវៈ ក្នុងឆ្នាំ ១៩៩៨។ ពុំមានករណីណាមួយរបស់ពួកគេត្រូវបានលើកយកមកកាត់ទោសឡើយ ទោះបីជាមានករណីខ្លះត្រូវបានដោះស្រាយក្រៅតុលាការ ហើយតាមការរាយការណ៍ឱ្យដឹង ករណីមួយចំនួនមានជាប់ពាក់ព័ន្ធនឹងអាពាហ៍ពិពាហ៍ដែលបានរៀបចំទុករវាងអ្នករំលោភគេ និងជនរងគ្រោះ។ ប្រហែលជាដោយសារថា សមាជិកនៃស្ថាប័នតុលាការតំរូវឱ្យមានការណែនាំក្នុងការដោះស្រាយ ករណីបែបនេះនោះ។ លើសពីនេះទៀត ប្រាក់បៀវត្សរ៍របស់ចៅក្រមគួរត្រូវបានដំឡើងដើម្បីធានាឱ្យមានជីវភាពរស់នៅសមរម្យ និងដើម្បីកាត់បន្ថយនូវភាពទោរទន់របស់ពួកគេទៅរកអំពើពុករលួយ។

៥២- ក្នុងឆ្នាំ១៩៩៧ អនុគណៈកម្មការទទួលបន្ទុកពលកម្មកុមារ ត្រូវបានបង្កើតឡើង ប៉ុន្តែការសិក្សាដែលត្រូវបានធ្វើឡើងនាពេលថ្មីៗនេះ ដោយកម្មវិធីស្តីពីការលុបបំបាត់ចោលនូវពលកម្មកុមារអន្តរជាតិរបស់អង្គការការងារអន្តរជាតិ **(IPEC)** បានរកឃើញថាកុមារកម្ពុជាប្រហែលជា៥០០.០០០នាក់ ដែលស្ថិតក្នុងអាយុចន្លោះពី៥ ទៅ១៧ឆ្នាំ បានកំពុងបំរើការងារនៅឡើយ។ កម្មវិធីសាកល្បងមួយចំនួនប្រឆាំងនឹងពលកម្មកុមារត្រូវបានចាប់ផ្តើមឡើងនៅឆ្នាំ១៩៩៦ ឬ១៩៩៧ តើកម្មវិធីនេះត្រូវបានពង្រីកដែរឬទេ? អ្វីខ្លះដែលត្រូវបានអនុវត ដោយអនុលោមទៅតាមកម្មវិធី**(IPEC)** ដើម្បីទប់ស្កាត់កុមារកុំឱ្យចូលបំរើការងារ និងដើម្បីធ្វើសមាហរណកម្មកុមារដែលបានបំរើការងារហើយទាំងនោះឱ្យចូលទៅក្នុងប្រព័ន្ធអប់រំវិញ ? ។

៥៣- <u>លោកស្រី **TIGERTEDT-TAHTELA**</u> បានមានប្រសាសន៍ថា ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារហាក់ដូចជាបាន ដើរតួនាទីជាអ្នកសំរបសំរួល និងឃ្លាំមើលនៅពេលដែលការអនុវត្តជាក់ស្តែងនៃអនុសញ្ញា ត្រូវបានផ្តល់ឱ្យក្រសួងផ្សេងៗរបស់រដ្ឋាភិបាលជាអ្នកបំពេញវិញ។ រដ្ឋាភិបាលបានថ្លែក្នុងការឆ្លើយតបជាលាយលក្ខ័អក្សរថាក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ត្រូវការជាចាំបាច់ដើម្បីពង្រឹងសមត្ថភាពរបស់ខ្លួននិងថាវាត្រូវការជំនួយបច្ចេកទេស និងការជួយឧបត្ថម្ភខាងហិរញ្ញវត្ថុពីបណ្តាប្រទេសផ្សេងៗ និងអង្គការអន្តរជាតិផងដែរ។ តើរដ្ឋាភិបាលមានគំរោងដើម្បីកែទំរង់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារពីស្ថាប័នប្រឹក្សាយោបល់ឱ្យក្លាយទៅជា ស្ថាបន័ប្រតិបត្តិមួយដែរឬទេ ?

<u>កិច្ចប្រជុំត្រូវបានឈប់សំរាកនៅម៉ោង ០៥:៣០នាទីល្ងាច ហើយចាប់ផ្តើមវិញនៅម៉ោង ០៥:៣៥នាទីល្ងាច</u>

៥៤- <u>លោក **PHEARITH**</u> (កម្ពុជា) បានមានប្រសាសាន៏ថា ច្បាប់ប្រឆាំងនឹងការធ្វើអាជីវកម្មខាងផ្លូវភេទលើស្ត្រី និងកុមារនៅមានជាអត្ថិភាពស្រាប់ ហើយត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាពក្នុងករណីមួយចំនួន។ ការកាត់ទោសឱ្យជាប់ពន្ធនាគាររហូតដល់១៥ឆ្នាំ ត្រូវបានអនុវត្តចំពោះការរំលោភសេចសន្ធវៈលើអនីតិជន ឬចំពោះការជួញដូរខាងផ្លូវភេទ។ ស្ថាបន័តុលាការដែលត្រូវបានចាត់ទុកដោយសហគមន៏អន្តរជាតិជាពិសេសថា មានលក្ខណៈទន់ខ្សោយនោះ បច្ចុប្បន្នកំពុងតែឆ្លងកាត់នូវការកែទំរង់យ៉ាងធំទូលាយមួយ។ ដោយមានជំនួយរបស់ ទីភ្នាក់ងារអន្តរជាតិមួយក្រសួងមហាផ្ទៃ បានបង្កើតឡើងនូវអង្គភាពពិសេសមួយដើម្បីប្រយុទ្ធប្រឆាំង និងការជួញដូរផ្លូវភេទលើអនីតិជន។ អង្គការក្រៅរដ្ឋាភិបាលមួយចំនួនបានកំពុងបំពេញការងារប្រឆាំងនឹងពលកម្មកុមារ ហើយអង្គការក្រៅរដ្ឋាភិបាលខ្លះបានដាក់ស្នើផែនការសកម្មភាពមួយជូនទៅអនុគណៈកម្មការទទួលបន្ទុកផ្នែកពលកម្មកុមារហើយ។ រដ្ឋាភិបាលនឹងបែងចែកធនធាននានា ទៅឱ្យអង្គការក្រៅរដ្ឋាភិបាលសំរាប់ការអនុវត្តនូវផែនការសកម្មនោះ ក្នុងនោះមានយុទ្ធនាការផ្សព្វផ្សាយតាមប្រព័ន្ធសារពតិមាន សន្និសីទសារពតិមាន និងជំនួយសំរាប់កុមារដែលងាយរងគ្រោះបំផុត។

៥៥- <u>លោកស្រី **HARANVADDEY**</u> បានមានប្រសាសន៏ថា ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ គឺជាស្ថាបន័ជាតិសំរាប់ ការសំរបសំរួលត្រួតពិនិត្យមើល និងវាយតំលៃលើកម្មវិធីនានាសំរាប់កុមារ ហើយក៏បានអនុវត្តយុទ្ធនាការខាងការការពារផងដែរ ។ វាតំរូវឱ្យមានថវិកាគ្រប់គ្រាន់ដើម្បីធានាឱ្យមានការអនុវត្តអនុសញ្ញាដោយក្រសួងផ្សេងៗ។ ឧទាហរណ៏នៅពេល ដែលផែនការសកម្មភាពប្រឆាំងនឹងអាជីវកម្មខាងផ្លូវភេទលើកុមារ ត្រូវបានតាក់តែងឡើងក្រសួងដែលមានពាក់ព័ន្ធនានាបានស្នើសុំការផ្តល់នូវហិរញ្ញប្បទានពីក្រុមប្រឹក្សាជាតិកម្ពុជា ដើម្បីកុមារសំរាប់ការអនុវត្តផែនការនេះ។ គេត្រូវការធនធានទាំងឡាយដើម្បីបង្កើតឡើងនូវគណៈកម្មាការ ទទួលបន្ទុកផ្នែកពលកម្មកុមារនេះ និងសំរាប់ការបណ្តុះបណ្តាលដែលក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារបានផ្តល់ឱ្យបុគ្គលិកក្នុងក្រសួងដែលពាក់ព័ន្ធ និងសំរាប់បុគ្គលិករបស់ខ្លួនផ្ទាល់ហើយ។ បុគ្គលិកបានចូលរួមក្នុងសិក្ខាសាលានានាក្នុងប្រទេសកម្ពុជា និងក្រៅប្រទេសដើម្បីសិក្សាអំពីវិធីដើម្បីត្រួតពិនិត្យមើលការអនុវត្តច្បាប់ និងអំពីរបៀបប្រមូលពតិមាន និងដាក់បញ្ចូលទិន្នន័យ។ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារមិនមែនគ្រាន់តែជា ស្ថាបន័មួយដែលចាំតែធ្វើការពិនិត្យតាមដាន និងផ្តល់

ប្រឹក្សាយោបល់ប៉ុណ្ណោះទេ ប៉ុន្តែវាថែមទាំងពាក់ព័ន្ធយ៉ាងជ្រៅក្នុងការបង្កើត និងអនុវត្តគោលនយោបាយរបស់រដ្ឋាភិបាលក្នុងវិស័យនេះដែរ ។

៥៦- <u>លោកស្រីប្រធានអង្គប្រជុំ</u> បានអញ្ជើញលោកស្រី **Tigerstedt-Tahtela** អ្នករាយការណ៍ប្រចាំប្រទេសឱ្យបង្ហាញនូវកំណត់សំគាល់ដំបូងលើការពិភាក្សានានាជាមួយគណៈប្រតិភូកម្ពុជា ។

៥៧- <u>លោកស្រី **Tigerstedt-Tahtela**</u> (អ្នករាយការណ៍ប្រចាំប្រទេស) បានថ្លែងអំណរគុណដល់គណៈប្រតិភូចំពោះការចូលរួមនៅក្នុងការសន្ទនាគ្នាប្រកបដោយលក្ខណៈស្ថាបនាក្នុងស្មារតីនៃសហប្រតិបត្តិការ ។គណៈកម្មាធិការបានដឹងអំពីប្រវត្តិសាស្ត្ររបស់ប្រទេសអំពើឃោឃៅដែលប្រទេសនេះបានជួបប្រទះ និងការខ្វះខាតនាពេលបច្ចុប្បន្ននេះនូវធនធានហិរញ្ញវត្ថុ និងធនធានមនុស្ស ។ ដូចដែលគណៈប្រតិភូបានថ្លែហើយកម្ពុជាបានចាប់ផ្តើម ស្ទើរតែពីបាតដៃទទេក្នុងវិស័យជាច្រើន ។

៥៨- ការអនុវត្តអនុសញ្ញា គឺជានយោបាយ គឺជាបញ្ហានយោបាយហើយគឺជាបញ្ហាមួយដែលសមទទួលបាននូវអាទិភាពខ្ពស់បំផុត។ ប្រហែលជាថវិការដ្ឋគួរត្រូវតែបែងចែងសារជាថ្មីដើម្បីឆ្លុះបញ្ចាំងឱ្យឃើញនូវអាទិភាពនោះ ឱ្យបានកាន់តែប្រសើរឡើង។ នៅខណៈពេលដែលអង្គការក្រៅរដ្ឋាភិបាល និងសហគមន៍អន្តរជាតិអាចជួយឧបត្ថម្ភបាន តែការទទួលខុសត្រូវទីបំផុត គឺជាការទទួលខុសត្រូវរបស់រដ្ឋាភិបាល ។

៥៩- កម្ពុជាបានយល់ព្រមចូលជាភាគីចំពោះឧបករណ៍សិទ្ធិមនុស្សសំខាន់ៗចំនួន៦ ។ កម្ពុជាបានដាក់បញ្ចូលក្នុងរដ្ឋធម្មនុញ្ញនូវសិទ្ធិទាំងឡាយដែលមានចែងក្នុងអនុសញ្ញា ហើយកម្ពុជាក៏បានធ្វើបញ្ចប់នូវមនុស្សរណៈនៃការយោគយល់គ្នាមួយ ជាមួយនឹងការិយាល័យនៃឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សដែរ។ ថ្មីៗនេះ កម្ពុជាក៏បានឱ្យស្ថាបន័អនុសញ្ញាស្តីពីអាយុអប្បបរិមាឆ្នាំ ១៩៧៣ របស់អង្គការការងារអន្តរជាតិ (លេខ១៣៨) ហើយកំពុងពិចារណាលើការឱ្យសច្ចាបន័លើអនុសញ្ញាស្តីពីរូបភាពដ៏អាក្រក់បំផុត នៃពលកម្មកុមារឆ្នាំ១៩៩៩ (លេខ១៨២)។ គណៈកម្មាធិការសូមផ្តល់អនុសាសន៍ថា ច្បាប់នានាដែលមានស្រាប់គួរត្រូវពិនិត្យមើលឡើងវិញ ដើម្បីធានាថាច្បាប់ទាំងនេះសមស្របទៅតាមបទបញ្ញត្តិនៃអនុសញ្ញា ជាពិសេសទាក់ទងនឹងការចុះបញ្ជីកំណើត បញ្ហាគ្រួសារ ការថែទាំដែលអាចជ្រើសរើសបាន និងយុត្តិធម៌អនីតិជន។ ប្រព័ន្ធប្រមូលទិន្នន័យរបស់ប្រទេសត្រូវតែបានពង្រឹងឡើង ។ រដ្ឋាភិបាលគួរចាត់វិធានការដើម្បីធានាថាកុមារទាំងអស់ ទទួលបាននូវសិទ្ធិទាំងអស់នេះ ដោយគ្មានការរើងអើងឡើយ ។ រដ្ឋាភិបាលគួរលើស្ទួយការចូលរួមរបស់កុមារក្នុងគ្រួសារ សាលារៀន ស្ថាបន័ និងក្នុងរដ្ឋបាលមូលដ្ឋាននានា ហើយគួរទទួលស្គាល់សិទ្ធិរបស់កុមារចំពោះសេរីភាពក្នុងការបញ្ចេញមតិ និងសមាគម។ បណ្តឹងអំពីការរំលោភបំពានលើកុមារគួរត្រូវ បានចាត់ការឱ្យឆាប់ និងប្រកបដោយប្រសិទ្ធភាព ដោយទីភ្នាក់ងារអនុវត្តច្បាប់ និងស្ថាបន័តុលាការតាមការរាយការណ៍បង្កើតឱ្យមាននូវនិតិវិធីដែលអាចអនុវត្តន៏បានចំពោះកុមារ ក្នុងគោលបំណងដើម្បីជៀសវៀង កុំឱ្យជនល្មើសគេចផុតពីការដាក់ទណ្ឌកម្ម។ ប្រព័ន្ធយុតិធមិអនីតិជនត្រូវតែបង្កើតឡើង។ រដ្ឋាភិបាលក៏គួរអភិវឌ្ឍន៏ផងដែរនូវបទបញ្ញត្តិសំរាប់ស្ថាបន័នានា និងទំរង់ផ្សេងៗនៃការថែទាំដែលអាចជ្រើសរើសបាន។ កុមារដែលមានពិការភាពគួរត្រូវបានធ្វើសមាហរណកម្មចូលទៅក្នុង ប្រព័ន្ធសាលារៀន និងគួរត្រូវបានផ្តល់នូវការគាំទ្រ ហើយសេវាកម្មខាងសង្គមកិច្ចសំរាប់ធ្វើសម្បទាជនរងគ្រោះជាកុមារដោយសារអំពើរំលោភបំពាន និងការធ្វើអាជីវកម្មគួរត្រូវពង្រឹង និងពង្រីក។ រាជរដ្ឋាភិបាលគួរអនុវត្តនូវបទបញ្ញត្តិផ្សេងៗ នៃច្បាប់ការងារ ដែលទាក់ទងនឹងអាយុអប្បបរិមាដើម្បីអាចចូលធ្វើការងារបាន ហើយគួរបណ្តុះបណ្តាលក្រុមអធិការកិច្ចការងារ និងផ្តល់ឱ្យពួកគេនូវវិធីដើម្បីតាមដានមើលពលកម្មកុមារ ។

៦០- <u>លោក **SETHY**</u> (កម្ពុជា) បានមានប្រសាសន៍ថា រាជរដ្ឋាភិបាលកម្ពុជាបានធ្វើការយកចិត្តទុកដាក់លើ អនុសាសន៍នានាដែលគណៈកម្មាធិការបានធ្វើឡើង។ គណៈប្រតិភូរបស់ លោកបានសំដែងនូវការដឹងគុណដល់អង្គការ **UNICEF** ចំពោះការជួយឧបត្ថម្ភខាងហិរញ្ញវត្ថុ និងស្បៀងដែលបានអនុញ្ញាតិឱ្យសមាជិករបស់គណៈប្រតិភូ២រូប ចូលរួមក្នុងកិច្ចប្រជុំរបស់គណៈកម្មាធិការ។

៦១- <u>លោកស្រីប្រធានអង្គប្រជុំ</u> បានមានប្រសាសន៍ថា វាមានសារៈសំខាន់ដើម្បីសំរបសំរួលសកម្មភាពរបស់អង្គការក្រៅរដ្ឋាភិបាល និងស្ថាប័នរទេសរាប់រយ ដែលបច្ចុប្បន្នកំពុងតែបំពេញការងារក្នុងប្រទេសកម្ពុជា។ លោកស្រីបានលើកទឹកចិត្តឱ្យរាជរដ្ឋាភិបាល ធ្វើការពិចារណាលើការបង្កើតឡើង អនុការិយាល័យទទួលបណ្តឹងខាងសិទ្ធិមនុស្ស **(an ombudsman for human rights)** ហើយបង្កើតឡើងវិញនូវគោលនយោបាយខាងការអប់រំ ដោយមានការចូលរួមមិនមែនតែប្រជាពលរដ្ឋទេ ប៉ុន្តែជាពិសេសកុមារផងដែរ ជាពិសេសទាក់ទងនឹងវិធីសាស្ត្រដែលបានប្រើប្រាស់ហើយ។ ទោះបីជាមានការទទួលស្គាល់របស់រាជរដ្ឋាភិបាលលើបញ្ហានៃការធ្វើអាជីវកម្មខាងផ្លូវភេទ គឺជាការគួរឱ្យសរសើរ រដ្ឋាភិបាលនៅតែត្រូវអនុមត័នីតិកម្មដែលនឹងកំណត់អាយុ ដែលនឹងអនុញ្ញាតិយល់ព្រមឱ្យមានការទំនាក់ទំនងខាងផ្លូវភេទបាន ដែលនេះនឹងបង្ហាញពិត។នូវសារៈប្រយោជន៍ក្នុងការផ្តល់នូវសិទ្ធិដល់កម្មវិធីការពារកុមារទាំងឡាយ ដែលខ្លួនបានអនុមត័យល់ព្រមនោះ។ លោកស្រីក៏បានអំពាវនាវសូមឱ្យគណៈប្រតិភូធ្វើការធានាថារបាយការណ៍នេះ និងកំណត់សំគាល់សន្និដ្ឋានរបស់គណៈកម្មាធិការពាក់ព័ន្ធនឹងកម្ពុជា និងត្រូវបានផ្សព្វផ្សាយទូទាំងប្រទេស ។

<u>កិច្ចប្រជុំនេះបញ្ចប់នៅម៉ោង ០៦:១០នាទី ល្ងាច</u>

**ព្រះរាជាណាចក្រកម្ពុជា**
**KINGDOM OF CAMBODIA**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**NATION RELIGION KING**

**ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ**
**CAMBODIAN NATIONAL COUNCIL FOR CHILDREN**

# របាយការណ៍សិក្ខាសាលាស្តីពីការអនុវត្តរបស់រាជរដ្ឋាភិបាល ចំពោះសេចក្តីសង្កេតចុងក្រោយរបស់គណៈកម្មាធិការសិទ្ធិកុមារនៃ អ.ស.ប ២២-២៣ មករា ២០០១

~~~~~~~~~

ឆ្នាំពីរពាន់មួយ ខែមករា ថ្ងៃទីម្ភៃពីរ និង ម្ភៃបី ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ បានរៀបចំសិក្ខាសាលាជាតិមួយស្តីពីការអនុវត្តរបស់រាជរដ្ឋាភិបាលចំពោះសេចក្តីសង្កេតចុងក្រោយរបស់គណៈកម្មាធិការសិទ្ធិកុមារ នៃអង្គការសហប្រជាជាតិដែលធ្វើឡើងក្រោមអធិបតីភាព ឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី និងបិទក្រោមអធិបតីភាពឯកឧត្តម **សុខ អាន** ទេសរដ្ឋមន្ត្រី-រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី។ សិក្ខាកាម និងភ្ញៀវកិត្តិយសចូលរួមចំនួន១០០នាក់ ជាថ្នាក់ដឹកនាំ និងមន្ត្រីនៃក្រសួង ស្ថាប័ន រដ្ឋាភិបាល ជាតំណាងអង្គការក្រៅរដ្ឋាភិបាល និងអង្គការអន្តរជាតិ។ សិក្ខាសាលានេះបានទទួលការឧបត្ថម្ភថវិកាពីអង្គការយូនីសេហ្វ និងការិយាល័យឧត្តមស្នងការសិទ្ធិមនុស្ស នៃអង្គការសហប្រជាជាតិ នឹងបានប្រព្រឹត្តទៅតាមកម្មវិធីដែលបានគ្រោងទុក ។

- ជាកិច្ចចាប់ផ្តើម ឯកឧត្តម **អ៊ិត សំហេង** ប្រធានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ បានឡើងថ្លែងសន្ទរកថាស្វាគមន៍ដោយបានជំរាបជូនអំពីកាតព្វកិច្ចធ្វើរបាយការណ៍របស់ប្រទេសកម្ពុជាស្តីពីការអនុវត្តអនុសញ្ញាសិទ្ធិកុមារ ការផ្តល់អនុសាសន៍ដោយអង្គការសហប្រជាជាតិ កិច្ចខិតខំប្រឹងប្រែងកន្លងមកលើការងារកុមារ និងបញ្ហាជាច្រើនដែលនៅតែកើតមានចំពោះកុមារ ដែលតំរូវឱ្យមានពិនិត្យឡើងវិញលើកម្មវិធីទាំងឡាយ និងរកវិធានការដោះស្រាយឱ្យបានសមស្របតាមអនុសាសន៍។ _ឧបសម្ព័ន្ធ ១_

- បន្ទាប់មកឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រី បានថ្លែងសន្ទរកថាបើកសិក្ខាសាលា ដោយបានស្វាគមន៍យ៉ាងកក់ក្តៅ បានបញ្ជាក់អំពីសារៈសំខាន់ និងអត្ថន័យដ៏ធំធេងដែលកន្លងមករាជរដ្ឋាភិបាល ក៏ដូចជាប្រជាជនកម្ពុជាបានអនុវត្ត ហើយក៏កំពុងផ្តោតការយកចិត្តទុកដាក់បន្ថែមទៀតដើម្បីសិទ្ធិកុមារ។ ឯកឧត្តមបានកោតសរសើរដល់ក្រសួង ស្ថាប័ន និងអង្គការទាំងអស់ដែលបានយកចិត្តទុកដាក់ធ្វើការងារកុមារប្រកបដោយលទ្ធផលល្អប្រសើរ និងបានលើកនូវចំណុចខ្វះខាតដែលជាអំពើផ្ទុយ នឹងចលនាពិភពលោក ។

ការអនុវត្តអនុសញ្ញាមិនទាមទារការយល់ដឹង និងបច្ចេកទេសប៉ុណ្ណោះទេ គឺត្រូវមានសុឆន្ទៈមោះមុត និងស្មារតីទទួលខុសត្រូវខ្ពស់ពីស្ថាប័នដែលពាក់ព័ន្ធ ក៏ដូចជាបុគ្គលទទួលខុសត្រូវ។ ដើម្បីកសាងប្រទេសឱ្យរឹងមាំ និងមានអភិវឌ្ឍន៍ភាព គឺត្រូវកសាងធនធានមនុស្ស ដែលក្នុងនោះកុមារមាន៥២.៤%។ ឯកឧត្តមមានជំនឿថា អង្គសិក្ខាសាលានឹងរកឃើញចំណុចខ្វះខាតព្រមទាំងបទពិសោធន៍ថ្មីៗដើម្បីអនុវត្ត និងបានថ្លែងអំណរគុណដល់អង្គការយូនីសេហ្វ និងការិយាល័យឧត្តមស្នងការសិទ្ធិមនុស្ស
~~~~~~~~~

នៃអង្គការសហប្រជាជាតិ ដែលឧបត្ថម្ភថវិកាសំរាប់សិក្ខាសាលា។ បន្ថែមលើនេះឯកឧត្តមបានណែនាំដល់ក្រសួង ស្ថាប័នពាក់ព័ន្ធ ឱ្យអនុវត្តតាមផ្លូវច្បាប់ ក្នុងការងារសុំកូនចិញ្ចឹមឱ្យមានការតាមដាន ត្រួតពិនិត្យ ហើយបានស្នើរឱ្យក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា ក្រសួងពាក់ព័ន្ធ ជំរុញថែមទៀតនូវការរៀបចំសេចក្តីព្រាងអនុក្រឹត្យ ឱ្យបានឆាប់រហ័ស ដោយត្រូវគិតដល់សុខភាពកុមារផងដែរ ដើម្បីរួចចំណែកលើកស្ទួយសិទ្ធិកុមារកាន់តែប្រសើរឡើង។ រាជរដ្ឋាភិបាល គ្មានគោលការណ៍ហាមឃាត់មិនឱ្យជនបរទេសសុំកុមារទៅចិញ្ចឹមទេ ប៉ុន្តែត្រូវបំពេញតាមគោលការណ៍ឱ្យបានត្រឹមត្រូវដើម្បីធានាបាននូវការគោរពសិទ្ធិមនុស្ស ។ *ឧបសម្ព័ន្ធ២*

- ឯកឧត្តម **អ៊ឹម សិទ្ធី** រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា បានជំរាបជូនអង្គសិក្ខាសាលាអំពីការចូលរួមប្រជុំសួរដេញដោលរបស់គណៈប្រតិភូរាជរដ្ឋាភិបាល ជាមួយគណៈកម្មាធិការសិទ្ធិកុមារនៃអង្គការសហប្រជាជាតិ នៅទីក្រុងស៊ឺណែវ កាលពីថ្ងៃទី២៤ ឧសភា ២០០០។ គណៈប្រតិភូបានធ្វើឱ្យគណៈកម្មាការជ្រាបអំពីស្ថានភាពនៅកម្ពុជា ការប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការងារកុមារ។ គណៈប្រតិភូបានទទួលការវាយតំលៃខ្ពស់ចំពោះការចូលរួម ដែលមានការចាត់តាំងមានរបៀបក្នុងការឆ្លើយតប និងតស៊ូធ្វើការរហូតចប់ចុងចប់ដើម ថ្វីបើពុំអាចឆ្លើយបានមួយរយភាគរយក៏ដោយ ក៏មានឆន្ទៈក្នុងការងារកុមារ។ គណៈកម្មាធិការបានផ្តល់អនុសាសន៍មួយចំនួន ដើម្បីរួមចំណែកលើកស្ទួយសិទ្ធិកុមារនៅកម្ពុជា ដែលក្នុងនោះមានការស្វាគមន៍៦ចំណុច និង មានការព្រួយបារម្ភជាច្រើន ដែលយើងត្រូវចាប់អារម្មណ៍ ទោះជាពុំអាចធ្វើអស់ក៏ដោយ ក៏យើងត្រូវធ្វើការងារជាអទិភាពលើអទិភាពដែរ។ ឯកឧត្តមបានបន្ថែមទៀតថា ចាំបាច់ត្រូវពង្រឹងការងារ ក.ជ.ក.ក ការងារសហការសំរបសំរួលដើម្បីងាយស្រួលប្រមូលទិន្នន័យ និង ឱ្យមានបណ្តាញគ្រប់ថ្នាក់ខេត្ត-ក្រុង ព្រមទាំងមានការជួបពិភាក្សាគ្នានូវអ្វីដែលខ្វះចន្លោះ។ ការប្រជុំជាមួយគណៈកម្មាធិការសិទ្ធិកុមារគួរមានការចូលរួមពីក្រសួងមហាផ្ទៃ ដែលជាអ្នកពង្រឹងការអនុវត្ត និងក្រសួងយុត្តិធមិជាអ្នកធ្វើច្បាប់។ ដើម្បីធ្វើរបាយការណ៍ សូមឱ្យរៀបចំជាមុន ត្រូវធ្វើការតាមដាន ការទំនាក់ទំនង ដើម្បីតភ្ជាប់ការងារដូចក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារកំពុងធ្វើ ។

- បន្ទាប់មកទៀត លោកស្រី **ចំនួ ហារ៉ានវឌ្ឍី** អគ្គលេខាធិការក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ បានបង្ហាញអំពីលទ្ធផលនៃការអនុវត្តកម្មវិធីសកម្មភាពជាតិដើម្បីកុមារ ឆ្នាំ១៩៩៨-២០០០ ដែលជាក់ស្តែងមានកម្មវិធីថ្មីៗបានកើតឡើងសំរាប់កុមារ និង ស្ថានភាពកុមារបានប្រសើរជាងឆ្នាំមុនៗ ។ *ឧបសម្ព័ន្ធ៣*

- លោកស្រី **ប្រាំងសេស្ទារ ម៉ារ៉ូតា** តំណាងការិយាល័យសិទ្ធិមនុស្ស នៃអង្គការសហប្រជាជាតិ បានជំរាបជូនជាសង្ខេបអំពីអនុសាសន៍របស់គណៈកម្មាធិការសិទ្ធិកុមារ ។ *ឧបសម្ព័ន្ធ៤*

ចូលដល់កម្មវិធីពេលរសៀល អង្គសិក្ខាសាលាបានបែងចែកជា៧ក្រុម ហើយធ្វើការពិភាក្សាលើប្រធានបទ ពង្រឹងការងារក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ Ombudperson ច្បាប់ កាតព្វកិច្ចគ្រួសារ ការថែទាំផ្សេងៗ សុខភាព និងសុខុមាលភាព ការសិក្សាអប់រំ ការប្រឆាំងពេស្យាចារកុមារ ការងារផ្សព្វផ្សាយពត៌មាន ។

♦ នៅថ្ងៃទី២៣ ខែមករា ឆ្នាំ២០០១ អង្គសិក្ខាសាលាបានបន្តការងាររបស់ខ្លួន តាមកម្មវិធីដូចមាន :

- លោក **ស៊ឹម សូយុទ** តំណាងអង្គការក្រៅរដ្ឋាភិបាលធ្វើការងារសិទ្ធិកុមារ បានឡើងធ្វើរបាយការណ៍អំពីអនុសាសន៍របស់អង្គសិក្ខាសាលា នៃអង្គការក្រៅរដ្ឋាភិបាលដែលបានធ្វើឡើងនៅថ្ងៃទី ១៦-១៧ វិច្ឆិកា ឆ្នាំ២០០០។ *ឧបសម្ព័ន្ធ៥*

-តំណាងក្រុមទាំង៧ បានធ្វើរបាយការណ៍អំពីលទ្ធផលនៃការពិភាក្សា ។ *ឧបសម្ព័ន្ធ៦*

នៅពេលម៉ោង២រសៀល លោកស្រី **ចំនួ ហារ៉ានវដ្តី** បានធ្វើសេចក្តីរាយការណ៍ជូនអ្នកកាសែតអំពីអនុសាសន៍របស់អង្គការសហប្រជាជាតិ និងលទ្ធផលនៃការពិភាក្សា។ បន្ទាប់មកទៀតអង្គសិក្ខាសាលា បានធ្វើការពិភាក្សាតាមក្រសួងនីមួយៗរបស់ខ្លួន ជាលទ្ធផលក្រសួងនីមួយៗបានលើកឡើងនូវកម្មវិធីជាក់ស្តែងដើម្បីអនុវត្តក្នុងក្រសួងរបស់ខ្លួនសំរាប់ឆ្នាំ២០០១។ *ឧបសម្ព័ន្ធ៧*

នៅវេលាម៉ោង១៨.00 អង្គសិក្ខាសាលាបានឈានដល់ការបិទកម្មវិធី ក្រោមអធិបតីឯកឧត្តម **សុខ អាន** ទេសរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ។ *ឧបសម្ព័ន្ធ៨*

ជាកិច្ចចាប់ផ្តើមឯកឧត្តម **អ៊ិត សំហេង** បានឡើងធ្វើសេចក្តីរាយការណ៍សង្ខេបអំពីដំណើរការប្រព្រឹត្តទៅរបស់សិក្ខា-សាលារយៈពេល២ថ្ងៃ តាមកម្មវិធីដែលបានគ្រោងទុក និងទទួលបាននូវលទ្ធផលជាមតិល្អៗ ដែលលើកឡើងជាសំណូមពរជូនរាជរដ្ឋាភិបាល ។

ឆ្លើយតបទៅនឹងសិក្ខាសាលាឯកឧត្តម **សុខ អាន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី បានថ្លែងសន្ទរកថា គាំទ្រយ៉ាងពេញទំហឹងចំពោះអង្គសិក្ខាសាលា ដែលបង្ហាញដល់សកលលោកនូវអ្វីដែលជាឆន្ទៈប្តេជ្ញារបស់ប្រទេសកម្ពុជាបង្ហាញឱ្យឃើញពីកិច្ចសហការជិតស្និទ្ធរវាង ក.ជ.ក.ក ក្រសួង និងអង្គការដែលពាក់ព័ន្ធ បានរកឃើញនូវវិធីសាស្រ្តដើម្បីសំរបសំរួល ត្រួតពិនិត្យ និងអនុវត្តអនុសញ្ញាសិទ្ធិកុមារ ឱ្យមានជាខ្សែរយៈពីថ្នាក់កណ្តាលរហូតដល់មូលដ្ឋាន ឈានទៅកាត់បន្ថយបញ្ហារបស់កុមារ។ កង្វះខាតផ្នែកសេដ្ឋកិច្ចជាកត្តាមួយ ប៉ុន្តែស្មារតីតស៊ូស្វិតស្វាញក៏ជាកត្តាសំខាន់ក្នុងការលើកស្ទួយសិទ្ធកុមារ ។ បច្ចុប្បន្នរាជរដ្ឋាភិបាលកំពុងប្រកាន់យកនូវការកែទំរង់មួយ ដែលនាំមកនូវការស្តារនឹងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធសង្គមក្នុងរយៈពេល១០ឆ្នាំខាងមុខ។ ឯកឧត្តមបានបន្ថែមទៀតថា អនុសញ្ញាបានត្រូវអនុវត្តទូទាំងសកលលោក សិក្ខាសាលាបានលើកសំណូមពរជាច្រើន មានទាំងការពង្រឹងក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ការពិនិត្យឡើងវិញ និងអនុវត្តច្បាប់ ថវិកាជាដើម។ ចំពោះថវិកា ត្រូវតែគិតគូរឱ្យមានតែជាចំណែកមួយប៉ុណ្ណោះ មិនអាចគ្រប់គ្រាន់ទេ ត្រូវស្វែងរកជំនួយពីក្រៅថែមទៀត។ ទាក់ទិននឹងការរៀបចំច្បាប់ដែលពាក់ព័ន្ធកុមារយើងមានប្រព័ន្ធ មានអ្នកច្បាប់ចូលរួម នេះជាចំណុចដែលត្រូវពិភាក្សា។ ឯកឧត្តម បានណែនាំ ឱ្យមានក្រុមការងារមួយដែលមានឯកឧត្តម **សោម សុផល** ចូលរួមមានសមាសភាពពីគណៈរដ្ឋមន្ត្រី ក្រសួងហិរញ្ញវត្ថុ ក្រសួងយុត្តិធម៌ តំណាងក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ អ្នកច្បាប់ នគរបាល ក្រសួងមហាផ្ទៃ ធ្វើការពិចារណា លើសំណូមពរ និង វិធីសាស្រ្តជាក់ស្តែងថាតើចង់ធ្វើអ្វី បញ្ហាណាត្រូវអនុវត្តមុន អ្វីត្រូវអនុវត្តជាបន្ទាប់ ធ្វើរបៀបណា ហើយស្នើឡើងទៅគណៈរដ្ឋមន្ត្រី។ រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់ ហើយផ្អែកតាមស្ថានភាពជាក់ស្តែង ក្រុមការងារត្រូវធ្វើឱ្យហ្មត់ចត់ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់យើង។ ជាអវសានឯកឧត្តមបានជូនពរដល់អង្គសិក្ខាសាលា ភ្ញៀវកិត្តិយស សូមប្រកបដោយសេចក្តីសុខ និង ជោគជ័យគ្រប់ប្រការ ។

អង្គសិក្ខាសាលាបានចប់សព្វគ្រប់នៅវេលាម៉ោងដប់ប្រាំបួន នាថ្ងៃទី២៣ ខែមករា ឆ្នាំ២០០១ ក្រោមបរិយាកាសរីករាយនិងស្និទ្ធស្នាល ។

*ភ្នំពេញ, ថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០០១*

បានឃើញ និងឯកភាព **អគ្គលេខាធិការ**

**ប្រធានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ**

*ឧបសម្ព័ន្ធ១*

# សន្ទរកថារបស់ឯកឧត្តម អ៊ិត សំហេង រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា និងជាប្រធានក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ថ្លែងក្នុងឱកាសបើកសិក្ខាសាលាជាតិ ស្តីពីការអនុវត្តរបស់រាជរដ្ឋាភិបាល ចំពោះសេចក្តីសង្កេតចុងក្រោយរបស់គណៈកម្មាធិការសិទ្ធិកុមារ នៃអ.ស.ប

**២២-២៣ មករា ២០០១**

- **សូមគោរព ឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាល ជាទីគោរព !**
- **សូមគោរព គណៈអធិបតី អគ្គទូត ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវកិត្តិយសជាតិ អន្តរជាតិ !**
- **សូមគោរព អង្គសិក្ខាសាលា !**

ជាបឋម តាងនាមក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ និង ក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំមានមោតនភាពខ្ពស់ សូមសំដែងនូវគារវកិច្ចស្វាគមន៍ចំពោះវត្តមានរបស់ឯកឧត្តម **ស ខេង** ឧបនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ដែលបានអញ្ជើញជាអធិបតីក្នុងពិធីបើកសិក្ខាសាលា និង វត្តមានរបស់អង្គទូត ឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងអស់ ជាភ្ញៀវជាតិ អន្តរជាតិ ។

សិក្ខាសាលាជាតិថ្ងៃនេះ រៀបចំឡើងក្នុងគោលបំណងឱ្យក្រសួង ស្ថាប័នទាំងអស់ពិនិត្យពិចារណាលើសេចក្តីសង្កេតចុងក្រោយរបស់គណៈកម្មាធិការសិទ្ធិកុមារ នៃអង្គការសហប្រជាជាតិ ស្តីពីការអនុវត្តអនុសញ្ញាសិទ្ធិកុមារនៅកម្ពុជា ហើយកំណត់ទិសដៅ និងផែនការជាក់ស្តែងដើម្បីអនុវត្ត។ ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមជំរាបជូនឯកឧត្តមឧបនាយករដ្ឋមន្ត្រី គណៈអធិបតី ភ្ញៀវកិត្តិយស និងអង្គសិក្ខាសាលាជ្រាបថា អនុសញ្ញាស្តីពីសិទ្ធិកុមារត្រូវបានអនុម័តដោយមហាសន្និបាត នៃអង្គការសហប្រជាជាតិ នៅថ្ងៃទី២០ ខែវិច្ឆកា ឆ្នាំ១៩៨៩ ហើយចូលជាធរមាននៅថ្ងៃទី២ ខែកញ្ញា ឆ្នាំ១៩៩០។ សន្និសីទកំពូលពិភពលោកឆ្នាំ១៩៩០ ដែលមាន១៥០ប្រទេសចូលរួម បានអនុម័តលើគោលដៅអន្តរជាតិ ដើម្បីកុមារលើសកលលោក ទទួលបាននូវការរស់រានមានជីវិត កិច្ចការពារ ការអភិវឌ្ឍ និងការបញ្ចេញទស្សនៈ ។

មាត្រា៤៤ នៃអនុសញ្ញាតំរូវឱ្យប្រទេសហត្ថលេខីផ្តល់របាយការណ៍ដំបូងរបស់ខ្លួន ក្នុងរយៈពេល២ឆ្នាំ ក្រោយពីការផ្តល់សច្ចាប័ន ហើយត្រូវធ្វើរបាយការណ៍ទៀងទាត់រៀងរាល់៥ឆ្នាំម្តង ។

ប្រទេសកម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាស្តីពីសិទ្ធិកុមារនៅថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩២។ នៅឆ្នាំ១៩៩៧ ប្រទេសកម្ពុជាបានធ្វើរបាយការណ៍ដំបូង ជូនគណៈកម្មាធិការសិទ្ធិកុមារនៃអង្គការសហប្រជាជាតិ។ នៅឆ្នាំ២០០០ ប្រទេសកម្ពុជាបានធ្វើរបាយការណ៍ឆ្លើយតបនឹងសំណួរចំនួន២០ របស់គណៈកម្មាធិការសិទ្ធិកុមារ ព្រមទាំងបានបញ្ជូនគណៈប្រតិភូជាន់ខ្ពស់របស់ រាជរដ្ឋាភិបាលកម្ពុជា ដើម្បីចូលរួមការប្រជុំសួរដេញដោលនៅថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០០ នៅទីក្រុងហ្សឺណែវ។ រួមចំណែក ក្នុងការលើកស្ទួយសិទ្ធិកុមារកម្ពុជា គណៈកម្មាធិការសិទ្ធិកុមារនៃអង្គការសហប្រជាជាតិ បានផ្តល់នូវសេចក្តីសង្កេតចុងក្រោយ ដែលជាត្រីវិស័យមួយសំដែងចេញនូវការព្រួយបារម្ភចំពោះចំណុចខ្វះខាត និងផ្តល់អនុសាសន៍ល្អៗ ដើម្បីជាមូលដ្ឋានឱ្យប្រទេសកម្ពុជាយកមកពិចារណាសំរាប់ការអនុវត្តអនុសញ្ញាសិទ្ធិកុមារ ។

កន្លងមក រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់យ៉ាងខ្លាំងក្លាចំពោះការងារកុមារ ពិសេសក្រោយថ្ងៃរំដោះ៧មករា កុមារកំព្រាគ្មានទីពឹងត្រូវបានប្រមូលផ្តុំចិញ្ចឹមបីបាច់ថែរក្សា អប់រំរៀនសូត្រនៅក្នុងមជ្ឈមណ្ឌល កុមារមានជម្ងឺត្រូវបានព្យាបាលនៅមន្ទីរពេទ្យ មានកម្មវិធីចាក់ថ្នាំបង្ការ កម្មវិធីអាហារូបត្ថម្ភ សាលាក៏ត្រូវបានបើកទ្វារប្រមូលសិស្សចូលរៀន។ កុមារបានចូលរួមក្នុងសកម្មភាពវប្បធម៌ សិល្បៈ កីឡា និងចូលរួមក្នុងពិធីផ្សេងៗ ដោយមានកិច្ចសហការពីអង្គការអន្តរជាតិ ក៏ដូចជាអង្គការក្រៅរដ្ឋាភិបាល និងក្រោមការដឹកនាំរបស់រាជរដ្ឋាភិបាល ក្រសួង ស្ថាប័នជំនាញបានអនុវត្តយ៉ាងស្វិតស្វាញលើការងារកុមារ ដែលមានសន្ទុះរីកចំរើនគ្រប់វិស័យ ។

ដើម្បីសំរបសំរួល និងត្រួតពិនិត្យតាមដានការងារសិទ្ធិកុមារ រាជរដ្ឋាភិបាលបានបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ។ ក្រុមប្រឹក្សាបានរៀបចំឱ្យមានអនុគណៈកម្មការធ្វើការងារជំនាញ ដូចជាអនុគណៈកម្មការប្រឆាំងពលកម្មកុមារ និងទំរង់កេងប្រវ័ញ្ចគ្រប់ប្រភេទ ហើយថ្មីៗនេះមានអនុគណៈកម្មការតាក់តែងច្បាប់ដែលពាក់ព័ន្ធនឹងកុមារ ដើម្បីតាក់តែងច្បាប់ឱ្យមានលក្ខណៈសមស្របទៅនឹងអនុសញ្ញា អនុគណៈកម្មការប្រឆាំងពេស្យាចារកុមារដែលមានតួនាទីសំរបសំរួល និងជំរុញការអនុវត្តផែនការ៥ឆ្នាំ ប្រឆាំងការជួញដូរ និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ។ ផែនការនេះ បានត្រូវក្រសួងជំនាញអនុវត្តយ៉ាងសស្រាក់សស្រាំ តែក៏នៅមានកម្មវិធីផ្សេងៗមួយចំនួនទៀតពុំទាន់បានអនុវត្ត ទោះបីការងារកុមារមានការរីកចំរើនជាងមុនក៏ដោយ ផ្អែកតាមស្ថានការណ៍ជាក់ស្តែងរបស់ប្រទេសកម្ពុជា លទ្ធផលទាំងនេះនៅពុំទាន់ឆ្លើយតបបានសមស្របទៅនឹងតំរូវការនៅឡើយទេ អត្រាមរណៈរបស់កុមារនៅមានកំរិតខ្ពស់ គុណភាពនៃការសិក្សារបស់កុមារមានកំរិតទាប អត្រាបោះចោល ការសិក្សាមានកំរិតខ្ពស់ សេវាថែទាំសុខភាពនៅមានការខ្វះខាត ជាពិសេសតាមជនបទ កុមារនៅតាមមូលដ្ឋានពុំទាន់បានទទួលសេវាសង្គមគ្រប់គ្រាន កុមារត្រូវគេលក់ គេរំលោភទាំងលើរាងកាយ និងផ្លូវភេទ ។ល។ និង ។ល។ ដែលទាមទារឱ្យមានការពិនិត្យឡើងវិញ ព្រមទាំងបន្ថែមនូវកម្មវិធី និង វិធានការផ្សេងៗ ដូចបានលើកឡើងក្នុងអនុសាសន៍នៃអង្គការសហប្រជាជាតិ។ សិក្ខាសាលាថ្ងៃនេះសំណូមពរដល់ឯកឧត្តម លោកជំទាវ លោកស្រី លោកទាំងអស់កំណត់បាននូវកម្មវិធី ជាក់ស្តែងដើម្បីកុមារសំរាប់អនុវត្តក្នុងឆ្នាំនេះ និងសំរាប់អនុវត្តក្នុងឆ្នាំខាងមុខ ។

ខ្ញុំសូមថ្លែងអំណរគុណចំពោះវត្តមានរបស់ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី អង្គទូត ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលបានចំណាយពេលវេលាចូលរួមសិក្ខាសាលា និង សូមថ្លែងអំណរគុណចំពោះអង្គការយូនីសេហ្វ និងការិយាល័យឧត្តមស្នងការសិទ្ធិមនុស្សនៅកម្ពុជា ដែលបានឧបត្ថម្ភថវិកា និង គាំទ្រការរៀបចំសិក្ខាសាលានេះឡើង ។

ជាអវសាន្ត ខ្ញុំសូមគោរពជូនពរ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី សូមប្រកបដោយសុខភាពល្អ និងមានជ័យជំនះគ្រប់ភារកិច្ច។

សូមគោរពជូនពរដល់អង្គទូត ឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងអស់ សូមមានសុខភាពល្អ ប្រាជ្ញាឈ្លាសវៃ និងសំរេចបានគ្រប់ភារកិច្ច ។

**សូមអរគុណ !**

*ឧបសម្ព័ន្ធ២*

# សន្ទរកថា

## ថ្លែងដោយឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី និង ជាសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ថ្លែងក្នុងឱកាសបើកសិក្ខាសាលាជាតិ ស្តីពីការអនុវត្តរបស់រាជរដ្ឋាភិបាល ចំពោះសេចក្តីសង្កេតចុងក្រោយរបស់គណៈកម្មាធិការសិទ្ធិកុមារ នៃអង្គការសហប្រជាជាតិ

## ថ្ងៃទី ២២-២៣ ខែ មករា ឆ្នាំ ២០០១

~~~~~~~~~~~~~

- *លោកជំទាវ ឯកឧត្តម លោកស្រី អស់លោកជាភ្ញៀវកិត្តិយសជាតិ និង អន្តរជាតិ ជាទីរាប់អាន !*

- *លោកជំទាវ ឯកឧត្តម លោកស្រី អស់លោកជាសមាជិក សមាជិកា នៃអង្គសិក្ខាសាលាជាទីមេត្រី !*

ថ្ងៃនេះ តាងនាមរាជរដ្ឋាភិបាលកម្ពុជា និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមសំដែងនូវបីតិសោមនស្សរីករាយយ៉ាងក្រៃលែង ដោយបានចូលរួមជាអធិបតីក្នុងពិធីបើកសិក្ខាសាលាជាតិ ស្តីពីការអនុវត្តរបស់រាជរដ្ឋាភិបាល ចំពោះសេចក្តីសង្កេតចុងក្រោយរបស់គណៈកម្មាធិការសិទ្ធិកុមារនៃអង្គការសហប្រជាជាតិ ដែលរៀបចំឡើងដោយ **ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ** សហការជាមួយ **អង្គការយូនីសេហ្វ**(UNICEF ) និង**ការិយាល័យឧត្តមស្នងការសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា** (COHCHR) ។ ជាមួយគ្នានេះដែរ ខ្ញុំសូមសំដែងនូវការស្វាគមន៍យ៉ាងកក់ក្តៅ និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះការអញ្ជើញចូលរួមពីសំណាក់ប្រតិភូនៃបណ្តាក្រសួង ស្ថាប័នពាក់ព័ន្ធ និងអង្គការក្រៅរដ្ឋាភិបាលនានា។ វត្តមានរបស់លោកជំទាវ ឯកឧត្តម លោកស្រី អស់លោកទាំងអស់ក្នុងអង្គសិក្ខាសាលា ព្រមទាំងមតិយោបល់ និងបញ្ញាញាណ ដ៏ឈ្លាសវៃពិតជានឹងធ្វើឱ្យសិក្ខាសាលានេះទទួលបានលទ្ធផលដ៏ប្រសើរ កំណត់បាននូវទិសដៅ និង ផែនការការងាររបស់ខ្លួនយ៉ាងសមស្របសំរាប់យកទៅអនុវត្តឱ្យមានប្រសិទ្ធភាព។ ដូចអង្គសិក្ខាសាលាទាំងមូលបានជ្រាបស្រាប់ហើយថា ប្រធានបទនៃសិក្ខាសាលាជាតិពេលនេះ គឺពាក់ព័ន្ធនឹងការអនុវត្តរបស់រាជរដ្ឋាភិបាល ចំពោះសេចក្តីសង្កេតចុងក្រោយរបស់គណៈកម្មាធិការសិទ្ធិកុមារ នៃអង្គការសហប្រជាជាតិ ខ្ញុំចាត់ទុកថានេះជាប្រធានបទមួយដែលមានសារៈសំខាន់ និងមានអត្ថន័យធំធេង ឆ្លើយតបនឹងបច្ចុប្បន្នភាពដែលរាជរដ្ឋាភិបាលក៏ដូចជាប្រជាជនកម្ពុជាកំពុងផ្តោតការយកចិត្តទុកដាក់នោះ គឺការធានានូវសិទ្ធិរបស់កុមារ រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ត្រង់មាត្រា៤៨ បានចែងថា " **រដ្ឋធានាការពារសិទ្ធិរបស់កុមារ ដែលមានចែងក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារ ជាពិសេសសិទ្ធិមានជីវិតរស់នៅ សិទ្ធិទទួលការអប់រំរៀនសូត្រ សិទ្ធិបានទទួលការគាំពារក្នុងស្ថានភាព មានសង្គ្រាម និងការការពារប្រឆាំងនឹងអាជីវកម្ម សេដ្ឋកិច្ច ឬ កាមគុណលើកុមារ** " ។ ម្យ៉ាងវិញទៀត អនុសញ្ញាស្តីពីសិទ្ធិកុមារ ត្រូវបានរាជរដ្ឋាភិបាលកម្ពុជាផ្តល់សច្ចាប័នរួចហើយ ដូច្នេះដើម្បីធានានូវសិទ្ធិកុមារដូចខាងលើនេះ រាជរដ្ឋាភិបាលបានចាត់វិធានការជាច្រើន និង យ៉ាងម៉ឹងម៉ាត់បំផុត សំដៅរាំងស្កាត់គ្រប់អំពើល្មើសទាំងឡាយដែលប្រព្រឹត្តិមកលើកុមារ ព្រមទាំងជួយបង្កលក្ខណៈឱ្យកុមារកម្ពុជាគ្រប់រូបមានការរីកចំរើន ទាំងខាងរាងកាយ និង បញ្ញាស្មារតី ។

រាជរដ្ឋាភិបាលបានបង្កើតក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ហើយក្រុមប្រឹក្សាបានធ្វើសកម្មភាពការងារជាច្រើន ដូចជាការចងក្រងឯកសារពាក់ព័ន្ធនឹងសិទ្ធិកុមារ ការផ្សព្វផ្សាយអំពីសិទ្ធិកុមារ បើកសិក្ខាសាលា ដើម្បីរកវិធានការធានាសិទ្ធិរបស់កុមារ
~~~~~~~~~~~~~

ប្រឆាំងការជួញដូរផ្លូវភេទ ព្រមទាំងប្រឆាំងបទល្មើសផ្សេងៗទៀតចំពោះកុមារ ។ បើពិនិត្យលើការជាក់ស្តែងវិញ ករណីបទល្មើសនានាចំពោះកុមារ ក៏ត្រូវបានទប់ស្កាត់ទាន់ពេលវេលា ហើយជនប្រព្រឹត្តិល្មើសក៏ត្រូវបានស្រាវជ្រាវ និង ចាប់បញ្ជូនទៅតុលាការជាបន្តបន្ទាប់។

ឆ្លៀតក្នុងឱកាសនេះ តាងនាមរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំសូមសំដែងនូវការកោតសរសើរ និងថ្លែងអំណរគុណចំពោះក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ក្រសួងមហាផ្ទៃ ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ក្រសួងកិច្ចការនារី និង អតីតយុទ្ធជន និង ក្រសួងពាក់ព័ន្ធដ៏ទៃទៀត ព្រមទាំងអង្គការក្រៅរដ្ឋាភិបាល ជាតិ និងអន្តរជាតិ ដែលបានយកចិត្តទុកដាក់អនុវត្តទទួលបានលទ្ធផលល្អប្រសើរ ក្នុងភារកិច្ចរួមសហការការពារសិទ្ធិកុមារកន្លងមក ។

*លោកជំទាវ ឯកឧត្តម លោកស្រី អស់លោក !*

*អង្គសិក្ខាសាលាទាំងមូលជាទីមេត្រី !*

កន្លងមក ទោះបីរាជរដ្ឋាភិបាលកម្ពុជា បានចាត់វិធានការម៉ឺងម៉ាត់យ៉ាងណាក្តី ក៏អំពើល្មើសនានា និង ចំណុចខ្វះខាតនានាចំពោះកុមារ ដូចជាការយកកុមារទៅធ្វើពេស្យាចារ ការលក់កុមារយកប្រាក់ ការមិនបានចិញ្ចឹមបីបាច់កុមារឱ្យបានល្អ ការមិនបានផ្តល់ការព្យាបាលជំងឺដល់កុមារទាន់ពេលវេលា ការមិនបានឱ្យកុមារបានចូលរៀន ។ល។ និង ។ល។ នៅតែកើតមានជាបន្តបន្ទាប់ ។ ទាំងនេះគឺជាអំពើរំលោភសិទ្ធិរបស់កុមារ ហើយក៏ជាអំពើផ្ទុយនឹងចលនាពិភពលោក ដែលរាជរដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ ទប់ស្កាត់ និងបំបាត់ឱ្យបាន។ គេតែងនិយាយថា ដើម្បីកសាងប្រទេសជាតិឱ្យបានរឹងមាំ និងមានការអភិវឌ្ឍ គឺត្រូវកសាងឱ្យបានល្អនូវធនធានមនុស្ស។ ប្រទេសកម្ពុជាយើងមានកុមារប្រមាណ៥២.៤% នៃចំនួនប្រជាជនទូទាំងប្រទេស នេះគឺជាមុខសញ្ញាដ៏ធំធេងនៃកំលាំងចលនាកសាងជាតិ ដែលយើងមិនត្រូវធ្វេសប្រហែសឡើយ។ ដូច្នេះ ជាបឋមយើងត្រូវធ្វើឱ្យកុមារទទួលបាននូវសិទ្ធិពេញលេញ ដូចដែលចែងនូវក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារ ។

ខ្ញុំមានយោបល់ថា ការអនុវត្តអនុសញ្ញាមិនទាមទារតែការយល់ដឹង និងបច្ចេកទេសប៉ុណ្ណោះទេ គឺត្រូវមានសុឆន្ទៈមុះមុត និង ស្មារតីទទួលខុសត្រូវខ្ពស់ពីស្ថាប័នដែលពាក់ព័ន្ធក៏ដូចជាបុគ្គលទទួលខុសត្រូវ។ រួមចំណែកជាមួយអង្គសិក្ខាសាលា ខ្ញុំសូមឱ្យឯកឧត្តម លោកជំទាវ លោក លោកស្រី ពិនិត្យទៅលើអ្វីដែលជាផលប្រយោជន៍ល្អបំផុតសំរាប់កុមារនៅក្នុងកម្មវិធីរបស់ខ្លួន ហើយធ្វើការបែងចែកការងារជាអាទិភាព និងការងារបន្ទាប់បន្សំឱ្យបានច្បាស់លាស់ រួមទាំងការកំណត់បាននូវរយៈពេលនៃការអនុវត្ត។ ចលនាចូលរួម និង ការគាំទ្រពីសហគមន៍ ការចូលរួមចំណែកពីមាតាបិតា ក៏ដូចជាកុមារខ្លួនឯង គឺជាកត្តាដែលមិនត្រូវបំភ្លេចឡើយ ហើយកិច្ចសហការ និងកិច្ចសហប្រតិបត្តិការល្អ ក៏ជាកត្តានៃជ័យជំនះដែលយើងត្រូវប្រកាន់ខ្ជាប់។ ខ្ញុំមានជំនឿយ៉ាងមុតមាំថា សិក្ខាសាលាជាតិរយៈពេល២ថ្ងៃនេះ លោកជំទាវ ឯកឧត្តម លោកស្រី អស់លោក នឹងក្តាប់បាននូវបទឧទ្ទេសនាមល្អៗ បទពិសោធន៍ថ្មីៗដែលពាក់ព័ន្ធនឹងប្រធានបទអនុសាសន៍របស់អង្គការសហប្រជាជាតិ ព្រមទាំងប្រឹងប្រែងយកចិត្តទុកដាក់ចូលរួមផ្តល់មតិយោបល់យ៉ាងល្អិតល្អន់លើចំណុចទាំងឡាយ ដើម្បីរកឱ្យឃើញនូវចំណុចខ្សោយ ចំណុចខ្លាំង លើការអនុវត្តការងាររបស់យើងកន្លងមក ហើយដាក់ចេញនូវកម្មវិធី និងវិធានការផ្សេងៗ ឬអនុសាសន៍ថ្មីៗដើម្បីអនុវត្តសេចក្តីសង្កេតចុងក្រោយរបស់គណៈកម្មាធិការសិទ្ធិមនុស្ស នៃអង្គការសហប្រជាជាតិនេះ ឱ្យមានប្រសិទ្ធភាព ។

ឆ្លៀតឱកាសនេះដែរ ជាថ្មីម្តងទៀត ខ្ញុំសូមកោតសសើរ និងថ្លែងអំណរគុណដល់អង្គការយូនីសេហ្វ និងការិយាល័យឧត្តមស្នងការសិទ្ធិមនុស្ស របស់អង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា (COHCHR) ដែលបានឧបត្ថម្ភថវិកា និងរួមសហការជាមួយក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ (ក.ជ.ក.ក) រៀបចំសិក្ខាសាលានេះឡើង និងសូមថ្លែងអំណរគុណចំពោះស្ថាប័នពាក់ព័ន្ធ

ផ្សេងៗទៀត ព្រមទាំងអង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិនានា ដែលបានយកចិត្តទុកដាក់ធ្វើការងារកុមារឱ្យមានស្ថានភាពល្អប្រសើរជារៀងរាល់ថ្ងៃ ហើយសង្ឃឹមថា នឹងជួយបន្តទៀតដល់កុមារ ។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរដល់គណៈអធិបតី ភ្ញៀវកិត្តិយសជាតិ និងអន្តរជាតិ និងអង្គសិក្ខាសាលាទាំងមូល សូមមានប្រាជ្ញាឈ្លាសវៃ ស្មារតីមុតមាំ និង សុខភាពល្អ និង សូមប្រសិទ្ធិពរឱ្យអង្គសិក្ខាសាលាទទួលបានជោគជ័យ ។

ខ្ញុំសូមប្រកាសបើកសិក្ខាសាលាជាតិ **ស្តីពីការអនុវត្តរបស់រាជរដ្ឋាភិបាល ចំពោះសេចក្តីសង្កេតចុងក្រោយរបស់គណៈកម្មាធិការសិទ្ធិកុមារនៃអង្គការសហប្រជាជាតិ** ចាប់ពីពេលនេះតទៅ ។

**សូមអរព្រះគុណ ! សូមអរគុណ !**

**ព្រះរាជាណាចក្រកម្ពុជា**
**KINGDOM OF CAMBODIA**
**ជាតិ សាសនា ព្រះមហាក្សត្រ**
**NATION RELIGION KING**

**ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ**
**CAMBODIAN NATIONAL COUNCIL FOR CHILDREN**

# លទ្ធផលនៃការអនុវត្តកម្មវិធីសកម្មភាពជាតិដើម្បីកុមារនៅកម្ពុជា ឆ្នាំ ១៩៩៨-២០០០

~~~~~~~~~

នៅឆ្នាំ១៩៩៨ រាជរដ្ឋាភិបាលបានអនុម័តលើ កម្មវិធីសកម្មភាពជាតិដើម្បីកុមារនៅកម្ពុជាឆ្នាំ១៩៩៨-២០០០។ កម្មវិធីសកម្មភាពជាតិនេះគឺជាការចងក្រងនូវគោលដៅជាតិ ដែលលើកឡើងក្នុងផែនការ៥ឆ្នាំ ឬ ៣ឆ្នាំរបស់ក្រសួងជំនាញដែលពាក់ព័ន្ធនឹងគោលដៅអន្តរជាតិ ដែលមានចែងនៅក្នុងសេចក្តីថ្លែងការពីសន្និសីទកំពូលពិភពលោកដើម្បីកុមារនៅឆ្នាំ១៩៩០។ ការបូកសរុបលើរបាយការណ៍របស់ក្រសួង និងស្ថាប័នពាក់ព័ន្ធ អង្គការនានា បានបង្ហាញឱ្យឃើញនូវការអនុវត្តគោលដៅជាតិដែលទទួលបានលទ្ធផលដូចខាងក្រោម :

## I- ការអភិវឌ្ឍកុមារភាពដំណាក់កាលដំបូង និង ការអប់រំជាមូលដ្ឋាន

### ១-មត្តេយ្យសិក្សា

- ក្រសួងអប់រំ យុវជន និង កីឡា នៅឆ្នាំសិក្សា១៩៩៨-៩៩ ផ្នែកមត្តេយ្យសិក្សាមានការរីកចំរើនជាងឆ្នាំមុន អត្រាចូលរៀនរបស់កុមារបានកើនឡើង៦.៣២% ។ ការកើនឡើងនេះ ពុំទាន់បានឆ្លើយតបតាមទិសដៅរបស់ក្រសួងទេ ព្រោះថាកុមារនៅតាមជនបទ កុមារក្រីក្រ កុមារជនជាតិភាគតិច និងកុមារពិការ ពិសេសកុមារីមិនទាន់បានចូលរៀនមានច្រើននៅឡើយ។ មកដល់ឆ្នាំសិក្សា១៩៩៩-២០០០ ក្រសួងអប់រំ បានពង្រីកបរិមាណសាលា សិស្ស គ្រូ ដោយសហការជាមួយគ្រប់អាជ្ញាធរមូលដ្ឋាន សហគមន៍ សប្បុរសជន ឯកជន អង្គការក្រៅរដ្ឋាភិបាល និងអង្គការអន្តរជាតិ ដើម្បីអនុវត្តសិទ្ធិចូលរៀនរបស់កុមារប្រកបដោយសមធម៌។ អត្រាចូលរៀនរបស់កុមារបានកើនឡើង៧.០៣% ចំនួនសាលាមត្តេយ្យទូទាំងប្រទេសមាន៩៥៤កន្លែង (សាលារដ្ឋ៩២៣) កើនឡើងជាងឆ្នាំមុន១៧៧សាលា។ ចំនួនសិស្សចំនួន៥៧.០៧២នាក់ (កុមារី២៨.៧២៤នាក់ ) កើនជាងឆ្នាំមុន ៤.២៦៥ នាក់ ។

- នៅក្នុងឆ្នាំ២០០០ ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន និងកម្មវិធីសកម្មភាពសហគមន៍ដើម្បីអភិវឌ្ឍសង្គម (ស.ស.អ.ស) បានធ្វើការងារក្នុងការថែទាំ និងអភិវឌ្ឍន៍កុមារតូចៗ(០-៥ឆ្នាំ) នៅតាមសហគមន៍ក្នុងខេត្ត-ក្រុងចំនួន១៨ គ្រូដែលថែទាំកុមារមាន១.០០៧នាក់ កុមារមាន ១៥.៧២៩នាក់ (កុមារី៨.៩៥៨នាក់) ។

### ២-បឋមសិក្សា

ក្នុងឆ្នាំសិក្សា១៩៩៨ ក្រសួងអប់រំ យុវជន និង កីឡា បានកំណត់គោលនយោបាយសំខាន់ៗមាន :

- សកលកម្មអប់រំចំណេះទូទៅមូលដ្ឋាន៩ឆ្នាំ និង អភិវឌ្ឍន៍អក្ខរកម្មវិជ្ជាជីវៈ
- ទំនើបកម្ម និង កំណែលំអរគុណភាពអប់រំ តាមរយៈការកែទំរង់ប្រកបដោយប្រសិទ្ធភាព
~~~~~~~~~

- ផ្សារភ្ជាប់ការអប់រំ បណ្តុះបណ្តាលទៅនឹងតំរូវការទីផ្សារពលកម្ម និង សង្គម

- ស្តារ និង អភិវឌ្ឍន៍ផ្នែកយុវជន និង កីឡា នៅក្នុងប្រព័ន្ធ និង ក្រៅប្រព័ន្ធអប់រំ

ក្នុងឆ្នាំ១៩៩៨-៩៩ សាលារៀនមាន៥.១៨៧សាលា កើនលើសជាងឆ្នាំមុន១៦១សាលា សិស្សសរុបមាន ២.០៩៦.៩៣០នាក់ ( ស្រី៩៤៦.១៩២នាក់ ) កើនលើសជាងឆ្នាំមុន៨៤.៧៥៨នាក់ ។ អនុវត្តតាមគោលដៅជាតិសំរាប់ការអប់រំនៅបឋមសិក្សា គឺពង្រីកលទ្ធភាពស្មើភាព ដើម្បីឱ្យកុមារបានទទួលនូវការអប់រំជាមូលដ្ឋានតាមការចុះឈ្មោះចូលរៀន និងការចូលរួមរបស់កុមារ ក្នុងការសិក្សារយៈពេល៩ឆ្នាំ ។ ហើយនៅក្នុងឆ្នាំសិក្សា ១៩៩៩-២០០០ អត្រានៃការចូលរៀនបឋមសិក្សាមាន ៨១,៣៣% កើនលើសឆ្នាំមុន ១៩% ។ សាលាបឋមសិក្សាមាន៥.៣៦០សាលា កើនលើសជាងឆ្នាំមុន១៧៣សាលា សិស្សសរុបមានចំនួន ២.១៩៦.៨៨៥នាក់ ( ស្រី ៩៧២.៦១២នាក់ ) កើនលើសជាងឆ្នាំមុន ៩០.៣៩៥នាក់ ។

លទ្ធផលនៃការបញ្ចប់បឋមសិក្សា អនុវត្តបានតែ៨៣,៦២% គឺតិចជាងឆ្នាំមុន ដូចនេះការបញ្ចប់បឋមសិក្សាតាមគោលដៅជាតិ៩៥% នឹងបន្តទៅអនុវិទ្យាល័យមិនបានជោគជ័យទេ។ មូលហេតុដោយសិស្សមួយចំនួនបានបោះបង់ចោលការសិក្សាមាន៦,៦% សិស្សរៀនត្រួតថ្នាក់មាន១០,៣២% ។

៣- <u>ថវិកាជាតិ</u>

ថវិកាជាតិសំរាប់ផ្នែកអប់រំគឺ បានធានាផ្គត់ផ្គង់នូវប្រាក់បៀវត្សរ៍មន្ត្រីអប់រំ ( គ្រូបង្រៀន និង មន្ត្រីគ្រប់គ្រងអប់រំ) ហើយនិងមានថវិកាបន្តិចបន្តួចទៀត សំរាប់ចំណាយបុព្វហេតុថ្នាក់កណ្តាល និងថ្នាក់ខេត្តតែប៉ុណ្ណោះ។ នៅក្នុងឆ្នាំ១៩៩៨ ចំណាយសរុបនូវថវិកាជាតិសំរាប់អប់រំមានចំនួន១៤៧ពាន់លានរៀល ស្មើនឹង១០.៣% នៃថវិកាជាតិទាំងមូល ឬប្រហាក់ប្រហែលនឹង ១.៥% នៃផលទុនក្នុងស្រុកសរុប (GDP)។ ធ្លយទៅវិញថវិកាឆ្នាំ១៩៩៧ មាន៨.១% នៃថវិការដ្ឋ ប៉ុន្តែនៅក្នុងឆ្នាំ១៩៩៩ គំរោងចំណាយថវិការបស់ជាតិមកលើវិស័យអប់រំ យុវជន និងកីឡា មាន៨.៣% បើគិតជាសាច់ប្រាក់ មានការកើនឡើងបន្តិច១៤៩.៥ពាន់លានរៀល។ នៅក្នុងឆ្នាំ២០០០នេះ គំរោងចំណាយថវិកាជាតិមកលើវិស័យអប់រំមានការកើនឡើង១៨៣.១៧០ពាន់លានរៀល ស្មើនឹង១៣.៩២%នៃថវិការដ្ឋ។ ជាការពិតថវិកាជាតិដែលផ្តល់នេះ នៅតែទាបជាងតំរូវការជាក់ស្តែងរបស់ក្រសួងឆ្ងាយណាស់ ។

ដោយសារសេវាអប់រំ និងភាពឃ្លាតឆ្ងាយរវាងសាលារៀនទីក្រុង និងសាលារៀនជនបទដាច់ស្រយាលនេះ រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់ដល់គ្រូបង្រៀន ដែលរហូតដល់ឆ្នាំ២០០០នេះ បានតំឡើងប្រាក់បៀវត្សរ៍៦០% បានបន្ថែមប្រាក់គរុកោសល្យបាន៦លើក ស្មើនឹងទឹកប្រាក់៩៣ពាន់ ទៅ៥៥ពាន់រៀន ទៅតាមប្រភេទកាំប្រាក់។ ចំពោះមន្ត្រីអប់រំដែលទើបចេញថ្មី ហើយស្ម័គ្រចិត្តទៅបំរើការងារនៅតំបន់ដាច់ស្រយាល បានទទួលប្រាក់ឧបត្ថម្ភពេលចេញដំណើរសំរាប់សំភារះប្រើប្រាស់ ស្មើនឹងទឹកប្រាក់ ៦០ដុល្លាអាមេរិក ។ ចំពោះគ្រូបង្រៀនដែលកំពុងបង្រៀននៅតំបន់វាលរាប ហើយស្ម័គ្រចិត្តទៅបង្រៀន ឬ បំរើការងារនៅតំបន់ដាច់ស្រយាល ក៏បានផ្តល់សោហ៊ុយធ្វើដំណើរ២ដង ( ទៅ-មក) ក្នុង១ឆ្នាំ សារពើពន្ធសំរាប់ទៅលេងស្រុកកំណើត។

៤- <u>អប់រំក្រៅប្រព័ន្ធធម្មតា</u>

ទន្ទឹមគ្នាជាមួយនឹងការអភិវឌ្ឍ ការអប់រំក្នុងប្រព័ន្ធធម្មតានេះ ក្រសួងអប់រំ យុវជន និងកីឡា ក៏បានយកចិត្តទុកដាក់ចំពោះការអប់រំក្រៅប្រព័ន្ធធម្មតា ដែលជាសមាសភាគសំខាន់មួយដែលមិនអាចអត់បាន នៅក្នុងប្រព័ន្ធអប់រំរបស់យើង ជាពិសេសក្នុងការបង្កើនអត្រាអក្ខរកម្ម។ អត្រាអក្ខរកម្មរបស់ជនដែលមានអាយុពី១៥ឆ្នាំឡើងទៅមាន៦៧% ។ ធៀបទៅជាមួយនឹងប្រទេសកំពុងអភិវឌ្ឍន៍ដ៏ទៃទៀតនៅក្នុងតំបន់នេះ អត្រាអក្ខរកម្មនៅក្នុងប្រទេសកម្ពុជាហាក់ដូចជាខ្ពស់បន្តិច។ ដោយសារយុទ្ធនាការ

អក្ខរកម្មនាពេលកន្លងមក អត្រាអក្ខរកម្មបានកើនឡើងដល់៦៨,៧%។ ក៏ប៉ុន្តែអត្រាអក្ខរកម្មនៅតំបន់ជនបទ និងតំបន់ដាច់ស្រយាលមានកំរិតទាបខ្លាំងជាងអត្រាអក្ខរកម្មនៅទីក្រុង និងទីប្រជុំជន។ ដើម្បីកែលំអរនូវស្ថានការណ៍នេះ ក្រសួងបានពង្រីកអក្ខរកម្មមនុស្សចាស់ និងបន្តបើកថ្នាក់បំពេញវិជ្ជា ជាពិសេសសំរាប់ក្រុមជនទន់ខ្សោយ រួមមាន កុមារ ស្ត្រីវ័យក្មេង និងជនជាតិភាគតិច ដែលមិនបានទទួលការអប់រំពីប្រព័ន្ធធម្មតា។ ទន្ទឹមនឹងនេះ ក្រសួងកិច្ចការនារី និង អតីតយុទ្ធជន សកម្មភាព ស.ស.អ.ស អង្គការអន្តរជាតិ អង្គការរដ្ឋាភិបាល និងខេត្ត-ក្រុង មួយចំនួន និងដោយមានការឧបត្ថម្ភពីអង្គការនានា បានធ្វើការបណ្តុះបណ្តាលគ្រូអក្ខរកម្ម និងអ្នកត្រួតពិនិត្យបានទាន់ពេលវេលា។ រហូតមកដល់ឆ្នាំ២០០០នេះ ថ្នាក់អក្ខរកម្មមាន២.៩១៦ថ្នាក់ សិស្សចំនួន ៥០.៤១៦នាក់ (ស្ត្រី៣៧.៧៩១នាក់) សិស្សទទួលបានប័ណ្ណអក្ខរកម្ម ២៥.៧២៥នាក់ (ស្ត្រី១៨.០៨៧នាក់) កើនលើសជាងឆ្នាំមុន៦.០០០នាក់។ គ្រូអក្ខរកម្មទាំងអស់មាន ២.៣៣៨នាក់ (ស្រី ៨២៩នាក់) កើនលើសឆ្នាំមុន៧៩០នាក់។ អ្នកត្រួតពិនិត្យ ២៧១នាក់ (ស្រី៥៩នាក់) កើនលើសឆ្នាំមុន១១២នាក់ ។

៥- កិច្ចសហការ

ក្រសួងអប់រំ យុវជន និងកីឡា បានសហការជាមួយក្រសួងវប្បធម៌រៀបចំបញ្ចូលក្នុងកម្មវិធីសិក្សា នៅភ្លេងចំរៀង ប្រពៃណី និង គំនូរ ។ល។ សំរាប់បណ្តុះបណ្តាលឡើងនូវគ្រឹះវប្បធម៌ជាតិដល់សិស្សានុសិស្សទូទាំងប្រទេស ។

## II- សុខភាពមាតា និង ទារក

១-កម្មវិធីលុបបំបាត់ជំងឺស្វិតដៃជើង

កម្មវិធីនេះ បានរៀបចំឡើងនាខែឧសភា ឆ្នាំ១៩៩៤ ក្រោយពីបានប្រារព្ធទិវាជាតិផ្តល់បន្ថែមថ្នាំបង្ការគ្រុនស្វិតដៃជើងដល់កុមារអាយុក្រោម៥ឆ្នាំ នៅទីក្រុងភ្នំពេញ និង ខេត្តកណ្តាល ។ កម្មវិធីនេះបានយកចិត្តទុកដាក់ ជាពិសេសលើការប្រារព្ធទិវាជាតិផ្តល់បន្ថែមថ្នាំបង្ការដល់កុមារអាយុក្រោម៥ឆ្នាំ។ ការពង្រឹង និងការពង្រីកសកម្មភាពស្រាវជ្រាវរកករណីខ្វិនទន់អវៈយវៈដល់កុមារក្រោម១៥ឆ្នាំ នៅគ្រប់ខេត្ត-ក្រុងទូទាំងប្រទេស ព្រមទាំងជួយពង្រឹងអត្រាគ្របដណ្តប់ដល់កម្មវិធីចាក់ថ្នាំបង្ការជាប្រចាំ។ តាមសកម្មភាពពិសេសនេះ ការចំលងវីរុសប៉ូលីយ៉ូត្រូវបានផ្តាច់ នៅគ្រប់តំបន់ក្នុងប្រទេសចាប់ពីខែមេសា ឆ្នាំ១៩៩៧។ ក្នុងឆ្នាំ ១៩៩៨-២០០០ ជំងឺស្វិតដៃជើង ត្រូវបានបំបាត់ទាំងស្រុងទូទាំងប្រទេសកម្ពុជា ដោយមានការអះអាងពីគណៈកម្មាធិការតំបន់ប៉ាស៊ីហ្វិចខាងលិច របស់អង្គការសុខភាពពិភពលោក។ នាថ្ងៃទី២៩ ខែតុលា ឆ្នាំ២០០០ ប្រទេសទាំងអស់ក្នុងតំបន់រួមទាំងកម្ពុជាផងត្រូវប្រកាសទទួលនូវវិញ្ញាបនប័ត្របញ្ជាក់ថាគ្មានជំងឺគ្រុនស្វិតដៃជើងទៀតទេ ដែលប្រារព្ធធ្វើនៅទីក្រុងតូក្យូ ប្រទេសជប៉ុន ។

២-ការចាក់ថ្នាំបង្ការ

- ការចាក់ថ្នាំបង្ការកញ្ជ្រិលលើកុមារអាយុក្រោម៥ឆ្នាំបានទទួល១៨៦.៨២២នាក់ ស្មើនឹង៨២% នៅក្នុងឆ្នាំ២០០០នេះ។ ជាមួយគ្នានេះ ការចាក់ថ្នាំបង្ការជំងឺដល់កុមារដែលមានអាយុតិចជាង១ឆ្នាំ មានអត្រាគ្របដណ្តប់ដូចតទៅ ការពារជំងឺរបេង៩៧% គ្រុនស្វិតដៃជើង៣លើក៤៦% ក្អកមាន់ ខាន់ស្លាក់ តេតាណូស៣លើក៤៦% កញ្ជ្រិល៤៣%។ បើប្រៀបធៀបទៅនឹងរយៈពេលដូចគ្នាអត្រាទាំងនេះមានកំរិតខ្ពស់ជាងប្រមាណ១១%លើសកម្មភាពឆ្នាំ១៩៩៩ ។ ដោយឡែកការចាក់ថ្នាំបង្ការជំងឺតេតាណូស ២លើក ដល់ស្ត្រីមានផ្ទៃពោះបាន២៧% នៃស្ត្រីមានផ្ទៃពោះទាំងអស់បើប្រៀបធៀបទៅនឹងឆ្នាំមុនអត្រានេះខ្ពស់ ជាង៥% ។

៣-ជំងឺរាគ និង ជំងឺរលាកផ្លូវដង្ហើម

- ជំងឺរាគ គឺជាបញ្ហាធ្ងន់ធ្ងរមួយចំពោះកុមារកម្ពុជា ដែលជាទូទៅច្រើនកើតមានចំពោះទារកអាយុពី៦ ដល់១១ខែ រហូត

ដល់ទៅ៤០% ក្នុងរយៈពេល២សប្តាហ៍ប៉ុណ្ណោះ ផ្អែកទៅតាមការធ្វើអង្កេតផ្នែកសុខភាពថ្មីមួយ និងករណីរាគរូសនេះចំនួន៤០% ជាប្រភេទរាគមួល។ ក្នុងចំណោមស្ត្រីទាំងអស់ដែលមានអាយុពី១៥ ទៅ៤៩ឆ្នាំ មានស្ត្រីជិតពាក់កណ្តាលហើយដែលយល់ដឹងអំពីសារៈសំខាន់នៃទឹកអូរ៉ាលីត្រ និង កុមារ៤នាក់ ក្នុងចំណោមកុមារ៥នាក់បានទទួលជាតិទឹកច្រើនជាងមុន នៅពេលកើតជំងឺរាគរូស។ ចំណែកឯជំងឺរលាកផ្លូវដង្ហើមយ៉ាងស្រួចស្រាវវិញ ក៏ដូចជាជំងឺរាគរូសដែរ គឺជាបញ្ហាមួយធ្ងន់ធ្ងរណាស់ចំពោះកុមារវ័យក្មេងៗ ព្រោះថា កុមារអាយុចាប់ពី៦ ដល់១១ខែ មាន២៦% មានកើតរោគក្អក និងដង្ហើមញាប់ ។ ចំពោះកុមារនៃគ្រួសារក្រីក្រ អ្នកមិនចេះអក្សរ និង រស់នៅតាមជនបទ ឬ តំបន់ដាច់ស្រយាល គឺកុមារទាំងនេះភាគច្រើនណាស់ ដែលកើតមានជំងឺរាគ ឬរលាកផ្លូវដង្ហើមស្រួចស្រាវ ។

៤-ជំងឺស្លេកស្លាំង

ជំងឺស្លេកសាំងបណ្តាលមកពីកង្វះជាតិដែក។ បញ្ហាកង្វះជាតិដែកមានអត្រាខ្ពស់ជាងគេបង្អស់ បើធៀបទៅនិងអត្រាកង្វះមីក្រូសារជាតិដ៏ទៃទៀត។ នៅក្នុងឆ្នាំ១៩៩៩ មានអត្រាខ្ពស់លើសពី៦០% ចំពោះកុមារ និងនារីក្នុងវ័យបន្តពូជ ក៏ដូចជាស្ត្រីមាន ផ្ទៃពោះ និង ស្ត្រីបំបៅកូន ។ ថ្វីបើយើងពុំទាន់មានកម្មវិធីជាតិប្រយុទ្ធ និង បញ្ហាស្លេកស្លាំងដោយកង្វះជាតិដែក កន្លងមកយើងបានធ្វើការទប់ស្កាត់តាមរយៈបណ្តាញសុខាភិបាល ដោយធ្វើការផ្តល់ថ្នាំគ្រាប់ជាតិដែកដល់ម្តាយមុន និងក្រោយពេលសំរាលកូន ក្រៅពីនេះការចែកចាយគ្រាប់ថ្នាំជាតិដែក ក៏បានធ្វើរួមជាមួយថ្នាំកំចាត់ព្រូន គ្រាប់វីតាមីនអាដល់ស្ត្រី និងកុមារជាសិស្សសាលាទៀតផង។ ក្នុងឆ្នាំ២០០០នេះ តាមលទ្ធផលអង្កេតរបស់កម្មវិធីសកម្មភាពសហគមន៍ដើម្បីអភិវឌ្ឍន៍សង្គម(ស.ស.អ.ស) គឺធ្វើក្នុងខេត្តចំនួន៨ បានបង្ហាញឱ្យឃើញថា ភាពស្លេកស្លាំងរបស់ស្ត្រីមានផ្ទៃពោះមានអត្រា៦៩% អត្រានេះមានការកើនឡើងបើប្រៀបធៀបទៅ នឹងឆ្នាំ១៩៩៨ មាន៦២% ។

៥-ការបំបៅកូនដោយទឹកដោះម្តាយ

ការបំបៅកូនដោយទឹកដោះម្តាយជាង៥០% នៃក្មេងនៅតាមជនបទ នៅតែបៅដោះក្នុងអាយុ២ឆ្នាំ ការផ្តាច់ដោះដោយមូលហេតុគ្មានទឹកដោះ៧៩.៤% ឯការបំបៅដោះនៅក្រោមអាយុ២ថ្ងៃ៥៦.៧% (ក្នុងឆ្នាំ១៩៩៤) ។ ដោយកម្មវិធីពង្រឹងការបំបៅកូនដោយទឹកដោះម្តាយ ជាលទ្ធផលមាន៩៥% ក្នុងឆ្នាំ១៩៩៩។ ក្នុងឆ្នាំ២០០០នេះមានមាតាដែលបានបំបៅកូនរហូតដល់អាយុ២ឆ្នាំ មាន៦៨% (លទ្ធផលអង្កេតកម្មវិធី ស.ស.អ.ស) ។

៦-កង្វះវិតាមីនអា

ការកង្វះវិតាមីនអា បានបង្ហាញឱ្យឃើញថាប្រេវ៉ាឡង់នៃករណីជំងឺខ្វាក់មាន់ ក្រោមអាយុ៦ឆ្នាំមានកំរិតខ្ពស់ ដូចជានៅខេត្តតាកែវ១១% ខេត្តរតនគីរី២១% ខេត្តកោះកុង៥.២% និងខេត្តពោធិសាត់១៥%។ ជំងឺពកកបណ្តាលកង្វះជាតិ អ៊ីយ៉ូដបានបង្ហាញពីប្រេវ៉ាឡង់នៃចំនួនប្រជាជនទូទៅ១១% ដែលក្នុងនោះ៨៨%ជាស្ត្រី។ បញ្ចូលជាតិអ៊ីយ៉ូតទៅក្នុងអំបិលសំរាប់ប្រើប្រាស់នៅតាមទីក្រុង និងតាមខេត្តនានា។ បើកវគ្គបណ្តុះបណ្តាលស្តីពីអាហារូបត្ថម្ភកង្វះជីវជាតិអា កង្វះជាតិដែក កង្វះជាតិអ៊ីយ៉ូតលើកុមារអាយុក្រោម៥ឆ្នាំ ដល់៤ស្រុក ក្នុងខេត្តតាកែវ និង មួយស្រុកក្នុងខេត្តកំពង់ ។

៧- ការពន្យារកំណើត

អត្រាប្រេវ៉ាឡង់ នៃការប្រើវិធីពន្យារកំណើតបានកើនឡើងពី៧% ក្នុងឆ្នាំ១៩៩៥ ទៅ១៦% ក្នុងឆ្នាំ១៩៩៨។ ក្នុងឆ្នាំ១៩៩៩ ការប្រើពន្យារកំណើតមាន១៦%។ ក្នុងឆ្នាំ២០០០ ការអនុវត្តផែនការគ្រួសារតាមបែបទំនើបក្នុងកម្មវិធីពន្យារកំណើតមាន២៩% ដោយប្រើវិធីពីរយ៉ាងគឺ ការចាក់ថ្នាំការពារមាន៦៥% និង ការលេបថ្នាំគ្រាប់មាន៣៦%។ ដូចនេះ ក្នុងឆ្នាំ២០០០

អត្រានៃការពន្យាកំណើតបានទទួលជោគជ័យតាមគោលដៅជាតិ។ ទន្ទឹមនឹងនេះ ក្រសួងកិច្ចការនារី និង អតីតយុទ្ធជនបានបង្កើតកម្មវិធីសាកល្បងនៃការពន្យាកំណើតនៅសហគមន៍ ហើយលទ្ធផលទទួលបានពីកម្មវិធីនេះមានអតិថិជនដែលទទួលការផ្សព្វផ្សាយមានចំនួន១១.៤៨៥ នៅក្នុងខេត្តចំនួន៨ ( កំ.ចាម. ព្រៃវែង. ស្វាយរៀង. បាត់ដំបង. សៀមរាប. កំពត. កំពង់ធំ. កំ.ឆ្នាំង) ចំនួនអតិថិជនដែលចាប់ផ្តើមប្រើស្រោមអនាម័យ១៧៧នាក់ អតិថិជនបានប្រើថ្នាំគ្រាប់១.៤៦៦នាក់ ចំនួនថ្នាំគ្រាប់ដែលបានចែកចាយមាន៤.០៣៤បន្ទះ ។

៨-ការសំរាលកូន

តាមរបាយការណ៍ក្រសួងសុខាភិបាលបានបង្ហាញថាមានស្ត្រីតែ៣៤%ប៉ុណ្ណោះ ដែលបានសំរាលកូនដោយបុគ្គលិកសុខាភិបាលដែលមានការបណ្តុះបណ្តាល។ រីឯការសំរាលកូនដោយឆ្មបបុរាណមានអត្រា៦៦%។ ក្នុងឆ្នាំ១៩៩៨ការសំរាលកូនដោយបុគ្គលិកសុខាភិបាល ឬ ឆ្មបបុរាណមានការបណ្តុះបណ្តាល៥០% ។

៩-មេរោគហ៊ីវ និង ជំងឺអេដស៍

មេរោគហ៊ីវ និងជំងឺអេដស៍ នៅតំបន់អាស៊ីអាគ្នេយ៍ប្រទេសកម្ពុជា កំពុងប្រឈមមុខនឹងការរីករាលដាលយ៉ាងឆាប់រហ័សបំផុតនៃមេរោគហ៊ីវ និងអេដស៍។ តាមការប៉ាន់ប្រមាណទុកជាមុនរបស់អង្គការសុខភាពពិភពលោក កុមារអាយុក្រោម១៥ឆ្នាំ ចំនួនជាង១៥.០០០នាក់ នឹងមានផ្ទុកមេរោគហ៊ីវ នៅចុងឆ្នាំ២០០០នេះ ហើយកុមារជិត៨.០០០នាក់ នឹងមានជម្ងឺអេដស៍។ កុមារកំព្រាអាយុក្រោម១៥ឆ្នាំ ដែលបន្សល់ទុកដោយសារមេរោគហ៊ីវ និងអេដស៍មានចំនួន៣០.០០០នាក់ ក្នុងឆ្នាំ២០០០ និងអាចកើនឡើងដល់៦០.០០០នាក់ ក្នុងឆ្នាំ២០០២។ ក្នុងឆ្នាំ១៩៩៨-៩៩ សមាមាត្រមនុស្សពេញវ័យយល់ដឹងពីជំងឺអេដស៍ មាន ៨០%។ ក្នុងឆ្នាំ២០០០នេះ សមាមាត្រមនុស្សពេញវ័យយល់ដឹងពីជំងឺអេដស៍មាន៩០% គឺកើនឡើងជាងឆ្នាំមុន។ តាមការប៉ាន់ស្មានបច្ចុប្បន្ននេះ ប្រទេសកម្ពុជាមានអ្នកផ្ទុកមេរោគអេដស៍ប្រមាណ១៧០.០០០នាក់ ។

អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ បានរៀបចំគោលនយោបាយជាតិ និង យុទ្ធសាស្ត្រជាអាទិភាព ដើម្បីបង្កាមេរោគហ៊ីវ និង ជំងឺអេដស៍ និង ត្រួតពិនិត្យចាប់ពីឆ្នាំ១៩៩៩-២០០៤ ។ ផ្អែកតាមគោលនយោបាយទាំងនោះមាន :

- គ្រប់ស្ថាប័នជាតិខេត្តក្រុងត្រូវធានាឱ្យមន្ត្រីរាជការ និងប្រជាពលរដ្ឋបានទទួលនូវពត៌មានជាអតិបរិមា ស្តីពីគ្រោះថ្នាក់នៃមេរោគហ៊ីវ និង ជំងឺអេដស៍ និង វិធានការណ៍បង្ការទប់ស្កាត់ ។
- កម្មវិធីអេដស៍ត្រូវបញ្ចូលទៅក្នុងកម្មវិធីជាតិដ៏ទៃទៀត ដែលស្ថិតនៅក្នុងការគ្រប់គ្រងរបស់រដ្ឋ និងឯកជន។ ឧទាហរណ៍ : កម្មវិធីប្រយុទ្ធ និង ជំងឺអេដស៍របស់ក្រសួងសុខាភិបាល ត្រូវបញ្ចូលទៅក្នុងកម្មវិធីជាតិ គាំពារមាតា និង ទារក កម្មវិធីជាតិសុខភាពបឋម កម្មវិធីជាតិកំចាត់ជំងឺរបេង កម្មវិធីជាតិកំចាត់ជំងឺគ្រុនចាញ់ ។ល។ ឱ្យមានទំនាក់ទំនងស៊ីសង្វាក់ គ្នា។
- ក្រសួងអប់រំ យុវជន និង កីឡា ត្រូវបញ្ចូលកម្មវិធីអប់រំសុខភាពស្តីពីជំងឺអេដស៍ ទៅក្នុងកម្មវិធីសិក្សា នានានៅគ្រប់កំរិតទាំងអស់តាមប្រធានបទសមស្រប ។
- មានការអប់រំអំពីការមិនរើសអើងជាមួយអ្នកមានមេរោគហ៊ីវ និង អេដស៍ ជំងឺកាមរោគ ដោយធ្វើឱ្យកុមារ មនុស្សពេញវ័យមើលឃើញច្បាស់ពីការមិនឆ្លងជំងឺអេដស៍ ។

## III- អាហារូបត្ថម្ភ

១- អត្រាមរណៈរបស់ទារក

- អត្រាស្លាប់របស់ទារកបានថយចុះពី១១៥នាក់ ក្នុងចំណោម១.០០០នាក់ កំណើតរស់(១៩៩៦) មកត្រឹម៨៩នាក់ ក្នុង១.០០០នាក់ ក្នុងឆ្នាំ១៩៩៩ ហើយអត្រាស្លាប់របស់កុមារក្រោម៥ឆ្នាំ បានថយចុះពី១៨១នាក់ ក្នុង១.០០០កំណើតរស់(១៩៩៦) មកត្រឹម១១៥នាក់ ក្នុង១.០០០កំណើតរស់ ក្នុងឆ្នាំ១៩៩៩ រីឯអត្រាស្លាប់ស្ត្រីនាពេលសំរាលកូននៅក្នុងឆ្នាំ១៩៩៩ មានចំនួន៤៧៣នាក់ ក្នុងចំណោមស្ត្រីបង្កើតកូនរស់១០០.០០០នាក់ ។

២- បញ្ហាអ៊ីយ៉ូដ

ការបញ្ចូលជាតិអ៊ីយ៉ូដចាប់ដំណើរការអនុវត្តពីឆ្នាំ១៩៩៨ ហើយរហូតមកដល់២០០០នេះ ភាពរីកចំរើនក្នុងការលុបបំបាត់បញ្ហាកង្វះជាតិអ៊ីយ៉ូដ តាមរយៈការបញ្ចូលជាតិអ៊ីយ៉ូដទៅក្នុងអំបិលជាសកលសំរាប់ប្រើប្រាស់ទៅតាមទីក្រុង និងតាមខេត្តនានា។ អនុគណៈកម្មការបំបាត់បញ្ហាកង្វះជាតិអ៊ីយ៉ូដ បានជំរុញការផលិតអំបិលអ៊ីយ៉ូដបានចំនួន៩.០៣៣,៦៣តោន។ ក្នុងនោះអំបិលអ៊ីយ៉ូដគ្រួសចំនួន៤.៩០១,៩៤តោន និងអំបិលអ៊ីយ៉ូដម៉ត់ចំនួន៤.១៣១,៦៩តោន។ ហើយបានចែកចាយទៅក្នុងទូទាំងប្រទេស។ ស្របជាមួយការជំរុញការផលិត អនុគណៈកម្មការបានធ្វើសកម្មភាពឃោសនា អប់រំ ផ្សព្វផ្សាយ ជាសាធារណៈដើម្បីឱ្យប្រជាជនបានយល់ពីសារៈសំខាន់របស់អំបិលអ៊ីយ៉ូដ។ ទន្ទឹមទឹងនេះ អនុគណៈកម្មការបានចុះតាមដាន និងត្រួតពិនិត្យគុណភាពអំបិលអ៊ីយ៉ូដតាមបណ្តាខេត្ត-ក្រុងចំនួន១៨ ដើម្បីពិនិត្យមើលគុណភាពអំបិលកំពុងដាក់លក់នៅលើទីផ្សារ។ ដោយឡែកចំពោះក្រសួងសុខាភិបាលក៏បានផ្តល់គ្រាប់ថ្នាំអ៊ីយ៉ូដចំនួន ២៣០.០០០គ្រាប់ និង ផ្តល់ដល់ស្ត្រីក្នុងវ័យបន្តពូជដែលមានអាយុពី១៤ ទៅ ៤៥ ឆ្នាំ លើខេត្តចំនួន៥ ដែលមានអត្រាពកកខ្ពស់ គឺខេត្តក្រចេះ ស្ទឹងត្រែង រតនគិរី មណ្ឌលគិរី និង ស្រុកស្វាយលើក្នុងខេត្តសៀមរាប ។

៣- កង្វះជីវជាតិ អា

ការកាត់បន្ថយជាអតិបរិមានូវជំងឺកង្វះជីវជាតិអា ក្រសួងសុខាភិបាលបានបង្កើតក្រុមការងារមួយ ដែលរួមមានមជ្ឈមណ្ឌលគាំពារមាតា និងទារក អង្គភាពនៃកម្មវិធីចាក់ថ្នាំបង្ការ (EPI) របស់ក្រសួងសុខាភិបាល អង្គការយូនីសេហ្វ និងអង្គការហេឡែនឃិល័រ ដើម្បីស្ទង់លទ្ធភាពនៃការអនុវត្តប្រព័ន្ធចាក់ថ្នាំបង្ការ និងការផ្តល់គ្រាប់ថ្នាំជីវជាតិអា។ ការផ្តល់គ្រាប់ថ្នាំជីវជាតិអាដល់កុមារដែលមានអាយុ៦ខែ ដល់៥៩ខែ បានធ្វើឡើងជាទៀងរាល់ឆ្នាំ ហើយក្នុងមួយឆ្នាំធ្វើ២ដង គឺនៅខែមិនា និងខែសីហា ។ នៅក្នុងឆមាសទី១ ឆ្នាំ ២០០០នេះ ការផ្តល់គ្រាប់ថ្នាំជីវជាតិអាសំរេចបាន :

- កុមារដែលមានអាយុ៦ខែដល់១២ខែ ចំនួន៦៥.១៩៥នាក់
- កុមារដែលមានអាយុ១២ខែ ដល់ ៥៩ខែ ចំនួន៤៤២.៧២៩នាក់

៤- កង្វះអាហារូបត្ថម្ភ

ការកាត់បន្ថយកង្វះអាហារូបត្ថម្ភក្នុងចំណោមកុមារអាយុក្រោម៥ឆ្នាំ ដែលមានទំងន់មិនគ្រប់គ្រាន់ប្រមាណ៤០-៥០% ឱ្យថយមកត្រឹម២៥%ក្នុងឆ្នាំ២០០០ នេះថ្វីត្បិតតែមិនសំរេចគោលដៅជាតិក៏ដោយ ក៏យើងសំរេចបាន៣៣%ដែរ នេះជាការខិតខំប្រឹងប្រែងរបស់ផ្នែកអាហារូបត្ថម្ភ ។

## IV- ផ្នែកទឹក និង អនាម័យ

១- ទឹកស្អាត

ក្នុងឆ្នាំ ១៩៩៩ មាន២ភាគ៣ នៃប្រជាជនកម្ពុជាហូបទឹកស្ទឹងទន្លេ អូរ ស្រះ ឬ អណ្តូង ដែលគ្មានគំរបការពារត្រឹមត្រូវ ។ ស្ថានភាពនៅជនបទយ៉ាប់យ៉ឺនជាងស្ថានភាពនៅទីក្រុង ។ ជាងពាក់កណ្តាលនៃគ្រួសារ ប្រជាជននៅទីក្រុងភ្នំពេញ មានលទ្ធភាព

ប្រើប្រាស់ទឹកម៉ាស៊ីន ដែលរដ្ឋករទឹកក្រុងភ្នំពេញលក់ឱ្យ (របាយការណ៍របស់ក្រុមប្រឹក្សាជាតិ ស្តីពីអាហារូបត្ថម្ភជាតិ)។ តាមលទ្ធផលអង្កេតរបស់អង្គការយូនីសេហ្វ កម្មវិធីសកម្មភាពសហគមន៍ដើម្បីអភិវឌ្ឍន៍សង្គម (ស.ស.អ.ស )ក្នុងឆ្នាំ ២០០០ នៅក្នុងខេត្តចំនួន៨ មានប្រជាជនដែលបានប្រើប្រាស់ទឹកស្អាត មាន៥៨% ។ កម្មវិធី ស.ស.អ.ស បានជីកអណ្តូងទឹកចំនួន ៣៣៩អណ្តូង ហើយកម្មវិធីស្បៀងពលកម្ម (FFW) បានធ្វើអណ្តូងលូ៥១៩អណ្តូង នៅតាមបណ្តាខេត្តចំនួន១៨។ តាមរបាយការណ៍របស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល បានឱ្យដឹងថា បច្ចុប្បន្ននេះ ក្នុងខេត្ត-ក្រុងចំនួន១៨ នៅតាមទីរួមខេត្តមានទឹកស្អាត ប្រើប្រាស់ ដោយឡែកខេត្ត-ក្រុង ចំនួន៥ទៀត ពុំទាន់មានទឹកស្អាត គឺក្រុងប៉ៃលិន ក្រុងកែប ខេត្តមណ្ឌលគិរី ខេត្តព្រះវិហារ និងខេត្តឧត្តរមានជ័យ។ ក្នុងឆ្នាំ២០០០នេះ ទឹកស្អាតដែលផលិតបាននៅតាមខេត្ត-ក្រុងទាំង១៨ មានចំនួន៥.៥៥៨.៦៧៤ម៉ែត្រគូប ។ ដោយឡែករដ្ឋករទឹកស្វយ័តក្រុងភ្នំពេញផលិតទឹកស្អាតបានចំនួន៣៩.៥៨៧.៧៤៥ម៉ែត្រគូប។ ទោះបីជាការអនុវត្តទឹកស្អាតមិនបានសំរេចតាមគោលដៅជាតិក៏ដោយ ក៏ការអនុវត្តទឹកស្អាតក្នុងឆ្នាំនេះមានការកើនឡើងជាងឆ្នាំមុនៗដែរ ។

២- អនាម័យ

នៅប្រទេសកម្ពុជាមានក្រុមគ្រួសារ៣/៤ ដែលគ្មានប្រព័ន្ធអនាម័យប្រើប្រាស់ មានភាពខុសគ្នារវាងជនបទ និងទីក្រុងលក្ខណៈច្បាស់លាស់ គឺគ្រួសារ៨៥% នៅទីជនបទ គ្មានប្រព័ន្ធអនាម័យ ឯនៅទីក្រុងវិញមាន៥០%ប៉ុណ្ណោះ។ នៅរាជធានីភ្នំពេញ គ្រួសារដែលគ្មានបង្គន់អនាម័យប្រើប្រាស់ មានតែ២០% (របាយការណ៍របស់ក្រុមប្រឹក្សាស្តីពីអាហារូបត្ថម្ភជាតិ ឆ្នាំ១៩៩៩)។ តាមលទ្ធផលអង្កេតរបស់អង្គការយូនីសេហ្វ កម្មវិធីសកម្មភាពសហគមដើម្បីអភិវឌ្ឍសង្គម (ស.ស.អ.ស) ក្នុងឆ្នាំ២០០០ នៅក្នុងខេត្តចំនួន៨ ដែលបានប្រើប្រាស់បង្គន់មាន១៤%។ ក្រសួងអភិវឌ្ឍន៍ជនបទ សហការជាមួយអង្គការ WFP បានអនុវត្តការងារកម្មវិធីស្បៀងពលកម្ម( FFW ) បានធ្វើបង្គន់អនាម័យចំនួន៥.៧០០បង្គន់ ហើយកម្មវិធី ស.ស.អ.ស ដែលគាំទ្រដោយ យូនីសេហ្វ បានធ្វើបង្គន់អនាម័យចំនួន៥.២១៩បង្គន់។ ដូច្នេះទោះបីជាមិនបានតួលេខសរុបទូទាំងប្រទេសក៏ដោយ ក៏យើងឃើញការប្រើប្រាស់បង្គន់ដែលមានអនាម័យល្អ មានការកើនឡើងជាងឆ្នាំមុនៗដែរ ។

## V- កិច្ចការពារកុមារដែលងាយរងគ្រោះ

១- ការងារឃោសនាអប់រំបណ្តុះបណ្តាល

- ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ដូចជាក្រសួងពាក់ព័ន្ធ អង្គការក្រៅរដ្ឋាភិបាល អង្គការអន្តរជាតិ បានផ្សព្វផ្សាយអនុសញ្ញាស្តីពីសិទ្ធិកុមារ និងបញ្ហាកុមារ ដូចជាការជួញដូរ ពេស្យាចារកុមារ ជំងឺអេដស៍ ដល់មន្ត្រីរាជការ និងសាធារណៈជនតាមរយៈសិក្ខាសាលាជាច្រើនលើក និង តាមប្រព័ន្ធឃោសនាផ្សព្វផ្សាយពត៌មានចំរុះ វិទ្យុ ទូរទស្សន៍ សៀវភៅជាដើម ប៉ុន្តែការយល់ដឹងនៅមានកំរិតទាប ។

- ឆ្នាំ១៩៩៩-២០០០ ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា បានសហការជាមួយអង្គការយូនីសេហ្វ អនុវត្តកម្មវិធី កុមារត្រូវការកិច្ចការពារពិសេស នៅខេត្តបាត់ដំបងដោយផ្តោតលើស្រុកថ្មគោលដែលបានជំរុញកុមារឱ្យបានទៅសាលារៀន៥១៨នាក់។ ទន្ទឹមនឹងនេះ ក្រសួងសហការជាមួយអង្គការ Save the Children UK ធ្វើការជំរុញកុមារឱ្យបានទៅសាលា ចំនួន ១.២១៧នាក់ នៅក្នុងខេត្តកំពង់ស្ពឺ ។

- ក្រសួងកិច្ចការនារី និង អតីតយុទ្ធជន សហការជាមួយ IOM ធ្វើកម្មវិធីអភិវឌ្ឍន៍ធនធានមនុស្ស នឹងពង្រីកសមត្ថភាពរៀបចំកម្មវិធីទប់ស្កាត់អំពើជួញដូរដោយធ្វើឱ្យមន្ត្រីយល់ដឹងពីច្បាប់ ការផ្សព្វផ្សាយពត៌មាន និង គោលនយោបាយ។

២- ការអនុវត្តផែនការជាតិ៥ឆ្នាំ ប្រឆាំងនឹងការជួញដូរកេងប្រវ័ញ្ចផ្លូវភេទ និង ការជួញដូរលើកុមារ

រាជរដ្ឋាភិបាលកម្ពុជាបានអនុម័តលើផែនការជាតិ៥ឆ្នាំ ប្រឆាំងការជួញដូរ និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ និងបានចេញសេចក្តីប្រកាសលេខ ០១ ស្តីពីវិធានការចាត់តាំងការអនុវត្តផែនការនេះ ។

- កិច្ចបង្ការទប់ស្កាត់ : ក្រសួង និងស្ថាប័នពាក់ព័ន្ធ បានធ្វើការងារផ្សព្វផ្សាយសិទ្ធិកុមារ ពេស្យាចារកុមារ និងការប្រឆាំងគ្រឿងញៀន ជំងឺអេដស៍តាមរយៈសិក្ខាសាលា ការអប់រំផ្ទាល់សហគមន៍ និងតាមរយៈការផ្សព្វផ្សាយចំរុះ។ សិទ្ធិកុមារត្រូវបានបញ្ចូលទៅក្នុងកម្មវិធីសិក្សា ។

- កិច្ចការពារ : បន្ថែមលើច្បាប់ស្តីពីការបង្ក្រាបអំពើពង្រាត់ និង លក់ដូរមនុស្ស និងអំពើធ្វើអាជីវកម្មលើមនុស្ស មានសារាចរ សេចក្តីសំរេច និង លិខិតណែនាំមួយចំនួនទៀត ដែលធ្វើឡើងដោយរាជរដ្ឋាភិបាល និងក្រសួងជំនាញមានក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ ក្រសួងពត៌មាន ក្រសួងមហាផ្ទៃ ក្រសួងទេសចរណ៍ ដើម្បីទប់ស្កាត់ការរំលោភលើផ្លូវភេទ ការទប់ស្កាត់អំពើហឹង្សាលើស្ត្រីភេទ ពង្រឹងកិច្ចការពារសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ បង្ក្រាបការធ្វើអាជីវកម្មបញ្ចាំង និងលក់កាសែតវីដេអូអាសអាភាស ហាមយកទីតាំងទេសចរណ៍ធ្វើកន្លែងពេស្យា បនល្បែង ប្រើគ្រឿងញៀន ។ល។

ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ បានបង្កើតអនុគណៈកម្មការប្រឆាំងការជួញដូរ និង កេងប្រវ័ញ្ចផ្លូវភេទលើកុមារ

- វិធានការ : ក្រសួងមហាផ្ទៃមានវិធានការស៊ើបអង្កេត និង បង្ក្រាបអំពើពេស្យាចារ ជាលទ្ធផលរួម បានសង្គ្រោះកុមារ និង ស្ត្រីរងគ្រោះចេញពីផ្ទះបន បញ្ជូនជនល្មើសទៅតុលាការ ។

ក្នុងឆ្នាំ២០០០នេះ ដោយជំនួយពីយូនីសេហ្វ ក្រសួងបានបង្កើតទូរស័ព្ទពិសេសមួយ សំរាប់ជាជំនួយក្នុងការបង្ក្រាបអំពើពេស្យាចារ ។

- ក្រុមការងារកុមារត្រូវការកិច្ចការពារពិសេស បានជួយធ្វើអន្តរាគមន៍ផ្នែកច្បាប់ ក្នុងករណីកុមារីត្រូវរំលោភផ្លូវភេទចំនួន៧នាក់ នៅខេត្តបាត់ដំបង ។

- ការស្តារ និង អភិវឌ្ឍន៍សមត្ថភាព និង សមាហរណកម្ម : ក្រសួងសង្គមកិច្ចបានសហការជាមួយ IOM និង UNICEF រៀបចំកម្មវិធីគាំទ្រស្ត្រី និងកុមារ ដែលរងគ្រោះដោយការជួញដូរទៅប្រទេសថៃ ហើយត្រូវធ្វើមាតុភូមិនិវត្តន៍មកប្រទេសកម្ពុជាវិញ ។

- នៅឆ្នាំ១៩៩៩ ក្រសួងបានសហការជាមួយអង្គការក្រៅរដ្ឋាភិបាល បានផ្តល់នូវសេវាសុខភាពបណ្តុះបណ្តាលវិជ្ជាជីវៈ និង រកការងារឱ្យធ្វើទៅដល់កុមារដែលត្រូវបានសង្គ្រោះពីផ្ទះបន ចំនួន៥០២នាក់។ ទន្ទឹមនេះ មានអង្គការក្រៅរដ្ឋាភិបាលមួយចំនួនដូចជា CPCCR , AFESEP , ផ្ទះនៃក្តីសង្ឃឹម ។ល។ ក៏បានចូលរួមក្នុងកម្មវិធីខាងលើនេះដែរ ។

៣- កុមារអនាថា

- តាមរបាយការណ៍របស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា ក្នុងឆមាសទី១ ឆ្នាំ២០០០ មានកុមារអនាថាចំនួន៩៧៤នាក់ ត្រូវបានទទួលឱ្យស្នាក់នៅ និងអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈ ។

- តាមរបាយការណ៍របស់ក្រសួងផែនការ បច្ចុប្បន្ននៅភ្នំពេញមានក្មេងអនាថាប្រហែល១.០០០នាក់ រស់នៅដោយខ្លួនឯងផ្ទាល់ ឬរស់នៅជាមួយគ្រួសាររបស់គេ។ ក្នុងចំណោមក្មេងអនាថាទាំងនោះ ភាគច្រើនជាក្មេងប្រុស។ មុខរបរទូទៅបំផុតរបស់ក្មេងអនាថា គឺដើររើសអេតចាយនៅតាមគំនរសំរាម មានចំនួន៤៦% និងដើរសុំទានមានចំនួន១៨%។ ក្មេងស្រីអនាថាប្រហែល៩% និងក្មេងប្រុសអនាថាប្រហែល៥% រកស៊ីផ្លូវភេទ។ ក្មេងអនាថាទាំងនេះ អាចទទួលការទាក់ទាញឱ្យចូលទៅក្នុងក្រុមអន្ធពាលបានយ៉ាងងាយស្រួល ហើយប្រព្រឹត្តអំពើឧក្រិដ្ឋ ដូចជាលួចហោប៉ៅ និង លួចឆក់ ដើម្បីទ្រទ្រង់ជីវភាពរស់នៅរបស់គេ ។

ពួកគេក៏ងាយរងគ្រោះដោយការ ប្រើថ្នាំញៀន និងការរកស៊ីផ្លូវភេទដើម្បីប្តូរយកប្រាក់ ឬទីជំរកបណ្តោះអាសន្នផងដែរ កុមារអនាថាក្រោមមណ្ឌលទទួលការអប់រំក្រៅប្រព័ន្ធបានចំនួន១៩.០២៩នាក់។ ជាមួយគ្នានេះ កុមារអនាថាមួយចំនួនបានត្រូវចិញ្ចឹមបីបាច់ថែរក្សាក្នុងមជ្ឈមណ្ឌលដោយអង្គការក្រៅរដ្ឋាភិបាលមួយចំនួន ។

៤- កុមារពិការ

- តាមរបាយការណ៍របស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា ក្នុងឆ្នាំ២០០០នេះ កុមារពិការមានចំនួន ១៦.០១០នាក់ នៅក្នុងខេត្តក្រុងចំនួន២០។ នៅតាមមណ្ឌលកុមារកំព្រារបស់រដ្ឋាភិបាលចំនួន២១ មានកុមារពិការចំនួន៧២នាក់ ត្រូវបានអប់រំ និង ថែទាំ។ បច្ចុប្បន្នក្រសួងសង្គមកិច្ចបានសហការជាមួយក្រុមប្រឹក្សាជនពិការ បង្កើតបាននូវកម្មវិធីសាកល្បងមួយឈ្មោះថា " ផ្ទះគំរូ " ចិញ្ចឹមកុមារពិការ កំព្រាចំនួន៥នាក់នៅសហគមន៍ ។ ដោយឡែក មានអង្គការ OEB នៅខេត្តបាត់ដំបងជួយថែរក្សាអប់រំ កុមារពិការនៅក្នុងសហគមន៍ ។ កុមារពិការ ខ្វាក់ គរ ថ្លង់ ត្រូវបានរៀនសូត្រនៅក្នុងសាលា ដែលគ្រប់គ្រងដោយអង្គការគ្រួសារថ្មីនៅភ្នំពេញ បាត់ដំបង សៀមរាប ។

៥- គ្រាប់មីន

- កន្លងមក បញ្ហាគ្រាប់មីន ត្រូវបានផ្សព្វផ្សាយតាមរយៈទូរទស្សន៍។ អង្គការយូនីសេហ្វ និង MAG បានផ្តួចផ្តើមនូវគំរោងការងារមួយ ដោយសហការជាមួយក្រសួងអប់រំ យុវជន និង កីឡា ធ្វើការបញ្ចូលការអប់រំ អំពីគ្រោះថ្នាក់នៃគ្រាប់មីនទៅក្នុងកម្មវិធីសិក្សា ហើយផ្តល់អាទិភាពទៅលើស្រុកដែលមានបញ្ហាមីន។ អង្គការក្រៅរដ្ឋាភិបាលមួយចំនួនកំពុងសហការជាមួយអង្គការក្រៅរដ្ឋាភិបាល ដែលធ្វើសកម្មភាពកំចាត់មីន ធ្វើផែនការអភិវឌ្ឍសកម្មភាព ដោយភ្ជាប់ទាក់ទងទៅនឹងសកម្មភាពកំចាត់មីន សំដៅធ្វើឱ្យប្រសើបំផុតនូវលទ្ធផលនៃការបោសសំអាតមីន ។

៦- ពលកម្មកុមារ

ផ្នែកពលកម្មកុមារនៃក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា បានរៀបចំសិក្ខាសាលាបណ្តុះបណ្តាលមន្ត្រីអធិការការងារ មកពីខេត្តក្រុងចំនួន១៤ ដែលមានអត្រាពលកម្មកុមារ និង ការជួញដូរកុមារខ្ពស់ និង អង្គការក្រៅរដ្ឋាភិបាល បានជាច្រើនលើក ដែលផ្តោតទៅលើ (១) ការពង្រឹងសមត្ថភាព និង ការបង្កើតការយល់ដឹងអំពីពលកម្មកុមារនៅក្នុងបរិបទរបស់ប្រទេសកម្ពុជានាពេលអនាគត។ (២ ) បណ្តុះបណ្តាលជូនដល់សិក្ខាកាមចំនួន២៤រូប ដែលអញ្ជើញមកពីស្ថាប័នរដ្ឋាភិបាល និង អង្គការក្រៅរដ្ឋាភិបាល ឱ្យចេះធ្វើការកសាងគ្រប់គ្រង និង វាយតំលៃគំរោងកម្មវិធីពលកម្មកុមារ។ (៣ ) ការប្រកាសជាផ្លូវការនូវកម្មវិធីអន្តរជាតិស្តីពីការលុបបំបាត់ពលកម្មកុមារនៅកម្ពុជា ការចុះហត្ថលេខាលើអនុសារណៈរវាង ក្រសួង ស.ក.ប.យ (តំណាងឱ្យរាជរដ្ឋាភិបាលកម្ពុជា) និងអង្គការអន្តរជាតិខាងការងារ ដែលបានកំណត់នូវផ្នែកគោលការណ៍ និងទំរង់បែបបទនៃកិច្ចសហប្រតិបត្តការ ការផ្សព្វផ្សាយលទ្ធផលនៃការអង្កេតស្តីពីពលកម្មកុមារនៅប្រទេសកម្ពុជា ការកសាងនូវអនុសាសន៍សំរាប់ផែនការជាតិប្រឆាំងពលកម្មកុមារ ។

អនុគណៈកម្មការពលកម្មកុមារ និងទំរង់នៃការកេងប្រវ័ញ្ចផ្សេងៗទៀតមកលើកុមារ មានតួនាទី និងគោលបំណងធានាកិច្ចអនុវត្ត ការតាមដានត្រួតពិនិត្យ និងវាយតំលៃគោលនយោបាយទាំងឡាយ និងកម្មវិធីដែលទាក់ទងទៅនឹងពលកម្មកុមារដែលរហូតមកដល់ពេលនេះ បានអនុម័តគំរោងចំនួន២៦គំរោង ដែលមានទឹកប្រាក់ចំនួន១៤២.៩៨៧,៨០ ដុល្លារអាមេរិក ជូនដល់ភ្នាក់ងារនានា ដែលកំពង់ផ្តល់សេវាកម្មពលកម្មកុមារ ។ ហើយនៅឆ្នាំ ២០០១នេះ ក្រសួង ស.ក.ប.យ និង ក្រសួងផែនការកំពុងរៀបចំធ្វើការអង្កេតពលកម្មកុមារទូទាំងប្រទេសលើកទី២ ដែលមានទឹកប្រាក់សរុបចំនួន៣១១.០១៥ដុល្លារអាមេរិក (លើកទី១ក្នុងឆ្នាំ ១៩៩៦ ) ។

៧- ផ្នែកច្បាប់

- ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ បានបង្កើតអនុគណៈកម្មការតាក់តែងច្បាប់ដែលពាក់ព័ន្ធទៅនឹងកុមារ ដែលមានសមាសភាពតំណាងក្រសួងពាក់ព័ន្ធ ។

- ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា បានធ្វើសេចក្តីព្រាងច្បាប់ស្តីពីការសុំកូនចិញ្ចឹម សេចក្តីព្រាងនេះ ដាក់ជូនគណៈរដ្ឋមន្ត្រីដើម្បីសុំការពិនិត្យ ។

~~~~~~~~~~~
~~~~~~~~~~~

# សេចក្តីសន្និដ្ឋានចុងក្រោយរបស់គណៈកម្មាធិការនៃ អ.ស.ប លើសិទ្ធិកុមារនៅកម្ពុជា សេចក្តីសន្និដ្ឋានជាអ្វី ?

* **ឯកសារផ្សព្វផ្សាយដែលមានខ្លឹមសារ :**

- វាយតំលៃដោយគណៈកម្មាធិការលើស្ថានភាពជាក់ស្តែងនៃសិទ្ធិកុមារនៅកម្ពុជា ផ្អែកលើរបាយការណ៍របស់រាជរដ្ឋាភិបាលកម្ពុជា របាយការណ៍របស់អង្គការក្រៅរដ្ឋាភិបាល និងការពិភាក្សាជាមួយគណៈប្រតិភូ នៃរាជរដ្ឋាភិបាលកម្ពុជា។
- អនុសាសន៍ស្តីអំពីវិធានការដែលត្រូវប្រកាន់យកដោយរាជរដ្ឋាភិបាលកម្ពុជា ដើម្បីការអនុវត្តសិទ្ធិដែលមានចែងក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារ ។

## **វិជ្ជមានភាពជាវិជ្ជមាន**

- ការបញ្ចូលទៅក្នុងរដ្ឋធនុម្មញ្ញនូវសិទ្ធិដែលធានាដោយអនុសញ្ញាស្តីពីសិទ្ធិកុមារ។
- វិធានការប្រឆាំងពលកម្មកុមាររួមមាន ការផ្តល់សច្ចាប័នលើអនុសញ្ញា ILO ស្តីពីអាយុអប្បបរិមា និងកិច្ចសហប្រតិបត្តិការ ជាមួយ ILO/IPEC ។
- កិច្ចសហប្រតិបត្តិការជាមួយការិយាល័យឧត្តមស្នងការសិទ្ធិមនុស្សលើកម្មវិធីសិទ្ធិមនុស្ស ។
- ការចូលរួមរបស់ NGOs ក្នុងការរៀបចំរបាយការណ៍របស់រាជរដ្ឋាភិបាល ។

## **កិច្ចស្វាគមន៍របស់គណៈកម្មាធិការលើគំនិតផ្តួចផ្តើមផ្សេងៗទៀត**

- ការបង្កើន ក.ជ.ក.ក
- វិធានការប្រមូលទិន្នន័យក្នុងវិស័យអប់រំ និង សុខាភិបាល
- ការបញ្ចូលអនុសញ្ញាស្តីពីសិទ្ធិកុមារក្នុងកម្មវិធីសិក្សា
- កិច្ចប្រឹងប្រែងបណ្តុះបណ្តាលជំនាញដល់ក្រុមអ្នកធ្វើការងារកុមារ
- កិច្ចប្រឹងប្រែងធ្វើសេចក្តីព្រាងច្បាប់ស្មុំកូនអន្តរប្រទេស
- ការហាមប្រាមមិនឱ្យជ្រើសរើសកុមារក្រោមអាយុ១៨ឆ្នាំចូលបំរើកងទ័ព
- ច្បាប់ប្រឆាំងនឹងការកេងប្រវ័ញ្ចផ្លូវភេទ និងផែនការ៥ឆ្នាំប្រឆាំងការកេងប្រវ័ញ្ចផ្លូវភេទលើកុមារ
- កិច្ចសហប្រតិ បត្តិការជាមួយទីភ្នាក់ងារ អ.ស.ប លើកម្មវិធីឱ្យយល់ដឹងអំពីសិទ្ធិកុមារ ។

## **វិធានការ**

* វិធានការស្នើឡើង ដើម្បីឱ្យប្រសើរឡើងនូវស្ថានភាពសិទ្ធិកុមាររួមមាន :

- ការអនុម័តច្បាប់ ឬការពិនិត្យច្បាប់ឡើងវិញ
- ពង្រឹងការអនុវត្តច្បាប់
- ការអភិវឌ្ឍគោលនយោបាយ ការបែងចែកធនធានថវិកា
- ការប្រមូលទិន្នន័យ

- ការអភិវឌ្ឍស្ថាប័ន និងយន្តការ
- ការលើកកំពស់ការយល់ដឹង ការអប់រំនិងការហ្វឹកហ្វឺន
- សហប្រតិបត្តិការជាមួយអន្តរជាតិ /ជំនួយ

## កិច្ចសហការសំរបសំរួល និង ការត្រួតពិនិត្យតាមដាន

- ពង្រឹងតួនាទី ក.ជ.ក.ក ក្នុងការអនុវត្តអនុសញ្ញាសិទ្ធិកុមារ តាមរយៈការបង្កើនប្រភពធនធាន
- បង្កើនកិច្ចសហប្រតិបត្តិការជាមួយ NGOs
- យន្តការដើម្បីត្រួតពិនិត្យការអនុវត្តអនុសញ្ញារួមភ្ជាប់ និងបណ្តឹង និងដំណោះស្រាយសំរាប់ការរំលោភបំពាន
- ពង្រឹងប្រព័ន្ធប្រមូលទិន្នន័យក្នុងវិស័យទាំងអស់នៃអនុសញ្ញា
- ការបែងចែកធនធានដល់ផ្នែកសុខាភិបាល អប់រំ និងសេវាសង្គមសំរាប់កុមារ
- ការអប់រំនិងការបណ្តុះបណ្តាលដល់គ្រប់ក្រុមអ្នកធ្វើការងារជំនាញសំរាប់កុមារ

## ច្បាប់ និង បទបញ្ជា

* វិធានការជាក់លាក់មួយចំនួន ត្រូវបានស្នើឡើងដើម្បីធ្វើឱ្យច្បាប់ក្នុងស្រុកសមស្របទៅតាមអនុសញ្ញា ស្តីពីសិទ្ធិកុមារ និងបង្កើតឱ្យបានគ្រប់គ្រាន់នូវក្របខ័ណ្ឌការងារ អនុវត្តច្បាប់ ដើម្បីការពារកុមារ និងជំរុញការអនុវត្តសិទ្ធិកុមារ ។

☞ អភិវឌ្ឍន៍ច្បាប់ថ្មីៗ

- យុត្តិធមិយុវវ័យ
- ការការពារកុមារជាជនភៀសខ្លួន
- ការការពារកុមារពីទំរង់ពលកម្មដែលមានគ្រោះថ្នាក់
- ការចូលរួមរបស់កុមារនៅក្នុងគ្រួសារ សាលា និងស្ថាប័នដ៏ទៃទៀត
- ការការពារកុមារកុំឱ្យទទួលពត៌មាន ដែលធ្វើឱ្យខូចប្រយោជន៍ និងធានាការទទួលបាននូវពត៌មានសមស្រប

☞ ការពិនិត្យច្បាប់ឡើងវិញ និងពង្រឹងច្បាប់ដែលមានស្រាប់

- បញ្ចូលសិទ្ធិកុមារដែលពាក់ព័ន្ធទៅក្នុងសេចក្តីព្រាងច្បាប់រដ្ឋប្បវេណី ច្បាប់ព្រហ្មទ័ណ្ឌ និងក្រមនីតិវិធីព្រហ្មទ័ណ្ឌ
- បញ្ចូលនិយមន័យ " កុមារ "ទៅក្នុងច្បាប់ស្រុក
- កំណត់ច្បាស់លាស់នូវអាយុអប្បបរិមាដើម្បីទទួលខុសត្រូវក្នុងបទ ឧក្រិដ្ឋ និងការយល់ព្រមរួមភេទ
- បញ្ចូលគោលការណ៍ទូទៅនៃអនុសញ្ញា( មិនរើសអើងផលប្រយោជន៍ដ៏ល្អបំផុតសំរាប់កុមារ សិទ្ធិរស់រានមានជីវិត និង ការអភិវឌ្ឍ) ទៅក្នុងច្បាប់ដែលពាក់ព័ន្ធទាំងអស់
- ធានាថាការ ចុះបញ្ជីអត្រានុកូលដ្ឋានជាកាតព្វកិច្ចសំរាប់កុមារទាំងអស់
- ពិនិត្យច្បាប់សញ្ជាតិឡើងវិញ ដើម្បីលុបបំបាត់មូលដ្ឋាន ដែលនាំឱ្យមានភាពរើសអើង
- ពិនិត្យច្បាប់សុំកូនក្នុងស្រុកឡើងវិញ
- ពង្រឹងច្បាប់ស្តីពីការជួញដូរផ្លូវភេទ លើកុមារ

☞ ជំរុញច្បាប់ដែលមានស្រាប់ស្តីអំពី :

- អាយុអប្បរិមាដែលអាចចូលបំរើការងារបាន អាយុអប្បបរិមាក្នុងការរៀបអាពាហ៍ពិពាហ៍

- អនុក្រឹត្យស្តីពីការ ស្នាក់នៅ និងសៀវភៅគ្រួសារដែលធានាឱ្យមានការចុះឈ្មោះកុមារ
- ការជួញដូរផ្លូវភេទលើកុមារ ។

## គ្រួសារ និងការថែទាំផ្សេង

- ការអភិវឌ្ឍគោលនយោបាយ និងបទបញ្ញត្តិផ្សេងៗទាក់ទងទៅនឹងមជ្ឈមណ្ឌលចិញ្ចឹមកុមារ និងទំរង់នៃការថែទាំផ្សេងៗទៀត រួមមានគ្រួសារជាអាណាព្យាបាល
- ពង្រឹងសេវាសង្គម ដើម្បីគ្របដណ្តប់កុមារដែលមានចំនួនធំធេង រួមទាំងកុមារកំព្រាដែលហ៊ីវ-អេដស៍
- ការផ្តល់ធនធានថវិការ និងធនធានមនុស្សឱ្យបានគ្រប់គ្រាន់សំរាប់ គោលបំណងទាំងនេះ
- ពិនិត្យឡើងវិញនូវច្បាប់សុំកូនក្នុងស្រុក និងអនុម័តច្បាប់សុំកូនអន្តរប្រទេស
- ឯកភាពចំពោះអនុសញ្ញាទីក្រុងឡាអេ ស្តីពីការការពារកុមារ និងកិច្ចសហប្រតិបត្តិការក្នុងការអនុវត្តសុំកូនអន្តរប្រទេស,,
- ពង្រឹងការិយាល័យសុំកូន
- ពង្រឹងវិធានការការពារ និងប្រឆាំងការរំលោភបំពាន ម៉ាក់ងាយកុមារនៅក្នុងគ្រួសារ សាលារៀន និងក្នុងមជ្ឈមណ្ឌលផ្សេងៗ ជារួមតាមរយៈ ការពង្រឹងការអនុវត្តច្បាប់ យន្តការដែលស្ថិតស្ថាល និងកុមារសំរាប់ទទួលពាក្យបណ្តឹង និងអប់រំកុមារ ។

## សុខភាព

- អនុវត្តយុទ្ធសាស្ត្រអន្តរវិស័យដើម្បីដោះស្រាយបញ្ហាសុខភាពកុមារ ដោយផ្អែកលើទិន្ន័យជាក់ស្តែងដែលប្រមូលបាន និងយកចិត្តទុកដាក់លើតំរូវការនៃសហគមន៍ដែលនៅដាច់ស្រយាល
- រៀបចំថែទាំសុខភាពជាមូលដ្ឋានដែលមាន សមត្ថភាពគ្រប់គ្រាន់
- បន្តការអនុវត្តវិធានការដ៏មានប្រសិទ្ធភាព ដើម្បីបង្កាជំងឺហ៊ីវ-អេដស៍ រួមមានការធ្វើឱ្យយល់ដឹង និងការអប់រំ
- ជំរុញសិទ្ធិរបស់កុមារពិការ ដោយអនុវត្តវិធានការផ្សេងៗ ដើម្បីឱ្យមានមជ្ឈមណ្ឌលដឹកនាំយុទ្ធនាការឱ្យមានការយល់ដឹង ដើម្បីបញ្ចៀសភាពរើសអើង សំរួលឱ្យទទួលបានការអប់រំ និងហ្វឹកហ្វឺន បុគ្គលិកជំនាញដែលពាក់ព័ន្ធ
- ធ្វើអោកុមារក្រីក្រទទួលបានសេវាថែទាំសុខភាព និងថ្នាំព្យាបាលបានប្រសើរឡើងថែមទៀត
- ធ្វើការសិក្សាអំពីបញ្ហាសុខភាពកុមារវ័យជំទង់ ដើម្បីអភិវឌ្ឍគោលនយោបាយដ៏សមស្រប ពង្រឹងការអប់រំសុខភាពបន្តពូជ និង អភិវឌ្ឍសេវាពិគ្រោះយោបល់ ។

## ការអប់រំ និង ការកំសាន្ត

- ធ្វើឱ្យមានការសិក្សាអប់រំកំរិតបឋម ដោយមិនបង់ថ្លៃ និងជាកាតព្វកិច្ចសំរាប់កុមារទាំងអស់
- ធ្វើឱ្យកុមារ ជនជាតិភាគតិច និងកុមារក្រីក្រ កុមារី និងកុមារនៅតំបន់ដាច់ស្រយោលបានចូលរៀនច្រើនជាងមុន
- ធ្វើឱ្យគុណភាពអប់រំប្រសើរឡើង ដោយបង្កើនថវិកាសំរាប់ផ្នែកអប់រំ ហ្វឹកហ្វឺនគ្រូ និងពិនិត្យកម្មវិធីសិក្សាឡើងវិញ។

## ការជួញដូរ និងការកេងប្រវ័ញ្ចលើកុមារ

☞ ការការពារ និងការដាក់ទ័ណ្ឌកម្មលើការកេងប្រវ័ញ្ចសេដ្ឋកិច្ចលើកុមារដោយ :

- ពង្រឹងបទដ្ឋាននៃអាយុអប្បបរិមា ដើម្បីចូលធ្វើការបាន

- ត្រួតពិនិត្យពលកម្មកុមារ តាមរយៈអធិការ
- អនុវត្តការ ផ្តន្ទាទោសដល់អ្នករំលោភបំពាន,អនុម័តច្បាប់ការពារកុមារពីទំរង់ពលកម្មដែលមានគ្រោះថ្នាក់
- ផ្តល់សច្ចានុម័ត ដល់អនុសញ្ញា១៨២ របស់ILO

☞ កិច្ចបង្កា និងដាក់ទ័ណ្ឌកម្មដល់ការកេងប្រវ័ញ្ចផ្លូវភេទ និងជួញដូរកុមារដោយ :

- អនុវត្តច្បាប់ក្នុងស្រុកឱ្យបានពេញលេញ និងពិនិតឡើងវិញដើម្បីពង្រឹងច្បាប់
- អនុវត្តបានពេញលេញនូវផែនការសកម្មភាព ប្រឆាំងការកេប្រវ័ញ្ចផ្លូវភេទលើកុមារឆ្នាំ២០០០-២០០៤នឹងផ្តល់ថវិការឱ្យបានគ្រប់គ្រាន់
- ពង្រឹងសេវាសង្គមសំរាប់ស្តាជនរងគ្រោះ
- ការចោទប្រកាន់លើជនល្មើស និងពង្រឹងកិច្ចសហប្រតិបត្តិការទ្វេភាគី
- ប្រកាន់ យកវិធានការបន្ថែមទៀតដើម្បីស្តារ និងសមាហរណកម្មកុមារយោធា
- លុបបំបាត់ភាពរើសអើង ប្រឆាំងកុមាររស់នៅ ឬធ្វើការតាមចិញ្ចើមថ្នល់ និងកុមារជាជនជាតិភាគតិច

## ពត៌មាន និង សកម្មភាពវប្បធម៌

- ចែកផ្សព្វផ្សាយនូវអនុសញ្ញាស្តីអំពីសិទ្ធិកុមារ ជាពិសេសក្នុងតំបន់ជនបទ និងក្នុងក្រុមចំណោមជនជាតិភាគតិច
- កម្មវិធីអប់រំ និងបណ្តុះបណ្តាលដល់ក្រុមអ្នកមានអាជីពធ្វើការជាមួយកុមារ
- ជំរុញការចូលរួមរបស់កុមារនៅក្នុង គ្រួសារ សាលា និងស្ថាប័នផ្សេងៗទៀត
- អនុម័តច្បាប់ដើម្បីការពារកុមារពីពត៌មានដែលធ្វើឱ្យខូចប្រយោជន៍ និងធានាថាកុមារទទួលបានពត៌មានសមស្រប
- ចែកផ្សព្វផ្សាយរបាយការណ៍របស់រាជរដ្ឋាភិបាល និងចំលើយ កំណត់ហេតុសង្ខេប និងអនុសាសន៍ ។

# លទ្ធផលសិក្ខាសាលារបស់អង្គការក្រៅរដ្ឋាភិបាល

# ស្តីពី អនុសាសន៍របស់ អ.ស.ប លើការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារ នៅកម្ពុជា

| បញ្ហាជាកង្វល់ចំបងៗ | អនុសាសន៍របស់NGOs |
|---|---|
| **I. វិធានការនៃការអនុវត្តទូទៅ**<br>១-ច្បាប់ដែលមានស្រាប់ពុំទាន់សមស្របទៅនឹងបទបញ្ញត្តិ និងគោលការណ៍របស់CRC<br>• ការចុះបញ្ជីជាតិ<br>• មធ្យោបាយនៃការថែទាំចំលាស់<br>• ប្រព័ន្ធយុត្តិធម៌សំរាប់កុមារ<br>២-ការបណ្តុះបណ្តាលពីCRC ដល់មន្ត្រីធ្វើច្បាប់ និងអនុវត្តច្បាប់នៅមានកំរិត<br>៣-ពុំទាន់មានយន្តការឯករាជ្យសំរាប់តាមដានត្រួតពិនិត្យការអនុវត្តCRC និងដោះស្រាយបណ្តឹងកុមារ | ► ធ្វើវិសោធនកម្មច្បាប់ដែលទាក់ទងទៅនឹងកុមារឱ្យស្របទៅនឹងបទបញ្ញត្តិ និងគោលការណ៍របស់CRC<br>► ពង្រឹងឱ្យមានការអនុវត្តច្បាប់នៃការចុះបញ្ជីជាតិ<br>► អនុវត្តច្បាប់ដើម្បីដកហូតអំណាចមេបាក្នុងករណីមានអំពើរំលោភធ្ងន់ធ្ងរមកលើកុមារ និងមានបទបញ្ញត្តិសំរាប់គ្រប់គ្រងមជ្ឈមណ្ឌលកុមារ<br>► បង្កើតឱ្យមានប្រព័ន្ធតុលាការសំរាប់កុមារ មានចៅក្រម ព្រះរាជអាជ្ញា មេធាវីមានជំនាញលើរឿងក្តីកុមារ<br>► បង្កើតយន្តការឯករាជ្យសំរាប់តាមដានត្រួតពិនិត្យការ អនុវត្តន៍ CRC និងដោះស្រាយបណ្តឹងកុមារ |
| **II. និយមន័យ គោលការណ៍ទូទៅ និងសិទ្ធិសេរីភាពពលរដ្ឋ**<br>១-ពុំទាន់មាននិយមន័យកុមារច្បាស់លាស់នៅក្នុងច្បាប់<br>២-គោលការណ៍ទូទៅរបស់CRC ពុំទាន់បានបញ្ជ្រាបក្នុងការអនុវត្តកម្មវិធីនិងសកម្មភាពនានាដើម្បីកុមារ<br>៣-កុមារភាគច្រើនពុំទាន់ត្រូវបានចុះបញ្ជីជាតិ<br>៤-ការចូលរួមរបស់កុមារនៅមានកំរិតទាប | ► កំណត់អាយុរបស់កុមារឱ្យបានច្បាស់ក្នុងច្បាប់ ដូចជាអាយុទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ អាយុក្នុងការព្រមព្រៀងរួមភេទ និងអាយុអប្បបរិមាក្នុងការបំរើការងារ ដែលមិនរៀបរយ<br>► ផ្សព្វផ្សាយពីសារៈសំខាន់នៃការចុះបញ្ជីជាតិ ដោយដាក់ជាភាតព្វកិច្ច និងឥតបង់ថ្លៃ<br>► បង្កើតឱ្យមានកម្មវិធីសួរដេញដោលដោយផ្តល់ឱកាសឱ្យកុមារបានចូលរួមជជែកវែកញែក និងបង្ហាញពីបញ្ហាពិតរបស់ពួកគេ |
| **III. បរិយាកាសគ្រួសារ និងការថែទាំចំលាស់**<br>១-កុមារដែលរងគ្រោះពីការរំលោភបំពាន ពុំទាន់ទទួលបាននូវការស្តារនីតិសម្បទាសមស្របទេ<br>២-ឱពុកម្តាយខ្លះពុំទាន់បានបំពេញតួនាទី ភារកិច្ច និងការទទួលខុសត្រូវជាអាណាព្យាបាលល្អនៅ ឡើយទេ | ► បង្កើតមជ្ឈមណ្ឌលស្តារនីតិសម្បទាឱ្យបានច្រើន និងមានគុណភាពសំរាប់កុមារជាជនល្មើស និងកុមារជាជនរងគ្រោះ<br>► បង្កើនការអប់រំដល់សហគមន៍ គ្រួសារ សាលារៀន ពីច្បាប់ ភាតព្វកិច្ចរបស់ឱពុកម្តាយ ឬអាណាព្យាបាល ក្នុងការបីបាច់ថែរក្សាកូន តាមរយៈប្រព័ន្ធផ្សព្វផ្សាយ... |
| **IV. សុខភាពមូលដ្ឋាន និងសុខុមាលភាព**<br>១-បញ្ហាអនក្ខរកម្ម ផ្គត់ផ្គង់ទឹកស្អាត និងអសន្តិសុខស្បៀង<br>២-សេវាសុខាភិបាលតាមមូលដ្ឋាននូវមានកំរិត និងពុំមានយន្តការត្រួតពិនិត្យសេវាសុខភាពឯកជន<br>៣-ការយល់ដឹងនៃជំងឺអេដស៍ ពុំទាន់បានទូលំទូលាយ | ► ផ្តល់ការអប់រំទាំងក្នុង និងក្រៅប្រព័ន្ធដល់ប្រជាពលរដ្ឋរស់តាមតំបន់ដាច់ស្រយាល<br>► ធានាការផ្គត់ផ្គង់ទឹកស្អាត ប្រព័ន្ធធារាសាស្ត្រ និងផ្តល់សេវាសុខភាពបឋមដល់តំបន់ដាច់ស្រយាល<br>► ផ្តល់ការអប់រំ និងព្យាបាលអ្នកកើតជំងឺអេដស៍ និងលុបបំបាត់អំពើពេស្យាចារកុមារ |

| | |
|---|---|
| V. ការអប់រំការលំហែរ និងសកម្មភាពវប្បធម៌<br>១-ការសិក្សានៅបឋមសិក្សា ពុំទាន់បានទៅដល់កុមារគ្រប់រូបនៅឡើយទេ<br>២-អត្រាបោះបង់ការសិក្សាខ្ពស់ និងឱកាសចូលសាលារៀនចំពោះកុមារក្រីក្រ ជនជាតិភាគតិច និងកុមារនៅតំបន់ដាច់ស្រយាលទាប<br>៣-ពុំទាន់មានការត្រួតពិនិត្យតឹងរឹងនូវការហូរចូលវប្បធម៌មិនសមរម្យ និងល្បែងនានាដែលកុមារអាចទទួលយកបាន<br>៤-ថវិការជាតិសំរាប់វិស័យអប់រំនៅទាប | ► ចាត់វិធានការតឹងរឹងដល់ឪពុកម្តាយឱ្យបញ្ជូនកូនដែលគ្រប់អាយុចូលរៀន<br>► គួរតែជំរុញការសិក្សាអប់រំនៅបឋមសិក្សាដោយដាក់ជាកាតព្វកិច្ច និងដោយឥតបង់ថ្លៃ<br>► បន្តកម្មវិធីអប់រំក្រៅប្រព័ន្ធសំរាប់កុមារដែលពុំបានចូលរៀន ឬកុមារបោះបង់ការសិក្សា<br>► ចាត់វិធានការតឹងរឹងដើម្បីត្រួតពិនិត្យ និងលុបបំបាត់ចោលរាល់ការហូរចូលនូវវប្បធម៌មិនសមរម្យ និងអំពើពាលានានាសំរាប់កុមារ<br>► ផ្តល់នូវអាគារសិក្សាឧបករណ៍ សំភារៈគ្រូ និងថវិកា |
| VI. វិធានការការពារពិសេស<br>១-កង្វះខាតច្បាប់និងការអនុវត្តច្បាប់មិនទាន់មានប្រសិទ្ធិ ភាព<br>២-សេវាសង្គមសំរាប់ស្តារនីតិសម្បទាសំរាប់កុមាររងគ្រោះពីការកេងប្រវ័ញ្ចផ្លូវភេទពុំទាន់សមស្រប<br>៣-រឿងក្តីរបស់កុមារពុំត្រូវបានដោះស្រាយឱ្យបានទាន់ពេលវេលា ជនល្មើសតែងតែគេចផុតពីការផ្តន្ទាទោស | ► បង្កើតឱ្យមានច្បាប់ដាច់ដោយឡែកសំរាប់កុមារ<br>► ចេញអនុក្រឹត្យ និងលិខិតបទដ្ឋាននានាដើម្បីអនុវត្តច្បាប់ជាធរមានឱ្យមានប្រសិទ្ធភាព<br>► អប់រំផ្សព្វផ្សាយច្បាប់ និងអ.ស.កដល់មន្ត្រីអនុវត្តច្បាប់និងជំរុញឱ្យមានការអនុវត្តច្បាប់ ឱ្យមានប្រសិទ្ធភាពនិងបំបាត់អំពើពុករលួយ<br>► ត្រូវបង្កើតមណ្ឌលស្តារនីតិសម្បទាដល់កុមារជាជនរងគ្រោះ<br>► បង្កើតកន្លែងសំរាប់ទទួលពាក្យបណ្តឹងកុមារ ដោះស្រាយបណ្តឹងកុមារឱ្យបានសមស្រប និងមិនទាន់ពេលវេលានិងមានកន្លែងឃុំកុមារដាច់ដោយឡែក |

ដើម្បីធ្វើឱ្យសំរេចនូវអនុសាសន៍ខាងលើ អង្គការក្រៅរដ្ឋាភិបាលអាចចូលរួមចំណែកជួយរដ្ឋាភិបាលនូវការងារមួយចំនួនដូចជា :

- អប់រំ និងផ្សព្វផ្សាយពីច្បាប់ជាតិ អន្តរជាតិ ដែលទាក់ទងទៅនឹងអនុសញ្ញាស្តីពីសិទ្ធិកុមារឱ្យបានទូលំទូលាយ
- ផ្តល់នូវធនធានមនុស្ស និងបច្ចេកទេសនានាក្នុងការចូលរួមធ្វើសេចក្តីព្រាងច្បាប់ដែលពាក់ព័ន្ធនិងកុមារ
- ចុះតាមដាន និងប្រមូលរាល់ទិន្នន័យដែលទាក់ទងទៅនឹងស្ថានភាពកុមារ និងការអនុវត្តអ.ស.ក
- រួមចំណែកក្នុងការផ្សព្វផ្សាយ ដើម្បីលើកកំពស់ការយល់ដឹងពីសារៈសំខាន់នៃការចុះបញ្ជីជាតិ
- ជួយផ្តល់សេវាផ្នែកច្បាប់ដល់កុមារដែលមានទំនាស់នឹងច្បាប់ និងកុមារដែលជាជនរងគ្រោះ
- សហការ និងជួយផ្តល់នូវសំភារៈ និងការបណ្តុះបណ្តាលវិជ្ជាជីវៈសំរាប់មជ្ឈមណ្ឌលស្តារនីតិសម្បទា
- សហការជាមួយក្រសួងអប់រំ ក្នុងការបង្កើតសាលារៀនក្រៅប្រព័ន្ធដល់កុមារក្រីក្រ និងកុមារនៅតំបន់ដាច់ស្រយោល
- ចុះផ្សព្វផ្សាយដល់សហគមន៍ពីសារៈសំខាន់ក្នុងការសិក្សារៀនសូត្រ និងការពារជំងឺអេដស៍
- ចូលរួមចំណែកអនុវត្តកម្មវិធីនានាដើម្បីការអភិវឌ្ឍកុមារ

រៀបចំដោយ គណៈកម្មាធិការអង្គការក្រៅរដ្ឋាភិបាលដើម្បីសិទ្ធិកុមារ

~~~~~~~~~~~~~~~
~~~~~~~~~~~~~~~

## ក្រុមពិភាក្សា ១

**ប្រធានបទពិភាក្សា :**

ការពង្រឹងតួនាទី ក.ជ.ក.ក និង Ombudsmen ការប្រមូលទិន្ន័យ ការត្រួតពិនិត្យ តាមដានពីថ្នាក់កណ្ដាលដល់ខេត្ត និង មូលដ្ឋាន ។

**លទ្ធផលនៃកិច្ចពិភាក្សា :**

១. - ការងារសហការសំរបសំរួល ពង្រឹងតួនាទី ក.ជក.ក ការប្រមូលទិន្ន័យ ថវិការ និងបណ្ដុះបណ្ដាល

- សំណូមពរពិនិត្យ និងកែសំរួលអនុក្រឹត្យស្ដីអំពីការបង្កើត ក.ជ.ក.ក ឡើងវិញ ដោយកំណត់ឱ្យបានច្បាស់នូវ ឋានានុក្រម រចនាសម្ព័ន្ធ តួនាទី ក្របខ័ណ្ឌ និងឱ្យមានធនធានមនុស្សគ្រប់គ្រាន់ និងមានថវិការដោយឡែក សមស្របដើម្បីឱ្យក.ជ.ក.កអាចអនុវត្តភារកិច្ចដ៏ធ្ងន់ធ្ងររបស់ខ្លួនបាន និងអាចធ្វើការសំរបសំរួល និងត្រួតពិនិត្យ តាមដានពីថ្នាក់កណ្ដាលដល់មូលដ្ឋាន ។
- ស្នើឱ្យក្រសួងពាក់ព័ន្ធយកចិត្តទុកដាក់បន្ថែមទៀតពីសមាសភាពដែលត្រូវចាត់តាំងជាសមាជិក ក.ជ.ក.ក គួរជា ថ្នាក់ដែលអាចសំរេចកិច្ចការ ជៀសវាងជាអ្នកនាំពាក្យ ឬអវត្តមានច្រើន។
- ចំពោះការបណ្ដុះបណ្ដាលធនធានមនុស្ស ស្នើសូមឱ្យមានផែនការយូរអង្វែង។ សូមឱ្យមានការបណ្ដុះបណ្ដាល សិទ្ធិកុមារឱ្យបានទូលំទូលាយ ។
- ស្នើឱ្យមានរៀបចំជាសំនួរដល់ថ្នាក់ខេត្ត-ស្រុក មានការប្រជុំទៀងទាត់ជាមួយសមាជិក ក.ជ.ក.ក ជាមួយ អង្គការក្រៅរដ្ឋាភិបាល ដើម្បីប្រមូលពត៌មានអំពីកុមារ និងដោះស្រាយបញ្ហា។

២. - Ombudsperson

- ស្នើឱ្យមានសិទ្ធិកុមារនៅព្រឹទ្ធសភា រដ្ឋសភា និងគណៈរដ្ឋមន្ត្រី

## ក្រុមពិភាក្សាទី២

**ប្រធានបទពិភាក្សា :**

ការពិនិត្យច្បាប់ឡើងវិញ និយមន័យកុមារ ការរើសអើង ការចុះបញ្ជីជាតិកុមារ ការចូលរួមមតិ និងទទួលពត៌មាន កុមារជនភៀសខ្លួន ស្មុំកូន ការជួញដូរផ្លូវភេទលើកុមារ ។

**លទ្ធផលនៃការសិក្សា :**

១. - ការពិនិត្យច្បាប់ឡើងវិញ និងការចុះបញ្ជីជាតិ

- ស្នើសូមឱ្យ ក.ជ.ក.ក ពង្រឹងអនុគណៈកម្មការតាក់តែងច្បាប់របស់ខ្លួនឱ្យបានខ្លាំង និងជាអ្នកដឹកនាំ និងលើក សំណើសំរាប់រៀបចំប្រព័ន្ធយុត្តិធមិយុវវ័យ ។
- កម្ពុជាត្រូវដាក់បញ្ហារបស់កុមារចូលក្នុងក្រមព្រហ្មទ័ណ្ឌ និងរដ្ឋប្បវេណីករណីណាដែលគ្មានក្នុងច្បាប់ខាងលើ ត្រូវធ្វើច្បាប់ពិសេស ។
- ត្រូវបណ្ដុះបណ្ដាលសិទ្ធិកុមារដល់អ្នកអនុវត្តច្បាប់ តាមក្រសួងស្ថាប័ន អ្នកធ្វើច្បាប់ និងសាលារៀន។
- ស្នើចាត់ទុកបញ្ហាចុះបញ្ជីជាតិជាអាទិភាព
- សូមបង្កើតប្រព័ន្ធយុត្តិធមិសំរាប់កុមារ

- ច្បាប់បទដ្ឋាន អនុក្រិត្យ ឬព្រះរាជក្រមមានរួចមកហើយ ប៉ុន្តែការផ្សព្វផ្សាយពុំទាន់បានទូលំទូលាយ ។

## ក្រុមពិភាក្សាទី៣

**ប្រធានបទពិភាក្សា :**

កាតព្វកិច្ចរបស់គ្រួសារ ការថែទាំដោយអាណាព្យាបាល ការត្រួតពិនិត្យតាមដាន ការការពារកុមារពីការរំលោភ និងអំពើឃោរឃៅបញ្ហាកុមារពិការ ។

**លទ្ធផលនៃការពិភាក្សា :**

១. - ច្បាប់ ការងារ គ្រួសារ និងការថែទាំ

- ស្នើឱ្យមានច្បាប់សម្រាប់គ្រួសារ ថែរក្សាដោយអាណាព្យាបាល ស្ថាប័នពាក់ព័ន្ធ និងអង្គការនានា
  - ចូលរួមសរសេរច្បាប់ ពង្រាងច្បាប់ ដោយក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា យុត្តិធម៌ មហាផ្ទៃ កិច្ចការនារី និងអតីតយុទ្ធជន អង្គការរដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាល ។
- សិក្សានូវការខ្វះខាតទៅលើច្បាប់ដែលឆ្លុះបញ្ចាំងទៅលើអនុសញ្ញាសិទ្ធិកុមារ ។

២. - ការងារសុំកូនចិញ្ចឹម

- អ្នកទទួលខុសត្រូវ និងអ្នកសុំកូនក្នុងស្រុកមិនគោរពកិច្ចសន្យា និងមិនគោរពតាមច្បាប់ត្រូវទទួលខុសត្រូវជាធរមាន ។
- ជំរុញច្បាប់ដែលមានហើយឱ្យចូលជាធរមានឱ្យបានឆាប់ តាមដានការសុំកូនថ្នាក់ជាតិ និងអន្តរជាតិ ។
- មានកិច្ចសន្យាច្បាស់លាស់ និងកិច្ចព្រមព្រៀងពីប្រទេសនិងប្រទេស ចំពោះអ្នកសុំកូនចិញ្ចឹមទាំងក្នុងប្រទេស និងក្រៅប្រទេស ។
- ក្នុងច្បាប់ត្រូវកំណត់អាយុ សុខភាព ប្រវត្តិរូបផ្ទាល់ខ្លួន កំណត់ផ្តល់មរតកឱ្យបានច្បាស់លាស់ និងអនុវត្តឱ្យបានត្រឹមត្រូវ ។
- បង្កើនសមត្ថភាពមន្ត្រី ក.ជ.ក.ក ថវិកាសំភារៈគ្រប់គ្រាន់សម្រាប់ការអនុវត្ត ។

៣. - ការការពារ និងការត្រួតពិនិត្យតាមដាន

- បង្កើត និងពង្រឹងប្រព័ន្ធប្រមូលទិន្នន័យឱ្យបានច្បាស់លាស់ និងវាយតម្លៃលើការអនុវត្តការងារតាមរយៈការប្រជុំសិក្ខាសាលា និងពង្រឹងកិច្ចសហការជាមួយអង្គការជាតិ អន្តរជាតិ និងស្ថាប័នពាក់ព័ន្ធ ។
- កុមារជាជនជាតិអ្វីក៏ដោយដែលប្រព្រឹត្តិល្មើសច្បាប់ ត្រូវទទួលទោសតាមច្បាប់ក្នុងស្រុក និងផ្តន្ទាទោស ចំពោះជនប្រព្រឹត្តិបទល្មើសលើកុមារ ។
- សូមឱ្យផ្សព្វផ្សាយសិទ្ធិកុមារឱ្យបានទូលំទូលាយ មានប្រសិទ្ធភាព មានតុលាការកុមារ និងមានការអនុវត្តច្បាប់ឱ្យបានត្រឹមត្រូវ ។
- ពង្រីក និងពង្រឹងសេវាសង្គម ដើម្បីទប់ស្កាត់កុមារពិការ និងកុមារងាយរងគ្រោះ ។
- សហការជាមួយអង្គការក្រៅរដ្ឋាភិបាល ជាតិ និងអន្តរជាតិ ដែលមានការគាំទ្រលើផ្នែកបច្ចេកទេស និងថវិកា (ជាពិសេសការបង្កើនថវិកាគាំទ្រដល់ទារកដ្ឋានតាមតម្រូវការជាក់ស្តែង) ។

- សុំឱ្យរដ្ឋាភិបាលប្រគល់សិទ្ធិឯករាជ្យដល់ ក.ជ.ក.ក ក្នុងការត្រួតពិនិត្យតាមដាន ហើយក្រសួងស្ថាប័ន ពាក់ព័ន្ធ សូមធ្វើរបាយការណ៍ឱ្យបានទៀងទាត់។ សុំ ក.ជ.ក.ក ចុះពិនិត្យផ្ទាល់ហើយអនុវត្តទៅតាមនីតិវិធីដែលមាន ប្រសិទ្ធភាព ។

## ក្រុមពិភាក្សា ៤

**ប្រធានបទពិភាក្សា :**

ការទទួលបានសេវាសុខាភិបាលដោយគ្មានការរើសអើង ជាពិសេសកុមារងាយរងគ្រោះ ថវិកា ការបណ្តុះបណ្តាលសិទ្ធិ កុមារដល់មន្ត្រីសុខាភិបាល ការបង្កើនការរស់រានរបស់កុមារ សុខភាព កុមារវ័យជំទង់ វិធានការដើម្បីបង្កើន ប្រសិទ្ធភាព

**លទ្ធផលនៃកិច្ចពិភាក្សា :**

១. - ការទទួលបានសេវាសុខាភិបាល ថវិកា បណ្តុះបណ្តាល

- ពង្រឹង និងពង្រីក មន្ទីរពេទ្យសុខភាព មានការលើកលែងការបង់ថ្លៃសេវាចំពោះកុមារក្រីក្រ ។
- ត្រូវតែបណ្តុះបណ្តាលសិទ្ធិកុមារដល់មន្ត្រីសុខាភិបាល និងត្រូវមានមនសិការវិជ្ជាជីវៈ

២. - ការព្យាបាល និងពង្រីកកម្មវិធីអប់រំ

- អប់រំសុខភាព និងអនាម័យឱ្យបានទូលំទូលាយគ្រប់លំដាប់ថ្នាក់
- បង្កើនការព្យាបាលឱ្យមានប្រសិទ្ធភាពនូវជម្ងឺកុមារ(ជម្ងឺរាគ និងជម្ងឺសួត) និងមានគម្រោងកម្មវិធីបង្កា ទប់ស្កាត់ចំលងមេរោគអេដស៍ពីម្តាយទៅទារក PMTCT ហើយជំរុញការអនុវត្ត PMTCT ។
- ការថែទាំសុខភាពនៅពេលមានគិក ពិនិត្យផ្ទៃពោះយ៉ាងតិចឱ្យបាន៣ដង ការចាក់ថ្នាំបង្កាជម្ងឺ៦មុខ និងផ្តល់ អាហារូបត្ថម្ភ ។
- ពង្រីកកម្មវិធីអប់រំសុខភាពបន្តពូជទាំងក្នុង និងក្រៅប្រព័ន្ធ និងបង្ហាញភាពជាក់ស្តែងអំពីជម្ងឺអេដស៍ ក្នុងគោល បំណងផ្លាស់ប្តូរការប្រព្រឹត្តិ និងចូលរួមសហការរវាងស្ថាប័នពាក់ព័ន្ធ ។

## ក្រុមពិភាក្សា ៥

**ប្រធានបទពិភាក្សា :**

ការត្រួតពិនិត្យតាមដាន និងប្រមូលទិន្នន័យថវិកា បណ្តុះបណ្តាលសិទ្ធិកុមារដល់គ្រូបង្រៀន កុមារបានចូលរៀន គុណភាពនៃការអប់រំ ការសិក្សារបស់កុមារី និងកុមារងាយរងគ្រោះ កិច្ចការពារកុមារក្នុងក្របខ័ណ្ឌប្រព័ន្ធអប់រំ ជាពិសេសការធ្វើទារុណកម្មលើរាងកាយកុមារ ។

**លទ្ធផលនៃកិច្ចពិភាក្សា :**

១. - បង្កើនការតាមដានត្រួតពិនិត្យ និងពង្រឹងថ្នាក់អប់រំក្រៅប្រព័ន្ធ

- ត្រូវបង្កើនការតាមដានត្រួតពិនិត្យ ការអនុវត្តសិទ្ធិកុមារតាមសាលារៀន និង ប្រមូលទិន្នន័យឱ្យបាន ជាក់លាក់ និងពង្រឹងថ្នាក់អប់រំក្រៅប្រព័ន្ធដល់កុមារដែលពុំបានចូលរៀន
- ត្រូវបង្កើនអំពីក្រុមការងារកុមារដែលមិនបានចូលរៀន និងបំពាក់បំប៉នកុមារខ្សោយឱ្យរៀនក្រៅម៉ោង
- ត្រូវសហការ និងសម្របសម្រួលជាមួយជំនួយខាងក្រៅ P.A.P

- ពង្រឹង ពង្រីក បង្កើនស្ថាប័នអប់រំសម្រាប់ទាំងអស់គ្នា ដោយមិនយកវិភាគទានពីមាតាបិតា និងអប់រំក្រៅប្រព័ន្ធដល់កុមារដែលបានចូលរៀន ។

## ក្រុមពិភាក្សា ៦

**ប្រធានបទពិភាក្សា :**

ពិភាក្សាអំពីការប្រមូលទិន្នន័យលើការចាប់ពង្រាត់ និងពេស្យាចារលើកុមារ សម្រាប់ប្រយុទ្ធប្រឆាំងការអនុវត្ត និងការងារសម្របសម្រួលផែនការជាតិ ៥ឆ្នាំ ការប្រឆាំងពលកម្មកុមារ ការពារកុមារពីភាពពាលាអាវ៉ាសែលើកុមារ ។

**លទ្ធផលនៃកិច្ចពិភាក្សា :**

១. - ការប្រមូលទិន្នន័យលើការចាប់ពង្រាត់ ពេស្យចារកុមារ និងថវិកា

- សូមឱ្យមានប្រព័ន្ធកុំព្យូទ័រ HOT LINE រក្សាទិន្នន័យ ប្រគល់ភារកិច្ចនេះឱ្យ ក.ជ.ក.ក ជាអ្នកគ្រប់គ្រងដោយសហការជាមួយក្រសួង NBO, IO និងក្រសួងពត៌មាន ។
- ថវិកាសម្រាប់ប្រយុទ្ធប្រឆាំងការចាប់ពង្រាត់ពេស្យាចារលើកុមារ ក.ជ.ក.ក ជាអ្នកស្វែងរកជំនួយពីអង្គការជាតិ អន្តរជាតិ អង្គការមនុស្សធម៌ផ្សេងៗ និងជាអ្នកលើកគម្រោងទៅក្រសួង ស.ក.ប.យ ដើម្បីពិចារណា និងដាក់ជូនទៅរាជរដ្ឋាភិបាល ។
- ពង្រឹងស្ថាប័ន ក.ជ.ក.ក ឱ្យមានតម្លាភាព (ឱ្យមានសកម្មភាព) និងមានធនធានមនុស្សសមស្របទៅតាមការងារ ។
- សុំឱ្យ ក.ជ.ក.ក ស្ថិតនៅក្រោមគណៈរដ្ឋមន្ត្រី
- សុំជំរុញឱ្យការអនុវត្តសេចក្តីប្រកាសលេខ០១ ចុះថ្ងៃទី៦ ខែមេសា ឆ្នាំ២០០០ ឱ្យមានប្រសិទ្ធភាពផ្សព្វផ្សាយឱ្យទូលំទូលាយផែនការជាតិ៥ឆ្នាំ ដល់គ្រប់ស្ថាប័ន និងសហគមន៍

២. - ការប្រយុទ្ធប្រឆាំងពលកម្មកុមារ និងការពារកុមារកុំឱ្យធ្លាក់ក្នុងភាពពាលាអាវ៉ាសែ

- សូមឱ្យសមាជិកម្នាក់ចេញពីផ្នែកពលកម្មកុមារបានចូលរួមជាសមាជិកក្រុមការងារ គ្រប់ស្ថាប័នទាំងអស់ចាប់អារម្មណ៍អំពីពលកម្មកុមារ ។
- រាជរដ្ឋាភិបាលចាប់អារម្មណ៍លើប្រាក់បៀវត្សរ៍ចំពោះលោកគ្រូ និងអ្នកគ្រូ យកចិត្តទុកដាក់លើកកំពស់គុណភាពអប់រំដល់កុមារ ដើម្បីការពារកុំឱ្យកុមារធ្លាក់ក្នុងអំពើពាលាអាវ៉ាសែ ។
- បង្កើនទំនាក់ទំនងអាណាព្យាបាល និងសាលា ដើម្បីពង្រឹងការអប់រំឱ្យបានខ្លាំងក្លា និងលុបបំបាត់ក្រុមបងធំតាមសាលារៀន ។
- ហាមឃាត់ល្បែងហ្គេម ដែលមានបង្កើតនៅក្បែរសាសារៀន អជ្ញាធរមូលដ្ឋានត្រូវចាប់អារម្មណ៍ឱ្យបានតឹងរឹងបំផុត ។
- ស្នើឱ្យមានមជ្ឈមណ្ឌលយុវនីតិសម្បទាបន្ថែមទៀត ជាពិសេសសូមឱ្យដាក់កុមារ ដែលមានទោសព្រហ្មទ័ណ្ឌដោយឡែកពីមនុស្សចាស់ ។

## ក្រុមពិភាក្សា ៧

**ប្រធានបទពិភាក្សា :**

ពិភាក្សាអំពីថវិកា ដើម្បីជំរុញកម្មវិធីផ្សព្វផ្សាយសម្រាប់កុមារ និងធ្វើឱ្យកុមារមានតួនាទី ទទួលនូវពត៌មានក្នុងការផ្សព្វផ្សាយសិទ្ធិកុមារជាទូទៅ ជាពិសេសគោលការណ៍ទាំងបួន ការជំរុញដល់កុមារជនជាតិ ។

**លទ្ធផលនៃកិច្ចពិភាក្សា :**

១. - ប្រព័ន្ធផ្សព្វផ្សាយស្តីពីសិទ្ធិកុមារ

- សូមឱ្យផ្សព្វផ្សាយសិទ្ធិកុមារឱ្យបានទូលំទូលាយដោយមិនយកកំរៃ
- សូមឱ្យរាជរដ្ឋាភិបាលបន្ថែមថវិកាសំរាប់កម្មវិធីផ្សព្វផ្សាយសិទ្ធិកុមារ គ្រប់ស្ថានីយ៍ទូរទស្សន៍ កាសែត វិទ្យុ ទស្សនាវដ្តីទាំងអស់បរិចាកម៉ោងដោយឥតគិតថ្លៃ។

២. - កុមារជនជាតិភាគតិច

- សូមឱ្យរាជរដ្ឋាភិបាលយកចិត្តទុកដាក់ចំពោះកុមារអនាថា កុមារជនជាតិភាគតិច និងមានកម្មវិធីផ្សព្វផ្សាយតាមទូរទស្សន៍ដែលទាក់ទងទៅនឹងសិទ្ធិកុមារ ជាពិសេសកុមារជនជាតិបានចូលរួម។

៣. - ការចូលរួមរបស់កុមារក្នុងសង្គម

- សូមឱ្យការចូលរួមរបស់កុមារក្នុងសកម្មភាពសង្គមឱ្យបានខ្លាំង និងឱ្យកុមារមានឱកាសបញ្ចេញមតិដើម្បីលើកកំពស់ការយល់ដឹងអំពីសិទ្ធិកុមារ ។
- ប្រព័ន្ធផ្សព្វផ្សាយសិទ្ធិកុមារឱ្យមានតាមរយៈគ្រូបង្រៀន និងព្រះសង្ឃ និងគ្រប់មជ្ឈដ្ឋានផ្សេងៗ ត្រូវយកចិត្តទុកដាក់អំពីអនុសញ្ញា ។
- លុបបំបាត់អាសអាភាសតាមរយៈកាសែត និងទស្សនាវដ្តីជាដើម ។

~~~~~~~~~~~~~~~~
~~~~~~~~~~~~~~~~

**ឧបសម្ព័ន្ធ៧**

# មន្ត្រីតំណាងក្រសួងនីមួយៗបានពិភាក្សាលើកម្មវិធី និងសកម្មភាព របស់ក្រសួងសំរាប់អនុវត្តក្នុងឆ្នាំ២០០១ ដែលទទួលបានលទ្ធផលដូចតទៅ

- **ក.ជ.ក.ក**

ធ្វើការពិនិត្យ និងតាក់តែងច្បាប់ពាក់ព័ន្ធនឹងកុមារ ជំរុញការអនុវត្តអនុគណ:កម្មការប្រឆាំងការជួញដូរ និង កេងប្រវ័ញ្ចផ្លូវភេទលើកុមារ ពិនិត្យ និងរៀបចំអនុក្រឹត្យឡើងវិញ ។

- **ក្រសួងយុត្តិធម៌**

សហការជាមួយ ក.ជ.ក.ក ក្នុងការងារពិនិត្យ និងតាក់តែងច្បាប់ដែលពាក់ព័ន្ធនឹងកុមារ

- **ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

⊕ កម្មវិធីការពារ និងទប់ស្កាត់ការជួញដូរ ពលកម្មកុមារ

⊕ កម្មវិធីស្តារ និងទប់ស្កាត់កុមារប្រើប្រាស់បំពានសារធាតុញៀន

⊕ កម្មវិធីទប់ស្កាត់បាតុភាពខុសឆ្គងរបស់កុមារ

⊕ កម្មវិធីតាមដាន ការធ្វើសមាហរណកម្មកុមារនៅតាមសហគមន៍

⊕ កម្មវិធីបន្តរៀបចំច្បាប់ស្តុំកូនចិញ្ចឹម

- **ក្រសួងមហាផ្ទៃ**

ក- ការងារអត្រានុកូលដ្ឋាន

ចុងឆ្នាំ២០០០នេះ ក្រសួងមហាផ្ទៃបានចេញសារាចរមួយ ដើម្បីណែនាំទៅបណ្តាខេត្ត-ក្រុង ស្តីពីការពង្រឹងអនុក្រឹត្យលេខ ០១៨ របស់រាជរដ្ឋាភិបាលស្តីពីអត្រានុកូលដ្ឋាននេះ ។ ក្នុងឆ្នាំ២០០១ នឹងផ្សព្វផ្សាយទូលំទូលាយ និងអនុវត្តផ្ទាល់ ។

ខ- ដើម្បីកិច្ចការងារការពារខាងផ្លូវច្បាប់ ប្រឆាំងនឹងអាជីវកម្មផ្លូវភេទលើកុមារ ក្រសួងមហាផ្ទៃអនុវត្តផែនការជាតិ៥ឆ្នាំ របស់រាជរដ្ឋាភិបាល ស្តីពីការប្រឆាំងការជួញដូរ និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារ និងបន្តការបើកវគ្គបណ្តុះបណ្តាលដល់មន្ត្រីនគរបាលយុត្តិធម៌ ក្នុងការប្រឆាំងអំពើខាងលើចំនួន១៣ខេត្ត ក្រុង និងបង្កើតឡើងនូវយន្តការមួយទប់ស្កាត់ និងប្រឆាំងអាជីវកម្មផ្លូវភេទលើកុមារ ដោយរួមសហការជាមួយអាជ្ញាធរដែនដី ស្ថាប័នតុលាការ ។

ផ្សព្វផ្សាយទូលំទូលាយដល់ខ័ណ្ឌ ឃុំ ស្រុក ដើម្បីស្វែងយល់អំពីការប្រឆាំងនឹងអាជីវកម្មផ្លូវភេទលើកុមារ ។

- **ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ**

ប្រឆាំងការជួញដូរកុមារឆ្លងដែន ដោយសហការជាមួយបណ្តាប្រទេសនានាក្នុងតំបន់ និងពិភពលោក និងរៀបចំបែបបទឱ្យកុមាររងគ្រោះទាំងនោះត្រឡប់មកស្រុកកំណើតវិញ តាមរយៈទំនាក់ទំនងការទូត ។

- **ក្រសួងទេសចរណ៍**

នៅក្នុងឆ្នាំ២០០១នេះ ក្រសួងទេសចរណ៍សូមលើកឡើងនូវសកម្មភាពការងាររបស់ខ្លួន ដើម្បីចូលរួមក្នុងការទប់ស្កាត់ និងបង្កាការជួញដូរ និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារដូចតទៅ :

- នៅដើមឆ្នាំ២០០១នេះ ក្រសួងទេសចរណ៍បានសហការជាមួយអង្គការទស្សនៈពិភពលោក-កម្ពុជា រៀបចំគំរោងផែនការ ការងារបណ្តុះបណ្តាលវិស័យឧស្សាហកម្មទេសចរណ៍ដូចជា :
  - ⊕ ទីភ្នាក់ងារទេសចរណ៍២០៤
  - ⊕ សណ្ឋាគារចំនួន២៤១ក្នុងតំបន់ភ្នំពេញ សៀមរាប និងក្រុងព្រះសីហនុ
  - ⊕ មធ្យោបាយដឹកជញ្ជូនផ្លូវទឹកភ្នំពេញ សៀមរាបចំនួន២៨ និងនាវាដឹកជញ្ជូនកំសាន្តនៅភ្នំពេញ និងសៀមរាបចំនួន៩១។
  - ⊕ មធ្យោបាយដឹកជញ្ជូនផ្លូវគោក រថយន្តតាក់ស៊ី៣៨៤ និងរថយន្តបឺសចំនួន១៩៤
  - ⊕ មគ្គុទេសក៍ ទេសចណើនៅភ្នំពេញចំនួន១១១នាក់ និងនៅសៀមរាបចំនួន៤១៤នាក់។

គំរោងផែនការបណ្តុះបណ្តាលមានបំណងលើកកំពស់ការយល់ដឹងអំពីកុមារ ក្នុងវិស័យទេសចរណ៍សំដៅកាត់បន្ថយការជួញដូរ និងកេងប្រវ័ញ្ចផ្លូវភេទលើកុមារក្នុងវិស័យទេសចរណ៍ និងការផ្សព្វផ្សាយច្បាប់ផ្តន្ទាទោសយ៉ាងទំងន់ដល់អំពើទេសចរណ៍ផ្លូវភេទ។ បើសិនជាគំរោងកម្មវិធីនេះត្រូវបានការឧបត្ថម្ភជាថវិកា សំភារៈបច្ចេកទេសពីអង្គការ អន្តរជាតិនានា។ ទន្ទឹមនឹងនេះ ក្រសួងទេសចរណ៍ ខិតខំស្វែងរកការឧបត្ថម្ភដើម្បីធ្វើការបោះពុម្ពឯកសារផ្សព្វផ្សាយអំពីការប្រឆាំងនឹងការជួញដូរផ្លូវភេទលើកុមារក្នុងវិស័យទេសចរណ៍ ។

- **ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន**
  - ការពារផ្លូវច្បាប់ និងការអប់រំ (សិទ្ធិកុមារ អប់រំក្រៅប្រព័ន្ធ )១៧ខេត្ត-ក្រុង។ ខេត្តព្រៃវែង ស្វាយរៀង កំពង់ស្ពឺ កំពង់ធំ ឧត្តមានជ័យ ស្ទឹងត្រែង ។ល។
  - ច្បាប់អាពាហ៍ពិពាហ៍ (អំពីរឿងចែកកូន និងអាហារកិច្ច)
  - ពង្រាងច្បាប់ស្តីពីការលុបបំបាត់អំពើហឹង្សាក្នុង គ្រួសារ (ស្ត្រី និងកុមារ)
  - គោលនយោបាយពីការគ្រប់គ្រងពេស្យាចារ (បននៅភ្នំពេញ)
  - លុបបំបាត់ការជួញដូរស្ត្រី និងកុមារ (រយៈពេល ៣ឆ្នាំ)៩០០ភូមិ ក្នុងខេត្ត ក្រុង។ ខេត្តស្វាយរៀង បន្ទាយមានជ័យ កោះកុង ក្រុងប៉ៃលិន ក្រុងភ្នំពេញ ។
    - ⊕ ពង្រឹងសមត្ថភាព
    - ⊕ ការផ្សព្វផ្សាយចល័ត
  - វិស័យសុខភាព
    - ⊕ ការពន្យាកំណើតនៅតាមសហគមន៍
    - ⊕ គាំពារមាតា និងទារក
    - ⊕ ផែនការនារីរតនៈ

~~~~~~~~~~~~
~~~~~~~~~~~~

**សុន្ទរកថាឯកឧត្តម សុខ អាន ទេសរដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**
**ថ្លែងក្នុងឱកាសបិទសិក្ខាសាលាជាតិ ស្តីពីការអនុវត្តរបស់រាជរដ្ឋាភិបាល**
**ចំពោះសេចក្តីសង្កេតចុងក្រោយរបស់គណៈកម្មាធិការសិទ្ធិកុមារនៃអ.ស.ប**
**២២-២៣ មករា ២០០១**

~~~~~~~~~

- **ឯកឧត្តម លោកជំទាវ ភ្ញៀវកិត្តិយសជាតិ អន្តរជាតិ**
- **ឯកឧត្តម លោកជំទាវ លោក លោកស្រី សមាជិក សមាជិការ អង្គសិក្ខាសាលា**

ជាបឋម ខ្ញុំសូមសំដែងនូវសេចក្តីស្វាគមន៍ និងគាំទ្រយ៉ាងពេញទំហឹង ចំពោះសិក្ខាសាលាជាតិ ដែលបានដំណើរការយ៉ាងសកម្ម និងស្វិតស្វាញអស់រយៈពេល២ថ្ងៃកន្លងទៅនេះ ទទួលបានលទ្ធផលប្រកបដោយផ្លែផ្កា។ របាយការណ៍របស់អង្គសិក្ខាសាលាបានបង្ហាញឱ្យឃើញពីកិច្ចសហការជិតស្និតរវាងក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ក្រសួងពាក់ព័ន្ធ អង្គការអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាលដែលរួមគ្នាយ៉ាងសស្រាក់សស្រាំពិភាក្សាប្តូរយោបល់ និងលើកឡើងនូវមត្តិល្អ១សំដៅអនុវត្តឱ្យបានលទ្ធផលខ្ពស់នូវអ្វីដែលជាផលប្រយោជន៍ល្អបំផុតសំរាប់កុមារកម្ពុជា ។

សេចក្តីសង្កេតចុងក្រោយរបស់គណៈកម្មាធិការសិទ្ធិកុមារ នៃអង្គការសហប្រជាជាតិ បានលើកឡើងនូវចំណុចខ្វះខាត និងចង្អុលបង្ហាញចំណុចដែលត្រូវរៀបចំបន្ថែមទៀត។ ឆ្លងតាមការពិភាក្សាអង្គសិក្ខាសាលាក៏បានរកឃើញនូវវិធីសាស្ត្រដែលត្រូវអនុវត្តដូចជាការធ្វើឱ្យការងារសំរបសំរួល ការត្រួតពិនិត្យតាមដាន លើការអនុវត្តអនុសញ្ញាសិទ្ធិកុមាររបស់ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ឱ្យមានខ្សែរយៈពីថ្នាក់កណ្តាលរហូតដល់ថ្នាក់មូលដ្ឋាន នឹងធ្វើការវាយតំលៃស្ថានភាពកុមារជូនរាជរដ្ឋាភិបាលឱ្យបានកាន់តែសុក្រឹត្យ ការធ្វើឱ្យកុមារទទួលបាននូវសុខុមាលភាព ដោយធ្វើឱ្យប្រសើរឡើងនូវសេវាសុខាភិបាល ទាំងនៅទីក្រុង និងតាមជនបទ ហើយឈានទៅកាន់បន្ថយអត្រាមរណៈរបស់កុមារតូច១ឱ្យកាន់តែតិចជាង១១៥ភាគពាន់។ ការថែទាំកុមារនៅតាមមជ្ឈមណ្ឌល ឬក្នុងគ្រួសារ ការប្រយុទ្ធប្រឆាំងនឹងអំពើជួញដូរកេងប្រវ័ញ្ចកុមារគ្រប់ប្រភេទ ក៏ដូចជាការអភិវឌ្ឍកុមារដោយធ្វើឱ្យគុណភាពបង្រៀន និងគុណភាពនៃការសិក្សាបានប្រសើរឡើងថែមទៀត ឈានទៅកាន់បន្ថយ បញ្ហាអសកម្មក្នុងវិស័យសិក្សាអប់រំ ។

ខ្ញុំបានដឹងថា ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារបានរៀបចំឱ្យមានអនុគណៈកម្មការតាក់តែងច្បាប់ដែលពាក់ព័ន្ធទៅនឹងកុមារ តែទន្ទឹមនឹងនេះ យើងក៏ត្រូវជំរុញឱ្យការអនុវត្តច្បាប់ឱ្យមានប្រសិទ្ធភាពខ្ពស់។ ប្រព័ន្ធផ្សព្វផ្សាយក៏ជាឧបករណ៍សំខាន់សំរាប់ការងារអប់រំ ការពិនិត្យឡើងវិញនូវខ្លឹមសារផ្សព្វផ្សាយ គឺជាការចាំបាច់បំផុត ដើម្បីបញ្ចៀសនូវឥទ្ធិពលមិនល្អដែលអាចជះលើកុមារ ហើយដើម្បីឱ្យកុមារទទួលបាននូវពត៌មានសមស្របទៅនឹងវ័យនៃការក្រេបជញ្ជក់ដើម្បីក្លាយខ្លួនទៅជាប្រជាពលរដ្ឋល្អប្រកបដោយសេចក្តីថ្លៃថ្នូរ។ មាតា បិតា ឬអាណាព្យាបាល និងសហគមន៍ក៏ជាកម្មវត្ថុទស្សនាការផ្សព្វផ្សាយដែរ ដែលយើងត្រូវធ្វើការអប់រំសិទ្ធិកុមារ ឱ្យពួកគេបានយល់ជ្រួតជ្រាប ។

គឺជាការពិតហើយថាបញ្ហាសេដ្ឋកិច្ច គឺជាកត្តាចម្បងក្នុងការសំរេចនូវគោលដៅនៃការអភិវឌ្ឍ ការអនុវត្តសិទ្ធិកុមារ យើងខ្វះខាតសាលារៀន យើងខ្វះខាតផ្លូវគមនាគមន៍ដែលត្រូវសំរួលដល់ការសិក្សារបស់កុមារ។ ជីវភាពក្រីក្ររបស់គ្រួសារ បានបង្ខំឱ្យឪពុកម្តាយដកកូនពីសាលារៀន មកជួយបន្ថែមពលកម្មក្នុងគ្រួសារ កុមារពិការលូតលាស់បានល្អដោយការខ្វះខាតចំណីអាហារ និងខ្វះខាតការថែទាំឱ្យបានដិតដល់ ។ល។ និង ។ល។ ប៉ុន្តែការប្តេជ្ញាចិត្តស្មារតីតស៊ូស្វិតស្វាញ និងមនោសញ្ចេតនាខ្ពស់ក្នុងការងារលើកស្ទួយសិទ្ធិកុមារ គឺជាកត្តាមួយដ៏សំខាន់ ។
~~~~~~~~~

ស្របគ្នានឹងពេលវេលានេះដែរ រាជរដ្ឋាភិបាលកម្ពុជាបាននឹងកំពុងប្រកាន់យកនូវការកែទម្រង់មួយដែលនឹងនាំមកនូវការស្តារ និងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសង្គមសេដ្ឋកិច្ច ដែលជាមាគ៌ាសម្រាប់ការរីកចំរើនលូតលាស់ប្រកបដោយនិរន្តភាពក្នុងរយៈពេល ១០ឆ្នាំខាងមុខនេះ។ រាជរដ្ឋាភិបាលកំពុងខិតខំប្រឹងប្រែងកាត់បន្ថយភាពក្រីក្រ តាមរយៈកម្មវិធីបង្កើនមុខរបរដល់ប្រជាជនតាមមូលដ្ឋាន ការកសាងផ្លូវគមនាគមន៍ ការកាត់ឡូតិ៍នៃសាទឱ្យទៅប្រជាជន និងបានបង្កើនថវិកាដល់វិស័យអប់រំ សង្គមកិច្ច សុខាភិបាលជាដើម ។

នៅពេលនេះ កម្ពុជាកំពុងបង្ហាញដល់សកលលោកនូវអ្វីដែលជាឆន្ទះប្តេជ្ញាអនុវត្តអនុសញ្ញាសិទ្ធិកុមារ។ ផលប្រយោជន៍ដ៏ល្អបំផុតសម្រាប់កុមារ ត្រូវបានយកមកពិចារណាមុនគេបំផុត ក្នុងការតស៊ូសេចក្តីសម្រេចទាំងឡាយនៃស្ថាប័នពាក់ព័ន្ធ ហើយក៏ត្រូវទទួលបាននូវអាទិភាព ដើម្បីកម្ពុជាឈានទៅការអភិវឌ្ឍមួយដែលមានកម្រិតដូចប្រទេសជិតខាងក្នុងតំបន់។ តាងនាមឱ្យរាជរដ្ឋាភិបាល និងខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមទទួលយកនូវគំនិតយោបល់ និងសំណូមពរទាំងអស់ ដែលអង្គសិក្ខាសាលាបានលើកឡើង ហើយសូមគាំទ្រទាំងស្រុងនូវការអនុវត្តកម្មវិធីតាមក្រសួង ស្ថាប័ននិមួយៗ។

កុមារជាទំពាំងស្នងឫស្សី ជាសសរទ្រូង និងជាកំលាំងដ៏រឹងមាំរបស់ប្រទេសជាតិ។ សុខុមាលភាពកុមារ កិច្ចការពារ និងអភិវឌ្ឍកុមារ គឺជាប្រធានបទដ៏សំខាន់ និងជាអាទិភាពក្នុងកម្មវិធីស្តារ និងអភិវឌ្ឍប្រទេស។

ជាអវសាន្ត ខ្ញុំសូមជូនពរដល់ឯកឧត្តម លោកជំទាវ ភ្ញៀវជាតិ អន្តរជាតិ និងសមាជិកអង្គសិក្ខាសាលាទាំងមូល សូមប្រកបដោយសុខភាពរឹងមាំ ប្រាជ្ញាវាងវៃ ដើម្បីជាកម្លាំងចលនាដ៏ខ្លាំងក្លាក្នុងការងារគាំទ្រសិទ្ធិកុមារនៅកម្ពុជាឱ្យបានរុងរឿង ។

កុមារគឺជាដួងព្រលឹងរបស់យើងគ្រប់ៗរូប !

**សូមអរគុណ !**

~~~~~~~~~~~~~~~~~~
~~~~~~~~~~~~~~~~~~

# បញ្ជីរាយនាមអ្នកចូលរួមសិក្ខាសាលា
## ថ្ងៃទី ២២-២៣ មករា ២០០១

~~~~~~~~~~~~~~~~

| ល.រ | ឈ្មោះអ្នកចូលរួម | ប្រុស | ស្រី | មុខងារ |
|---|---|---|---|---|
| | **គណៈអធិបតី** | | | |
| ១ | ឯកឧត្តម អ៊ិត សំហេង | ប | | រដ្ឋមន្ត្រីក្រសួងស.ក.ប.យ |
| ២ | ឯកឧត្តម អ៊ឹម សិទ្ធី | ប | | រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា |
| ៣ | ឯកឧត្តម ឱម យិនទៀង | ប | | ប្រធានគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា |
| | **ភ្ញៀវកិត្តិយស** | | | |
| ៤ | លោកស្រី ជា វ៉ាសនា | | ស | ជំនួយការអង្គការ COHCHR |
| ៥ | បណ្ឌិត ឡៅ ម៉ុងហៃ | ប | | K . I . D |
| ៦ | លោក ចាយ ច័ន្ទតារាវណ្ណ | ប | | មន្ត្រីសិទ្ធិកុមារ SCA |
| ៧ | លោក Bo Harvold | ប | | Director S.C Norway |
| ៨ | លោក Guide Camole | ប | | តំណាង UICEF |
| ៩ | លោក Alex Amirh | ប | | U.S Embassy |
| ១០ | ឯកឧត្តម សយ ស៊ីផុន | ប | | អនុរដ្ឋលេខាធិការ ស.ក.ប.យ |
| ១១ | លោក កែវ សាកាន់ | ប | | អគ្គនាយករង ស.ក.ប.យ |
| ១២ | លោក អ៊ុយ ស៊ឹម | ប | | នាយកខុទ្ទកាល័យ ឯ.ឧ ស ខេង |
| | **សមាជិកចូលរួមទីស្តីការគណៈរដ្ឋមន្ត្រី** | | | |
| ១៣ | ឯកឧត្តម សេង លីមនៅ | ប | | អនុរដ្ឋលេខាធិការ |
| ១៤ | លោក កុង វ៉ុក | ប | | ប្រធាននាយកដ្ឋានសង្គមស៊ីវិល |
| ១៥ | លោក ហាវ៉ាន់ ស៊ីរីល័យ | ប | | ទីប្រឹក្សា ឯ.ឧ ស ខេង |
| ១៦ | លោក មាស សារឹម | ប | | ទីប្រឹក្សា ឯ.ឧ ស ខេង |
| ១៧ | លោក គង់ អ៊ួក | ប | | ប្រធានន.អង្គការក្រៅរដ្ឋាភិបាល និងសិទ្ធិមនុស្ស |
| | **ក្រសួងមហាផ្ទៃ** | | | |
| ១៨ | លោក ទែន បូរ៉ានី | ប | | អនុប្រធាននាយកដ្ឋាននគរបាលព្រហ្មទ័ណ្ឌ |
| ១៩ | លោក ឈឹម នី | ប | | អនុប្រធាននាយកដ្ឋានពន្ធនាគារ |
| | **ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និង យុវនីតិសម្បទា** | | | |
| ២០ | ឯកឧត្តម នូវ ភារិទ្ធិ | ប | | អនុរដ្ឋលេខាធិការ |
| ២១ | ឯកឧត្តម យូ បុណ្យណា | ប | | អនុរដ្ឋលេខាធិការ |
| ២២ | ឯកឧត្តម អ៊ុំ មាន | ប | | អគ្គនាយក |
~~~~~~~~~~~~~~~~

| | | | | |
|---|---|---|---|---|
| ២៣ | ឯកឧត្តម ថាច់ សែម | ប | | ទីប្រឹក្សាក្រសួង ស.ក.ប.យ |
| ២៤ | លោក គង់ ឆាន | ប | | អគ្គនាយករងយុវនីតិសម្បទា |
| ២៥ | លោក ហាំង ស៊ីថា | ប | | អគ្គនាយករង |
| ២៦ | លោក ទូច សាម៉ុន | ប | | អគ្គនាយករងសង្គមកិច្ច និងយុវនីតិសម្បទា |
| ២៧ | លោក កែវ សឿន | ប | | ប្រធាននាយកដ្ឋានស្តារលទ្ធភាពពលកម្ម |
| ២៨ | លោក ឆែម ស៊ុនហេង | ប | | ការិយាល័យស្នំកូន |
| ២៩ | លោក កែវ សុខសិទ្ធិទី | ប | | ទីប្រឹក្សារដ្ឋមន្ត្រី ស.ក.ប.យ |
| ៣០ | លោក គ្រួច សុផារី | ប | | នាយកខុទ្ទកាល័យ |
| ៣១ | លោក ម៉ៅ សុវត្ថិ | | | ប្រធាននាយកដ្ឋានសុខុមាលភាពកុមារ |
| ៣២ | លោកស្រី យួន សុវណ្ណា | | ស | ប្រធានមជ្ឈមណ្ឌលសង្គ្រោះទារក នៃស.ក.ប.យ |
| ៣៣ | លោកស្រី អ៊ុក សាផន | | ស | អនុប្រធាននាយកដ្ឋានសុខុមាលភាពកុមារ |
| | **ក្រសួងការបរទេស** | | | |
| ៣៤ | លោកស្រី ផាន់ឡូរី | | ស | ប្រធានការិយាល័យ |
| ៣៥ | លោក គីម សុវណ្ណា | ប | | ប្រធានការិយាល័យច្បាប់ |
| | **ក្រសួងយុត្តិធម៌** | | | |
| ៣៦ | លោក សោ សុភារី | ប | | ប្រធានតុលាការក្រុង |
| ៣៧ | លោក ឆេង ផាត់ | ប | | ព្រះរាជអាជ្ញាអមតុលាការខេត្តកណ្តាល |
| ៣៨ | លោក ហួត វុឌ្ឍី | ប | | ប្រធានការិយាល័យរដ្ឋប្បវេណី |
| | **ក្រសួងការពារជាតិ** | | | |
| ៣៩ | លោក នាង អេង | ប | | ប្រធាននាយកដ្ឋានឃោសនា អប់រំ |
| | **ក្រសួងអប់រំ យុវជន និងកីឡា** | | | |
| ៤០ | ឯកឧត្តម ប៊ុន សុខ | ប | | អនុរដ្ឋលេខាធិការ |
| ៤១ | លោក អ៊ិន ថេរ | ប | | ប្រធាននាយកដ្ឋានអប់រំក្រៅប្រព័ន្ធ |
| ៤២ | លោក សាន សូត្រ | ប | | អនុប្រធាននាយកដ្ឋានមធ្យមសិក្សា |
| ៤៣ | លោក សេង គួនឈូ | ប | | ប្រធានការិយាល័យយុវជន |
| ៤៤ | លោក ផន សូគីម | ប | | ប្រធាននាយកដ្ឋានយុវជន |
| ៤៥ | លោក អ៊ូ ជា | ប | | អនុប្រធានរដ្ឋបាល |
| | **ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន** | | | |
| ៤៦ | លោកជំទាវ សាន អរុណ | | ស | អនុរដ្ឋលេខាធិការ |
| ៤៧ | លោកស្រី សំ មុន្នីការ | | ស | អគ្គនាយករង |
| ៤៨ | លោកស្រី សាត សាលិម | | ស | អនុប្រធាននាយកដ្ឋាន |
| ៤៩ | លោកស្រី គង្គ ប៊ុណ្យន័ក្ស | | ស | ប្រធានការិយាល័យ ន.អភិវឌ្ឍន៍ធនធានមនុស្ស |

| | | | | |
|---|---|---|---|---|
| | **ក្រសួងសុខាភិបាល** | | | |
| ៥០ | ឯកឧត្តម សេង ហាក់ស្រ៊ុន | ប | | រដ្ឋលេខាធិការ |
| ៥១ | លោក ឈុន តុត | ប | | ការពារសុខភាព |
| ៥២ | លោក គីម លឹមប៊ុណ្ណា | ប | | ម.ជ.ប.អ |
| ៥៣ | លោក លី សំអុល | ប | | អាជ្ញាធរជាតិប្រឆាំងជំងឺអេដស៍ |
| | **ក្រសួងអភិវឌ្ឍន៍ជនបទ** | | | |
| ៥៤ | លោកស្រី ទុម ទិត្យធាវី | | ស | មន្ត្រីនាយកដ្ឋានអប់រំសុខភាព |
| | **ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល** | | | |
| ៥៥ | លោក គីម ទូច | ប | | ប្រធាននាយកដ្ឋាន |
| | **ក្រសួងផែនការ** | | | |
| ៥៦ | លោក គី ឡុង | ប | | អនុប្រធានការិយាល័យ |
| | **ក្រសួងទេសចរណ៍** | | | |
| ៥៧ | លោក យ៉ង់ វ៉ន | ប | | ប្រធាននាយកដ្ឋាន |
| | **ក្រសួងធម្មការ និងសាសនា** | | | |
| ៥៨ | លោក អ៊ឹង សុភារិទ្ធ | ប | | អនុប្រធាននាយកដ្ឋាន |
| | **អង្គការក្រៅរដ្ឋាភិបាល** | | | |
| ៥៩ | លោកស្រី តាតុន វ៉ាលីរី | | ស | UNICEF. |
| ៦០ | លោក កែវ សុគា | ប | | UNICEF. |
| ៦១ | លោក ភោគ សុខភា | ប | | UNICEF. |
| ៦២ | លោក អ៊ូ វ៉ុន | ប | | UNICEF. |
| ៦៣ | លោកស្រី ហៀង នាង | | ស | UNICEF. |
| ៦៤ | លោកស្រី ញ៉ិញ សោភា | | ស | COHCHR. |
| ៦៥ | លោកស្រី វ៉ាន់ណារី | | ស | COHCHR. |
| ៦៦ | លោកស្រី ហ្វ្រង់ ស៊ីស្កាម៉ារូត | | ស | COHCHR. |
| ៦៧ | លោក អ៊ុក វិរៈ | ប | | COHCHR. |
| ៦៨ | លោក ស៊ឹម សូយ៉ុង | ប | | ប្រធាន CRC |
| ៦៩ | លោក មាស សំណាង | ប | | LAC. |
| ៧០ | លោក ហួត ចាន់ឌី | ប | | Lawyer LAC. |
| ៧១ | លោក ង៉េង តេង | ប | | លីកាដូភ្នំពេញ |
| ៧២ | លោក អ៊ិត រ៉ាឌី | ប | | គណៈកម្មាធិការសិទ្ធមនុស្ស |
| ៧៣ | លោក ឯម ចាន់មករា | ប | | ប្រធានគណៈកម្មាធិការសិទ្ធិកុមារ |
| ៧៤ | លោកស្រី មុំ ថានី | | ស | Senior advisor CRC. |

| | | | | |
|---|---|---|---|---|
| ៧៥ | លោកស្រី ប្រាក់ សារ៉ាំង | | ស | ប្រធានមណ្ឌលកុមារកំព្រាកណ្ដាល |
| ៧៦ | លោកស្រី ម៉ុ មាគាំ | | ស | SCUK. |
| ៧៧ | លោកស្រី អូ ខេម៉ាលីន | | ស | VOR. |
| ៧៨ | លោក ឡេង សំអុល | ប | | NAA. |
| ៧៩ | លោក ជា មូនី | ប | | ILO. |
| ៨០ | លោក ងួនរិទ្ធី | ប | | WVC. |
| ៨១ | លោក ម៉ែន សុផារតន៍ | ប | | UNICEF. |
| ៨២ | លោក តាន់ ទ្រី | ប | | UNICEF. |

~~~~~~~~~~~~~~~~~~~~
~~~~~~~~~~~~~~~~~~~~

# លទ្ធផលនៃអង្គសិក្ខាសាលា ស្តីពីអនុសាសន៍របស់ អ.ស.ប លើការអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារនៅកម្ពុជា
# ១៦.១៧ វិច្ឆិកា ២០០០

~~~~~~~~~

ព្រឹកថ្ងៃទីពីរនៃអង្គសិក្ខាសាលា សិក្ខាកាមទាំងអស់ត្រូវបានបែងចែកជាក្រុមពិភាក្សាដើម្បីកំណត់លំដាប់ជាអាទិភាពនៃអនុសាសន៍របស់អង្គការសហប្រជាជាតិ ។ លទ្ធផលនៃការពិភាក្សានេះមានដូចខាងក្រោម :

## ក. លំដាប់អាទិភាពនៃអនុសាសន៍ របស់អង្គការសហប្រជាជាតិ

### ១. វិធានការអនុវត្តន៍ទូទៅ

១- ពិនិត្យមើលឡើងវិញនូវច្បាប់ដែលចូលជាធរមាន ឱ្យស្របនឹងបទបញ្ញត្តិទាំងអស់នៃអនុសញ្ញា ជាពិសេសស្របនឹងគោលការណ៍ទូទៅនៃអនុសញ្ញាដោយយកចិត្តទុកដាក់ជាពិសេសដល់ :

- ការចុះបញ្ជីជាតិ
- គ្រួសារ និងមធ្យោបាយថែរក្សាចំលាស់
- ការផ្តល់យុត្តិធម៌សំរាប់កុមារ

២- បន្តការអប់រំដែលមានលក្ខណៈជាប្រព័ន្ធ និងកម្មវិធីហ្វឹកហ្វឺនស្តីពីសិទ្ធិកុមារដល់សមាជិកសភា ចៅក្រម មេធាវី មន្ត្រីអនុវត្តច្បាប់ មន្ត្រីរាជការស៊ីវិល អ្នកធ្វើការនៅសាលាក្រុង បុគ្គលិកបំរើការនៅស្ថាប័ន ឬមន្ទីរឃុំឃាំង កុមារនានា គ្រូបង្រៀន បុគ្គលិកសុខាភិបាលសង្គមកិច្ច និងអ្នកចិត្តវិទ្យា ។

៣- គិតគួរពិចារណាដល់ការបង្កើតយន្តការឯករាជ្យមួយ ដើម្បីត្រួតពិនិត្យតាមដានការអនុវត្តអនុសញ្ញា និងដោះស្រាយបណ្តឹងរបស់កុមារ ដែលប្តឹងពីករណីនៃការរំលោភបំពានសិទ្ធិរបស់គេ ។

៤- បញ្ចូលការបារម្ភនានា ទាក់ទងនឹងសិទ្ធិកុមារទៅក្នុងដំណើរការធ្វើសេចក្តីព្រាងច្បាប់នាពេលបច្ចុប្បន្ន និងអនាគត ជាពិសេសក្តីព្រាងច្បាប់រដ្ឋប្បវេណី ព្រាងច្បាប់ព្រហ្មទណ្ឌ និងព្រាងច្បាប់និតិវិធីព្រហ្មទណ្ឌ ។

៥- ផ្តល់អាទិភាព និងធានានូវធនធានជាអតិបរិមាដែលខ្លួនមានសំរាប់វិស័យសុខាភិបាល អប់រំ និង សេវាសង្គមដល់កុមារ ជាពិសេសគឺយកចិត្តទុកដាក់ដល់ការការពារកុមារ ដែលស្ថិតនៅក្នុងក្រុមងាយរងគ្រោះ និងក្រុមដែលគេពុំសូវទឹកនាដល់ ។

៦- បន្តអភិវឌ្ឍន៍ និងពង្រឹងប្រព័ន្ធទិន្នន័យ ដែលបញ្ចូលនូវគ្រប់វិស័យទាំងអស់នៃអនុសញ្ញា ជាពិសេសទៅលើក្រុមកុមារដែលងាយរងគ្រោះ ។

៧- ពង្រឹងតួនាទីរបស់ ក.ជ.ក.ក ក្នុងការសម្របសម្រួលការអនុវត្តអនុសញ្ញានៅថ្នាក់ជាតិ ថ្នាក់តំបន់ និងនៅតាមមូលដ្ឋាន ។

៨- ផ្តល់ធនធានមនុស្ស និងធនធានហិរញ្ញវត្ថុសមស្របដល់ ក.ជ.ក.ក ក្នុងការបំពេញតួនាទីឱ្យមានប្រសិទ្ធភាព ។

៩- ធានាឱ្យមានកិច្ចសហការ និងការសម្របសម្រួលកាន់តែជិតស្និទ្ធ ជាមួយនឹងអង្គការក្រៅរដ្ឋាភិបាលនានា ដែលធ្វើការនៅក្នុងវិស័យសិទ្ធិកុមារ ។

១០-ធ្វើយុទ្ធនាការលើកកំពស់ការយល់ដឹង សំដៅបង្កលក្ខណៈងាយស្រួលឱ្យកុមារប្រើប្រាស់យន្តការនេះ ប្រកបដោយប្រសិទ្ធភាព។
~~~~~~~~~

១១-ពង្រឹងការផ្សព្វផ្សាយពីសិទ្ធិកុមារ ជាពិសេសដល់ក្រុមជនជាតិភាគតិចក៏ដូចជានៅតាមតំបន់ជនបទ និងដាច់ស្រយាល ។

## ២. និយមន័យ

១- បញ្ចូលនិយមន័យកុមារក្នុងច្បាប់ ។

២- គិតគូរដល់ការដាក់បញ្ចូលបទបញ្ញត្តិទាក់ទងនឹងអាយុជាអតិបរមា សំរាប់ការទទួលខុសត្រូវលើផ្នែកព្រហ្មទណ្ឌ និងការយល់ព្រមរួមភេទ ។

៣- អនុវត្តបញ្ញត្តិច្បាប់ទាក់ទងនឹងអាយុជាអប្បបរមាសំរាប់ការរៀបអាពាហ៍អាពាហ៍ ។

## ៣. គោលការណ៍ទូទៅ

១- ដាក់បញ្ចូលគោលការណ៍ទូទៅនៃអនុសញ្ញា ទៅក្នុងច្បាប់ទាំងអស់ដែលមានការទាក់ទងនឹងមានផលប៉ះពាល់ទៅលើកុមារ ។

២- យកគោលការណ៍ទៅពិចារណានៅក្នុងការធ្វើសេចក្តីសំរេចចិត្តតាមផ្លូវរដ្ឋបាល និងតាមផ្លូវតុលាការក៏ដូចជានៅក្នុងគោលនយោបាយ និងកម្មវិធីដែលទាក់ទងនឹងកុមារ ។

៣- លើកកំពស់ការយល់ដឹងពីគោលការណ៍ទាំងនោះ ទៅដល់សាធារណៈជនទូទៅ រួមមានសហគមន៍ និងមេដឹកនាំ សាសនានានា ព្រមទាំងកម្មវិធីអប់រំស្តីពីការអនុវត្តគោលការណ៍ ។

៤- ប្រកាន់យកនូវវិធានការណ៍ដ៏មានប្រសិទ្ធភាពនានា ដើម្បីបំបាត់ការរើសអើងប្រឆាំងនឹងកុមារីជា ពិសេសគឺការទទួលបាននូវការសិក្សាអប់រំ ។

៥- ត្រូវមានការប្រឹងប្រែង ដើម្បីបំបាត់ការរើសអើងប្រឆាំងនឹង កុមារតាមចិញ្ចើមថ្នល់ កុមារក្រុមជនជាតិភាគតិច ជាពិសេសកុមារដែលមានដើមកំណើតជាជាតិវៀតណាម ។

## ៤. សិទ្ធិ និងសេរីភាពរដ្ឋ

១- បើកយុទ្ធនាការលើកកំពស់ការយល់ដឹង ដើម្បីជំរុញឱ្យមានការចុះបញ្ជីជាតិ ដល់កុមារគ្រប់រូប បន្ទាប់ពីការប្រសូតមកភ្លាម ។

២- ពិនិត្យច្បាប់ជាតិវិញ ដើម្បីដាក់ឱ្យការចុះបញ្ជីជាតិកុមារគ្រប់រូប ក្លាយជាកាតព្វកិច្ចដោយគ្មានការរើសអើង ។

៣- ចាត់វិធានការដ៏មានប្រសិទ្ធភាព ដើម្បីអនុវត្តន៍អនុក្រិត្យលេខ៧៤ ស្តីពីសៀវភៅគ្រួសារ និងលេខ៧៣ ស្តីពីសៀវភៅស្នាក់នៅជាពិសេសធានាថាកុមារទាំងអស់ដែលមិនបានចុះបញ្ជីជាតិ នៅពេលប្រសូតរួចភ្លាមត្រូវបានចុះបញ្ជីជាតិ ។

៤- បង្កើតច្បាប់ពិសេស ដើម្បីការពារកុមារពីពត៌មានដែលបណ្តាលឱ្យមានការអន្តរាយ ជាពិសេសលើកម្មវិធីទូរទស្សន៍ និងខ្សែភាពយន្តដែលបង្ហាញពីភាពសាហាវឃោរឃៅ និងអាសអាភាស និងដើម្បីធានាការទទួលបានពត៌មានសមស្រប ។

៥- លើកកំពស់ការយល់ដឹងដល់សាធារណៈជន អំពីសិទ្ធិចូលរួមរបស់កុមារនៅក្នុងគ្រួសារ សហគមន៍ ស្ថាប័ន និង សាលារៀន ។

៦- ចាត់វិធានការនានាជាបន្ថែម រួមមានការកែទំរង់ច្បាប់ដើម្បីជំរុញការចូលរួមរបស់កុមារនៅក្នុងស្ថាបន័សង្គមដទៃទៀត ។

៧- ធានានូវការទទួលបានសេរីភាពជាមួយដ្ឋានក្នុងការផ្តល់មតិ សំដែងមតិ និងសេរីភាពក្នុងការបង្កើត និងចូលរួមជាមួយសមាគមន៍ ។

៨- ពិនិត្យឡើងវិញនូវច្បាប់ស្តីពីសញ្ជាតិ ឱ្យអនុលោមទៅតាមអនុសញ្ញា ដើម្បីលុបបំបាត់មូលដ្ឋានរើសអើង ដែលអាចមានបំបាត់ទាំងស្រុង និងបង្ការបញ្ហាកុមារគ្មានសញ្ជាតិ ។

៩- យកចិត្តទុកដាក់ពិចារណាលើអនុសាសន៍របស់គណៈកម្មាធិការសិទ្ធិកុមារ ក្នុងទិវាពិភាក្សាជាទូទៅលើប្រធានបទ " កុមារ និងប្រព័ន្ធឃោសនា " ១៩៩៦ ។

## ៥. បរិយាកាសគ្រួសារនិងការថែរក្សាចំលាស់

១- ចាត់វិធានការដ៏មានប្រសិទ្ធភាព រួមមានការបង្កើតកម្មវិធីចំរុះ វិធានការថែរក្សា និង ស្ដានីតិសម្បទា ដើម្បីបង្ការទប់ស្កាត់ ប្រយុទ្ធប្រឆាំងនឹងការរំលោភបំពានលើកុមារ និងអំពើឃោរឃៅលើកុមារក្នុងរង្វង់គ្រួសារនៅតាមសាលា និងស្ថាប័ននានា និងនៅក្នុងសង្គម ។

២- ចាត់វិធានការដ៏មានប្រសិទ្ធភាព សំដៅលើកដំកើងគ្រួសារដែលជាមជ្ឈដ្ឋានដ៏ល្អបំផុតសំរាប់កុមារ ដើម្បីនឹងប្រគល់អំណាចឱ្យឪពុកម្ដាយបីបាច់ថែរក្សាកូនក្នុងគោលបំណងបញ្ចៀសការដាក់កុមារទៅក្នុងមណ្ឌលសង្គ្រោះកុមារនានា (តាមរយៈការផ្ដល់ការពិគ្រោះយោបល់ និងកម្មវិធីតាមសហគមន៍) ដោយបែងចែងធនធានមនុស្ស និងហិរញ្ញវត្ថុគ្រប់គ្រាន់ ។

៣- ពង្រឹងនីតិវិធីដែលសមស្របនឹងកុមារ ព្រមទាំងយន្តការដោះស្រាយបណ្ដឹង ស្ដីពីការរំលោភបំពានកុមារ ដើម្បីឱ្យកុមារទទួលបានឆាប់រហ័សនូវភាពយុត្តិធម៌ ហើយជៀសវាងនូវនិទណ្ឌភាពរបស់ជនល្មើស ។

៤- ពង្រឹងនិងពង្រីកសេវាសង្គមនានា ឱ្យកុមារភាគច្រើនទទួលបាន ជាពិសេសកុមារកំព្រាដោយសារការរាតត្បាត ដោយមេរោគ និងជំងឺអេដស៍ និងបង្កើតនូវទំរង់ថែរក្សាចំលាស់ផ្សេង ដូចជាការថែរក្សាដោយគ្រួសារផ្សេងៗ ដោយបែងចែកធនធានមនុស្ស និង ហិរញ្ញវត្ថុគ្រប់គ្រាន់ ។

៥- ពង្រឹងការអនុវត្តច្បាប់ដែលទាក់ទងនឹងបទល្មើសព្រហ្មទណ្ឌបែបនោះ ។

៦- បង្កើតគោលនយោបាយ និងបទបញ្ញាទាក់ទងនឹងមណ្ឌលថែទាំកុមារ និងការថែរក្សាចំលាស់ផ្សេងៗ ដោយបែងចែកធនធានមនុស្ស និង ហិរញ្ញវត្ថុគ្រប់គ្រាន់ ។

៧- បង្កើតកម្មវិធីអប់រំនានា ដើម្បីប្រយុទ្ធប្រឆាំងនឹងឥរិយាបថប្រពៃណីនៅក្នុងសង្គមចំពោះបញ្ហានេះ ។

៨- បន្តដំណើរការរៀបចំ ធ្វើច្បាប់សុំកូនអន្តរប្រទេស និងធ្វើកំណែទំរង់ច្បាប់ជាធរមានដែលទាក់ទងទៅនឹងសុំកូនក្នុងស្រុក ។

៩- ចូលជាសមាជិកនៃអនុសញ្ញាក្រុងឡាអេឆ្នាំ ១៩៩៣ ស្ដីពីការការពារកុមារ និង សហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេស ។

## ៦. សុខភាពមូលដ្ឋាន និងសុខុមាលភាព

១- លើកយកបញ្ហាជំងឺ និងមរណៈភាពកុមារមកដោះស្រាយតាមរយៈយុទ្ធវិធីចំរុះ ដោយគិតគូរទៅដល់បញ្ហាអនក្ខរជនការផ្គត់ផ្គង់ទឹកស្អាត និងអសន្តិសុខស្បៀង ។

២- ត្រូវករឱ្យឃើញនូវវិស័យជាអាទិភាព ដោយផ្អែកទៅលើទិន្នន័យមូលដ្ឋានដែលប្រមូលបានតាមការស្រាវជ្រាវដ៏ប្រុងប្រយ័ត្ន និងទូលំទូលាយ ក្នុងនោះត្រូវតែគិតទៅដល់ការថែរក្សាសុខភាព ភាគច្រើននៅក្រៅអាគារសុខាភិបាល និងគ្មានការត្រួតពិនិត្យពីរដ្ឋ ហើយត្រូវតែគិតគូរផងដែរ ទៅដល់សេចក្ដីត្រូវការជាពិសេសរបស់សហគមន៍ ដែលនៅដាច់ពីគេ ។

៣- ចាត់វិធានការមានប្រសិទ្ធភាព ដើម្បីបង្ការមេរោគ ឬជំងឺអេដស៍ រួមមានការលើកកំពស់ការយល់ដឹង និងយុទ្ធ នាការអប់រំ ។

៤- ចាត់ឱ្យមានវិធានការត្រឹមត្រូវ ក្នុងការបង្កើតឱ្យមានផ្នែកថែរក្សាសុខភាពបឋមមួយដ៏មានប្រសិទ្ធភាពហើយ វិធានការនេះរួមបញ្ចូលទាំងយុទ្ធសាស្ត្រលើកទឹកចិត្តដល់ការស្វែងរកការថែរក្សាជំងឺកុមារ ។

៥- កែលំអនឹងពង្រីកការទទួលសេវាថែរក្សាសុខភាព និងថ្នាំសង្កូវ ដើម្បីធានាឱ្យកុមារនៃគ្រួសារក្រីក្រ និងកុមារ នៃក្រុមដែលពុំសូវបានគេអើពើ ទទួលបានសេវាទាំងនេះ ។

៦- ធ្វើការសិក្សាក្រោមប្រធានបទចំរុះដ៏ទូលំទូលាយមួយ ដើម្បីស្វែងយល់ពីវិសាលភាពនៃបញ្ហាសុខភាពរបស់មនុស្សជំទង់ រួមទាំងសុខភាពផ្លូវចិត្តផង ដើម្បីយកធ្វើជាមូលដ្ឋាន សំរាប់លើកដំកើនគោលនយោបាយសុខភាពមនុស្សជំទង់ និងពង្រឹងការអប់រំសុខភាពបន្តពូជ ។

៧- បង្កើតកម្មវិធីអប់រំ ពិសេសមជ្ឈមណ្ឌលនានា និងលើកទឹកចិត្តការបញ្ចូលកុមារពិការទៅក្នុងប្រព័ន្ធអប់រំ និង ក្នុងសង្គម ។

៨- ធ្វើការសហការឱ្យបានជិតស្និទ្ធជាមួយនិងការគាំទ្រដល់សកម្មភាពនានា ដែលអនុវត្តន៍ដោយអង្គការក្រៅរដ្ឋាភិបាលដែលធ្វើការក្នុងវិស័យនេះ ដើម្បីអភិវឌ្ឍន៏កម្មវិធីកំណត់រកមុខសញ្ញា ដែលអាចពិការ ឱ្យទាន់ពេលសំដៅបង្ការពិការភាព ។

៩- ធ្វើយុទ្ធនាការលើកកំពស់ការយល់ដឹង ដើម្បីកាត់បន្ថយការរើសអើងជនពិការ ។

១០- យកចិត្តទុកដាក់ទៅលើអនុសាសន៏របស់គណៈកម្មាធិការ ដែលបានអនុមត័លើទិវាពិភាក្សាទូទៅស្ដីអំពី "កុមាររស់នៅក្នុងពិភពលោកមួយ ដែលមានជំងឺឬមេរោគអេដស៏ "

១១- ខិតខំបន្ថែមទៀតដើម្បីអភិវឌ្ឍន៏សេវាផ្ដល់ការពិគ្រោះយោបល់ ដែលកុមារងាយស្រួលយល់ព្រម ទាំងភាពងាយស្រួលក្នុងការថែរក្សា និងការស្ដារនីតិសម្បទាដល់មនុស្សវ័យជំទង់ ។

១២- អនុវត្តវិធានការនានា ជំនួសការយកកុមារពិការទៅដាក់ក្នុងមណ្ឌល ។

១៣- បង្កើតឱ្យមានកិច្ចត្រួតពិនិត្យតាមដានគ្រប់គ្រាន់ លើមណ្ឌលកុមារកំព្រាឯកជន ។

## ៧. ការអប់រំ ការលំហែ និងសកម្មភាពវប្បធម៌

១- ចាត់វិធានការដ៏មានប្រសិទ្ធភាពដើម្បីធ្វើឱ្យបឋមសិក្សាប្រព្រឹត្តទៅដោយឥតបង់ថ្លៃ និង មានលក្ខណៈជាកាតព្វកិច្ច ចំពោះកុមារគ្រប់រូប ។

២- បន្តចាត់វិធានការធ្វើឱ្យប្រសើរឡើងនូវប្រព័ន្ធអប់រំតាមរយៈការបង្កើនថវិកា ដែលត្រូវបែងចែកទុកដោយឡែកសំរាប់ផ្នែកសិក្សាអប់រំ ។

៣- បង្កើនអត្រាចុះឈ្មោះចូលរៀន និងកាត់បន្ថយអត្រាបោះបង់ការសិក្សា និងការត្រួតថ្នាក់ បង្កើនឱកាសចូលសាលារៀន ជាពិសេសចំពោះករណីកុមារក្រីក្រ កុមារី កុមារក្រុមជនភាគតិច និងកុមាររស់នៅតាមតំបន់ដាច់ស្រយាល ។

៤- ពង្រីកឱកាសទទួលបានការបណ្ដុះបណ្ដាលវិជ្ជាជីវៈ និងការអប់រំក្រៅប្រព័ន្ធដែលរួមមានកំរិតមត្តេយ្យសិក្សា និងមធ្យមសិក្សា

៥- ធ្វើឱ្យកម្មវិធីសិក្សាកាន់តែមានទំនាក់ទំនងនឹងសេចក្ដីត្រូវការរបស់កុមារ ។

៦- បណ្ដុះបណ្ដាលលើកកំពស់ជំនាញគ្រូបង្រៀន ។

៧- បង្កើតប្រព័ន្ធវាយតំលៃមួយ ដើម្បីវាស់ស្ទង់ប្រសិទ្ធភាពប្រពន្ធ័អប់រំ ។

## ៨. វិធានការការពារពិសេស

១- ពិនិត្យមើលច្បាប់ឡើងវិញ ដើម្បីពង្រឹងច្បាប់នោះ ហើយក្នុងពេលដំណាលគ្នានោះ ត្រូវអនុវត្តន៏ច្បាប់ទាក់ទងនឹងការកេងប្រវ័ញ្ចផ្លូវភេទនាពេលបច្ចុប្បន្នឱ្យបានពេញលេញ ។

២- ធ្វើការចោទប្រកាន់ជនល្មើសច្បាប់ ។

៣- អនុវត្តន៏បទបញ្ញត្តិច្បាប់ការងារ ដែលទាក់ទងនឹងអាយុអប្បរមាដើម្បីចូលធ្វើការ ។

៤- ពង្រឹង និងពង្រីកសេវាសង្គម សំរាប់ស្ដារនីតិសម្បទាកុមាររងគ្រោះ ពីការកេងប្រវ័ញ្ចផ្លូវភេទ ។

៥- ពង្រឹងកិច្ចសហប្រតិបត្តិការទ្វេភាគី ជាពិសេសជាមួយប្រទេសជិតខាងនានា និងបង្កើនទូវការត្រួតពិនិត្យព្រំដែន ។
៦- អនុវត្តន៍យ៉ាងពេញលេញនូវផែនការជាតិ ៥ឆ្នាំ ។
៧- ដាក់ទ័ណ្ឌកម្មដល់ជនរំលោភបំពានច្បាប់ ។
៨- បង្កើតប្រព័ន្ធយុត្តិធម៌មួយសំរាប់កុមារ ដោយយកគោលការណ៍ និងបទបញ្ញត្តិនៃអនុសញ្ញា ព្រមទាំងឧបករណ៍ និងវិធាន អន្តរជាតិទាំងឡាយដែលពាក់ព័ន្ធនឹងកិច្ចការនេះមកពិចារណា ។
៩- បណ្តុះបណ្តាល និង ផ្តល់មធ្យោបាយត្រួតពិនិត្យពលកម្មកុមារដល់អធិការកិច្ចការងារ ។
១០- អនុម័តច្បាប់ក្នុងស្រុក សំដៅការពារកុមារ ពីទំរង់គ្រោះថ្នាក់នៃការងារ ។
១១- បង្កើតគោលនយោបាយដ៏ទូលំទូលាយមួយ និង កម្មវិធីនានាស្តីពីស្ថានភាពកុមារ ប្រព្រឹត្តិអំពើល្មើសនឹងច្បាប់ដោយយកចិត្តទុកដាក់ជាពិសេសលើស្ថានភាពកុមារ ដែលត្រូវដកហូតសេរីភាព និងកិច្ចបង្ការយុវទោសកម្ម ។
១២- ផ្តល់សច្ចាបន៍លើអនុញ្ញា ILO ថ្មីលេខ ១៨២ ពាក់ព័ន្ធទៅនឹងការហាមប្រាម និងការលុបបំបាត់ជាបន្ទាន់នូវទំរង់ធ្ងន់ធ្ងរ នៃពលកម្មកុមារ ។
១៣- ធ្វើឱ្យសាធារណៈជនទូទៅអាចរកបានយ៉ាងទូលំទូលាយ នូវរបាយការណ៍ដំបូង និងរបាយការណ៍លាយលក្ខណ៍អក្សរ ឆ្លើយតបសំនួរ ហើយសុំឱ្យមានការបោះពុម្ពផ្សាយរបាយការណ៍ ដែលត្រូវបានពិចារណាដោយគណៈកម្មាធិការគួបផ្សំជាមួយនឹងកំនត់ហេតុសង្ខេបនានា ដែលពាក់ព័ន្ធនឹងសេចក្តីសង្កេតចុងក្រោយ ដើម្បីញ៉ាំងឱ្យមានការជជែកពិភាក្សា និង ការយល់ដឹងអំពីការអនុវត្តអនុសញ្ញា និងការតាមដានអនុសញ្ញានៅក្នុងរង្វង់រដ្ឋាភិបាល សភា និងសាធារណៈជនទូទៅ រួមទាំងអង្គការក្រៅរដ្ឋាភិបាលដែលពាក់ព័ន្ធ ។
១៤- ចាត់វិធានការដ៏មានប្រសិទ្ធភាព ដើម្បីរកឱ្យឃើញនូវអត្តសញ្ញាណការរំសាយទ័ព និងការស្តារលទ្ធភាពផ្នែកចិត្តសាស្ត្រ និងការធ្វើសមាហរណកម្មកុមារ ដែលជាទាហាន ទៅក្នុងសង្គមវិញ ។
១៥- ធ្វើយុទ្ធនាការលើកកំពស់ការយល់ដឹងដល់មន្ត្រីយោធា ក្នុងគោលបំនងបង្ការកុំឱ្យមានការជ្រើសយកកុមារ ឱ្យចូលបំរើកងទ័ពតទៅទៀត ។
១៦- បន្តធ្វើការស្តារនិតិសម្បទា និងធ្វើសមាហរណកម្មទាហានដែលមានអាយុក្រោមការកំនត់ ដោយសហការជាមួយអង្គការយូនីសែហ្វ ។
១៧- ចាត់វិធានការចាំបាច់ ដើម្បីរៀបចំបង្កើតឱ្យមានការការពារសិទ្ធិកុមារ ជាជនភៀសខ្លួន ដោយធ្វើឱ្យស្របទៅតាមស្មារតីនៃបទដ្ឋានអន្តរជាតិ ដែលពាក់ពន្ធ័ ។
១៨- ធ្វើយុទ្ធនាការលើកកំពស់ការយល់ដឹង ដើម្បីបង្ការគ្រោះថ្នាក់ដែលទាក់ទិននឹងគ្រាប់មីន ។
១៩- បង្កើតនីតិវិធីធ្វើឱ្យមានការជួបជុំគ្រួសារមួយ ដើម្បីដោយកុមារជាជនភៀសខ្លួន ដែលអាចត្រូវបំបែកចេញពីគ្រួសាររបស់គេ ។
២០- បង្កើនថវិកាសំរាប់ដោះមីនក្នុងតំបន់ជំលោះប្រដាប់អាវុធត្រូវបានបញ្ចប់ ។

## ខ. **អនុសាសន៍របស់អង្គការក្រៅរដ្ឋាភិបាលទៅលើការអនុវត្តអនុសាសន៍របស់ អ. ស. ប**

បន្ទាប់ពីបានពិភាក្សាក្នុងការកំណត់ជាលំដាប់អាទិភាពខាងលើរួចមក អង្គសិក្ខាសាលាបានបន្តការពិភាក្សាស៊ីជំរៅ ទៅលើលំដាប់អាទិភាព ដែលបានជ្រើសរើសក្នុងគោលបំណង ប្រមូលនៅមតិយោបល់នឹងវិះរកសកម្មភាពដែលត្រូវអនុវត្តន៍ឱ្យបានសំរេចនៅអនុសាសន៍នេះ ។ ការពិភាក្សាបានធ្វើឡើងដោយផ្អែកទៅលើសំនួរទាំង ៣ ដូចខាងក្រោម :

១- ដើម្បីឱ្យបានសំរេចនូវអនុសាសន៍របស់អង្គការសហប្រជាជាតិ ដែលបានជ្រើសរើសជាអាទិភាព តើរដ្ឋាភិបាលគួរធ្វើអ្វីខ្លះ ?
២- តើអង្គការក្រៅរដ្ឋាភិបាលគួររួមចំណែកធ្វើអ្វីខ្លះ ដើម្បីជួយរដ្ឋាភិបាលឱ្យបានសំរេចនៅសកម្មភាពខាងលើ ?
៣- តើរដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាលត្រូវមានវិធានការណ៍យ៉ាងណា ដើម្បីតាមដាននូវការអនុវត្តសកម្មភាពនេះឱ្យ មានប្រសិទ្ធភាព ?

➢ ដោយពេលវេលាមានកំណត់ អង្គការសិក្ខាសាលាបានសំរេចធ្វើការពិភាក្សាតែលើអាទិភាព ២ ឬ ៣ តាមលំដាប់ខាងលើនៃផ្នែកនីមួយៗ ។ លទ្ធផលនៃក្រុមពិភាក្សាមានដូចខាងក្រោម :

## ១-វិធានការណ៍អនុវត្តទូទៅ

### ដើម្បីអនុវត្តអនុសាសន៍ អ.ស.ប ឱ្យមានប្រសិទ្ធភាព រដ្ឋាភិបាលគួរតែ :

☞ ពង្រឹងការអនុវត្តច្បាប់ និង ពិនិត្យលិខិតបទដ្ឋានដែលមានស្រាប់ ក្នុងការចុះបញ្ជីជាតិឱ្យបានត្រឹមត្រូវ និងធ្វើវិសោធនកម្មនូវចំណុចណាដែលមិនស្របទៅនឹងអនុញ្ញាតស្ដីពីសិទ្ធិកុមារ ។
☞ ពង្រឹងការអនុវត្តច្បាប់ឬលិខិតបទដ្ឋានដែលមានស្រាប់ដើម្បីដកហូតអំណាចមេបា ឬ អាណាព្យាបាល ក្នុងករណីមានការធ្វើទារុណកម្មធ្ងន់ធ្ងរលើកុមារ និងគួរតែមានច្បាប់សំរាប់គ្រប់គ្រងមណ្ឌលកុមារ ព្រមទាំងអ្នកពាក់ពន្ធ័ក្នុងការថែទាំចំលាស់ ។
☞ ធ្វើច្បាប់ដើម្បីបង្កើតឱ្យមានតុលាការកុមារ ។
☞ ផ្សព្វផ្សាយ និងបញ្ចូលកម្មវិធីហ្វឹកហ្វឺនស្ដីពីសិទ្ធិកុមារ ដោយស្ថាបន័អាជ្ញាធរគ្រប់ជាន់ថ្នាក់ ស្ថាបន័តុលាការ និងដល់មន្ត្រីអនុវត្តន៍ច្បាប់ ។
☞ បង្កើតស្ថាបន័ឯករាជ្យមួយសំរាប់កុមារដែលមានសមាសភាពចំរុះ ក្នុងនោះមានព្រឹទ្ធសភា រដ្ឋសភា រដ្ឋាភិបាល អង្គការក្រៅរដ្ឋាភិបាល ព្រះសង្ឃ ប្រជាជន ពាណិជ្ជករ សមាជិកនៃស្ថាបន័នេះត្រូវមានសីលធម៌ខ្ពស់ បទពិសោធន៍ចំណេះដឹងខាងការងារកុមារ ដើម្បីតាមដានការអនុវត្តសិទ្ធិកុមារ និងដោះស្រាយពាក្យបណ្ដឹងរបស់កុមារ ដោយឥតបង់ថ្លៃ ។
☞ ផ្ដល់ធនធានហិរញ្ញវត្ថុ គ្រប់គ្រាន់សំរាប់ការអនុវត្តការងារនេះ ។

### ដើម្បីធ្វើឱ្យសំរេចបាននូវអនុសាសន៍ខាងលើ អង្គការក្រៅរដ្ឋាភិបាលគួររួមចំណែក

☞ ធ្វើយុទ្ធនាការផ្សព្វផ្សាយអំពីសិទ្ធិកុមារ ផ្សព្វផ្សាយច្បាប់ដែលទាក់ទងនឹងកុមារ គ្រួសារ និង ការប្រើប្រាស់ស្ថាបន័យុត្តិធម៌កុមារ ស្ថាបន័ឯករាជ្យ ដែលតាមដានការអនុវត្តសិទ្ធិកុមារ ដល់សារធារណៈជនស្រទាប់ជាន់ថ្នាក់ ។
☞ បណ្ដុះបណ្ដាលបុគ្គលិកមន្ត្រីរាជការដែលពាក់ព័ន្ធ ស្ដីពីសិទ្ធិកុមារ និង ច្បាប់ដែលពាក់ព័ន្ធនឹងកុមារ ។
☞ ប្រមូលទិន្នន័យពតិមាន ស្ដីពីការរំលោភសិទ្ធិកុមារ បញ្ជូនដល់ស្ថាបន័ឯករាជ្យ និង រាជរដ្ឋាភិបាល ព្រមទាំងចូលរួមផ្ដល់ជាយោបល់ក្នុងការធ្វើសេចក្ដីព្រាងច្បាប់ដែលពាក់ព័ន្ធនិងកុមារ ។
☞ ផ្ដល់សំភារៈ និងបច្ចេកទេសសមស្រប ដើម្បីជំរុញការអនុវត្តសកម្មភាពខាងលើ ដែលពាក់ព័ន្ធនឹងកុមារ ។

### ដើម្បីតាមដានលើការអនុវត្តសកម្មភាពនេះឱ្យមានប្រសិទ្ធភាព រដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាលគួរតែ :

☞ ធ្វើការចុះអង្កេតដំបូង និងធ្វើរបាយការណ៍ឆមាស ឬប្រចាំឆ្នាំ និងធ្វើការប្រជុំពិភាក្សា ត្រួតពិនិត្យវាយតំលៃការចុះអង្កេតពីលទ្ធផលនៃកម្មវិធីការងារទាំងនេះ ត្រូវមានការចូលរួមពីកុមារ ។

## ២- និយមន័យ គោលការណ៍ទូទៅ និង សិទ្ធិសេរីភាពពលរដ្ឋ

### ដើម្បីអនុវត្តអនុសាសន៍របស់ អ.ស.ប ឱ្យមានប្រសិទ្ធភាព រដ្ឋាភិបាលគួរតែ :

☞ បញ្ចូលនូវបទបញ្ញត្តិដែលទាក់ទងនឹងអាយុទទួលខុសត្រូវផ្នែកព្រហ្មទ័ណ្ឌ និងអាយុនៃការព្រមព្រៀងរួមភេទ ពាក់ពន្ធ័ ព្រមទាំងកំណត់អាយុរបស់កុមារឱ្យបានច្បាស់លាស់ ។

☞ បំផុសឱ្យមានការយល់ដឹង ពីគោលការណ៍ទូទៅនៃអនុសញ្ញាស្តីពីសិទ្ធិកុមារ និងបញ្ចូលគោលការណ៍នេះទៅក្នុងគ្រប់ច្បាប់ដែលពាក់ព័ន្ធនឹងកុមារ ។

☞ ផ្សព្វផ្សាយតាមគ្រប់ប្រព័ន្ធឃោសនា ពីសារៈសំខាន់នៃការចុះបញ្ជីកំណើត និងផលប៉ះពាល់នៃការមិនចុះបញ្ជីកំណើត ដល់គ្រប់ស្រទាប់ប្រជាពលរដ្ឋ អាជ្ញាធរដែនដីគ្រប់ជាន់ថ្នាក់ ។

☞ ជំរុញឱ្យមានការចុះបញ្ជីជាតិដោយឥតបង់ថ្លៃ និង ដោយដាក់ការចុះបញ្ជីជាតិនេះ ជាកាតព្វកិច្ចរបស់ អាជ្ញាធរ ឃុំ សង្កាត់ និង ប្រជាពលរដ្ឋម្នាក់ៗ ។

### ដើម្បីធ្វើឱ្យសំរេចបានអនុសាសន៍ខាងលើ អង្គការក្រៅរដ្ឋាភិបាល គួររួមចំណែក :

☞ ផ្តល់ជាមតិ និងទាក់ទាញការគាំទ្រ ដល់ការបញ្ចូលនូវរាល់បទបញ្ញត្តិ និងគោលការណ៍ទូទៅនៃអនុសញ្ញាទៅក្នុងច្បាប់ ។

☞ បង្កើតក្រុមការងារពិសេស ដែលមានសមាសភាពពីតំណាងអង្គការក្រៅរដ្ឋាភិបាល និងតំណាងរដ្ឋាភិបាល ដើម្បីធានាការបញ្ចូល និងការអនុម័តបទបញ្ញត្តិដែលទាក់ទងទៅនឹងការកំណត់អាយុរបស់កុមារ និងអាយុព្រមព្រៀងក្នុងការរួមភេទ ។

☞ រួមចំណែកក្នុងការផ្សព្វផ្សាយ ដើម្បីលើកកំពស់ការយល់ដឹងពីសារៈសំខាន់នៃការចុះបញ្ជីកំណើត ។

### ដើម្បីតាមដានការអនុវត្តសកម្មភាពនេះឱ្យមានប្រសិទ្ធភាព រដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាលគួរតែ :

☞ សហការជាមួយវិទ្យាស្ថានជាតិស្ថិតិ អង្គការ និង អាជ្ញាធរពាក់ពន្ធ័ដើម្បីប្រមូលទិន្នន័យ ដែលទាក់ទិននឹងកុមារ ។

☞ ផ្ទៀងផ្ទាត់ពីការដាក់បញ្ចូលនូវបទបញ្ញត្តិ គោលការទូទៅនៃអនុសញ្ញាស្តីពីកុមារ ការកំណត់អាយុកុមារ នៅក្នុងច្បាប់ និងសេចក្តីព្រៀងច្បាប់ ។

## ៣- បរិយាកាសគ្រួសារ និងការថែរក្សាជំលាស់

### ដើម្បីអនុវត្តអនុសាសន៍របស់ អ.ស.ប ឱ្យមានប្រសិទ្ធភាពរដ្ឋាភិបាលគួរតែ :

☞ បង្កើនការអប់រំដល់គ្រួសារ សហគមន៍ សាលារៀនអំពីសីលធម៌រស់នៅ ច្បាប់សិទ្ធិកុមារ និងការទទួលខុសត្រូវរបស់ឪពុកម្តាយ ចំពោះការថែរក្សាកូនតាមរយៈការបង្កើនប្រពន្ធ័ផ្សព្វផ្សាយឱ្យទូលំទូលាយ ដូចជាសៀវភៅអប់រំគ្រួសារ ខិតបណ្ណ័ ទស្សនាវដ្តី វិទ្យុ ទូរទស្សន៍ ។

☞ ពង្រឹងការអនុវត្តច្បាប់ដែលមានស្រាប់ឱ្យមានប្រសិទ្ធភាព ដោយផ្តន្ទាទោសដល់ជនល្មើសយ៉ាងតឹងរឹងសំដៅការពារ និងទប់ស្កាត់រាល់អំពើរំលោភបំពានលើកុមារ ។

☞ បង្កើត និងបង្កើនកម្មវិធីយុវនីតិសម្បទានឱ្យបានច្រើន ។

☞ ចាត់វិធានការលើកកំពស់ជីវភាពគ្រួសារក្រីក្រ ឱ្យបានល្អប្រសើរឡើង ដោយផ្តល់ដីធ្លី ទីលំនៅសមរម្យ ផ្តល់ដើមទុន ផ្តល់ចំណេះដឹង និងជំនាញក្នុងការរកចំណូលដើម្បីគ្រួសារ ។

☞ ផ្តល់ការអប់រំដល់កុមារនៅតាមសហគមន៍ ជាពិសេសសហគមន៍ក្រីក្រ ។

☞ បង្កើតទីកន្លែងសំរាប់ទទួលពាក្យបណ្តឹងដែលពាក់ពន្ធ័ពីបញ្ហាកុមារ ព្រមទាំងពង្រឹងនីតិវិធីក្នុងការដោះស្រាយពាក្យបណ្តឹងឱ្យបានឆាប់ និងដោយមានការធានាសុវត្ថិភាពដល់កុមារ ។

☞ ត្រូវមានមេធាវីសំរាប់ជួយកុមារតាមផ្លូវច្បាប់ និងពង្រឹងប្រពន្ធ័តុលាការឱ្យកាន់តែមានភាពសុក្រិត្យ ។

☞ បង្កើតកន្លែងឃុំឃាំងកុមារ ឱ្យដាច់ដោយឡែកពីមនុស្សចាស់ ។

**ដើម្បីធ្វើឱ្យសំរេចបានអនុសាសន៍ខាងលើ អង្គការក្រៅរដ្ឋាភិបាល គួររួមចំណែក**

☞ ពង្រឹងកម្មវិធីចុះអប់រំកុមារ គ្រួសារសហគមន៍ផ្ទាល់ ក្នុងការថែទាំ និងការពារព្រមទាំងរួមចំណែក ក្នុងការផ្តល់សេវាសុខភាពអប់រំដល់កុមារ ។

☞ ជួយធ្វើអន្តរាគមន៍ និងស្វែងរកយុត្តិធម៌ដល់កុមាររងគ្រោះ ក្នុងការដោះស្រាយពាក្យបណ្តឹងឱ្យកុមារតាមរយៈការបង្កើតឱ្យមានមេធាវីសំរាប់ជួយកុមារដោយឥតគិតថ្លៃ និង ជួយពង្រឹងស្មារតីកុមារក្នុងការចូលរួមក្នុង សវនការ និងធ្វើការសើរើ រឿងក្តី អយុត្តិធម៌របស់កុមារ ។

☞ សហការដើម្បីធ្វើការផ្សព្វផ្សាយ ឱ្យបានយល់ដឹងពីនីតិវិធីក្នុងការធ្វើពាក្យបណ្តឹង ដោះស្រាយពាក្យបណ្តឹង ស្តីពីការរំលោភបំពានលើកុមារ ។

**ដើម្បីតាមដានលើការអនុវត្តសកម្មភាពនេះឱ្យមានប្រសិទ្ធភាព រដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាលគួរតែ :**

☞ មានគំរោងផែនការច្បាស់លាស់ និងអនុវត្តតាមផែនការឱ្យត្រឹមត្រូវ

## ៤- __សុខភាព មូលដ្ឋាន និងសុខុមាលភាព__

**ដើម្បីកាត់បន្ថយអាត្រាមរណៈភាពកុមារ និង ធ្វើឱ្យស្ថានភាពសុខុមាលភាពកុមារកាន់តែប្រសើរឡើង រដ្ឋាភិបាលគួរតែ :**

☞ ជំរុញការអប់រំក្នុង និងក្រៅប្រព័ន្ធឱ្យបានដល់ជនបទដាច់ស្រយាល ដើម្បីធានាលុបបំបាត់អក្ខរកម្ម ដោយផ្តល់ការឧបត្ថម្ភផ្នែកសំភារៈ និងថវិកា ។

☞ ផ្តល់ការអប់រំសុខភាពបឋម ជាពិសេសធានាដល់ការទទួលបាននូវទឹកស្អាតគ្រប់គ្រាន់ តាមរយៈការជីកអណ្តូងស្នប់ស្រះ ពាង និងមានវិធានការថែទាំការពារ ។

☞ ជំរុញឱ្យមានប្រព័ន្ធធារាសាស្ត្រគ្រប់គ្រាន់ ដើម្បីបង្កបង្កើនផលស្រូវ និង ដំណាំ ផ្តល់បច្ចេកទេសផ្នែកកសិកម្ម និងជ្រើសរើសស្រូវពូជដែលមានទិន្នផលខ្ពស់ចែកជូនដល់ប្រជាជន ។

☞ ពង្រីកសេវាសុខាភិបាលឱ្យបានទូលំទូលាយ ដោយផ្តល់សំភារៈបរិក្ខា និងឱសថគ្រប់គ្រាន់ ព្រមទាំងបណ្តុះបណ្តាលបន្ថែម និងលើកទឹកចិត្តដល់អ្នកបច្ចេកទេស បុគ្គលិកសុខាភិបាលដែលចុះធ្វើការដល់មូលដ្ឋានដាច់ស្រយាល ។

☞ បំបាត់អំពើពុករលួយ និងអកប្បកិរិយាមិនសមស្របរបស់បុគ្គលិកមួយចំនួន ដែលធ្វើឱ្យប្រជាជនខ្លាចរអារក្នុងការទៅកាន់មណ្ឌលសុខភាព ។

- ☞ ចាត់វិធានការតឹងរឹងត្រួតពិនិត្យដល់សេវាឯកជនទាំងឡាយណា ដែលមិនស្របច្បាប់ និងអនុវត្តន៍ច្បាប់ដែលមានស្រាប់ ក្នុងការត្រួតពិនិត្យសេវាសុខាភិបាល ។
- ☞ ជួយសំរួលប្រព័ន្ធឃោសនាឱ្យមានតំលៃទាបបំផុត ក្នុងការអប់រំផ្សព្វផ្សាយពីជំងឺអេដស៍ សុខភាពបន្តពូជដល់ប្រជាពលរដ្ឋ ជាពិសេសយុវវ័យ ។
- ☞ ផ្តល់ការពិគ្រោះយោបល់ឱ្យបានសមស្របដល់អ្នកផ្ទុកមេរោគអេដស៍ និងបង្កើតសេវាថែទាំសុខភាពអ្នកដែលមានជម្ងឺអេដស៍ និងកូនដែលនៅរស់ ។
- ☞ លុបបំបាត់ការជួញដូរ និង ពេស្យាចារកុមារ ។

## ៥- ការអប់រំ ការលំហែ និង សកម្មភាពវប្បធម៌

**រដ្ឋាភិបាលគួរតែ :**

- ☞ បន្តការអនុវត្តគោលនយោបាយ **PAP** ។
- ☞ បន្តការឧបត្ថម្ភគាំទ្រវិស័យអប់រំ ដោយផ្តល់នូវអាគារសិក្សា ឧបករណ៍ សំភារៈបច្ចេកទេស ព្រមទាំងគ្រូបង្រៀនឱ្យបានទៅដល់ជនបទដាច់ស្រយាល ។
- ☞ បង្កើនការផ្សព្វផ្សាយអំពីសិទ្ធិកុមារ ឱ្យមានការយល់ដឹងដល់ឪពុកម្តាយ សហគមន៍អាជ្ញាធរ ។
- ☞ អាជ្ញាធរដែនដីត្រូវមានវិធានការតឹងតែង ជាមួយឪពុកម្តាយឱ្យបញ្ជូនកូនដែលគ្រប់អាយុចូលសាលារៀន ។
- ☞ លើកស្ទួយជីវភាពប្រជាជន តាមរយៈការផ្តល់ការបណ្តុះបណ្តាលវិជ្ជាជីវៈ ដល់ឪពុកម្តាយ ។
- ☞ បែងចែកថវិការអប់រំ សំដៅលើកកំពស់ក៏រិតជីវភាពគ្រូបង្រៀន និង ផ្តល់ប្រាក់កំរៃដល់គ្រូជាប់កិច្ចសន្យា ឱ្យទៀងទាត់ និង ទាន់ពេលវេលា ។
- ☞ ពង្រឹងសមត្ថភាពគ្រូ និង បុគ្គលិកសិក្សា ពិសេសបង្កើនសមត្ថភាពនៅក្រៅប្រទេស ។
- ☞ បង្កើតយន្តការតាមដាន ត្រួតពិនិត្យ លើការបែងចែក និង ប្រើប្រាស់ថវិកាអប់រំ ។
- ☞ បង្កើតឱកាសចូលរៀន ដោយផ្តល់ឱកាសជាអាទិភាពដល់កុមារក្រីក្រ កុមារជនជាតិភាគតិច និងកុមារនៅតំបន់ដាច់ស្រយាល ។
- ☞ បន្តកម្មវិធីអប់រំក្រៅប្រព័ន្ធ សំរាប់កុមារដែលពុំបានចូលរៀន ឬកុមារបោះបង់ការសិក្សា សហការជាមួយអង្គការក្រៅរដ្ឋាភិបាល ដើម្បីផ្តល់បច្ចេកទេសគរុកោសល្យដល់គ្រូស្ម័គ្រចិត្ត និង គ្រូជាប់កិច្ចសន្យា ។

**ដើម្បីធ្វើឱ្យសំរេចបានអនុសាសន៍ខាងលើ អង្គការក្រៅរដ្ឋាភិបាលគួររួមចំណែក :**

- ☞ បន្តបើកការអប់រំក្រៅប្រព័ន្ធ ឱ្យបានដល់មូលដ្ឋានដាច់ស្រយាល និងតំបន់ជនជាតិភាគតិច ។

**ដើម្បីតាមដានការអនុវត្តសកម្មភាពនេះឱ្យមានប្រសិទ្ធភាព រដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាលគួរតែ :**

- ☞ រាជរដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាលបន្តការសហការគ្នា ត្រួតពិនិត្យ និងតាមដានគណនីភាព នៃការអប់រំក្រៅប្រព័ន្ធ ។
- ☞ ពង្រឹងការងារអធិការកិច្ចឱ្យមានប្រសិទ្ធភាព ដោយសហការជាមួយអង្គការក្រៅរដ្ឋាភិបាល

## ៦- វិធានការការពារពិសេស

**រដ្ឋាភិបាលគួរតែ :**

☞ សិក្សា និងពិនិត្យឡើងវិញអំពីច្បាប់ ស្តីពីការជួញដូរ និងកេងប្រវ័ញ្ចផ្លូវភេទ និងធ្វើវិសោធនកម្មច្បាប់ដែលមានស្រាប់ ឱ្យស្របទៅនឹងគោលការណ៍សិទ្ធិកុមារ ។

☞ ចេញអនុក្រឹត្យ និងលិខិតបទដ្ឋាននានា ដើម្បីអនុវត្តច្បាប់ជាធរមានឱ្យមានប្រសិទ្ធភាព ។

☞ អប់រំ និងផ្សព្វផ្សាយច្បាប់ ដល់មន្ត្រីអនុវត្តច្បាប់គ្រប់ជាន់ថ្នាក់ ពីក្រុងដល់មូលដ្ឋាន និងបណ្តុះបណ្តាលប៉ូលីសឱ្យចេះពីយុទ្ធវិធីស៊ើបអង្កេត និងបង្កសំណុំរឿងទៅតុលាការ ។

☞ ចាត់វិធានការឱ្យមានការចុះបញ្ជីជាតិ ដើម្បីរួមចំណែកអនុវត្តបទបញ្ញត្តិច្បាប់ការងារ ឱ្យមានប្រសិទ្ធភាព។

☞ កំណត់ប្រភេទការងារឱ្យមានច្បាស់លាស់ ពិសេសទំរង់ការងារប្រកបដោយគ្រោះថ្នាក់ដល់កុមារ និងប្រភេទការងារស្រាលៗដែលកុមារអាចធ្វើបាន ។

☞ ត្រូវមានការចុះធ្វើអធិការកិច្ចឱ្យបានហ្មត់ចត់ និងទៀងទាត់នៅតាមផ្ទះ សិប្បកម្ម សហគ្រាសនានា ទាក់ទងនឹងអាយុចូលបំរើការងារ ។

☞ បង្កើតប្រព័ន្ធបច្ចេកទេសណាមួយ ក្នុងការធ្វើកោសល្យវិច្ច័យអាយុកុមារ មុនពេលអនុញ្ញាតិឱ្យចូលធ្វើការ ។

☞ ត្រូវមានមណ្ឌលស្តារនីតិសម្បទាសំរាប់កុមាររងគ្រោះដោយការកេងប្រវ័ញ្ចផ្លូវភេទ ដោយផ្តល់វិជ្ជាជីវៈ និងសេវាស្តារសុខភាពផ្លូវកាយ និងផ្លូវចិត្ត ។

☞ ធ្វើសមាហរណកម្ម និងមានការតាមដាននៅក្នុងគ្រួសារ និង សង្គមវិញ ព្រមទាំងជួយការងារ និងឧបត្ថម្ភដល់ជីវភាពរស់នៅរបស់គេ ។

### ដើម្បីធ្វើឱ្យសំរេចបានអនុសាសន៍ខាងលើអង្គការក្រៅរដ្ឋាភិបាលគួររួមចំណែក :

☞ ផ្តល់អ្នកឯកទេសខាងច្បាប់ ( កុមារ ) ក្នុងដំណើរការពង្រៀងច្បាប់ និងជំរុញឱ្យចេញអនុក្រឹត្យ និង អនុវត្តច្បាប់

☞ ជួយពង្រឹងការអនុវត្តច្បាប់ តាមរយៈការផ្តល់សំភារៈ ឯកសារ ថវិកា និងការហ្វឹកហ្វឺនដល់មន្ត្រីអនុវត្តច្បាប់ ជួយតាមដាន និងផ្តល់ពត៌មានអំពីការអនុវត្តច្បាប់ ផ្តល់យោបល់ ក្នុងការធ្វើការវិសោធនកម្មច្បាប់ ។

☞ សហការជាមួយរាជរដ្ឋាភិបាល ក្នុងការជួយសង្គ្រោះ និងផ្តល់មណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈ និងសេវានានាដល់កុមាររងគ្រោះ ។

☞ ធ្វើការផ្សព្វផ្សាយឱ្យមានការយល់ដឹង ពីសារៈសំខាន់នៃការចុះបញ្ជីជាតិដល់កុមារ ផ្តល់ពត៌មានដល់ក្រសួងមានសមត្ថកិច្ចអំពីការបន្លំអាយុ និងការអនុញ្ញាតិឱ្យក្មេងដែលមិនទាន់គ្រប់អាយុចូលធ្វើការ ជួយផ្តល់បច្ចេកទេស ក្នុងការធ្វើកោសល្យវិច្ឆ័យអាយុ ។

☞ ផ្សព្វផ្សាយឱ្យបានទូលំទូលាយពីល្បិចកលជនល្មើស ទៅដល់សាធារណៈជន ។

### ដើម្បីតាមដានលើការអនុវត្តសកម្មភាពនេះឱ្យមានប្រសិទ្ធភាព រាជរដ្ឋាភិបាល និងអង្គការក្រៅរដ្ឋាភិបាលគួរតែៈ

☞ សង្កេតលើការអនុវត្តនិតិវិធីច្បាប់ ។

☞ ប្រមូលទិន្នន័យអំពីករណីរំលោភច្បាប់ និងចាត់វិធានការដោះស្រាយឱ្យបានសមស្រប ។

☞ ផ្តល់ពត៌មាន និងផ្សព្វផ្សាយពីករណីរំលោភផ្សេងៗ និងប្រសិទ្ធភាពនៃការអនុវត្តច្បាប់ ។

~~~~~~~~~~~~
~~~~~~~~~~~~